ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

(គ.ជ.ប)

បទបញ្ជា និង នីតិវិធី

សម្រាប់

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

នីតិកាលទី ៦

[ថ្ងៃអាទិត្យ ទី២៩ ខែកក្កដា ឆ្នាំ២០១៨]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៨៤ គ.ជ.ប.ស.ស.រ

សេចក្តីសម្រេច

ស្តីពី

ការដាក់ឱ្យប្រើប្រាស់បទបញ្ជា និងនីតិវិធី
សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០៣ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១០ ចុះថ្ងៃ២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានលាឈប់
- បានឃើញសេចក្តីសម្រេចលេខ ០៤៥ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការប្រកាសឱ្យប្រើប្រាស់បទបញ្ជាផ្ទៃក្នុងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងការអនុម័តរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ លើបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

សម្រេច

ប្រការ ១.-

ដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨ ដែលមាន ១០ ជំពូក ១៥៣ ប្រការ និងឧបសម្ព័ន្ធចំនួន ៩។

ប្រការ ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងបទបញ្ជា និងនីតិវិធីនេះ ត្រូវចាត់ទុកជានិរាករណ៍។

ថ្ងៃចន្ទ ១១រោچ ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ២០១៨

៥. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ស៊ុក ប៊ុនហុក

មាតិកា

ទំព័រ

ជំពូកទី ១. បទប្បញ្ញត្តិទូទៅ ០១

- សមត្ថកិច្ចគ្រប់គ្រងការបោះឆ្នោត ០៤
- ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត ០៨
- សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប ០៨
- លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប ០៨
- សមាសភាព តួនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ គឃ.សប ០៩
- លក្ខណៈវិនិច្ឆ័យដើម្បីជ្រើសរើសសមាសភាព គឃ.សប ០៩
- សមាសភាព តួនាទី និងភារកិច្ចរបស់ គ.ក.ប ០៩
- បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើស និងការស្នើសុំតែងតាំង សមាសភាព គ.ក.ប ១១
- ប្រព័ន្ធជ្រើសរើសសមាជិក និងមន្ត្រី បុគ្គលិកនៃ គធ.ខប គឃ.សប និងសមាសភាព គ.ក.ប ១៤
- ប្រាក់កម្រៃរបស់មន្ត្រីបោះឆ្នោត ១៤
- អាណត្តិរបស់គណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ១៥
- ការតែងតាំងក្នុងរយៈពេលមានកំណត់ ១៥
- គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខារនៃ គ.ជ.ប ១៦
- ប្រតិទិននៃការងារបោះឆ្នោត ១៧
- ការងារសន្តិសុខបោះឆ្នោត ១៧

ជំពូកទី ២. ប្រព័ន្ធបោះឆ្នោត និងការកំណត់ចំនួនអាសនៈក្នុងរដ្ឋសភា ២៣

ជំពូកទី ៣. ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ២៥

- ភ្នាក់ងារគណបក្សនយោបាយ ២៥
- អ្នកសង្កេតការណ៍បោះឆ្នោត ២៩
- អ្នកសង្កេតការណ៍ជាតិ ៣០
- អ្នកសង្កេតការណ៍អន្តរជាតិ ៣៣
- អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ៣៥

ជំពូកទី ៤. ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ៣៩

- ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ៤៣
- ការពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ៤៤
- សិទ្ធិទទួលបាននូវការការពារសុវត្ថិភាពរបស់បេក្ខជន ៤៦
- សិទ្ធិប្តូរការិយាល័យបោះឆ្នោត ៤៧
- ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយ
  ឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត ៤៧

ជំពូកទី ៥. ការិយាល័យបោះឆ្នោត ៥១

- ការកំណត់ទីតាំងការិយាល័យបោះឆ្នោត ៥១
- ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ៥៤
- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យ
  រាប់សន្លឹកឆ្នោត ៥៤
- វិធានការការពារសន្តិសុខ ៥៥

ជំពូកទី ៦. ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត ៥៩

- ការបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើ
  នៅពេលបោះឆ្នោត ៦១
- នីតិវិធីនៃការស្នើសុំ និងការចេញ ឯ.អ ៦២

ជំពូកទី ៧. ការយោសនាបោះឆ្នោត ៦៨

- គោលការណ៍នៃការយោសនាបោះឆ្នោត ៦៨
- សម្ភារអប់រំអ្នកបោះឆ្នោត ៨១
- រូបភាព និងសម្ភារយោសនាផ្សព្វផ្សាយ ៨៤
- កិច្ចសហការ និងការកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ៩៣

ជំពូកទី ៨. ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផល

នៃការបោះឆ្នោត ៩៤

- ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ៩៤
- ការផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារ ឧបករណ៍ចាំបាច់សម្រាប់ការបោះឆ្នោត ៩៥
- ការទទួលខុសត្រូវ និងការកិច្ចរបស់ គ.ក.ប/គ.ក.រ ៩៧
- ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យ
  បោះឆ្នោត ១០៤
- ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ១១០
- ការប្រព្រឹត្តទៅនៃការបោះឆ្នោត ១១១
- ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត ១៣១
- ការបិទការិយាល័យបោះឆ្នោតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ
  ឬកាល:ទេស:មានអាសន្ន ១៣៥
- ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោត ដែលមិនត្រូវបានបើក
  ឬត្រូវបានបិទ ១៣៨
- ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ១៤១
- សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ១៥១
- ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត
  កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ១៥៤
- ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត
  ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅទីស្នាក់ការ គយ.សប ១៥៨

- ការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គយ.សប ឬនៅទីតាំងសុវត្ថិភាពណាមួយ ១៦២
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការ
  បោះឆ្នោត និងការរាប់សន្លឹកឆ្នោតទៅ គយ.សប ១៦៦
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតី
  នៅមួយ (១)ថ្ងៃ មុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោតទៅ គយ.សប ១៧០
- ប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផល
  នៃការបោះឆ្នោត ១៧៥
- ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត
  នៃ គធ.ខប ១៨៩
- ការប្រគល់ និងការទទួលកញ្ចប់ " គ ពិសេស " និងស្បោង " គ " ឬ/និងស្បោង
  " គ មានបណ្តឹង " និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ.ខប..... ១៩៤
- ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេច
  របស់ គយ.សប នៅ គធ.ខប ១៩៦
- ប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោត
  តាមឃុំ សង្កាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត.....១៩៩
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យ
  បណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ២០១
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានពាក្យ
  បណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ដាក់នៅ គយ.សប និងនៅ គធ.ខប ២០៤
- ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ២០៩
- ការបូកសរុប និងការបំពេញលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត.....២១៤
- ការវេចខ្ចប់ និងបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាល់
  សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅ គ.ជ.ប.....២១៩
- ការដាក់ពាក្យបណ្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ គធ.ខប នៅ គ.ជ.ប ២២៣
- ការបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផល
  និងក្រុមកំណត់ដែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណៈសម្បត្តិ
  បម្រើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ.....២២៥

- ការប្រគល់ និងការទទួលកញ្ចប់ " ឃ ពិសេស " ដាក់លទ្ធផលនៃការ
  បោះឆ្នោតក្នុងរាជធានី ខេត្ត ស្បោង " ឃ " និងស្បោង " ឃ មានបណ្តឹង "
  និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្តីការ គ.ជ.ប ២៣២
- ប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសន:
  ក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើស
  តាំងតំណាងរាស្ត្រ ២៣៧
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ
  ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែល គធ.ខប
  បានសម្រេចព្យូរជាបណ្តោះអាសន្ន ២៣៩
- ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលគ្មានពាក្យ
  បណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គឃ.សប
  ឬ/និង គធ.ខប ឬ/និង គ.ជ.ប ២៤៥
- ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត
  ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់
  នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ហើយដែលក្នុងនោះ
  មានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ត្រូវបានបើក ២៤៧
- ការបញ្ជូល និងការផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលក្នុងកុំព្យូទ័រ និងការកំណត់
  បែងចែកអាសន: សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
  តាមមណ្ឌលរាជធានី ខេត្ត ២៥៣
- ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ទាក់ទងនឹងលទ្ធផល
  បណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២៥៦
- ការរៀបចំ និងប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ២៦២

ជំពូកទី ៩. ការបាត់បង់អាសន:នៃរដ្ឋសភា និងការជ្រើសតាំងជំនួស

ព្រមទាំងការបែងចែកអាសន:នៅទំនេរ ២៦៤

- ការរកកូតានៃអាសន: ដែលបោះបង់ចោល ២៦៥
- ការកំណត់ចំនួនអាសន:បឋម ២៦៦
- ការបែងចែកអាសន:នៅសល់ពីការបែងចែកជំហានទីពីរ ២៦៨
- ការជ្រើសតាំងជំនួស ២៨៤

ជំពូកទី ១០.នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះត្រាប់
អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ន.ร
និងសមត្ថកិច្ច និងនីតិវិធីប្រជុំផ្ទុះផ្ទា ប្រជុំសម្រេច និងសវនាការ
ដោះស្រាយពាក្យបណ្តឹង.....២៨៦

- **ផ្នែកទី ១. នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះត្រាប់**
  អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ន.ร..... ២៨៦
- ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត
  ឬគណបក្សនយោបាយ.....២៨៦
- នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គយ.សប.....២៨៦
- ការដាក់ ការទទួលពាក្យបណ្តឹងនៅ គយ.សប.....២៨៦
- ការដោះស្រាយពាក្យបណ្តឹងនៅ គយ.សប ២៨៨
- នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប.....២៩០
- ការដាក់ ការទទួលពាក្យបណ្តឹងនៅ គធ.ខប.....២៩០
- ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប ២៩១
- នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប.....២៩៤
- ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប.....២៩៤
- ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប ២៩៥
- នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ.....២៩៧
- ការដាក់ ការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ២៩៧
- ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ.....២៩៧
- ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត ២៩៨
- **ផ្នែកទី ២. សមត្ថកិច្ច និងនីតិវិធីប្រជុំផ្ទុះផ្ទា ប្រជុំសម្រេច**
  និងសវនាការដោះស្រាយពាក្យបណ្តឹង.....២៩៩
- សមត្ថកិច្ចដោះស្រាយពាក្យបណ្តឹងក្នុងការបោះឆ្នោត ២៩៧
- សមាសភាពក្រុមប្រឹក្សាប្រជុំផ្ទុះផ្ទា ឬក្រុមប្រឹក្សាប្រជុំសម្រេច
  ឬក្រុមប្រឹក្សាជំនុំជម្រះ.....២៩៩

- ការប្តឹងតវ៉ា ឬការប្តឹងជំទាស់ ៣០២
- ការដកពាក្យបណ្តឹង ៣០៣
- ការរួមបញ្ចូលរឿងក្តី ៣០៤
- សិទ្ធិ និងកាតព្វកិច្ចរបស់គូភាគី ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង ៣០៤
- សិទ្ធិ និងកាតព្វកិច្ចរបស់សាក្សី ៣០៦
- នីតិវិធីប្រជុំផ្សះផ្សា ឬនីតិវិធីប្រជុំសម្រេច ឬនីតិវិធីសវនាការ ៣០៧
- ប្រភេទសវនាការ ៣០៧
- ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ៣០៨
- ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ៣០៨
- ភារកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ៣១០
- ពេលវេលាដោះស្រាយបណ្តឹង ៣១១
- ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការ ៣១២
- ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេចនៅ គយ.សប ៣១២
- ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ខប ៣១២
- ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប ៣១២
- ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ៣១២
- ការប្រកាសសេចក្តីសម្រេច ៣១៣
- ការបំពេញ និងប្រើប្រាស់ ទ.១២០៣ ..... ៣១៤
- ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្សះផ្សា ការប្រជុំសម្រេច និងសវនាការ ៣១៦
- បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយពាក្យបណ្តឹង ៣១៧
- នីតិវិធី និងខ្លឹមសារនៃសម្បថ ៣១៨

ឧបសម្ព័ន្ធ

១. ក្រមសីលធម៌ សម្រាប់មន្ត្រីបោះឆ្នោត ៣២០

២. ក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន
និងភ្នាក់ងារគណបក្សនយោបាយ ក្នុងដំណើរការបោះឆ្នោត ៣៣៦

៣. ក្រមសីលធម៌ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ក្នុងដំណើរការបោះឆ្នោត ៣៥៤

៤. ក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត ៣៦៣

៥. ក្រមសីលធម៌ សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ
និងភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដំណើរការបោះឆ្នោត ៣៧៤

៦. សម្ភារ ឯកសារដែលត្រូវប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់
ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ៣៨៧

៧. សម្ភារ ឯកសារដែលត្រូវប្រគល់ជូន គឃ.សប និងឯកសារផ្សេងទៀត
ដែលត្រូវប្រគល់ជូន គ.ក.ប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ៣៨៩

៨. សម្ភារ ឯកសារបោះឆ្នោត ដែលត្រូវប្រគល់ជូន គ.ក.ប/គ.ក.រ
សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ៣៩១

៩. ប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសន: ៣៩៣

អក្សរកាត់

១- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត	គ.ជ.ប
២- គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត	គធ.ខប
៣- លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត	លធ.ខប
៤- ក្រុមប្រឹក្សាឃុំ សង្កាត់	កបឃ.ស
៥- គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត	គឃ.សប
៦- គណៈកម្មការការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត	គ.ក.ប/គ.ក.រ
៧- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត	ច.គ.ជ.ប
៨- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ	ច.ប.ត.រ
៩- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ	ប.ន.ត.រ
១០- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ	អ.ខ
១១- ឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត	ឯ.អ
១២- ទម្រង់បែបបទលេខ	ទ.

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

ប្រការ ១.១.-

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ច.ប.ត.រ) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានសិទ្ធិ និងមានការកិច្ចរៀបចំបទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ (ប.ន.ត.រ) ដើម្បីកំណត់ពីបែបបទ វិធាន និងបញ្ញត្តិនានាសម្រាប់ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ប្រការ ១.២.-

រាជធានី ខេត្តនីមួយៗត្រូវមានតំណាងរាស្ត្រ ១ (មួយ) រូបយ៉ាងតិច ដែលត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋនៃរាជធានី ខេត្តនោះ តាមការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ស្របតាមបញ្ញត្តិដូចមានចែងក្នុង ច.ប.ត.រ និង ប.ន.ត.រ នេះ ។

ប្រការ ១.៣.-

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅព្រះរាជាណាចក្រកម្ពុជាត្រូវធ្វើឡើងជារៀងរាល់ ៥ (ប្រាំ) ឆ្នាំម្តង ។

១.៣.១ កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

១.៣.២ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើ ៥ (ប្រាំ)ឆ្នាំម្តង នៅថ្ងៃអាទិត្យតែ ១ (មួយ)ថ្ងៃ លើកលែងតែក្នុងស្ថានភាពណាមួយដូចខាងក្រោម ។

- ក្នុងករណីប្រធានសក្តិ ដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត
- ក្នុងករណីដែលរដ្ឋសភាត្រូវរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសតាំងរដ្ឋសភាថ្មីត្រូវប្រព្រឹត្តទៅក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ យ៉ាងយូរ ចាប់តាំងពីថ្ងៃរំលាយរដ្ឋសភា ។
- ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសឱ្យបន្តនីតិកាលរបស់ខ្លួន ស្របតាមកថាខណ្ឌទី៥ មាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

១.៣.៣ ករណីប្រធានសក្តិ ឬអសន្តិសុខត្រូវបានកំណត់ថា ជាបាតុភូតធម្មជាតិ សង្គ្រាម សង្គ្រាមស៊ីវិល ឬអំពើបះបោរ ។

១.៣.៣.១ បាតុភូតធម្មជាតិដែលរួមមាន ការរញ្ជួយផែនដីកម្រិតចាប់ពី ៤ រិចទ័រឡើងទៅ ទឹកជំនន់ ភាពរាំងស្ងួត អគ្គិភ័យ ឬមហាអគ្គិភ័យ ភាពក្តៅខ្លាំង ខ្យល់ព្យុះ ជំងឺរាតត្បាតនៅផ្នែកណាមួយ ឬនៅទូទាំងប្រទេស ដែលរារាំងប្រជាពលរដ្ឋមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬទៅបោះឆ្នោតបាន ដោយសេរី ឬមិនអាចឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោតបានដោយសេរី ។

១.៣.៣.២ សង្គ្រាមគឺជាការប្រយុទ្ធរវាងកងទ័ពនៃភាគី ដែលមានជម្លោះនឹងគ្នាក្នុងប្រទេស ឬការវាយប្រយុទ្ធគ្នាប្រឆាំងកងទ័ពបរទេស ដែលរារាំងប្រជាពលរដ្ឋមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬទៅបោះឆ្នោតបានដោយសេរី ឬមិនឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោតបានដោយសេរី ។

១.៣.៣.៣ សង្គ្រាមស៊ីវិលគឺជាជម្លោះនៅក្នុងប្រទេស ដែលប្រជាជនប្រើអាវុធដើម្បីប្រយុទ្ធតតាំងនឹងរាជរដ្ឋាភិបាល ឬដើម្បីដណ្តើមយកអំណាចដែលរារាំងប្រជាពលរដ្ឋមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬទៅបោះឆ្នោតបានដោយសេរី ឬមិនឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោតបានដោយសេរី ។

១.៣.៣.៤ ការបះបោរគឺជាចលនាឧទ្ទាមប្រឆាំងទល់នឹងរាជរដ្ឋាភិបាលលើបញ្ហាមួយ ឬបញ្ហាច្រើន ដែលអាចមានអំពើហិង្សា ឬដោយសន្តិវិធីនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឬនៅក្នុងប្រទេសទាំងមូល ដែលរារាំងប្រជាពលរដ្ឋមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬទៅបោះឆ្នោតបានដោយសេរី ឬមិនឱ្យគណបក្សនយោបាយធ្វើការឃោសនាបោះឆ្នោតបានដោយសេរី ។

ប្រការ ១.៤.-

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាចនឹងធ្វើឡើងនៅក្រោយរយៈពេល ៥ (ប្រាំ) ឆ្នាំបានប្រសិនបើនីតិកាលរបស់រដ្ឋសភា ត្រូវបានបន្តស្របតាមមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញ និងក្រោមបទប្បញ្ញត្តិ " កាលៈទេសៈពិសេស " ។

១.៤.១ គ.ជ.ប ត្រូវរៀបចំប្រតិទិនសម្រាប់ការបោះឆ្នោត ស្របតាមបទប្បញ្ញត្តិនៃ ច.ប.ត.រ ។

១.៤.២ ក្នុងការរៀបចំប្រតិទិនសម្រាប់ការបោះឆ្នោត គ.ជ.ប ត្រូវគោរពពេលវេលាដែលបានកំណត់ដោយមាត្រា ៧៨ និង មាត្រា ៨២ថ្មី នៃរដ្ឋធម្មនុញ្ញ ដើម្បីឱ្យរដ្ឋសភាដែលទើបជ្រើសតាំងថ្មីបើកសម័យប្រជុំដំបូងក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបោះឆ្នោតជ្រើសតាំង តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ។

ប្រការ ១.៥.

រាជធានី ខេត្ត ឃុំ សង្កាត់ណា ដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របាន ដោយករណីប្រធានសក្តិ ឬអសន្តិសុខ ដូចកំណត់ក្រោមចំណុច ១.៣.៣ ខាងលើ ឬ កាលៈទេសៈមានអាសន្ន គ.ជ.ប ត្រូវធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល និងរដ្ឋសភា។

១.៥.១ ករណីកាលៈទេសៈមានអាសន្នអាចជាករណីណាមួយ ក្នុងចំណោមករណីខាងក្រោម ៖

- ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោត ដោយយថាហេតុណាមួយ ឬ ការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់ ។
- ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន ។

១.៥.២ ក្នុងពេលកំពុងដំណើរការរៀបចំការបោះឆ្នោត គ.ជ.ប ត្រូវរាយការណ៍ភ្លាមជូនរាជរដ្ឋាភិបាល និងរដ្ឋសភា ពីការិយាល័យ ឬឃុំ សង្កាត់ណាដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្របាន ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ។

១.៥.៣ គ.ជ.ប មានសិទ្ធិសម្រេចមិនបើកការិយាល័យបោះឆ្នោត និងមានសិទ្ធិបិទការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួនក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាព មន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោត នៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតណាមួយ ឬ មួយចំនួននោះ ។

ប្រការ ១.៦.-

ករណីការិយាល័យ ឬឃុំ សង្កាត់ណា ដែលមិនអាចដំណើរការរៀបចំការបោះឆ្នោតបាន ដោយសារករណីដូចមានចែងក្រោមចំណុច ១.៣.៣ និងចំណុច ១.៥.១ ខាងលើ ការបោះឆ្នោតសាជាថ្មី នឹងត្រូវដំណើរការនៅពេលស្ថានការណ៍នៅឃុំ សង្កាត់នោះមានប្រក្រតីភាពឡើងវិញ និងតាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប ។

ប្រការ ១.៧.-

ការបោះឆ្នោតសាជាថ្មីត្រូវធ្វើឡើងក្នុងរយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃដែល គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួន ឬឃុំ សង្កាត់ណាមួយ ។

សមត្ថកិច្ចត្រួតត្រួតពិនិត្យការបោះឆ្នោត

ប្រការ ១.៨.-

ការចាត់ចែង រៀបចំ និងការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាសមត្ថកិច្ចរបស់ គ.ជ.ប ដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ។

គ.ជ.ប ត្រូវអនុវត្តសមត្ថកិច្ចរបស់ខ្លួន ដោយឯករាជ្យ និងអព្យាក្រឹត ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ។ សមាជិកទាំងឡាយនៃ គ.ជ.ប និងសមាជិក នៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវមានជំហរអព្យាក្រឹតឥតលម្អៀងក្នុងការអនុវត្តការងារបោះឆ្នោត ។

ប្រការ ១.៩.-

គ.ជ.ប ត្រូវដាក់ចេញនូវបទបញ្ជា និងនីតិវិធីសម្រាប់ចាត់ចែងរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ផ្អែកតាមលក្ខខណ្ឌដូចមានចែងក្នុង ច.ប.ត.រ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

ប្រការ ១.១០.-

គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវទាក់ទងនឹងផែនការកម្ម ការរៀបចំ ការចាត់ចែង និងត្រួតពិនិត្យការបោះឆ្នោត ដូចតទៅ ៖

១.១០.១ ចាត់វិធានការគ្រប់រូបភាព ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

១.១០.២ រៀបចំគម្រោងផែនការការងារ ថវិកា និងសម្ភារបម្រើឱ្យការបោះឆ្នោត និងផ្សព្វផ្សាយប្រតិទិននៃការបោះឆ្នោត ។

១.១០.៣ តែងតាំងគណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងគណៈកម្មការការិយាល័យបោះឆ្នោត ។

១.១០.៤ ធ្វើបទបញ្ជា នីតិវិធី និងសេចក្ដីណែនាំនានាសម្រាប់ដំណើរការបោះឆ្នោតក្នុងក្របខ័ណ្ឌនៃច្បាប់ជាធរមាន ។

១.១០.៥ លើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈក្នុងសម័យបោះឆ្នោត ។

១.១០.៦ ត្រួតពិនិត្យការងាររបស់គណៈកម្មការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

១.១០.៧ កំណត់ព្រំដែនការិយាល័យបោះឆ្នោត ។

១.១០.៨ ចេញសេចក្ដីសម្រេចកំណត់ទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ។

១.១០.៩ ផលិត និងបែងចែកសម្ភារ បរិក្ខារបម្រើឱ្យការងារបោះឆ្នោត ។

១.១០.១០ ជ្រើសរើស និងតែងតាំងមន្ត្រីចុះជួយពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

១.១០.១១ រៀបចំបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

១.១០.១២ ពិនិត្យ និងផ្ដល់សុពលភាពបញ្ជីបោះឆ្នោត ។

១.១០.១៣ ទទួល និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ស្របតាមច្បាប់បោះឆ្នោតជាធរមាន ។

១.១០.១៤ គ្រប់គ្រង និងត្រួតពិនិត្យការប្រព្រឹត្តទៅនៃការយោសនាបោះឆ្នោត ។

១.១០.១៥ រៀបចំ និងចាត់ចែងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផល ។

១.១០.១៦ ដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬផ្តល់សិទ្ធិបោះឆ្នោតឡើងវិញ។
ចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬលុបចេញពីបញ្ជីឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ។
លុបបេក្ខភាពរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត ឬទទួលស្គាល់បេក្ខភាពឈរឈ្មោះបោះឆ្នោតឡើងវិញ ។

១.១០.១៧ ត្រួតពិនិត្យចំណូល និងចំណាយក្នុងរយៈពេលយោសនាបោះឆ្នោតរបស់បេក្ខជន និងគណបក្សនយោបាយ ។

១.១០.១៨ ចាត់វិធានការ និងសម្របសម្រួលដើម្បីឱ្យមានការប្រើប្រាស់ប្រព័ន្ធយោសនាសាធារណៈ តាមគោលការណ៍ស្មើភាព និងសមធម៌ ។

១.១០.១៩ ផ្តល់ព័ត៌មាន ទិន្នន័យ និងស្ថិតិអំពីដំណើរការបោះឆ្នោតដល់គណបក្សនយោបាយ និងបេក្ខជន និងទទួលសំណើនានាទាក់ទងនឹងការងារបោះឆ្នោត ។
ធានាឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងការសម្របសម្រួលជាប្រចាំអំពីកិច្ចដំណើរការបោះឆ្នោតរវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាមួយគណបក្សនយោបាយ បេក្ខជន និងអ្នកដែលពាក់ព័ន្ធនានា ។

១.១០.២០ ផលិតឯកសារផ្សព្វផ្សាយអំពីការងារបោះឆ្នោត ។

១.១០.២១ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការងារបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ និងដោយមធ្យោបាយផ្សេងៗទៀត ។

១.១០.២២ រៀបចំឯកសារ កម្មវិធី និងបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុករៀបចំការបោះឆ្នោត ។

១.១០.២៣ ពិនិត្យសម្រេច និងចេញបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ។

១.១០.២៤ ត្រួតពិនិត្យ ដើម្បីធានាភាពត្រឹមត្រូវតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

១.១០.២៥ សម្រេចដោយបើកសវនាការជាសាធារណៈលើបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត ស្របតាមច្បាប់ បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត លើកលែងតែបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

១.១០.២៦ បង្ការ និងត្រួតពិនិត្យភាពមិនប្រក្រតីនៃការបោះឆ្នោត ។

១.១០.២៧ រៀបចំគណៈកម្មការដើម្បីបំផ្លាញសន្លឹកឆ្នោត ដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតាមអាណត្តិនីមួយៗ បន្ទាប់ពីបានរក្សាទុកប្រកបដោយសុវត្ថិភាព ទ្ធវសន្លឹកឆ្នោតទាំងនោះរយៈពេល ៦ (ប្រាំមួយ) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោតតាមអាណត្តិនីមួយៗ ។ ដំណើរការនៃការបំផ្លាញសន្លឹកឆ្នោតខាងលើនេះ ត្រូវធ្វើឡើងប្រកបដោយលក្ខណៈបើកចំហ និងមានការចូលរួមពីគណបក្សនយោបាយដែលពាក់ព័ន្ធ ។

១.១០.២៨ អនុវត្តការងារដទៃទៀតតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ប្រការ ១.១១.-

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គ.ជ.ប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុងផ្នែកទី២ ផ្នែកទី៣ និងផ្នែកទី៥ ជំពូកទី១ នៃបទបញ្ជាផ្ទៃក្នុង គ.ជ.ប ។

ប្រការ ១.១២.-

គ.ជ.ប មានសិទ្ធិតែងតាំង គធ.ខប ឬ គយ.សប ឬ គ.ក.ប ក្នុងរយៈពេលមានកំណត់ នៅពេលណាមួយបន្ទាប់ពីការបោះឆ្នោតជាទូទៅត្រូវបានបញ្ចប់ ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតសាជាថ្មី (បើមាន) ។

ការប្រគល់សិទ្ធិអំណាចរបស់ គ.ជ.ប ទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឬមន្ត្រីបោះឆ្នោត

ប្រការ ១.១៣.-

យោងតាម ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គ.ជ.ប អាចចេញសេចក្តីសម្រេចប្រគល់សិទ្ធិអំណាចរបស់ខ្លួនដល់ គធ.ខប គយ.សប គ.ក.ប ឬមន្ត្រី ឬភ្នាក់ងារបម្រើការងារបោះឆ្នោត ដើម្បីអនុវត្តការងារបោះឆ្នោត ។

សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប

ប្រការ ១.១៤.-

គធ.ខប ជាគណៈកម្មការគ្រប់គ្រងការបោះឆ្នោតនៅថ្នាក់រាជធានី ខេត្តដែលត្រូវតែងតាំងដោយ គ.ជ.ប ដើម្បីជាជំនួយក្នុងការធ្វើផែនការ រៀបចំចាត់ចែង និងត្រួតពិនិត្យដំណើរការបោះឆ្នោត ។ សមាសភាព រចនាសម្ព័ន្ធ និងរបៀបរបបធ្វើការងាររបស់ គធ.ខប ត្រូវអនុវត្តតាមបញ្ញត្តិដូចមានចែងក្នុងផ្នែកទី១ និងផ្នែកទី២ ជំពូកទី២ នៃបទបញ្ជាផ្ទៃក្នុង គ.ជ.ប ។

លក្ខណៈនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប

ប្រការ ១.១៥.-

បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គធ.ខប ត្រូវអនុវត្តតាមមាត្រា ១៦ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

១.១៥.១ សមាសភាព គធ.ខប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងរាជធានី ខេត្តដែលមានសិទ្ធិបោះឆ្នោត លើកលែងតែកងយោធពល ខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

១.១៥.២ សមាសភាព និងមន្ត្រីបុគ្គលិកនៃ គធ.ខប ត្រូវបានជ្រើសរើសដោយអនុលោមតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដូចបានកំណត់ក្នុងផ្នែកទី១ ជំពូកទី៦ នៃបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

សមាសភាព តូនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ គយ.សប

ប្រការ ១.១៦.-

សមាសភាព តូនាទី ភារកិច្ច និងរបៀបរបបធ្វើការងាររបស់ គយ.សប ត្រូវអនុវត្តតាមបញ្ញត្តិ ដូចមានចែងក្នុងផ្នែកទី១ និង ផ្នែកទី២ ជំពូកទី៣ នៃបទបញ្ជាផ្ទៃក្នុង គ.ជ.ប ។

លក្ខណៀនិច្ឆ័យដើម្បីជ្រើសរើសសមាសភាព គយ.សប

ប្រការ ១.១៧.-

បែបបទ នីតិវិធី និងលក្ខណវិនិច្ឆ័យដើម្បីជ្រើសរើសសមាសភាព គយ.សប ត្រូវអនុវត្តតាមមាត្រា ២៧ នៃ ច.គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

១.១៧.១ សមាសភាព គយ.សប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និង មន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពល ខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ហើយមិនទាន់មាននីតិសម្បទាឡើងវិញ ។

១.១៧.២ សមាសភាព គយ.សប ត្រូវជ្រើសរើសដោយអនុលោមតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រី បុគ្គលិក ដូចបានកំណត់ក្នុងផ្នែកទី២ ជំពូកទី៦ នៃ បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

សមាសភាព តូនាទី និងភារកិច្ចរបស់ គ.ក.ប

ប្រការ ១.១៨.-

សមាសភាព តូនាទី និងភារកិច្ចរបស់ គ.ក.ប ត្រូវអនុវត្តតាមមាត្រា ៣៤ នៃ ច.គ.ជ.ប និង ជំពូកទី៤ នៃបទបញ្ជាផ្ទៃក្នុង គ.ជ.ប ។

១.១៨.១ គ.ក.ប ត្រូវមានសមាសភាព ៦ (ប្រាំមួយ)រូប ដែលរួមមាន ប្រធាន ១ (មួយ)រូប អនុប្រធាន ១ (មួយ)រូប លេខាធិការ ១ (មួយ)រូប និងសមាជិក ចំនួន ៣ (បី)រូប ។ ភារកិច្ចទទួលខុសត្រូវរបស់សមាសភាព គ.ក.ប ត្រូវបានកំណត់ដូចខាងក្រោម ៖

១.១៨.១.១	ប្រធានមានភារ:ទទួលខុសត្រូវរួមក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោត ។
១.១៨.១.២	អនុប្រធានមានភារ:ជាជំនួយការរបស់ប្រធាន ទទួលខុសត្រូវក្នុងការផ្តល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតនៅពេលបោះឆ្នោត និងក្នុងការកត់ត្រាសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។
១.១៨.១.៣	លេខាធិការមានភារ:ទទួលខុសត្រូវក្នុងការពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត និងការបំពេញកំណត់ហេតុ និងរាល់ទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។
១.១៨.១.៤	សមាជិកទី១ ដែលនៅក្នុងការិយាល័យបោះឆ្នោតមានភារ:ទទួលខុសត្រូវ ពិនិត្យការស៊ិកសន្លឹកឆ្នោតទៅក្នុងហិបឆ្នោត និងជ្រលក់ម្រាមដៃអ្នកបោះឆ្នោតក្នុងទឹកខ្មៅលុបមិនជ្រះ និងទទួលគូសសំឡេងឆ្នោតនៅពេលរាប់សន្លឹកឆ្នោត ។
១.១៨.១.៥	សមាជិកទី២ ដែលនៅខាងក្រៅការិយាល័យបោះឆ្នោតមានភារ:ទទួលខុសត្រូវជួយរកឈ្មោះអ្នកបោះឆ្នោត ក្នុងបញ្ជីបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ ជូនអ្នកបោះឆ្នោត និងចោះ ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើ ដើម្បីធ្វើមោឃភាព ។
១.១៨.១.៦	សមាជិកទី៣ មានភារ:ទទួលខុសត្រូវការងារសណ្តាប់ធ្នាប់របៀបរៀបរយ និងថែរក្សាសម្ភារឯកសារបោះឆ្នោត នៅពេលបោះឆ្នោត និងនៅពេលរាប់សន្លឹកឆ្នោត ។

១.១៨.២ គ.ក.ប ត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវគ្រប់គ្រង និងចាត់ចែងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ ៨.៣ ប្រការ ៨.៤ និងប្រការ ៨.៥ នៃ ប.ន.ត.រ នេះ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

១.១៨.៣ គ.ក.ប ត្រូវទទួលខុសត្រូវចំពោះមុខ គយ.សប ។

១.១៨.៤ គ.ក.ប ទទួលសេចក្តីណែនាំពី គ.ជ.ប តាមរយ: គធ.ខប និង គយ.សប ។

ប្រការ ១.១៩.

បែបបទ នីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសមាសភាព គ.ក.ប ត្រូវអនុវត្តតាមមាត្រា ៣៥ នៃ ច.គ.ជ.ប និងផ្នែកទី៣ និងផ្នែកទី៤ ជំពូកទី៦ នៃបទបញ្ជាផ្ទៃក្នុង គ.ជ.ប ។

១.១៩.១ សមាសភាព គ.ក.ប ត្រូវជ្រើសរើសឡើងក្នុងចំណោមប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ លើកលែងតែកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ បេក្ខជនឈរឈ្មោះបោះឆ្នោតសម្រាប់សមាជិកក្រុមប្រឹក្សាទាំងនោះ មេភូមិ ជំនួយការមេភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ។

១.១៩.២ អ្នកដែលត្រូវបានជ្រើសរើសជាសមាជិក គ.ក.ប គឺជាបេក្ខជនដាក់ពាក្យសុំចូលបម្រើការងារណា ដែលបានទទួលជោគជ័យក្នុងការធ្វើសម្ភាសន៍ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង និងបានចុះហត្ថលេខាលើកិច្ចសន្យាបម្រើការងារក្នុង គ.ក.ប (ទ.១០០២) នៅក្រោយពេលវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់ ។ ក្នុងការជ្រើសរើសនេះ ត្រូវផ្តល់អាទិភាពចំពោះបេក្ខជនដែលធ្លាប់មានបទពិសោធន៍ក្នុងការងារបោះឆ្នោតពីមុនមក ឬបទពិសោធន៍ការងារពាក់ព័ន្ធនឹងមុខតំណែង ។

- ១.១៩.២.១ បេក្ខជនណាដែលត្រូវបានជ្រើសរើសហើយ ប៉ុន្តែមិនបានចូលរួមវគ្គបណ្តុះបណ្តាល ត្រូវដាក់ជំនួសជាបន្ទាន់ដោយបេក្ខជនបម្រុង។
- ១.១៩.២.២ ប្រសិនបើគ្មានបេក្ខជនបម្រុងសម្រាប់ជំនួស គយ.សប ត្រូវចាត់ចែងស្នើសុំ គ.ជ.ប តាមរយៈ គធ.ខប ជ្រើសរើសអ្នកជំនួសជាបន្ទាន់ ។

១.១៩.៣ ដើម្បីទទួលបានការជ្រើសរើស និងបានបម្រើការងារក្នុងលក្ខណៈជាប់កិច្ចសន្យាជាសមាជិក គ.ក.ប បេក្ខជនដាក់ពាក្យសុំបម្រើការងារត្រូវ ៖

- ១.១៩.៣.១ ឆ្លងកាត់ដោយជោគជ័យនូវការធ្វើសម្ភាសន៍ ដែលគ្រប់គ្រងពិនិត្យដោយអនុគណៈកម្មការសម្ភាសន៍ជ្រើសរើស ។

១.១៩.៣.២ គោរពរដ្ឋធម្មនុញ្ញ និងអនុវត្តតាម ច.គ.ជ.ប ច.ប.ត.រ និង ប.ន.ត.រ របស់ គ.ជ.ប ។

១.១៩.៣.៣ យល់ព្រមធ្វើសច្ចាប្រណិធានថា ប្រកាន់ជំហរអព្យាក្រឹត និងមិនលម្អៀង ។

១.១៩.៣.៤ យល់ព្រមលើលក្ខខណ្ឌការងារ និងប្រាក់កម្រៃ ។

១.១៩.៣.៥ បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលពេញម៉ោង ។

១.១៩.៣.៦ ចុះហត្ថលេខាយល់ព្រមលើកិច្ចសន្យាបម្រើការងារក្នុង គ.ក.ប/គ.ក.រ ។

១.១៩.៤ ទម្រង់បែបបទសម្រាប់បំពេញកិច្ចសន្យាបម្រើការងារក្នុង គ.ក.ប (ទ.១០០២) ត្រូវបញ្ជាក់ ៖

១.១៩.៤.១ ឈ្មោះ អាសយដ្ឋាន និងកស្តុតាងបញ្ជាក់ពីភាពមានសិទ្ធិបោះឆ្នោតនៃអ្នកដែលត្រូវតែងតាំង ។

១.១៩.៤.២ មុខតំណែងក្នុង គ.ក.ប នៃអ្នកដែលត្រូវតែងតាំង ។

១.១៩.៤.៣ លក្ខណៈសម្គាល់ នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត ដែលបុគ្គលនោះត្រូវបានតែងតាំង ។

១.១៩.៤.៤ លក្ខខណ្ឌការងារ ភារកិច្ច និងការទទួលខុសត្រូវនៃអ្នកដែលត្រូវបានតែងតាំង ។

១.១៩.៤.៥ ការសន្យាយល់ព្រមទទួលយកភារកិច្ចលក្ខខណ្ឌការងារ និងប្រាក់កម្រៃ ។

១.១៩.៤.៦ ការសន្យាថានឹងអនុវត្តភារកិច្ចរបស់ខ្លួនដោយអព្យាក្រឹត និងមិនលម្អៀង ។

១.១៩.៤.៧ ការសន្យាថានឹងអនុវត្តតាម ច.គ.ជ.ប ច.ប.ត.រ ប.ន.ត.រ ព្រមទាំងរាល់សេចក្តីណែនាំរបស់ គ.ជ.ប ។

១.១៩.៤.៨ ការសន្យាថានឹងគោរពតាមគោលការណ៍នៃការបោះឆ្នោត ។

១.១៩.៤.៩ ហត្ថលេខារបស់អ្នកដែលត្រូវតែងតាំង និងហត្ថលេខារបស់ប្រធាន គយ.សប ។

១.១៩.៥ សមាសភាព គ.ក.ប ត្រូវតែជ្រើសរើស ដោយផ្អែកតាមប្រព័ន្ធជ្រើសរើស និងគណៈកម្មការជ្រើសរើសមន្ត្រីបុគ្គលិក ដូចបានកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

១.១៩.៦ គធ.ខប ត្រូវប្រគល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងជាសមាជិក គ.ក.ប ទាំងអស់តាមឃុំ សង្កាត់ចំណុះរាជធានី ខេត្តរបស់ខ្លួន ដោយភ្ជាប់ជាមួយនូវកិច្ចសន្យាបម្រើការងារក្នុង គ.ក.ប (ទ.១០០២) ដែលបានបំពេញ និងចុះហត្ថលេខារួចម្នាក់ៗ ១ (មួយ) ច្បាប់ ដើម្បីស្នើសុំសេចក្តីសម្រេចតែងតាំងពី គ.ជ.ប ។

១.១៩.៧ នៅពេលទទួលបានសំណើតែងតាំង ដូចបញ្ជាក់ក្នុងចំណុច ១.១៩.៦ ខាងលើ គ.ជ.ប ត្រូវពិនិត្យ និងចេញសេចក្តីសម្រេចតែងតាំង គ.ក.ប ហើយត្រូវរក្សាទុកឯកសារនៃបញ្ជីឈ្មោះមន្ត្រីការិយាល័យបោះឆ្នោតទាំងនោះជាផ្លូវការ ។

១.១៩.៨ បន្ទាប់ពីទទួលបានសេចក្តីសម្រេចរបស់ គ.ជ.ប គធ.ខប ត្រូវបញ្ជូនបន្ត និងណែនាំ គយ.សប ឱ្យបំពេញ និងផ្តល់បណ្ណសម្គាល់ខ្លួនជូនសមាជិក គ.ក.ប សម្រាប់ពាក់នៅពេលបំពេញការកិច្ចក្នុងអាណត្តិការងាររបស់ខ្លួន ។

១.១៩.៩ សមាជិក គ.ក.ប ត្រូវស្ថិតនៅក្នុងមុខតំណែងរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតនៅក្នុងការិយាល័យរបស់ខ្លួន និងក្រោយពីបានប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតចប់សព្វគ្រប់ជូន គយ.សប ។ ផ្អែកតាមមុខតំណែងរបស់ខ្លួន សមាជិក គ.ក.ប ម្នាក់ៗនឹងទទួលបានប្រាក់កម្រៃជាប្រាក់រៀល សម្រាប់ការងាររបស់ខ្លួន ដោយគិតបញ្ចូលទាំងថ្លៃម្ហូបអាហារ និងថ្លៃធ្វើដំណើរផង ។

- ១.១៩.៩.១ ចំនួនទឹកប្រាក់ដែលត្រូវបានផ្តល់ជាកម្រៃ សម្រាប់ការបំពេញការងារជាសមាជិក គ.ក.ប ក្នុងរយៈពេល ៤ (បួន) ថ្ងៃ ត្រូវគិតទាំងការចូលរួមវគ្គបណ្តុះបណ្តាលផង ។
- ១.១៩.៩.២ ក្នុងករណីសមាជិក គ.ក.ប ណាដែលតម្រូវឱ្យស្ថិតក្នុងមុខតំណែងយូរជាងការកំណត់ដូចចែងក្នុងចំណុច ១.១៩.៩.១ ខាងលើ មន្ត្រីនោះនឹងត្រូវទទួលបានប្រាក់កម្រៃបន្ថែម តាមសេចក្តីសម្រេចរបស់ គ.ជ.ប ។

១.១៩.១០ គយ.សប ត្រូវអនុវត្តការវាយតម្លៃសមាជិក គ.ក.ប ទាំងអស់ចំណុះឃុំ សង្កាត់ រយៈពេល ២ (ពីរ) សប្តាហ៍យ៉ាងយូរបន្ទាប់ពីថ្ងៃបោះឆ្នោត ។

១.១៩.១០.១ នៅមុនបញ្ចប់ការកិច្ចរបស់ខ្លួន គយ.សប ត្រូវផ្តល់កំណត់ហេតុវាយតម្លៃសមាជិក គ.ក.ប (ទ.១១១៣) ដែលបានបំពេញរួចហើយ ទៅ គធ.ខប ។

១.១៩.១០.២ គធ.ខប ត្រូវផ្ញើកំណត់ហេតុវាយតម្លៃសមាជិក គ.ក.ប/គ.ក.រ ទាំងអស់ ចំណុះរាជធានី ខេត្តម្នាក់ៗ ១ (មួយ) ច្បាប់ជូន គ.ជ.ប ។

១.១៩.១០.៣ គ.ជ.ប ត្រូវកត់ត្រាបន្ថែមទិន្នន័យនៃកំណត់ហេតុវាយតម្លៃសមាជិក គ.ក.ប ទាំងអស់ទៅក្នុងបញ្ជីឈ្មោះនៃសមាជិក គ.ក.ប ដែលត្រូវរក្សាទុក ។

ប្រព័ន្ធជ្រើសរើសសមាជិក និងមន្ត្រី បុគ្គលិកនៃ គធ.ខប គយ.សប និងសមាសភាព គ.ក.ប

ប្រការ ១.២០.-

ប្រព័ន្ធជ្រើសរើសសមាជិក និងមន្ត្រី បុគ្គលិកនៃ គធ.ខប គយ.សប និងសមាសភាព គ.ក.ប ត្រូវឈរលើគោលការណ៍ស្មើភាព ដោយត្រឹមត្រូវ តម្លាភាព អព្យាក្រឹត សមត្ថភាព មិនប្រកាន់និន្នាការនយោបាយ និងការងារពាក់ព័ន្ធ ដែលមានកំណត់នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។ គ.ជ.ប លើកទឹកចិត្ត និងផ្តល់អាទិភាពដល់បេក្ខនារី ឬបេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងការងារពាក់ព័ន្ធ ។

ប្រាក់កម្រៃរបស់មន្ត្រីបោះឆ្នោត

ប្រការ ១.២១.-

ប្រាក់កម្រៃរបស់សមាជិក និងមន្ត្រី បុគ្គលិកនៃគណៈកម្មាធិការជាតិ និងសមាជិក និងមន្ត្រីបុគ្គលិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវបានកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប ។

១.២១.១ ប្រាក់កម្រៃត្រូវបើកជារៀងរាល់ខែចំពោះ អ.គ.ជ.ប និងមន្ត្រី បុគ្គលិកជាប់កិច្ចសន្យា ហើយត្រូវបើកផ្តាច់ចំពោះមន្ត្រី បុគ្គលិកក្រោយការបញ្ចប់ការងារ ។

១.២១.២ ប្រាក់កម្រៃត្រូវបើកជូនជាប្រាក់រៀល បន្ទាប់ពី គ.ជ.ប ទទួលបានប្រាក់ពីរតនាគារជាតិ ។

អាណាត្តិរបស់គណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

ប្រការ ១.២២.

អាណត្តិរបស់គណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ រួមមាន ៖

១.២២.១ គ.ក.ប ត្រូវបំពេញការងាររបស់ខ្លួន រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតរបស់ខ្លួន និងក្រោយពីបានប្រគល់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឧបករណ៍បោះឆ្នោតចប់សព្វគ្រប់ជូន គយ.សប រួចរាល់ហើយ ។

១.២២.២ គយ.សប ត្រូវបំពេញភារកិច្ចរបស់ខ្លួនរហូតដល់ ៣០ (សាមសិប) ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ អាណត្តិរបស់ គយ.សប ដូចមានចែងក្នុងចំណុចនេះ អាចកំណត់ផ្សេងពីនេះ ដោយសេចក្ដីសម្រេចរបស់ គ.ជ.ប តាមតម្រូវការជាក់ស្តែង ។

១.២២.៣ គធ.ខប ត្រូវបំពេញភារកិច្ចរបស់ខ្លួន រហូតដល់ ៦០ (ហុកសិប) ថ្ងៃ ក្រោយពីការប្រកាសលទ្ធផលជាផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ អាណត្តិរបស់ គធ.ខប ដូចមានចែងក្នុងចំណុចនេះ អាចកំណត់ផ្សេងពីនេះ ដោយសេចក្ដីសម្រេចរបស់ គ.ជ.ប តាមតម្រូវការជាក់ស្តែង ។

១.២២.៤ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួនរហូតដល់មានសមាសភាព គ.ជ.ប ថ្មីចូលកាន់តំណែង ។

ការតែងតាំងក្នុងរយៈពេលមានកំណត់

ប្រការ ១.២៣.

គ.ជ.ប មានសិទ្ធិតែងតាំង គធ.ខប គយ.សប ឬ គ.ក.ប ក្នុងរយៈពេលមានកំណត់នៅពេលណាមួយបន្ទាប់ពីការបោះឆ្នោតជាទូទៅត្រូវបានបញ្ចប់ ក្នុងគោលបំណងគ្រប់គ្រង និងចាត់ចែងការបោះឆ្នោតសាជាថ្មី (បើមាន) ។

១.២៣.១ ក្នុងការតែងតាំងក្នុងរយៈពេលមានកំណត់នេះ នីតិវិធីអំពីការជ្រើសរើស រចនាសម្ព័ន្ធ សមាសភាព លក្ខណៈវិនិច្ឆ័យ សិទ្ធិអំណាច ការទទួលខុសត្រូវ ប្រាក់កម្រៃ ត្រូវអនុលោមតាម ច.គ.ជ.ប បទបញ្ជាផ្ទៃក្នុង គ.ជ.ប ប.ន.ត.រ និងតាមការសម្រេចរបស់ គ.ជ.ប ។

១.២៣.២ អាណត្តិរបស់ គធ.ខប គយ.សប និង គ.ក.ប ដែលត្រូវបានតែងតាំងក្នុងរយៈពេលមានកំណត់នេះ ត្រូវបញ្ចប់នៅពេលចប់ភារកិច្ចតាមការកំណត់របស់ គ.ជ.ប ។

គោលការណ៍នៃការប្រើប្រាស់សម្ភារ និងបរិក្ខារនៃ គ.ជ.ប

ប្រការ ១.២៤.-

សម្ភារ និងបរិក្ខាររបស់ គ.ជ.ប ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការងាររៀបចំការបោះឆ្នោតលើកលែងតែមានការសម្រេចផ្សេងពីនេះរបស់ គ.ជ.ប ។

១.២៤.១ គ្មានសមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយអាចប្រើប្រាស់បរិក្ខារ ឬ/និងសម្ភាររបស់ គ.ជ.ប ក្រៅពីការរៀបចំការបោះឆ្នោតឡើយ ។ ត្រូវបានកំណត់ជាសម្ភារ និងបរិក្ខារមានដូចជា រថយន្ត សម្ភារការិយាល័យ សម្ភារចុះឈ្មោះបោះឆ្នោត សម្ភារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬសម្ភារផ្គត់ផ្គង់ការបោះឆ្នោត និងប្រេងឥន្ធនៈ ។ល។

១.២៤.២ ប្រសិនបើសមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិ និងគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ណាមួយល្មើសនឹងចំណុច ១.២៤.១ ជននោះនឹងត្រូវដាក់ពិន័យ ។ វិធានការដាក់ពិន័យគឺគិតចាប់ពីការព្រមាន រហូតដល់ការបណ្តេញចេញពីការងារ ។

១.២៤.៣ សមាជិក ឬបុគ្គលិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ ដែលល្មើសក្នុងការប្រើប្រាស់សម្ភារ បរិក្ខារទាំងនេះ ត្រូវទូទាត់សងតម្លៃទៅតាមការកំណត់របស់ គ.ជ.ប ។

១.២៤.៤ ប្រសិនបើសមាជិក ឬបុគ្គលិកណាម្នាក់នៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ធ្វើឱ្យបាត់បង់ ឬខូចខាតសម្ភារបរិក្ខារក្នុងពេលប្រើប្រាស់ខុសច្បាប់បុគ្គលនោះត្រូវទូទាត់សងតម្លៃនៃសម្ភារបរិក្ខារដែលបានបាត់បង់ ឬខូចខាតនោះ ។

១.២៤.៥ គ.ជ.ប ត្រូវចេញផ្សាយបទបញ្ជាជាមូលដ្ឋាន សម្រាប់ការប្រើប្រាស់សម្ភារ បរិក្ខារ ។

ប្រតិទិនៃការបោះឆ្នោត

ប្រការ ១.២៥.-

គ.ជ.ប ត្រូវបោះពុម្ពផ្សាយប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

១.២៥.១ បន្ទាប់ពីប្រកាសថ្ងៃបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប ត្រូវចាត់ចែងធ្វើប្រតិទិននៃការបោះឆ្នោត និងបោះពុម្ពផ្សាយជាបន្ទាន់ ។

១.២៥.២ ប្រតិទិននៃការបោះឆ្នោតត្រូវកំណត់ ៖

- ថ្ងៃចាប់ផ្តើមចុះឈ្មោះអ្នកសង្កេតការណ៍ និងថ្ងៃបញ្ចប់
- ថ្ងៃចាប់ផ្តើមចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងថ្ងៃបញ្ចប់
- ថ្ងៃចាប់ផ្តើមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ និងថ្ងៃបញ្ចប់ទទួលពាក្យ
- ថ្ងៃចាប់ផ្តើម និងថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត
- ថ្ងៃបោះឆ្នោត និងថ្ងៃប្រកាសលទ្ធផលបណ្តោះអាសន្ន និងលទ្ធផលផ្លូវការ
- ថ្ងៃចាប់ផ្តើមទទួល និងដោះស្រាយពាក្យបណ្តឹងតាមដំណាក់កាលនីមួយៗ ។

ការការពារសន្តិសុខបោះឆ្នោត

ប្រការ ១.២៦.-

គ.ជ.ប មានសិទ្ធិអំណាច ភារកិច្ច និងការទទួលខុសត្រូវក្នុងការលើកវិធានការ និងចាត់ចែងការងារ ដើម្បីធានាកិច្ចការពារសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងដំណើរការបោះឆ្នោត ក្នុងនោះ ត្រូវណែនាំ គធ.ខប គយ.សប និង គ.ក.ប ឱ្យសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច លើកវិធានការការពារ បង្ការ និងដោះស្រាយជាក់ស្តែង តាមពេលវេលា ទីកន្លែង ក្នុងភូមិសាស្ត្រ និងចាត់ចែងឱ្យមានការផ្លាស់ប្តូរព័ត៌មាន និងធ្វើការផ្សព្វផ្សាយក្នុងករណីចាំបាច់ ។

ប្រការ ១.២៧.-

ក្រសួង ឬស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហប្រតិបត្តិការដល់ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់

សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត តាមសំណើរបស់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

១.២៧.១ ផ្អែកតាមផែនការអន្តរស្ថាប័នមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប លេខ ០០៩ ផក/១៦ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៦ ស្តីពីកិច្ចការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ - ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦-២០១៩ រាជរដ្ឋាភិបាលបានសម្រេចបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ អក្សរកាត់ (គ.ស.អ) ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការ និងមានតួនាទី ភារកិច្ចត្រូវសហការ និងរៀបចំចាត់វិធានការ ឬសេចក្តីណែនាំផ្សេងៗ ស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ និងតាមដានត្រួតពិនិត្យ គ្រប់គ្រងការប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ឱ្យបំពេញការកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោតនៅក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

១.២៧.២ គ.ជ.ប មានលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃអគ្គលេខាធិការដ្ឋាន ដែលត្រូវបានបង្កើតឡើងតាមសេចក្តីសម្រេចរបស់ គ.ជ.ប ជាជំនួយការផ្នែកការងារសន្តិសុខបោះឆ្នោតឱ្យ គ.ជ.ប មានការកិច្ចសម្របសម្រួល និងសហការជាមួយលេខាធិការដ្ឋានរបស់ គ.ស.អ ឬ/និងអង្គភាពជំនាញនៃស្ថាប័នពាក់ព័ន្ធ ក្នុងការរៀបចំខ្លឹមសារនៃផែនការ ឬសេចក្តីណែនាំផ្សេងៗ ស្តីពីការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ជាសេនាធិការឱ្យលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដើម្បីជួយការងារបច្ចេកទេស និងរដ្ឋបាល ។

១.២៧.៣ យន្តការ និងរចនាសម្ព័ន្ធផ្នែកសន្តិសុខរបស់ គ.ជ.ប និង គ.ស.អ ៖



១.២៧.៤ គ.ជ.ប (លេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃអគ្គលេខាធិការដ្ឋាន) គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ ត្រូវសហការតាមហ៊ានានុក្រមនៃរចនាសម្ព័ន្ធចាត់តាំងផ្នែកសន្តិសុខរបស់ គ.ស.អ ដែលរួមមាន ៖ លេខាធិការដ្ឋានរបស់ គ.ស.អ អភិបាលនៃគណៈអភិបាល និងជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ និងភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ដើម្បីរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងដំណើរការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូចបានកំណត់បង្ហាញក្នុងចំណុច ១.២៧.៣ ខាងលើ។

១.២៧.៥ ភ្នាក់ងារសន្តិសុខបោះឆ្នោតទាំងអស់ ត្រូវស្ថិតក្នុងឯកសណ្ឋានផ្លូវការរបស់កងនគរបាលជាតិ ឬកងយោធពលខេមរភូមិន្ទ ឱ្យបានត្រឹមត្រូវ និងត្រូវគោរពអនុវត្តតាមគោលការណ៍នៃ ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌ ព្រមទាំងសេចក្តីណែនាំផ្សេងៗ ។ យន្តការ និងរចនាសម្ព័ន្ធ សន្តិសុខបោះឆ្នោត ត្រូវចាត់ចែងភ្នាក់ងារសន្តិសុខបោះឆ្នោតឱ្យការពារមុខសញ្ញា និងគោលដៅសំខាន់ៗតាមសំណូមពររបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បី

ការពារមុខសញ្ញា ឬគោលដៅខ្លះដែលត្រូវការពារជារួម ឬការពារដោយប្រយោល ដោយយោលទៅលើលទ្ធភាពនៃការប្រើប្រាស់កម្លាំង មធ្យោបាយ សម្ភារនៅក្នុងការការពារមុខសញ្ញា និងគោលដៅដែលបានកំណត់ ។ មុខសញ្ញា និងគោលដៅសំខាន់ៗរួមមាន ៖

ក. មុខសញ្ញាការពារ

- សមាជិក គ.ជ.ប មន្ត្រីបោះឆ្នោតគ្រប់ជាន់ថ្នាក់របស់ គ.ជ.ប
- គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងអ្នកគាំទ្រ
- ប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោត
- អ្នកសង្កេតការណ៍បោះឆ្នោតនៃសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ តំណាង ឬភ្នាក់ងារគណបក្សនយោបាយដែលទទួលបានការអនុញ្ញាត
- តំណាងរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬប្រទេសនានា និងតំណាងអង្គការអន្តរជាតិ ដែលត្រូវបាន គ.ជ.ប អញ្ជើញឱ្យចូលរួមជាអ្នកសង្កេតការណ៍ ។

ខ. គោលដៅការពារ

- ទីស្តីការ គ.ជ.ប និងទីស្នាក់ការ គធ.ខប និង គយ.សប
- ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ទីតាំងបិទផ្សាយបញ្ជីបោះឆ្នោត និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត
- ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត
- កន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងសង្ហារិមបម្រើការងារបោះឆ្នោត ឯកសារបោះឆ្នោត សន្លឹកឆ្នោត និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគោលដៅមួយ ទៅគោលដៅមួយ ដែលកំណត់ដោយ គ.ជ.ប ឬ គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- ទីស្នាក់ការ និងកន្លែងជួបប្រជុំ ឬក្សនព្យុហយាត្រាយោសនារបស់គណបក្សនយោបាយ ឬបេក្ខជន ។

១.២៧.៦ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដែលជាសេនាធិការឱ្យលេខាធិការដ្ឋានសន្តិសុខបោះឆ្នោតនៃអគ្គលេខាធិការដ្ឋាន មានភារកិច្ចរៀបចំផលិតឯកសារ និងសម្ភារទាក់ទងការងារសន្តិសុខសំខាន់ៗរួមមាន សៀវភៅក្រមសីលធម៌សម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ខិត្តប័ណ្ណផ្សព្វផ្សាយផ្សេងៗទាក់ទងការងារសន្តិសុខ និងប្រឡងដៃសន្តិសុខ ដើម្បីសុំគោលការណ៍សម្រេចពី គ.ជ.ប ។

១.២៧.៧ គធ.ខប ត្រូវចាត់ចែងរៀបចំកិច្ចប្រជុំចម្រុះ ក្នុងគោលដៅជួបពិភាក្សា និងស្វែងរកដំណោះស្រាយសមស្រប រួមនឹងការចាត់វិធានការផ្សេងៗដើម្បីបង្ការ ទប់ស្កាត់ និងកាត់បន្ថយឱ្យបានរាល់បញ្ហាទំនាស់ ឬក៏បាតុភាពនានា ដែលអាចនឹងកើតមានឡើងជាយថាហេតុនៅគ្រប់ដំណាក់កាលនៃការរៀបចំការបោះឆ្នោត ។ កិច្ចប្រជុំត្រូវរៀបចំប្រជុំម្តងក្នុងមួយសប្តាហ៍ និងអាចកោះប្រជុំតាមការចាំបាច់ ។ សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះ រួមមាន ៖

- ប្រធាន គធ.ខប ជាសហប្រធាន
- អភិបាលរាជធានី ខេត្ត ឬតំណាង ១នាក់ ជាសហប្រធាន
- តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជាសមាជិក
- តំណាងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ជាសមាជិក
- ស្នងការនគរបាលរាជធានី ខេត្ត ឬតំណាង ១នាក់ ជាសមាជិក
- មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត ឬតំណាង ១នាក់ ជាសមាជិក
- មេបញ្ជាការយោធភូមិភាគពិសេស ឬយោធភូមិភាគ ១-៥ នៃ រាជធានី ខេត្តពាក់ព័ន្ធ ឬតំណាង ១នាក់ ជាសមាជិក
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹកងរាជធានី ខេត្ត ឬតំណាង ១នាក់ ជាសមាជិក

១.២៧.៨ នៅពេលយោសនាបោះឆ្នោត យោធិននៃកងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ ឬភ្នាក់ងារសន្តិសុខបោះឆ្នោត ដែលកំពុងបំពេញការកិច្ច មិនត្រូវ ៖

១.២៧.៨.១ ឈរក្បែរ ឬដើរកៀកពេកនឹងទីតាំង ឬក្បួនយោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីយោសនាបោះឆ្នោតនានា ដោយត្រូវធានាចំពោះគ្រប់គណបក្សនយោបាយឈរឈ្មោះ និងបេក្ខជនគ្រប់រូបនូវសិទ្ធិស្មើៗគ្នា ក្នុងការធ្វើសកម្មភាព និងក្នុងការទទួលបានសេវាសន្តិសុខ សុវត្ថិភាព ការរៀបចំសណ្តាប់ធ្នាប់ និងរបៀបរៀបរយពីអាជ្ញាធរមានសមត្ថកិច្ច ។

១.២៧.៨.២ ចូលរួម ឬក៏ប្រឆាំងចំពោះសកម្មភាពយោសនាបោះឆ្នោតរបស់គណបក្សនយោបាយឈរឈ្មោះ ឬបេក្ខជនណាមួយដាច់ខាត ។

១.២៧.៩ នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣ (បី) នាក់ ដែលការពារនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតតែមួយដាច់តែឯង ត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងពាក់ប្រឡង់ដៃសន្តិសុខរបស់ គ.ជ.ប រហូតដល់ចប់ការកិច្ច ។

១.២៧.៩.១ ភ្នាក់ងារសន្តិសុខបោះឆ្នោត ១ (មួយ) នាក់ ត្រូវចល័តការពារជុំវិញបរិវេណខាងក្នុងនៃការិយាល័យ ដែលមានកាំយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត និងមិនចាំបាច់ប្រើប្រាស់អាវុធ។

១.២៧.៩.២ ភ្នាក់ងារសន្តិសុខបោះឆ្នោត ២ (ពីរ) នាក់ ត្រូវចល័តការពារជុំវិញបរិវេណខាងក្រៅនៃការិយាល័យ ដោយត្រូវស្ថិតនៅក្នុងចម្ងាយពី ១០០ (មួយរយ)ម៉ែត្រ ឬទម្រង់ផ្សេង ឬមានកាំតូចជាង ស្របទៅតាមស្ថានភាពជាក់ស្តែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗ អាចប្រើប្រាស់អាវុធវែង ១ (មួយ) ដើម ដែលមានគ្រាប់យ៉ាងច្រើន ៣០ (សាមសិប) គ្រាប់ ។

១.២៧.១០ ក្នុងករណីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតច្រើន ប្រមូលផ្តុំនៅក្នុងបរិវេណ ឬអគារតែមួយ ចំនួនភ្នាក់ងារសន្តិសុខបោះឆ្នោត សម្រាប់ការិយាល័យនីមួយៗ ត្រូវសមស្របទៅនឹងស្ថានភាពជាក់ស្តែង ប៉ុន្តែមិនត្រូវឱ្យលើសពី ៣ (បី) នាក់ ក្នុងមួយការិយាល័យ ។

១.២៧.១១ ភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវហាមជនគ្រប់រូបយកអាវុធជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីជៀសវាងកុំឱ្យមានការរំខាន ការអុកឡុក ការបំភិតបំភ័យ និងការគំរាមកំហែង ឬក៏ហេតុការណ៍អសន្តិសុខផ្សេងៗ ដែលនឹងអាចកើតមានជាចៃដន្យ ។

១.២៧.១២ ភ្នាក់ងារសន្តិសុខបោះឆ្នោត ឬ/និងភ្នាក់ងារសង្គ្រោះ (ក្រុមបុគ្គលិកពេទ្យ ឬ/និងក្រុមពន្លត់អគ្គិភ័យ...) អាចចូលធ្វើអន្តរាគមន៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតបាន តែក្នុងករណីមានសំណូមពរចាំបាច់ពីប្រធាន គ.ជ.ប ប្រធាន គធ.ខប ប្រធាន គយ.សប ឬពីប្រធាន គ.ក.ប/គ.ក.រ ។

ជំពូកទី ២

ប្រព័ន្ធបោះឆ្នោត និងការកំណត់ចំនួនអាសនៈក្នុងរដ្ឋសភា

ប្រការ ២.១.-

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវអនុវត្តតាមប្រព័ន្ធសមាមាត្រដោយយករាជធានី ខេត្ត ធ្វើជាមណ្ឌលបោះឆ្នោត ។

ប្រការ ២.២.-

អាសនៈនៅក្នុងរដ្ឋសភាមានចំនួន ១២៥ (មួយរយម្ភៃប្រាំ) ដែលបែងចែកតាមមណ្ឌលរាជធានី ខេត្ត ដូចខាងក្រោម ៖

- មណ្ឌលខេត្តបន្ទាយមានជ័យ ចំនួន ០៦ (ប្រាំមួយ) អាសនៈ
- មណ្ឌលខេត្តបាត់ដំបង ចំនួន ០៨ (ប្រាំបី) អាសនៈ
- មណ្ឌលខេត្តកំពង់ចាម ចំនួន ១០ (ដប់) អាសនៈ
- មណ្ឌលខេត្តកំពង់ឆ្នាំង ចំនួន ០៤ (បួន) អាសនៈ
- មណ្ឌលខេត្តកំពង់ស្ពឺ ចំនួន ០៦ (ប្រាំមួយ) អាសនៈ
- មណ្ឌលខេត្តកំពង់ធំ ចំនួន ០៦ (ប្រាំមួយ) អាសនៈ
- មណ្ឌលខេត្តកំពត ចំនួន ០៦ (ប្រាំមួយ) អាសនៈ
- មណ្ឌលខេត្តកណ្តាល ចំនួន ១១ (ដប់មួយ) អាសនៈ
- មណ្ឌលខេត្តកោះកុង ចំនួន ០១ (មួយ) អាសនៈ
- មណ្ឌលខេត្តក្រចេះ ចំនួន ០៣ (បី) អាសនៈ
- មណ្ឌលខេត្តមណ្ឌលគិរី ចំនួន ០១ (មួយ) អាសនៈ
- មណ្ឌលរាជធានីភ្នំពេញ ចំនួន ១២ (ដប់ពីរ) អាសនៈ
- មណ្ឌលខេត្តព្រះវិហារ ចំនួន ០១ (មួយ) អាសនៈ
- មណ្ឌលខេត្តព្រៃវែង ចំនួន ១១ (ដប់មួយ) អាសនៈ
- មណ្ឌលខេត្តពោធិ៍សាត់ ចំនួន ០៤ (បួន) អាសនៈ
- មណ្ឌលខេត្តរតនគិរី ចំនួន ០១ (មួយ) អាសនៈ
- មណ្ឌលខេត្តសៀមរាប ចំនួន ០៦ (ប្រាំមួយ) អាសនៈ

- មណ្ឌលខេត្តព្រះសីហនុ ចំនួន ០៣ (បី) អាសនៈ
- មណ្ឌលខេត្តស្ទឹងត្រែង ចំនួន ០១ (មួយ) អាសនៈ
- មណ្ឌលខេត្តស្វាយរៀង ចំនួន ០៥ (ប្រាំ) អាសនៈ
- មណ្ឌលខេត្តតាកែវ ចំនួន ០៨ (ប្រាំបី) អាសនៈ
- មណ្ឌលខេត្តកែប ចំនួន ០១ (មួយ) អាសនៈ
- មណ្ឌលខេត្តប៉ៃលិន ចំនួន ០១ (មួយ) អាសនៈ
- មណ្ឌលខេត្តឧត្តរមានជ័យ ចំនួន ០១ (មួយ) អាសនៈ
- មណ្ឌលខេត្តត្បូងឃ្មុំ ចំនួន ០៨ (ប្រាំបី) អាសនៈ ។

ជំពូកទី ៣

ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន

ភ្នាក់ងារគណបក្សនយោបាយ

ប្រការ ៣.១.-

នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវអនុវត្តការងារទាក់ទងទៅនឹងភ្នាក់ងារគណបក្សនយោបាយ ។

៣.១.១ អនុលោមទៅតាម ច.ប.ត.រ ភ្នាក់ងារគណបក្សនយោបាយគឺជាតំណាងដែលចាត់តាំងដោយគណបក្សនយោបាយ និងត្រូវបានអនុញ្ញាតដោយ គយ.សប ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។ ភ្នាក់ងារគណបក្សនយោបាយគឺជាអ្នកសង្កេតការណ៍ដែលមានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ ។

៣.១.២ ការផ្តល់បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ គឺសម្រាប់សង្កេតមើលដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៣.១.៣ គណបក្សនយោបាយត្រូវហ្វឹកហ្វឺនដល់ភ្នាក់ងាររបស់ខ្លួនអំពី ច.ប.ត.រ និងច្បាប់ស្តីពីគណបក្សនយោបាយ ព្រមទាំង ប.ន.ត.រ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត ។

៣.១.៤ គណបក្សនយោបាយ ដែលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តណាមួយ មានសិទ្ធិចាត់តាំងភ្នាក់ងារពេញសិទ្ធិរបស់ខ្លួន ១ (មួយ) រូប និងភ្នាក់ងារបម្រុង ១ (មួយ) រូប ដើម្បីសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ ។

៣.១.៥ បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិក កបយ.ស មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយ ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតនៅគ្រប់ដំណាក់កាល ។

៣.១.៦ ភ្នាក់ងារពេញសិទ្ធិនៃគណបក្សនយោបាយនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។ ភ្នាក់ងារបម្រុងនៃគណបក្សនយោបាយត្រូវអនុញ្ញាតឱ្យចាំនៅក្រៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីអវត្តមាន ។

៣.១.៧ គណបក្សនយោបាយ ដែលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅ គយ.សប ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការ ។

៣.១.៨ គណបក្សនយោបាយដែលបានទទួលស្គាល់ឱ្យចុះឈ្មោះភ្នាក់ងារ ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត មានសិទ្ធិផ្លាស់ប្តូរភ្នាក់ងាររបស់ខ្លួនរហូតដល់ម៉ោង ១៧:៣០ នាទី មួយថ្ងៃមុនថ្ងៃបោះឆ្នោត ។

៣.១.៩ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវផ្តល់គំរូពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ទ.១០០៧ ដល់គណបក្សនយោបាយដែលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដោយឥតគិតថ្លៃ ។ គណបក្សនយោបាយអាចថតចម្លងគំរូពាក្យសុំ ទ.១០០៧ ដើម្បីប្រើប្រាស់ក្នុងការដាក់ពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប (www.necelect.org.kh) ។

៣.១.១០ ពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ត្រូវធ្វើជា ៣ (បី) ច្បាប់ ដោយភ្ជាប់មកជាមួយនូវ ៖

- ៣.១.១០.១ ច្បាប់ថតចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់។
- ៣.១.១០.២ បញ្ជីឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុង ដែលជានីតិជនដោយបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃ ខែ ឆ្នាំកំណើត អាសយដ្ឋាន និងការិយាល័យបោះឆ្នោត ដែលភ្នាក់ងារនោះត្រូវបំពេញការងារ។

៣.១.១០.៣ លិខិតបញ្ជាក់របស់មេឃុំ ចៅសង្កាត់សាមីពាក់ព័ន្ធដែលបញ្ជាក់ថាភ្នាក់ងារនោះ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់សាមីពាក់ព័ន្ធនោះ ។

៣.១.១០.៤ សេចក្តីប្រកាសគោរព ច.ប.ត.រ ច្បាប់ស្តីពីគណបក្សនយោបាយ ប.ន.ត.រ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត ។

៣.១.១១ ភ្នាក់ងារគណបក្សនយោបាយត្រូវជាអ្នក ៖

៣.១.១១.១ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ចំណុះរាជធានី ខេត្ត។

៣.១.១១.២ មានសមត្ថភាពអាចបំពេញការងារបាន តាមការធានារបស់គណបក្សនយោបាយ ។

៣.១.១១.៣ បានទទួលការហ្វឹកហ្វឺនជាភ្នាក់ងារគណបក្សនយោបាយតាមការធានារបស់គណបក្សនយោបាយសាមី ។

៣.១.១២ ភ្នាក់ងារគណបក្សនយោបាយត្រូវចុះហត្ថលេខាក្នុងខ្ទង់ហត្ថលេខា ត្រង់បន្ទាត់ឈ្មោះរបស់ខ្លួន ក្នុងបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយ ដើម្បីជាភស្តុតាងនៃការប្រកាសសន្យាថា ៖

៣.១.១២.១ ស្ម័គ្រចិត្តយល់ព្រមតាមការតែងតាំងរបស់គណបក្សឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយ សម្រាប់សង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៣.១.១២.២ គោរព ច.ប.ត.រ ប.ន.ត.រ និងក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត ។

៣.១.១២.៣ ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណីសាមីខ្លួនរំលោភបំពានលើសេចក្តីប្រកាសសន្យានៅចំណុច ៣.១.១២.២ ខាងលើនេះ ។

៣.១.១៣ ពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ត្រូវចុះហត្ថលេខាដោយប្រធានឬតំណាងគណបក្សនយោបាយ ដែលទទួលបានការផ្ទេរសិទ្ធិជាលាយលក្ខណ៍

អក្សរពីប្រធានគណបក្សនយោបាយ ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះ មានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។

៣.១.១៤ គយ.សប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ និងចេញសេចក្ដីសម្រេចអនុញ្ញាត ឬបដិសេធលើឈ្មោះភ្នាក់ងារគណបក្សនយោបាយ ដែលមានក្នុងបញ្ជីឈ្មោះស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ។ បន្ទាប់ពី គយ.សប ពិនិត្យ និងសម្រេចលើបញ្ជីឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ គយ.សប ត្រូវចុះហត្ថលេខា និងបោះត្រា គយ.សប លើគ្រប់ទំព័រទាំង ៣ (បី) ច្បាប់ ដើម្បី ៖

៣.១.១៤.១ ផ្ញើទៅសាមីគណបក្សនយោបាយ ១ (មួយ) ច្បាប់ ។

៣.១.១៤.២ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ។

៣.១.១៤.៣ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៣.១.១៥ ប្រសិនបើ គយ.សប ពិនិត្យលើពាក្យស្នើសុំឃើញថា ភ្នាក់ងារគណបក្សនយោបាយណាម្នាក់ពុំមានលក្ខណសម្បត្តិត្រឹមត្រូវតាមលក្ខខណ្ឌ ដូចបានកំណត់ខាងលើ គយ.សប ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅតំណាងសាមីគណបក្សនយោបាយ ដោយបញ្ជាក់ពីមូលហេតុ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី)ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ ។ គណបក្សនយោបាយមានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនជាថ្មីមួយលើកទៀតជំនួសឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលបានបដិសេធមក គយ.សប ក្នុងរយៈពេលយ៉ាងយូរ ៣ (បី)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងអំពីការបដិសេធនេះ ។ ក្នុងរយៈពេលនេះ ប្រសិនបើតំណាងគណបក្សនយោបាយនៅតែពុំព្រមកែតម្រូវតាមលក្ខខណ្ឌដូចបានកំណត់ទេនោះ គយ.សប ត្រូវសម្រេចទទួលស្គាល់តែឈ្មោះភ្នាក់ងារគណបក្សនយោបាយណា ដែលបំពេញបានត្រឹមត្រូវតាមលក្ខខណ្ឌតែប៉ុណ្ណោះ។ បន្ទាប់ពី គយ.សប សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយរួចហើយ គយ.សប ត្រូវចុះហត្ថលេខា និងចុះកាលបរិច្ឆេទលើបណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងបោះត្រានៅលើជ្រុងខាងស្តាំនៃរូបថត និងផ្តល់ជូនភ្នាក់ងារនោះ ដើម្បីពាក់ក្នុងពេលបំពេញការងារ ។

៣.១.១៦ បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ មានសុពលភាពប្រើប្រាស់សម្រាប់តែការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៣.១.១៧ គ.ក.ប/គ.ក.រ គយ.សប និង គធ.ខប ត្រូវរាយការណ៍ទៅថ្នាក់លើមួយថ្នាក់របស់ខ្លួនអំពីវត្តមាន និងសកម្មភាពនានារបស់ភ្នាក់ងារគណបក្សនយោបាយ ក្នុងអំឡុងពេលនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

អ្នកសង្កេតការណ៍បោះឆ្នោត

ប្រការ ៣.២.-

អ្នកសង្កេតការណ៍រួមមានអ្នកសង្កេតការណ៍ជាតិ និងអ្នកសង្កេតការណ៍អន្តរជាតិ ៖

៣.២.១ អ្នកសង្កេតការណ៍ជាតិ គឺជាជនជាតិខ្មែរ ឬជនបរទេសជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតដោយ គ.ជ.ប ។

៣.២.២ បេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិក កបយ.ស មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍ ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។

៣.២.៣ អ្នកសង្កេតការណ៍ជាតិចល័ត សំដៅលើមន្ត្រីរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិដែលសាមីអង្គភាពស្នើសុំ និងត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស ។

៣.២.៤ អ្នកសង្កេតការណ៍អន្តរជាតិ គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានា ដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ឬដោយ គ.ជ.ប ហើយនឹងអនុញ្ញាតដោយ គ.ជ.ប ។

៣.២.៥ ពាក់ការចំណាយទាំងឡាយរបស់អ្នកសង្កេតការណ៍ ជាបន្ទុករបស់ស្ថាប័ន អង្គការ ឬសាមីខ្លួន ។

អ្នកសង្កេតការណ៍ជាតិ

ប្រការ ៣.៣.-

គ.ជ.ប ត្រូវធ្វើសេចក្តីជូនដំណឹងជាមុន អំពីប្រតិទិននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ការដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ជាតិត្រូវធ្វើនៅ គ.ជ.ប ។ ការទទួលពាក្យចាប់ផ្តើមពីថ្ងៃជូនដំណឹងរហូតដល់ ១០ (ដប់) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៣.៣.១ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងចូលរួមសង្កេតការណ៍បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវមានលក្ខខណ្ឌដូចខាងក្រោម ៖

- ៣.៣.១.១ មានលិខិតបញ្ជាក់ការចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ។
- ៣.៣.១.២ មានលក្ខន្តិក: ឬឯកសារប្រហាក់ប្រហែលគ្នា ដែលបញ្ជាក់ពីគោលបំណង ឬទិសដៅក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ប្រជាធិបតេយ្យ ឬការបោះឆ្នោត ឬសិទ្ធិមនុស្ស ឬច្បាប់ ឬយុត្តិធម៌សង្គម ។
- ៣.៣.១.៣ មានកម្មវិធីបណ្តុះបណ្តាលអប់រំ ស្តីពីការបោះឆ្នោតជូនសមាជិកសង្កេតការណ៍របស់ខ្លួន ។
- ៣.៣.១.៤ មានផែនការការងារ និងស្ថានភាពថវិការបស់ខ្លួន ។

៣.៣.២ ដើម្បីចូលរួមសង្កេតការណ៍មើលការបោះឆ្នោត និងរាប់សន្លឹកឆ្នោត អ្នកសង្កេតការណ៍ជាតិ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានលក្ខណសម្បត្តិដូចខាងលើ ត្រូវដាក់ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួនទៅ គ.ជ.ប តាមប្រតិទិននៃការបោះឆ្នោតដែលកំណត់ដោយ គ.ជ.ប ។

៣.៣.៣ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវផ្តល់គំរូនៃពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ដោយឥតគិតថ្លៃ ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប (www.necelect.org.kh) ។ ពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍ ត្រូវធ្វើជា ៣ (បី) ច្បាប់ ដោយភ្ជាប់មកជាមួយ ៖

- ៣.៣.៣.១ លក្ខខណ្ឌដូចចែងក្នុងចំណុច ៣.៣.១ ខាងលើ ។
- ៣.៣.៣.២ បញ្ជីឈ្មោះអ្នកសង្កេតការណ៍តាមរាជធានី ខេត្ត ដែលត្រូវធ្វើការសង្កេតការណ៍ ។

៣.៣.៣.៣ សេចក្ដីប្រកាសគោរព ច.ប.ត.រ ប.ន.ត.រ និងក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោត ។

៣.៣.៤ អ្នកសង្កេតការណ៍ត្រូវជាអ្នក ៖

៣.៣.៤.១ មានសិទ្ធិបោះឆ្នោត លើកលែងតែជនបរទេស ដូចចែងក្នុងចំណុច ៣.២.១ ។

៣.៣.៤.២ បានទទួលការបណ្ដុះបណ្ដាលអំពី ច.ប.ត.រ ប.ន.ត.រ និងក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍ក្នុងដំណើរការបោះឆ្នោត ។

៣.៣.៥ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងរយៈពេលយ៉ាងយូរ ៣ (បី)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំ ។

៣.៣.៦ ក្នុងករណីពិនិត្យបញ្ជីឈ្មោះដែលដាក់ស្នើសុំឃើញថា អ្នកសង្កេតការណ៍ណាម្នាក់ពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ គ.ជ.ប ត្រូវបដិសេធឈ្មោះរបស់ជននោះ ដោយត្រូវ ៖

៣.៣.៦.១ រក្សាទុកឈ្មោះអ្នកសង្កេតការណ៍ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ។

៣.៣.៦.២ គូសបន្ទាត់លុបលើឈ្មោះ ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់ និងចារ " បដិសេធ " នៅខាងចុងឈ្មោះត្រង់ខ្វង់ផ្សេងៗ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ ។

៣.៣.៧ គ.ជ.ប ត្រូវចេញសេចក្ដីសម្រេចអនុញ្ញាតជាលាយលក្ខណ៍អក្សរ ចំពោះតែអ្នកសង្កេតការណ៍ណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងបដិសេធឈ្មោះអ្នកសង្កេតការណ៍ដែលមានលក្ខណសម្បត្តិមិនគ្រប់គ្រាន់នោះចោល ។

៣.៣.៨ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍របស់ខ្លួនជាថ្មី តាមប្រតិទិនដែលកំណត់ដោយ គ.ជ.ប ។

៣.៣.៩ សេចក្ដីសម្រេចអនុញ្ញាតលើឈ្មោះអ្នកសង្កេតការណ៍ជាតិ ត្រូវធ្វើជា ៤ (បួន) ច្បាប់ ដើម្បី ៖

៣.៣.៩.១ រក្សាទុកនៅ គ.ជ.ប ១ (មួយ) ច្បាប់ ។

៣.៣.៩.២ ផ្ញើទៅ គធ.ខប ៣ក់ព័ន្ធ ១ (មួយ) ច្បាប់ ។

៣.៣.៩.៣ ជូនសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ២ (ពីរ) ច្បាប់ ។

៣.៣.១០ បញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលត្រូវបានសម្រេចត្រូវបោះត្រាលើគ្រប់ទំព័រ រួចផ្ញើបញ្ជីឈ្មោះនោះទៅ គធ.ខប ៣ក់ព័ន្ធ ។

៣.៣.១១ គធ.ខប ត្រូវផ្ដល់បណ្ណសម្គាល់សម្រាប់អ្នកសង្កេតការណ៍ជាតិ បំពេញការងារសង្កេតការណ៍នៅរាជធានី ខេត្តរបស់ខ្លួន ។ គធ.ខប ត្រូវផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលតំណាងរបស់សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបង្ហាញជូនជាមួយនឹងបញ្ជីឈ្មោះអ្នកសង្កេតការណ៍ ដែលផ្ញើជូនជាផ្លូវការដោយ គ.ជ.ប ។

៣.៣.១២ ក្រោយពីបានពិនិត្យឃើញថា ត្រឹមត្រូវហើយ គធ.ខប ត្រូវ ៖

៣.៣.១២.១ ប្រគល់បណ្ណគ្រប់ចំនួនតាមឈ្មោះនៃអ្នកសង្កេតការណ៍ ដែលមាននៅក្នុងបញ្ជីឈ្មោះដើម្បីឱ្យតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបំពេញ និងបិទរូបថត ។

៣.៣.១២.២ ប្រាប់ទៅតំណាងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានទទួលបណ្ណសម្គាល់អ្នកសង្កេតការណ៍គ្រប់ចំនួនហើយនោះថាឱ្យបំពេញឱ្យបានត្រឹមត្រូវ ។

៣.៣.១២.៣ ចុះហត្ថលេខា និងបោះត្រាលើបណ្ណសម្គាល់អ្នកសង្កេតការណ៍ ដែលសាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល បានបំពេញត្រឹមត្រូវ និងបិទរូបថតរួច ដោយសាមីខ្លួនអាចចុះហត្ថលេខាជាក្រោយ ។

៣.៣.១៣ បណ្ណសម្គាល់អ្នកសង្កេតការណ៍ដែលអាចយកជាផ្លូវការបាន ក្នុងដំណើរការសង្កេតការណ៍បោះឆ្នោតលុះត្រាតែ ៖

៣.៣.១៣.១ បណ្ណសម្គាល់ចេញដោយ គ.ជ.ប តាមរយៈ គធ.ខប ។

៣.៣.១៣.២ បណ្ណមានបិទរូបថត និងបំពេញត្រឹមត្រូវតាមខ្លឹមសារក្នុងបណ្ណសម្គាល់ ។

៣.៣.១៣.៣ ត្រូវបាន គធ.ខប បោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថត ។

៣.៣.១៤ ប្រធាន ឬតំណាងរបស់សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ត្រូវចុះហត្ថលេខាលើការធានា និងការទទួលខុសត្រូវលើបញ្ជីឈ្មោះអ្នកសង្កេតការណ៍របស់ខ្លួន ជាពិសេសគឺការទទួលខុសត្រូវចំពោះមុខច្បាប់ អំពីអត្តសញ្ញាណរបស់អ្នកសង្កេតការណ៍ម្នាក់ៗ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។

៣.៣.១៥ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល អាចស្នើសុំដាក់អ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេស បានយ៉ាងច្រើន ១០ (ដប់) នាក់ ក្នុងករណី សាមីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះ មានអ្នកសង្កេតការណ៍របស់ខ្លួនចាប់ពី ៥ (ប្រាំ) រាជធានីខេត្តឡើងទៅ ។ បណ្ណចល័តទូទាំងប្រទេសមានគំរូ និងពណ៌ផ្សេងគ្នាពីបណ្ណអ្នកសង្កេតការណ៍ជាតិ ។ ការដាក់ពាក្យសុំអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេស មាននីតិវិធីដូចគ្នានឹងការដាក់ពាក្យសុំអ្នកសង្កេតការណ៍ជាតិដែរ ។ អ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសមានសិទ្ធិ និងភារកិច្ចដូចមានចែងក្នុងក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោត ។

៣.៣.១៦ អង្គការដែលបង្កើតដោយរាជរដ្ឋាភិបាល មិនអនុញ្ញាតឱ្យធ្វើជាអ្នកសង្កេតការណ៍ឡើយ ។

៣.៣.១៧ គធ.ខប ត្រូវធ្វើរបាយការណ៍ប្ញកសរុបចំនួនអ្នកសង្កេតការណ៍ជាតិ តាមដំណាក់កាលនីមួយៗ រួចផ្ញើមក គ.ជ.ប ។

អ្នកសង្កេតការណ៍អន្តរជាតិ

ប្រការ ៣.៤.-

នៅពេលអញ្ជើញចូលមកដល់ព្រះរាជាណាចក្រកម្ពុជា អ្នកសង្កេតការណ៍អន្តរជាតិ ត្រូវទៅបង្ហាញខ្លួននៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើម្បីទទួលព័ត៌មានផ្សេងៗ។

៣.៤.១ អ្នកសង្កេតការណ៍អន្តរជាតិ ដែលមានបំណងចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍អន្តរជាតិ នៅ គ.ជ.ប ក្នុងរយៈពេលចាប់តាំងពីថ្ងៃប្រកាសផ្សាយប្រតិទិនបោះឆ្នោតរហូតដល់ ៣ (បី) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៣.៤.២ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវផ្តល់ជូននូវគំរូពាក្យសុំចុះឈ្មោះអ្នកសង្កេតការណ៍អន្តរជាតិ និងបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិ ដោយឥតគិតថ្លៃ ដើម្បីបំពេញ និងបិទរូបថត ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័រ គ.ជ.ប (www.necelect.org.kh) ។

៣.៤.៣ គ.ជ.ប ត្រូវពិនិត្យពាក្យសុំចុះឈ្មោះ និងបណ្ណសម្គាល់ដែលបានបំពេញហើយ និងចេញសេចក្តីសម្រេចអនុញ្ញាតយល់ព្រមឱ្យអ្នកសង្កេតការណ៍អន្តរជាតិ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលពាក្យសុំ ។

៣.៤.៤ ក្រោយពីពិនិត្យឃើញថា ពាក្យសុំចុះឈ្មោះរៀបចំពុំទាន់បានត្រឹមត្រូវ គ.ជ.ប ត្រូវណែនាំអ្នកសង្កេតការណ៍អន្តរជាតិនោះឱ្យបំពេញ ឬកែតម្រូវឡើងវិញភ្លាមៗ ដើម្បី គ.ជ.ប ចេញសេចក្តីសម្រេចអនុញ្ញាត ។

៣.៤.៥ ក្នុងករណីពិនិត្យឃើញថា ពាក្យសុំចុះឈ្មោះមានលក្ខណសម្បត្តិគ្រប់គ្រាន់ហើយ គ.ជ.ប ត្រូវជូនបណ្ណអ្នកសង្កេតការណ៍អន្តរជាតិឱ្យសាមីខ្លួន ឬតំណាង ដើម្បីសរសេរបំពេញ បិទរូបថត និងចុះហត្ថលេខាសាមីខ្លួន រួចហើយត្រូវជូនបណ្ណនោះមក គ.ជ.ប វិញ ។

៣.៤.៦ បន្ទាប់ពីទទួលបណ្ណដែលបានបំពេញត្រឹមត្រូវហើយ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចអនុញ្ញាត ចុះហត្ថលេខា និងបោះត្រានៅលើជ្រុងខាងស្តាំ ផ្នែកខាងក្រោមនៃរូបថតភ្ជាប់ទៅនឹងបណ្ណសម្គាល់អ្នកសង្កេតការណ៍អន្តរជាតិ រួចប្រគល់ជូនទៅអ្នកសង្កេតការណ៍នោះវិញ ដើម្បីពាក់បំពេញការងារ ។

៣.៤.៧ អ្នកសង្កេតការណ៍អន្តរជាតិ ដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប មានសិទ្ធិសង្កេតមើលដំណើរការបោះឆ្នោតទាំងមូល ឬតាមដំណាក់កាល និងគ្រប់ទីកន្លែងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៣.៤.៨ អ្នកបកប្រែរបស់អ្នកសង្កេតការណ៍អន្តរជាតិ ត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយ នឹងពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍អន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង ។ អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសង្កេតការណ៍អន្តរជាតិឡើយ ប៉ុន្តែអាចចូលរួមដំណើរជាមួយអ្នកសង្កេតការណ៍អន្តរជាតិទៅគ្រប់កន្លែងធ្វើការសង្កេតការណ៍ ។

អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ

ប្រការ ៣.៥.

សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ ដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះ ដោយផ្ទាល់នៅ គ.ជ.ប ។

៣.៥.១ នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈត្រូវអនុវត្តការងារទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន អ្នកសារព័ត៌មានជាតិ អន្តរជាតិ និងអ្នកសារព័ត៌មានឯករាជ ដែលចូលរួមក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៣.៥.២ គ.ជ.ប ត្រូវផ្តល់ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មាន ដល់សមាគមអ្នកសារព័ត៌មាន ឬអង្គភាពសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ តាមការស្នើសុំដោយឥតគិតថ្លៃ ។ ទម្រង់បែបបទស្នើសុំអាចទាញយកពីគេហទំព័រ គ.ជ.ប (www.necelect.org.kh) ។

៣.៥.២.១ រយៈពេលនៃការទទួលពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានជាតិ គឺចាប់តាំងពីថ្ងៃប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតរហូតដល់ ១០ (ដប់)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៣.៥.២.២ រយៈពេលនៃការដាក់ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានអន្តរជាតិ គឺចាប់តាំងពីថ្ងៃប្រកាសកាលបរិច្ឆេទនៃការបោះឆ្នោតរហូតដល់ ៣ (បី)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៣.៥.៣ ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានជាតិ និងអន្តរជាតិត្រូវភ្ជាប់ជាមួយនូវឯកសារមួយចំនួន ដូចខាងក្រោម ៖

៣.៥.៣.១ សម្រាប់អ្នកសារព័ត៌មានជាតិ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន

- លិខិតស្នើសុំធ្វើបណ្ណអ្នកសារព័ត៌មានពី គ.ជ.ប របស់សាមីអង្គភាព
- ច្បាប់ចម្លងនៃបណ្ណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប ។

៣.៥.៣.២ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិ ដែលមានការិយាល័យអចិន្ត្រៃយ៍នៅព្រះរាជាណាចក្រកម្ពុជា ត្រូវភ្ជាប់មកជាមួយនូវ ៖
- ច្បាប់ចម្លងប្រកាសអនុញ្ញាតដោយក្រសួងព័ត៌មាន
- លិខិតស្នើសុំធ្វើបណ្ណអ្នកសារព័ត៌មានពី គ.ជ.ប របស់សាមីអង្គភាព
- ច្បាប់ចម្លងនៃបណ្ណអ្នកសារព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគម ឬបណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប
- ច្បាប់ចម្លងនៃលិខិតឆ្លងដែន (សម្រាប់ជនបរទេស) ។

៣.៥.៣.៣ សម្រាប់អ្នកសារព័ត៌មានអន្តរជាតិ ដែលពុំមានការិយាល័យអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យដោយផ្ទាល់នៅ គ.ជ.ប ឬតាមអ៊ីម៉ែល necinfo@forum.org.kh និងត្រូវភ្ជាប់ជាមួយនូវ ៖
- ច្បាប់ចម្លងនៃលិខិតឆ្លងដែន
- បណ្ណសម្គាល់ខ្លួនជាអ្នកសារព័ត៌មានរបស់សាមីអង្គភាព
- ប្រវត្តិរូបសង្ខេប ។

៣.៥.៣.៤ សម្រាប់អ្នកសារព័ត៌មានឯករាជ ត្រូវភ្ជាប់មកជាមួយនូវ ៖
- ច្បាប់ចម្លងនៃបណ្ណព័ត៌មាន ដែលចេញដោយក្រសួងព័ត៌មាន ឬសមាគមអ្នកសារព័ត៌មាន
- ប្រវត្តិរូបសង្ខេប
- អត្ថបទចុងក្រោយ ដែលខ្លួនបានសរសេរចុះផ្សាយក្នុងសារព័ត៌មានស្របច្បាប់ក្នុងអំឡុងឆ្នាំចុងក្រោយចំនួន ៣ (បី) អត្ថបទ ។

៣.៥.៤ គ.ជ.ប ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ សម្រាប់អ្នកសារព័ត៌មានជាតិ ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានជាតិដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកសារព័ត៌មាន អាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀត ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតបដិសេធ ។

៣.៥.៥ គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ ។ ក្នុងករណី គ.ជ.ប បដិសេធការសុំចុះឈ្មោះអ្នកសារព័ត៌មានអន្តរជាតិ ដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់ សាមីអង្គភាព ឬសាមីអ្នកសារព័ត៌មានអាចបំពេញឯកសារបន្ថែមឱ្យបានគ្រប់គ្រាន់ ហើយដាក់ពាក្យសុំមួយលើកទៀត ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

៣.៥.៦ គ.ជ.ប ត្រូវបោះពុម្ពបណ្ណសម្គាល់អ្នកសារព័ត៌មានជាតិ និងបណ្ណសម្គាល់អ្នកសារព័ត៌មានអន្តរជាតិ ដើម្បីផ្តល់ជូនដោយឥតគិតថ្លៃដល់អ្នកសារព័ត៌មាន ដែលត្រូវបានអនុញ្ញាតឱ្យយកព័ត៌មានដោយ គ.ជ.ប ដើម្បីពាក់ក្នុងពេលបំពេញការងារ ។

៣.៥.៧ អ្នកសារព័ត៌មានត្រូវគោរពច្បាប់ស្តីពីរបបសារព័ត៌មាន ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌ និងវិជ្ជាជីវៈអ្នកសារព័ត៌មាន ។

៣.៥.៨ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលបានទទួលការអនុញ្ញាតដោយ គ.ជ.ប អាចយកព័ត៌មានក្នុងដំណើរការបោះឆ្នោតទាំងមូល ដោយត្រូវគោរព ច.ប.ត.រ ប.ន.ត.រ និងគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ។

៣.៥.៩ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ មានសិទ្ធិថត និងយកព័ត៌មាន ។

៣.៥.១០ ការយកព័ត៌មានដោយរូបភាពក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវជម្រាបជូនដំណឹងទៅប្រធាន គ.ក.ប/គ.ក.រ ជាមុន ។

៣.៥.១១ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិមិនត្រូវ ៖

- ជ្រៀតជ្រែក ឬរំខានដល់ការងារបោះឆ្នោត និងរាប់សន្លឹកឆ្នោត។
- ធ្វើសម្ភាសន៍នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៣.៥.១២ អ្នកបកប្រែរបស់អ្នកសារព័ត៌មានអន្តរជាតិ ត្រូវដាក់ឈ្មោះភ្ជាប់មកជាមួយនឹងពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានអន្តរជាតិ ដោយបញ្ជាក់ពីមុខងាររបស់ខ្លួនផង ។ អ្នកបកប្រែភាសាពុំមានសិទ្ធិដូចអ្នកសារព័ត៌មានអន្តរជាតិឡើយ ប៉ុន្តែអាចចូលរួមដំណើរជាមួយអ្នកសារព័ត៌មានអន្តរជាតិទៅគ្រប់កន្លែង ។

៣.៥.១៣ អ្នកសារព័ត៌មានមិនត្រូវប្រើប្រាស់ត្តនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើសមាជិក គយ.សប ឬសមាជិក គ.ក.ប/គ.ក.រ ឬអ្នកសង្កេតការណ៍ ឬបេក្ខជន ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកមានសិទ្ធិបោះឆ្នោតឡើយ ។

ជំពូកទី ៤
ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត
និងបញ្ជីបេក្ខជនឈរឈ្មោះ

ប្រការ ៤.១.-

អនុលោមតាមមាត្រា ២៣ នៃ ច.ប.ត.រ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពលរដ្ឋម្នាក់ៗត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ។

៤.១.១ មានសញ្ជាតិខ្មែរពីកំណើត ។

៤.១.២ មានអាយុ ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត ។

៤.១.៣ មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។

៤.១.៤ មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

៤.១.៥ មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ប្រការ ៤.២.-

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺ ៖

៤.២.១ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា ឬ

៤.២.២ ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

៤.២.៣ ជនដែលត្រូវផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត

៤.២.៤ ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

៤.២.៥ ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោតដោយ គ.ជ.ប ឬ

៤.២.៦ សមាជិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ

៤.២.៧ សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

៤.២.៨ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

ប្រការ ៤.៣.-

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទ រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការយោសនាបោះឆ្នោត ។

៤.៣.១ ប្រសិនបើជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ឬអង្គភាពរបស់ខ្លួនទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីខ្លួនត្រូវមានសិទ្ធិឡើងឋានន្តរស័ក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារ សម្រាប់ទទួលសោធននិវត្តន៍ ។

៤.៣.២ នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

ប្រការ ៤.៤.-

លិខិតបញ្ជាក់ការអនុញ្ញាតច្បាប់ឈប់ពិសេសពីក្រសួង ឬអង្គភាពអាចភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។ ក្នុងករណីមិនអាចធ្វើទាន់ ត្រូវធ្វើពាក្យសុំច្បាប់ឈប់ពិសេសជូន គ.ជ.ប ក្នុងរយៈពេលយ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃចាប់ផ្តើមបើកយុទ្ធនាការយោសនាបោះឆ្នោត ។

លិខិតបញ្ជាក់អនុញ្ញាតច្បាប់ឈប់ពិសេស ត្រូវបញ្ជាក់ឱ្យបានច្បាស់អំពីឈ្មោះសាមីជន ដែលបានសុំច្បាប់ឈប់ពិសេស មុខតំណែង ក្រសួង ឬអង្គភាព ដែលសាមីជនកំពុងបម្រើការងារ កាលបរិច្ឆេទសុំច្បាប់ឈប់ពិសេស និងមានហត្ថលេខារបស់ថ្នាក់ដឹកនាំរបស់ខ្លួន ពោលគឺនៅថ្នាក់លើមួយថ្នាក់ដែលខ្លួននៅក្រោមឱវាទ ។

ប្រការ ៤.៥.

គណបក្សនយោបាយ ដែលបានចុះបញ្ជីត្រឹមត្រូវតាមលក្ខខណ្ឌ ដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៤.៥.១ គណបក្សនយោបាយដូចចែងក្នុងប្រការ ៤.៥ ដែលមានបំណងចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវរៀបចំបញ្ជីបេក្ខជនរបស់ខ្លួនតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗ ។

៤.៥.២ គណបក្សនយោបាយ ដែលបានតែងតាំងបេក្ខជន ត្រូវបំពេញបែបបទសេចក្តីប្រកាសបេក្ខភាពតាមគំរូដែលផ្តល់ដោយ គ.ជ.ប ។ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត តាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗ ត្រូវ ៖

- ៤.៥.២.១ ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។
- ៤.៥.២.២ មានសេចក្តីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោត ដោយអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត ។
- ៤.៥.២.៣ ភ្ជាប់សេចក្តីប្រកាសរបស់បេក្ខជន យល់ព្រមទទួលការតែងតាំងជាបេក្ខជន តាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

៤.៥.៣ បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់មណ្ឌលតែមួយគត់ ។ បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះលើសពីមួយមណ្ឌល នឹងត្រូវបានប្រកាសថាបាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយ គ.ជ.ប ទោះជាសាមីខ្លួនទៅឈរឈ្មោះជាបេក្ខជន ក្នុងគណបក្សនយោបាយណាផ្សេងទៀតក៏ដោយ ។

ប្រការ ៤.៦.

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវចាប់ផ្តើម ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ប្រការ ៤.៧.

ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាផ្លូវការ គណ-បក្សនយោបាយ ត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមបែបបទកំណត់ ដោយ គ.ជ.ប មក គ.ជ.ប ។

៤.៧.១ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គឺជាទម្រង់បែបបទ លេខ ១០០៨ (ទ.១០០៨) ។ ពាក្យសុំចុះបញ្ជីនេះត្រូវបានផ្តល់ដោយឥតគិតថ្លៃជូន គណបក្សនយោបាយ ដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រ ។ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីនេះជា ២ (ពីរ) ច្បាប់ ។

៤.៧.២ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាង ដែលបាន ទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរ ពីប្រធានគណបក្សនយោបាយនោះ ។ ការផ្ទេរសិទ្ធិបន្ត ត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រធានគណបក្ស នយោបាយ ។

៤.៧.៣ ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវភ្ជាប់មកជាមួយនូវ ៖

- ៤.៧.៣.១ សេចក្ដីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅ ក្រសួងមហាផ្ទៃ ១ (មួយ) ច្បាប់ ។
- ៤.៧.៣.២ ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និង សញ្ញាសម្គាល់គណបក្សនយោបាយ ។
- ៤.៧.៣.៣ អាសយដ្ឋាននៃទីស្នាក់ការកណ្ដាលគណបក្សនយោបាយ ។
- ៤.៧.៣.៤ បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបទូទាំងប្រទេស ។ បញ្ជីនេះ ត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិច ១/៣ (មួយភាគបី) នៃ ចំនួនអាសនៈក្នុងរដ្ឋសភា និងបេក្ខជនបម្រុងចំនួនស្មើគ្នានឹង បេក្ខជនពេញសិទ្ធិ ។

៤.៧.៣.៥ ឈ្មោះមណ្ឌល ដែលគណបក្សនយោបាយមានបំណងទៅឈរ និងបញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលទាំងនោះ ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌល ត្រូវមានបេក្ខជនគ្រប់តាមចំនួន អាសនៈ និងតាមគំរូដែល គ.ជ.ប ផ្តល់ជូន ។ ចំពោះមណ្ឌលបោះឆ្នោតដែលមានអាសនៈ ១ (មួយ) ឬ ២ (ពីរ) ត្រូវមានបេក្ខជនបម្រុងចំនួនយ៉ាងតិច ៣ (បី) រូប ។

៤.៧.៣.៦ សេចក្តីប្រកាសអំពីគណនីធនាគារ ដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗ រួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

៤.៧.៣.៧ លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗ ដែលបញ្ជាក់ពីការបង្កើតគណបក្សនយោបាយ ។

៤.៧.៣.៨ សេចក្តីប្រកាសរបស់គណបក្សនយោបាយថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលបោះឆ្នោត ដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងចូលរួមអនុវត្ត ច.ប.ត.រ ប.ន.ត.រ របស់ គ.ជ.ប និងក្រមសីលធម៌ និងច្បាប់ស្តីពីគណបក្សនយោបាយ ។

៤.៧.៣.៩ បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ ។

៤.៧.៣.១០ បង្កាន់ដៃបង់ប្រាក់តម្លៃចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដែលចេញដោយរតនាគារជាតិ ។

ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

ប្រការ ៤.៨.-

គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៤.៨.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈ នូវកាលបរិច្ឆេទ ទីកន្លែង និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

៤.៨.២ ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ២:០០នាទី ដល់ម៉ោង ៥:៣០នាទី ។

៤.៨.៣ គ.ជ.ប ត្រូវចេញបង្កាន់ដៃទទួលពាក្យ ជូនគណបក្សនយោបាយដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងរក្សាគល់បញ្ជី ១ (មួយ) ច្បាប់ ទុកជាឯកសារ ។

៤.៨.៤ បង្កាន់ដៃទទួលពាក្យត្រូវបញ្ជាក់អំពីចំនួន និងប្រភេទឯកសារ ដែលបានទទួល ដោយត្រូវចុះកាលបរិច្ឆេទប្រគល់ ទទួល និងចុះហត្ថលេខា ឬស្នាមមេដៃរបស់អ្នកប្រគល់ ទទួល ។

ការពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

ប្រការ ៤.៩.

គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ ។

៤.៩.១ ក្នុងករណី គ.ជ.ប យល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនសាមីគណបក្សនយោបាយ ។

៤.៩.២ ក្នុងករណី គ.ជ.ប ពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយណាមួយពុំបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៤.៧ ខាងលើ គ.ជ.ប ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញ ដើម្បីបំពេញបន្ថែម ឬកែតម្រូវ ។

៤.៩.២.១ សាមីគណបក្សនយោបាយត្រូវបំពេញ ឬកែតម្រូវលក្ខខណ្ឌ ដែលខ្វះខាតយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានទទួលលិខិតជូនដំណឹង ។

៤.៩.២.២ ក្នុងករណីគណបក្សនយោបាយពុំបានបំពេញលក្ខខណ្ឌតាមការកំណត់ ដូចមានចែងក្នុងចំណុច ៤.៩.២.១ ខាងលើ គ.ជ.ប ត្រូវចាត់ទុកថា សាមីគណបក្សនយោបាយបានបោះបង់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

៤.៩.៣ ក្នុងការសម្រេចបដិសេធការសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវ ៖

៤.៩.៣.១ ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្តីសម្រេចបដិសេធ ចំនួន ៣ (បី) ច្បាប់ រួចផ្ញើជូន ៖

- គណបក្សនយោបាយសាមី ឬតំណាង ១ (មួយ) ច្បាប់
- ក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៤.៩.៣.២ ផ្តល់ព័ត៌មានទៅសាមីគណបក្សនយោបាយ ឬតំណាងថា គាត់អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ ។

៤.៩.៣.៣ នីតិវិធីដាក់/ទទួលពាក្យបណ្តឹង ត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

ប្រការ ៤.១០.-

គណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ហើយត្រូវបានបដិសេធដោយ គ.ជ.ប សាមីគណបក្សនយោបាយ ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ ។

៤.១០.១ ក្នុងករណីទទួលសេចក្តីសម្រេចបដិសេធ និងទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាហើយ ប៉ុន្តែសាមីគណបក្ស ឬតំណាង ពុំបានដាក់ពាក្យប្តឹងតវ៉ាទៅតាមពេលវេលា ដូចចែងក្នុងប្រការ ៤.១០ ទេនោះ ត្រូវចាត់ទុកថាមិនបានប្តឹងតវ៉ា ។

៤.១០.២ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

ប្រការ ៤.១១.-

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមលើពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចយល់ព្រម និងជូនដំណឹងទៅអ្នកប្តឹងតវ៉ា ហើយបង្គាប់ឱ្យ គ.ជ.ប ចុះឈ្មោះសាមីគណបក្សនយោបាយទៅក្នុងបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាបន្ទាន់ ។

៤.១១.១ បន្ទាប់ពីបានទទួលសេចក្ដីសម្រេចពីក្រុមប្រឹក្សាធម្មនុញ្ញ គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនទៅសាមីគណបក្សនយោបាយ ។

៤.១១.២ គ.ជ.ប ត្រូវផ្ញើលិខិតបញ្ជាក់នេះ ១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

ប្រការ ៤.១២.-

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធបណ្ដឹងតវ៉ា សេចក្ដីសម្រេចនេះ គឺជាសេចក្ដីសម្រេចចុងក្រោយបិទផ្លូវតវ៉ា ហើយក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

៤.១២.១ ផ្ដល់សេចក្ដីសម្រេចបដិសេធនេះ ១ (មួយ) ច្បាប់ ទៅសាមីគណបក្សនយោបាយ ឬតំណាង ។

៤.១២.២ ផ្ញើសេចក្ដីសម្រេចបដិសេធ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ។

ប្រការ ៤.១៣.-

បន្ទាប់ពីបានបញ្ឈប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ ឬ/និងក្រោយពេល ដែលបណ្ដឹងតវ៉ាត្រូវបានដោះស្រាយបញ្ចប់ជាស្ថាពរ គ.ជ.ប ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្ត របស់គណបក្សនយោបាយទាំងនោះ ដូចមានចែងក្នុងប្រការ ៤.១៤ ខាងក្រោម ។

សិទ្ធិទទួលបាននូវការការពារសុវត្ថិភាពរបស់បេក្ខជន

ប្រការ ៤.១៤.-

គ.ជ.ប ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតផ្លូវការតាមរាជធានី ខេត្ត ក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៤.១៤.១ បេក្ខជនម្នាក់ៗមានសិទ្ធិទទួលបាននូវការការពារសន្តិសុខ និងសុវត្ថិភាព ដូចមានចែងក្នុងជំពូកទី ៣ មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

៤.១៤.២ ប្រសិនបើបេក្ខជនអាចផ្ដល់ភស្តុតាង ឬមានមូលហេតុច្បាស់លាស់ថា សន្តិសុខ និងសុវត្ថិភាពរបស់ខ្លួនត្រូវបាន និងកំពុងរងនូវការគំរាមកំហែងនោះ បេក្ខជនអាចប្តឹងទៅ គ.ជ.ប ជាបន្ទាន់ ។

៤.១៤.៣ គ.ជ.ប ត្រូវប្រជុំការងារសន្តិសុខ ដើម្បីដោះស្រាយពាក្យប្តឹង ដោយបើកការស៊ើបអង្កេត ហើយទន្ទឹមគ្នានេះត្រូវចាត់វិធានការចាំបាច់គ្រប់រូបភាព ដើម្បីផ្តល់សន្តិសុខ និងសុវត្ថិភាពជូនបេក្ខជន ។

៤.១៤.៤ នៅពេលដែលការស៊ើបអង្កេតរកឃើញកស្តុតាងអំពីការគំរាមកំហែងសន្តិសុខ និងសុវត្ថិភាពដល់បេក្ខជនឈរឈ្មោះបោះឆ្នោត គ.ជ.ប ត្រូវដោះស្រាយតាមច្បាប់ និងនីតិវិធីនៃការបោះឆ្នោត ។

សិទ្ធិប្តឹងការិយាល័យបោះឆ្នោត

ប្រការ ៤.១៥.-

យោងតាមមាត្រា ៤៧ នៃ ច.ប.ត.រ បេក្ខជនឈរឈ្មោះបោះឆ្នោត សហព័ទ្ធ (ប្តី ឬប្រពន្ធ) និងកូនអាចទៅបោះឆ្នោតនៅមណ្ឌលដែលខ្លួនឈរឈ្មោះបោះឆ្នោតបាន ។

៤.១៥.១ នៅពេលដែល គ.ជ.ប បានអនុម័តយល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះរួចហើយ បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជន ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ដែលមានឈ្មោះបោះឆ្នោតក្នុងមណ្ឌលផ្សេងពីមណ្ឌលដែលខ្លួនឈរឈ្មោះ អាចស្នើសុំមក គ.ជ.ប ឱ្យផ្ទេរឈ្មោះរបស់ខ្លួន ព្រមទាំងសហព័ទ្ធ និងកូន ក្នុងករណីមានការយល់ព្រមពីសហព័ទ្ធ និងកូនរបស់ខ្លួន ទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយ ក្នុងមណ្ឌលដែលខ្លួនឈរឈ្មោះ ។

៤.១៥.២ ការដាក់ពាក្យស្នើសុំមក គ.ជ.ប ត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្រោមប្រការ ៦.៩ និងប្រការ ៦.១០ ក្នុងជំពូកទី៦ នៃ ប.ន.ត.រ នេះ ។

ការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនៅលើសន្លឹកឆ្នោត

ប្រការ ៤.១៦.-

គ.ជ.ប ត្រូវរៀបចំពិធីចាប់ឆ្នោតមួយ ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលត្រូវបោះពុម្ពលើសន្លឹកឆ្នោត ។

៤.១៦.១ ផ្អែកលើបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះផ្លូវការ គ.ជ.ប ត្រូវធ្វើការចាប់ឆ្នោត ដើម្បីកំណត់លំដាប់លេខរៀងឈ្មោះគណបក្សនយោបាយ ដែលនឹងត្រូវដាក់លើសន្លឹកឆ្នោត ។

៤.១៦.២ ការចាប់ឆ្នោតត្រូវធ្វើឡើងជាសាធារណៈ ។ គ.ជ.ប ត្រូវបិទផ្សាយជាសាធារណៈអំពីទីកន្លែង កាលបរិច្ឆេទ និងពេលវេលាយ៉ាងហោចណាស់ ២៤ (ម្តៃបួន) ម៉ោងមុនការចាប់ផ្តើមពិធីចាប់ឆ្នោត ។

៤.១៦.៣ លិខិតអញ្ជើញត្រូវប្រគល់ជូនទៅគណបក្សនយោបាយនីមួយៗ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតយ៉ាងហោចណាស់ម្តៃបួន (២៤) ម៉ោង មុនពិធីចាប់ឆ្នោតចាប់ផ្តើម ។ ក្នុងការទទួលលិខិតអញ្ជើញនេះ ត្រូវមានចុះហត្ថលេខារបស់អ្នកទទួល ដើម្បីទុកជាឯកសារ ។

៤.១៦.៤ របៀបវារៈនៃពិធីចាប់ឆ្នោតមានដូចខាងក្រោមនេះ ៖

- ៤.១៦.៤.១ សុន្ទរកថាបើកពិធី ថ្លែងដោយប្រធាន គ.ជ.ប ។
- ៤.១៦.៤.២ ការបង្ហាញសន្លឹកឆ្នោត និងស្រោមសំបុត្រដាក់សន្លឹកឆ្នោត សម្រាប់ចាប់ឆ្នោត ។
- ៤.១៦.៤.៣ ការចាប់ឆ្នោតត្រូវធ្វើឡើងដោយសម្តេចព្រះសង្ឆរាជ ដែលមានជំហរអព្យាក្រឹត និងដែលអាចទទួលយកបានពីគ្រប់គណបក្សនយោបាយ ។
- ៤.១៦.៤.៤ ការប្រកាសលទ្ធផលនៃការចាប់ឆ្នោត ។
- ៤.១៦.៤.៥ ការបិទពិធីចាប់ឆ្នោត ។

៤.១៦.៥ គ.ជ.ប ត្រូវរៀបចំសន្លឹកឆ្នោត ១ (មួយ) សន្លឹក សម្រាប់គណបក្សនយោបាយនីមួយៗ ដែលចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ។

- ៤.១៦.៥.១ ក្រដាសសន្លឹកឆ្នោតនេះត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា ។
- ៤.១៦.៥.២ ឈ្មោះគណបក្សនយោបាយត្រូវសរសេរ ឬបោះពុម្ពជាអក្សរ ដែលមានពណ៌ ប្រភេទ និងទំហំតួអក្សរដូចគ្នានៅលើសន្លឹកឆ្នោតនេះ។
- ៤.១៦.៥.៣ សន្លឹកឆ្នោត ១ (មួយ) សន្លឹក ដែលមានសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយមួយ ត្រូវបត់ដាក់ចូលក្នុងស្រោមសំបុត្រដែលមានប្រភេទ ទំហំ និងពណ៌ដូចគ្នាដែលមិនអាចសម្គាល់បានរួចមូរនិងចងកៅស៊ូកង ពណ៌ដូចគ្នា ។

៤.១៦.៦ មុនចាប់ផ្តើមការចាប់ឆ្នោត គ.ជ.ប ត្រូវបង្ហាញសន្លឹកឆ្នោតរបស់គណបក្សនយោបាយនីមួយៗនៅចំពោះមុខអង្គពិធី មុននឹងបត់ដាក់ចូលក្នុងស្រោមសំបុត្រ រួចបិទភ្ជិត ។

៤.១៦.៦.១ សន្លឹកឆ្នោតនីមួយៗត្រូវបត់ជាពីរផ្នត់ ហើយស៊ីកបញ្ចូលក្នុងស្រោមសំបុត្ររួចបិទភ្ជិត រួចមូរនិងចងកៅស៊ូកង ពណ៌ដូចគ្នា ។

៤.១៦.៦.២ ស្រោមសំបុត្រឆ្នោតទាំងអស់ ត្រូវដាក់ច្របល់បញ្ចូលគ្នាក្នុងហិបឆ្នោតតែមួយ ហើយត្រូវក្រឡុកហិបឆ្នោតនោះ ។

៤.១៦.៧ បន្ទាប់មកត្រូវយាងសម្តេចព្រះសង្ឆរាជ ដែលត្រូវបានជ្រើសរើសហើយតាមលក្ខខណ្ឌដូចចំណុច ៤.១៦.៤.៣ ចាប់យកស្រោមសំបុត្រឆ្នោតម្តងមួយៗពីក្នុងហិបឆ្នោត ។

៤.១៦.៧.១ ស្រោមសំបុត្រឆ្នោតដែលចាប់បានត្រូវប្រគល់ទៅមន្ត្រីបោះឆ្នោតម្នាក់ក្នុងចំណោមពីរនាក់ ដែលមកពីនាយកដ្ឋានប្រតិបត្តិការ ។

៤.១៦.៧.២ មន្ត្រីរូបនោះ ត្រូវបើកស្រោមសំបុត្របង្ហាញសន្លឹកឆ្នោតរបស់គណ-បក្សនយោបាយ នៅចំពោះមុខអង្គពិធី ហើយជូនសន្លឹកឆ្នោតនោះទៅឱ្យមន្ត្រីទីពីរ ។

៤.១៦.៧.៣ មន្ត្រីទីពីរត្រូវអានឈ្មោះគណបក្សនយោបាយ ដែលសរសេរនៅលើសន្លឹកឆ្នោតឱ្យបានឮ បង្ហាញអ្នកចូលរួម និងសរសេរលេខរៀង " ទី១ " នៅលើសន្លឹកឆ្នោតនោះ ។

៤.១៦.៧.៤ លទ្ធផលនៃការចាប់ឆ្នោត ត្រូវសរសេរនៅលើក្តារខៀន ដើម្បីបង្ហាញបន្ថែមនៅចំពោះមុខអង្គពិធី ។

៤.១៦.៧.៥ ការចាប់ឆ្នោត និងចុះលេខរៀង ត្រូវធ្វើបន្តតាមលំដាប់លំដោយរហូតដល់សន្លឹកឆ្នោតចុងក្រោយបង្អស់ ។

៤.១៦.៨ លេខាធិការនៃពិធីចាប់ឆ្នោត ត្រូវធានាបំពេញកំណត់ហេតុនៃការចាប់ឆ្នោតកំណត់លំដាប់លេខរៀងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតឱ្យបានរួចរាល់ ដោយត្រូវដាក់ភ្ជាប់ជាមួយនូវសន្លឹកឆ្នោត របស់គណបក្សដែលបានចុះលេខរៀងហើយដូចមានចែងក្នុងចំណុច ៤.១៦.៧.៣ ។ តំណាងគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខានៅលើកំណត់ហេតុនេះបាន ។

៤.១៦.៩ គ.ជ.ប ត្រូវធ្វើគំរូ និងបោះពុម្ពសន្លឹកឆ្នោតសម្រាប់មណ្ឌលបោះឆ្នោតនៃរាជធានី ខេត្តនីមួយៗ ។

៤.១៦.៩.១ ការបោះពុម្ពសន្លឹកឆ្នោត ត្រូវផ្អែកតាមបញ្ជីគណបក្សនយោបាយ ឈរឈ្មោះបោះឆ្នោតផ្លូវការ នៅក្នុងមណ្ឌលរាជធានី ខេត្ត នីមួយៗ ។ សន្លឹកឆ្នោតសម្រាប់មណ្ឌលរាជធានី ខេត្តណាប្រើប្រាស់ បានតែនៅក្នុងមណ្ឌលរាជធានី ខេត្តនោះប៉ុណ្ណោះ ។

៤.១៦.៩.២ ឈ្មោះ និងរូបសញ្ញាគណបក្សនយោបាយនៅលើសន្លឹកឆ្នោត ត្រូវបោះពុម្ពតាមរបៀបតែមួយគត់ ហើយលេខសម្គាល់របស់ គណបក្សនយោបាយត្រូវដាក់ជាលេខរៀងតាមលទ្ធផល នៃការ ចាប់ឆ្នោត ។

ប្រការ ៤.១៧.-

បញ្ជីបេក្ខជនផ្លូវការ ឈ្មោះ និងលំដាប់ឈ្មោះបេក្ខជននៅក្នុងបញ្ជីមិនអាចកែប្រែបានឡើយ ។

ប្រការ ៤.១៨.-

គណបក្សនយោបាយ និងបេក្ខជននៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែល បានចុះបញ្ជីជាផ្លូវការត្រូវគោរពតាម ច.ប.ត.រ និង ប.ន.ត.រ ព្រមទាំងក្រមសីលធម៌សម្រាប់គណបក្ស នយោបាយដែលកំណត់ដោយ គ.ជ.ប ។

ជំពូកទី ៥
ការិយាល័យបោះឆ្នោត

ការកំណត់ទីតាំងការិយាល័យបោះឆ្នោត

ប្រការ ៥.១.-

គ.ជ.ប ត្រូវកំណត់ក្នុងជំហានដំបូងនូវចំនួន និងទីតាំងការិយាល័យបោះឆ្នោតចំនួនមួយ ឬច្រើនក្នុងឃុំ សង្កាត់នីមួយៗ នៅក្នុងរយៈពេលយ៉ាងតិចដប់ប្រាំ (១៥) ថ្ងៃ មុនថ្ងៃចាប់ផ្តើមការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨ ។ ចំនួន និងទីតាំងការិយាល័យបោះឆ្នោត អាចនឹងកែសម្រួលជាចុងក្រោយ និងកំណត់ជាផ្លូវការដោយ គ.ជ.ប បន្ទាប់ពីការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៧ បានបញ្ចប់ និងត្រូវធ្វើឱ្យហើយរួចរាល់មុនថ្ងៃផ្តល់សុពលភាពបញ្ជីបោះឆ្នោតផ្លូវការ ។

៥.១.១ ការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ត្រូវផ្អែកលើមូលដ្ឋានស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មានសម្រាប់ការចុះឈ្មោះបោះឆ្នោតនៅតាមភូមិ ក្នុងឃុំ សង្កាត់នីមួយៗ ។ ទន្ទឹមនឹងនេះ គ.ជ.ប ត្រូវកែសម្រួលការិយាល័យបោះឆ្នោត ឬ/និងបង្កើតការិយាល័យបោះឆ្នោតថ្មី បន្ថែមឱ្យសមស្របតាមសភាពជាក់ស្តែង និងការចាំបាច់ ដោយត្រូវប្រើប្រាស់លក្ខណៈវិនិច្ឆ័យលើកត្តាប្រជាសាស្ត្រ ចម្ងាយផ្លូវ ភូមិសាស្ត្រ សង្គម និងរដ្ឋបាល ។

៥.១.២ គ.ជ.ប អាចធ្វើការកែសម្រួលចំនួន និងទីតាំងការិយាល័យបោះឆ្នោត និងតំបន់ស្ថិតក្នុងដែនសមត្ថកិច្ច ដែលការិយាល័យនោះទទួលខុសត្រូវបានតែក្នុងករណីមានការប្រែប្រួលខាងប្រជាសាស្ត្រ សង្គម ឬ/និងមានការប្រែប្រួលខាងភូមិសាស្ត្រ និងរដ្ឋបាល ។

៥.១.៣ ការកំណត់ និងការកែសម្រួលការិយាល័យបោះឆ្នោត ឬ/និងការបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងឃុំ សង្កាត់ ត្រូវគោរពតាមលក្ខខណ្ឌនៃ ច.ប.ត.រ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

៥.១.៤ ការបង្កើតការិយាល័យបោះឆ្នោត ជាដំបូងគឺសម្រាប់បម្រើឱ្យការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ។ ការិយាល័យបោះឆ្នោត ដែលបញ្ជីបោះឆ្នោតនៃការិយាល័យទាំងនោះត្រូវបានផ្តល់សុពលភាពជាផ្លូវការចុងក្រោយដោយ គ.ជ.ប នឹងត្រូវប្រើជាការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ការិយាល័យបោះឆ្នោត នឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត នៅពេលរាប់សន្លឹកឆ្នោត ។

៥.១.៥ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបម្រើឱ្យតំបន់បោះឆ្នោតមួយដែលបានកំណត់ ។ ការិយាល័យបោះឆ្នោត និងតំបន់ស្ថិតក្នុងដែនសមត្ថកិច្ច ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវតែស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន ។

៥.១.៦ គ.ជ.ប ត្រូវធានាថាទីតាំងការិយាល័យបោះឆ្នោតនីមួយៗ មិនត្រូវស្ថិតនៅឆ្ងាយជាងប្រាំ (៥) គីឡូម៉ែត្រ ពីទីកន្លែងរស់នៅរបស់អ្នកបោះឆ្នោតឡើយ ។

៥.១.៧ ទីតាំងការិយាល័យបោះឆ្នោតត្រូវតែជាទីកន្លែង ដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ ។

៥.១.៨ នៅទីណាមានស្ទឹង ទន្លេ ឬភូមិសាស្ត្រដែលនាំឱ្យប្រជាពលរដ្ឋពិបាកធ្វើដំណើរឆ្លងកាត់ ត្រូវតែបង្កើតការិយាល័យបោះឆ្នោតនៅទាំងសងខាងស្ទឹង ទន្លេ ឬ/និងនៅទីតាំងជាក់លាក់ណាមួយ ដែលមានលក្ខណៈប្រសើរជាង ។

៥.១.៩ នៅតំបន់ដាច់ស្រយាល ដែលមានប្រជាពលរដ្ឋមានសិទ្ធិបោះឆ្នោតតិចជាង ១០០ (មួយរយ) នាក់ ក៏ត្រូវតែបង្កើតការិយាល័យបោះឆ្នោតមួយដែរ ។

៥.១.១០ ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវប្រមូលផ្តុំដោយភូមិទាំងមូល និងត្រូវបង្ក លក្ខណៈឱ្យសមាជិកគ្រួសារទាំងអស់ក្នុងភូមិនោះ បានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

៥.១.១១ គ.ជ.ប ត្រូវធានាថា ការិយាល័យបោះឆ្នោតមួយ ត្រូវទទួលចុះឈ្មោះអ្នកបោះឆ្នោតយ៉ាងច្រើនបំផុតត្រឹមចំនួន ៧៥០ (ប្រាំពីររយហាសិប) នាក់ ។ ក្នុងករណីការិយាល័យ

បោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០ (ប្រាំពីរយហាសិប) នាក់ គ.ជ.ប ត្រូវបញ្ជូលឈ្មោះអ្នកដែលលើសនោះ ទៅក្នុងការិយាល័យបោះឆ្នោតណាមួយក្នុងភូមិជាមួយ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មីក្នុងភូមិជាមួយ តាមការចាំបាច់ ។

ប្រការ ៥.២..

ការិយាល័យបោះឆ្នោតជាការិយាល័យនៅមួយកន្លែង ដែលបង្កើតឡើងនៅទីតាំងជាក់លាក់មួយសម្រាប់តំបន់បោះឆ្នោតមួយដែលបានកំណត់ ហើយដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

ប្រការ ៥.៣..

ទីតាំងដែលអ្នកបោះឆ្នោតងាយរកឃើញ និងអាចធ្វើដំណើរទៅមកបាន គឺជាលក្ខណៈវិនិច្ឆ័យសំខាន់ ក្នុងការបង្កើតការិយាល័យបោះឆ្នោត ។

៥.៣.១ ការិយាល័យបោះឆ្នោតត្រូវមានទីតាំងនៅកន្លែងណា ដែលអ្នកបោះឆ្នោតអាចធ្វើដំណើរទៅមកបានដោយគ្មានឧបសគ្គ និងគ្មានការរំខាន ហើយជាការប្រសើរ ត្រូវស្ថិតនៅជាន់ផ្ទាល់ដី ។

៥.៣.២ ក្នុងករណីចាំបាច់ ការិយាល័យបោះឆ្នោតចំនួនពីរ ឬច្រើនអាចតាំងនៅក្នុងបរិវេណសំណង់ ឬអគារតែមួយ ប៉ុន្តែមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតទេ ។ ការិយាល័យបោះឆ្នោតចំនួនពីរ ឬច្រើនដែលតាំងនៅក្នុងបរិវេណសំណង់ ឬអគារតែមួយនោះ ត្រូវតែរៀបចំខណ្ឌដាច់ពីគ្នា និងគ្រប់គ្រងដោយឡែកពីគ្នា ។

៥.៣.៣ ការិយាល័យបោះឆ្នោតមិនត្រូវបានបង្កើតនៅក្នុងបរិវេណទីធ្លា និងអគាររបស់រាជរដ្ឋាភិបាលដូចជា សាលារាជធានី ខេត្ត សាលាក្រុង ស្រុក ខណ្ឌ សាលាឃុំ សង្កាត់ជាដើម ឬនៅបន្ទាយ ឬអគារនៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ ឬ/និងអគាររបស់គណបក្សនយោបាយនៅគ្រប់លំដាប់ថ្នាក់ ។

ការផ្សព្វផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

ប្រការ ៥.៤..

គ.ជ.ប ត្រូវផ្សព្វផ្សាយ និងត្រូវបោះពុម្ពផ្សាយ និងបញ្ជូនបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅតាមដំណាក់កាលនីមួយៗទៅគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ដើម្បីចាត់ចែងបិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតទាំងនោះនៅតាមទីកន្លែង និងតាមកាលបរិច្ឆេទដែល គ.ជ.ប បានកំណត់ ។

៥.៤.១ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈ នូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត តាមគេហទំព័រ គ.ជ.ប : www.voterlist.org.kh និង www.necelect.org.kh ។

៥.៤.២ គធ.ខប ត្រូវបន្តចាត់ឱ្យ គយ.សប បិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ និងនៅទីស្នាក់ការ គយ.សប លើកទីមួយនៅ ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៥.៤.៣ គធ.ខប ត្រូវបន្តចាត់ចែងឱ្យ គយ.សប បិទផ្សាយជាសាធារណៈនូវបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅតាមទីតាំងការិយាល័យបោះឆ្នោតនីមួយៗ និងនៅទីស្នាក់ការ គយ.សប លើកទីពីរនៅ ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៥.៤.៤ ក្នុងករណីមានការកែសម្រួលទីតាំងការិយាល័យបោះឆ្នោត គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណៈ ដោយបញ្ជាក់មូលហេតុឱ្យបានច្បាស់លាស់ ។

ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ប្រការ ៥.៥..

គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត គឺជាទីតាំងរដ្ឋបាល និងសន្តិសុខដែលត្រូវមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ។

៥.៥.១ បរិវេណខាងក្នុងជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយដែលខណ្ឌដោយវណ្ឌមណ្ឌលមួយ មានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ ។ បរិវេណខាងក្នុងត្រូវរៀបចំឱ្យមានច្រកចេញមួយ និងច្រកចូលមួយ ។

៥.៥.២ បរិវេណខាងក្រៅជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដែលខណ្ឌដោយវណ្ឌមណ្ឌលមានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬតូចជាងអាស្រ័យដោយស្ថានភាពទីតាំងជាក់ស្តែង ឬមានទម្រង់ផ្សេងពីនេះ ដូចជា បរិវេណរបងនៃសាលារៀន វត្តអារាម សាលមហោស្រព ឬទីសាធារណៈជាដើម។

៥.៥.៣ នៅតំបន់ទីប្រជុំជន បរិវេណខាងក្រៅត្រូវបានកំណត់ដោយ គយ.សប ដោយយោងលើការវាយតម្លៃអំពីស្ថានភាពសន្តិសុខ និងសណ្តាប់ធ្នាប់ក្នុងតំបន់នោះ ។

៥.៥.៤ នៅតំបន់ទីប្រជុំជន ក្នុងករណីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមួយតាំងនៅប្រមាណ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យពាក់ព័ន្ធមួយផ្សេងទៀត មួយផ្នែកនៃផ្លូវនេះត្រូវតែបិទចរាចរណ៍ ។

វិធានការការពារសន្តិសុខ

ប្រការ ៥.៦.-

ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ឱ្យជៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងដើម្បីរក្សាការពារឧបករណ៍ សម្ភារ ឯកសារបោះឆ្នោតទាំងអស់ក្នុងការិយាល័យទាំងនោះ គ.ជ.ប គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ពិសេស គ.ក.ប/គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានាដូចខាងក្រោម ។

៥.៦.១ ហាមជនគ្រប់រូបយកអាវុធ ជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែក្នុងករណីមានជនណាបង្កការអុកឡុកក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលប្រធាន គ.ជ.ប ឬ/និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ មានការកិច្ចស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៨៧ នៃ ច.ប.ត.រ ។

៥.៦.១.១ ប្រធាន គ.ជ.ប និងប្រធានគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវប្រគល់សិទ្ធិអំណាចដល់ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងការស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីដូចបានបញ្ជាក់ក្នុងចំណុច ៥.៦.១ ខាងលើ។

៥.៦.១.២ ក្នុងករណី មានសំណូមពរពីប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយក្នុងការិយាល័យណាមួយនោះ ភ្នាក់ងារសន្តិសុខមានបំពាក់អាវុធ ដែលត្រូវបានតែងតាំងអាចចូលធ្វើអន្តរាគមន៍ក្នុងការិយាល័យពាក់ព័ន្ធ ។

៥.៦.២ ហាមដាច់ខាតយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងហាមស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែក្នុងករណីអ្នកទាំងនោះត្រូវបានប្រគល់ភារកិច្ចជាភ្នាក់ងារសន្តិសុខ ឬភ្នាក់ងារសង្គ្រោះ និងត្រូវបានប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតស្នើសុំឱ្យធ្វើអន្តរាគមន៍ ដូចចែងក្នុងប្រការ ៥.៦ និងលក្ខខណ្ឌទាំងឡាយក្រោមចំណុច ៥.៦.១ ខាងលើ ។

៥.៦.៣ ហាមជនគ្រប់រូបចូលក្នុងការិយាល័យបោះឆ្នោត នៅមុនពេលចាប់ផ្តើមការបោះឆ្នោត ឬក្រោយពេលបិទការបោះឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម ៖

- ៥.៦.៣.១ មន្ត្រីបោះឆ្នោត ដែលបានទទួលការតែងតាំងពី គ.ជ.ប ។
- ៥.៦.៣.២ ភ្នាក់ងារនៃគណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងដែលត្រូវបានអនុញ្ញាត ។
- ៥.៦.៣.៣ អ្នកសង្កេតការណ៍ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។
- ៥.៦.៣.៤ អ្នកសារព័ត៌មានដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។
- ៥.៦.៣.៥ អ្នកដែលមានសិទ្ធិបោះឆ្នោត ហើយត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។
- ៥.៦.៣.៦ ជនដែលអមដំណើរអ្នកបោះឆ្នោតជាជនដែលមានពិការភាពតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១០៧ នៃ ច.ប.ត.រ ។
- ៥.៦.៣.៧ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានការិយាល័យបោះឆ្នោត ធ្វើសំណូមពរក្នុងករណីចាំបាច់ ។

៥.៦.៤ ហាមជនគ្រប់រូបចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេលចាប់ផ្តើមការរាប់សន្លឹកឆ្នោត ឬក្រោយការរាប់សន្លឹកឆ្នោត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងបរិវេណខាងក្នុង នូវជនទាំងឡាយដូចខាងក្រោម ៖

- ៥.៦.៤.១ មន្ត្រីរាប់សន្លឹកឆ្នោត ដែលបានទទួលការតែងតាំងពី គ.ជ.ប ។
- ៥.៦.៤.២ ភ្នាក់ងារគណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះ និងដែលត្រូវបានអនុញ្ញាត ។
- ៥.៦.៤.៣ អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។
- ៥.៦.៤.៤ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះ នៅពេលដែលប្រធានការិយាល័យរាប់សន្លឹកឆ្នោត ធ្វើសំណូមពរក្នុងករណីចាំបាច់ ។

៥.៦.៥ សកម្មភាពទាំងឡាយដូចខាងក្រោម ត្រូវហាមឃាត់នៅក្នុងការិយាល័យបោះឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

- ៥.៦.៥.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ ។
- ៥.៦.៥.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពលធ្វើឱ្យអ្នកបោះឆ្នោតបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។
- ៥.៦.៥.៣ ការបង្ហាញការគាំទ្រ ឬការប្រឆាំងគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយណាមួយ ។

៥.៦.៦ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់ នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត បរិវេណខាងក្នុង និងបរិវេណខាងក្រៅ ៖

- ៥.៦.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបេក្ខជននៃគណបក្សនយោបាយ ។
- ៥.៦.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វី ដែលមានឥទ្ធិពលធ្វើឱ្យមន្ត្រីរាប់សន្លឹកឆ្នោតរាប់គំនូសនៅលើសន្លឹកឆ្នោត ដើម្បីបំពេញចិត្ត ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនណាមួយ ។

៥.៦.៧ ក្នុងករណីមានការរំខានដល់ដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតមានភារកិច្ច អនុវត្តនូវលក្ខខណ្ឌ ដូចមានចែងក្រោមចំណុច ៥.៥.៣ ៥.៦.៣ និង ៥.៦.៤ ចំពោះបរិវេណខាងក្រៅទាំងមូល ឬមួយផ្នែក ដើម្បីធានាឱ្យការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព ។

៥.៦.៨ ជនគ្រប់រូបដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅបរិវេណខាងក្នុងនៃការិយាល័យទាំងនោះ ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងណែនាំរបស់ គ.ជ.ប ស្របតាមលក្ខខណ្ឌនៃ ច.ប.ត.រ និង ប.ន.ត.រ ។

ប្រការ ៥.៧.-

ចំពោះការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ក្នុងករណីកាល:ទេស:មានអាសន្ន គ.ជ.ប ត្រូវសម្រេចឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅកន្លែងផ្សេងទៀត ។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាបន្ទាន់ និងជាសាធារណ: អំពីសេចក្តីសម្រេចនេះ ។

ប្រការ ៥.៨.-

សាលារៀន ទីវត្តអារាម រាល់សំណង់ អគារ សាល ឬទីសាធារណ: ត្រូវបានផ្តល់ដោយឥតគិតថ្លៃទៅ គ.ជ.ប សម្រាប់គោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

ជំពូកទី ៦

ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត

ប្រការ ៦.១.-

អនុលោមតាមមាត្រា ១៦៧ មាត្រា ១៦៨ និងមាត្រា ១៦៩ នៃ ច.ប.ត.រ គ.ជ.ប ត្រូវរៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៦ ឆ្នាំ២០១៨ ។ ការរៀបចំ ការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ ត្រូវអនុវត្តដោយអនុលោមទៅតាម ច.ប.ត.រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៧ របស់ គ.ជ.ប ។

ប្រការ ៦.២.-

គ.ជ.ប ត្រូវផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រផ្លូវការ ៩០ (កៅសិប)ថ្ងៃយ៉ាងតិច មុនថ្ងៃបោះឆ្នោត ។ បញ្ជីបោះឆ្នោតផ្លូវការ ត្រូវមានទិន្នន័យ ដូចខាងក្រោម ៖

៦.២.១ ឈ្មោះ និងលេខកូដរាជធានី ខេត្ត

៦.២.២ ឈ្មោះ និងលេខកូដឃុំ សង្កាត់

៦.២.៣ ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត

៦.២.៤ កូនប្រអប់សម្រាប់ធិក និងលេខរៀងនៃឈ្មោះក្នុងបញ្ជីបោះឆ្នោត

៦.២.៥ អត្តលេខអ្នកបោះឆ្នោត

៦.២.៦ លេខ អ.ខ ឬ ឯ.អ ប្រើពេលចុះឈ្មោះបោះឆ្នោត

៦.២.៧ រូបថតអ្នកបោះឆ្នោត

៦.២.៨ នាមត្រកូល និងនាមខ្លួនដែលរៀបចំតាមលំដាប់អក្ខរក្រមខ្មែរ

៦.២.៩ ភេទ

៦.២.១០ ថ្ងៃ ខែ ឆ្នាំកំណើត

៦.២.១១ លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់នៃអ្នកបោះឆ្នោត ។

ប្រការ ៦.៣.-

គ.ជ.ប ត្រូវបោះពុម្ពបញ្ជីបោះឆ្នោតផ្លូវការ និងបញ្ជូនសម្រាប់ប្រើប្រាស់ ដូចខាងក្រោម ៖

៦.៣.១ ក្រុមប្រឹក្សាឃុំ សង្កាត់ ចំនួន ១ (មួយ) ច្បាប់ សម្រាប់រក្សាទុកជាឯកសារផ្លូវការ និងប្រើប្រាស់សម្រាប់បញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតជូនប្រជាពលរដ្ឋដើម្បីបំពេញលក្ខខណ្ឌឈរឈ្មោះជាបេក្ខជន សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ទន្ទឹមនេះ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោតត្រូវរៀបចំផលិតស៊ីឌីផ្ទុកបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ ក្នុងរាជធានី ខេត្តពាក់ព័ន្ធ សម្រាប់ផ្តល់ជូន គធ.ខប ។

៦.៣.២ គយ.សប ចំនួន ២ (ពីរ) ច្បាប់ ក្នុងនោះ ១ (មួយ)ច្បាប់ សម្រាប់បិទផ្សាយជាសាធារណៈនៅទីស្នាក់ការ គយ.សប ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងថែរក្សាទុករហូតដល់ថ្ងៃបោះឆ្នោត និង ១ (មួយ) ច្បាប់ទៀត រក្សាទុកនៅ គយ.សប ប្រើប្រាស់សម្រាប់បញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោតជូនប្រជាពលរដ្ឋដែលស្នើសុំ ឯ.អ ។

៦.៣.៣ គ.ក.ប ចំនួន ២ (ពីរ) ច្បាប់ ក្នុងនោះ ១ (មួយ) ច្បាប់ សម្រាប់បិទផ្សាយនៅមុខការិយាល័យបោះឆ្នោតនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និង ១ (មួយ) ច្បាប់ទៀត សម្រាប់ប្រើប្រាស់ក្នុងការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

៦.៣.៤ គ.ជ.ប ត្រូវបង្ហោះបញ្ជីបោះឆ្នោតផ្លូវការនៅលើគេហទំព័ររបស់ខ្លួន(www.voterlist.org.kh) ដោយត្រូវធានា ការសម្ងាត់ សន្តិសុខ និងសុវត្ថិភាពរបស់បុគ្គល និងបង្ហាញតែឈ្មោះ និងលេខកូដរាជធានី ខេត្ត ឃុំ សង្កាត់ ឈ្មោះទីតាំង និងលេខកូដការិយាល័យ

បោះឆ្នោត អត្តលេខ នាមត្រកូល និងនាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោតប៉ុណ្ណោះ ។ ទិន្នន័យបញ្ជីបោះឆ្នោតផ្លូវការ ត្រូវបានរក្សាទុកដោយសុវត្ថិភាព (Backup Database) និងអាចត្រួតពិនិត្យបាន ។

ប្រការ ៦.៤.-

ដើម្បីជួយដល់អ្នកបោះឆ្នោត ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានយល់ដឹងច្បាស់អំពីលេខរៀង ឈ្មោះ ទិន្នន័យពាក់ព័ន្ធនឹងសាមីខ្លួនក្នុងបញ្ជីបោះឆ្នោត ឈ្មោះទីតាំង និងលេខកូដការិយាល័យបោះឆ្នោត កាលបរិច្ឆេទ និងពេលវេលានៃការបោះឆ្នោត ព្រមទាំងប្រភេទឯកសារដែលត្រូវប្រើប្រាស់សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប ត្រូវអនុវត្តការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។ ដំណើរការផលិត និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ គ.ជ.ប ។

ការបោះឆ្នោត និងឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការសម្រាប់ប្រើនៅពេលបោះឆ្នោត

ប្រការ ៦.៥.-

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវ ៖

៦.៥.១ មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការដែលបានផ្តល់សុពលភាពដោយ គ.ជ.ប សម្រាប់បម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៨ ។

៦.៥.២ មានឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការណាមួយនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ប្រើនៅពេលបោះឆ្នោត ។ ឯកសារបញ្ជាក់អត្តសញ្ញាណផ្លូវការរួមមាន ៖

- ៦.៥.២.១ អ.ខ ។
- ៦.៥.២.២ ឯ.អ ។

ប្រការ ៦.៦.-

នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ទោះបីមានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ដូចចែងក្រោមចំណុច ៦.៥.២ ខាងលើ ក៏មិនត្រូវអនុញ្ញាតឱ្យបោះឆ្នោតដែរ។

ប្រការ ៦.៧.-

នៅថ្ងៃបោះឆ្នោត អ្នកបោះឆ្នោតណាដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត ប៉ុន្តែគ្មានឯកសារបញ្ជាក់អត្តសញ្ញាណណាមួយ ដូចចែងក្រោមចំណុច ៦.៥.២ ខាងលើ ក៏មិនត្រូវអនុញ្ញាតឱ្យបោះឆ្នោតដែរ។

នីតិវិធីនៃការស្នើសុំ និងការចេញ ឯ.អ

ប្រការ ៦.៨.

យោងតាមមាត្រា ១៦៩ នៃ ច.ប.ត.រ ករណីប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហើយពុំមាន អ.ខ ដើម្បីបោះឆ្នោត ប្រជាពលរដ្ឋនេះអាចប្រើប្រាស់ ឯ.អ ដើម្បីបោះឆ្នោត ។ អាជ្ញាធរឃុំ សង្កាត់ និង គយ.សប ត្រូវបានអនុញ្ញាតឱ្យចេញ ឯ.អ តាមការស្នើសុំជូនប្រជាពលរដ្ឋ ។ នីតិវិធីនៃការស្នើសុំ និងការចេញ ឯ.អ ត្រូវបានកំណត់ដូចខាងក្រោម ។

៦.៨.១ ប្រជាពលរដ្ឋដែលស្នើសុំ ឯ.អ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- ត្រូវស្នើសុំ ឯ.អ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងបញ្ចប់ ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ដោយត្រូវបង្ហាញខ្លួនដោយផ្ទាល់នៅចំពោះមុខ គយ.សប និងអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនកំពុងស្នាក់នៅ និងត្រូវបោះឆ្នោត ។
- ត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ។
- នាំមកនូវសាក្សី ២ (ពីរ) រូប មកបង្ហាញខ្លួននៅចំពោះមុខ គយ.សប ។
- យកមកនូវរូបថតរបស់សាមីខ្លួន ទំហំ ៣x៤ ចំនួន ៣ (បី) សន្លឹក ថតចំពីមុខ ដែលបង្ហាញមុខ និងស្មា និងដែលអាចបញ្ជាក់អត្តសញ្ញាណរបស់សាមីអ្នកស្នើសុំបានត្រឹមត្រូវ និងច្បាស់លាស់ ។ រូបថតនេះ សម្រាប់បិទនៅផ្នែកខាងលើចំហៀងខាងស្តាំនៃគល់បញ្ជី និងចុងសន្លឹកទាំងពីរនៃ ឯ.អ ។
- បំពេញលិខិតស្នើសុំ ឯ.អ ហើយត្រូវផ្ទិតមេដៃនៅចំពោះមុខ គយ.សប ។
- ត្រូវបន្តយកលិខិតស្នើសុំ និងចុងទម្រង់ ឯ.អ ២ (ពីរ) សន្លឹក ពី គយ.សប ទៅជូនមេឃុំ ចៅសង្កាត់ ពិនិត្យចេញ ឯ.អ ជូន ។

៦.៨.២ សាក្សីត្រូវមានលក្ខណៈសម្បត្តិ និងបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- មានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ជាមួយ ។
- ផ្ទិតមេដៃធានាអះអាងលើលិខិតស្នើសុំ ឯ.អ នៅចំពោះមុខ គយ.សប ។
- មិនមែនជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង ឬស្មៀនឃុំ សង្កាត់ ។

៦.៨.៣ ប្រធាន គយ.សប និង មេឃុំ ចៅសង្កាត់ មានសមត្ថកិច្ចក្នុងការចេញ ឯ.អ ជូនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយក្នុងឃុំ សង្កាត់ របស់ខ្លួនតាមការស្នើសុំ ដោយមិនតម្រូវឱ្យបង់ថ្លៃឡើយ ។

ប្រធាន គយ.សប ត្រូវអនុវត្តការបំពេញ ឯ.អ ដូចខាងក្រោម ៖

- បំពេញការបញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៅផ្នែកគល់បញ្ជីនៃទម្រង់ ដោយយោងតាមលិខិតស្នើសុំរបស់សាមីខ្លួន និងផ្នែកលើបញ្ជីបោះឆ្នោតផ្លូវការ និងឱ្យសាមីខ្លួន និងសាក្សីទាំងពីរផ្ដិតមេដៃលើផ្នែកគល់បញ្ជីនៃទម្រង់ ។
- បំពេញទម្រង់ ឯ.អ នៅលើចុងសន្លឹកទាំងពីរនៃទម្រង់ ។
- ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គយ.សប នៅលើហត្ថលេខាសង្ខេបរបស់ខ្លួន បោះត្រានៅលើផ្នែកកណ្ដាលខាងក្រោមនៃរូបថតរបស់អ្នកស្នើសុំ នៅលើគល់បញ្ជី និងបោះត្រាបន្ថែមនៅចំពាក់កណ្ដាលរវាងគល់បញ្ជី និងចុងសន្លឹកទាំងពីរនៃទម្រង់ ។
- ចុះហត្ថលេខាសង្ខេបនៅផ្នែកខាងលើ ចំហៀងខាងស្ដាំរូបថត ដែលបិទនៅចុងសន្លឹកទាំងពីរនៃទម្រង់ ។
- ហែកផ្ដាច់ចុងសន្លឹកទាំងពីរពីគល់បញ្ជីនៃទម្រង់ រួចប្រគល់ចុងសន្លឹកទាំងពីរនោះជូនអ្នកស្នើសុំ និងរក្សាទុកគល់បញ្ជីក្នុងសៀវភៅបញ្ជីនៃទម្រង់ជាឯកសាររបស់ គយ.សប ។
- ជម្រាបអ្នកស្នើសុំឱ្យយកចុងសន្លឹកទាំងពីរនៃ ឯ.អ នេះ និងលិខិតស្នើសុំ ឯ.អ ទៅជូនមេឃុំ ឬចៅសង្កាត់ ដើម្បីចុះហត្ថលេខាផ្ដល់សុពលភាពសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត ។

ក្នុងករណីអ្នកស្នើសុំ ឯ.អ ពុំបានបំពេញលក្ខខណ្ឌ ឬប្រសិនបើអ្នកស្នើសុំ និងសាក្សីពុំបានផ្ដល់ព័ត៌មាន និងការធានាអះអាងគ្រប់គ្រាន់ និងត្រឹមត្រូវ ដូចមានចែងក្នុងចំណុច ៦.៨.១ និង ៦.៨.២ ខាងលើ ប្រធាន គយ.សប ត្រូវណែនាំអ្នកស្នើសុំឱ្យបំពេញលក្ខខណ្ឌ និងព័ត៌មានឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ ដើម្បីធ្វើការស្នើសុំជាថ្មី ។

ក្នុងករណីបំពេញ ឯ.អ ខុស និងមិនអាចចេញឱ្យប្រើប្រាស់បាន ប្រធាន គយ.សប ត្រូវគូសខ្វែងលើគល់បញ្ជី និងចុងសន្លឹកនៃទម្រង់ និងរក្សាទុកទាំងគល់បញ្ជី និងចុងសន្លឹក ដែលខុសនោះនៅក្នុងសៀវភៅ ។

៦.៨.៤ មេឃុំ ឬចៅសង្កាត់ ត្រូវចាត់ចែងផ្ទៀងផ្ទាត់ភ្លាម បន្ទាប់ពីទទួលបានចុងសន្លឹកទាំងពីរនៃ ឯ.អ និងលិខិតស្នើសុំ ឯ.អ ដូចចែងក្នុងចំណុច ៦.៨.៣ ខាងលើ ដោយត្រូវអនុវត្តការកិច្ច ដូចខាងក្រោម ៖

- ផ្ទៀងផ្ទាត់ភាពត្រឹមត្រូវក្នុងបញ្ជីបោះឆ្នោតរវាងឈ្មោះ និងទិន្នន័យក្នុងសេចក្តីបញ្ជាក់អំពីការមានឈ្មោះដោយ គយ.សប ជាមួយនឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ។
- ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រាឃុំ សង្កាត់ លើហត្ថលេខារបស់ខ្លួន ។
- បោះត្រាលើរូបថត ។
- ប្រគល់ចុងសន្លឹកនៃ ឯ.អ ១ (មួយ) ច្បាប់ ជូនអ្នកស្នើសុំ និងរក្សាទុកចុងសន្លឹក ១ (មួយ) ច្បាប់ ជាឯកសាររបស់ឃុំ សង្កាត់ ។
- ក្នុងករណីទិន្នន័យខាងលើខុសគ្នា មេឃុំ ឬចៅសង្កាត់ ត្រូវឱ្យសាមីខ្លួនទៅជួប គយ.សប វិញ ដោយបញ្ជាក់ពីភាពខុសគ្នា ។

៦.៨.៥ ប្រជាពលរដ្ឋដែលបានចុះឈ្មោះបោះឆ្នោត ដោយប្រើប្រាស់ ឯ.អ បម្រើឱ្យការចុះឈ្មោះបោះឆ្នោត និងមានឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតផ្លូវការដែល គ.ជ.ប បានផ្តល់សុពលភាពចុងក្រោយ ហើយមិនទាន់មាន អ.ខ អាចយក ឯ.អ បម្រើឱ្យការចុះឈ្មោះបោះឆ្នោត ទៅជួប គយ.សប ដោយផ្ទាល់ខ្លួន និងត្រូវស្នើសុំឱ្យ គយ.សប បញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទផ្តល់សុពលភាពលើឯកសារនេះ ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោត ។ គយ.សប ត្រូវធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យក្នុងបញ្ជីបោះឆ្នោត និងភ្ជាប់ភាគ សាមីអ្នកស្នើសុំឱ្យបានច្បាស់លាស់មុននឹងសម្រេចចារបញ្ជាក់អំពីការមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទផ្តល់សុពលភាពឱ្យប្រើប្រាស់ជាផ្លូវការ ។

៦.៨.៦ គយ.សប ត្រូវធ្វើរបាយការណ៍ឫកសរុបស្តីពីការចេញ ឯ.អ (គិតទាំងការបញ្ជាក់អំពីសុពលភាពលើ ឯ.អ បម្រើឱ្យការចុះឈ្មោះបោះឆ្នោតផងដែរ) តាមការិយាល័យបោះឆ្នោតពាក់ព័ន្ធដោយឡែកពីគ្នាក្នុងឃុំ សង្កាត់របស់ខ្លួនចំនួន ២ (ពីរ) ច្បាប់ ឱ្យរួចរាល់នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត ។ គ.ជ.ប (នាយកដ្ឋានប្រតិបត្តិការ) ត្រូវរៀបចំផលិតទម្រង់របាយការណ៍ឫកសរុបនេះ សម្រាប់ផ្តល់ជូន គយ.សប បំពេញប្រចាំថ្ងៃក្នុងអំឡុងពេលនៃការចេញ ឯ.អ ។ របាយការណ៍នេះ ត្រូវចុះហត្ថលេខា កាលបរិច្ឆេទ បោះត្រា គយ.សប និងត្រូវប្រើប្រាស់ដូចខាងក្រោម ៖

៦.៨.៦.១ ផ្តល់ជូន គ.ក.ប ៣ក់ព័ន្ធ ១ (មួយ) ច្បាប់ សម្រាប់បិទផ្សាយនៅមុខការិយាល័យបោះឆ្នោតនៅថ្ងៃបោះឆ្នោត ។

៦.៨.៦.២ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ ដោយភ្ជាប់មកជាមួយនូវសៀវភៅគល់បញ្ជី និងសៀវភៅបញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណដែលនៅសល់ ស្របពេលជាមួយគ្នានឹងការបញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោត ។ បន្ទាប់ពីទទួលបានរបាយការណ៍ពី គយ.សប គធ.ខប ត្រូវធ្វើការបូកសរុបរបាយការណ៍នៅក្នុងរាជធានី ខេត្ត របស់ខ្លួន ដើម្បីផ្ញើជូន គ.ជ.ប ដោយភ្ជាប់មកជាមួយនូវសៀវភៅគល់បញ្ជី និងសៀវភៅ បញ្ជីឯកសារបញ្ជាក់អត្តសញ្ញាណដែលនៅសល់ ស្របពេលជាមួយគ្នានឹងការបញ្ជូនសម្ភារ បរិក្ខារ និងឯកសារបោះឆ្នោតមក គ.ជ.ប ។

ប្រការ ៦.៩.-

អនុលោមតាមមាត្រា ៤៧ នៃ ច.ប.ត.រ បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជន នៃគណបក្សនយោបាយ ដែលបានអនុម័តយល់ព្រមឱ្យចុះបញ្ជីឈរឈ្មោះបោះឆ្នោត ដោយ គ.ជ.ប ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ដែលបានចុះឈ្មោះបោះឆ្នោតនៅមណ្ឌលបោះឆ្នោតផ្សេង ពីមណ្ឌលដែលបេក្ខជនឈរឈ្មោះ អាចធ្វើសេចក្តីស្នើសុំមក គ.ជ.ប ឱ្យផ្ទេរឈ្មោះខ្លួន ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន (ក្នុងករណីមានការយល់ព្រមពីសហព័ទ្ធ និងកូន) ទៅការិយាល័យបោះឆ្នោតណាមួយ ក្នុងមណ្ឌលបោះឆ្នោត ដែលបេក្ខជននោះឈរឈ្មោះ ។ ប្រសិនបើមានសំណើបែបនេះ គ.ជ.ប ត្រូវយល់ព្រមដោយចេញសេចក្តីសម្រេចស្តីពីការផ្ទេរឈ្មោះបេក្ខជន សហព័ទ្ធ និងកូន ចេញពីបញ្ជីបោះឆ្នោតនៃការិយាល័យដើម និងបញ្ចូលឈ្មោះអ្នកទាំងនោះទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យណាមួយ ដែលស្ថិតក្នុងមណ្ឌលឈរឈ្មោះរបស់បេក្ខជននោះ ។

៦.៩.១ បេក្ខជនឈរឈ្មោះបោះឆ្នោត ដូចចែងក្នុងប្រការ ៦.៩ ត្រូវដាក់លិខិតស្នើសុំមក គ.ជ.ប ចាប់ពីក្រោយថ្ងៃប្រកាសផ្សាយជាផ្លូវការ នូវបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត រហូតដល់រយៈពេល ៣០ (សាមសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

៦.៩.២ ការស្នើសុំនេះត្រូវតែមានការយល់ព្រមពីសហព័ទ្ធ និងកូនរបស់បេក្ខជន ។

៦.៩.៣ ពាក្យស្នើសុំនេះ ត្រូវតែមានភ្ជាប់ជាមួយនូវ ៖

៦.៩.៣.១ បញ្ជីរាយនាមបេក្ខជន សហព័ទ្ធ និងកូន ដែលត្រូវសុំផ្ទេរឈ្មោះចូលក្នុងការិយាល័យណាមួយ ក្នុងមណ្ឌលឈរឈ្មោះរបស់បេក្ខជន ដោយត្រូវបញ្ជាក់ឱ្យអំពីលេខកូដ និងឈ្មោះទីតាំងនៃការិយាល័យបោះឆ្នោតដើម ។

៦.៩.៣.២ លិខិតរបស់សហព័ទ្ធ និងកូន យល់ព្រមទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោត ដែលបេក្ខជនត្រូវឈរឈ្មោះ ។

៦.៩.៤ ក្នុងករណីមានសំណើសុំផ្ទេរឈ្មោះបេក្ខជន សហព័ទ្ធ និងកូន ទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយនៃមណ្ឌលឈរឈ្មោះរបស់បេក្ខជន គ.ជ.ប ត្រូវចេញសេចក្ដីសម្រេចយល់ព្រម ដូចចែងក្នុងប្រការ ៦.៩ និងត្រូវធានាថា ៖

៦.៩.៤.១ ការបញ្ចូលឈ្មោះបេក្ខជន សហព័ទ្ធ និងកូន ដែលបានសុំផ្ទេរ ទៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យថ្មី មិនត្រូវឱ្យចំនួនអ្នកបោះឆ្នោតសរុបក្នុងការិយាល័យនោះមានចំនួនលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់ឡើយ ។

៦.៩.៤.២ សេចក្ដីសម្រេចនេះមានបញ្ជាក់ច្បាស់លាស់អំពីលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដែលត្រូវផ្ទេរឈ្មោះពួកគាត់ចេញ និងលេខកូដ និងឈ្មោះទីតាំងការិយាល័យបោះឆ្នោត ដែលត្រូវបញ្ចូលឈ្មោះពួកគាត់ ។

៦.៩.៤.៣ សេចក្ដីសម្រេចនេះត្រូវបានចេញ និងផ្ដល់ជូនសាមីបេក្ខជន សហព័ទ្ធ និងកូន តាមរយៈសាមីគណបក្សនយោបាយយ៉ាងតិច ១០ (ដប់) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

៦.៩.៤.៤ សេចក្ដីសម្រេចនេះនឹងត្រូវបានរៀបចំឱ្យរួចរាល់ ទន្ទឹមគ្នានឹងការបញ្ជូនបញ្ជីបោះឆ្នោតផ្លូវការ ទៅគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ពាក់ព័ន្ធ ដើម្បីចាត់ចែងប្រើប្រាស់ និងអនុវត្តក្នុងពេលបោះឆ្នោត ។

៦.៩.៥ នៅពេលទទួលបានសេចក្ដីសម្រេចរបស់ គ.ជ.ប ដូចចែងក្នុងចំណុច ៦.៩.៤.៤ ខាងលើ គធ.ខប និង គយ.សប ត្រូវចាត់ចែងបញ្ជូនសេចក្ដីសម្រេចនេះជាបន្ទាន់ទៅ គ.ក.ប ពាក់ព័ន្ធ ដើម្បីអនុវត្តសេចក្ដីសម្រេចនេះ នៅថ្ងៃបោះឆ្នោត ។

៦.៩.៦ គ.ជ.ប ត្រូវផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការផ្ទេរឈ្មោះបេក្ខជន សហព័ទ្ធ និងកូន ក្នុងបញ្ជីបោះឆ្នោត តាមគេហទំព័ររបស់ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ប្រការ ៦.១០..

បន្ទាប់ពីថ្ងៃបោះឆ្នោត ឈ្មោះរបស់បេក្ខជន សហព័ទ្ធ និងកូនដែលបានផ្ទេរទៅការិយាល័យថ្មី ត្រូវរក្សាទុកនៅក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតដើមវិញ ។

ជំពូកទី ៧

ការយោសនាបោះឆ្នោត

គោលការណ៍នៃការយោសនាបោះឆ្នោត

ប្រការ ៧.១.-

អនុលោមតាម ច.ប.ត.រ ការយោសនាបោះឆ្នោតមានទិសដៅឱ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។

ការយោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោត ឱ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ មានដូចជា ៖

៧.១.១ ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ។

៧.១.២ ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងច្រើន ៤ (បួន)ដង ក្នុងអំឡុងពេលយោសនាបោះឆ្នោត ។

៧.១.៣ ការជួបជុំ ឬការយោសនាតាមផ្ទះ ។

៧.១.៤ ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។

៧.១.៥ ការផ្សព្វផ្សាយតាមរលកអាកាស ឬការយោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែតវីដេអូ ឬវីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ ។

៧.១.៦ សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពយោសនាផ្សេងៗ ។

៧.១.៧ សកម្មភាពចែកចាយខិត្តប័ណ្ណគណបក្សនយោបាយ ។

៧.១.៨ សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀតដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជន ជូនអ្នកបោះឆ្នោត ។

៧.១.៩ សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទក្រដាសផ្សាយពីកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬបេក្ខជន ។

៧.១.១០ ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងយោសនា ឬការលេងល្បែងយោសនាបោះឆ្នោត ។

៧.១.១១ ការរៀបចំកម្មវិធីប្រកួតកីឬ ។

ប្រការ ៧.២.-

ការយោសនាត្រូវបើក ២២ (ម្ភៃពីរ) ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ការយោសនាបោះឆ្នោត មានរយៈពេល ២១ (ម្ភៃមួយ)ថ្ងៃ ហើយគ្រប់សកម្មភាពយោសនាត្រូវចប់ ២៤ (ម្ភៃបួន)ម៉ោង មុនថ្ងៃបោះឆ្នោត ។

៧.២.១ គ្រប់សកម្មភាពយោសនាបោះឆ្នោតរបស់គណបក្សនយោបាយត្រូវចាប់ផ្តើម ពីម៉ោង ៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០ (ដប់) យប់ ។

៧.២.២ គ្រប់សកម្មភាពយោសនារបស់គណបក្សនយោបាយត្រូវឈប់សម្រាក នៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ០៦ (ប្រាំមួយ) ព្រឹក ។

៧.២.៣ សកម្មភាពយោសនាដោយឧបករណ៍បំពងសំឡេង ត្រូវបានកំណត់ ដូចខាងក្រោម ៖
- ត្រូវហាមឃាត់ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២ (ពីរ) រសៀល
- ត្រូវហាមឃាត់នៅក្បែរមន្ទីរពេទ្យ
- ត្រូវហាមឃាត់នៅក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា ។

៧.២.៤ ការយោសនាបោះឆ្នោតត្រូវបញ្ឈប់ក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោត ។

៧.២.៥ រាល់ការស្វង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្វង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត ត្រូវបញ្ឈប់ ៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ការស្វង់មតិពាក់ព័ន្ធនឹងកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរ ដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីដំណើរការបោះឆ្នោត ។ រាល់ការរៀបចំការស្វង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

- ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង
- រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ
- ការគោរពសិទ្ធិ សេរីភាពបុគ្គល
- រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត
- ការមិនបង្កឱ្យមានអសន្តិសុខ ភាពចលាចល ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬការធ្វើឱ្យកាន់ច្រឡំក្នុងដំណើរការបោះឆ្នោត
- លទ្ធផលដែលបានមកពីការស្វង់មតិ ត្រូវផ្តល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព ។

ប្រការ ៧.៣.

គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រឹមត្រូវតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាចលើកស្លាកសញ្ញាគណបក្ស ឬបិទផ្សាយឯកសារយោសនាបោះឆ្នោតបម្រើឱ្យគោលដៅយោសនាបោះឆ្នោតនៅទីសាធារណៈ ឬលំនៅឋានឯកជនក្នុងអំឡុងពេលយោសនាបោះឆ្នោត ។

៧.៣.១ ស្លាកសញ្ញា និងសម្ភារយោសនាផ្សេងៗរបស់គណបក្សនយោបាយ អាចលើក ឬបិទនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរ ឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ ។

៧.៣.២ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារយោសនារបស់គណបក្សនយោបាយ មិនត្រូវអនុញ្ញាតឱ្យលើក ឬបិទនៅបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ ។

៧.៣.៣ ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាយោសនា រូបសញ្ញាយោសនា ពាក្យស្លោក ខិត្តប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនបើមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន ។ ប្រជា

ពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទ ស្លាកសញ្ញា បដាយោសនា រូបសញ្ញាយោសនា ពាក្យស្លោក ខិតប័ណ្ណរបស់គណបក្ស ណាមួយបាន ។

៧.៣.៤ ស្លាកសញ្ញា ឬសម្ភារយោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុត នៅថ្ងៃបញ្ចប់ការយោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការ អចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

៧.៣.៥ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារយោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈ ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។

ប្រការ ៧.៤.

ការដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ឬការផ្តល់ជូននូវយានជំនិះមិនរួមបញ្ចូលនៅក្នុងសកម្មភាពយោសនាបោះឆ្នោតទេ ប្រសិនបើការប្រើប្រាស់យានជំនិះទាំងនោះមានលក្ខណៈឯកជន មិនមានទ្រង់ទ្រាយធំ និងមិនមានភ្ជាប់នូវការផ្សព្វផ្សាយដែលពាក់ព័ន្ធនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៧.៤.១ ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពយោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងហាមការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

៧.៤.២ មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋត្រូវបានកំណត់ដូចជា ៖ រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬ/និងរដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល ។

៧.៤.៣ ការដឹកជញ្ជូនមានលក្ខណៈប្រមូលផ្តុំ ឬរៀបចំទុកជាមុនត្រូវហាមឃាត់ លើកលែងតែករណីចាំបាច់មានការសម្រេចផ្សេងពីនេះដោយ គ.ជ.ប ។

ប្រការ ៧.៥.

ការស្លៀកពាក់ (សម្លៀកបំពាក់-មួក) ដែលតាំងបង្ហាញឱ្យឃើញនូវរូបសញ្ញា សារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរួមបញ្ចូលនៅក្នុងសកម្មភាពឃោសនាបោះឆ្នោតទេ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ។

ប្រការ ៧.៦.

គណបក្សនយោបាយអាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងច្រើន ៤ (បួន) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត។

៧.៦.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ដូចខាងក្រោម ៖

៧.៦.១.១ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទត្រូវបានអនុញ្ញាតឱ្យធ្វើក្នុងក្របខណ្ឌមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ។

៧.៦.១.២ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ មិនត្រូវបានអនុញ្ញាតឱ្យធ្វើឆ្លងរាជធានី ខេត្ត ។

៧.៦.១.៣ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទក្នុងក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត ឬការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទពីក្រុង ស្រុក ខណ្ឌមួយទៅក្រុង ស្រុក ខណ្ឌមួយផ្សេងទៀតក្នុងរាជធានី ខេត្តដដែល ត្រូវបានចាត់ទុកថាជាការហែក្បួនក្នុងក្របខណ្ឌមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ។

៧.៦.១.៤ ការហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ ត្រូវបានកំណត់ទម្រង់ និងទំហំ ដូចខាងក្រោម ៖

- មានការរៀបចំជាក្បួន មានបិទបដា ឬ/និងពាក្យស្លោក ឬ/និងសារនយោបាយផ្សេងៗ ភ្ជាប់នឹងរថយន្ត ឬ/និងទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង ។

- មានអ្នកចូលរួមចាប់ពី ២០ នាក់ឡើងទៅ ដោយប្រើប្រាស់យានជំនិះតាមប្រភេទណាមួយ ឬទាំងអស់ ក្នុងការយោសនាបោះឆ្នោត មានដូចខាងក្រោម ៖
  - ➢ រថយន្តចាប់ពី ២ គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ១០ គ្រឿងឡើងទៅ ។
  - ➢ ទោចក្រយានយន្ត ឬ/និងត្រីចក្រយានយន្តចាប់ពី ២០ គ្រឿង ។
  - ➢ ជលយានគ្រប់ប្រភេទចាប់ពី ៥ គ្រឿងឡើងទៅ ។

៧.៦.២ គណបក្សនយោបាយ ដែលមានបំណងហែក្បួនយោសនាបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គធ.ខប យ៉ាងហោចណាស់ឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃហែក្បួនយោសនា ។ ការជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់អំពី ៖

៧.៦.២.១ នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ ។

៧.៦.២.២ កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន ។

៧.៦.២.៣ ទីតាំងប្រមូលផ្តុំ និងគម្រោយផ្លូវ ដែលត្រូវហែក្បួន ។

៧.៦.២.៤ ចំនួនអ្នកចូលរួម ។

៧.៦.២.៥ ចំនួនយានជំនិះតាមប្រភេទនីមួយៗ ។

៧.៦.៣ គធ.ខប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីសម្របសម្រួលទីកន្លែង ផ្លូវ ពេលវេលា និងកម្មវិធីនៃការហែក្បួនយោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ។

៧.៦.៤ ក្បួនយោសនាបោះឆ្នោតរបស់គណបក្សនយោបាយនីមួយៗ ត្រូវរក្សាសុវត្ថិភាពអ្នកចូលរួម និងសណ្តាប់ធ្នាប់ល្អតាមដងផ្លូវ ទីប្រជុំជន ទីសាធារណៈ និងត្រូវយកចិត្តទុកដាក់គោរពតាមច្បាប់ចរាចរណ៍ ។

ប្រការ ៧.៧.-

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវធ្វើសកម្មភាពដូចខាងក្រោម ។

៧.៧.១ មិនត្រូវប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជា ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ ។

៧.៧.២ មិនត្រូវប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីយោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ ។

៧.៧.៣ មិនត្រូវចូលរួមសកម្មក្នុងការយោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ ។ ការចូលរួមសកម្មក្នុងការយោសនាបោះឆ្នោតដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ដូចតទៅ ៖

- ៧.៧.៣.១ ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការយោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។
- ៧.៧.៣.២ ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់។
- ៧.៧.៣.៣ ការចូលរួមក្នុងការស្វង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ៧.៧.៣.៤ ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ៧.៧.៣.៥ ការធ្វើសកម្មភាពចែកចាយសម្ភារយោសនាបោះឆ្នោតដល់អ្នកបោះឆ្នោតក្នុងគោលបំណងគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។
- ៧.៧.៣.៦ ការធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។
- ៧.៧.៣.៧ ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

ប្រការ ៧.៨.

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពយោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ ។

ប្រការ ៧.៩.

ក្នុងដំណើរការបោះឆ្នោត មេភូមិ និងជំនួយការមេភូមិ ត្រូវអនុវត្តតួនាទី និងកាតព្វកិច្ចរបស់ខ្លួនស្របតាមគោលការណ៍ណែនាំ ដូចមានចែងក្នុងសៀវភៅណែនាំរបស់ គ.ជ.ប ស្តីពីភារកិច្ច និងកាតព្វកិច្ចរបស់មេភូមិ និងជំនួយការមេភូមិ ក្នុងដំណើរការរៀបចំការបោះឆ្នោត ។ មេភូមិ និងជំនួយការមេភូមិ មានសិទ្ធិបញ្ចេញមតិយោបល់ផ្ទាល់ខ្លួន និងមានសិទ្ធិចូលរួមក្នុងជីវភាពនយោបាយដើម្បីគាំទ្រគណបក្សនយោបាយដែលខ្លួនជ្រើសរើស ប៉ុន្តែសកម្មភាពទាំងនោះ ត្រូវធ្វើក្នុងឋានៈជាបុគ្គលឯកជន គឺមិនមែនក្នុងតួនាទីជាមេភូមិ ឬជំនួយការមេភូមិឡើយ ។ មេភូមិ និងជំនួយការមេភូមិ ត្រូវព្យាយាមធ្វើឱ្យបាននូវសកម្មភាពដូចខាងក្រោម ៖

៧.៩.១ ផ្តល់សេវា និងព័ត៌មានដូចគ្នាៗជូនដល់អ្នកភូមិទាំងអស់ ដោយមិនប្រកាន់និន្នាការនយោបាយ ដើម្បីបង្កើតបរិយាកាសជឿទុកចិត្តគ្នា ។

៧.៩.២ ធានាថាការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងព័ត៌មានផ្សេងៗដទៃទៀត ត្រូវបានអនុវត្តដោយយុត្តិធម៌ ដោយស្មើភាព និងអស់ពីកម្លាំងចិត្ត ដល់អ្នកភូមិគ្រប់ៗរូប និងដោយឥតគិតថ្លៃ ។

៧.៩.៣ ត្រូវប្រកាន់ខ្ជាប់ឥរិយាបថ អព្យាក្រឹត ឥតលម្អៀងនៅក្នុងការបំពេញការងារទាក់ទងនឹងដំណើរការរៀបចំការបោះឆ្នោត ។

៧.៩.៤ ត្រូវរាប់អាន ទទួលស្គាល់ និងអនុវត្តការងារចំពោះអ្នកភូមិគ្រប់ៗរូប ឱ្យបានស្មើគ្នា។

៧.៩.៥ ផ្តល់កិច្ចសហការជាមួយ គយ.សប គធ.ខប និង គ.ជ.ប ទាក់ទងនឹងការអនុវត្តការងារបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ដូចជាការផ្តល់ព័ត៌មានអំពីការបោះឆ្នោត ការចែកខិត្តប័ណ្ណ សៀវភៅព័ត៌មាន ឬបណ្ណប្រកាសផ្សេងៗ ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

ប្រការ ៧.១០.

មេភូមិ និងជំនួយការមេភូមិ ដាច់ខាតមិនត្រូវគំរាមកំហែង ឬបង្ហាញឥរិយាបថលម្អៀងក្នុងការអនុវត្តការងាររបស់ខ្លួនចំពោះអ្នកភូមិទាក់ទងនឹងការបោះឆ្នោត ។ មេភូមិ និងជំនួយការមេភូមិ មិនត្រូវអនុវត្តដូចខាងក្រោម ៖

៧.១០.១ បង្ហាញការគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយជាសាធារណៈ ។

៧.១០.២ ប្រើប្រាស់ឥទ្ធិពល ឬតួនាទីរបស់ខ្លួនរំលោភលើសិទ្ធិសម្រេចរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការបោះឆ្នោត ។ ការរំលោភលើសិទ្ធិរួមមាន ៖

- ៧.១០.២.១ បំភិតបំភ័យ ឬគំរាមកំហែងអ្នកបោះឆ្នោតក្នុងគោលបំណងឱ្យអ្នកបោះឆ្នោត គាំទ្រគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់។
- ៧.១០.២.២ សួរនាំអ្នកបោះឆ្នោត ឬចង់ដឹងអំពីការបោះឆ្នោតជាសម្ងាត់របស់អ្នកបោះឆ្នោត ។
- ៧.១០.២.៣ ដកហូតអ.ខ ឬ ឯ.អ ពីប្រជាពលរដ្ឋ ។
- ៧.១០.២.៤ ជ្រៀតជ្រែកលើសិទ្ធិអ្នកបោះឆ្នោត ក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយសេរី ដើម្បីគាំទ្រដល់គណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ ។
- ៧.១០.២.៥ បញ្ជុះបញ្ចូលអ្នកបោះឆ្នោតឱ្យគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយ ឬបេក្ខជនណាម្នាក់ ។
- ៧.១០.២.៦ រារាំងអ្នកភូមិ ដែលមានបំណងចូលរួមក្នុងកិច្ចប្រជុំសាធារណៈរបស់ភូមិ ឃុំ សង្កាត់ ឬរបស់គណបក្សនយោបាយណាមួយ ឬរារាំងការទទួលព័ត៌មានពីគណបក្សនយោបាយណាមួយ ។

៧.១០.៣ ធ្វើសកម្មភាពណាមួយ ទោះដោយប្រយោលក្តី ឬផ្ទាល់ក្តី ដើម្បីបំភិតបំភ័យ គំរាមកំហែងអ្នកបោះឆ្នោត ដែលនាំឱ្យបាត់សេរីភាពនៃការជ្រើសរើសរបស់ប្រជាពលរដ្ឋក្នុងការបោះឆ្នោត ។

៧.១០.៤ ធ្វើជាអ្នកផ្សព្វផ្សាយឱ្យគណបក្សនយោបាយណាមួយ ដែលនាំឱ្យជះឥទ្ធិពលដល់អ្នកភូមិ និងបាត់បង់ភាពយុត្តិធម៌សម្រាប់គណបក្សនយោបាយផ្សេងទៀត ។

៧.១០.៥ ផ្ដិបទុកព័ត៌មាន ឬផ្សព្វផ្សាយព័ត៌មានដោយមានការរើសអើង ចំពោះអ្នកគាំទ្រគណបក្សនយោបាយណាមួយ ។

ប្រការ ៧.១១.

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម ៖

៧.១១.១ ផ្តួចផ្តើម ឬចូលរួមនៅក្នុងការយោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តួចផ្តើម ឬការចូលរួមយោសនារួមមាន ៖

- ៧.១១.១.១ ការបញ្ជុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមយោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ៧.១១.១.២ ការចូលរួមក្នុងក្បួនដង្ហែ ការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ៧.១១.១.៣ ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬ សម្ភារយោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬ បេក្ខជនណាម្នាក់ ។
- ៧.១១.១.៤ ការចូលជាសមាជិកគណៈកម្មការយោសនាបោះឆ្នោត នៃគណបក្សនយោបាយណាមួយ ។

៧.១១.២ ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀងរួមមាន ៖

- ៧.១១.២.១ ការស្នងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ៧.១១.២.២ ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ៧.១១.២.៣ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យប្រមាថ មាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៧.១១.២.៤ ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗភ្ជាប់នឹងយានយន្ត របស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៧.១១.៣ ផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តល់មធ្យោបាយជាថវិកា សម្ភារ បរិក្ខារ ធនធានមនុស្ស រួមមាន ៖

៧.១១.៣.១ ការផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់យោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៧.១១.៣.២ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗ ជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមយោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៧.១១.៣.៣ ការផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ក្បួនដង្ហែយោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្ប: និងការបោះពុម្ពសម្ភារយោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៧.១១.៤ ហាមជនបរទេស ដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការយោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

ប្រការ ៧.១២.

មុននឹងបើកការយោសនាបោះឆ្នោត គធ.ខប និង គយ.សប ត្រូវផ្សព្វផ្សាយដល់មន្ត្រីដែលបានរៀបរាប់ក្រោមប្រការ ៧.៧ ៧.៨ និងប្រការ ៧.៩ ខាងលើ តាមរយៈអាជ្ញាធរដែនដី កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ អំពីការកិច្ច និងអព្យាក្រឹតភាពក្នុងម៉ោងធ្វើការទាក់ទិនដល់ការយោសនាបោះឆ្នោត ។

ប្រការ ៧.១៣.

គធ.ខប និង គយ.សប ត្រូវចាត់ចែងកម្មវិធីប្រជុំប្រចាំសប្តាហ៍ និងប្រជុំបន្ថែម តាមការចាំបាច់ជាមួយនឹងតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងភាគីពាក់ព័ន្ធនានា ដើម្បី ៖

៧.១៣.១ ជម្រាបឱ្យដឹងពីការវិវត្តនៃដំណើរការបោះឆ្នោត ។

៧.១៣.២ ជម្រាបជូនជាសង្ខេបពី ប.ន.ត.រ ។

៧.១៣.៣ ស្តាប់មតិយោបល់ សំណូមពរ និងការកត់សម្គាល់ផ្សេងៗ ។

៧.១៣.៤ ពិភាក្សាលើបញ្ហាផ្សេងៗទៀត ដែលពាក់ព័ន្ធដល់ដំណើរការបោះឆ្នោត ។

ប្រការ ៧.១៤.

ក្នុងពេលយោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវតែគោរពតាមវិធានបទប្បញ្ញត្តិ និងគោលការណ៍ដែលចែងក្នុង ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌សម្រាប់ការបោះឆ្នោត គោលការណ៍ស្តីពីសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

៧.១៤.១ គ្រប់បេក្ខជន និងគណបក្សនយោបាយទាំងអស់ត្រូវប្រកាន់អាកប្បកិរិយាថ្លៃថ្នូ។

៧.១៤.២ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង មិនត្រូវបង្គាប់បញ្ជាឱ្យអ្នកគាំទ្ររបស់ខ្លួនទៅហែក ឬបំផ្លាញចោលសម្ភារ ឯកសារយោសនា របស់គណបក្សនយោបាយ ឬ/និងបេក្ខជនដទៃឡើយ ។

៧.១៤.៣ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

៧.១៤.៤ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ ។

៧.១៤.៥ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យ អសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន ឬអ្នកគាំទ្រ ឬលើបុគ្គលណាមួយឡើយ ។

៧.១៤.៦ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រទាំងអស់ មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយឡើយ ។

៧.១៤.៧ គ្រប់គណបក្សនយោបាយ ឬបេក្ខជន ឬតំណាងទាំងអស់ មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត វិភាគទាន ជូនសគុណ ឬរង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។

៧.១៤.៨ គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង មិនត្រូវគំរាមកំហែង ឬបំភិតបំភ័យដោយផ្ទាល់ ឬដោយប្រយោលដល់បុគ្គលណាម្នាក់ ឬក្រុមគ្រាំទ្រណាមួយ ដើម្បីឱ្យគេគាំទ្រខ្លួន ឬបំបាក់ទឹកចិត្តបុគ្គលទាំងនោះ ឱ្យឈប់គាំទ្រដល់បេក្ខជន ឬគណបក្សនយោបាយដទៃទៀតឡើយ ។ ការគំរាមកំហែង បំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន ៖

- ៧.១៤.៨.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ។
- ៧.១៤.៨.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថានឹងធ្វើទារុណកម្ម ។
- ៧.១៤.៨.៣ ការវាយតប់បន្ទិចបន្ទូច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់ ។
- ៧.១៤.៨.៤ ការគំរាមដោយពាក្យសម្តីថានឹងធ្វើទុក្ខទោសដល់រាងកាយ ។
- ៧.១៤.៨.៥ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធដើម្បីបំភិតបំភ័យ ។
- ៧.១៤.៨.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាលដូចជា ឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។
- ៧.១៤.៨.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ។
- ៧.១៤.៨.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះ មានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន ។

៧.១៤.៨.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈ របស់ជននោះ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ ឬសុវត្ថិភាពគ្រួសាររបស់ខ្លួន ។

៧.១៤.៨.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះសម្បែង ឬអចលនទ្រព្យដទៃទៀត ឬធ្វើឱ្យខូចផលប្រយោជន៍មុខរបរ ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត។

៧.១៤.៨.១១ ការប្រមូល ឬការដកហូត ឬការបំផ្លាញឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត របស់អ្នកបោះឆ្នោត ។

៧.១៤.៨.១២ ការដាក់កំហិតសិទ្ធិណាមួយចំពោះអ្នកបោះឆ្នោតក្នុងការស្វែងរក ឬស្តាប់នូវព័ត៌មានអំពីគណបក្សនយោបាយនានា ។

ប្រការ ៧.១៥.-

គណបក្សនយោបាយ ឬបេក្ខជន ឬតំណាង ដែលប្រព្រឹត្តផ្ទុយនឹងប្រការ ៧.១៤ នឹងត្រូវទទួលទោសតាមបញ្ញត្តិនៃ ច.ប.ត.រ ។

សម្ភារអប់រំអ្នកបោះឆ្នោត

ប្រការ ៧.១៦.-

នាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និង នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ទទួលខុសត្រូវក្នុងការផលិត និងផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត និងសាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីដំណើរការបោះឆ្នោត ។

៧.១៦.១ គ.ជ.ប អំពាវនាវ និងលើកទឹកចិត្តអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញការកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យចូលរួមយ៉ាងសកម្ម ដើម្បីឱ្យការអប់រំសាធារណជនដែលទាក់ទងដល់ដំណើរការបោះឆ្នោតមានប្រសិទ្ធភាពខ្ពស់។

៧.១៦.២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញការកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានបំណងសហការជាមួយ គ.ជ.ប នៅក្នុងផ្នែកណាមួយនៃការអប់រំសាធារណជនអំពីការបោះឆ្នោត អាចទាក់ទងព័ត៌មានជាមួយនឹងនាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និងនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ ។

៧.១៦.៣ ខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវតែគោរពតាមគោលការណ៍អព្យាក្រឹត និងមិនលម្អៀង ។ សម្ភារទាំងនោះមិនត្រូវគាំទ្រ ឬបន្ទុះបង្ហាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ឡើយ ហើយត្រូវគោរពទៅតាម ច.ប.ត.រ និង ប.ន.ត.រ របស់ គ.ជ.ប ។

៧.១៦.៤ សម្ភារព័ត៌មានសាធារណៈ និងសម្ភារអប់រំដែលផលិតដោយ គ.ជ.ប និងសម្ភារអប់រំដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិ ដែលទទួលលិខិតយល់ព្រមពី គ.ជ.ប ត្រូវបានរក្សាសិទ្ធិ ហើយមិនត្រូវបន្ថែម ឬបន្ថយខ្លឹមសារ ដោយគ្មានការយល់ព្រមពី គ.ជ.ប ឡើយ ។

៧.១៦.៥ ដើម្បីធានាថា ខ្លឹមសារនៃសម្ភារអប់រំអ្នកបោះឆ្នោតដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬ/និងអន្តរជាតិត្រឹមត្រូវតាមបច្ចេកទេស និងតាម ច.ប.ត.រ និង ប.ន.ត.រ គ.ជ.ប នឹងជួយផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ យល់ព្រម និងណែនាំដល់អង្គការមិនមែនរដ្ឋាភិបាលអំពីលក្ខណៈបច្ចេកទេស និងបញ្ជាក់ពីភាពស្របច្បាប់នៃសម្ភារអប់រំនេះ ។

៧.១៦.៦ ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារអប់រំអ្នកបោះឆ្នោត ពុំតម្រូវឱ្យមានសេវាពិនិត្យផ្ទៀងផ្ទាត់ យល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ ។

៧.១៦.៧ ទោះបីជាសម្ភារអប់រំត្រូវបានទទួល ឬមិនបានទទួលលិខិតយល់ព្រមក៏ដោយ អ្នកទទួលបោះពុម្ពផ្សាយ និងអ្នកទទួលផ្សព្វផ្សាយត្រូវស្គាល់អត្តសញ្ញាណអតិថិជនរបស់ខ្លួន ហើយនឹងមិនទទួលខុសត្រូវចំពោះមុខច្បាប់ ចំពោះខ្លឹមសារបច្ចេកទេស នៃសម្ភារអប់រំនោះឡើយ លើកលែងតែមានច្បាប់កំណត់ផ្សេងពីនេះ ។ ម្ចាស់សម្ភារអប់រំត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

៧.១៦.៨ ករណីដែលមានការស្នើសុំការផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ គណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងគោលនយោបាយរបស់គណបក្សនយោបាយ ដូចមានចែងក្រោមប្រការ ៧.១៨ មានភារកិច្ចក្នុងការផ្តល់សេវាពិនិត្យផ្ទៀងផ្ទាត់ យល់ព្រមក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីទទួលបានសំណើពីអង្គការមិនមែនរដ្ឋាភិបាលនានា សុំឱ្យជួយពិនិត្យផ្ទៀងផ្ទាត់សម្ភារអប់រំនោះ។

ករណីពិនិត្យឃើញថា សម្ភារ ឬខ្លឹមសារអប់រំ មិនសមស្របតាម ច.ប.ត.រ ឬ/និង ប.ន.ត.រ គណៈកម្មការសម្របសម្រួល ត្រូវបង្ហាញអំពីការខុសឆ្គង ហើយស្នើសុំឱ្យមានការកែតម្រូវ និងប្រគល់ឱ្យគណៈកម្មការសម្របសម្រួលពិនិត្យឡើងវិញ ។ ករណីគណៈកម្មការសម្របសម្រួល ធ្វើការពិនិត្យផ្ទៀងផ្ទាត់សម្ភារអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាលហួសរយៈពេល ៧២ (ចិតសិបពីរ) ម៉ោង ដោយពុំទាន់ផ្តល់លិខិតយល់ព្រមទេ ចាត់ទុកថាគណៈកម្មការសម្របសម្រួលបានឯកភាពលើខ្លឹមសារ និងអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយឯកសារនោះជាសាធារណៈបាន ។

៧.១៦.៩ សម្ភារអប់រំដែលត្រូវបានពិនិត្យផ្ទៀងផ្ទាត់ និងទទួលបានលិខិតយល់ព្រមពី គ.ជ.ប មានដូចជា ៖

- ៧.១៦.៩.១ ស្ប៊ីតវីដេអូ ឬរឿងវីដេអូអប់រំខ្លីៗ ។
- ៧.១៦.៩.២ កាសែតម៉ាញ៉ូ ឬខ្សែអាត់សំឡេង ។
- ៧.១៦.៩.៣ ខិត្តប័ណ្ណផ្សេងៗ និងបដា ។
- ៧.១៦.៩.៤ សៀវភៅអប់រំទាក់ទងដល់ការបោះឆ្នោត ។
- ៧.១៦.៩.៥ ការផ្សព្វផ្សាយ និងរូបភាពចុះលើទំព័រសារព័ត៌មាន ។
- ៧.១៦.៩.៦ រូបភាព ឬពាក្យស្លោកបោះពុម្ពលើសម្លៀកបំពាក់ ឬមួក ។

៧.១៦.១០ សម្ភារដែលបានពិនិត្យផ្ទៀងផ្ទាត់ ហើយទទួលបានលិខិតយល់ព្រមពី គ.ជ.ប ត្រូវតម្កល់ទុកនៅ គ.ជ.ប មួយមុខ ១ (មួយ) ច្បាប់ សម្រាប់ជាឯកសារ ។

៧.១៦.១១ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលមិនប្រើប្រាស់ប្រព័ន្ធពិនិត្យផ្ទៀងផ្ទាត់យល់ព្រម ដែលផ្តល់ដោយ គ.ជ.ប ត្រូវទទួលខុសត្រូវលើខ្លឹមសារនៃសម្ភារអប់រំតាម ច.ប.ត.រ ។ ប្រសិនបើព័ត៌មាននៅក្នុងសម្ភារអប់រំ ដែលខ្លួនបានផលិតនោះ ត្រូវបានរកឃើញថា មានភាពលម្អៀងក្នុងន័យគាំទ្រសកម្មភាពគណ-បក្សនយោបាយណាមួយ ដែលផ្ទុយពី ច.ប.ត.រ ឬ/និង ប.ន.ត.រ ឬធ្វើឱ្យសាធារណជនយល់ខុសពី ច.ប.ត.រ និង ប.ន.ត.រ គ.ជ.ប ត្រូវឱ្យសាមីអង្គការធ្វើការកែតម្រូវ ឬបញ្ជាឱ្យដកហូតសម្ភារនោះទាំងស្រុងតែម្តង ។ សម្ភារដែលរកឃើញថា មានភាពលម្អៀង ក្នុងន័យគាំទ្រសកម្មភាពគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ត្រូវបានកំណត់ដូចចំណុច ៧.១៧.៥ ខាងក្រោម ។

៧.១៦.១២ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ត្រូវបានអនុញ្ញាតឱ្យផលិតតាមគោលការណ៍ស្មើភាពនូវសៀវភៅអប់រំអ្នកបោះឆ្នោត ដែលមានកម្មវិធីនយោបាយរបស់គណបក្សទាំងអស់ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ សៀវភៅអប់រំអ្នកបោះឆ្នោតនេះអាចបោះពុម្ព និងធ្វើការដឹកជញ្ជូនទៅដល់មូលដ្ឋានមុនថ្ងៃចាប់ផ្តើមយោសនាបោះឆ្នោត ប៉ុន្តែអាចចែកចាយ និងធ្វើការផ្សព្វផ្សាយជាសាធារណៈ បានតែក្នុងអំឡុងពេលយោសនាបោះឆ្នោតតែប៉ុណ្ណោះ ។

៧.១៦.១៣ គ.ជ.ប មានសិទ្ធិធ្វើការកែតម្រូវ ឬដកហូតនូវផ្នែកណាមួយ ឬទាំងអស់នៃសម្ភារអប់រំណាដែលមិនគោរពតាមចំណុច ៧.១៦.៣ ៧.១៦.១២ និង ៧.១៧.៥ ហើយសាមីអង្គការ ត្រូវធ្វើការកែតម្រូវតាមសំណើរបស់ គ.ជ.ប ជាចាំបាច់ ។ ក្នុងករណីកំហុសធ្ងន់ធ្ងរមានលក្ខណៈធ្ងន់ធ្ងរ សាមីអង្គការត្រូវទទួលទោសតាម ច.ប.ត.រ ។

រូបភាព និងសម្ភារយោសនាផ្សព្វផ្សាយ

ប្រការ ៧.១៧..

យោងតាមប្រការ ៧.២ គណបក្សនយោបាយ បេក្ខជននានា និងអ្នកគាំទ្រទាំងឡាយអាចប្រើប្រាស់រូបភាព ឬសម្ភារយោសនាផ្សព្វផ្សាយបានដូចជា ៖

៧.១៧.១ ខិត្តប័ណ្ណយោសនាបោះឆ្នោត ។

៧.១៧.២ ការយោសនា តាមរលកអាកាស ឬតាមឧបករណ៍បំពងសំឡេង ឬតាមឧបករណ៍បញ្ចាំងរូបភាព ។

៧.១៧.២.១ អត្ថបទយោសនា ។

៧.១៧.២.២ បទភ្លេង និងចម្រៀងជាពាក្យស្លោកខ្លីៗ ។

៧.១៧.២.៣ ការសូត្រកំណាព្យ ។

៧.១៧.២.៤ ការប្រគំតន្ត្រីនៅនឹងកន្លែង ។

៧.១៧.២.៥ សម្តាសន៍ដោយបន្តផ្ទាល់ ឬដោយមិនបន្តផ្ទាល់ ។

៧.១៧.២.៦ ការសម្តែងសិល្ប: ។

៧.១៧.២.៧ ការចាក់ផ្សាយកាស្សែតវីដេអូ ឬវ៉ីស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូជាសាធារណៈ ឬទីធ្លាសាធារណៈ ។

៧.១៧.២.៨ ការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គមផ្ទាល់ការរបស់ខ្លួន ។

៧.១៧.៣ ក្រៅពីរូបភាព និងសម្ភារ ដូចបានបញ្ជាក់ខាងលើ មធ្យោបាយផ្សេងៗទៀតដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ សម្រាប់ការយោសនាបោះឆ្នោត មានដូចខាងក្រោម៖

៧.១៧.៣.១ រឿងល្ខោនខ្លីៗ និងការសម្តែងសិល្ប: ការបញ្ចាំងខ្សែភាពយន្ត វីដេអូ។

៧.១៧.៣.២ ប៉ែងប៉ោង ឬ/និងបង្ហោះខ្លែង ។

៧.១៧.៣.៣ សម្ភារបោះពុម្ពដូចជា រូបភាពបិទផ្សាយ សម្លៀកបំពាក់ អាវយឺត មួក ស្លាកសញ្ញា ពាក្យស្លោក ឬរូបភាពបិទតាមរថយន្ត ស្លាកសញ្ញា លោហ:ខ្ទាស់ បដា ។ល។

៧.១៧.៤ គ្រប់សម្ភារ ឯកសារយោសនាបោះឆ្នោតទាំងអស់ដែលបានបោះពុម្ព ចែកផ្សាយ ឬផ្សព្វផ្សាយដោយបេក្ខជន ឬ/និងគណបក្សនយោបាយ ត្រូវតែមានដាក់សញ្ញាសម្គាល់របស់សាមីគណបក្សនយោបាយ (ឈ្មោះ ឬ/និងអាសយដ្ឋាន) ។

៧.១៧.៥ សម្ភារអប់រំ និងសម្ភារយោសនាដែលត្រូវបានផ្សព្វផ្សាយជាទម្រង់អត្ថបទបោះពុម្ព ឬតាមឧបករណ៍បំពងសំឡេង ឬការចាក់ផ្សាយ មិនត្រូវរួមបញ្ចូល ឬប្រើប្រាស់នូវរូបភាព ឬខ្លឹមសារណាមួយ ដូចខាងក្រោម ៖

៧.១៧.៥.១ ប្រើប្រាស់រូបភាព ឬភាសាដែលញុះញង់អ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើហិង្សា បំភិតបំភ័យ គំរាមកំហែងប្រឆាំងអ្នកបោះឆ្នោត ឬគណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ឬធ្វើឱ្យបាត់បង់ជំនឿជឿជាក់លើភាពសម្ងាត់នៃការបោះឆ្នោត ។

៧.១៧.៥.២ ប្រើប្រាស់រូបភាព ឬភាសាដែលមាក់ងាយ បំភិតបំភ័យ ប្រមាថ សម្តែងការមាក់ងាយ ឬអសីលធម៌ ឬការរើសអើងប្រកាន់ពូជសាសន៍។

៧.១៧.៥.៣ ប្រើប្រាស់រូបភាព ឬភាសាដែលសាបព្រោះភាពភ័យខ្លាចធ្វើឱ្យកាន់ច្រឡំ ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយ និងខូចរបៀបរបបសង្គម ។

៧.១៧.៥.៤ ប្រើប្រាស់រូបភាព ឬភាសា ឬព័ត៌មានមិនត្រឹមត្រូវចំពោះដំណើរការបោះឆ្នោត ។

៧.១៧.៥.៥ ប្រើប្រាស់សារជាសំឡេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន។

៧.១៧.៥.៦ ប្រើប្រាស់រូបភាពសារជាសំឡេង ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់បុគ្គល ដែលត្រូវបានហាមឃាត់ការធ្វើសកម្មភាពនយោបាយដោយស្ថាប័នមានសមត្ថកិច្ច ។

៧.១៧.៦ ការផ្សព្វផ្សាយ ការចុះផ្សាយ ឬការបោះពុម្ពផ្សាយសម្ភារអប់រំ និងសម្ភារយោសនាដែលត្រូវបានរកឃើញថារំលោភចំណុច ៧.១៧.៥ ខាងលើ គ.ជ.ប អាចបញ្ជាឱ្យដកហូត ឬបញ្ឈប់ការផ្សព្វផ្សាយ និងការប្រើប្រាស់សម្ភារខុសច្បាប់ទាំងនោះ ។

៧.១៧.៧ គណបក្សនយោបាយត្រូវទទួលខុសត្រូវចំពោះសម្ភារអប់រំ និងសម្ភារយោសនាដែលខ្លួនផ្សព្វផ្សាយ និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ប្រសិនបើសម្ភារទាំងនោះរំលោភលើលក្ខខណ្ឌដូចមានចែងក្នុងជំពូកទី៧ ។

៧.១៧.៨ ហាមធ្វើសកម្មភាពយោសនាដោយយកព្រះនាយាលក្ខណ៍ ព្រះរាជឱង្ការ ព្រះរាជសារ ស្នាព្រះហស្ត និងព្រះនាមព្រះមហាក្សត្រ ព្រះមហាវីរក្សត្រ ព្រះមហាក្សត្រី ព្រះវររាជមាតា រូបសញ្ញា គ.ជ.ប ទៅប្រើប្រាស់ដើម្បីរកសំឡេងឆ្នោត ។

៧.១៧.៩ ហាមលើកបដាយោសនា ស្លាកសញ្ញាគណបក្សនយោបាយ និងរូបសញ្ញាណាមួយដែលបង្ហាញពីការគាំទ្រគណបក្សនយោបាយ ឬបក្ខជនណាម្នាក់ឆ្លងកាត់ទទឹងផ្លូវសាធារណៈ ។

ប្រការ ៧.១៨.-

គ.ជ.ប ត្រូវបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីផ្សព្វផ្សាយអប់រំអ្នកបោះឆ្នោត និងផ្សព្វផ្សាយកម្មវិធីនយោបាយរបស់គណបក្សនយោបាយ ហៅថា " គណៈកម្មការសម្របសម្រួល " តាមសេចក្ដីសម្រេចរបស់ គ.ជ.ប ដើម្បីត្រួតពិនិត្យសម្ភារអប់រំរបស់អង្គការមិនមែនរដ្ឋាភិបាល ឬ/និងសម្ភារយោសនារបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្ដឹង ព្រមទាំងរៀបចំគោលការណ៍កម្មវិធីស្មើភាព ឬ/និងសមធម៌ ។

៧.១៨.១ តួនាទី និងភារកិច្ចរបស់គណៈកម្មការសម្របសម្រួល ត្រូវបានកំណត់ដូចខាងក្រោម ។

៧.១៨.១.១ ត្រួតពិនិត្យ និងកែសម្រួលលើខ្លឹមសារសម្ភារអប់រំអ្នកបោះឆ្នោត ដែលផលិតដោយអង្គការមិនមែនរដ្ឋាភិបាល ក្នុងករណីមានការស្នើសុំពីសាមីអង្គការ ។

៧.១៨.១.២ ត្រួតពិនិត្យសម្ភារអប់រំអ្នកបោះឆ្នោត និងសម្ភារយោសនារបស់គណបក្សនយោបាយ ក្នុងករណីមានការតវ៉ា ឬមានពាក្យបណ្តឹងពីគណបក្សនយោបាយ បេក្ខជន ឬតំណាងដទៃទៀត ដោយយោងតាម ច.ប.ត.រ និងយោងតាមចំណុច ៧.១៨.៨ ៧.១៧.៥ និង ៧.១៧.៨ នៃ ប.ន.ត.រ នេះ ។

៧.១៨.១.៣ សម្របសម្រួលកម្មវិធីស្មើភាព ឬ/និងសមធម៌ ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ។

៧.១៨.១.៤ សម្របសម្រួលជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ក្នុងពេលយោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ដើម្បីមានឱកាសទិញ ឬជួលម៉ោងផ្សាយ ផ្អែកតាមគោលការណ៍ស្មើភាព ឬ/និងសមធម៌ និងតាមលំដាប់មុនក្រោយ ។

៧.១៨.១.៥ សម្របសម្រួលជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលមានបំណងរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ សម្រាប់គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ។

៧.១៨.២ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានគោលការណ៍ សម្រាប់ការរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ ជូនគ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាផ្លូវការ ឱ្យមានឱកាសផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួន ជូនអ្នកបោះឆ្នោត តាមវិទ្យុ និងទូរទស្សន៍របស់រដ្ឋ ផ្អែកតាមគោលការណ៍ស្មើភាព ឬ/និងសមធម៌ និងតាមលំដាប់មុនក្រោយ ។

៧.១៨.២.១ គណៈកម្មការសម្របសម្រួល ត្រូវរៀបចំចាត់ចែងឱ្យមានកិច្ចប្រជុំជាមួយគណបក្សនយោបាយឈរឈ្មោះ ដើម្បីពិភាក្សាកំណត់អំពីការរៀបចំកម្មវិធីស្មើភាព ឬ/និងសមធម៌ ហើយត្រូវមានបទបញ្ជាមួយសម្រាប់ថតកម្មវិធី ដែលអនុម័តដោយ គ.ជ.ប ។

៧.១៨.២.២ គណៈកម្មការសម្របសម្រួល ត្រូវអនុវត្តតាមគោលការណ៍ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃកម្មវិធីស្មើភាព ឬ/និងសមធម៌របស់ គ.ជ.ប ក្នុងការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ។

៧.១៨.៣ កម្មវិធីស្មើភាព ឬ/និងសមធម៌ ដែលរៀបចំដោយ គ.ជ.ប សម្រាប់គណបក្ស នយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម ។

៧.១៨.៣.១ កម្មវិធីចាក់ផ្សាយកិច្ចពិភាក្សាតាមប្រធានបទ រវាងបេក្ខជនឈរឈ្មោះ បោះឆ្នោត ឬតំណាងគណបក្សនយោបាយ អំពីកម្មវិធីនយោបាយ របស់ខ្លួន តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ ។

៧.១៨.៣.២ កម្មវិធីចាក់ផ្សាយស្ប៊ីតរបស់គណបក្សនយោបាយតាមវិទ្យុ និង ទូរទស្សន៍រដ្ឋ ។

៧.១៨.៣.៣ ការបោះពុម្ពផ្សាយអត្ថបទឃោសនា អំពីគោលនយោបាយ និង កម្មវិធីនយោបាយរបស់គណបក្សនយោបាយ ឬប្រសាសន៍ដើម ទាំងស្រុងរបស់បេក្ខជនឈរឈ្មោះបោះឆ្នោត លើព្រឹត្តិបត្រគោល នយោបាយដែលបោះពុម្ពផ្សាយដោយ គ.ជ.ប ។

៧.១៨.៤ គណៈកម្មការសម្របសម្រួល ត្រូវជួបពិភាក្សាជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ និង ឯកជន និងភាគីពាក់ព័ន្ធ ដើម្បីពន្យល់ណែនាំអំពីបទបញ្ជា និងនីតិវិធី ក្រមសីលធម៌ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត និងគោលការណ៍ណែនាំ ផ្សេងៗរបស់ គ.ជ.ប ។

ប្រការ ៧.១៩.-

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ត្រូវផ្តល់ ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរ ឈ្មោះបោះឆ្នោត ដែលសុំជួលប្រើប្រាស់សម្រាប់ធ្វើការឃោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយនៃការស្នើសុំ ។ គណបក្សនយោបាយ ឬបេក្ខជន ដែលមានបំណងជួល រោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ត្រូវធ្វើពាក្យសុំទៅអ្នក គ្រប់គ្រងទីកន្លែងនោះ ៣ (បី) ថ្ងៃយ៉ាងតិច មុនថ្ងៃប្រជុំឃោសនា ហើយត្រូវផ្ញើសេចក្តីចម្លង នៃពាក្យសុំនេះ ១ (មួយ) ច្បាប់ដល់ គឃ.សប ។ អ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបទៅនឹងពាក្យស្នើសុំជួល ក្នុងរយៈពេល ២៤ (ម្តៃបួន) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ។

៧.១៩.១ គធ.ខប និង គឃ.សប ត្រូវសហការជាមួយអាជ្ញាធរដែនដី ដើម្បីកំណត់ ទីសាធារណៈសម្រាប់ការឃោសនាបោះឆ្នោត ហើយត្រូវផ្សព្វផ្សាយជាសាធារណៈ នៅក្នុងឃុំ សង្កាត់ យ៉ាងតិច ៧ (ប្រាំពីរ) ថ្ងៃមុនថ្ងៃចាប់ផ្តើមឃោសនាបោះឆ្នោត ។

៧.១៩.២ បន្ទាប់ពីបានទទួលសេចក្ដីជូនដំណឹង ដូចមានចែងក្នុងប្រការ ៧.១៩ គធ.ខប គយ.សប ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីសម្របសម្រួល អំពីការងារសន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ សម្រាប់ឱ្យគណបក្សនយោបាយ ឬ បេក្ខជន ធ្វើការយោសនា ។

៧.១៩.៣ គយ.សប ត្រូវមានសៀវភៅចុះលិខិតចម្លងនៃពាក្យស្នើសុំធ្វើការយោសនារបស់គណបក្ស នយោបាយ ឬបេក្ខជនដែលបានទទួល ដើម្បីឱ្យបានដឹងថា គណបក្សនយោបាយ ណាបានស្នើសុំធ្វើការយោសនាមុន និងគណបក្សនយោបាយណាបានស្នើសុំធ្វើការ យោសនាបន្តបន្ទាប់ ។

៧.១៩.៤ គយ.សប ត្រូវធ្វើកាលវិភាគប្រចាំសប្ដាហ៍ ស្ដីពីកាលកំណត់តាមលំដាប់មុនក្រោយ នៃការស្នើសុំប្រើប្រាស់ទីសាធារណៈ ឬទីកន្លែងឯកជន រួចបិទផ្សាយជាសាធារណៈ នៅទីស្នាក់ការ គយ.សប ១ (មួយ)ច្បាប់ និងនៅទីកន្លែងដែលត្រូវធ្វើការយោសនា ១ (មួយ) ច្បាប់ ។

៧.១៩.៥ គធ.ខប គយ.សប ត្រូវតាមដាន សម្របសម្រួល និងរៀបចំតាមលំដាប់មុនក្រោយ នៃការជូនដំណឹងស្ដីពីការធ្វើការយោសនាបោះឆ្នោត របស់គណបក្សនយោបាយ នីមួយៗ ដោយណែនាំឱ្យគោរពក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ និងចាត់វិធានការទប់ស្កាត់ និងដោះស្រាយ ចំពោះការយោសនាទាំងឡាយណាដែលផ្ទុយនឹង ច.ប.ត.រ ប.ន.ត.រ ។

៧.១៩.៦ គ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងដែលមានបំណងធ្វើសកម្មភាពចែកខិត្តប័ណ្ណនៅក្នុងផ្សារ សាមីគណបក្សនយោបាយ ទាំងនោះត្រូវស្នើសុំទៅអ្នកគ្រប់គ្រងផ្សារ និងជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គយ.សប ពាក់ព័ន្ធយ៉ាងហោចឱ្យបាន ៣ (បី) ថ្ងៃ មុនថ្ងៃធ្វើសកម្មភាព ។

៧.១៩.៦.១ ការជូនដំណឹងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពី ៖

- នាមត្រកូល នាមខ្លួន និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្សនយោបាយ
- កាលបរិច្ឆេទ ពេលវេលា និងឈ្មោះផ្សារ ដែលត្រូវធ្វើសកម្មភាព ។
- ចំនួនអ្នកចូលរួម ។

៧.១៩.៦.២ ការធ្វើសកម្មភាពក្នុងផ្សារត្រូវកម្រិតយ៉ាងច្រើនត្រឹម ១០ (ដប់) នាក់ប៉ុណ្ណោះ ហើយត្រូវយកចិត្តទុកដាក់គោរព និងរក្សាឱ្យបាននូវសន្តិសុខសុវត្ថិភាព សណ្តាប់ធ្នាប់ និងមិនត្រូវយកតាមខ្លួននូវឧបករណ៍បំពងសំឡេងឡើយ ។

៧.១៩.៦.៣ ការផ្សព្វផ្សាយតាមឧបករណ៍បំពងសំឡេង អំពីគោលនយោបាយ ឬ/និងកម្មវិធីនយោបាយ ឬ/និងសារនយោបាយរបស់គណបក្ស អាចធ្វើបាននៅក្រៅបរិវេណផ្សារ ។

៧.១៩.៦.៤ គយ.សប ត្រូវសហការ សម្របសម្រួលជាមួយអាជ្ញាធរដែនដី និងអ្នកគ្រប់គ្រងផ្សារ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការធ្វើសកម្មភាពនេះ។

ប្រការ ៧.២០.-

គ្រប់សកម្មភាពយោសនារបស់គណបក្សនយោបាយត្រូវរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយឱ្យបានល្អ និងត្រឹមត្រូវតាមពេលវេលា ទីកន្លែងកំណត់ តាមដងផ្លូវ ទីប្រជុំជន និងទីសាធារណៈ ។

ប្រការ ៧.២១.-

គណបក្សនយោបាយ ឬ/និងបេក្ខជនអាចធ្វើសកម្មភាពយោសនានៅតាមកន្លែងឯកជនបានប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ ហើយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គយ.សប យ៉ាងតិច ៣(បី) ថ្ងៃ មុនថ្ងៃប្រជុំយោសនា ។ អ្នកគ្រប់គ្រងទីកន្លែងត្រូវផ្តល់ទីកន្លែងរបស់ខ្លួនដល់គ្រប់បេក្ខជន ឬគ្រប់គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតដែលមានបំណងសុំជួលប្រើប្រាស់សម្រាប់បម្រើការយោសនា ដោយផ្អែកលើគោលការណ៍ស្មើភាព តម្លៃស្មើគ្នា និងតាមលំដាប់នៃពេលវេលាដែលបានស្នើសុំ ។

ប្រការ ៧.២២.-

គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឱ្យរំខាន ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពយោសនារបស់គណបក្សនយោបាយ ឬ/និងបេក្ខជន ឬអ្នកគាំទ្រផ្សេងទៀតឡើយ ។ សកម្មភាពដែលជ្រៀតជ្រែក និងធ្វើឱ្យរំខាន រាំងស្ទះនោះរួមមាន ៖

៧.២២.១ ការនិយាយដៀមដាមប្រមាថមើលងាយ ។

៧.២២.២ ការធ្វើទុក្ខទោសដល់រាងកាយ ។

៧.២២.៣ ការវាយតប់លើរាងកាយនៃបុគ្គលណាម្នាក់ ។

៧.២២.៤ ការបាញ់កាំភ្លើងនៅនឹងកន្លែងដែលគណបក្សនយោបាយកំពុងធ្វើការយោសនា ឬកន្លែងប្រជុំ ឬបង្ហើរលើកញ្ជាលអ្នកណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ។

៧.២២.៥ ការរារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យយោសនាបោះឆ្នោតតាមកាលកំណត់ ។

៧.២២.៦ ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ទច់បង្ហាក់មិនឱ្យក្បួនដង្ហែយោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពយោសនាផ្សេងៗទៀត ។

៧.២២.៧ ការហាមឃាត់ ឬរារាំងប្រជាពលរដ្ឋមិនឱ្យចូលរួមក្នុងកិច្ចប្រជុំ ឬក្បួនដង្ហែរបស់គណបក្សនយោបាយណាមួយ ។

៧.២២.៨ ការប្រើគ្រឿងផ្ទុះដើម្បីរំខានដល់សកម្មភាពយោសនា របស់គណបក្សនយោបាយ ឬបេក្ខជន ។

៧.២២.៩ ការប្រើឧបករណ៍បំពងសំឡេងដើម្បីរំខានដល់ទីកន្លែងដែលគណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការយោសនា ឬការជួបប្រជុំ ។

៧.២២.១០ ការទម្លាក់ស្លាក ឬបំផ្លាញបដាគណបក្សនយោបាយ ឬសម្ភារយោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ។

៧.២២.១១ ការបង្កើត ការផ្ញើ ការបញ្ជូនព័ត៌មានក្លែងក្លាយ ឬទិន្នន័យមិនត្រឹមត្រូវ ដោយមធ្យោបាយណាក៏ដោយដើម្បីបង្ខូច ឬបង្ហាប់គណបក្សនយោបាយ ឬបេក្ខជនផ្សេងទៀត ។

ប្រការ ៧.២៣.-

បេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់មានសិទ្ធិស្មើៗគ្នា ក្នុងការទទួលបានការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការយោសនាបោះឆ្នោត ។

๗.๒๓.๑ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មានភារកិច្ច និងការទទួលខុសត្រូវក្នុងការរក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណ: សម្រាប់ការយោសនាបោះឆ្នោត ។

๗.๒๓.๒ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ មានភារកិច្ច និងការទទួលខុសត្រូវដោយធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលបានការការពារសន្តិសុខ និងសុវត្ថិភាពក្នុងអំឡុងពេលនៃការយោសនាបោះឆ្នោត ។

๗.๒๓.๓ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ ដែលមានភារកិច្ចការពារ មិនត្រូវឈរក្បែរ ឬដើរកៀកពេកទៅនឹងទីតាំង ឬក្បួនយោសនាបោះឆ្នោត ឬក៏ស្ថិតនៅក្នុងបរិវេណនៃអង្គពិធីយោសនាបោះឆ្នោតនានា លើកលែងតែមានការស្នើសុំដោយបេក្ខជន ឬ/និងគណបក្សនយោបាយណាមួយ ។

๗.๒๓.๔ ក្នុងអំឡុងពេលនៃការយោសនាបោះឆ្នោត គយ.សប ត្រូវតាមដានកម្រិតសន្តិសុខ និងសុវត្ថិភាពក្នុងឃុំ សង្កាត់ ព្រមទាំងត្រូវជូនព័ត៌មានទៅ គធ.ខប ជារៀងរាល់ថ្ងៃ ។ គធ.ខប ត្រូវសរុបសភាពការណ៍សន្តិសុខ សុវត្ថិភាព និងរាយការណ៍ជូន គ.ជ.ប ជារៀងរាល់ថ្ងៃ ។

ប្រការ ៧.២៤.

គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនីដើម្បីកត់ត្រាចំណូល ប្រភពនៃប្រាក់ចំណូល និងចំណាយសម្រាប់ការយោសនាបោះឆ្នោត ។

๗.๒๔.๑ ការចំណាយសម្រាប់ការយោសនារបស់គណបក្សនយោបាយ និងរបស់បេក្ខជនម្នាក់ៗជាបន្ទុករបស់គណបក្សនយោបាយ ឬបេក្ខជនផ្ទាល់ ។

๗.๒๔.๒ វិភាគទានទាំងអស់ដែលគណបក្សនយោបាយទទួលបាន ត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការយោសនា ត្រូវតែចេញពីគណនីតែមួយនេះ។

๗.๒๔.๓ គណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត អាចត្រួតពិនិត្យសៀវភៅគណនីរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត តាមការចាំបាច់ ។

កិច្ចសហការ និងការកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រការ ៧.២៥._

កាសែត វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវផ្សព្វផ្សាយគ្រប់ព័ត៌មាន ដែលស្នើឡើងដោយ គ.ជ.ប ដោយឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយអំពីការប្រព្រឹត្តទៅនៃការបោះឆ្នោត និងការចាត់ចែងអប់រំការបោះឆ្នោត ។ គ.ជ.ប ត្រូវស្នើសុំកិច្ចសហការ និងការគាំទ្រពីក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយព័ត៌មានអំពីការបោះឆ្នោតជូនសាធារណជន និងតាមដានការផ្សព្វផ្សាយ ត្រួតពិនិត្យ និងចាត់វិធានការ ក្នុងករណីមិនគោរពតាម ច.ប.ត.រ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ។

ប្រការ ៧.២៦._

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់ឯកជន ដែលមានបំណងផ្សព្វផ្សាយព័ត៌មានដល់អ្នកបោះឆ្នោត ត្រូវអនុវត្តតាមក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដើម្បីឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ។

ប្រការ ៧.២៧._

គ្រប់ប្រព័ន្ធផ្សព្វផ្សាយ ទាំងរដ្ឋ ទាំងឯកជន ត្រូវគោរពក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ។ ប្រព័ន្ធផ្សព្វផ្សាយដែលមិនគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងអំឡុងពេលឃោសនាបោះឆ្នោតត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ ។

ប្រការ ៧.២៨._

រាល់ពាក្យបណ្តឹងពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោត ត្រូវអនុវត្តតាមជំពូកទី ១០ នៃ ប.ន.ត.រ នេះ ។

ជំពូកទី ៨

ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត

និងការប្រកាសរុបលទ្ធផលនៃការបោះឆ្នោត

ការបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត

ប្រការ ៨.១.-

អនុលោមតាមមាត្រា ៤៣ និងមាត្រា ៩៤ នៃ ច.ប.ត.រ គ.ជ.ប ត្រូវបោះពុម្ព និងចាត់ចែងឱ្យបិទផ្សាយជាសាធារណៈ:បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅគ្រប់ការិយាល័យបោះឆ្នោត និងនៅទីស្នាក់ការ គយ.សប យ៉ាងតិច ៣០ (សាមសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត ។

៨.១.១ គ.ជ.ប ត្រូវណែនាំដល់គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឱ្យចាត់ចែងបិទផ្សាយបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតខាងលើ បានទាន់ពេលវេលា ដោយត្រូវធានាថា ៖

៨.១.១.១ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗត្រូវបានថតចម្លង និងផ្ញើជូន គយ.សប ចំនួន ៣ (បី) ច្បាប់ សម្រាប់ប្រើប្រាស់ ដូចខាងក្រោម ៖

- បិទផ្សាយលើកទីមួយ ១ (មួយ) ច្បាប់ នៅទីស្នាក់ការ គយ.សប ៣០ (សាមសិប) ថ្ងៃមុនថ្ងៃបោះឆ្នោត
- បិទផ្សាយលើកទីពីរ ១ (មួយ) ច្បាប់ នៅគ្រប់ការិយាល័យបោះឆ្នោត ១ (មួយ) ថ្ងៃ មុនថ្ងៃបោះឆ្នោត
- រក្សាទុកជាឯកសារនៅ គយ.សប ១ (មួយ) ច្បាប់។

៨.១.១.២ បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ ចំណុះរាជធានី ខេត្តនីមួយៗ ត្រូវបានថតចម្លងលើក្រដាស ឬក្នុងស៊ីឌីផ្ញើជូន គធ.ខប ពាក់ព័ន្ធ ដើម្បីរក្សាទុកជាឯកសារ និងបម្រើដល់សាធារណជន ។

៨.១.២ នាយកដ្ឋានប្រតិបត្តិការ ត្រូវសហការជាមួយនាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ដើម្បីរៀបចំបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ។

៨.១.៣ នាយកដ្ឋានប្រតិបត្តិការ ត្រូវផ្តល់បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត ជូននាយកដ្ឋានរដ្ឋបាល ១ (មួយ) ច្បាប់ ដើម្បីសហការគ្នាធ្វើជាសេនាធិការជូន គ.ជ.ប ក្នុងការកំណត់ចំនួនមន្ត្រីការិយាល័យបោះឆ្នោត ដើម្បីជ្រើសរើសសមាសភាព គ.ក.ប។

ការផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារ ឧបករណ៍ចាំបាច់សម្រាប់ការបោះឆ្នោត

ប្រការ ៨.២.

គ.ជ.ប ត្រូវផ្គត់ផ្គង់សន្លឹកឆ្នោត និងសម្ភារឧបករណ៍សម្រាប់បម្រើឱ្យការបោះឆ្នោត តាមការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ ឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលា។

៨.២.១ គ.ជ.ប ត្រូវធានាបោះពុម្ពសន្លឹកឆ្នោតគ្រប់ចំនួនសម្រាប់រាជធានី ខេត្តនីមួយៗ នៅលើក្រដាសពណ៌ស ។

៨.២.២ សន្លឹកឆ្នោតនីមួយៗ ត្រូវមានគល់បញ្ជីសន្លឹកឆ្នោត ។ លេខរៀងតាមលំដាប់តគ្នានៃសន្លឹកឆ្នោត ត្រូវបោះនៅលើគល់បញ្ជីសន្លឹកឆ្នោត ។

៨.២.៣ សន្លឹកឆ្នោតនីមួយៗ ត្រូវមានសញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ ។ សញ្ញាសម្គាល់គណបក្សនយោបាយ និងឈ្មោះគណបក្សនយោបាយជាអក្សរពេញ និងអក្សរកាត់ដែលត្រូវដាក់នៅលើសន្លឹកឆ្នោត ត្រូវដាក់តាមលំដាប់លំដោយ ផ្អែកតាមលទ្ធផលនៃការចាប់ឆ្នោត ដូចមានចែងក្នុងចំណុច ៤.១៦.៨ នៃ ប.ន.ត.រ នេះ ។

៨.២.៤ រាជធានី ខេត្តនីមួយៗ ត្រូវមានសន្លឹកឆ្នោតដោយឡែករបស់ខ្លួន ដែល គ.ជ.ប ផ្តល់ជូន ។

៨.២.៥ គ.ជ.ប ត្រូវធានាផ្តល់ហិបឆ្នោតឱ្យបានគ្រប់ចំនួន សម្រាប់ឃុំ សង្កាត់នីមួយៗ ។ គ្រប់ហិបឆ្នោតទាំងអស់ត្រូវ ៖

- មានគម្របជាប់មកជាមួយ ដែលអាចចាក់បិទបានដោយប្រើប្រាស់សោឃ្លុំមានលេខ
- ធានានូវសុវត្ថិភាព ដែលមិនអាចហូតយកសន្លឹកឆ្នោតចេញពីក្នុងហិបឆ្នោតបានប្រសិនបើមិនបើកគម្រប
- មានសោ ឬឧបករណ៍ផ្សេងទៀតសម្រាប់កិបពេលបិទហិបឆ្នោត

- មានស្លាកលេខ ឬសញ្ញាសម្គាល់នៅផ្នែកខាងក្រៅយ៉ាងច្បាស់ដែលមិនអាចដូរ ឬលុបបានដោយងាយ ហើយស្លាកលេខ ឬសញ្ញាសម្គាល់នេះ ត្រូវមានតែមួយគត់សម្រាប់ហិបឆ្នោតនោះ និងសម្គាល់បានថាហិបឆ្នោតនោះទាក់ទងទៅនឹងឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតណាមួយ ។

៨.២.៦ គ.ជ.ប ត្រូវធានាឱ្យមានត្រាសម្ងាត់ជាផ្លូវការគ្រប់ចំនួន និងខុសៗគ្នា សម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ ។
គ.ជ.ប ត្រូវតាក់តែងបទបញ្ជា និងនីតិវិធីសម្រាប់ការប្រគល់ទទួល និងការប្រគល់ត្រឡប់មកវិញ និងធានាភាពសម្ងាត់នៃត្រានេះ ។

៨.២.៧ គ.ជ.ប ត្រូវធានាឱ្យការិយាល័យបោះឆ្នោតនីមួយៗមានសម្ភារ ឧបករណ៍ ដូចខាងក្រោម ៖

១- បញ្ជីបោះឆ្នោត ។
២- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។
៣- ហិបឆ្នោត ដែលអាចចាក់ជាមួយសោឃ្លុំមានលេខ ។
៤- បន្ទប់សម្ងាត់ ។
៥- ត្រាការិយាល័យបោះឆ្នោត ។
៦- ត្រាសម្ងាត់សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។
៧- ទឹកខ្មៅលុបមិនជ្រះ សម្រាប់ជ្រលក់ម្រាមដៃសម្គាល់ថាបានបោះឆ្នោតហើយ ។
៨- សោ និងប្រដាប់ឃ្លុំ ។
៩- ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។
១០- ប៊ិកសរសេរដែលមានគុណភាពល្អ ។
១១- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។
១២- កញ្ចប់ និងស្បោងប្លាស្ទិក ។
១៣- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗ ទៀត ។

ការទទួលខុសត្រូវ និងការកិច្ចរបស់ គ.ក.ប/គ.ក.រ

ប្រការ ៨.៣.-

គ.ក.ប នឹងក្លាយទៅជា គ.ក.រ នៅពេលរាប់សន្លឹកឆ្នោត ។ គ.ក.ប/គ.ក.រ នីមួយៗមានភារកិច្ចចាត់ចែង គ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោតនិងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតដែល គ.ក.ប/គ.ក.រ នោះ ទទួលខុសត្រូវ ។

៨.៣.១ ប្រធាន គ.ក.ប/គ.ក.រ មានភារកិច្ចចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ដែលខ្លួនទទួលខុសត្រូវ និងត្រូវ ៖

- ៨.៣.១.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។
- ៨.៣.១.២ ម្ចាស់ការ និងចាត់ចែងក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប ។
- ៨.៣.១.៣ ទទួលពិនិត្យផ្ទៀងផ្ទាត់ និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារ ឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត ពិសេសពិនិត្យលេខកូដនៃកញ្ចប់សន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតសម្រាប់ការិយាល័យ ៣ក់ព័ន្ធ ។
- ៨.៣.១.៤ រៀបចំទីតាំងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ទៅតាមគំរូប្លង់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងបំ៣ក់គ្រឿងសង្ហារិម ។
- ៨.៣.១.៥ តាមដាន និងត្រួតពិនិត្យការបំពេញការងាររបស់ សមាសភាព គ.ក.ប/គ.ក.រ នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងអាណត្តិរបស់ខ្លួន ។
- ៨.៣.១.៦ ដាក់ជំនួសតំណែងសមាជិក គ.ក.ប/គ.ក.រ ណាដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា ដោយយោងទៅតាមចំណុច ៨.៤.៩ នៃជំពូកនេះ ។
- ៨.៣.១.៧ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោត ក្នុងការិយាល័យបោះឆ្នោត ។ ក្នុងពេលកំពុងដំណើរការបោះឆ្នោត យ៉ាងយូរ ១ (មួយ)

ម៉ោងម្តង ត្រូវចូលក្នុងបន្ទប់សម្ងាត់ ដើម្បីត្រួតពិនិត្យសុវត្ថិភាព សម្ភារដែលបំពាក់នៅទីនោះ និងសណ្តាប់ធ្នាប់ ក្នុងករណីគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់ ។

៨.៣.១.៨ ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបានបំពេញ និងចុះហត្ថលេខា ត្រឹមត្រូវ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខាជាសាក្សី ។

៨.៣.១.៩ ចាត់ចែងចែកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។

៨.៣.១.១០ ត្រួតពិនិត្យលិខិតតែងតាំង និងទទួលស្គាល់ភ្នាក់ងារគណបក្សនយោបាយ និងលិខិតតែងតាំង និងទទួលស្គាល់អ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៨.៣.១.១១ អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផ្លាស់ប្តូរទីកន្លែងពិនិត្យមើលដំណើរការបោះឆ្នោត ។

៨.៣.១.១២ ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោត ដល់អ្នកដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ។

៨.៣.១.១៣ បើក និងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ។

៨.៣.១.១៤ ធានារបៀបរៀបរយក្នុង និងក្រៅបរិវេណការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣.១.១៥ ចាក់ ឬកាត់ផ្តាច់សោឃ្លុំការពារហិបឆ្នោត ។

៨.៣.១.១៦ ធានាឱ្យប្រាកដថា អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានណែនាំឱ្យចេះពីរបៀបបោះឆ្នោត និងតាមដានពិនិត្យមើល ដើម្បីឱ្យប្រាកដថានៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបានបត់សន្លឹកឆ្នោតតាមផ្នត់ដើមតាមការណែនាំ ។

៨.៣.១.១៧ ធានាឱ្យប្រាកដថា ការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះ ត្រូវតែបានអនុវត្តតាមការណែនាំ ។

៨.៣.១.១៨ ធានាឱ្យប្រាកដថា ការប្តឹងជំទាស់ ឬ/និងតវ៉ា ក្នុងការិយាល័យបោះឆ្នោត ដោយភ្នាក់ងារគណបក្សនយោបាយ ស្របតាមមាត្រា ១១៤ នៃ ច.ប.ត.រ ត្រូវតែបានដោះស្រាយភ្លាម ដោយអនុវត្តស្របតាម ប.ន.ត.រ និងការណែនាំ របស់ គ.ជ.ប ។

៨.៣.១.១៩ ជួយអ្នកបោះឆ្នោតជាជនដែលមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបានតាមការស្នើសុំរបស់សាមីខ្លួន ។

៨.៣.១.២០ ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត។

៨.៣.១.២១ ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្ស នយោបាយ ដែលបានទទួលសំឡេងឆ្នោត ។

៨.៣.១.២២ ប្រគល់ជូន គឃ.សប នូវកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ។

៨.៣.១.២៣ ប្រគល់ជូន គឃ.សប នូវកំណត់ហេតុស្តីពីការបោះឆ្នោត និងហិបឆ្នោត ដែលមានសន្លឹកឆ្នោតខាងក្នុង ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ក្នុងកាល:ទេស:មានអាសន្ន ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះបាន ។

៨.៣.១.២៤ បំពេញការកិច្ចរបស់ខ្លួន ដោយជំហរអព្យាក្រឹត និងមិនលម្អៀង ។

៨.៣.១.២៥ បំពេញការកិច្ចផ្សេងៗទៀតដែល គឃ.សប ប្រគល់ឱ្យ ។

៨.៣.២ អនុប្រធាន គ.ក.ប/គ.ក.រ ត្រូវជួយប្រធាន និងមានភារកិច្ចដោយឡែកដូចខាងក្រោម ៖

៨.៣.២.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣.២.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប ។

៨.៣.២.៣ ជូនតំណែងប្រធាន ក្នុងករណីប្រធានមិនអាចមកបំពេញការងារបាន។

៨.៣.២.៤ រាប់ចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្តែង សម្រាប់ប្រើក្នុងការិយាល័យបោះឆ្នោតមុននឹងបើកកិច្ចប្រតិបត្តិការបោះឆ្នោត ។

៨.៣.២.៥ ហែកសន្លឹកឆ្នោតផ្តាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បោះត្រាសម្ងាត់លើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្នត់តាមការណែនាំរបស់ គ.ជ.ប រួចប្រគល់ជូនអ្នកបោះឆ្នោត ។

៨.៣.២.៦ ផ្តល់ការណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត។

៨.៣.២.៧ អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់ នៅពេលដែលបន្ទប់សម្ងាត់នោះទំនេរ គ្មានអ្នកបោះឆ្នោតផ្សេងទៀត ។

៨.៣.២.៨ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតនៅពេលបញ្ចប់ការបោះឆ្នោត ។

៨.៣.២.៩ ត្រួតពិនិត្យ និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់នៅខាងខ្នង មុននឹងប្រគល់ជូនប្រធាន ។

៨.៣.២.១០ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗ បានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

៨.៣.២.១១ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងរួមជាមួយលេខាធិការពិនិត្យបញ្ជាក់ឡើងវិញអំពីភាពត្រឹមត្រូវ មុនដាក់ជូនប្រធានចុះហត្ថលេខា ដើម្បីចែកជូនភ្នាក់ងារគណបក្សនយោបាយ ដែលមានវត្តមាន ។

៨.៣.២.១២ អមដំណើរប្រធាន ក្នុងការបញ្ជូន និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈ ឯកសារបោះឆ្នោតផ្សេងទៀតជូន គយ.សប ។

៨.៣.២.១៣ បំពេញការកិច្ចផ្សេងទៀត ដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

៨.៣.៣ លេខាធិការនៃ គ.ក.ប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងជាអ្នកទទួលបន្ទុកពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងការបំពេញទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ហើយត្រូវ ៖

៨.៣.៣.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣.៣.២ ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាម ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប ។

៨.៣.៣.៣ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារៈ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣.៣.៤ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

៨.៣.៣.៥ ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បោះឆ្នោត នៅមុនពេលពិនិត្យរកមើលឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត ។

៨.៣.៣.៦ សួរបញ្ជាក់ឈ្មោះ ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពដូចគ្នារវាងរូបពិត ឈ្មោះ និងទិន្នន័យក្នុង អ.ខ ឬ ឯ.អ របស់សាមីអ្នកបោះឆ្នោត ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត រួចគូសសម្គាល់ថាបានមកបោះឆ្នោត ក្នុងកូនប្រអប់បូនជ្រុងទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះលើបញ្ជីបោះឆ្នោត ។

៨.៣.៣.៧ ណែនាំអ្នកបោះឆ្នោត ដែលបានមកបោះឆ្នោត ឱ្យធ្វើសម្គាល់នៅក្នុងបញ្ជីបោះឆ្នោត ត្រង់កន្ទុយឈ្មោះរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ថាសាមីខ្លួនបានមកបោះឆ្នោតរួចហើយ ។

៨.៣.៣.៨ រាប់គំនូសសញ្ញាលើបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងមិនបានបោះឆ្នោត ។

៨.៣.៣.៩ បំពេញកំណត់ហេតុនៃការបោះឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា រួចដាក់បង្ហាញឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល ។

៨.៣.៣.១០ កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកយោបល់តវ៉ ឬជំទាស់ ឬករណីប្តឹងតវ៉ និងប្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣.៣.១១ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត ។

៨.៣.៣.១២ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងរួមជាមួយសមាជិកទី១ ពិនិត្យបញ្ជាក់ឡើងវិញអំពីភាពត្រឹមត្រូវ មុនដាក់ជូនប្រធានចុះហត្ថលេខា ។

៨.៣.៣.១៣ បំពេញការកិច្ចផ្សេងទៀត ដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

៨.៣.៤ សមាជិកទី ១ នៃ គ.ក.ប ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញការកិច្ច ដូចខាងក្រោម ៖

៨.៣.៤.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣.៤.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត ។

៨.៣.៤.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប ។

៨.៣.៤.៤ ត្រួតពិនិត្យហិបឆ្នោត និងការស៊ីកសន្លឹកឆ្នោតចូលក្នុងហិបឆ្នោតក្នុងពេលកំពុងដំណើរការបោះឆ្នោត ។

៨.៣.៤.៥ រាយការណ៍ជូនប្រធាន ក្នុងករណីពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់ បានប៉ុនប៉ងស៊ីកសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលក្នុងហិបឆ្នោត ។

៨.៣.៤.៦ ជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោត ដែលបានបោះឆ្នោតរួច ទៅក្នុងទឹកខ្មៅលុបមិនជ្រះឱ្យដល់គល់ក្រចក និងណែនាំគាត់ឱ្យរង់ចាំ៣០វិនាទី ដើម្បីឱ្យទឹកខ្មៅស្ងួត មុននឹងចេញពីការិយាល័យបោះឆ្នោត ។

៨.៣.៤.៧ រាប់ចំនួនសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីផ្ទៀងផ្ទាត់ទៅនឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងដកយកវត្ថុមិនមែនជាសន្លឹកឆ្នោត (បើមាន) ដាក់ទៅក្នុងស្រោមសំបុត្រដោយឡែក ។

៨.៣.៤.៨ លាសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីត្រួតពិនិត្យស្នាមត្រាសម្ងាត់នៅផ្នែកខាងខ្នង និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់ ។

៨.៣.៤.៩ កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើផ្ទាំងក្រដាសធំ ។

៨.៣.៤.១០ ជួយបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងរួមជាមួយលេខាធិការពិនិត្យបញ្ជាក់ឡើងវិញអំពីភាពត្រឹមត្រូវ មុនដាក់ជូនលេខាធិការ និងប្រធានចុះហត្ថលេខា ដើម្បីចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន។

៨.៣.៤.១១ បំពេញការកិច្ចផ្សេងទៀតដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

៨.៣.៥ សមាជិកទី ២ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

៨.៣.៥.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣.៥.២ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប ។

៨.៣.៥.៣ ជួយរកឈ្មោះអ្នកបោះឆ្នោត នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅខាងក្រៅការិយាល័យបោះឆ្នោត និងប្រាប់លេខរៀងឈ្មោះរបស់គាត់ ។

៨.៣.៥.៤ ចាត់ចែង និងថែរក្សារបៀបរៀបរយជូនអ្នកបោះឆ្នោត (ក្នុងករណីចាំបាច់ អាចផ្តល់បណ្ណលេខរៀងតាមលំដាប់អ្នកមកមុនមកក្រោយ) ព្រមទាំងរាយការណ៍ជូនប្រធាន អំពីការរំខាន ឬការអុកឡុកនានាក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត (បើមាន) ។

៨.៣.៥.៥ រាយការណ៍ជូនប្រធាន ក្នុងករណីពិនិត្យឃើញថា មានអ្នកបោះឆ្នោតណាម្នាក់ បានយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

៨.៣.៥.៦ ប្រមូល អ.ខ ឬ ឯ.អ ពីអ្នកបោះឆ្នោត ដែលស្ថិតក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល បើមាន ។

៨.៣.៥.៧ ចោះ ឬកាត់សន្លឹកឆ្នោត ដែលនៅសល់មិនបានប្រើប្រាស់ បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ។

៨.៣.៥.៨ សហការជាមួយសមាជិកទី ៣ ក្នុងការការពារមាត់ទ្វារការិយាល័យបោះឆ្នោត ការថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

៨.៣.៥.៩ បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

៨.៣.៥.១០ បំពេញការកិច្ចផ្សេងទៀតដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

៨.៣.៦ សមាជិកទី ៣ នៃ គ.ក.ប/គ.ក.រ ត្រូវស្ថិតក្រោមការដឹកនាំរបស់ប្រធាន និងត្រូវបំពេញភារកិច្ចដូចខាងក្រោម ៖

៨.៣.៦.១ ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣.៦.២ ជួយប្រធានក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត ។

៨.៣.៦.៣ ជួយប្រធានក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប ។

៨.៣.៦.៤ ត្រួតពិនិត្យច្រកទ្វារចូលនៃការិយាល័យបោះឆ្នោត ណែនាំអ្នកបោះឆ្នោត ឱ្យឈរបន្តគ្នាជាជួរ តាមលំដាប់មុនក្រោយ ប្រសិនបើគាត់ត្រូវបោះឆ្នោត នៅការិយាល័យបោះឆ្នោតនេះ និងត្រួតពិនិត្យ អ.ខ ឬ ឯ.អ របស់គាត់ ។

៨.៣.៦.៥ អនុញ្ញាតឱ្យអ្នកបោះឆ្នោតមានវត្តមានក្នុងការិយាល័យបោះឆ្នោត ចំនួន ៤ នាក់ ក្នុងពេលតែមួយ ។

៨.៣.៦.៦ ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត ចំពោះអ្នកបោះឆ្នោត ជាព្រះសង្ឆ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច ជនដែលមានពិការភាព និងអ្នកមានជំងឺបន្ទាប់មកគឺអ្នកឈរខាងមុខគេក្នុងជួរ ។

៨.៣.៦.៧ ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត ។

៨.៣.៦.៨ ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការអុកឡុករំខានជូនប្រធាន ។

៨.៣.៦.៩ សហការជាមួយសមាជិកទី ២ ក្នុងការការពារសន្តិសុខនៅច្រកផ្លូវចេញ ចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត។

៨.៣.៦.១០ បំពេញការកិច្ចផ្សេងទៀតដែល គយ.សប និងប្រធាន គ.ក.ប/គ.ក.រ ប្រគល់ឱ្យ ។

ការត្រៀមសម្ភារ ឯកសារបោះឆ្នោត និងការត្រួតពិនិត្យទីតាំងការិយាល័យបោះឆ្នោត

ប្រការ ៨.៤.-

គ.ជ.ប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោត ត្រូវតែបានបញ្ជូន និងប្រគល់ជូន គ.ក.ប មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោងមុនថ្ងៃបោះឆ្នោត ។ នៅពេលព្រឹកនៃថ្ងៃ មុនថ្ងៃបោះឆ្នោត ប្រធាន គ.ក.ប ត្រូវកោះប្រជុំសមាសភាពទាំងអស់នៃ គ.ក.ប ឱ្យមកបង្ហាញខ្លួននៅទីតាំងការិយាល័យបោះឆ្នោត ដើម្បីធ្វើការត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត និងរៀបចំគំរូប្លង់ការិយាល័យបោះឆ្នោត ។

៨.៤.១ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារគ្រប់គ្រាន់ សម្រាប់បម្រើកិច្ចប្រតិបត្តិការនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ជូន គធ.ខប គយ.សប និង គ.ក.ប ទាំងអស់ ។

៨.៤.២ នាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីបោះឆ្នោត ត្រូវទទួលខុសត្រូវក្នុងការផលិតបញ្ជីបោះឆ្នោតផ្លូវការចំនួន ៤ (បួន)ច្បាប់ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ សម្រាប់បែងចែកជូន គយ.សប និង គ.ក.ប ដើម្បីប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៨.៤.៣ នាយកដ្ឋានប្រតិបត្តិការ ត្រូវរៀបចំផែនការបែងចែក និងត្រៀមសម្ភារ ឯកសារសម្រាប់ដឹកជញ្ជូនទៅកាន់គោលដៅនានា ដើម្បីបម្រើការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឱ្យបានគ្រប់គ្រាន់ជាមុន ។ សម្ភារ ឯកសារសម្រាប់បម្រើការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបូកសរុបលទ្ធផលនៃការបោះឆ្នោត ត្រូវបានរៀបចំដាក់ក្នុងហិបដែលរួមមាន ៥ប្រភេទ គឺ ៖

- ៨.៤.៣.១ ហិបបរិក្ខារសម្រាប់បណ្តុះបណ្តាលដែលត្រូវបញ្ជូន និងប្រគល់ជូននាយកដ្ឋានបណ្តុះបណ្តាល និងអប់រំអ្នកបោះឆ្នោត និង គធ.ខប ។
- ៨.៤.៣.២ ហិបបរិក្ខារ គធ.ខប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប ។
- ៨.៤.៣.៣ ហិបបរិក្ខារ គយ.សប ដែលអាចមានមួយ ឬច្រើន ហើយត្រូវបញ្ជូន និងប្រគល់ជូន គយ.សប ។
- ៨.៤.៣.៤ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប ។

៨.៤.៤ នៅរាល់ពេលនៃការបញ្ជូន និងប្រគល់ ទទួលហិបបរិក្ខារ ដូចមានចែងក្រោមចំណុច ៨.៤.៣ ខាងលើ មន្ត្រីដែលទទួលបន្ទុកការបញ្ជូននៅតាមថ្នាក់នីមួយៗ ត្រូវបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) និងត្រូវឱ្យមន្ត្រីដែលទទួលបន្ទុកការទទួលនៅតាមថ្នាក់នីមួយៗ ចុះហត្ថលេខា បញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ ។

៨.៤.៥ ហិបបរិក្ខារ គធ.ខប ដែលត្រូវបញ្ជូន និងប្រគល់ជូន គធ.ខប សម្រាប់ប្រើប្រាស់ ក្នុងដំណើរការបោះឆ្នោត ដូចមានក្នុងឧបសម្ព័ន្ធទី ៦ ។

៨.៤.៦ ហិបបរិក្ខារ គឃ.សប ដែលត្រូវបញ្ជូន និងប្រគល់ជូន គឃ.សប សម្រាប់ប្រើប្រាស់ ក្នុងដំណើរការបោះឆ្នោតទាំងមូល ដូចមានក្នុងឧបសម្ព័ន្ធទី ៧ ។

៨.៤.៧ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងកញ្ចប់សម្ភារ ឧបករណ៍ និងឯកសារផ្សេងទៀត ដូចមានក្នុងឧបសម្ព័ន្ធទី ៨ ដែល គឃ.សប ត្រូវបញ្ជូន និងប្រគល់ជូន គ.ក.ប នីមួយៗ មិនឱ្យលើសពី ៣៦ (សាមសិបប្រាំមួយ) ម៉ោង មុនថ្ងៃបោះឆ្នោត ។

៨.៤.៨ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវធានាក្នុងការបញ្ជូន និងប្រគល់ឱ្យបានគ្រប់គ្រាន់ជូន គ.ក.ប នៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត នូវសម្ភារ ឯកសារបោះឆ្នោតដូចចែងក្នុងចំណុច ៨.៤.៧ ខាងលើ ។ គឃ.សប ត្រូវជូនដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីចូលរួមសង្កេតមើល គ.ក.ប នៅពេលធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោត ដូចចែងក្នុងចំណុច ៨.៤.១០ ខាងក្រោម ។

៨.៤.៩ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវតែមកបង្ហាញខ្លួនតាមការកោះអញ្ជើញ របស់ប្រធាន គ.ក.ប និងត្រូវធានាថា នឹងមានវត្តមានក្នុងការបំពេញការងារនៅថ្ងៃបោះឆ្នោត ។

៨.៤.៩.១ មុនថ្ងៃបោះឆ្នោត ២៤ (ម្ភៃបួន) ម៉ោង ប្រធាន គ.ក.ប ត្រូវប្រជុំមន្ត្រីទាំងអស់ ដើម្បីពិនិត្យវត្តមាន និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារ បរិក្ខារបម្រើឱ្យការបោះឆ្នោត ។ ក្នុងករណីបើមានមន្ត្រីណាម្នាក់អវត្តមាន មន្ត្រីនោះត្រូវជំនួសដោយមន្ត្រីថ្មី ដែលជ្រើសតាំងឡើងតាមការសម្រេចរបស់ គឃ.សប ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ។

៨.៤.៩.២ ប្រសិនបើសមាសភាពណាម្នាក់នៃ គ.ក.ប មិនអាចបំពេញការងារក្នុងថ្ងៃបោះឆ្នោតបាន ប្រធានត្រូវតែជូនដំណឹងដល់ គឃ.សប ជាបន្ទាន់ដើម្បីដាក់ជំនួស ។

៨.៤.៩.៣ ប្រសិនបើប្រធាន មិនអាចមកបំពេញការងារបាន ដោយសារមូលហេតុសំខាន់ណាមួយនោះ អនុប្រធានត្រូវចូលកាន់តំណែងប្រធាន ហើយសមាជិកទី ១ ចូលកាន់តំណែងអនុប្រធាន ចំណែកអ្នកដែលត្រូវជ្រើសរើសថ្មីចេញពីក្នុងចំណោមប្រជាពលរដ្ឋដែលបានដាក់ពាក្យសម្គាសន៍ ត្រូវចូលកាន់តំណែងជួសសមាជិកទី ១ ។

៨.៤.៩.៤ ប្រសិនបើអនុប្រធាន មិនអាចមកធ្វើការបាននោះ ត្រូវតែងតាំងសមាជិកទី ១ ជាអនុប្រធាន ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងកាន់តំណែងជាសមាជិកទី ១ ។

៨.៤.៩.៥ ប្រសិនបើលេខាធិការ មិនអាចមកធ្វើការបាន ត្រូវតែងតាំងសមាជិកទី១ ជាលេខាធិការ ហើយអ្នកដែលត្រូវជ្រើសរើសថ្មី នឹងកាន់តំណែងជាសមាជិកទី ១ ។

៨.៤.៩.៦ សមាសភាពទាំងអស់នៃ គ.ក.ប រួមទាំងអ្នកដែលទើបតែជ្រើសរើសថ្មី ត្រូវរួមគ្នាសិក្សាឡើងវិញ នូវនីតិវិធីនៃការបោះឆ្នោត និងសៀវភៅណែនាំ គ.ក.ប ។

៨.៤.៩.៧ អ្នកតែងតាំងថ្មីទាំងអស់ត្រូវតែបានទទួលការបណ្តុះបណ្តាល និងអនុវត្ត ដូចចែងក្នុងចំណុច ៨.៤.៩.៦ ខាងលើ ។

៨.៤.៩.៨ ប្រធាន គ.ក.ប ត្រូវតែជូនដំណឹងជាបន្ទាន់ដល់ គយ.សប អំពីអ្វីដែលបានអនុវត្តពាក់ព័ន្ធនឹងការដាក់ជួសតំណែងណាមួយនៃ គ.ក.ប។

៨.៤.១០ បន្ទាប់ពីអនុវត្តចំណុច ៨.៤.៩ រួច គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវសម្ភារ ឯកសារបោះឆ្នោតទាំងអស់ដែល គ.ក.ប បានទទួល ហើយដែលមានរាយមុខក្នុងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ។

៨.៤.១០.១ គ.ក.ប ត្រូវធ្វើការត្រួតពិនិត្យឡើងវិញនូវរាល់សម្ភារ ឯកសារបោះឆ្នោត ដោយប្រើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ។

៨.៤.១០.២ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតដែលបានទទួលមានចំនួនគ្រប់គ្រាន់ ហើយ សមាសភាពទាំងអស់នៃ គ.ក.ប ត្រូវចុះហត្ថលេខាលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ។

៨.៤.១០.៣ ប្រសិនបើសម្ភារ ឯកសារបោះឆ្នោតណាមួយ ឬច្រើនដែលបានទទួលនោះមិនមានចំនួនគ្រប់គ្រាន់ លេខាធិការ ត្រូវបំពេញត្រង់ផ្នែកសម្ភារ ឯកសារបោះឆ្នោតដែលបាត់បង់ នៅលើតារាងត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោត (ទ.១១១២) ហើយត្រូវផ្ញើតារាងត្រួតពិនិត្យនេះ ១ (មួយ) ច្បាប់ ជាបន្ទាន់ទៅ គយ.សប ។

៨.៤.១០.៤ ប្រសិនបើ សម្ភារ ឯកសារដែលបាត់បង់ទៅនោះ ជាសម្ភារ ឯកសារសំខាន់ សម្រាប់ការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់សមាជិក ២ (ពីរ)រូប ឱ្យធ្វើដំណើរទៅទីស្នាក់ការ គយ.សប ដើម្បីទទួលសម្ភារ ឯកសារថ្មីជំនួស សម្ភារ ឯកសារដែលខ្វះ ឬបានបាត់បង់ទៅ លើកលែងតែមានវិទ្យុទាក់ទង ឬទូរស័ព្ទដែលអាចបញ្ជូនព័ត៌មានស្នើសុំ គយ.សប ដោះស្រាយបញ្ហាខាងលើបាន ។

៨.៤.១០.៥ ក្នុងការត្រួតពិនិត្យឡើងវិញ នូវសម្ភារ ឯកសារបោះឆ្នោតខាងលើនេះ គ.ក.ប ត្រូវយកចិត្តទុកដាក់ចំពោះមុខសម្ភារ ដូចខាងក្រោម ៖

- ពិនិត្យកញ្ចប់សន្លឹកឆ្នោតឱ្យប្រាកដថា ជាកញ្ចប់សន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់នោះ ហើយគ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ចំនួន និងលេខរៀងដែលបានកត់ត្រានៅលើកញ្ចប់សន្លឹកឆ្នោតប៉ុណ្ណោះ ដោយមិនត្រូវបើកកញ្ចប់សន្លឹកឆ្នោតជាដាច់ខាត ។
- ពិនិត្យស្រោមសំបុត្រដាក់ត្រាសម្ងាត់ឱ្យប្រាកដថា ពិតជាមានត្រាសម្ងាត់នៅខាងក្នុង ប៉ុន្តែមិនត្រូវបើកស្រោមសំបុត្រជាដាច់ខាត ។

៨.៤.១១ សម្ភារ ឯកសារសំខាន់ៗដែល គ.ក.ប មិនបានទទួល ហើយដែលអាចរាំងស្ទះដល់ការបើកការិយាល័យបោះឆ្នោត រួមមាន ៖

៨.៤.១១.១ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។

៨.៤.១១.២ ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

៨.៤.១១.៣ បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

៨.៤.១១.៤ ហិបឆ្នោត និងសោយ៉ូមានលេខ ។

៨.៤.១១.៥ ទឹកខ្មៅលុបមិនជ្រះសម្រាប់ជ្រលក់ម្រាមដៃសម្គាល់ថាបានបោះឆ្នោតហើយ ។

๘.๔.๑๒ សម្ភារ ឯកសារដទៃទៀត ដែលប្រសិនបើមិនបានផ្តល់ដោយ គយ.សប នោះ គ.ក.ប ត្រូវច្នៃបង្កើតឡើង ឬដោះស្រាយដោយខ្លួនឯង ៖

๘.๔.๑๒.๑ កន្ទេល ឬក្រដាសកាតុងក្រាស់ ឬរបស់ផ្សេងទៀតដែលអាចប្រើបិទ បាំងជំនួសបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត ។

๘.๔.๑๒.๒ ក្រដាសសម្រាប់សរសេរកំណត់ហេតុដោយដៃ ដែលអាចជំនួសទម្រង់ បែបបទ សម្រាប់បំពេញកំណត់ហេតុជាគំរូ ។

๘.๔.๑๒.๓ បិកសរសេរ បន្ទាត់ កន្ត្រៃ ខ្សែចង... ។

๘.๔.๑๓ នៅពេលដែលសម្ភារ ឯកសារបោះឆ្នោតមានគ្រប់ចំនួនហើយ ប្រធាន គ.ក.ប ត្រូវ ចាត់សមាជិកទី ២ ឱ្យបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ១ (មួយ) ច្បាប់ និង បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅមុខការិយាល័យបោះឆ្នោត លើកស្លាក ការិយាល័យបោះឆ្នោត និងលេខកូដការិយាល័យបោះឆ្នោត នៅនឹងមាត់ច្រកចូល ការិយាល័យបោះឆ្នោត ។

๘.๔.๑๔ បន្ទាប់ពីបានអនុវត្តចំណុច ៨.៥.១៣ រួច គ.ក.ប ត្រូវរៀបចំការិយាល័យ តាមគំរូប្លង់ ការិយាល័យបោះឆ្នោតដើម្បីឱ្យប្រាកដថា ទីតាំងការិយាល័យបោះឆ្នោតនោះ អាច ដំណើរការបោះឆ្នោតបានហើយដែលអាចរៀបចំឱ្យរួចស្រេចនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹកនៃថ្ងៃបោះឆ្នោត ។

๘.๔.๑๔.๑ គ.ក.ប ត្រូវរៀបចំការិយាល័យបោះឆ្នោតតាមគំរូប្លង់ ឯកភាពគ្នាមួយ ដោយត្រូវគោរពតាមគោលការណ៍ ដូចមានចែងក្នុងសៀវភៅណែនាំ គ.ក.ប/គ.ក.រ ។

๘.๔.๑๔.๒ ប្រសិនបើ គ្មានគ្រឿងសង្ហារិមនៅក្នុងការិយាល័យបោះឆ្នោតទេ ប្រធាន ត្រូវធ្វើសំណើសុំខ្ចីពីអាជ្ញាធរមូលដ្ឋានជាបន្ទាន់ នូវគ្រឿងសង្ហារិម ចាំបាច់មួយចំនួនសម្រាប់បម្រើការបោះឆ្នោតដូចជា តុ កៅអី និង សម្ភារដទៃទៀត ដែលអាចសម្រួលដល់ការងារបោះឆ្នោត ។

๘.๔.๑๔.๓ ប្រធាន ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខយាមកាម រក្សាសន្តិសុខ ទីតាំងការិយាល័យបោះឆ្នោត ហើយប្រសិនបើអាចធ្វើបាន ប្រធាន ត្រូវបិទទ្វារចាក់សោទីតាំងការិយាល័យបោះឆ្នោតនោះផង ។

៨.៤.១៥ ប្រធានរួមជាមួយសមាជិក គ.ក.ប ត្រូវរក្សាការពារសម្ភារ ឯកសារទាំងនោះឱ្យបានហ្មត់ចត់នៅមុនពេលបោះឆ្នោត ។

៨.៤.១៥.១ សម្ភារ ឯកសារបោះឆ្នោតអាចនឹងរក្សាទុកនៅផ្ទះរបស់ប្រធាន ឬសមាជិកណាម្នាក់ ឬនៅទីតាំងណាមួយដែល គ.ក.ប ឯកភាពគ្នាថាមានសុវត្ថិភាព ។

៨.៤.១៥.២ យ៉ាងហោចណាស់ត្រូវមានសមាជិក គ.ក.ប ៣ (បី) នាក់ គិតទាំងប្រធានផងសម្រាកនៅផ្ទះ ឬទីតាំងដែលទទួលរក្សាសម្ភារ ឯកសារបោះឆ្នោត ដើម្បីរួមចំណែកក្នុងការថែរក្សាសុវត្ថិភាព ។

៨.៤.១៥.៣ ប្រធាន គ.ក.ប ត្រូវស្នើសុំឱ្យមានកម្លាំងសន្តិសុខ ដើម្បីរួមសហការការពារបរិវេណខាងក្រៅផ្ទះ ឬទីតាំងដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោត ។

៨.៤.១៦ ប្រធាន គ.ក.ប ត្រូវណាត់ជាមួយសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យមកកាន់ផ្ទះ ឬទីតាំងសុវត្ថិភាពដែលទទួលរក្សាទុកសម្ភារ ឯកសារបោះឆ្នោតនៅម៉ោង ៥:៣០ (ប្រាំសាមសិប) នាទីព្រឹកនៃថ្ងៃបោះឆ្នោតជាកំហិត ដើម្បីដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោតទៅកាន់ទីតាំងការិយាល័យបោះឆ្នោត ។

៨.៤.១៧ សមាជិកទាំងអស់នៃ គ.ក.ប ត្រូវត្រៀមអាហារសម្រាប់រយៈពេល ១ (មួយ) ថ្ងៃ សម្រាប់ហូបនៅពេលទំនេរ ដែលពុំមានអ្នកបោះឆ្នោត ឬនៅពេលណាមួយសមស្រប ។

ទីតាំងរដ្ឋបាល និងសន្តិសុខនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត

ប្រការ ៨.៥.-

ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតគឺជាទីតាំងរដ្ឋបាល និងសន្តិសុខ ដែលមានបរិវេណខាងក្នុង និងបរិវេណខាងក្រៅ ដូចចែងក្រោមប្រការ ៥.៥ ក្នុងជំពូកទី ៥ នៃ ប.ន.ត.រ នេះ ។ ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតត្រូវតែជាកន្លែងដែលមានការត្រួតពិនិត្យ និងយាមកាមយ៉ាងតឹងរ៉ឹងបំផុតក្នុងគោលបំណងនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៥.១ ប្រធាន គ.ក.ប ឬប្រធាន គ.ក.រ ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីការពារអ្នកនៅខាងក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងអ្នកនៅក្នុងបរិវេណខាងក្នុងការិយាល័យទាំងនោះ ឱ្យចៀសផុតពីការបង្កឱ្យមានរបួសស្នាម ការរំខានអុកឡុក ការបំភិតបំភ័យ ឬការគំរាមកំហែង និងរក្សាការពារសម្ភារ ឯកសារបោះឆ្នោតទាំងអស់នៅក្នុងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងនោះ ។

៨.៥.២ ក្របខ័ណ្ឌនៃការិយាល័យបោះឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយ ដែលបានចែងក្នុងប្រការ ៥.៦ និងក្រោមចំណុច ៥.៦.១ ៥.៦.២ ៥.៦.៣ ៥.៦.៥ ៥.៦.៧ និង ៥.៦.៨ ក្នុងជំពូកទី ៥ នៃ ប.ន.ត.រ នេះ ត្រូវតែបានអនុវត្ត ។

៨.៥.៣ ក្របខ័ណ្ឌនៃការិយាល័យរាប់សន្លឹកឆ្នោត វិធានការ និងលក្ខខណ្ឌទាំងឡាយ ដែលបានចែងក្នុងប្រការ ៥.៦ និងក្រោមចំណុច ៥.៦.១ ៥.៦.២ ៥.៦.៤ ៥.៦.៦ ៥.៦.៧ និង ៥.៦.៨ ក្នុងជំពូកទី ៥ នៃ ប.ន.ត.រ នេះ ត្រូវតែបានអនុវត្ត ។

៨.៥.៤ ហាមដាច់ខាតយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងហាមស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេសពីប្រធាន គ.ជ.ប ។

ការប្រព្រឹត្តទៅនៃការបោះឆ្នោត

ប្រការ ៨.៦.

គ.ក.ប ត្រូវចូលដល់ទីតាំងការិយាល័យបោះឆ្នោត ដោយនាំមកជាមួយនូវសម្ភារ ឯកសារបោះឆ្នោត ឱ្យបានទាន់ពេលនៅម៉ោង ៦:00 (ប្រាំមួយ) ព្រឹក នាថ្ងៃបោះឆ្នោតជាកំហិត ដើម្បីគ្រប់គ្រងនិងចាត់ចែងការបោះឆ្នោត ។

៨.៦.១ បន្ទាប់ពី គ.ក.ប បានចូលដល់ក្នុងការិយាល័យបោះឆ្នោតភ្លាម ប្រធាន គ.ក.ប ត្រូវប្រកាសឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិចូលក្នុងការិយាល័យបោះឆ្នោត ដោយធ្វើការត្រួតពិនិត្យបណ្ណសម្គាល់ ឬ/និងសេចក្ដីសម្រេចតែងតាំង និងទទួលស្គាល់ជាផ្លូវការម្នាក់ម្តងៗ រួចប្រាប់ទីកន្លែងដែលបម្រុងទុកសម្រាប់ពួកគេ ដូចមានចែងក្នុងចំណុច ៨.៦.២.៥ ខាងក្រោម ។

៨.៦.២ ទន្ទឹមពេលអនុវត្តចំណុច ៨.៦.១ ខាងលើ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី ២ ឱ្យទៅបំពេញមុខនាទីរបស់ខ្លួននៅបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត ព្រមទាំងត្រូវចាត់ចែងសមាជិកដទៃទៀតនៃ គ.ក.ប ឱ្យរៀបចំគ្រឿងសង្ហារិម និងដាក់សម្ភារឯកសារសម្រាប់ការបោះឆ្នោតដូចបានកំណត់ឯកភាពគ្នា លើគំរូប្លង់ការិយាល័យបោះឆ្នោត ដែលបានរៀបចំមុនមួយថ្ងៃ និងដូចបានបញ្ជាក់នៅក្នុងសៀវភៅណែនាំ គ.ក.ប ។

៨.៦.២.១ តុមួយដាក់នៅប៉ែកខាងឆ្វេងដៃ បន្ទាប់ពីផ្លូវចូលសម្រាប់ប្រធាន ដែលនៅលើនោះមានសម្ភារ ឯកសារបោះឆ្នោត រួមទាំង ទ.១១២០ សម្រាប់អ្នកសង្កេតការណ៍ចុះហត្ថលេខា និង ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹង ។

៨.៦.២.២ តុវែងមួយ ឬតុតូចពីរដាក់នៅប៉ែកខាងស្តាំដៃ បន្ទាប់ពីផ្លូវចូល សម្រាប់លេខាធិការ និងអនុប្រធានអង្គុយជាប់គ្នា ដែលនៅចំកន្លែងលេខាធិការ មានដាក់បញ្ជីបោះឆ្នោត ត្រាការិយាល័យ ទម្រង់បែបបទសម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត និងទម្រង់បែបបទផ្សេងទៀត ហើយនៅចំកន្លែងអនុប្រធានមានដាក់កញ្ចប់សន្លឹកឆ្នោតតាំប៉ុង និងស្រោមសំបុត្រដាក់ត្រាសម្ងាត់ សម្រាប់បោះលើខ្នងសន្លឹកឆ្នោត ។

៨.៦.២.៣ បន្ទប់សម្ងាត់សម្រាប់បិទបាំងការគូសសន្លឹកឆ្នោតចំនួន ២ (ពីរ) ដែលមានបិកចងខ្សែភ្ជាប់ស្រាប់ ដាក់នៅលើតុពីរក្បែរជញ្ជាំងប្រមាណ ១,៥០ (មួយម៉ែត្រហាសិប) ពីជញ្ជាំង និងមានចម្ងាយពីគ្នាយ៉ាងតិច ១ (មួយ) ម៉ែត្រ ប៉ុន្តែមិនត្រូវដាក់នៅក្បែរបង្អួចទេ ។ ផ្ទាំងក្រដាស សម្រាប់ទ្រាប់គូសសន្លឹកឆ្នោត ១ (មួយ) សន្លឹក ត្រូវបិទភ្ជាប់ទៅនឹងផ្ទៃតុនៃបន្ទប់សម្ងាត់នីមួយៗ ។ បន្ទប់សម្ងាត់ត្រូវមានពន្លឺគ្រប់គ្រាន់ ។

៨.៦.២.៤ ហិបឆ្នោត ទឹកខ្មៅលុបមិនជ្រះ និងកំណាត់សម្រាប់ជូត ដាក់នៅលើតុវែងមួយ ដែលស្ថិតនៅត្រង់កណ្តាលបន្ទប់ ទល់មុខតុរបស់ប្រធានសម្រាប់សមាជិកទី១ ។

៨.៦.២.៥ តុ និងកៅអីសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ (បើមាន) ដាក់នៅអែបជញ្ជាំង ប៉ែកខាងឆ្វេងដៃនៃតុរបស់ប្រធាន និងនៅក្រោយតុអនុប្រធាន និងលេខាធិការ ។

៨.៦.២.៦ ហិបបរិក្ខារបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលមានសម្ភារ ឯកសារមិនទាន់ត្រូវប្រើប្រាស់ ត្រូវរក្សាទុកនៅក្បែរតុប្រធាន ។

៨.៦.៣ ពេលអនុវត្តចំណុច ៨.៦.១ និង ៨.៦.២ រួចរាល់ ប្រធានត្រូវពន្យល់ណែនាំជារួម ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ដោយសង្ខេបអំពីខ្លឹមសារសំខាន់ៗ ដែលត្រូវអនុវត្តដូចខាងក្រោម ៖

៨.៦.៣.១ ត្រូវគោរព ច.ប.ត.រ ប.ន.ត.រ ក្រមសីលធម៌សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយក្នុងដំណើរការបោះឆ្នោត ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត និងក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត ដែលកំណត់ដោយ គ.ជ.ប ។

៨.៦.៣.២ ត្រូវតាមដានជាប្រចាំកិច្ចប្រតិបត្តិការ និងនីតិវិធីនៃការបោះឆ្នោត បង្ការក្រែងមានករណីមិនប្រក្រតីក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ។

៨.៦.៣.៣ ជួយពិនិត្យ និងតាមដាន ដើម្បីបង្ការ និងទប់ស្កាត់ការបន្លំនាំយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត ។

៨.៦.៣.៤ មិនត្រូវណែនាំ ឬស្តីបន្ទោសអ្វីដល់សមាសភាព គ.ក.ប/គ.ក.រ ។

៨.៦.៣.៥ មិនត្រូវណែនាំ ឬសាកសួរអ្វីចំពោះអ្នកបោះឆ្នោត ។

៨.៦.៣.៦ មិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើយ ។

៨.៦.៣.៧ ត្រូវលើកសំណូរ សំណូមពរផ្សេងៗ ឬ/និងយោបល់ជំទាស់ដោយផ្ទាល់ទៅប្រធាន គ.ក.ប/គ.ក.រ ចំពោះភ្នាក់ងារគណបក្សនយោបាយ ។

៨.៦.៣.៨ ត្រូវបំពេញវត្តមានអ្នកសង្កេតការណ៍ ក្នុងពេលបោះឆ្នោត (ទ.១១២០) ដោយត្រូវបញ្ជាក់ឈ្មោះសាមីអង្គការ ម៉ោងចូល ម៉ោងចេញ និងចុះហត្ថលេខា ។

៨.៦.៣.៩ ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ចូលតាមទីកន្លែង ដូចបានកំណត់ក្នុងចំណុច ៨.៦.២.៥ ខាងលើ ។

៨.៦.៤ នៅចន្លោះពីម៉ោង ៦:០០ (ប្រាំមួយ) ដល់ម៉ោង ៦:៣០ (ប្រាំមួយសាមសិប) ព្រឹកនៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតជូនអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោត តាមនីតិវិធីដូចខាងក្រោម ៖

៨.៦.៤.១ ប្រធានត្រូវពិនិត្យឡើងវិញនូវហិបឆ្នោត ដើម្បីឱ្យប្រាកដថាត្រូវបានដំឡើងត្រឹមត្រូវតាមការណែនាំ ។

៨.៦.៤.២ ប្រធានត្រូវបើកគម្របក្រៅ និងគម្របក្នុងនៃហិបឆ្នោត រួចបង្ហាញហិបឆ្នោតទទេ ចំពោះអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវបិទគម្របក្នុងនៃហិបឆ្នោតទៅវិញ មូលភ្ជិតគម្របសន្ទះ បិទប្រឡោះសម្រាប់បោះឆ្នោត ហើយខ្ទាស់គន្លឹះគម្របក្នុងរួចចាក់សោឃ្លុំ និងប្រាប់លេខាធិការ ឱ្យកត់ត្រាលេខសោឃ្លុំក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ។

៨.៦.៤.៣ ប្រធានត្រូវយកក្រដាសលេខកូដការិយាល័យបោះឆ្នោត ២ (ពីរ) សន្លឹក និងបោះត្រាការិយាល័យបោះឆ្នោត រួចបិទភ្ជាប់ទៅនឹងជញ្ជាំងមុខក្រោយនៃហិបឆ្នោត ហើយបន្ទាប់មក អនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល និងកត់ចំណាំហិបឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

៨.៦.៤.៤ លេខាធិការត្រូវកត់ត្រាពេលម៉ោងនៃការពិនិត្យហិបឆ្នោត នៅលើកំណត់ហេតុនៃការបោះឆ្នោត ។

៨.៦.៥ ហិបឆ្នោតដែលបានបិទសម្គាល់លេខកូដការិយាល័យបោះឆ្នោត និងចាក់សោឃ្លុំ រួចហើយ ដូចមានចែងក្នុងចំណុច ៨.៦.៤ ខាងលើ គ.ក.ប ត្រូវធានាដូចខាងក្រោម ៖

៨.៦.៥.១ មិនអនុញ្ញាតឱ្យបើកចំហដាច់ខាត លើកលែងតែក្នុងបំណងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់ពីការបោះឆ្នោតបានបញ្ចប់ ។

៨.៦.៥.២ មិនអនុញ្ញាតឱ្យយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែ គ.ជ.ប សម្រេចឱ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ក្នុងករណីប្រធានសក្តិ ឬកាលៈទេសៈមានអាសន្ន ។

៨.៦.៦ ប្រសិនបើ សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោត ត្រូវបានប្រគល់ ទទួលនៅក្រោយម៉ោង ៦:៣០ (ប្រាំមួយសាមសិប) ប៉ុន្តែមិនហួសពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក ប្រធាន គ.ក.ប ត្រូវព្យួរការអនុវត្តនីតិវិធីដូចចែងក្រោមចំណុច ៨.៦.៧ នៅការិយាល័យបោះឆ្នោតនោះជាបណ្តោះអាសន្នសិន រហូតទាល់តែនីតិវិធីដូចមានចែងក្រោមចំណុច ៨.៦.៤ ខាងលើ ត្រូវបានបំពេញចប់សព្វគ្រប់ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាអំពីពេលម៉ោងនៃការអនុវត្តនីតិវិធីបោះឆ្នោតនីមួយៗទៅក្នុងកំណត់ហេតុនៃការបោះឆ្នោតឱ្យបានច្បាស់លាស់ ។

៨.៦.៧ នៅចន្លោះពីម៉ោង ៦:៣០ (ប្រាំមួយសាមសិប) ដល់ម៉ោង ៧:០០ (ប្រាពីរ) ព្រឹក នៃថ្ងៃបោះឆ្នោត គ.ក.ប ត្រូវត្រួតពិនិត្យ និងរាប់ចំនួនសន្លឹកឆ្នោត ដែលទទួលជាក់ស្តែង ព្រមទាំងត្រួតពិនិត្យ និងបង្ហាញគ្រាសម្ងាត់ផ្លូវការសម្រាប់ការិយាល័យបោះឆ្នោតនោះ ចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមាន ។

៨.៦.៧.១ អនុប្រធានត្រូវត្រួតពិនិត្យមើលកញ្ចប់សន្លឹកឆ្នោត ដើម្បីឱ្យប្រាកដថា សន្លឹកឆ្នោតនេះ ជាសន្លឹកឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃមណ្ឌលរាជធានី ខេត្តរបស់ខ្លួនប្រាកដមែន ។ ក្នុងករណីពិនិត្យឃើញថា សន្លឹកឆ្នោតនេះមិនមែនជាសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៃមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធទេ គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់តាមរយៈ គយ.សប និង គធ.ខប ជូន គ.ជ.ប ដើម្បីមានវិធានការដោះស្រាយ ។

៨.៦.៧.២ បន្ទាប់មក អនុប្រធានត្រូវបើកកញ្ចប់សន្លឹកឆ្នោត រួចរាប់សន្លឹកឆ្នោត ដែលជាធម្មតាមានចំនួនលើសចំនួនអ្នកបោះឆ្នោត ដែលមានក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ក្នុងចន្លោះពី ២៥ (ម្ភៃប្រាំ) ដល់ ៧៤ (ចិតសិបបួន) សន្លឹក ។

៨.៦.៧.៣ លេខាធិការត្រូវកត់ត្រាចំនួនសន្លឹកឆ្នោត ដែលបានរាប់ឃើញជាក់ស្តែង ព្រមទាំងលេខរៀងសន្លឹកឆ្នោតដំបូងនៃក្បាលទី១ និងលេខរៀងសន្លឹកឆ្នោតចុងក្រោយនៃក្បាលចុងក្រោយ ទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត ។ ទោះបីសន្លឹកឆ្នោតរាប់ឃើញជាក់ស្តែងមានចំនួនលើស ឬខ្វះ ធៀបនឹងចំនួនសន្លឹកឆ្នោតដែលត្រូវប្រគល់ឱ្យក្តី ក៏លេខាធិការត្រូវកត់ត្រាចំនួនដែលលើស ឬខ្វះនោះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោតដែរ ។

៨.៦.៧.៤ លេខាធិការត្រូវពិនិត្យចំនួនអ្នកបោះឆ្នោត ដែលមាននៅក្នុងបញ្ជីបោះឆ្នោត និងកត់ត្រាចំនួននេះទៅក្នុងកំណត់ហេតុនៃការបោះឆ្នោត។

៨.៦.៧.៥ ប្រធានត្រូវបើកស្រោមសំបុត្រ ដែលមានគ្រាសម្ងាត់សម្រាប់បោះ នៅលើខ្នងសន្លឹកឆ្នោត រួចដកយកគ្រានោះមកបោះសាកល្បងនៅលើក្រដាសធម្មតាពណ៌ស និងលើកបង្ហាញអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោតទាំងអស់ឱ្យបានឃើញច្បាស់ និងចំណាំបានរូបសញ្ញានៃគ្រានោះ ។

៨.៦.៨ ប្រធាន គ.ក.ប ត្រូវប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួន នៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក នៃថ្ងៃបោះឆ្នោត និងអញ្ជើញសមាសភាព គ.ក.ប ឱ្យបោះឆ្នោតមុនគេបង្អស់ រួចបន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកយកព័ត៌មាន ប្រសិនបើអ្នកទាំងនេះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។ ផ្អែកតាមករណីដូចមានចែងក្នុងចំណុច ៨.៦.៦ ខាងលើ ប្រសិនបើប្រធាន គ.ក.ប មិនអាចប្រកាសបើកការិយាល័យបោះឆ្នោតនៅម៉ោង ៧:០០ (ប្រាំពីរ) ព្រឹកបាន គាត់អាចប្រកាសបើកការិយាល័យបោះឆ្នោតនៅក្រោយម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក ប៉ុន្តែមិនត្រូវឱ្យហួសពីម៉ោង ៨:០០ (ប្រាំបី) ព្រឹកឡើយ។

៨.៦.៩ សមាជិកទី២ ត្រូវបន្តចាត់ចែងសណ្តាប់ធ្នាប់អ្នកបោះឆ្នោត នៅបរិវេណខាងក្នុង ដោយជួយរកឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ប្រាប់លេខរៀង ឈ្មោះរបស់អ្នកបោះឆ្នោត ចេញក្រដាសលេខរៀងតាមលំដាប់មុនក្រោយ និងណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តកន្ទុយគ្នាជាជួរ ។

៨.៦.១០ បន្ទាប់ពីប្រធាន គ.ក.ប ប្រកាសបើកការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ សមាជិកទី ៣ ដែលប្រចាំការនៅត្រង់មាត់ទ្វារ ត្រូវជម្រាបអ្នកបោះឆ្នោត ដែលកំពុងឈរជាជួរបន្តគ្នាតម្រង់ទៅកាន់មាត់ទ្វារចូលការិយាល័យបោះឆ្នោត អំពីអាទិភាពក្នុងការចូលបោះឆ្នោតតាមលំដាប់លំដោយគឺ ព្រះសង្ឆ ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ ស្ត្រីមានកូនតូច អ្នកមានជំងឺ ជនដែលមានពិការភាពមិនអាចបោះឆ្នោតបានដោយខ្លួនឯង និងអ្នកជំនួយអមដំណើរជនដែលមានពិការភាពនោះ ព្រមទាំងអ្នកឈរក្នុងជួរខាងមុខគេ។ សមាជិកទី៣ អាចសួររំលឹកអ្នកបោះឆ្នោតថាបានស្នើឱ្យសមាជិកទី ២ ជួយរកឈ្មោះ និងឃើញឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតនេះហើយឬនៅ ។ សមាជិកទី៣ ត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោត មានវត្តមានក្នុងការិយាល័យបោះឆ្នោតតែចំនួន ៤ (បួន) នាក់ ក្នុងពេលតែមួយ ដោយត្រូវយកចិត្តទុកដាក់ដូចខាងក្រោម ៖

៨.៦.១០.១ ត្រូវពិនិត្យមើលអ្នកបោះឆ្នោតមាន អ.ខ ឬ ឯ.អ សម្រាប់បោះឆ្នោតឬទេ ?

៨.៦.១០.២ ត្រូវពិនិត្យមើលម្រាមដៃអ្នកបោះឆ្នោត ដែលពិតជាពុំមានស្នាមទឹកខ្មៅលុបមិនជ្រះមែន ។ ករណីឃើញមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះ ត្រូវនាំគាត់ទៅជួបប្រធាន គ.ក.ប ។

៨.៦.១០.៣ ត្រូវជម្រាបអ្នកបោះឆ្នោតដែលចូលក្នុងការិយាល័យបោះឆ្នោត ឱ្យដើរតម្រង់ទៅតុលេខាធិការ និងអនុប្រធាន និងឱ្យបង្ហាញ អ.ខ ឬ ឯ.អ ទៅលេខាធិការ ។

៨.៦.១១ នៅពេលអ្នកបោះឆ្នោតចូលមកដល់លេខាធិការ ត្រូវសុំឱ្យអ្នកបោះឆ្នោតបង្ហាញ អ.ខ ឬ ឯ.អ របស់ខ្លួន ។ ពេលនោះ លេខាធិការត្រូវ ៖

៨.៦.១១.១ ត្រួតពិនិត្យម្រាមដៃរបស់អ្នកបោះឆ្នោត ដើម្បីបញ្ជាក់ឱ្យប្រាកដថាគ្មានស្នាមទឹកខ្មៅលុបមិនជ្រះជាប់នៅលើម្រាមដៃគាត់ទេ ។

៨.៦.១១.២ ពិនិត្យមើលលេខរៀងនៅលើបណ្ណព័ត៌មាន (បើមាន) ដើម្បីរកឈ្មោះអ្នកបោះឆ្នោត រួចប្រគល់បណ្ណព័ត៌មានជូនអ្នកបោះឆ្នោតវិញ ។ បន្ទាប់មកសួរបញ្ជាក់ឈ្មោះ ពិនិត្យផ្ទៀងផ្ទាត់ អ.ខ ឬ ឯ.អ របស់គាត់ជាមួយនឹងរូបពិត រួចពិនិត្យផ្ទៀងផ្ទាត់ជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យពាក់ព័ន្ធនៅក្នុងបញ្ជីបោះឆ្នោត ។

៨.៦.១១.៣ ដាក់បន្ទាត់តម្រង់តាមបណ្តោយជួរឈ្មោះរបស់គាត់ និងគូសសញ្ញាធិកបញ្ជាក់ការបានមកបោះឆ្នោតរបស់អ្នកបោះឆ្នោត ក្នុងកូនប្រអប់ទំនេរនៅប៉ែកខាងដើម ទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះ ។

៨.៦.១១.៤ ណែនាំអ្នកបោះឆ្នោតឱ្យគូសសញ្ញាធិកនៅចុងឈ្មោះរបស់គាត់ ក្នុងបញ្ជីបោះឆ្នោត រួចហុច អ.ខ ឬ ឯ.អ របស់គាត់បន្តទៅឱ្យអនុប្រធាន ប្រសិនបើឈ្មោះ និងទិន្នន័យក្នុង អ.ខ ឬ ឯ.អ របស់អ្នកបោះឆ្នោតដូចគ្នានឹងឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត ។

៨.៦.១១.៥ ប្រាប់អ្នកបោះឆ្នោតឱ្យទៅទទួលយកសន្លឹកឆ្នោតពីអនុប្រធាន ។

៨.៦.១២ ប្រសិនបើ ក្នុងពេលអនុវត្តក្រោមចំណុច ៨.៦.១១ លេខាធិការបានរកឃើញថាអ្នកបោះឆ្នោតមានស្នាមប្រឡាក់ទឹកខ្មៅលុបមិនជ្រះជាប់នៅនឹងម្រាមដៃ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា ត្រូវជូនអ្នកបោះឆ្នោតនោះទៅជួបប្រធាន គ.ក.ប ដើម្បីរាយការណ៍អំពីករណីនេះ ។

៨.៦.១២.១ ប្រធានត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ឱ្យមកធ្វើការកត់សម្គាល់អំពីបញ្ហានេះ ហើយត្រូវឱ្យអ្នកបោះឆ្នោតរូបនេះ ពន្យល់អំពីស្នាមទឹកខ្មៅលុបមិនជ្រះ ដែលមានជាប់នឹងម្រាមដៃរបស់គាត់ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នា ។

៨.៦.១២.២ ប្រសិនបើអ្នកបោះឆ្នោតនោះ មិនអាចផ្តល់ការពន្យល់របស់ខ្លួនបានសមហេតុផលអំពីបញ្ហាទឹកខ្មៅ ឬរូបថតមិនដូចគ្នា ឬឈ្មោះ និងទិន្នន័យមិនដូចគ្នានេះទេ នោះគាត់នឹងត្រូវបានសន្និដ្ឋានថា មានបំណងបោះឆ្នោតលើសពីមួយដង ឬមានចេតនាទុច្ចរិតក្នុងការបោះឆ្នោតដែលត្រូវមានទោសតាមច្បាប់ ។

៨.៦.១២.៣ ប្រធានត្រូវដកហូត អ.ខ ឬ ឯ.អ របស់គាត់ជាបណ្តោះអាសន្ន ហើយបញ្ជូនទៅ គយ.សប ដើម្បីចាត់វិធានការបន្ត ។

៨.៦.១២.៤ លេខាធិការត្រូវកត់ត្រាទុកអំពីហេតុការណ៍នេះ នៅក្នុងកំណត់ហេតុនៃការបោះឆ្នោត និងត្រូវស្រង់ឈ្មោះ និងទិន្នន័យពី អ.ខ ឬ ឯ.អ របស់ជននោះ សម្រាប់ជាការតាមដានបន្ថែមទៀត ។

៨.៦.១២.៥ ប្រសិនបើអ្នកបោះឆ្នោតនោះ មិនយល់ព្រមតាមការអនុវត្តនីតិវិធីខាងលើ ប្រធាន គ.ក.ប ឬ គយ.សប ត្រូវស្នើសុំអាជ្ញាធរមានសមត្ថកិច្ចឱ្យឃាត់ខ្លួនជននោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

៨.៦.១៣ ប្រសិនបើ ក្នុងពេលអនុវត្តចំណុច ៨.៦.១១.២ លេខាធិការមិនឃើញមានឈ្មោះអ្នកបោះឆ្នោតនៅក្នុងបញ្ជីបោះឆ្នោតទេ ត្រូវជូនអ្នកបោះឆ្នោតនោះ ទៅជួបប្រធាន គ.ក.ប និងរាយការណ៍អំពីករណីនេះជូនប្រធាន ។

៨.៦.១៣.១ ប្រធានត្រូវប្រាប់អ្នកបោះឆ្នោតនោះថា គាត់មិនអាចបោះឆ្នោតបានឡើយ ពីព្រោះគាត់គ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត នៃការិយាល័យបោះឆ្នោតនោះ ទោះបីជាគាត់មាន អ.ខ ឬ ឯ.អ ក៏ដោយ។

៨.៦.១៣.២ ប្រសិនបើជាករណីច្រឡំការិយាល័យបោះឆ្នោត ប្រធានអាចសួررកបណ្ណព័ត៌មានអ្នកបោះឆ្នោតរបស់គាត់ដើម្បីផ្ទៀងផ្ទាត់ និងត្រូវណែនាំគាត់អំពីទីតាំងការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ដែលឈ្មោះរបស់គាត់មានក្នុងបញ្ជីបោះឆ្នោត ។

៨.៦.១៣.៣ ប្រធានត្រូវប្រាប់គាត់ឱ្យចេញពីការិយាល័យបោះឆ្នោត ។

៨.៦.១៤ បន្ទាប់ពីអនុវត្តនីតិវិធី ដូចមានចែងក្រោមចំណុច ៨.៦.១១ រួច អនុប្រធានត្រូវហែកសន្លឹកឆ្នោត ១ (មួយ) សន្លឹកចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្ទត់ តាមការកំណត់របស់ គ.ជ.ប ហើយប្រគល់ជូនអ្នកបោះឆ្នោតរួមជាមួយ អ.ខ ឬ ឯ.អ របស់គាត់ផង ។ អនុប្រធានមិនត្រូវប្រគល់សន្លឹកឆ្នោត និងមិនត្រូវអនុញ្ញាតឱ្យអ្នកបោះឆ្នោតបន្ទាប់ ចូលក្នុងបន្ទប់សម្ងាត់ទេ ប្រសិនបើអ្នកបោះឆ្នោតមុនមិនទាន់ចេញផុតពីបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោតនៅឡើយ ។ នៅពេលប្រគល់សន្លឹកឆ្នោតជូនអ្នកបោះឆ្នោតរួចហើយ អនុប្រធានត្រូវណែនាំជាសង្ខេបជូនអ្នកបោះឆ្នោត ដូចខាងក្រោម ៖

៨.៦.១៤.១ នេះគឺជាសន្លឹកឆ្នោត ។

៨.៦.១៤.២ អ្នកត្រូវដើរទៅកាន់បន្ទប់សម្ងាត់ ប្រើបិកដែលមាននៅទីនោះស្រាប់ ឬបិកផ្ទាល់ខ្លួន (លើកលែងតែខ្មៅដៃ) អ្នកត្រូវគូសសញ្ញាគាំទ្រនៅក្នុងប្រឡោះបួនជ្រុងទ្រវែងនៃគណបក្សនយោបាយដែលអ្នកពេញចិត្ត ។ អ្នកត្រូវគិតពិចារណាឱ្យបានហ្មត់ចត់ មុននឹងគូសសញ្ញាគាំទ្រ ដើម្បីបង្ការការខូចសន្លឹកឆ្នោត ដោយសារការផ្លាស់ប្តូរចិត្ត បន្ទាប់ពីបានគូសសញ្ញារួច ។

៨.៦.១៤.៣ មុននឹងចេញពីបន្ទប់សម្ងាត់ អ្នកត្រូវបត់សន្លឹកឆ្នោតតាមផ្ទត់ដើមដើម្បីឱ្យសញ្ញាដែលអ្នកបានគូសស្ថិតនៅក្នុងផ្ទត់ មិនអាចមើលឃើញ និងឱ្យរូបសញ្ញានៃត្រាសម្ងាត់ស្ថិតនៅខាងក្រៅ ។

៨.៦.១៥ បន្ទាប់ពីទទួលបានសន្លឹកឆ្នោត អ្នកបោះឆ្នោតមិនត្រូវសួរអ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឬ/និងមិនត្រូវធ្វើសកម្មភាពណាមួយ ដែលរំលោភទៅលើការសម្ងាត់នៃការបោះឆ្នោតឡើយ ។

៨.៦.១៥.១ អ្នកបោះឆ្នោតមិនត្រូវសួរនាំ ឬប្រាប់អ្នកណាម្នាក់ក្នុងការិយាល័យបោះឆ្នោត ឱ្យដឹងអំពីគណបក្សនយោបាយជាក់លាក់ណាមួយដែលគាត់ពេញចិត្ត ឬមិនពេញចិត្តឡើយ ។

៨.៦.១៥.២ អ្នកបោះឆ្នោតទូទៅ ទោះបីមិនចេះអក្សរក៏ដោយ ក៏មិនអាចស្នើសុំជំនួយពីជនណាម្នាក់ ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោតឱ្យជួយគាត់ក្នុងការបោះឆ្នោតឡើយ លើកលែងតែអ្នកបោះឆ្នោតជាជនដែលមានពិការភាព ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯងដូចមានចែងក្នុងចំណុច ៨.៦.១៨ ខាងក្រោម ។

៨.៦.១៥.៣ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលនៅក្នុងការិយាល័យបោះឆ្នោត មិនត្រូវបានអនុញ្ញាតឱ្យជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតទេ ទោះបីអ្នកបោះឆ្នោតនោះស្នើសុំឱ្យជួយក៏ដោយ ។

៨.៦.១៥.៤ ហាមអ្នកបោះឆ្នោត និងអ្នកមានវត្តមានក្នុងការិយាល័យបោះឆ្នោតប្រើទូរស័ព្ទដៃ ឬ/និងម៉ាស៊ីនថត ឬ/និងឧបករណ៍ផ្សេងទៀត ដែលអាចថតរូបបាន និងហាមធ្វើសកម្មភាពរំលោភលើការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត ។ អ្នកសារព័ត៌មាន ដែលទទួលស្គាល់ដោយ គ.ជ.ប និងបានការអនុញ្ញាតពីប្រធាន គ.ក.ប អាចថតសកម្មភាពនៅការិយាល័យបោះឆ្នោត ប៉ុន្តែមិនត្រូវរំលោភលើការសម្ងាត់នៃការបោះឆ្នោត ។

៨.៦.១៦ បន្ទាប់ពីទទួលបានសន្លឹកឆ្នោត និងអនុវត្តតាមការណែនាំរបស់អនុប្រធាន ដូចមានចែងក្នុងចំណុច ៨.៦.១៤.២ និង ៨.៦.១៤.៣ ខាងលើរួច អ្នកបោះឆ្នោតត្រូវចេញពីបន្ទប់សម្ងាត់ ហើយដើរតម្រង់ទៅតុដាក់ហិបឆ្នោត ។

៨.៦.១៦.១ អ្នកបោះឆ្នោតត្រូវបង្ហាញសន្លឹកឆ្នោតរបស់ខ្លួន ដែលបានបត់រួចនោះដោយដាក់បែរផ្នែកខាងខ្នង ដែលមានបោះត្រាសម្ងាត់ទៅរកសមាជិកទី១ ហើយសិកវាដោយខ្លួនឯង តាមប្រហោះតូចចូលទៅក្នុងហិបឆ្នោត លើកលែងតែអ្នកបោះឆ្នោតជាជនដែលមានពិការភាពមិនអាចសិកដោយខ្លួនឯងបាន ។

៨.៦.១៦.២ ស្របពេលដែលអ្នកបោះឆ្នោតបង្ហាញសន្លឹកឆ្នោត ដែលបត់រួចបម្រុងនឹងសិកទៅក្នុងហិបឆ្នោត សមាជិកទី ១ ត្រូវពិនិត្យឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតផ្លូវការតែមួយសន្លឹក ដែលមានបោះត្រាសម្ងាត់ជាផ្លូវការសម្រាប់ការិយាល័យនោះ ។

៨.៦.១៦.៣ បន្ទាប់មក អ្នកបោះឆ្នោតត្រូវយល់ព្រមឱ្យសមាជិកទី ១ ជ្រលក់ម្រាមចង្អុលដៃស្តាំ ឬម្រាមផ្សេងទៀត ប្រសិនបើម្រាមចង្អុលដៃស្តាំពិការ ចូលទៅក្នុងដបទឹកខ្មៅលុបមិនជ្រះឱ្យលិចដល់គល់ក្រចក ដូចដែលកំណត់ក្រោមចំណុច ៨.៦.១៧ ខាងក្រោម ។

៨.៦.១៦.៤ ប្រសិនបើ សមាជិកទី១ ពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បានស៊ីកសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលទៅក្នុងហិបឆ្នោត ត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប ។ ក្នុងករណីនេះ ប្រធាន គ.ក.ប ត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត មុននឹងចាត់វិធានការឆែកឆេរកសន្លឹកឆ្នោតផ្លូវការ ។

៨.៦.១៦.៥ ប្រសិនបើមានអ្នកបោះឆ្នោតណាម្នាក់ ដែលត្រូវបានចាប់ភស្តុតាងបានថា មានបំណងស៊ីកសន្លឹកឆ្នោតក្លែងក្លាយ ឬ/និងវត្ថុផ្សេងទៀត ឬ/និងសន្លឹកឆ្នោតលើសពី ១ (មួយ) សន្លឹក ទៅក្នុងហិបឆ្នោត ឬ/និងលាក់ទុកសន្លឹកឆ្នោតផ្លូវការ ដើម្បីនាំចេញទៅក្រៅការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតនោះត្រូវតែមានទោស ដោយផ្អែកតាម ច.ប.ត.រ ។

៨.៦.១៦.៦ ប្រធាន គ.ក.ប ត្រូវឃាត់អ្នកបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៨.៦.១៦.៥ ខាងលើ មិនឱ្យបោះឆ្នោត រួចដកហូតសន្លឹកឆ្នោតមិនត្រឹមត្រូវទាំងនោះ និងឆែកឆេរកសន្លឹកឆ្នោតផ្លូវការ (បើមាន) ដាក់ទៅក្នុងស្រោមសំបុត្រមានកាខ្ជងថា " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " បន្ទាប់មកត្រូវដកហូត អ.ខ ឬ ឯ.អ របស់ជននោះ ជាបណ្តោះអាសន្ន ព្រមទាំងចាត់ចែងឱ្យធ្វើកំណត់ហេតុ និងបំពេញទម្រង់បែបបទប្តឹងចោទប្រកាន់ជនប្រព្រឹត្តអំពើល្មើសទៅ គយ.សប ។

៨.៦.១៦.៧ ប្រសិនបើជនដែលបានប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ហើយបើមានភស្តុតាងគ្រប់គ្រាន់នោះ គយ.សប ត្រូវបន្តប្តឹងទៅ គធ.ខប និង គ.ជ.ប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

៨.៦.១៧ ទឹកខ្មៅលុបមិនជ្រះដែលអាចមើលឃើញច្បាស់ ត្រូវបានដាក់បញ្ញត្តិឱ្យប្រើក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់បង្ការការបោះឆ្នោតលើសពី ១ (មួយ) ដង ។

៨.៦.១៧.១ ក្នុងការិយាល័យបោះឆ្នោតនីមួយៗ ត្រូវបានផ្គត់ផ្គង់ទឹកខ្មៅលុបមិនជ្រះ ចំនួន ២ (ពីរ) ដប ។

៨.៦.១៧.២ ដបទឹកខ្មៅលុបមិនជ្រះ ១ (មួយ) ដប ត្រូវបានបើកគម្របប្រើនៅពេលបើកការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងបម្រុងទុក ១ (មួយ) ដប សម្រាប់ប្រើនៅពេលអស់ទឹកខ្មៅដបទីមួយ ។

៨.៦.១៧.៣ បន្ទាប់ពីអ្នកបោះឆ្នោតបានសិកសន្លឹកឆ្នោតរបស់ខ្លួនទៅក្នុងហិបឆ្នោត និងនៅមុនពេលគាត់ដើរចេញពីការិយាល័យបោះឆ្នោត គាត់ត្រូវយល់ព្រមឱ្យសមាជិកទី ១ ជ្រលក់ម្រាមចង្អុលដៃស្តាំរបស់គាត់ទៅក្នុងដបទឹកខ្មៅលុបមិនជ្រះឱ្យលិចដល់គល់ក្រចក និងរង់ចាំឱ្យស្ងួតបន្តិចប្រមាណ ៣០ វិនាទី ទើបអនុញ្ញាតឱ្យគាត់ចេញពីការិយាល័យបោះឆ្នោត ។

៨.៦.១៧.៤ ក្នុងករណី ម្រាមចង្អុលដៃស្តាំពិការ អ្នកបោះឆ្នោតត្រូវប្រើម្រាមដៃផ្សេងណាមួយតាមលំដាប់លំដោយដូចតទៅ ៖ ម្រាមចង្អុលខ្មោចស្តាំ ឬនាងដៃស្តាំ ឬកូនដៃស្តាំ ឬមេដៃស្តាំ ឬមេដៃឆ្វេង ឬចង្អុលដៃឆ្វេង ឬម្រាមចង្អុលខ្មោចឆ្វេង ឬនាងដៃឆ្វេង ឬកូនដៃឆ្វេង ។ ប្រសិនបើគាត់មិនអាចធ្វើបានតាមការកំណត់ខាងលើ រាល់ការជ្រលក់ ឬលាបត្រង់ផ្នែកណាមួយនៃអវយវៈរបស់គាត់ត្រូវទទួលយកជាបានការ ។

៨.៦.១៧.៥ រៀងរាល់ ៣០ (សាមសិប) នាទីម្តង ដបទឹកខ្មៅលុបមិនជ្រះ ត្រូវតែបានបិទគម្របយ៉ាងជិតហើយក្រឡុក ។

៨.៦.១៧.៦ ប្រសិនបើគ្មានអ្នកបោះឆ្នោតមួយរយៈពេលយូរគួរសម សមាជិកទី ១ ត្រូវបិទគម្របដបទឹកខ្មៅ ដើម្បីការពារកុំឱ្យវាហួត ។

៨.៦.១៨ គ្មានជនណាម្នាក់អាចចូលទៅជ្រៀតជ្រែកនៅក្នុងការិយាល័យបោះឆ្នោត ឬជួយអ្នកបោះឆ្នោតក្នុងការបោះឆ្នោតបានឡើយ លើកលែងតែអ្នកបោះឆ្នោតនោះជាជនដែលមានពិការភាព ដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ហើយបានស្នើសុំអ្នកជំនួយជានីតិជនម្នាក់មកជាមួយ ឬស្នើសុំជំនួយពីប្រធាន គ.ក.ប ដូចមានចែងក្នុងមាត្រា ១០៧ នៃ ច.ប.ត.រ ដោយត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

៨.៦.១៨.១ បន្ទាប់ពីបានអនុញ្ញាតឱ្យចូលការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនដែលមានពិការភាពមិនអាចបោះឆ្នោតដោយខ្លួនឯងបាន និង

អ្នកជំនួយជានីតិជនម្នាក់ ដែលអមដំណើរជាមួយដើម្បីជួយគាត់ក្នុងការបោះឆ្នោត ត្រូវអនុវត្តជាបន្តបន្ទាប់តាមចំណុច ៨.៦.១១ ៨.៦.១៤ និង ៨.៦.១៦ ខាងលើ ។

៨.៦.១៨.២ បន្ទាប់ពីបានចូលក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតជាជនដែលមានពិការភាពមិនអាចបោះឆ្នោតបានដោយខ្លួនឯង ដែលមានបំណងស្នើសុំជំនួយពីប្រធាន គ.ក.ប ត្រូវទៅជួបប្រធានដោយផ្ទាល់ ។ បន្ទាប់មកប្រធាន ត្រូវអមដំណើរអ្នកបោះឆ្នោតជាជនដែលមានពិការភាពនោះ អនុវត្តជាបន្តបន្ទាប់តាមចំណុច ៨.៦.១១ ៨.៦.១៤ និង ៨.៦.១៦ ខាងលើ ។ ក្នុងករណីនេះ ប្រធានអាចចាត់សមាជិក គ.ក.ប ណាម្នាក់ឱ្យជួយក៏បានប៉ុន្តែត្រូវមានការយល់ព្រមពីសាមីខ្លួន ។

៨.៦.១៨.៣ អ្នកបោះឆ្នោតមានពិការភាពដែលមិនអាចបោះឆ្នោតបានដោយខ្លួនឯង ត្រូវសួរនាំ ឬប្រាប់អំពីគណបក្សនយោបាយដែលខ្លួនពេញចិត្តទៅប្រធាន គ.ក.ប ឬអ្នកជំនួយដែលខ្លួនជ្រើសរើសតែនៅក្នុងបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតប៉ុណ្ណោះ ។

៨.៦.១៨.៤ នៅក្នុងបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោត ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលជួយអ្នកបោះឆ្នោតមានពិការភាពក្នុងការបោះឆ្នោត ត្រូវសួរអ្នកបោះឆ្នោត ដែលមានពិការភាពនោះថា តើគាត់បោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ដោយសួរតិចៗធ្វើយ៉ាងណាកុំឱ្យមនុស្សដែលនៅក្នុងការិយាល័យបោះឆ្នោត ឮឱ្យសោះ។ បន្ទាប់មកប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយ ត្រូវគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយនៅលើសន្លឹកឆ្នោតដែលឆ្លើយតបនឹងការជ្រើសរើស របស់អ្នកបោះឆ្នោតមានពិការភាព ហើយបត់សន្លឹកឆ្នោតនោះតាមផ្ដត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅក្នុងផ្ដត់ រួចត្រូវនាំអ្នកបោះឆ្នោតដែលមានពិការភាពទៅកាន់ហិបឆ្នោត និងជួយស៊ីកសន្លឹកឆ្នោតរបស់គាត់តាមប្រឡោះតូចចូលទៅក្នុងហិបឆ្នោត ។

៨.៦.១៨.៥ ប្រធាន ឬសមាជិក គ.ក.ប ឬអ្នកជំនួយដែលបានជួយអ្នកបោះឆ្នោតមានពិការភាពដូចលក្ខខណ្ឌមានចែងក្នុងចំណុច ៨.៦.១៨ ត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតរបស់គាត់ ។

៨.៦.១៩ ចំពោះអ្នកបោះឆ្នោតដែលជាជនពិការភ្នែកទាំងសងខាង ហើយមានបំណងចង់បោះឆ្នោតដោយខ្លួនឯង ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតនោះឱ្យប្រើក្របក្រដាសពិសេស ដែលជាសម្ភារជំនួយដល់ការបោះឆ្នោត ។

៨.៦.១៩.១ ប្រធាន គ.ក.ប ត្រូវណែនាំអ្នកបោះឆ្នោតពិការភ្នែកទាំងសងខាងនោះទៅជួបលេខាធិការ ដើម្បីអនុវត្តនីតិវិធីដូចចែងក្រោមចំណុច ៨.៦.១១ ខាងលើ ។ នៅពេលអនុវត្តចំណុច ៨.៦.១១ រួចរាល់ លេខាធិការត្រូវហុច អ.ខ ឬ ឯ.អ ជូនអនុប្រធាន គ.ក.ប ។

៨.៦.១៩.២ អនុប្រធាន គ.ក.ប ត្រូវហែកសន្លឹកឆ្នោត ១ (មួយ) សន្លឹក ចេញពីគល់បញ្ជី រួចបោះត្រាសម្ងាត់នៅលើផ្នែកខាងខ្នង បត់ជា ៤ (បួន) ផ្នត់តាមការកំណត់ និងត្រូវណែនាំអ្នកពិការឱ្យស្ទាបសន្លឹកឆ្នោត និងស្ទាមបត់ រួចលាសន្លឹកឆ្នោតឱ្យស្មើឡើងវិញ និងដាក់នៅក្នុងក្របក្រដាសពិសេស ដោយឱ្យផ្នែកខាងមុខនៃសន្លឹកឆ្នោតលេចចេញប្រអប់ សម្រាប់គូសសញ្ញាគាំទ្រគណបក្សតាមប្រហោងសម្រាប់គូស និងប្រើឃ្នាបគាបសន្លឹកឆ្នោតនោះភ្ជាប់នឹងក្របក្រដាសពិសេស ដើម្បីបង្ការកុំឱ្យប្រអប់លេខរៀង សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយងាក ឬល្ហៀងចេញពីប្រហោងនៃក្របក្រដាសពិសេស ។

៨.៦.១៩.៣ អនុប្រធាន គ.ក.ប ត្រូវប្រគល់ក្របក្រដាសពិសេស ដែលមានដាក់សន្លឹកឆ្នោតខាងក្នុង ជូនទៅអ្នកបោះឆ្នោតដែលពិការភ្នែកទាំងសងខាង និងកាន់ម្រាមដៃណាមួយរបស់គាត់ឱ្យមកប៉ះ និងស្ទាបប្រហោងរាងបួនជ្រុងទ្រវែង និងរាងមូលតូច ដែលចោះលើក្របក្រដាសពិសេសពីលើចុះក្រោម និងជម្រាបគាត់ថា ៖

- អ្នកអាចស្ទាប និងរាប់ប្រហោងរាងបួនជ្រុងទ្រវែង និងរាងមូលតូចដែលកំណត់លេខរៀង និងចំនួនគណបក្សនយោបាយទាំងអស់នៅលើសន្លឹកឆ្នោត ។ ប្រហោងរាងបួនជ្រុងទ្រវែង គឺជាប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលបោះឆ្នោតពាក់ព័ន្ធ ។ ឯប្រហោងរាងមូលតូច គឺជាកំណត់សម្គាល់គណបក្សនយោបាយដែលពុំបានឈរឈ្មោះក្នុងមណ្ឌលពាក់ព័ន្ធ ។

- អ្នកត្រូវចងចាំអំពីលេខរៀងរបស់គណបក្សនយោបាយ ដែលខ្លួនពេញចិត្ត ។
- អ្នកត្រូវប្រើបិកគូសសញ្ញាគាំទ្រ ក្នុងប្រហោងរាងបួនជ្រុងទ្រវែង បន្ទាប់ពីអ្នកបានស្គាល់ និងដឹងច្បាស់អំពីប្រអប់លេខរៀងគណបក្ស ដែលអ្នកពេញចិត្ត ។
- អ្នកត្រូវដោះឃ្នាប និងដកសន្លឹកឆ្នោតចេញពីក្របក្រដាសពិសេស រួចបត់តាមផ្ត់ដើម ហើយស្នើសុំប្រធាន គ.ក.ប ឱ្យជួយជូនទៅ ស៊ីកសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត ។

៨.៦.១៩.៤ ប្រធាន គ.ក.ប ត្រូវអនុវត្តការកិច្ចដូចខាងក្រោម បន្ទាប់ពីអ្នកបោះឆ្នោតពិការភ្នែកទាំងសងខាង បានទទួលក្របក្រដាសពិសេសដែលមានសន្លឹកឆ្នោតផ្លូវការនៅខាងក្នុងរួចហើយ ។

- ជួយជូនអ្នកបោះឆ្នោតជាជនពិការភ្នែកទាំងសងខាងនោះ ទៅកាន់ បន្ទប់សម្ងាត់ និងជួយរកបិកសម្រាប់គូសសញ្ញាគាំទ្រគណបក្ស នយោបាយ ។
- ជួយរៀបចំក្របក្រដាសពិសេស ឱ្យមានភាពត្រឹមត្រូវ ប្រសិនបើ ពិនិត្យឃើញថា ក្របក្រដាសពិសេសនោះមានសភាពមិនប្រក្រតី ឬដាក់មិនទំនង ។
- ចេញពីបន្ទប់សម្ងាត់ និងរង់ចាំជួយបន្ថែមទៀត ប្រសិនបើមាន សំណូមពរពីអ្នកបោះឆ្នោតនោះ ។

៨.៦.១៩.៥ រាល់ការអនុវត្តនីតិវិធីខាងលើនេះ ត្រូវធ្វើឡើងចំពោះមុខភ្នាក់ងារ គណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាននៅ ក្នុងការិយាល័យបោះឆ្នោត ។

៨.៦.១៩.៦ គ.ជ.ប ត្រូវរៀបចំឱ្យមានក្របក្រដាសពិសេស មានទម្រង់ជា ២ (ពីរ) សន្លឹកជាប់គ្នា ដែលមានក្របមុខ និងក្របខាងខ្នង មានទំហំប៉ុនគ្នានឹង សន្លឹកឆ្នោតផ្លូវការ ហើយក្របក្រដាសពិសេសនេះ ត្រូវចោះប្រហោង រាងបួនជ្រុងទ្រវែង មានទំហំប៉ុនគ្នានៅចំប្រអប់សម្រាប់គូសសញ្ញា គាំទ្រគណបក្សនយោបាយ ដែលមាននៅលើសន្លឹកឆ្នោតផ្លូវការ និង រាងមូលតូចនៅចំប្រអប់សម្រាប់គូសសញ្ញាគាំទ្រគណបក្សនយោបាយ ណាដែលពុំបានឈរឈ្មោះបោះឆ្នោត ។

៨.៦.២០ ក្នុងអំឡុងពេលនៃការបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត ប្រសិនបើក្នុងការិយាល័យបោះឆ្នោត គ្មានអ្នកបោះឆ្នោតទេនោះ សមាជិកទី ១ ត្រូវបិទភ្ជិតសន្ទះបិទប្រឡោះសម្រាប់ស៊ីកសន្លឹកឆ្នោតជាបណ្តោះអាសន្ន ហើយត្រូវបើកឡើងវិញនៅពេលមានវត្តមានអ្នកបោះឆ្នោត ។

៨.៦.២១ គ្មានជនណាម្នាក់ ដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត អាចពិនិត្យមើលការគូសសញ្ញាលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតឡើយ លើកលែងតែអ្នកដែលជួយអ្នកបោះឆ្នោតមានពិការភាពដូចមានចែងក្នុងចំណុច ៨.៦.១៨ ខាងលើ ។

៨.៦.២១.១ ជនណាក៏ដោយដូចមានចែងក្នុងចំណុច ៨.៦.២១ ខាងលើ ដែលប៉ុនប៉ងចង់ឃើញការគូសសញ្ញានៅលើសន្លឹកឆ្នោតរបស់អ្នកបោះឆ្នោតជននោះ នឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.ប ។ ការប៉ុនប៉ងជាលើកទីពីរ ដើម្បីធ្វើឱ្យបែកធ្លាយការសម្ងាត់នៃការបោះឆ្នោត នឹងត្រូវចាត់ទុកថា ជាការរំលោភទៅលើច្បាប់ ហើយជនដែលពាក់ព័ន្ធត្រូវតែបានបណ្តេញចេញពីការិយាល័យបោះឆ្នោត និងត្រូវទទួលទោសតាម ច.ប.ត.រ ។

៨.៦.២១.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍ទាំងនេះ ក្នុងកំណត់ហេតុដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត ។

៨.៦.២១.៣ ប្រសិនបើ ជនប្រព្រឹត្តអំពើល្មើសលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ដូចមានចែងក្នុងចំណុច ៨.៦.២១.១ ខាងលើ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ប្រធាន គ.ក.ប ត្រូវបញ្ជូនកំណត់ហេតុស្តីពីហេតុការណ៍នោះទៅ គយ.សប ។

៨.៦.២១.៤ ពេលបានទទួលកំណត់ហេតុដូចមានចែងក្នុងចំណុច ៨.៦.២១.៣ ខាងលើភ្លាម គយ.សប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនោះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន ត្រូវតែប្តឹងជនប្រព្រឹត្តអំពើល្មើសទៅ គធ.ខប ដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ។

៨.៦.២២ អ្នកបោះឆ្នោតណាម្នាក់ ដែលបានធ្វើឱ្យខូចសន្លឹកឆ្នោត ឬធ្វើឱ្យរហែក ឬធ្វើឱ្យប្រឡាក់ដោយអចេតនា ឬដែលបានគូសសញ្ញានៅលើសន្លឹកឆ្នោតរួចហើយ តែបានប្តូរចិត្តវិញ គាត់អាចសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀតពីប្រធាន គ.ក.ប ។

៨.៦.២២.១ អ្នកបោះឆ្នោតដែលស្នើសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀត ត្រូវបត់សន្លឹកឆ្នោតខូចតាមផ្ដត់ដើម ដើម្បីឱ្យសញ្ញាដែលបានគូសស្ថិតនៅខាងក្នុងផ្ដត់ រួចប្រគល់ជូនប្រធាន គ.ក.ប ។

៨.៦.២២.២ ប្រធានត្រូវសិកសន្លឹកឆ្នោត ដែលខូចនោះទៅក្នុងស្រោមសំបុត្រមួយ ដែលមានកាខ្ពងស្រាប់ថា " សន្លឹកឆ្នោតខូច " ។

៨.៦.២២.៣ លេខាធិការដែលបានគូសសញ្ញាសម្គាល់ម្ដងហើយ ក្នុងប្រអប់នៅប៉ែកខាងដើមទន្ទឹមនឹងឈ្មោះគាត់ក្នុងបញ្ជីបោះឆ្នោត ដូចក្នុងចំណុច ៨.៦.១១.៣ ខាងលើ មិនចាំបាច់ធិចសម្គាល់ជាលើកទីពីរឡើយ ប៉ុន្តែត្រូវកត់ចំណុចទុក សម្រាប់សរសេរចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

៨.៦.២២.៤ ប្រធាន ត្រូវអនុញ្ញាតឱ្យអនុប្រធានផ្ដល់សន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀត ជូនអ្នកបោះឆ្នោតដូចមានចែងក្នុងចំណុច ៨.៦.២២ តែមួយលើកគត់ និងត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់គ្រាន់សម្រាប់ការបោះឆ្នោតនៅថ្ងៃបោះឆ្នោត និងត្រូវរំលឹកអនុប្រធានឱ្យណែនាំអ្នកបោះឆ្នោតបន្ទាប់ តាមខ្លឹមសារនៃចំណុច ៨.៦.១៤.២ ខាងលើ ដោយផ្អែកលើចំនួនជាក់ស្ដែងនៃសន្លឹកឆ្នោតនៅការិយាល័យនោះ ។

៨.៦.២២.៥ ក្នុងករណី មានអ្នកបោះឆ្នោតមួយចំនួនជាបន្តបន្ទាប់គ្នាសុំសន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀត ដូចមានចែងក្នុងចំណុច ៨.៦.២២ ខាងលើ ដែលអាចចាត់ទុកថាជាភាពមិនប្រក្រតីមួយនោះ ប្រធាន គ.ក.ប អាចសម្រេចមិនព្រមផ្ដល់សន្លឹកឆ្នោត ១ (មួយ) សន្លឹកផ្សេងទៀត តាមការស្នើសុំទេ ហើយឱ្យលេខាធិការកត់ត្រាបញ្ហាទាំងនេះចូលក្នុងកំណត់ហេតុនៃការបោះឆ្នោត ។

៨.៦.២៣ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់ជំទាស់ ឬតវ៉ានឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬភាពមិនប្រក្រតីនៃការបោះឆ្នោត ឬសេចក្ដីសម្រេចណាមួយរបស់ គ.ក.ប គាត់ត្រូវលើកការជំទាស់ ឬតវ៉ានោះ ដោយផ្ទាល់ទៅប្រធាន គ.ក.ប ដោយបង្ហាញអំពីមូលហេតុ ឬ/និងភស្ដុតាងដែលនាំឱ្យគាត់ជឿថាមានភាពមិនប្រក្រតី ឬការរំលោភច្បាប់ ឬ/និងការរំលោភ ប.ន.ត.រ ក្នុងការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ។

៨.៦.២៣.១ ប្រសិនបើយល់ឃើញថាសមហេតុផល ប្រធានត្រូវបញ្ជូនជាបណ្តោះអាសន្ននូវកិច្ចប្រតិបត្តិការបោះឆ្នោត ដើម្បីស្តាប់ការជំទាស់ ឬតវ៉ារបស់ភ្នាក់ងារគណបក្សនយោបាយនោះ ហើយបន្ទាប់មកពិភាក្សាបញ្ហានេះជាមួយនឹងសមាជិក គ.ក.ប ដទៃទៀត ។

៨.៦.២៣.២ បន្ទាប់ពីបានពិនិត្យឡើងវិញអំពីករណីដែលបានលើកជំទាស់ ឬតវ៉ា ប្រសិនបើប្រធាន គ.ក.ប យល់ព្រមតាមការជំទាស់ ឬតវ៉ា ប្រធានត្រូវណែនាំ និងរំលឹកសមាជិក គ.ក.ប និងអ្នកដែលមានវត្តមានក្នុងការិយាល័យបោះឆ្នោត អំពីខ្លឹមសារពាក់ព័ន្ធ ដូចមានចែងក្នុង ច.ប.ត.រ និង ប.ន.ត.រ ហើយត្រូវចាត់វិធានការដោះស្រាយភាពមិនប្រក្រតីនោះជាបន្ទាន់ ។

៨.៦.២៣.៣ ប្រសិនបើប្រធាន គ.ក.ប បដិសេធលើការលើកជំទាស់ ឬតវ៉ា គាត់ត្រូវផ្តល់ហេតុផលពាក់ព័ន្ធនឹងការបដិសេធនោះ ជូនភ្នាក់ងារគណបក្សនយោបាយ ។

៨.៦.២៣.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ា ប្រធាន គ.ក.ប ត្រូវកត់ត្រាការជំទាស់ ឬតវ៉ានេះក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដោយឱ្យអ្នកជំទាស់ ឬតវ៉ានោះចុះហត្ថលេខាលើកំណត់ហេតុនេះ ។

៨.៦.២៣.៥ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយនោះមិនយល់ព្រមចុះហត្ថលេខាករណីនៃការជំទាស់ ឬតវ៉ានោះ មិនត្រូវបានកត់ត្រាក្នុងកំណត់ហេតុនៃការបោះឆ្នោតទេ ។

៨.៦.២៣.៦ ការសម្រេចរបស់ប្រធាន គ.ក.ប ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការបោះឆ្នោតតទៅទៀត។

៨.៦.២៣.៧ ចំណុច ៨.៦.២៣.៦ ខាងលើ មិនបានច្រានចោលជាមុននូវការណ៍ដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្តឹងជំទាស់ ឬតវ៉ាទៅ គយ.សប អំពីករណីដែលគាត់បានលើកជំទាស់ក្នុងការិយាល័យបោះឆ្នោតនោះទេ ប៉ុន្តែក្នុងស្ថានភាពនេះ គាត់ត្រូវតែយល់ព្រមទទួលយកនូវវិធាននៃការគ្រប់គ្រងរបស់ប្រធាន គ.ក.ប និងមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះ ដល់កិច្ចប្រតិបត្តិការបោះឆ្នោតឡើយ ។

៨.៦.២៣.៨ ប្រធានត្រូវផ្តល់ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹង ប្រសិនបើ ភ្នាក់ងារគណបក្សនយោបាយស្នើសុំ សម្រាប់ប្តឹងបន្តទៅ គយ.សប ។

៨.៦.២៤ ប្រសិនបើមាន អ្នកបោះឆ្នោតណាម្នាក់រំខានដល់កិច្ចប្រតិបត្តិការបោះឆ្នោត ទោះបីគាត់ស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬកំពុងឈរតម្រង់ជួរនៅខាងក្រៅការិយាល័យក្តី ប្រធាន គ.ក.ប ត្រូវណែនាំគាត់ឱ្យរក្សារបៀបរៀបរយ ។ ក្នុងករណីអ្នកបោះឆ្នោតនោះបដិសេធ មិនព្រមគោរពតាមបញ្ជារបស់ខ្លួន ប្រធាន គ.ក.ប ត្រូវស្នើកម្លាំងសន្តិសុខឱ្យបណ្តេញបុគ្គលនោះចេញ ឬឃាត់ខ្លួនបុគ្គលនោះ រហូតដល់ការបោះឆ្នោតត្រូវបានបញ្ចប់ ។

៨.៦.២៥ ប្រធាន គ.ក.ប អាចស្នើសុំកម្លាំងសន្តិសុខឱ្យរៀបចំសាឡើងវិញ នូវរបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោត ប្រសិនបើកិច្ចប្រតិបត្តិការបោះឆ្នោតត្រូវបានរំខានដល់កម្រិត ដែលអ្នកបោះឆ្នោតមិនអាចធ្វើការបោះឆ្នោតបន្តទៀតបាន ឬធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅដោយសេរី ។ ការរំខានដល់អ្នកបោះឆ្នោត ឬដល់ការប្រព្រឹត្តទៅនៃការបោះឆ្នោត គឺជាសកម្មភាពទាំងឡាយណា ដែលកើតមានឡើងនៅក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោតដូចខាងក្រោមនេះ ៖

- ៨.៦.២៥.១ ការបញ្ចេញសម្រែកខ្លាំងៗ ឬការបញ្ចេញសម្តីគំរាមកំហែង ឬជេរប្រមាថមាក់ងាយ ។
- ៨.៦.២៥.២ ការធ្វើសកម្មភាពរារាំងអ្នកបោះឆ្នោត មិនឱ្យទៅបោះឆ្នោត ។
- ៨.៦.២៥.៣ ការរុញច្រានដោយប្រើកម្លាំងធ្ងន់ ។
- ៨.៦.២៥.៤ ការគប់វត្ថុផ្សេងៗសំដៅអ្នកបោះឆ្នោត ឬការិយាល័យបោះឆ្នោត។
- ៨.៦.២៥.៥ ការអុកឡុកនៃបុគ្គលណាម្នាក់ ឬច្រើននាក់ ដែលធ្វើឱ្យរំខានដល់អ្នកបោះឆ្នោត ។
- ៨.៦.២៥.៦ ការបញ្ចេញអាកប្បកិរិយា និងភាសាមិនសមរម្យ ។
- ៨.៦.២៥.៧ ការបញ្ចេញឱ្យឃើញនូវអាវុធ គ្រឿងផ្ទុះ ឬសារធាតុផ្សេងៗ ប្រកបដោយគ្រោះថ្នាក់ ។

៨.៦.២៦ ប្រសិនបើការបោះឆ្នោតឈានដល់ម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល នៃថ្ងៃបោះឆ្នោត ដែលជាពេលវេលាកំណត់ សម្រាប់ការបញ្ចប់ដំណើរការបោះឆ្នោត ប៉ុន្តែនៅមានអ្នកបោះឆ្នោត កំពុងស្ថិតក្នុងការិយាល័យបោះឆ្នោត ឬឈរតម្រង់ជួរក្នុងបរិវេណខាងក្នុងការិយាល័យបោះឆ្នោត អ្នកបោះឆ្នោតទាំងនោះត្រូវតែបានអនុញ្ញាតឱ្យបោះឆ្នោត ។

៨.៦.២៦.១ ក្នុងករណីនេះ សមាជិកទី ២ ត្រូវប្រកាសប្រាប់អ្នកបោះឆ្នោតដែលមានវត្តមាននៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត និងត្រូវប្រមូលយក អ.ខ ឬ ឯ.អ ពីអ្នកបោះឆ្នោតដែលនៅក្នុងជួរ ដោយចាប់ផ្តើមពីអ្នកបោះឆ្នោត ដែលឈរក្រោយគេបង្អស់ រហូតដល់អ្នកនៅខាងមុខគេបង្អស់ រួចប្រគល់ទៅឱ្យសមាជិកទី ៣ នៅត្រង់មាត់ទ្វារ ។

៨.៦.២៦.២ សមាជិកទី ៣ ត្រូវហៅឈ្មោះអ្នកបោះឆ្នោតម្នាក់ម្តងៗ រហូតដល់អ្នកបោះឆ្នោតចុងក្រោយបង្អស់ឱ្យចូលក្នុងការិយាល័យបោះឆ្នោត ដើម្បីបោះឆ្នោតតាមលំដាប់លំដោយរហូតដល់អស់អ្នកបោះឆ្នោត ។

៨.៦.២៦.៣ អ្នកបោះឆ្នោត ដែលគ្មានវត្តមាននៅខាងក្នុងការិយាល័យបោះឆ្នោត ឬនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅនាទីចុងក្រោយ នាម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល នៃថ្ងៃបោះឆ្នោតទេនោះ អ្នកបោះឆ្នោតទាំងនោះ ពុំត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតឡើយ ។

៨.៦.២៧ ប្រសិនបើអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត មិនទាន់បានមកបោះឆ្នោតគ្រប់គ្នាទេ ទោះបីគ្មានអ្នកបោះឆ្នោតឈររង់ចាំបោះឆ្នោតក្តី ប្រធាន គ.ក.ប មិនអាចបិទការបោះឆ្នោត នៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល នៃថ្ងៃបោះឆ្នោតបានឡើយ ។

៨.៦.២៨ ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត បានបោះឆ្នោតគ្រប់គ្នាហើយ ប្រធាន គ.ក.ប អាចប្រកាសបញ្ចប់ការបោះឆ្នោតនៅការិយាល័យរបស់ខ្លួននៅមុនម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល ។

ការបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោត នាថ្ងៃបោះឆ្នោត

ប្រការ ៨.៧.-

នៅពេលដែលអ្នកបោះឆ្នោតចុងក្រោយបង្អស់បានបោះឆ្នោតរួច និងបានចេញផុតពីការិយាល័យ ប្រធាន គ.ក.ប ត្រូវចាត់សមាជិកទី ៣ ឱ្យចាត់វិធានការចាំបាច់ ដើម្បីការពារច្រកចូលការិយាល័យ បោះឆ្នោតកុំឱ្យអ្នកគ្មានភារកិច្ចចេញចូល ។ ប្រធាន គ.ក.ប ត្រូវប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ បន្ទាប់មកត្រូវចាត់ចែងការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត និងចំនួនសន្លឹកឆ្នោត និងការបំពេញកំណត់ហេតុនៃការបោះឆ្នោត ។

៨.៧.១ បន្ទាប់ពីបានប្រកាសបិទការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ប្រធាន គ.ក.ប ត្រូវចាត់ចែងតាមនីតិវិធីដើម្បីធានាសុវត្ថិភាពហិបឆ្នោត ដែលក្នុងនោះ ៖

៨.៧.១.១ ប្រធានត្រូវបិទភ្ជិតសន្ទះបិទប្រឡោះ សម្រាប់ស៊ីកសន្លឹកឆ្នោតទាំងពីរនៃហិបឆ្នោត ព្រមទាំងបិទក្រដាសស្តើងមួយសន្លឹក ដែលមានចុះហត្ថលេខារបស់ប្រធាន គ.ក.ប និងភ្នាក់ងារគណបក្សនយោបាយ ៣សពីលើសន្ទះបិទប្រឡោះ សម្រាប់ស៊ីកសន្លឹកឆ្នោតទាំងពីរនោះផង ។

៨.៧.១.២ ប្រធានត្រូវបិទគម្របខាងក្រៅនៃហិបឆ្នោត និងចាក់សោឃ្លុំមានលេខនៅត្រង់ក្រវិលសម្រាប់ចាក់សោទាំងពីរនៃហិបឆ្នោត រួចអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត និងសោឃ្លុំមានលេខទាំងពីរនោះ ។

៨.៧.១.៣ លេខាធិការត្រូវកត់ត្រាបន្ថែមក្នុងកំណត់ហេតុនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត (ទ.១១០១) នៅពេលវេលានៃការបិទការបោះឆ្នោត ព្រមទាំងលក្ខណៈសម្គាល់ និងលេខនៃសោឃ្លុំទាំងពីរ ។

៨.៧.១.៤ ប្រធានត្រូវចាត់វិធានការការពារហិបឆ្នោត ដែលមានសន្លឹកឆ្នោតនៅខាងក្នុងយ៉ាងហ្មត់ចត់ សម្រាប់ការរាប់សន្លឹកឆ្នោតនៅនឹងកន្លែងការិយាល័យបោះឆ្នោត ឬសម្រាប់ការបញ្ជូនទៅរាប់នៅកន្លែងផ្សេង ប្រសិនបើមានការសម្រេចឱ្យធ្វើដូច្នេះដោយ គ.ជ.ប ។

៨.៧.១.៥ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត អាចថតយកសកម្មភាពនៅការិយាល័យបោះឆ្នោត ក្រោយពីការប្រកាសបិទការបោះឆ្នោតដោយសុំការអនុញ្ញាតពីប្រធាន គ.ក.ប ។

៨.៧.២ បន្ទាប់មកស្ថិតនៅចំពោះមុខវត្តមានភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិកនៃ គ.ក.ប ឱ្យធ្វើការផ្ទៀងផ្ទាត់ចំនួនអ្នកបោះឆ្នោត ចំនួនសន្លឹកឆ្នោតដែលបានប្រើ សន្លឹកឆ្នោតមិនបានប្រើ និងសន្លឹកឆ្នោតខូច (បើមាន) ដែលក្នុងនោះ ៖

៨.៧.២.១ លេខាធិការត្រូវរាប់ចំនួនគំនូសសញ្ញាក្នុងកូនប្រអប់ផ្នែកខាងដើម នៅក្នុងបញ្ជីបោះឆ្នោត ដូចមានចែងក្នុងចំណុច ៨.៦.១១.៣ ខាងលើ និងរាយការណ៍ជូនប្រធានអំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ។

៨.៧.២.២ អនុប្រធាន ត្រូវកំណត់សម្គាល់រវាងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ និងគល់បញ្ជីនៃសន្លឹកឆ្នោតដែលមិនបានប្រើ រួចរាប់ចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ និងសន្លឹកឆ្នោតខូច ដោយឡែកពីគ្នា។ ប្រសិនបើចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង ដូចបញ្ជាក់ក្នុងចំណុច ៨.៦.៧.៣ ខាងលើ ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ ស្មើគ្នានឹងចំនួនអ្នកបោះឆ្នោត ដែលបានបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៨.៧.២.១ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខចំនួនទាំងនេះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ។

៨.៧.២.៣ ប្រសិនបើក្នុងការផ្ទៀងផ្ទាត់នេះបង្ហាញថា នៅមានភាពខុសគ្នារវាងចំនួនសន្លឹកឆ្នោតដែលបានប្រើ និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត លេខាធិការត្រូវផ្ទៀងផ្ទាត់ជាលើកទីពីរ នូវចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោតនៅលើបញ្ជីបោះឆ្នោត ហើយអនុប្រធាន ក៏ត្រូវផ្ទៀងផ្ទាត់ឡើងវិញដែរ នូវចំនួនសន្លឹកឆ្នោតដែលបានប្រើ (រាប់ចំនួនសន្លឹកគល់បញ្ជីនៃសន្លឹកឆ្នោតដែលបានប្រើ) ចំនួនសន្លឹកឆ្នោតមិនបានប្រើ និងចំនួនសន្លឹកឆ្នោតខូច ។ ប្រសិនបើភាពខុសគ្នានៅតែមាន លេខាធិការត្រូវកត់ត្រានូវតួលេខនៃចំនួនដែលខុសគ្នានោះ ក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ហើយប្រធាន គ.ក.ប ត្រូវបន្តចាត់ចែងអនុវត្តតាមនីតិវិធីជាបន្ត ។

៨.៧.២.៤ សមាជិកទី២ ត្រូវចោះ ឬកាត់សន្លឹកឆ្នោត ដែលមិនបានប្រើទាំងអស់ជាមួយនឹងប្រដាប់ចោះ ឬកន្ត្រៃ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ ។

៨.៧.២.៥ អនុប្រធានត្រូវដាក់សន្លឹកឆ្នោតមោឃភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ទៅក្នុងស្បោងប្លាស្ទិកតែមួយរួចបិទឱ្យជិត ។

៨.៧.៣ ប្រធានត្រូវធានាថា លេខាធិការបានកត់ត្រាជាមុននូវលេខសោឃ្លុំ ដែលនឹងត្រូវប្រើសម្រាប់ចាក់ឃ្លុំមាត់ស្បោង " ខ " ដូចមានចែងក្នុងចំណុច ៨.១២.៩ ខាងក្រោម ក្នុងកំណត់ហេតុនៃការបោះឆ្នោត និងបោះត្រាសម្ងាត់នៅជ្រុងខាងស្តាំប៉ែកខាងលើនៃកំណត់ហេតុនេះ ។ កំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត (ទ.១១០១) ចំនួន ៣ (បី)ច្បាប់ ដែលលេខាធិការបានបំពេញរួច ត្រូវចុះហត្ថលេខាដោយលេខាធិការ ប្រធាន គ.ក.ប និងបោះត្រាការិយាល័យ ។

៨.៧.៣.១ ប្រធានត្រូវដាក់បង្ហាញកំណត់ហេតុ ដូចមានចែងក្នុងចំណុច ៨.៧.៣ ខាងលើ ចំពោះភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ។

៨.៧.៣.២ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះ ។

៨.៧.៣.៣ ការមិនព្រមចុះហត្ថលេខាលើកំណត់ហេតុ ពីភ្នាក់ងារគណបក្សនយោបាយណាម្នាក់ មិនអាចចាត់ទុកជាមោឃ:នូវកំណត់ហេតុនេះបានទេ ។

៨.៧.៤ ប្រធាន គ.ក.ប ត្រូវរៀបចំកំណត់ហេតុនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត (ទ.១១០១) ដែលបានចុះហត្ថលេខារួច ដូចមានចែងក្រោមចំណុច ៨.៧.៣ ខាងលើ ដូចខាងក្រោម ៖

៨.៧.៤.១ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ព ដែលមានកាខ្ជង ថា " កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ផ្ញើជូន គ.ជ.ប " ។

៨.៧.៤.២ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្ជង ថា " កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ផ្ញើជូន គធ.ខប "។

៨.៧.៤.៣ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្របោះពុម្ពដែលមានកាខ្ជង ថា " កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ផ្ញើជូន គយ.សប " ។

៨.៧.៥ បន្ទាប់មកប្រធាន គ.ក.ប ត្រូវរៀបចំដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រដោយឡែកពីគ្នា រួចដាក់ទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ដែលមានបោះពុម្ពសម្គាល់ថា " ការិយាល័យបោះឆ្នោតលេខ...” នូវ ៖

៨.៧.៥.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដូចមានចែងក្នុងចំណុច ៨.៧.៤.១ ខាងលើ ។

៨.៧.៥.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត។

៨.៧.៥.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " (ប្រសិនបើមាន) ។

៨.៧.៥.៤ ស្បោងប្លាស្ទិកដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " ។

៨.៧.៥.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

៨.៧.៥.៦ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " (បើមាន) ។

៨.៧.៥.៧ ស្រោមសំបុត្រដាក់ឯកសារកត្តាងដែលបានដកហូត (បើមាន) ។

៨.៧.៦ ប្រធាន គ.ក.ប ត្រូវពិនិត្យ និងផ្ទៀងផ្ទាត់ឱ្យបានហ្មត់ចត់ថា រាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារ ដូចមានចែងក្រោមចំណុច ៨.៧.៥ ខាងលើ ត្រូវបានដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " ។ ប្រធាន គ.ក.ប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " នៅពេលនេះមិនត្រូវបិទភ្ជិតឡើយ ហើយនឹងត្រូវបិទភ្ជិតដោយការសុវត្ថិភាពបម្រុងស្រាប់ លុះណាតែ គ.ក.រ បានបញ្ចប់ការរាប់សន្លឹកឆ្នោត និងបានដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធរួចរាល់សិន ។

៨.៧.៧ ប្រធាន គ.ក.ប ត្រូវធានាថា កញ្ចប់សុវត្ថិភាព " ក " ដូចមានចែងក្នុងចំណុច ៨.៧.៦ និងស្រោមសំបុត្រ ដូចមានចែងក្នុងចំណុច ៨.៧.៤.២ និង ៨.៧.៤.៣ ខាងលើ ត្រូវបានបំពេញលេខកូដការិយាល័យពាក់ព័ន្ធយ៉ាងត្រឹមត្រូវ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ ព្រមទាំងត្រូវរក្សាទុកឱ្យបានហ្មត់ចត់ និងមានសុវត្ថិភាព ក្នុងពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតកំពុងដំណើរការ ។

៨.៧.៨ ប្រធាន គ.ក.ប ត្រូវចាត់ចែងសមាជិកឱ្យរៀបចំទុកដាក់សម្ភារ ឯកសារដែលនៅសល់ក្នុងកេសស័ង្កសី និងវេចខ្ចប់ដបទឹកខ្មៅលុបមិនជ្រះដោយឡែក ។ ទន្ទឹមនឹងនេះ ត្រូវរុះរើបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតទាំង ២ (ពីរ) រួចច្រកទៅក្នុងការុងនីឡុង ដែលបានប្រើសម្រាប់ដាក់បន្ទប់សម្ងាត់ ដូចនៅពេលប្រគល់ជូន គ.ក.ប នាពេលដំបូង ។

ការបិទការិយាល័យបោះឆ្នោតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន

ប្រការ ៨.៨.-

មុនថ្ងៃបោះឆ្នោត ឬនៅថ្ងៃបោះឆ្នោត ប្រសិនបើការិយាល័យបោះឆ្នោតណាមួយ ឬមួយចំនួន ស្ថិតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬគំរាមកំហែងដល់សុវត្ថិភាពមន្ត្រីបោះឆ្នោត និងអ្នកបោះឆ្នោតនៅបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត គ.ជ.ប មានសិទ្ធិសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះបាន ។

៨.៨.១ ការសម្រេចមិនបើក ឬបិទការិយាល័យបោះឆ្នោតបាន លុះត្រាតែការិយាល័យបោះឆ្នោតនោះ ឬទាំងនោះស្ថិតក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ។ ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ត្រូវបានកំណត់ដូចជាករណីណាមួយ ក្នុងចំណោមករណីដូចមានចែងក្រោមចំណុច ១.៣.៣ និងចំណុច ១.៥.១ នៃ ច.ប.ត.រ នេះ ។

៨.៨.២ នៅមុនថ្ងៃបោះឆ្នោត ប្រសិនបើកើតមានករណីណាមួយនៃករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដូចមានចែងក្នុងចំណុច ៨.៨.១ ប្រធានការិយាល័យបោះឆ្នោត ត្រូវរាយការណ៍ជាបន្ទាន់អំពីស្ថានភាពជាក់ស្តែងទៅ គយ.សប។

៨.៨.២.១ គយ.សប ត្រូវវាយតម្លៃសភាពការណ៍ជាក់ស្តែង ពិនិត្យលទ្ធភាពអាចបើកការិយាល័យបោះឆ្នោតបាន ឬមិនបាន និងរាយការណ៍បន្ទាន់ជូន គធ.ខប ។

៨.៨.២.២ គធ.ខប ត្រូវពិនិត្យ និងវាយតម្លៃសភាពការណ៍ច្បាស់លាស់ដោយផ្តល់យោបល់ និងរាយការណ៍បន្ទាន់ជូន គ.ជ.ប ដើម្បី គ.ជ.ប សម្រេចអំពីការបើក ឬមិនបើកការិយាល័យបោះឆ្នោត ។

៨.៨.២.៣ ក្រោយការសម្រេចបើក ឬមិនបើកការិយាល័យបោះឆ្នោត គ.ជ.ប ត្រូវជូនដំណឹងបន្ទាន់ទៅ គធ.ខប ដើម្បី គធ.ខប ចាត់ចែងបន្ត ។

៨.៨.២.៤ ការរាយការណ៍ជាបន្ទាន់ និងការជូនដំណឹងជាបន្ទាន់ខាងលើ ត្រូវធ្វើតាមទូរស័ព្ទ ទូរសារ ឬវិទ្យុទាក់ទង ឬអ៊ីមែល ។

៨.៨.៣ នៅក្នុងថ្ងៃបោះឆ្នោត នៅមុនពេល ឬក្នុងពេលដំណើរការបោះឆ្នោត ប្រសិនបើកើតមានករណីណាមួយនៃប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដូចមានចែងក្នុងចំណុច ៨.៨.១ ប្រធាន គ.ក.ប មានសិទ្ធិសម្រេចមិនបើក ឬបិទ

ការិយាល័យបោះឆ្នោត ។ ប្រធាន គ.ក.ប ត្រូវរាយការណ៍ជាបន្ទាន់អំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោតជូន គយ.សប ដើម្បី គយ.សប រាយការណ៍បន្តទៅ គធ.ខប និងដើម្បី គធ.ខប រាយការណ៍ជាបន្ទាន់ជូន គ.ជ.ប ។

៨.៨.៤ ការិយាល័យបោះឆ្នោតដែលមិនត្រូវបានបើក ឬដែលត្រូវបានបិទនៅថ្ងៃបោះឆ្នោត ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ត្រូវតែបិទ រហូតពេញមួយថ្ងៃ ។

៨.៨.៥ គ.ជ.ប ត្រូវរាយការណ៍ភ្លាមជូនរាជរដ្ឋាភិបាល និងរដ្ឋសភា អំពីការិយាល័យ បោះឆ្នោតណាមួយ ដែលមិនត្រូវបានបើក ឬត្រូវបានបិទដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ននៅមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត។

៨.៨.៦ ក្នុងករណីមានការិយាល័យបោះឆ្នោតណាមួយ ឬច្រើន មិនត្រូវបានបើក ឬត្រូវបាន បិទដោយករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន គយ.សប ត្រូវចាត់ចែងណែនាំអំពីការមិនបើក ឬបិទការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ដោយត្រូវ ៖

- ៨.៨.៦.១ ជូនដំណឹងដល់អ្នកបោះឆ្នោត ដែលត្រូវបោះឆ្នោតនៅការិយាល័យ នោះ ឬទាំងនោះ អំពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោត ដោយបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។
- ៨.៨.៦.២ ចាត់ឱ្យ គ.ក.ប រៀបចំប្លាប់ហាបឆ្នោតមានសន្លឹកឆ្នោត ដែលបានបោះ រួចនៅខាងក្នុង សន្លឹកឆ្នោតមិនទាន់ប្រើ ព្រមទាំងប្រមូលសម្ភារ ឧបករណ៍ និងឯកសារពាក់ព័ន្ធផ្សេងទៀត សម្រាប់ប្រើប្រាស់ក្នុង ការបោះឆ្នោត ដោយត្រូវបំពេញលិខិតប្រគល់ទទួលសម្ភារ ឯកសារ បោះឆ្នោត (ទ.១១០៧) រួចបញ្ជូនយកមករក្សាទុកនៅ គយ.សប ។
- ៨.៨.៦.៣ ចាត់ឱ្យ គ.ក.ប ធ្វើកំណត់ហេតុស្តីពីការមិនបើក ឬការបិទការិយា ល័យបោះឆ្នោតនោះ ឬទាំងនោះ ដែលត្រូវបញ្ជូនមក គយ.សប រួមជាមួយសម្ភារ ឯកសារ ដូចចែងក្នុងចំណុច ៨.៨.៦.២ ខាងលើ ។
- ៨.៨.៦.៤ កំណត់សន្លឹកឆ្នោត ដែលបានបោះរួចនៅក្នុងហាប ដូចមានចែងក្នុង ចំណុច ៨.៨.៦.២ ខាងលើ ទុកជាមោឃៈ ដោយមិនត្រូវរាប់បញ្ចូល ជាលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ឡើយ ។

៨.៨.៦.៥ ផ្អែកលើកំណត់ហេតុរបស់ គ.ក.ប ត្រូវរាយការណ៍ជូន គធ.ខប ដើម្បីបន្តរាយការណ៍ជូន គ.ជ.ប ។

៨.៨.៦.៦ ជូនដំណឹងដល់សមាសភាព គ.ក.ប នៃការិយាល័យបោះឆ្នោត ដែលមិនត្រូវបានបើក ឬត្រូវបានបិទថា គ.ក.ប នេះ ត្រូវរំសាយ និងទទួលបានប្រាក់កម្រៃស្របតាមកិច្ចសន្យា ។

៨.៨.៧ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាល:ទេស:មានអាសន្ន កើតមានឡើងនៅក្រោយពេលបិទការិយាល័យបោះឆ្នោត ដែលពេលនោះកំណត់ហេតុនៃការបោះឆ្នោតត្រូវបានធ្វើរួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង រួមទាំងសម្ភារ ឯកសារពាក់ព័ន្ធនៅរក្សាបានល្អ ប្រធាន គ.ក.ប ត្រូវបញ្ជូនសម្ភារ ឯកសារទាំងនោះទៅ គយ.សប ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ដើម្បីចាត់ចែងការរាប់សន្លឹកឆ្នោត តាមលំនាំនីតិវិធី ដូចមានចែងក្រោមប្រការ ៨.១៥ នៃ ប.ន.ត.រ នេះ ។

៨.៨.៨ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាល:ទេស:មានអាសន្ន កើតមានឡើងនៅក្រោយពេលបិទការិយាល័យបោះឆ្នោត ហើយកំណត់ហេតុនៃការបោះឆ្នោតត្រូវបានធ្វើរួចរាល់ ប៉ុន្តែហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចហើយនៅខាងក្នុង រួមទាំងសម្ភារ ឯកសារពាក់ព័ន្ធ ត្រូវបានបំផ្លាញ ឬខូចនោះ ប្រធាន គ.ក.ប ត្រូវបញ្ជូនសម្ភារ ឯកសារទាំងនោះទៅរក្សាទុកនៅ គយ.សប ។

៨.៨.៩ នៅពេលទទួលបានរបាយការណ៍ស្តីពីការមិនបើក ឬការបិទការិយាល័យបោះឆ្នោត ដោយករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាល:ទេស:មានអាសន្ន ដូចមានចែងក្នុងចំណុច ៨.៨.៣ និងករណីដូចមានចែងក្នុងចំណុច ៨.៨.៨ គយ.សប ត្រូវបន្តលើកយោបល់ស្នើជាបន្ទាន់ទៅ គធ.ខប និង គ.ជ.ប ដើម្បីសុំឱ្យមានការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទាំងនោះ ។

៨.៨.១០ ការិយាល័យបោះឆ្នោតផ្សេងទៀតនៃឃុំ សង្កាត់ ដែលមិនត្រូវបានបិទ ត្រូវចាត់ចែងអនុវត្តដំណើរការបោះឆ្នោត ការបិទការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការវេចខ្ចប់ និងការប្រគល់ ទទួលសម្ភារ ឯកសារជាធម្មតាតាម ប.ន.ត.រ នេះ ។

៨.៨.១០.១ គយ.សប ត្រូវរក្សាទុក និងការពារសន្លឹកឆ្នោត ដែលបានប្រើប្រាស់ហើយ និងមិនទាន់ប្រើប្រាស់ លទ្ធផលនៃការរាប់សន្លឹកឆ្នោត និងឯកសារបោះឆ្នោតពាក់ព័ន្ធ នៃការិយាល័យដែលមិនត្រូវបានបិទនៅទីស្នាក់ការ គយ.សប ឬនៅកន្លែងធានាសុវត្ថិភាពណាមួយ ដែលត្រូវបានអនុញ្ញាតដោយ គ.ជ.ប រហូតដល់ពេលបញ្ចប់ការបោះឆ្នោតសាជាថ្មីនៅការិយាល័យ ដែលមិនត្រូវបានបើក ឬត្រូវបានបិទ ។

៨.៨.១០.២ សម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យ ដែលមិនត្រូវបានបិទ អាចត្រូវប្រមូល និងប្រគល់ទៅឱ្យ គធ.ខប ឬរក្សាទុកសិននៅ គយ.សប ទៅតាមសភាពជាក់ស្តែង ដែលសម្រេចដោយ គធ.ខប ។

៨.៨.១០.៣ គយ.សប ត្រូវរក្សាទុកសម្ភារ ឯកសារ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ដែលត្រូវបោះឆ្នោតសាជាថ្មី ។

ការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោត ដែលមិនត្រូវបានបើក ឬត្រូវបានបិទ

ប្រការ ៨.៩.

គ.ជ.ប ត្រូវរៀបចំបោះឆ្នោតសាជាថ្មីក្នុងរយៈពេលមិនលើសពី ៨ (ប្រាំបី) ថ្ងៃ បន្ទាប់ពីថ្ងៃដែល គ.ជ.ប បានប្រកាសថា ការិយាល័យបោះឆ្នោតណាមួយ ឬច្រើនមិនត្រូវបានបើក ឬត្រូវបានបិទ ដោយសារ ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ។ គ.ជ.ប អាចរៀបចំការបោះឆ្នោតសាជាថ្មីនៅទីតាំងការិយាល័យបោះឆ្នោតដដែល ឬទីតាំងណាមួយមិនឆ្ងាយពីទីតាំងចាស់ ដែលមានសន្តិសុខ និងសុវត្ថិភាពល្អ ។ ក្នុងករណី មិនអាចរៀបចំការបោះឆ្នោតសាជាថ្មីតាមការកំណត់ខាងលើ ដោយមូលហេតុស្ថានភាពនៃប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន មិនទាន់វិលមករកប្រក្រតីភាពនៅឡើយ គ.ជ.ប មានសិទ្ធិសម្រេចឱ្យបន្តរៀបចំ ឬមិនបាច់រៀបចំការបោះឆ្នោតសាជាថ្មីនេះ ។

៨.៩.១ គ.ជ.ប ត្រូវកំណត់កាលបរិច្ឆេទ និងទីតាំងការិយាល័យបោះឆ្នោត ដែលត្រូវបោះឆ្នោតសាជាថ្មី និងណែនាំឱ្យ គយ.សប ផ្សព្វផ្សាយ និងបិទផ្សាយនៅ គយ.សប និងទីតាំងការិយាល័យបោះឆ្នោតដែលត្រូវបោះឆ្នោតសាជាថ្មីយ៉ាងតិច ៣ (បី) ថ្ងៃ មុនថ្ងៃបោះឆ្នោតសាជាថ្មី ។

៨.៩.២ ដើម្បីរៀបចំ និងចាត់ចែងការបោះឆ្នោតសាជាថ្មី គ.ជ.ប ត្រូវណែនាំដោយឡែកចំពោះ គធ.ខប និង គយ.សប ពាក់ព័ន្ធអំពីការងារជាក់ស្តែងទាក់ទងនឹងការបោះឆ្នោតសាជាថ្មី ។

៨.៩.៣ ដើម្បីរៀបចំ និងចាត់ចែងការបោះឆ្នោតសាជាថ្មី គ.ជ.ប ត្រូវ ៖

៨.៩.៣.១ រក្សាសមាសភាព គធ.ខប និងមន្ត្រីបម្រើការងារនៅ គធ.ខប មួយចំនួនតាមតម្រូវការនៃការងារ ។

៨.៩.៣.២ រក្សាសមាសភាព គយ.សប ពាក់ព័ន្ធ ។

៨.៩.៣.៣ រក្សាសមាសភាព គ.ក.ប ដែលធ្លាប់បម្រើការងារនៅការិយាល័យដែលត្រូវបានបិទនោះ ឬទាំងនោះ ឬតែងតាំង គ.ក.ប ដែលធ្លាប់បម្រើការងារនៅការិយាល័យបោះឆ្នោតផ្សេងទៀត ដើម្បីងាយស្រួល និងពុំចាំបាច់ធ្វើការបណ្តុះបណ្តាលជាថ្មីឡើយ ។

៨.៩.៤ អាណត្តិរបស់ គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ សម្រាប់ការបោះឆ្នោតសាជាថ្មី ត្រូវបញ្ចប់តាមការកំណត់របស់ គ.ជ.ប ។

៨.៩.៥ សិទ្ធិអំណាច និងការកិច្ចរបស់ គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ ត្រូវអនុលោមតាម ច.គ.ជ.ប ច.ប.ត.រ ប.ន.ត.រ នេះ ទៅតាមតម្រូវការជាក់ស្តែងនៃការបោះឆ្នោតសាជាថ្មី ដែលកំណត់ដោយ គ.ជ.ប ។

៨.៩.៦ អ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោតសាជាថ្មីនៅការិយាល័យនោះ ឬទាំងនោះ គឺអ្នកបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យនោះ ឬទាំងនោះ ទោះបីជាអ្នកទាំងនោះបានបោះឆ្នោតហើយក្តី ឬមិនទាន់បានបោះឆ្នោតក្តី ។

៨.៩.៧ ដើម្បីបោះឆ្នោតសាជាថ្មីបាន ប្រជាពលរដ្ឋត្រូវ ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យបោះឆ្នោតនោះ ។
- មាន អ.ខ ឬ ឯ.អ ។

៨.៩.៨ គយ.សប ត្រូវសហការជាមួយមេឃុំ ចៅសង្កាត់ ចេញឯកសារបញ្ជាក់អត្តសញ្ញាណ បម្រើឱ្យការបោះឆ្នោតជូនអ្នកបោះឆ្នោត ដែលត្រូវបោះឆ្នោតសាជាថ្មីទាំងឡាយ ណាដែល អ.ខ ឬ ឯ.អ របស់គាត់ត្រូវបាត់ ឬខូច តាមសំណើសុំរបស់សាមីខ្លួន រហូតដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរសាមសិប)នាទី នៅ ១ (មួយ)ថ្ងៃ មុនថ្ងៃបោះឆ្នោតសាជាថ្មី ។

៨.៩.៩ បញ្ជីបោះឆ្នោតផ្លូវការនៃការិយាល័យពាក់ព័ន្ធ ត្រូវបានប្រើប្រាស់ សម្រាប់ការបោះឆ្នោតសាជាថ្មី ។ បញ្ជីបោះឆ្នោតនេះ ត្រូវបិទផ្សាយនៅ គយ.សប និងនៅការិយាល័យបោះឆ្នោតសាជាថ្មី ១ (មួយ)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

៨.៩.១០ សមាសភាពភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត ដែលត្រូវសង្កេតមើលការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ត្រូវរក្សាទុកដដែលសម្រាប់ការបោះឆ្នោតសាជាថ្មីនេះ ។

៨.៩.១១ គ.ជ.ប ត្រូវបោះពុម្ពសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតសាជាថ្មី តាមគំរូសន្លឹកឆ្នោតលើកមុនរបស់មណ្ឌលបោះឆ្នោតរាជធានី ខេត្តពាក់ព័ន្ធ នៅលើក្រដាសពណ៌ផ្សេងពីសន្លឹកឆ្នោតលើកមុន និងត្រូវឱ្យមានចំនួនគ្រប់គ្រាន់តាមតម្រូវការប្រើប្រាស់ ។

៨.៩.១២ គ.ជ.ប ត្រូវផ្គត់ផ្គង់សម្ភារ ឯកសារបោះឆ្នោតឱ្យបានគ្រប់គ្រាន់ និងទាន់ពេលវេលាដល់ គធ.ខប គយ.សប និង គ.ក.ប/គ.ក.រ សម្រាប់ការបោះឆ្នោតសាជាថ្មី ។

៨.៩.១៣ ក្នុងការបោះឆ្នោតសាជាថ្មី ការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តពាក់ព័ន្ធ ត្រូវបានហាមឃាត់ ។

៨.៩.១៤ ការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្រោមប្រការ ៨.៤ ប្រការ ៨.៥ និងប្រការ ៨.៦ នៃ ប.ន.ត.រ នេះ ។ ដោយឡែកការជ្រលក់ទឹកខ្មៅ លុបមិនជ្រះត្រូវធ្វើលើម្រាមដៃឆ្វេង ។

៨.៩.១៥ ការបញ្ចប់ការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តការបិទការបោះឆ្នោត ការបំពេញកំណត់ហេតុនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការប្រមូល ប្រគល់ និងទទួលសម្ភារ ឯកសារបោះឆ្នោត ដូចការបោះឆ្នោតសកល ដែលមានចែងក្នុង ប.ន.ត.រ នេះ ។

៨.៩.១៦ បន្ទាប់ពីបញ្ចប់ការបោះឆ្នោតសាជាថ្មី គយ.សប ត្រូវត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ស្របតាម ប.ន.ត.រ នេះ ។ ក្នុងការបូកសរុបលទ្ធផលនេះ គយ.សប ត្រូវបូកសរុបលទ្ធផលទូទាំងឃុំ សង្កាត់ ដោយបូកបញ្ចូលទាំងលទ្ធផលនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែល

មិនត្រូវបានបិទ ដូចមានចែងក្នុងចំណុច ៨.៨.១០ ខាងលើ ជាមួយនឹងលទ្ធផលនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលត្រូវបោះឆ្នោតសាជាថ្មី ដូចមានចែងក្នុងចំណុច ៨.៩.១៥ រួចបញ្ជូនកំណត់ហេតុការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ រួមនឹងឯកសារពាក់ព័ន្ធផ្សេងទៀតទៅ គធ.ខប ។

៨.៩.១៧ គធ.ខប ត្រូវធ្វើការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ ចំណុះរាជធានី ខេត្ត ដោយបូកបញ្ចូលទាំងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានការិយាល័យមួយ ឬច្រើន ត្រូវបោះឆ្នោតសាជាថ្មីផង ។ បន្ទាប់មក គធ.ខប ត្រូវបញ្ជូនកំណត់ហេតុនេះទៅ គ.ជ.ប ដោយភ្ជាប់ជាមួយនូវសន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ រួមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ។

៨.៩.១៨ ក្នុងអំឡុងពេលនៃដំណើរការបោះឆ្នោតសាជាថ្មី រហូតដល់ការប្រកាសលទ្ធផលផ្លូវការ ការប្តឹងតវ៉ា ឬ/និងការប្តឹងជំទាស់ ការប្រជុំសម្រេច ឬ/និងសវនាការដោះស្រាយពាក្យបណ្តឹងទាក់ទងនឹងការបោះឆ្នោតសាជាថ្មីនេះ ត្រូវអនុវត្តតាមនីតិវិធីដូចគ្នានឹងការបោះឆ្នោតសកល ដែលមានចែងក្នុង ប.ន.ត. រ នេះ ។

ការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត

ប្រការ ៨.១០..

យោងមាត្រា ១១៦ នៃ ច.ប.ត.រ ការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ បន្ទាប់ពីបិទការបោះឆ្នោត និងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួច លើកលែងតែការិយាល័យបោះឆ្នោតណាដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាល:ទេស:មានអាសន្ន ហើយដែល គ.ជ.ប បានសម្រេចឱ្យ គយ.សប ចាត់ចែងរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ នៅទីស្នាក់ការ គយ.សប ឬនៅកន្លែងណាមួយដែលមានសុវត្ថិភាព ។

៨.១០.១ ក្នុងករណីដែលការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅការិយាល័យបោះឆ្នោត ការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត ហើយ គ.ក.ប នឹងក្លាយទៅជា គ.ក.រ ។ ក្នុងករណីនេះ ប្រធាន គ.ក.ប នឹងក្លាយទៅជាប្រធាន គ.ក.រ ត្រូវចាត់វិធានការអនុវត្តតាមចំណុច ៨.៥.១ និង ៨.៥.៣ ប្រការ ៨.៥ ជំពូកទី ៨ នៃ ប.ន.ត.រ នេះ ហើយត្រូវចាត់ចែងរៀបចំឡើងវិញ នូវគំរូប្លង់បន្ទប់សម្រាប់ការរាប់សន្លឹកឆ្នោត ដែលក្នុងនោះត្រូវ ៖

៨.១០.១.១ រៀបចំតុធំមួយ ឬតុតូចច្រើនផ្ទុំគ្នា និងកៅអីបួនសម្រាប់សមាជិក គ.ក.រ ដោយដាក់នៅចំកណ្តាលបន្ទប់ ដើម្បីអាចឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ដើរចុះឡើងជុំវិញតុក្នុងការសង្កេតតាមដានកិច្ចប្រតិបត្តិការនៃការរាប់សន្លឹកឆ្នោត ។

៨.១០.១.២ លើកហិបឆ្នោតដាក់នៅចំកណ្តាលតុ ព្រមទាំងយកកញ្ចប់សុវត្ថិភាព " ក " ដូចបានបញ្ជាក់ក្នុងចំណុច ៨.៧.៥ និងរាល់សម្ភារ ឯកសារ និងទម្រង់បែបបទចាំបាច់ត្រៀម សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតដាក់នៅលើតុ ត្រង់កន្លែងប្រធានអង្គុយ ។

៨.១០.១.៣ ចាត់សមាជិកទី ២ និងសមាជិកទី ៣ ឱ្យសហការគ្នាការពារមាត់ទ្វារ និងបង្អួចដែលត្រូវបើកចំហ កុំឱ្យមានអ្នកចេញចូល មើលថែរក្សាសុវត្ថិភាព សម្ភារ ឯកសារបោះឆ្នោត ដែលមិនត្រូវប្រើប្រាស់ក្នុងការរាប់សន្លឹកឆ្នោត និងមើលថែរក្សាសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត ។

៨.១០.២ កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតត្រូវធ្វើនៅតែមួយកន្លែង សម្រាប់ការិយាល័យរាប់សន្លឹកឆ្នោតមួយ ។ ប្រសិនបើចាប់ផ្តើមហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយពុំត្រូវឈប់សម្រាកឡើយ ។ ប្រធាន គ.ក.រ ត្រូវចាត់ចែងត្រៀមឱ្យមានភ្លើងបំភ្លឺនៅការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីបង្ការក្នុងករណីការរាប់សន្លឹកឆ្នោត ត្រូវអូសបន្លាយដល់ពេលយប់ ។

៨.១០.២.១ ក្នុងដំណើរការនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិត ល្មមដែលអាចសង្កេតមើលឃើញសកម្មភាពនៃការរាប់សន្លឹកឆ្នោត ។

៨.១០.២.២ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលដំណើរការនៃការរាប់សន្លឹកឆ្នោត នៅតាមការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ និងត្រូវចុះឈ្មោះក្នុងបញ្ជីវត្តមាន (ទ.១១១៥) នៅមុនពេលចាប់ផ្តើមរាប់សន្លឹកឆ្នោត ។

៨.១០.២.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចផ្លាស់ប្តូរភ្នាក់ងារបម្រុងរបស់ខ្លួន (បើមាន) ឱ្យបំពេញភារកិច្ចជំនួស និងត្រូវចូលរួមឱ្យបានចប់ចុងចប់ដើម ។

៨.១០.២.៤ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចថតយករូបភាព នៅការិយាល័យរាប់សន្លឹកឆ្នោតបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ ។

៨.១០.៣ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ប្រធាន គ.ក.រ ត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយអនុប្រធាន និងសមាជិកទី១ ត្រូវអង្គុយនៅអមសងខាងតុទល់មុខគ្នា ។ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានវត្តមានក្នុងបន្ទប់ ប្រធាន គ.ក.រ ត្រូវប្រកាសចាប់ផ្តើមកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ហើយត្រូវ ៖

៨.១០.៣.១ បម្រុងទុកនៅក្បែរខ្លួនគាត់នូវ ៖

- កញ្ចប់សុវត្ថិភាព " ក " ដែលមានស្បោងប្លាស្ទិក ឬស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ។
- ទ.១២០២ សម្រាប់ចែកជូនភ្នាក់ងារគណបក្សនយោបាយបំពេញពាក្យបណ្តឹង ប្រសិនបើគាត់ស្នើសុំ។
- ស្បោងប្លាស្ទិកថ្លា សម្រាប់ដាក់សន្លឹកឆ្នោតបានការ និងស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ។
- កៅស៊ូកង ។

៨.១០.៣.២ ប្រគល់ទៅឱ្យអនុប្រធាននូវតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់ ។

៨.១០.៣.៣ ប្រគល់ទៅឱ្យលេខាធិការនូវ ទ.១១០២ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់ និងស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត ដែលត្រូវដកយកពីកញ្ចប់សុវត្ថិភាព " ក " ។

៨.១០.៣.៤ ប្រគល់ឱ្យសមាជិកទី១ នូវបិកហ្វឹតធំ ១ (មួយ)ដើម និងផ្ទាំងក្រដាសធំ ១ (មួយ)ផ្ទាំង សម្រាប់កត់ត្រាសំឡេងឆ្នោត ។

៨.១០.៣.៥ ចាត់លេខាធិការ ឱ្យចាប់ផ្តើមបំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដោយចម្លងនូវតួលេខនៃចំនួនសន្លឹកឆ្នោត ដែលបាន

ទទួល សន្លឹកឆ្នោតដែលមិនបានប្រើ សន្លឹកឆ្នោតខូច និងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ដែលតួលេខទាំងនេះត្រូវបានពិនិត្យផ្ទៀងផ្ទាត់រួចហើយដូចមានចែងក្រោមចំណុច ៨.៧.២ ខាងលើ និងដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត (ទ.១១០១) ។

៨.១០.៤ ស្ថិតនៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ ប្រធាន គ.ក.រ ត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ឱ្យច្បាស់ថា សោឃ្លុំទាំងពីរដែលចាក់ជាប់នឹងគម្របខាងក្រៅនៃហ៊ីបឆ្នោតស្ថិតក្នុងស្ថានភាពដើម រួចកាត់ផ្តាច់សោឃ្លុំទាំងនេះដោយកន្ត្រៃ ឬកូនកាំបិតដែលអាចរកបានដោយខ្លួនឯង និងបើកគម្របខាងក្រៅចេញ ។ បន្ទាប់មក ប្រធានត្រូវបន្តត្រួតពិនិត្យផ្ទៀងផ្ទាត់លេខសោឃ្លុំ ដែលចាក់ជាប់នឹងគន្លឹះខ្ជាស់បិទគម្របខាងក្នុងនៃហ៊ីបឆ្នោត និងក្រដាសស្តើងដែលបិទពាសពីលើសន្ទះបិទភ្ជិតប្រអេះ សម្រាប់ស៊ីកសន្លឹកឆ្នោត ដើម្បីបញ្ជាក់ថាគ្មានការរុះរើ រួចកាត់ផ្តាច់សោឃ្លុំ និងហែកក្រដាសនេះចោល ។ ចុងក្រោយ ប្រធានត្រូវបើកគម្របខាងក្នុងនៃហ៊ីបឆ្នោត និងចាក់សន្លឹកឆ្នោតឱ្យអស់ពីហ៊ីបឆ្នោត ដាក់នៅលើតុត្រង់ចន្លោះអនុប្រធាន និងសមាជិកទី១ ហើយដាក់ហ៊ីបឆ្នោតទទេនៅក្បែរគាត់ ។

៨.១០.៤.១ សមាជិកទី ១ ត្រូវរើសយកវត្ថុមិនមែនជាសន្លឹកឆ្នោត ដែលមិនស្ថិតនៅជាប់ជាមួយសន្លឹកឆ្នោត (បើមាន) ចេញពីគំនរសន្លឹកឆ្នោត រួចដាក់ទៅក្នុងស្រោមសំបុត្រមួយបម្រុងស្រាប់ ។

៨.១០.៤.២ លេខាធិការត្រូវកត់ត្រាអំពីករណី ដូចមានចែងក្នុងចំណុច ៨.១០.៤.១ ខាងលើ (បើមាន) ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២)។

៨.១០.៥ ប្រធាន គ.ក.រ ត្រូវបង្គាប់អនុប្រធាន និងសមាជិកទី១ឱ្យលា និងតម្រៀបសន្លឹកឆ្នោតដែលទើបបានចាក់ចេញពីហ៊ីបឆ្នោត ដោយដាក់ផ្តាប់ចុះក្រោម និងដាក់សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នងក្នុង ១(មួយ)បាច់ មាន ២៥ (ម្ភៃប្រាំ)សន្លឹកនៅពំនូកទី១ ហើយដាក់សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៅខាងខ្នង (បើមាន) នៅពំនូកទី២ ។ បន្ទាប់មក អនុប្រធាន និងសមាជិកទី១ ត្រូវរាប់សន្លឹកឆ្នោតទាំង ២ ពំនូក រួចរាយការណ៍ជូនប្រធាន អំពីចំនួនសន្លឹកឆ្នោតសរុបដែលបានរាប់ឃើញ ។ ប្រធាន គ.ក.រ ត្រូវធានាថា នីតិវិធីមួយចំនួនដូចខាងក្រោមត្រូវតែបានអនុវត្ត ៖

៨.១០.៥.១ ក្នុងករណី ចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើ មានចំនួនសរុបស្មើគ្នា នឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬស្មើនឹងចំនួនសន្លឹកឆ្នោត ដែលបានទទួលជាក់ស្តែង ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតដែលមិនបានប្រើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួននេះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត។

៨.១០.៥.២ ប្រសិនបើចំនួនសន្លឹកឆ្នោតដែលបានរាប់ខាងលើមានចំនួនតិចជាង ឬច្រើនជាងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត ឬម្យ៉ាងបើមានចំនួនតិចជាង ឬច្រើនជាងផលសងរវាងចំនួនសន្លឹកឆ្នោតរួម ដែលបានទទួលជាក់ស្តែង ដកផលបូកនៃចំនួនសន្លឹកឆ្នោតខូច និងចំនួនសន្លឹកឆ្នោតមិនបានប្រើនោះ ប្រធាន គ.ក.រ ត្រូវរាប់សន្លឹកឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៨.១០.៥ ខាងលើ ឡើងវិញជាលើកទីពីរ ។

៨.១០.៥.៣ ប្រសិនបើបន្ទាប់ពីប្រធានបានរាប់ឡើងវិញហើយ តួលេខនៃចំនួនសន្លឹកឆ្នោត នៅតែមានភាពខុសគ្នាដដែល ដូចបញ្ជាក់ក្នុងចំណុច ៨.១០.៥.២ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នានោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

៨.១០.៥.៤ ប្រធានត្រូវប្រកាសប្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៨.១០.៥.១ ឬ ៨.១០.៥.២ ឬ/និង ៨.១០.៥.៣ ខាងលើ ដើម្បីឱ្យអ្នកទាំងនោះ អាចពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនោះបាន។

៨.១០.៥.៥ អនុប្រធានត្រូវហុចសន្លឹកឆ្នោតពំនូកទី ២ ដែលគ្មានបោះត្រាសម្ងាត់ផ្លូវការនៅខាងខ្នង បើមាន ជូនប្រធានដែលគាត់ត្រូវដាក់ដោយឡែកនៅខាងស្តាំដៃគាត់ ។

៨.១០.៥.៦ អនុប្រធានត្រូវហុចសន្លឹកឆ្នោតពំនូកទី ១ ដែលខ្វាស់ជាបាច់ក្នុងមួយបាច់ ២៥ (ម្ភៃប្រាំ) សន្លឹក ជូនប្រធាន ដែលគាត់ត្រូវដាក់ដោយឡែកនៅខាងឆ្វេងដៃគាត់ ។

៨.១០.៦ បន្ទាប់ពីការផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតបានបញ្ចប់ ប្រធាន គ.ក.រ ត្រូវចាប់ផ្តើមរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ជាដំបូងត្រូវពិនិត្យផ្ទៀងផ្ទាត់សុពលភាពនៃសន្លឹកឆ្នោត រួចកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ

ហើយបន្ទាប់មក ត្រូវប្រកាសសន្លឹកឆ្នោតដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ។ ប្រធាន គ.ក.រ ត្រូវធានាថា កិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតត្រូវបានអនុវត្តតាមលំដាប់លំដោយ ដូចខាងក្រោម ៖

៨.១០.៦.១ ដោយផ្អែកតាមការកំណត់ ដូចមានចែងក្រោមប្រការ ៨.១១ ខាងក្រោម ប្រធាន គ.ក.រ ត្រូវយកសន្លឹកឆ្នោតម្តង ១ (មួយ) សន្លឹក ពីពំនូកទី១ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬជាសន្លឹកឆ្នោតមិនបានការ ព្រមទាំងត្រូវលើកបង្ហាញសន្លឹកឆ្នោតដែលបានកំណត់ហើយនោះ ដើម្បីឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចមើលឃើញច្បាស់ ។

៨.១០.៦.២ ប្រសិនបើប្រធាន គ.ក.រ កំណត់សន្លឹកឆ្នោតនោះ ជាសន្លឹកឆ្នោតមិនបានការ គាត់ត្រូវប្រកាសថា " សន្លឹកឆ្នោតមិនបានការ " រួចដាក់សន្លឹកឆ្នោតនោះ នៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដែលស្ថិតនៅខាងស្តាំដៃគាត់ ។

៨.១០.៦.៣ ប្រសិនបើប្រធាន គ.ក.រ កំណត់សន្លឹកឆ្នោតនោះ ជាសន្លឹកឆ្នោតបានការ គាត់ត្រូវប្រកាសឱ្យឮៗនូវឈ្មោះគណបក្សនយោបាយ ដែលសន្លឹកឆ្នោតនោះ ត្រូវបានអ្នកបោះឆ្នោតគូសសញ្ញាគាំទ្រ ហើយត្រូវដាក់សន្លឹកឆ្នោតនោះ ទៅតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយពាក់ព័ន្ធនីមួយៗ ។

៨.១០.៦.៤ ផ្អែកតាមការប្រកាសរបស់ប្រធាន គ.ក.រ អនុប្រធាន និងលេខាធិការ ត្រូវគូសពិន្ទុ ១ (មួយ) សម្រាប់សន្លឹកឆ្នោត ១ (មួយ) សន្លឹក ដែលគណបក្សនយោបាយណាមួយត្រូវបានទទួល តាមការណែនាំរបស់ គ.ជ.ប នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ។ ទន្ទឹមនឹងនេះ សមាជិកទី១ ត្រូវប្រើបិកហ្វឹតគូសពិន្ទុ ១ (មួយ) នៅលើផ្ទាំងក្រដាសធំ ដែលបិទភ្ជាប់នឹងជញ្ជាំង ឬលើក្តារខៀន ។

៨.១០.៦.៥ ក្នុងករណីមានការជំទាស់ចំពោះសន្លឹកឆ្នោត ដែលបានផ្ទៀងផ្ទាត់រាប់តាមចំណុច ៨.១០.៦.៣ ខាងលើ ប្រធានត្រូវដាក់សន្លឹកឆ្នោត ដែលមានការជំទាស់នោះ ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការ ដូចមានចែងក្នុងចំណុច ៨.១០.៦.២ ខាងលើ ។ សន្លឹកឆ្នោតទាំងនោះ នឹងត្រូវពិនិត្យផ្ទៀងផ្ទាត់ និងកំណត់ម្តងទៀតជាចុងក្រោយដោយអនុវត្តតាមចំណុច ៨.១០.៦.៦ ខាងក្រោម ។

៨.១០.៦.៦ នៅពេលផ្ទៀងផ្ទាត់សុពលភាព និងរាប់អស់សន្លឹកឆ្នោតពីពំនូកទី១ ប្រធាន ត្រូវបន្តយកសន្លឹកឆ្នោតម្តង ១ (មួយ)សន្លឹកៗ ពីពំនូកសន្លឹកឆ្នោតមិនបានការ មកពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ម្តងទៀតជាចុងក្រោយ ដើម្បីឱ្យប្រាកដថាជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ ។

៨.១០.៦.៧ ប្រសិនបើប្រធាន គ.ក.រ សម្រេចថា ជាសន្លឹកឆ្នោតបានការវិញ ត្រូវអនុវត្តតាមចំណុច ៨.១០.៦.៣ និង ៨.១០.៦.៤ ខាងលើ ។

៨.១០.៦.៨ ប្រសិនបើប្រធានសម្រេចថា ជាសន្លឹកឆ្នោតមិនបានការ ប្រធានត្រូវដាក់សន្លឹកឆ្នោតនោះ ទៅក្នុងពំនូកសន្លឹកឆ្នោតមិនបានការដដែល ។

៨.១០.៧ ក្នុងអំឡុងពេលនៃការពិនិត្យផ្ទៀងផ្ទាត់ និងកំណត់សន្លឹកឆ្នោត ដូចមានចែងក្នុងចំណុច ៨.១០.៦.១ និង ៨.១០.៦.៦ ខាងលើ ប្រសិនបើប្រធាន គ.ក.រ សម្គាល់ឃើញថា សន្លឹកឆ្នោតណាមួយជាសន្លឹកឆ្នោតមិនច្បាស់លាស់ ដោយយោងទៅតាមសេចក្តីណែនាំ ដូចបានបញ្ជាក់ក្រោមប្រការ ៨.១១ ខាងក្រោម គាត់ត្រូវពិភាក្សាជាមួយសមាជិកទាំងអស់នៃ គ.ក.រ អំពីសុពលភាព និងការកំណត់ប្រភេទនៃសន្លឹកឆ្នោតនោះម្តងទៀត ដើម្បីកំណត់ចុងក្រោយថា ពិតជាសន្លឹកឆ្នោតមិនបានការ ឬជាសន្លឹកឆ្នោតបានការ ។

៨.១០.៧.១ ទោះបីប្រធានកំណត់ថា ជាសន្លឹកឆ្នោតបានការក្តី ឬជាសន្លឹកឆ្នោតមិនបានការក្តី ប្រធានត្រូវប្រកាសឱ្យឮៗអំពីហេតុផលនៃការកំណត់នោះ និងត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រួតពិនិត្យសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការទាំងនោះ និងឱ្យចោទជាសំណួរចំពោះហេតុផលនៃការកំណត់របស់ប្រធាន ចំពោះសន្លឹកឆ្នោតនោះ ។ ក្នុងករណីនេះ ភ្នាក់ងារគណក្សនយោបាយ និងអ្នកសង្កេតការណ៍ មិនត្រូវបានអនុញ្ញាតឱ្យកាន់សន្លឹកឆ្នោតនោះឡើយ ។

៨.១០.៧.២ ក្នុងករណីប្រធានកំណត់ថា ជាសន្លឹកឆ្នោតបានការ ត្រូវអនុវត្តតាមចំណុច ៨.១០.៦.៣ និង ៨.១០.៦.៤ ខាងលើ ។

៨.១០.៧.៣ ក្នុងករណីប្រធានកំណត់ថា ជាសន្លឹកឆ្នោតមិនបានការ ប្រធានត្រូវដាក់សន្លឹកឆ្នោតនោះនៅពំនូកសន្លឹកឆ្នោតមិនបានការ ។

៨.១០.៧.៤ ប្រសិនបើភ្នាក់ងារគណបក្សនយោបាយណាម្នាក់ មិនឯកភាពនឹងសេចក្តីសម្រេចរបស់ប្រធាន ក្នុងការកំណត់សន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការខាងលើ ភ្នាក់ងារនោះមានសិទ្ធិលើកការជំទាស់ និងស្នើសុំឱ្យកត់ត្រាខ្លឹមសារ និងហេតុផលនៃការជំទាស់នោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។ ខ្លឹមសារ និងហេតុផលនៃការជំទាស់នោះ មិនត្រូវបានកត់ត្រាឡើយ ក្នុងករណីភ្នាក់ងារនោះមិនយល់ព្រមចុះហត្ថលេខាលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

៨.១០.៧.៥ សេចក្តីសម្រេចរបស់ប្រធាន ត្រូវតែមានប្រសិទ្ធភាព ក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ហើយប្រធានត្រូវប្រកាសបន្តដំណើរការរាប់សន្លឹកឆ្នោតតទៅទៀត ។

៨.១០.៧.៦ ការកំណត់ដូចមានចែងក្នុងចំណុច ៨.១០.៧.៥ ខាងលើ មិនបានត្រាន ចោលជាមុននូវការណ៍ ដែលភ្នាក់ងារគណបក្សនយោបាយណាម្នាក់ចង់បន្តប្តឹងជំទាស់ទៅ គយ.សប អំពីករណីដែលគាត់បានលើកជំទាស់ដូចមានចែងក្នុងចំណុច ៨.១០.៧.៤ ខាងលើនោះទេ ប៉ុន្តែគាត់ត្រូវតែយល់ព្រមទទួលយកនូវវិធានការ នៃការគ្រប់គ្រងរបស់ប្រធាន គ.ក.រ និងមិនត្រូវជ្រៀតជ្រែកកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតឡើយ។

៨.១០.៧.៧ ប្រធានត្រូវផ្តល់ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ជូនភ្នាក់ងារគណបក្សនយោបាយតាមសំណើសុំ សម្រាប់បំពេញពាក្យបណ្តឹងទៅ គយ.សប។

៨.១០.៨ ដើម្បីរក្សាការសម្ងាត់នៃការបោះឆ្នោតក្នុងការិយាល័យរាប់សន្លឹកឆ្នោត ក្នុងពេលកំពុងរាប់សន្លឹកឆ្នោត ហាមជនគ្រប់រូបព្យាយាមធ្វើសកម្មភាពដោយទុច្ចរិត ក្នុងគោលបំណងកត់សម្គាល់ ដើម្បីឱ្យដឹងថាតើអ្នកបោះឆ្នោតណាម្នាក់ ឬច្រើននាក់ បានបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ។

៨.១០.៨.១ ជនណាក៏ដោយដែលបានធ្វើសកម្មភាព ដូចមានចែងក្នុងចំណុច ៨.១០.៨ នឹងត្រូវទទួលការព្រមានពីប្រធាន គ.ក.រ ។ ការធ្វើសកម្មភាពដដែលឡើងវិញជាលើកទីពីរ នឹងត្រូវចាត់ទុកថាជាការរំលោភលើគោលការណ៍សម្ងាត់នៃការបោះឆ្នោត ហើយជនដែលមានការពាក់ព័ន្ធត្រូវតែបានបណ្តេញចេញពីការិយាល័យរាប់សន្លឹកឆ្នោត និងត្រូវទទួលទោសតាម ច.ប.ត.រ ។

៨.១០.៨.២ លេខាធិការត្រូវកត់ត្រាទុកនូវហេតុការណ៍នេះ ក្នុងកំណត់ហេតុ ដោយឡែក ដើម្បីធ្វើការតាមដានបន្ថែមទៀត និងរាយការណ៍ជូន គយ.សប ។

៨.១០.៨.៣ ពេលទទួលបានកំណត់ហេតុ ដូចមានចែងក្នុងចំណុច ៨.១០.៨.២ ខាងលើភ្លាម គយ.សប ត្រូវធ្វើការស៊ើបអង្កេតអំពើរំលោភនេះជាបន្ទាន់ ហើយប្រសិនបើមានភស្តុតាងបញ្ជាក់ថាពិតប្រាកដមែន ប្រធាន គយ.សប ត្រូវប្តឹងទៅ គធ.ខប ដើម្បីចាត់វិធានការទៅតាមផ្លូវច្បាប់។

៨.១០.៩ នៅពេលដែលសន្លឹកឆ្នោតទាំងអស់ត្រូវបានរាប់រួចហើយ ប្រធាន គ.ក.រ ត្រូវចាត់អនុប្រធាន និងលេខាធិការ ឱ្យបូកសរុប និងកត់ត្រាចំនួនសន្លឹកឆ្នោតមិនបានការសរុប ចំនួនសន្លឹកឆ្នោតបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតបានការដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ នៅលើតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ព្រមទាំងបង្ហាប់សមាជិកទី១ ឱ្យធ្វើកិច្ចការដូចគ្នានេះ នៅលើផ្ទាំងក្រដាសធំ ដែលបានប្រើសម្រាប់គូសសំឡេងឆ្នោត ។ ទន្ទឹមនេះ ដោយមានការពិនិត្យសង្កេតមើលរបស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ប្រធាន គ.ក.រ ត្រូវរាប់ចំនួនសន្លឹកឆ្នោតបានការតាមពំនូកដោយឡែកសម្រាប់គណបក្សនយោបាយនីមួយៗ និងតាមពំនូកសន្លឹកឆ្នោតមិនបានការ ហើយត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខចំនួនសន្លឹកឆ្នោតដែលបានរាប់ឃើញ ជាមួយនឹងតួលេខចំនួនសន្លឹកឆ្នោតដែលអនុប្រធាន លេខាធិការ និងសមាជិកទី១ បានបូកសរុបឃើញខាងលើ ។ ប្រធាន គ.ក.រ ត្រូវធានាថា តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ទាំង ២ (ពីរ) ច្បាប់ និងផ្ទាំងក្រដាសធំកត់ត្រាសំឡេងឆ្នោត ១ (មួយ) ផ្ទាំង ត្រូវបានចុះហត្ថលេខាដោយលេខាធិការ ខ្លួនគាត់ផ្ទាល់ ហើយភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន អាចចុះហត្ថលេខាលើ ទ.១១០៨ បាន ។

៨.១០.១០ ប្រធាន គ.ក.រ ត្រូវប្រកាសជាចំហនូវលទ្ធផលនៃការបូកសរុប និងការរាប់ចំនួនសន្លឹកឆ្នោត ដែលបានអនុវត្តតាមចំណុច ៨.១០.៩ ខាងលើ និងត្រូវធ្វើការផ្ទៀងផ្ទាត់ដោយធ្វើប្រមាណវិធី បូកបញ្ចូលគ្នានូវចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះគាំទ្រគណបក្សនយោបាយទាំងអស់ និងចំនួនសន្លឹកឆ្នោតមិនបានការសរុប ។

៨.១០.១០.១ ប្រសិនបើផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ ស្មើគ្នាទៅនឹងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចចែងក្នុងចំណុច ៨.១០.៥ ខាងលើ លេខាធិការត្រូវកត់ត្រាតួលេខ នៃចំនួនសន្លឹកឆ្នោត ដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ និងចំនួនសន្លឹកឆ្នោតមិនបានការ ទៅក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ។

៨.១០.១០.២ ប្រសិនបើផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ មានចំនួនតិចជាងឬច្រើនជាងចំនួនសន្លឹកឆ្នោតដែលបានចាក់ចេញពីហិបឆ្នោត និងបានរាប់ដូចមានចែងក្នុងចំណុច ៨.១០.៥ ខាងលើ ប្រធានត្រូវរាប់សន្លឹកឆ្នោតតាមពំនូកដោយឡែក សម្រាប់គណបក្សនយោបាយនីមួយៗ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការឡើងវិញម្តងទៀត ។

៨.១០.១០.៣ ប្រសិនបើបន្ទាប់ពីប្រធានបានរាប់ឡើងវិញ និងធ្វើប្រមាណវិធីបូកឃើញផលបូកនៃចំនួនសន្លឹកឆ្នោតទាំងនេះ នៅតែមានភាពខុសគ្នាដដែល ម្យ៉ាងប្រសិនបើគ្មានព្រឹត្តិការណ៍ណាមួយរំខានដល់ការរាប់សន្លឹកឆ្នោតទេ ឬ/និងគ្មានសន្លឹកឆ្នោតណាមួយ ឬច្រើន ត្រូវបានគេរកឃើញនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត ដោយសារការធ្លាក់ជ្រុះទេនោះ ត្រូវសន្មតថាភាពខុសគ្នានេះ បានកើតឡើងមុនជាយថាហេតុ ។ ក្នុងករណីនេះ លេខាធិការត្រូវកត់ត្រាតួលេខនៃចំនួនខុសគ្នាទាំងនោះ ក្នុងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ។

៨.១០.១១ ប្រធាន គ.ក.រ ត្រូវធានាថា សន្លឹកឆ្នោតបានការដែលបោះគាំទ្រគណបក្សនយោបាយនីមួយៗ ត្រូវបានចងនឹងកៅស៊ូកងឱ្យជាប់ដោយឡែកពីគ្នា ។

៨.១០.១២ ប្រធាន គ.ក.រ ត្រូវធានាថា សន្លឹកឆ្នោតមិនបានការទាំងអស់ត្រូវបានចងនឹងកៅស៊ូកង និងដាក់បញ្ចូលទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ជងថា " សន្លឹកឆ្នោតមិនបានការ " ។

៨.១០.១៣ ប្រធាន គ.ក.រ ត្រូវធានាថាសន្លឹកឆ្នោតបានការ ដែលបានចងនឹងកៅស៊ូកង ដូចមានចែងក្នុងចំណុច ៨.១០.១១ ស្រោមសំបុត្រដាក់សន្លឹកឆ្នោតមិនបានការ ដូចមានចែង

ក្នុងចំណុច ៨.១០.១២ ផ្ទាំងក្រដាសកត់ត្រាសំឡេងឆ្នោតដូចមានចែងក្នុងចំណុច ៨.១០.៩ និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (បើមាន) ដូចមានចែងក្នុងចំណុច ៨.១០.៤.១ ខាងលើ ត្រូវបានដាក់រួមគ្នាក្នុងស្បោងប្លាស្ទិកតែមួយ ដែលមានបោះពុម្ពសម្គាល់ពីខាងក្រៅថា " សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការនៃការិយាល័យបោះឆ្នោតលេខ..." បន្ទាប់មកត្រូវចងមាត់ស្បោងប្លាស្ទិកនេះ និងត្រូវសរសេរលេខកូដការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដោយប្រើប៊ិកហ្វឺតធំលុបមិនជ្រះ នៅលើផ្នែកខាងក្រៅនៃស្បោងប្លាស្ទិកដើម្បីត្រៀមបញ្ជូន និងប្រគល់ជូន គយ.សប។

៨.១០.១៤ បន្ទាប់ពីបានអនុវត្តតាមលក្ខខណ្ឌដូចមានចែងក្រោមប្រការ ៨.១០ ខាងលើ ប្រធាន គ.ក.រ ត្រូវចាត់លេខាធិការ អនុប្រធាន និងសមាជិកទី១ បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) សម្រាប់ការិយាល័យរបស់ខ្លួន តាមចំនួនដែលត្រូវប្រើប្រាស់ និងបានចុះហត្ថលេខាដោយលេខាធិការ និងប្រធាន ព្រមទាំងបោះត្រាសម្រាប់បន្តចាត់ចែងអនុវត្ត ដូចមានបញ្ជាក់ក្នុងប្រការ ៨.១២ ខាងក្រោម និងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន និងបញ្ជូនទៅ គយ.សប ជាបន្ទាន់ ដើម្បីស្រង់ជាលទ្ធផលបឋមនៃការបោះឆ្នោត ។

៨.១០.១៥ ក្នុងអំឡុងពេលនៃការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀង ស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣៧ នៃ ច.ប.ត.រ និងប្រការ ៧.១១ នៃ ប.ន.ត.រ នេះ ។

សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ

ប្រការ ៨.១១.

ដើម្បីអនុវត្តកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតបានល្អត្រឹមត្រូវ សមាសភាពទាំងអស់នៃ គ.ក.រ ជាពិសេស ប្រធាន និងអនុប្រធាន គ.ក.រ ត្រូវយល់ដឹងយ៉ាងច្បាស់លាស់អំពីលក្ខណៈនៃសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

៨.១១.១ សន្លឹកឆ្នោតបានការ គឺជាសន្លឹកឆ្នោតផ្លូវការដែលបានផ្តល់ជូនដោយ គ.ជ.ប សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រតាមមណ្ឌលរាជធានី ខេត្តនីមួយៗ និងមាន

បោះគ្រាសម្ងាត់នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធនៅផ្នែកខាងខ្នង ហើយដែលនៅលើសន្លឹកឆ្នោតនោះ អ្នកបោះឆ្នោតបានបញ្ជាក់យ៉ាងច្បាស់ពីឆន្ទៈរបស់ខ្លួន ដោយមានគូសសញ្ញាគាំទ្រក្នុងប្រអប់ចន្លោះជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយដែលគាត់ពេញចិត្ត។

៨.១១.២ សន្លឹកឆ្នោតមិនបានការ គឺជាសន្លឹកឆ្នោតដែលត្រូវបានចាត់ទុកជាមោឃៈ ដែលក្នុងនោះ រួមមានសន្លឹកឆ្នោតដែលមិនមែនជាសន្លឹកឆ្នោតផ្លូវការ ឬ/និងសន្លឹកឆ្នោតដែលគ្មានគំនូស ឬមានគំនូស ប៉ុន្តែ គ.ក.រ ពុំអាចសន្និដ្ឋានបានថា បោះគាំទ្រឱ្យគណបក្សនយោបាយណាមួយ ឬ/និងសន្លឹកឆ្នោតដែលមានសញ្ញានាំឱ្យគេស្គាល់អ្នកបោះឆ្នោត ឬ/និងសន្លឹកឆ្នោតដែលមានរហែក ឬប្រឡាក់ខូច ឬ/និងសន្លឹកឆ្នោតដែលគ្មានបោះគ្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។ សន្លឹកឆ្នោតមិនបានការរួមមាន ៥ (ប្រាំ) ប្រភេទ ដូចខាងក្រោម ដែលត្រូវបានចាត់ទុកជាមោឃៈ។

៨.១១.២.១ សន្លឹកឆ្នោតមិនផ្លូវការ ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតមានខ្នាតតូចជាង ឬធំជាងសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។
- សន្លឹកឆ្នោតបោះពុម្ពលើក្រដាសផ្សេង (ក្រាស់ជាង ឬស្តើងជាង) ខុសគ្នាពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប ។
- សន្លឹកឆ្នោតមានពណ៌ផ្សេងខុសពីសន្លឹកឆ្នោតផ្លូវការរបស់ គ.ជ.ប។
- សន្លឹកឆ្នោត ដែលគ្មានឈ្មោះគណបក្សនយោបាយមួយ ឬច្រើនដែលបានឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ ។
- សន្លឹកឆ្នោត ដែលមានឈ្មោះគណបក្សនយោបាយលើសពីចំនួនគណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ ។
- សន្លឹកឆ្នោតបោះពុម្ពមានខុសឈ្មោះ ឬ/និងខុសលំដាប់លេខរៀងនៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ ។
- សន្លឹកឆ្នោតក្លែងបន្លំ ឬក្លែងក្លាយ ដែលមានខ្លឹមសារមិនគ្រប់គ្រាន់ មិនត្រឹមត្រូវ ឬ/និងមានខ្លឹមសារផ្សេងមិនដូចសន្លឹកឆ្នោត ដែល គ.ជ.ប បានបោះពុម្ពជាផ្លូវការ និងដែលមិនបានផ្តល់ឱ្យដោយ គ.ក.ប ពាក់ព័ន្ធ ។

៨.១១.២.២ សន្លឹកឆ្នោតគ្មានគំនូស ឬមានគំនូសដែល គ.ក.រ ពុំអាចសន្និដ្ឋានបានថាបោះគាំទ្រគណបក្សនយោបាយណាមួយត្រូវបានកំណត់ ដូចខាងក្រោម ៖

- សន្លឹកឆ្នោតគ្មានគំនូសសញ្ញាអ្វីទាំងអស់ (សន្លឹកឆ្នោតទំនេរ) ។
- សន្លឹកឆ្នោតមានគូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយលើសពីមួយគណបក្ស ។
- សន្លឹកឆ្នោតមានគំនូសសញ្ញាក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយ ដោយគូសហួសចូលទៅក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយមួយទៀត ។
- សន្លឹកឆ្នោតមានគំនូសសញ្ញាមួយ ឬច្រើន នៅក្រៅប្រអប់បួនជ្រុងទ្រវែងរបស់គណបក្សនយោបាយណាមួយ ទោះបីជាសន្លឹកឆ្នោតនោះមាន ឬគ្មានគំនូសសញ្ញាគាំទ្រក្នុងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយក៏ដោយ ។

៨.១១.២.៣ សន្លឹកឆ្នោតមានគំនូសសញ្ញា ឬរូបភាពផ្សេងៗ ដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតមានសរសេរពាក្យពេចន៍ ពាក្យអធិប្បាយ ឬឃ្លាប្រយោគផ្សេងៗ ទោះនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។
- សន្លឹកឆ្នោតមានផ្ដិតស្នាមម្រាមដៃ ទោះបីនៅក្នុងប្រអប់ ឬក្រៅប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬ/និងនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។
- សន្លឹកឆ្នោតមានបិទតែម ឬក្រដាសប្រាក់ ឬក្រដាសបកបិទ ឬក្រដាសមានសំណេរ ឬរូបសញ្ញាផ្សេងៗ ភ្ជាប់នឹងប្រអប់បួនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ឬនៅលើផ្នែកខាងមុខ ឬខាងខ្នងនៃសន្លឹកឆ្នោត ។
- សន្លឹកឆ្នោតមានឯកសារផ្សេងៗបិទ ឬខ្ទាស់ជាប់ជាមួយ ។
- សន្លឹកឆ្នោតមានសរសេរឈ្មោះ ឬហត្ថលេខា ឬសញ្ញាដែលនាំឱ្យគេស្គាល់អត្តសញ្ញាណអ្នកបោះឆ្នោត ។

๘.๑๑.๒.๔ សន្លឹកឆ្នោតរហែក ឬប្រឡាក់ខូចមិនអាចយកជាការបាន ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតរហែកដាច់បាត់លេខរៀង ឬប្រអប់បូនជ្រុងទ្រវែងនៃគណបក្សនយោបាយណាមួយ ។
- សន្លឹកឆ្នោតរហែកដាច់ចេញពីគ្នាទាំងស្រុង ។
- សន្លឹកឆ្នោតដែលមានប្រឡាក់ពណ៌នៅលើផ្នែកខាងមុខ ឬ/និងនៅផ្នែកខាងខ្នង ដែលមិនអាចមើលយល់នូវរូបសញ្ញា និងអក្សរដែលត្រូវបានបោះពុម្ពនៅលើសន្លឹកឆ្នោត ឬ/និងគំនូសសញ្ញាដែលបោះគាំទ្រគណបក្សនយោបាយណាមួយ ។

๘.๑๑.๒.๕ សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ជាផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ត្រូវបានកំណត់ដូចខាងក្រោម ៖

- សន្លឹកឆ្នោតគ្មានបោះត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។
- សន្លឹកឆ្នោតមានបោះត្រាសម្ងាត់ ប៉ុន្តែពុំមែនជាត្រាសម្ងាត់ផ្លូវការនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

ការរៀបចំ និងការវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ

ប្រការ ៨.១២.

នៅពេលដែលកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដូចមានចែងក្រោមប្រការ ៨.១០ ខាងលើ ត្រូវបានបំពេញរួចរាល់ ប្រធាន គ.ក.រ ត្រូវធានាថា តារាងកត់ត្រាសំឡេងឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១០៨) ចំនួន ២ (ពីរ) ច្បាប់ និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលលេខាធិការបានបំពេញត្រឹមត្រូវហើយដូចមានចែងក្នុងចំណុច ៨.១០.១៤ ត្រូវបានចុះហត្ថលេខាដោយលេខាធិការ និងខ្លួនគាត់ផ្ទាល់ព្រមទាំងបោះត្រា ។ ប្រធាន គ.ក.រ ត្រូវចាត់ចែងវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនព្រមទាំងរាល់សម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ដើម្បីបញ្ជូនទៅ គយ.សប ។

๘.១២.១ ប្រធាន គ.ក.រ ត្រូវដាក់បង្ហាញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ដូចមានចែងក្នុងប្រការ ៨.១២ ខាងលើ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យព្រមទាំងអញ្ជើញភ្នាក់ងារគណបក្សនយោបាយ ឱ្យចូលរួមចុះហត្ថលេខាជាសាក្សី ។

៨.១២.១.១ ភ្នាក់ងារគណបក្សនយោបាយអាចចុះហត្ថលេខា ជាសាក្សីលើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតខាងលើ ។

៨.១២.១.២ ការមិនព្រមចុះហត្ថលេខា លើកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោឃៈនៃកំណត់ហេតុនេះបានទេ ។

៨.១២.២ ប្រធាន គ.ក.រ ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ១ (មួយ) ច្បាប់ និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ) ច្បាប់ ដូចមានចែងក្នុងចំណុច ៨.១០.៩ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ជងថា " ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គ.ជ.ប " ។ បន្ទាប់មក ប្រធាន គ.ក.រ ត្រូវរៀបចំវេចខ្ជប់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ព្រមទាំងរាល់ស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ហើយត្រូវបិទភ្ជិតដោយការសុវត្ថិភាពដែលបម្រុងស្រាប់ និងបំពេញលេខកូដការិយាល័យពាក់ព័ន្ធឱ្យបានត្រឹមត្រូវ ។ ប្រធាន គ.ក.រ ត្រូវធានាថា នៅក្នុងកញ្ចប់សុវត្ថិភាព " ក " រួមមានសម្ភារ ឯកសារដូចខាងក្រោម ៖

៨.១២.២.១ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គ.ជ.ប។

៨.១២.២.២ ស្រោមសំបុត្រដាក់បញ្ជីបោះឆ្នោតដែលបានប្រើក្នុងការបោះឆ្នោត ។

៨.១២.២.៣ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតខូច " (បើមាន) ។

៨.១២.២.៤ ស្បោងប្លាស្ទិកដាក់ " សន្លឹកឆ្នោតមិនបានប្រើ និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ " ។

៨.១២.២.៥ ស្រោមសំបុត្រតូចដាក់ត្រាសម្ងាត់ ។

៨.១២.២.៦ ស្រោមសំបុត្រដាក់ " សន្លឹកឆ្នោតមិនត្រឹមត្រូវដែលបានដកហូត " (បើមាន) ។

៨.១២.២.៧ ស្រោមសំបុត្រដាក់ឯកសារកស្តុតាង ដែលបានដកហូត (បើមាន) ។

៨.១២.២.៨ ស្បោងប្លាស្ទិកដាក់សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ ផ្ទាំងក្រដាសធ្វើកត់ត្រាសំឡេងឆ្នោត និងស្រោមសំបុត្រដាក់វត្ថុមិនមែនជាសន្លឹកឆ្នោត (បើមាន) ដូចមានចែងក្នុងចំណុច ៨.១០.១៣ ខាងលើ ។

៨.១២.៣ ប្រធាន គ.ក.រ ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ១ (មួយ)ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាឧ្នងថា " កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គយ.សប " ដូចមានចែងក្នុងចំណុច ៨.៧.៤.៣ ខាងលើ ។

៨.១២.៤ ប្រធាន គ.ក.រ ត្រូវដាក់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាឧ្នងថា " កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតផ្ញើជូន គធ.ខប " ដូចមានចែងក្នុងចំណុច ៨.៧.៤.២ ខាងលើ ។

៨.១២.៥ ប្រធាន គ.ក.រ ត្រូវចាត់សមាជិកទី២ ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ ជាសាធារណៈនៅត្រង់ច្រកចូលទីតាំងការិយាល័យបោះឆ្នោត ព្រមទាំងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។

៨.១២.៦ ប្រធាន គ.ក.រ ត្រូវចាត់សមាជិកទី២ ឱ្យនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ១ (មួយ) ច្បាប់ ទៅប្រគល់ជូន គយ.សប សម្រាប់ចូកសរុបជាលទ្ធផលបឋម និងបញ្ជូនបន្តទៅ គ.ជ.ប តាមនីតិវិធីកំណត់ដោយ គ.ជ.ប ។

៨.១២.៧ ប្រធាន គ.ក.រ ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញលម្អិតមុខសម្ភារ ឯកសារបោះឆ្នោតដោយលេខាធិការ និងចុះហត្ថលេខាដោយប្រធានផ្ទាល់ សម្រាប់ប្រើក្នុងការបញ្ជូន និងប្រគល់ ទទួលស្បោង " ខ " នៅ គយ.សប ។ ប្រធាន គ.ក.រ ត្រូវ ៖

៨.១២.៧.១ ដាក់ ១ (មួយ) ច្បាប់ ក្នុងស្រោមសំបុត្ររួចដាក់ទៅក្នុងស្បោង " ខ "។

៨.១២.៧.២ ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង " ខ " ។

៨.១២.៧.៣ រក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការចុះហត្ថលេខា ប្រគល់ទទួលស្បោង " ខ " នៅ គយ.សប ។

៨.១២.៨ ប្រធាន គ.ក.រ ត្រូវធានាក្នុងការវេចខ្ចប់ដាក់ក្នុងស្បោង " ខ " ដើម្បីបញ្ជូនទៅ គយ.សប នូវសម្ភារ ឯកសារបោះឆ្នោត ដូចខាងក្រោម ៖

៨.១២.៨.១ កញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ដូចមានចែងក្នុងចំណុច ៨.១២.២ ខាងលើ ។

៨.១២.៨.២ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោតផ្ញើជូន គយ.សប ដូចមានចែងក្នុងចំណុច ៨.១២.៣ ខាងលើ ។

៨.១២.៨.៣ ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតផ្ញើជូន គធ.ខប ដូចមានចែងក្នុងចំណុច ៨.១២.៤ ខាងលើ ។

៨.១២.៨.៤ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារឯកសារបោះឆ្នោត ១ (មួយ) ច្បាប់ ដូចមានចែងក្នុងចំណុច ៨.១២.៧.១ ខាងលើ ។

៨.១២.៨.៥ ស្រោមសំបុត្រតូចមួយដាក់ត្រាការិយាល័យបោះឆ្នោត (ដាក់ក្រោយពេលបានបោះត្រាលើ ទ.១១០៧ រួចរាល់ហើយ) ។

៨.១២.៩ ប្រធាន គ.ក.រ ត្រូវធានាថា ស្បោង " ខ " ដែលផ្ទុកសម្ភារ ឯកសារបោះឆ្នោត ដូចមានចែងក្រោមចំណុច ៨.១២.៨ ខាងលើ ត្រូវបានចងភ្ជិត ចាក់សោយ៉ាំមានលេខសរសេរលេខកូដការិយាល័យបោះឆ្នោតឱ្យបានត្រឹមត្រូវ ដោយប្រើបិកហ្វីតលុបមិនជ្រះ និងដាក់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១(មួយ)ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង " ខ " ។

៨.១២.១០ ប្រធាន គ.ក.រ ត្រូវអនុញ្ញាតឱ្យភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ បានសង្កេតមើលក្នុងរាល់ដំណើរការនៃការរៀបចំ និង

វេចខ្ចប់សម្ភារ ឯកសារបោះឆ្នោតសម្រាប់ការបញ្ជូនទៅ គយ.សប និងបានកត់ត្រាលេខសោឃ្លុំ ដែលបានចាក់នៅត្រង់មាត់ស្បោង " ខ " ដូចចែងក្នុងចំណុច ៨.១២.៩ ខាងលើ ។

៨.១២.១១ ប្រធាន គ.ក.រ ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលត្រូវផ្ញើជូន គ.ជ.ប វិញដូចជា ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ទឹកខ្មៅ លុបមិនជ្រះ ស្លាកសញ្ញាការិយាល័យបោះឆ្នោតជាដើម ហើយត្រូវបញ្ជូន និងប្រគល់សម្ភារ ឯកសារបោះឆ្នោតទាំងនោះជូន គយ.សប អមជាមួយនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។ ប្រធាន គ.ក.រ ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ ត្រូវបានបំពេញលម្អិតមុខសម្ភារ ឯកសារនៅសល់ទាំងអស់ សម្រាប់ប្រើក្នុងពេលប្រគល់ទទួលនៅ គយ.សប ។ ទន្ទឹមនេះ ប្រធាន គ.ក.រ ត្រូវយកបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ជូន គយ.សប ស្របពេលនឹងការបញ្ជូនសម្ភារ ឯកសារបោះឆ្នោត ។

ការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅទីស្នាក់ការ គយ.សប

ប្រការ ៨.១៣..

បន្ទាប់ពីបានធ្វើការវេចខ្ចប់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតរួចសព្វគ្រប់ហើយ ប្រធាន គ.ក.រ ត្រូវចាត់វិធានការចាំបាច់ទាំងឡាយក្នុងការបញ្ជូនជាបន្ទាន់នូវស្បោង " ខ " ដូចចែងក្នុងចំណុច ៨.១២.៩ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ដូចចែងក្នុងចំណុច ៨.១២.១១ ខាងលើ ឱ្យបានទៅដល់ទីស្នាក់ការ គយ.សប ក្នុងវេលាល្ងាច ឬយប់នៃថ្ងៃបោះឆ្នោត ។

៨.១៣.១ ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា និងសភាពការណ៍សន្តិសុខ ប្រសិនបើ ប្រធាន គ.ក.រ យល់ថាអាចនឹងបញ្ជូនស្បោង " ខ " និងសម្ភារ ឯកសារ ដូចមានចែងក្នុងប្រការ ៨.១៣ ខាងលើ ទៅ គយ.សប បានតាមពេលវេលាកំណត់ និងធានាបាននូវសុវត្ថិភាពនោះ ប្រធានត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានាឱ្យចូលរួមក្នុងការបញ្ជូនខាងលើ និងត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរ ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ទទួលស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅទីស្នាក់ការ គយ.សប ។

៨.១៣.២ ប្រធាន គ.ក.រ ដែលអមដំណើរដោយអនុប្រធាន ត្រូវទទួលខុសត្រូវដឹកជញ្ជូនដោយផ្ទាល់នូវស្បោង " ខ " និងសម្ភារ ឯកសារដូចមានចែងក្នុងប្រការ ៨.១៣ ខាងលើ ទៅទីស្នាក់ការ គយ.សប ។ ប្រធានត្រូវចាត់សមាជិក គ.ក.រ តាមការចាំបាច់ ដើម្បីជួយដឹកជញ្ជូនឱ្យអស់សម្ភារ ឯកសារនៅសល់ផ្សេងទៀត ។

៨.១៣.៣ ប្រសិនបើចាំបាច់ប្រធាន គ.ក.រ ត្រូវស្នើសុំកម្លាំងសន្តិសុខ ២ (ពីរ) រូប ដើម្បីអមដំណើរការដឹកជញ្ជូនស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅ គយ.សប ។

៨.១៣.៤ នៅពេលទទួលស្បោង " ខ " និងសម្ភារ ឯកសារ ដូចចែងក្នុងប្រការ ៨.១៣ ខាងលើ គយ.សប ត្រូវធានាថា បានត្រួតពិនិត្យរាល់សម្ភារ ឯកសារទាំងអស់ និងចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) បញ្ជាក់ថាបានទទួលគ្រប់ចំនួនហើយ ។ ដោយឡែកក្នុងការប្រគល់ ទទួលស្បោង " ខ " គយ.សប ត្រូវ ៖

៨.១៣.៤.១ បើកស្បោង " ខ " ត្រួតពិនិត្យសម្ភារ ឯកសារបោះឆ្នោតខាងក្នុង ដោយផ្ដែកលើលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោតទាំង ៣ (បី) ច្បាប់ ប៉ុន្តែមិនត្រូវរុះរើកញ្ចប់សុវត្ថិភាព " ក " ឡើយ ។

៨.១៣.៤.២ ចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ បន្ទាប់ពីបានត្រួតពិនិត្យត្រឹមត្រូវហើយ ។

៨.១៣.៤.៣ អញ្ជើញភ្នាក់ងារគណបក្សនយោបាយ ចូលរួមចុះហត្ថលេខាជាសាក្សីលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ។ ការមិនព្រមចុះហត្ថលេខា ពីភ្នាក់ងារគណបក្សនយោបាយមិនអាចចាត់ទុកជាមោយ:នូវលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារនេះបានទេ ។

៨.១៣.៤.៤ ប្រគល់លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ដែលចុះហត្ថលេខារួច ១ (មួយ) ច្បាប់ ជូនប្រធាន គ.ក.រ ៣ក់ព័ន្ធ ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅខាងក្រៅនៃស្បោង " ខ " វិញ និងរក្សាទុក ១ (មួយ) ច្បាប់ ចងក្រងជាឯកសារ ។

៨.១៣.៤.៥ ប្រមូលបញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ពីគ្រប់ការិយាល័យបោះឆ្នោត ដាក់ក្នុងស្រោមសំបុត្រដោយឡែកសម្រាប់ប្រគល់ជូន គធ.ខប ។

៨.១៣.៥ រាល់ស្បោង " ខ " ដែល គយ.សប បានទទួលខាងលើ ត្រូវតែបានកត់ចំណាំ និងរក្សាទុកនៅកន្លែងមានសុវត្ថិភាពដោយដាក់តាមលំដាប់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ ។

៨.១៣.៦ គយ.សប ត្រូវចាត់វិធានការយ៉ាងឬត្ត់ចត់ក្នុងការការពារសន្តិសុខ និងសុវត្ថិភាពនៃស្បោង " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ។ ក្នុងនោះ គយ.សប ត្រូវ ៖

៨.១៣.៦.១ ទាក់ទងស្នើសុំកម្លាំងសន្តិសុខ ដើម្បីយាមការពារបរិវេណទីស្នាក់ការ គយ.សប ឬអគារដែលត្រូវរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោត ។

៨.១៣.៦.២ ចាត់ចែងឱ្យមានភ្លើងបំភ្លឺ នៅទីស្នាក់ការ គយ.សប ឬអគារ ដែលត្រូវរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោត ។

៨.១៣.៧ នៅល្ងាចនៃថ្ងៃបោះឆ្នោត គយ.សប ត្រូវរង់ចាំទទួលកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ពីគ្រប់ការិយាល័យបោះឆ្នោត ដែលសមាជិកទី២ នៃ គ.ក.ប បានប្រគល់ជូន ហើយត្រូវបូកសរុបបញ្ចូលគ្នាជាលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងចាត់ចែងបញ្ជូនលទ្ធផលនេះ តាមកម្មវិធីកំណត់ដោយ គ.ជ.ប ។

ប្រការ ៨.១៤.-

ផ្អែកលើស្ថានភាពនៃចម្ងាយផ្លូវ មធ្យោបាយដឹកជញ្ជូន ពេលវេលា និងសភាពការណ៍សន្តិសុខ ប្រសិនបើប្រធាន គ.ក.រ យល់ថាមិនអាចបញ្ជូនស្បោង " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៃការិយាល័យរបស់ខ្លួន ព្រមទាំងសម្ភារ ឯកសារនៅសល់ផ្សេងទៀតទៅ គយ.សប នៅពេលល្ងាច ឬយប់នៃថ្ងៃបោះឆ្នោតបានទេនោះ ប្រធានត្រូវចាត់វិធានការ ដើម្បីថែរក្សាការពារស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅពេលយប់ នៅទីតាំងសុវត្ថិភាពណាមួយដោយត្រូវផ្តល់ព័ត៌មានអំពីបញ្ហានេះ ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា ។

៨.១៤.១ ប្រធាន គ.ក.រ ត្រូវថែរក្សាការពារស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោត ខាងលើនៅផ្ទះរបស់គាត់ ឬផ្ទះរបស់សមាជិកណាម្នាក់នៃ គ.ក.រ ឬនៅទីតាំងសុវត្ថិភាពណាមួយ ដែលបានកំណត់ ។

៨.១៤.២ ប្រធាន គ.ក.រ ត្រូវប្រាប់ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ឱ្យបានដឹងអំពីផ្ទះ ឬទីតាំងសុវត្ថិភាពដែលនឹងត្រូវរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតនៅពេលយប់ ហើយត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ឱ្យចូលរួមថែរក្សាការពារ ។ ទន្ទឹមនឹងនេះ ត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរនៅព្រឹកស្អែក និងពេលវេលានៃការប្រគល់ទទួលស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះនៅទីស្នាក់ការ គយ.សប ។

៨.១៤.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោត អាចស្នាក់នៅពេលយប់នៅផ្ទះ ឬទីតាំងសុវត្ថិភាព ដែលទទួលរក្សាការពារស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោត ។

៨.១៤.៤ ប្រធាន គ.ក.រ ត្រូវចាត់សមាជិកនៃ គ.ក.រ យ៉ាងហោចណាស់ចំនួន ៣ (បី) នាក់ គិតទាំងរូបគាត់ផង ចូលរួមក្នុងការរក្សាការពារស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតទាំងនោះ ។

៨.១៤.៥ ប្រធាន គ.ក.រ មិនត្រូវទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតចោលដោយគ្មានការយាមកាមទេ ។

៨.១៤.៦ ប្រសិនបើចាំបាច់ ប្រធាន គ.ក.រ ត្រូវស្នើសុំកម្លាំងសន្តិសុខ ២ (ពីរ) នាក់ ដើម្បីយាមការពារបរិវេណផ្ទះ ឬទីតាំងដែលរក្សាទុកស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតនៅពេលយប់ ។

៨.១៤.៧ នៅព្រឹកថ្ងៃបន្ទាប់ អនុវត្តតាមពេលវេលាដែលបានកំណត់ ប្រធាន គ.ក.រ ត្រូវទទួលបន្ទុកក្នុងការបញ្ជូនស្បោង " ខ " និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតទៅប្រគល់ជូន គយ.សប ។ ក្នុងករណីនេះ បទបញ្ជា និងនីតិវិធី ដូចមានចែងក្នុងចំណុច ៨.១៣.២ ៨.១៣.៣ ៨.១៣.៤ និង ៨.១៣.៥ ខាងលើ ត្រូវតែបានអនុវត្ត ។

ការរាប់សន្លឹកឆ្នោតនៅទីស្នាក់ការ គឃ.សប ឬនៅទីតាំងសុវត្ថិភាពណាមួយ

ប្រការ ៨.១៥.

យោងមាត្រា ១១៦ នៃ ច.ប.ត.រ ចំពោះការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬច្រើនដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យរបស់ខ្លួនបាន ដោយសារករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នកើតឡើងនៅពេលបន្ទាប់ពីបានបិទការបោះឆ្នោត ព្រមទាំងធ្វើកំណត់ហេតុនៃការបោះឆ្នោតរួចរាល់ ហើយហិបឆ្នោតដែលមានសន្លឹកឆ្នោតបោះរួចនៅខាងក្នុង និងកំណត់ហេតុនៃការបោះឆ្នោត និងឯកសារពាក់ព័ន្ធនៅរក្សាបានល្អ គ.ជ.ប ត្រូវណែនាំដល់ គឃ.សប ពាក់ព័ន្ធឱ្យចាត់ចែងការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះនៅទីស្នាក់ការ គឃ.សប ឬទីតាំងសុវត្ថិភាពណាមួយ ។

៨.១៥.១ ករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ត្រូវបានកំណត់ក្នុងចំណោមករណីណាមួយដូចមានចែងក្រោមចំណុច ១.៣.៣ និងចំណុច ១.៥.១ ជំពូកទី ១ នៃ ប.ន.ត.រ នេះ ។

៨.១៥.២ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ន ដែលកើតឡើងនៅក្រោយពេល គ.ក.ប បានអនុវត្តចប់សព្វគ្រប់ នូវរាល់នីតិវិធីដូចមានចែងក្រោមប្រការ ៨.៧ ខាងលើ ហើយប្រសិនបើគ្រោះអាសន្ននោះ បានបណ្តាលឱ្យខូចខាតដល់ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងឯកសារពាក់ព័ន្ធ និងរាល់កំណត់ហេតុនៃការបោះឆ្នោត ប្រធាន គ.ក.ប ត្រូវចាត់ចែងជាបន្ទាន់ដូចខាងក្រោម៖

៨.១៥.២.១ ធ្វើរបាយការណ៍ស្តីពីស្ថានភាពនៃករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្ននោះ ព្រមទាំងការខូចខាតជាក់ស្តែងជូន គឃ.សប ។

៨.១៥.២.២ ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារនៅសេសសល់ទាំងអស់ដែលអមដោយរបាយការណ៍ខាងលើ រួចបញ្ជូន និងប្រគល់ជូន គឃ.សប ។ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍អាចចូលរួមអមដំណើរក្នុងការបញ្ជូននេះ ។

៨.១៥.២.៣ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ ទទួលសម្ភារ ឯកសារនៅ គឃ.សប ។

៨.១៥.៣ នៅពេលប្រគល់របាយការណ៍ និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើ ប្រធាន គយ.សប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ជូនប្រធាន គ.ក.ប វិញ ១ (មួយ)ច្បាប់ ។

៨.១៥.៣.១ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សីលើ លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតខាងលើ ។

៨.១៥.៣.២ ការមិនព្រមចុះហត្ថលេខាពីភ្នាក់ងារគណបក្សនយោបាយ មិនអាច ចាត់ទុកជាមោឃ:នូវលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារនេះបានទេ។

៨.១៥.៤ នៅពេលទទួលបានរបាយការណ៍ដូចមានចែងក្នុងចំណុច ៨.១៥.៣ ខាងលើ គយ.សប ត្រូវបន្តលើកយោបល់ស្នើជាបន្ទាន់ទៅ គធ.ខប និង គ.ជ.ប សុំឱ្យមានការបោះឆ្នោត សាជាថ្មីនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៨.១៥.៥ ក្នុងករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាល:ទេស:មានអាសន្ន ដែលកើតឡើងនៅ ក្រោយពេល គ.ក.ប បានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធី ដូចចែងក្រោមប្រការ ៨.៧ ខាងលើ ហើយប្រសិនបើ គ្រោះអាសន្ននោះមិនបានបណ្តាលឱ្យខូចខាតដល់ ហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងកំណត់ហេតុនៃការបោះឆ្នោតទេ ប្រធាន គ.ក.ប ត្រូវចាត់ចែងជាបន្ទាន់ដូចខាងក្រោម ៖

៨.១៥.៥.១ ថែរក្សាហិបឆ្នោតដែលបានបិទភ្ជិត និងចាក់សោយ៉ាងរួច ដូចបញ្ជាក់ក្នុង ចំណុច ៨.៧.១.២ ខាងលើ ឱ្យបានហ្មត់ចត់ត្រៀមសម្រាប់ការបញ្ជូន ទៅ គយ.សប ។

៨.១៥.៥.២ រៀបចំស្រោមសំបុត្រសម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត ដូច មានចែងក្នុងចំណុច ៨.៧.៤ និងវេចខ្ចប់រាល់ស្រោមសំបុត្រ និង ស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារ ដូចមានចែងក្រោមចំណុច ៨.៧.៥ ខាងលើ ទៅក្នុងកញ្ចប់សុវត្ថិភាព " ក " ប៉ុន្តែមិនចាំបាច់បិទភ្ជិត ដោយការសុវត្ថិភាពនៅពេលនេះទេ បន្ទាប់មកត្រូវសរសេរលេខកូដ ការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៨.១៥.៥.៣ វេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់កំណត់ហេតុ នៃការបោះឆ្នោត ដូចចែងក្នុងចំណុច ៨.៧.៤.២ និង ៨.៧.៤.៣ ខាងលើ ព្រមទាំងស្រោមសំបុត្រដាក់ត្រា គ.ក.ប (បន្ទាប់ពីបោះត្រា លើ ទ.១១០៧ រួច) ទៅក្នុងស្បោង " ខ " ហើយចងភ្ជិត និងចាក់ សោយ៉ាង ។

៨.១៥.៥.៤ ប្រមូល និងវេចខ្ចប់រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ទាំងអស់ដោយឡែក ។

៨.១៥.៥.៥ បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ប្រើនៅពេលប្រគល់ ទទួលនៅ គយ.សប ។

៨.១៥.៥.៦ បញ្ជូន និងប្រគល់ហិបឆ្នោត ស្បោង " ខ " និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើជូន គយ.សប ។ ប្រធាន ដែលអមដំណើរដោយអនុប្រធាន និងសមាជិក គ.ក.ប មួយចំនួនទៀត ត្រូវទទួលបន្ទុកក្នុងការបញ្ជូន និងប្រគល់ ទទួលនេះដោយផ្ទាល់ ព្រមទាំងត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ចូលរួម និងត្រូវស្នើសុំកម្លាំងសន្តិសុខ ២ (ពីរ) នាក់ ឱ្យជួយការពារ និងជួនដំណើរនេះ ។

៨.១៥.៦ នៅពេលទទួលហិបឆ្នោតមានសន្លឹកឆ្នោតនៅខាងក្នុង ស្បោង " ខ " និងរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ខាងលើ ប្រធាន គយ.សប ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលទាំង ២ (ពីរ) ច្បាប់ រួចប្រគល់ជូនប្រធាន គ.ក.ប វិញ ១ (មួយ) ច្បាប់ ។

៨.១៥.៦.១ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខាជាសាក្សី លើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតខាងលើ។

៨.១៥.៦.២ ការមិនព្រមចុះហត្ថលេខា ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារនេះជាមោឃៈបានទេ។

៨.១៥.៧ បន្ទាប់ពីបានទទួលហិបឆ្នោតដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត ដែលមានករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាលៈទេសៈមានអាសន្នភ្លាម គយ.សប ត្រូវធ្វើការកត់ចំណាំ និងរក្សាទុកដោយឡែកនៅកន្លែងមានសុវត្ថិភាព និងត្រូវជូនដំណឹងដល់សមាសភាព គ.ក.ប ព្រមទាំងភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធ ឱ្យមកកាន់ទីស្នាក់ការ គយ.សប នៅវេលាម៉ោងប្រាំពីរ (៧:00) ព្រឹកនៃថ្ងៃបន្ទាប់ ដើម្បីរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតរបស់ខ្លួន ។

៨.១៥.៧.១ គយ.សប អាចចាត់ចែងសមាសភាព គ.ក.ប ផ្សេង ឬសមាជិក គយ.សប ឱ្យរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ប្រសិនបើ សមាសភាព គ.ក.ប ពាក់ព័ន្ធអវត្តមាន ។

៨.១៥.៧.២ សមាសភាព គ.ក.ប ដែលត្រូវបំពេញការកិច្ចរាប់សន្លឹកឆ្នោតនៅ ទីស្នាក់ការ គយ.សប ឬនៅទីតាំងណាមួយដែលមានសុវត្ថិភាព ត្រូវតែបានទទួលប្រាក់ឧបត្ថម្ភសម្រាប់ការធ្វើដំណើរ និងម្ហូបអាហារ ក្នុងអំឡុងពេលនៃកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតនោះ ។

៨.១៥.៨ តាមពេលវេលាដូចមានចែងក្នុងចំណុច ៨.១៥.៧ ខាងលើ គយ.សប ត្រូវចាត់ចែងឱ្យ រាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត ដែលជួបករណីប្រធានសក្តិ ឬអសន្តិសុខ ឬកាល:ទេស:មានអាសន្ននោះ នៅទីស្នាក់ការរបស់ខ្លួន ឬនៅទីតាំងណាមួយដែល មានសុវត្ថិភាព ។

៨.១៥.៩ នៅពេលសមាសភាព គ.ក.រ ឬមន្ត្រីបោះឆ្នោត ដែលទទួលការកិច្ចរាប់សន្លឹកឆ្នោត មានវត្តមាននៅក្នុងបន្ទប់រាប់សន្លឹកឆ្នោតហើយ ប្រធាន គយ.សប ត្រូវប្រគល់ហិបឆ្នោត ដែលមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង " ខ " ដែលមានកញ្ចប់សុវត្ថិភាព " ក " ដាក់កំណត់ហេតុនៃការបោះឆ្នោត ព្រមទាំងទម្រង់បែបបទចាំបាច់ផ្សេងទៀតឱ្យទៅ ប្រធាន គ.ក.រ ដើម្បីអនុវត្តការរាប់សន្លឹកឆ្នោត ។ ប្រធាន គ.ក.រ ត្រូវ ៖

៨.១៥.៩.១ ពិនិត្យឱ្យប្រាកដថា ហិបឆ្នោតមានសន្លឹកឆ្នោតនៅខាងក្នុង និងស្បោង " ខ " ដែលបានទទួល ពុំត្រូវបានគេរុះរើឡើយ ។

៨.១៥.៩.២ កាត់ផ្តាច់សោឃ្លុំស្បោង " ខ " និងត្រួតពិនិត្យសម្ភារ ឯកសារ បោះឆ្នោតខាងក្នុង ដោយផ្ទៀងផ្ទាត់ទៅនឹងលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ។

៨.១៥.១០ ក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោតខាងលើ រាល់បទបញ្ជា និងនីតិវិធីដូចមានចែង ក្រោមប្រការ ៨.១០ ៨.១១ និង ៨.១២ ខាងលើ ត្រូវតែបានអនុវត្ត ។ ដោយសារ ការរាប់សន្លឹកឆ្នោតនេះត្រូវបានធ្វើនៅទីស្នាក់ការ គយ.សប នីតិវិធីពាក់ព័ន្ធមួយចំនួន ត្រូវបានកំណត់ឱ្យអនុវត្តដោយឡែក ដែលក្នុងនោះ ប្រធាន គ.ក.រ ត្រូវ ៖

៨.១៥.១០.១ ទទួលខុសត្រូវនាំយកកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) មួយ ១ (មួយ) ច្បាប់ ទៅបិទផ្សាយនៅខាងមុខទីតាំងការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៨.១៥.១០.២ បង្គាប់សមាជិកទី២ ឱ្យបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ១ (មួយ) ច្បាប់ នៅខាងមុខទីស្នាក់ការ គយ.សប ព្រមទាំងបែងចែកជូនភ្នាក់ងារគណបក្សនយោបាយដែលមានវត្តមាន ។

៨.១៥.១០.៣ ធានាថា បន្ទាប់ពីការរាប់សន្លឹកឆ្នោតត្រូវបានបញ្ចប់ រាល់សម្ភារ ឯកសារបោះឆ្នោតត្រូវបានវេចខ្ចប់ក្នុងស្បោងប្លាស្ទិក ឬស្រោមសំបុត្រ និងដាក់ក្នុងកញ្ចប់សុវត្ថិភាព " ក " រួចបិទភ្ជិតដោយការសុវត្ថិភាពបម្រុងស្រាប់ ។ បន្ទាប់មកស្បោង " ខ " ត្រូវបានវេចខ្ចប់ជាថ្មីដោយដាក់សម្ភារ ឯកសារតាមលំនាំ ដូចចែងក្នុងចំណុច ៨.១២.៨ ខាងលើ រួចចងមាត់កញ្ចប់ឡើងវិញ ហើយត្រូវប្រគល់ជូន គយ.សប ដោយផ្ទាល់នៅបន្ទប់រាប់សន្លឹកឆ្នោតនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

៨.១៥.១០.៤ ប្រគល់ហិបឆ្នោតទទេ ជូន គយ.សប ។

៨.១៥.១០.៥ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារ (ទ.១១០៧) ត្រូវបានបំពេញ និងប្រើប្រាស់ក្នុងការប្រគល់ ទទួលស្របតាមការកំណត់របស់ គ.ជ.ប ។

៨.១៥.១១ នៅពេលទទួលបានស្បោង " ខ " ដូចមានចែងក្នុងចំណុច ៨.១៥.១០.៣ ខាងលើ គយ.សប ត្រូវអនុវត្តនីតិវិធីដូចមានចែងក្នុងចំណុច ៨.១៣.៤ និង ៨.១៣.៥ ខាងលើ ។

ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតទៅ គយ.សប

ប្រការ ៨.១៦.

ភ្នាក់ងារគណបក្សនយោបាយ ដែលមិនសុខចិត្តនឹងការសម្រេចរបស់ គ.ក.ប/គ.ក.រ ពាក់ព័ន្ធនឹងការតវ៉ា ឬ/និងការជំទាស់ ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ដូចចែងក្នុងចំណុច ៨.៦.២៣ ឬ/និងក្នុងកិច្ចប្រតិបត្តិការរាប់សន្លឹកឆ្នោត ដូចចែងក្រោមចំណុច ៨.១០.៧ ខាងលើ អាចបំពេញបែបបទសម្រាប់ប្តឹងទៅ គយ.សប ។ ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និង

ការរាប់សន្លឹកឆ្នោត ត្រូវធ្វើឡើងជាបន្ទាន់ស្របពេលនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតទៅ គយ.សប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០ (ដប់មួយសាមសិប) នាទី ព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។ ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើនេះ គយ.សប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថា គ្មានការប្តឹងតវ៉ា ឬប្តឹងជំទាស់ពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតឡើយ ។

៨.១៦.១ ភ្នាក់ងារគណបក្សនយោបាយ ដែលមានបំណងប្តឹងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ទិតមេដៃលើពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចខាងក្រោម ៖

- ៨.១៦.១.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ។
- ៨.១៦.១.២ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត ។
- ៨.១៦.១.៣ ពេលវេលានៃការកើតឡើងនូវភាពមិនប្រក្រតី ។
- ៨.១៦.១.៤ ប្រភេទនៃភាពមិនប្រក្រតី ឬកំហុសឆ្គង ដែលជាកម្មវត្ថុនៃបណ្តឹង ។
- ៨.១៦.១.៥ មនុស្សដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹងនេះ ។
- ៨.១៦.១.៦ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន ។
- ៨.១៦.១.៧ សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងៗទៀត បើមាន ។
- ៨.១៦.១.៨ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង បើមាន ។

៨.១៦.២ ចំពោះពាក្យបណ្តឹងដែលបានទទួលក្រោយរយៈពេលកំណត់ដូចចែងក្នុងប្រការ ៨.១៦ ខាងលើ ប្រធាន គយ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ និងប្រាប់អ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គយ.សប មិនអាចទទួលយកមកដោះស្រាយបានទេ ។

៨.១៦.៣ ចំពោះពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ គយ.សប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាក្នុងកំណត់ហេតុ ។ ក្នុងករណីដែល

ដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គយ.សប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចធ្វើឱ្យអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងធ្វើជូន គធ.ខប ១ (មួយ) ច្បាប់ ។

៨.១៦.៤ ចំពោះពាក្យបណ្តឹងដែលបានទទួលក្នុងរយៈពេលកំណត់ដូចចែងក្នុងប្រការ ៨.១៦ ខាងលើ និងមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវធ្វើកំណត់ហេតុសាកសួរ បន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនោះ ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ ។ បន្ទាប់មកត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គយ.សប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាងវិញ ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅ គយ.សប ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់ សម្រាប់ គយ.សប ប្រើក្នុងពេលប្រជុំសម្រេច។ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវជម្រាបអ្នកប្តឹងថា គយ.សប នឹងធ្វើការត្រួតពិនិត្យឡើងវិញ ព្រមទាំងប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ នៅក្នុងអំឡុងពេលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនានាក្នុងឃុំ សង្កាត់។

៨.១៦.៥ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់មានភស្តុតាងបញ្ជាក់ដែលអាចឱ្យជឿថា មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គយ.សប ត្រូវ ៖

- ៨.១៦.៥.១ ចាត់ចែងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹង ។
- ៨.១៦.៥.២ បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមប្រការ ៨.២០ ។
- ៨.១៦.៥.៣ អនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាង និងអ្នកសង្កេតការណ៍ចូលរួមសង្កេតមើលការអនុវត្តនីតិវិធីចំណុច ៨.១៦.៥.១ និង ៨.១៦.៥.២ ខាងលើ។

៨.១៦.៦ ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញដូចចែងក្នុងចំណុច ៨.១៦.៥.១ និង ៨.១៦.៥.២ ខាងលើ គយ.សប មិនឃើញមានភស្តុតាងបញ្ជាក់ថា មានកំហុសណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គយ.សប ត្រូវប្រជុំសម្រេចបដិសេធលើពាក្យបណ្តឹងនោះដោយត្រូវ ៖

៨.១៦.៦.១ ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង ។

៨.១៦.៦.២ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ លើសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដែលសមាជិកទទួលបន្ទុកសេវាកម្មច្បាប់បានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.១៦.៦.៣ ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គយ.សប ទៅ គធ.ខប ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃបានទទួល ទ.១២០៣ នេះ ។

៨.១៦.៦.៤ ប្រគល់ជូនអ្នកប្តឹង ឬតំណាងនូវ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាចំនួន ៣ (បី) ច្បាប់ បើគាត់ស្នើសុំ ។

៨.១៦.៧ ប្រសិនបើ ក្នុងការត្រួតពិនិត្យឡើងវិញដូចចែងក្នុងចំណុច ៨.១៦.៥.១ និង ៨.១៦.៥.២ ខាងលើ គយ.សប បានរកឃើញភស្តុតាងបញ្ជាក់ថា មានកំហុសណាមួយក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតនោះ គយ.សប ត្រូវប្រជុំសម្រេចយល់ព្រមលើពាក្យបណ្តឹងនោះ ដោយត្រូវ ៖

៨.១៦.៧.១ ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមកែតម្រូវតួលេខលទ្ធផលតាមពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង។

៨.១៦.៧.២ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ លើសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដែលសមាជិកសេវាកម្មច្បាប់បានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

ការដាក់ពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាក់ទងនឹងភាពមិនប្រក្រតីនៅមួយ (១) ថ្ងៃ មុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោតទៅ គយ.សប

ប្រការ ៨.១៧.-

ភ្នាក់ងារគណបក្សនយោបាយដែលមិនសុខចិត្តនឹងការសម្រេចរបស់ គ.ក.ប ពាក់ព័ន្ធនឹងការតវ៉ា ឬ/និងការជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬដែលឃើញភាពមិនប្រក្រតីនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដែលបានកើតឡើងនៅក្នុងតំបន់បោះឆ្នោតណាមួយនៅមួយ (១) ថ្ងៃមុនថ្ងៃបោះឆ្នោត និងក្នុងថ្ងៃបោះឆ្នោត អាចបំពេញបែបបទសម្រាប់ប្តឹងទៅ គយ.សប ។ ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬដែលឃើញភាពមិនប្រក្រតីណាមួយ ត្រូវធ្វើឡើងជាបន្ទាន់ស្របពេលនឹងការបញ្ជូនកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារៈឯកសារបោះឆ្នោតផ្សេងទៀតទៅ គយ.សប នៅពេលល្ងាចនៃថ្ងៃបោះឆ្នោត ឬយ៉ាងយូរបំផុតត្រឹមម៉ោង ១១:៣០ (ដប់មួយសាមសិប) នាទីព្រឹក នៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ។ ប្រសិនបើនៅក្នុងរយៈពេលកំណត់ខាងលើនេះ គយ.សប មិនបានទទួលពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានការប្តឹងតវ៉ា ឬការប្តឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬភាពមិនប្រក្រតីណាមួយឡើយ ។

៨.១៧.១ ភ្នាក់ងារគណបក្សនយោបាយដែលមានបំណងប្តឹងត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ទិតមេដៃលើពាក្យបណ្តឹង (ទ.១២០២) ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចខាងក្រោម៖

- ៨.១៧.១.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ។
- ៨.១៧.១.២ លក្ខណៈសម្គាល់នៃការិយាល័យបោះឆ្នោត ។
- ៨.១៧.១.៣ ពេលវេលានៃការកើតឡើងភាពមិនប្រក្រតី ។
- ៨.១៧.១.៤ ប្រភេទនៃភាពមិនប្រក្រតី ដែលជាកម្មវត្ថុនៃបណ្តឹង ។
- ៨.១៧.១.៥ ប្រសិនបើអាច ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ត.រ ឬ ប.ន.ត.រ ដែលត្រូវបានរំលោភ ។
- ៨.១៧.១.៦ មនុស្សដែលពាក់ព័ន្ធក្នុងភាពមិនប្រក្រតីនេះ ។
- ៨.១៧.១.៧ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន ។
- ៨.១៧.១.៨ សេចក្តីអះអាងគាំទ្រ ឬកស្តុតាងផ្សេងៗទៀត បើមាន ។
- ៨.១៧.១.៩ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង បើមាន ។

៨.១៧.២ អំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយដូចបញ្ជាក់ក្នុងប្រការ ៨.១៧ ខាងលើ ត្រូវបានកំណត់ជាក់ស្តែងតាមរយៈកិច្ចសង្កេតការណ៍ ឬការរាយការណ៍ ឬការចោទប្រកាន់ដោយមានភស្តុតាងគ្រប់គ្រាន់ ដែលរួមមានប្រភេទបទរំលោភ ដូចខាងក្រោម ៖

- ៨.១៧.២.១ ការប្រើកម្លាំងដកហូតឯកសារសម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតពីអ្នកបោះឆ្នោត។
- ៨.១៧.២.២ ការប្រើកម្លាំង ឬអំពើហិង្សា ដើម្បីរារាំងអ្នកបោះឆ្នោតមិនឱ្យទៅបោះឆ្នោត ។
- ៨.១៧.២.៣ ការគាបសង្កត់ ឬគំរាមកំហែង ឬបង្ខំអ្នកបោះឆ្នោតឱ្យស្បថថានឹងបោះឆ្នោតគាំទ្រគណបក្សនយោបាយណាមួយ ។
- ៨.១៧.២.៤ ការធ្វើឱ្យខូចរបៀបរៀបរយ ឬការអុកឡុករំខានកិច្ចប្រតិបត្តិការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតមិនឱ្យដំណើរការបាន។
- ៨.១៧.២.៥ ការញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង ឬអំពើហិង្សាទៅលើបេក្ខជននៃគណបក្សនយោបាយណាមួយ ។
- ៨.១៧.២.៦ ការប្រើកម្លាំង ឬអំពើហិង្សា ឬការបំភិតបំភ័យ ដែលបង្កឱ្យមានការភ័យខ្លាច ការភាន់ច្រឡំ ភាពច្របូកច្របល់ និងការបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។
- ៨.១៧.២.៧ ការបោកបញ្ឆោត ឬការលួងលោមដើម្បីទិញទឹកចិត្តអ្នកបោះឆ្នោតដោយការផ្តល់អំណោយជាសម្ភារ ឬប្រាក់កាស ។

៨.១៧.៣ រូបភាពនៃការបំភិតបំភ័យ ការគាបសង្កត់ ការគំរាមកំហែង ការប្រើកម្លាំង ឬអំពើហិង្សា ការរំលោភបំពាន ឬការគំរាមកំហែងដោយហិង្សា ត្រូវបានកំណត់តាមរយៈការស្តែងឡើងដោយពាក្យសម្តី ជាលាយលក្ខណ៍អក្សរ ឬដោយកាយវិការ ដូចខាងក្រោម ៖

- ៨.១៧.៣.១ ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬដោយការសរសេរជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ។

៨.១៧.៣.២ ការនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬការសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យថានឹងធ្វើទារុណកម្ម ។

៨.១៧.៣.៣ ការវាយតប់បន្ទិចបន្ទួច ឬធ្ងន់ធ្ងរលើបុគ្គលណាម្នាក់ ។

៨.១៧.៣.៤ ការរំលោភដោយពាក្យសម្តីថា នឹងធ្វើទុក្ខទោសដល់រាងកាយ។

៨.១៧.៣.៥ ការបង្ហាញ ឬការប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។

៨.១៧.៣.៦ ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដែលយោងទៅលើព្រឹត្តិការណ៍ពីអតីតកាលដូចជាឃាតកម្ម ការវាយដំ ការរំលោភ ឬការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់ ។

៨.១៧.៣.៧ ការបាញ់ដោយកាំភ្លើងបង្ហើរលើក្បាលបុគ្គលណាម្នាក់ ឬលើដំបូលផ្ទះ ឬលើយានជំនិះ ឬនៅទីកន្លែងជុំវិញខ្លួនបុគ្គលនោះ ។

៨.១៧.៣.៨ ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ខ្លួន ។

៨.១៧.៣.៩ ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលផ្ទុយនឹងឆន្ទៈរបស់ជននោះដែលធ្វើឱ្យអារម្មណ៍គាត់មានការភ័យខ្លាច ឬធ្វើឱ្យគាត់ខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសារគាត់ ។

៨.១៧.៣.១០ ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ឬដកហូតមុខតំណែង ការដកហូតដីធ្លី ផ្ទះសម្បែង ឬផលប្រយោជន៍ហិរញ្ញវត្ថុផ្សេងទៀត ។

៨.១៧.៤ ចំពោះពាក្យបណ្តឹងដែលបានទទួលក្រោយរយៈពេលកំណត់ដូចចែងក្នុងប្រការ ៨.១៧ ខាងលើប្រធាន គយ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា ពោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ឱ្យអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ និងប្រាប់អ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គយ.សប មិនអាចទទួលយកមកដោះស្រាយបានទេ ។

៨.១៧.៥ ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ គយ.សប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងកំណត់នៃការដាក់ពាក្យបណ្តឹង ហើយត្រូវកត់ត្រាក្នុងកំណត់ហេតុ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គយ.សប ត្រូវចារបដិសេធ លើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខាបោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើឱ្យអ្នកប្តឹងវិញ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.១៧.៦ ចំពោះពាក្យបណ្តឹងដែលបានទទួលក្នុងរយៈពេលកំណត់ដូចចែងក្នុងប្រការ ៨.១៧ ខាងលើ និងមានបញ្ជាក់ព័ត៌មានគ្រប់គ្រាន់ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវធ្វើកំណត់ហេតុសាកសួរបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្ទិតមេដៃលើកំណត់ហេតុនោះ ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ទិតមេដៃ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ឬសមាជិកដែលបានទទួលសិទ្ធិ ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ទិតមេដៃលើកំណត់ហេតុនេះ ។ បន្ទាប់មកត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គយ.សប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាងវិញ ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅ គយ.សប ១ (មួយ) ច្បាប់ និងទុក ១ (មួយ) ច្បាប់ សម្រាប់ គយ.សប ប្រើក្នុងពេលប្រជុំសម្រេច ។ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឬសមាជិកដែលបានទទួលសិទ្ធិត្រូវជម្រាបអ្នកប្តឹងថា គយ.សប នឹងធ្វើការត្រួតពិនិត្យឡើងវិញ ព្រមទាំងប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ នៅក្នុងអំឡុងពេលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោតនានាក្នុងឃុំ សង្កាត់ ។

៨.១៧.៧ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់មានភស្តុតាងបញ្ជាក់ដែលអាចឱ្យជឿថាមានអំពើរំលោភ ឬភាពមិនប្រក្រតីដូចខាងលើ ដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ ប្រធាន គយ.សប ត្រូវ ៖

៨.១៧.៧.១ ចាត់ចែងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោតដែលមានពាក្យបណ្តឹង ។

៨.១៧.៧.២ បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីធ្វើការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមប្រការ ៨.២០ ។

៨.១៧.៧.៣ អនុញ្ញាតឱ្យអ្នកបណ្តឹង ឬតំណាង និងអ្នកសង្កេតការណ៍ចូលរួមសង្កេតមើលការអនុវត្តនីតិវិធីចំណុច ៨.១៧.៧.១ និង ៨.១៧.៧.២ ខាងលើ។

៨.១៧.៨ ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញដូចមានចែងក្នុងចំណុច ៨.១៧.៧.១ និង ៨.១៧.៧.២ ខាងលើ គយ.សប មិនឃើញមានភស្តុតាងបញ្ជាក់ថាមានអំពើរំលោភ ឬភាពមិនប្រក្រតីណាមួយ ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតពាក់ព័ន្ធទេនោះ គយ.សប ត្រូវប្រជុំសម្រេចបដិសេធលើពាក្យបណ្តឹងនោះ ដោយត្រូវ ៖

៨.១៧.៨.១ ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង ។

៨.១៧.៨.២ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទលើសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដែលសមាជិកទទួលបន្ទុកសេវាកម្មច្បាប់បានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.១៧.៨.៣ ជម្រាបអ្នកប្តឹងថា គាត់អាចប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គយ.សប ទៅ គធ.ខប ក្នុងរយៈពេល ២ (ពីរ) ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃទទួល ទ.១២០៣ ។

៨.១៧.៨.៤ ប្រគល់ជូនអ្នកប្តឹង ឬតំណាងនូវ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ាចំនួន ៣ (បី) ច្បាប់ បើគាត់ស្នើសុំ ។

៨.១៧.៩ ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញដូចមានចែងក្នុងចំណុច ៨.១៧.៧.១ និង ៨.១៧.៧.២ ខាងលើ គយ.សប បានរកឃើញភស្តុតាងបញ្ជាក់ថា មានអំពើរំលោភ ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលអាចធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ គយ.សប ត្រូវប្រជុំសម្រេចយល់ព្រមតាមពាក្យបណ្តឹង ដោយត្រូវ ៖

៨.១៧.៩.១ ចាត់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) យល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាផង ។

៨.១៧.៩.២ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ លើសម្រង់សេចក្តីសម្រេច (ទ.១២០៣) ដែលសមាជិកទទួលបន្ទុកសេវាកម្មច្បាប់បានបំពេញ រួចប្រគល់ឱ្យអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.១៧.៩.៣ ជម្រាបអ្នកប្តឹង ឬតំណាងថា គយ.សប នឹងធ្វើរបាយការណ៍ និងលើកយោបល់ស្តីពីករណីនេះ ដោយភ្ជាប់ជាមួយនូវកំណត់ហេតុ បូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និង ទ.១២០៣ ជូន គធ.ខប ដើម្បីពិនិត្យសម្រេច ។

៨.១៧.១០ ការប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់ពាក់ព័ន្ធនឹងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ដូចមានចែងក្នុងប្រការ ៨.១៧ ខាងលើ មិនបានច្រានចោលការប្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ ឡើយ ។ ការប្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ នៃ ច.ប.ត.រ ត្រូវអនុវត្តតាមជំពូកទី១០ នៃ ប.ន.ត.រ នេះ ។

ប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត

ប្រការ ៨.១៨.-

បន្ទាប់ពីបានទទួលស្បោង " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធពីគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតចំណុះឃុំ សង្កាត់ ដូចបានបញ្ជាក់ក្នុងចំណុច ៨.១៣.៤ ៨.១៤.៧ ៨.១៥.៦ និង ៨.១៥.១០.៣ ខាងលើ គយ.សប ត្រូវចាត់វិធានការចាំបាច់នានា ដើម្បីត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនានាក្នុងឃុំ សង្កាត់ បញ្ជូលគ្នាឱ្យរួចរាល់ឆាប់រហ័ស តាមដែលអាចធ្វើបាន និងមិនត្រូវឱ្យហួសរយៈពេល ២ (ពីរ) ថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោតឡើយ ។

៨.១៨.១ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពាក់ព័ន្ធ ត្រូវបានអនុញ្ញាតឱ្យចូលរួមសង្កេតមើលប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតចំណុះឃុំ សង្កាត់ ។

៨.១៨.១.១ ភ្នាក់ងារគណបក្សនយោបាយនីមួយៗ ឬអ្នកសង្កេតការណ៍នៃអង្គការនីមួយៗប្រចាំការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ត្រូវជ្រើសតាំងឱ្យមានតំណាងរបស់ខ្លួនម្នាក់ និងតំណាងបម្រុងម្នាក់ សម្រាប់ចូលរួមសង្កេតមើលប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ ។

៨.១៨.១.២ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលដំណើរការនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ខាងលើ អាចផ្លាស់ប្តូរតំណាងបម្រុងឱ្យបំពេញការកិច្ចជំនួសខ្លួនបាន ។

៨.១៨.១.៣ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិតល្មមដែលអាចសង្កេតមើលឃើញ នូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៨.១៨.១.៤ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ អាចថតយករូបភាពនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់បាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែកធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ ។

៨.១៨.២ ប្រតិបត្តិការរបស់ គយ.សប ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយក្នុងឃុំ សង្កាត់ ប្រសិនបើ ចាប់ដំណើរការហើយត្រូវធ្វើឱ្យចប់ចុងចប់ដើមដោយមិនត្រូវឈប់សម្រាកឡើយ ។ គយ.សប ត្រូវត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយរួមបញ្ចូលទាំងលទ្ធផលនៃការបោះឆ្នោតរបស់ការិយាល័យ ដែលត្រូវបានរាប់នៅទីស្នាក់ការ គយ.សប ឬទីតាំងសុវត្ថិភាពណាមួយ រួមនឹងការិយាល័យដែលត្រូវបាន គយ.សប សម្រេចបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយផ្អែកលើបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ទៅនឹងភាពមិនប្រក្រតីដែលកើតមានឡើង (បើមាន) ។

៨.១៨.៣ គយ.សប ត្រូវបើកកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត តាមការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងឃុំ សង្កាត់ នៅទីស្នាក់ការ របស់ខ្លួន ឬនៅអគារណាមួយ ដែលតម្រូវឱ្យមានបរិវេណសន្តិសុខ ធានាបាន សុវត្ថិភាពល្អ ហើយត្រូវរៀបចំបន្ទប់តាមលំនាំគំរូប្លង់បន្ទប់រាប់សន្លឹកឆ្នោត ដូចបញ្ជាក់ ក្នុងចំណុច ៨.១០.១.១ ខាងលើ ។ ក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលខាងលើ នេះ ប្រធាន គយ.សប ត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យសមាជិកទទួលបន្ទុក រដ្ឋបាលអង្គុយនៅចុងតុម្ខាងទៀតទល់មុខគាត់ ហើយឱ្យអនុប្រធាន និងសមាជិក ទទួលបន្ទុកសេវាកម្មច្បាប់ អង្គុយនៅអមសងខាងតុទល់មុខគ្នា ។ ចំណែកសមាជិក ទទួលបន្ទុកបណ្តុះបណ្តាល ត្រូវទទួលបន្ទុកការពារមាត់ទ្វារ និងរក្សាសណ្តាប់ធ្នាប់ ក្នុងបន្ទប់ត្រួតពិនិត្យបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។ ប្រធាន គយ.សប ត្រូវ ៖

៨.១៨.៣.១ ត្រៀមនៅលើតុខាងមុខគាត់នូវ ៖

- ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹង ដែលត្រូវប្រគល់ជូន ភ្នាក់ងារគណបក្សនយោបាយតាមការស្នើសុំ ។
- ម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង ។
- សម្ភារ ឯកសារចាំបាច់ផ្សេងទៀត ។

៨.១៨.៣.២ ប្រគល់ជូនអនុប្រធាននូវ ទ.១១០៩ សម្រាប់បំពេញតារាងបូកសរុប លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និងទម្រង់បែបបទចាំបាច់ ផ្សេងទៀតសម្រាប់ប្រើក្នុងការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនេះ ។

៨.១៨.៣.៣ ប្រគល់ជូនសមាជិកទទួលបន្ទុករដ្ឋបាលនូវ ទ.១១០៣ សម្រាប់ បំពេញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ទ.១១០៩ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ និងទម្រង់បែបបទចាំបាច់ផ្សេងទៀត សម្រាប់ប្រើក្នុង ការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនេះ ។

៨.១៨.៣.៤ ប្រគល់ជូនសមាជិកទទួលបន្ទុកសេវាកម្មច្បាប់នូវ ទ.១១០៩ សម្រាប់ បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និង ទម្រង់បែបបទចាំបាច់ផ្សេងទៀតសម្រាប់ប្រើក្នុងការត្រួតពិនិត្យ និង បូកសរុបលទ្ធផលនេះ ។

ក្នុងករណីឃុំ សង្កាត់ណាគ្មានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ ឬមានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ដែលបានដាក់ក្រោយពេលវេលាកំណត់ ឬមានពាក្យបណ្តឹងតវ៉ា និងពាក្យបណ្តឹងជំទាស់ ដែលគ្មានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតី នាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយទេនោះ គយ.សប មិនអាចបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតទេ ។ ក្នុងករណីនេះ គយ.សប ត្រូវចាត់ចែងត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ចំណុះឃុំ សង្កាត់ បញ្ចូលគ្នាជាលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។

៨.១៩.១ ក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ សម្រាប់ករណីដូចចែងក្នុងប្រការ ៨.១៩ ខាងលើនេះ គយ.សប គ្រាន់តែពិនិត្យផ្ទៀងផ្ទាត់ និងគណនាដោយផ្អែកលើកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ប៉ុណ្ណោះ ។ ប្រធាន គយ.សប ត្រូវ ៖

៨.១៩.១.១ បង្គាប់សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ឱ្យនាំយកស្បោង " ខ " ដែលដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតម្តងមួយៗ ពីកន្លែងរក្សាទុកមកដាក់នៅលើតុចំមុខប្រធាន ។

៨.១៩.១.២ បើកស្បោង " ខ " រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ផ្ញើជូន គយ.សប ដាក់នៅលើតុ ។

៨.១៩.១.៣ ដកយកស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតផ្ញើជូន គធ.ខប ពីក្នុងស្បោង " ខ " ដាក់ទៅក្នុងកញ្ចប់ " គ ពិសេស " ដែលត្រៀមបម្រុងជាស្រេច ដូចចែងក្នុងចំណុច ៨.១៩.៦ ខាងក្រោម បន្ទាប់មកដាក់នៅក្បែរខ្លួនគាត់ នូវស្បោង " ខ " ដែលមានកញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់ត្រា គ.ក.ប នៅខាងក្នុង ។

៨.១៩.១.៤ ត្រួតពិនិត្យផ្ទៀងផ្ទាត់ និងបូកសរុបតួលេខដែលមានកត់ត្រានៅក្នុងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងតារាងកត់ត្រាសំឡេងឆ្នោត

(ទ.១១០៨) នៃការិយាល័យបោះឆ្នោតនីមួយៗ រួចធ្វើការប្រៀបធៀប លទ្ធផលជាមួយនឹងតួលេខពាក់ព័ន្ធ ដែលមានកត់ត្រាក្នុងកំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៅការិយាល័យបោះឆ្នោត ពាក់ព័ន្ធ ដើម្បីឱ្យដឹងប្រាកដថាលទ្ធផលដែលបានកត់ត្រាក្នុងកំណត់ ហេតុនៃការរាប់សន្លឹកឆ្នោត ពិតជាត្រឹមត្រូវមែន ឬមានកំហុសក្នុង ការគណនាលេខណាមួយ ។

៨.១៩.១.៥ សម្រេចកែតម្រូវតួលេខលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យ បោះឆ្នោតនោះ នៅចំពោះមុខភ្នាក់ងារនៃគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ ដែលមានវត្តមាន ប្រសិនបើបានរកឃើញថា គ.ក.ប/គ.ក.រ មានកំហុសក្នុងការគណនាលេខ ។ ក្នុងការកែតម្រូវ កំហុសនេះ ប្រធាន គយ.សប ត្រូវគូសធ្លុតលុបតួលេខដែលខុស រួច សរសេរតួលេខថ្មីក្បែរនោះ ដោយត្រូវមានចុះហត្ថលេខារបស់ប្រធាន គយ.សប ផង ។ ក្នុងករណីនេះ ត្រូវឱ្យសមាជិកទទួលបន្ទុករដ្ឋបាល កត់ត្រាអំពីបញ្ហានេះ ទៅក្នុងកំណត់ហេតុបូកសរុបលទ្ធផលនៃការ បោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ផង ។ ប្រធាន គយ.សប ត្រូវ ប្រកាសជាចំហដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេត ការណ៍ដែលមានវត្តមាន អំពីការកែតម្រូវនេះ ។ ប្រធាន គយ.សប ត្រូវធ្វើកំណត់ហេតុអំពីការកែតម្រូវនេះ ដោយបញ្ជាក់ពីមូលហេតុ ព្រមទាំងចុះហត្ថលេខា បោះត្រា គយ.សប និងចែកជូនភ្នាក់ងារ គណបក្សនយោបាយ ដែលមានវត្តមាន ។

៨.១៩.១.៦ ស្រង់ និងហៅតួលេខសន្លឹកឆ្នោតបានការ ដែលបោះគាំទ្រគណបក្ស នយោបាយនីមួយៗ សន្លឹកឆ្នោតមិនបានការ ទិន្នន័យ និងតួលេខ ពាក់ព័ន្ធផ្សេងទៀត ដែលបានពិនិត្យត្រឹមត្រូវហើយ ពីកំណត់ហេតុនៃ ការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ហើយណែនាំអនុប្រធាន សមាជិកទទួលបន្ទុករដ្ឋបាល និងសមាជិក ទទួលបន្ទុកសេវាកម្មច្បាប់ ឱ្យកត់ត្រាតួលេខទាំងនេះ ទៅក្នុងតារាង បូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ។

៨.១៩.១.៧ ធានាថារាល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុ នៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត

(ទ.១១០៨) នៃការិយាល័យបោះឆ្នោតនីមួយៗ ដែលបានប្រើប្រាស់ក្នុងដំណើរការត្រួតពិនិត្យ និងបូកសរុបលទ្ធផលខាងលើនេះរួច ត្រូវតែបានដាក់ទៅក្នុងស្រោមសំបុត្រដដែលវិញ និងចងក្រងទុកជាឯកសាររបស់ គយ.សប ។

៨.១៩.១.៨ ចាត់ចែងសមាជិក គយ.សប ឱ្យវេចខ្ចប់ស្បោង " ខ " ឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់ត្រា គ.ក.ប បន្ទាប់មកឱ្យនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គធ.ខប ។

៨.១៩.២ ប្រធាន គយ.សប ត្រូវធានាថា នីតិវិធីទាំងឡាយដូចមានចែងក្រោមចំណុច ៨.១៩.១ ខាងលើ ត្រូវតែបានអនុវត្តដូចគ្នាសម្រាប់ស្បោង " ខ " ដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតរបស់ការិយាល័យបោះឆ្នោតនីមួយៗ ម្តងមួយៗរហូតដល់អស់ស្បោង " ខ " នៃការិយាល័យទាំងអស់ក្នុងឃុំ សង្កាត់ ។

៨.១៩.៣ ប្រធាន គយ.សប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ទាំង ៣ (បី) ច្បាប់ ដែលអនុប្រធាន សមាជិកទទួលបន្ទុករដ្ឋបាល និងសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ បានកត់ត្រាតួលេខលទ្ធផលរាប់សន្លឹកឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ត្រូវបានគណនាសរុបដោយប្រើប្រមាណវិធីដោយដៃផង និងដោយម៉ាស៊ីនគិតលេខផង ។ តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ទាំង ៣ (បី) ច្បាប់នោះ ត្រូវតែពិនិត្យផ្ទៀងផ្ទាត់ជាមួយគ្នាឡើងវិញឱ្យបានត្រឹមត្រូវ និងចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គយ.សប ហើយដែលត្រូវផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ ជូន គ.ជ.ប ១ (មួយ)ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.១៩.៤ ប្រធាន គយ.សប ត្រូវធានាថាសមាជិកទទួលបន្ទុករដ្ឋបាល បានបំពេញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ជា ៤ (បួន) ច្បាប់ ដោយបញ្ជាក់ច្បាស់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ទិន្នន័យ និងតួលេខពាក់ព័ន្ធផ្សេងទៀត ព្រមទាំងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលបានគណនាសរុបត្រឹមត្រូវរួចហើយ ដូចមានចែងក្នុងចំណុច

៨.១៩.៣ ខាងលើ ។ កំណត់ហេតុនេះ ត្រូវតែបានចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គយ.សប និងត្រូវដាក់បង្ហាញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដើម្បីពិនិត្យ ។

៨.១៩.៤.១ ភ្នាក់ងារគណបក្សនយោបាយ អាចចូលរួមចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ។

៨.១៩.៤.២ ការមិនព្រមចុះហត្ថលេខា ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកជាមោយ:នូវកំណត់ហេតុនេះបានទេ ។

៨.១៩.៥ ប្រធាន គយ.សប ត្រូវរៀបចំបែងចែក និងប្រើប្រាស់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ដូចមានចែងក្នុងចំណុច ៨.១៩.៤ ខាងលើ ដូចខាងក្រោម ៖

៨.១៩.៥.១ បិទផ្សាយ ១ (មួយ) ច្បាប់ នៅខាងមុខទីស្នាក់ការ គយ.សប និងត្រូវធ្វើកំណត់ហេតុស្តីពីការបិទផ្សាយ ដោយបញ្ជាក់ច្បាស់ពីពេលវេលា និងកាលបរិច្ឆេទនៃការបិទផ្សាយនេះផង ។ ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា លើកំណត់ហេតុស្តីពីការបិទផ្សាយនេះ ប៉ុន្តែការមិនព្រមចុះហត្ថលេខារបស់ភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកកំណត់ហេតុនេះជាមោយ:បានទេ ។

៨.១៩.៥.២ ផ្ញើជូន គធ.ខប ១ (មួយ) ច្បាប់ ដែលត្រូវដាក់រួមជាមួយតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ១ (មួយ) ច្បាប់ និងកំណត់ហេតុស្តីពីការបិទផ្សាយ ដូចមានចែងក្នុងចំណុច ៨.១៩.៥.១ ខាងលើ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ ដែលមានកាខ្ទងថា " កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ផ្ញើជូន គធ.ខប " ។

៨.១៩.៥.៣ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ដែលត្រូវដាក់រួមជាមួយតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ១ (មួយ)ច្បាប់ ទៅក្នុងស្រោមសំបុត្របោះពុម្ពស្រាប់ដែលមានកាខ្ទងថា " កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ផ្ញើជូន គ.ជ.ប " ។

៨.១៩.៥.៤ រក្សាទុក ១ (មួយ) ច្បាប់ ជាឯកសាររបស់ គយ.សប ។

៨.១៩.៦ ប្រធាន គឃ.សប ត្រូវត្រៀមកញ្ចប់ " គ ពិសេស " មួយ ដែលត្រូវដាក់រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោតសម្រាប់ផ្ញើជូន គធ.ខប និងផ្ញើជូន គ.ជ.ប តាមរយៈ គធ.ខប ។ ប្រធាន គឃ.សប ត្រូវប្រមូល និងចងជាបាច់ទៅតាមមុខឯកសារ និងគោលដៅដែលត្រូវទទួល ហើយរៀបចំដាក់ទៅក្នុងកញ្ចប់ " គ ពិសេស " នូវ ៖

៨.១៩.៦.១ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោតផ្ញើជូន គធ.ខប ដែលត្រូវដកយកពីស្បោង " ខ " នៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនីមួយៗ ។

៨.១៩.៦.២ រាល់ស្រោមសំបុត្រ ដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដូចចែងក្នុងចំណុច ៨.១៩.៥.២ និង ៨.១៩.៥.៣ ខាងលើ ។

៨.១៩.៦.៣ ស្រោមសំបុត្រតែមួយដាក់រាល់ឯកសារពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលត្រូវផ្ញើជូន គធ.ខប ។

៨.១៩.៦.៤ ក្នុងករណីឃុំ សង្កាត់ណាមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលតម្រូវឱ្យមានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យមួយ ឬច្រើន ប្រធាន ត្រូវធានាថា ស្រោមសំបុត្រដាក់របាយការណ៍ផ្ញើជូន គធ.ខប ដូចចែងក្នុងចំណុច ៨.២០.៣.២ ខាងក្រោម ត្រូវតែបានកិបភ្ជាប់ទៅនឹងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដូចចែងក្នុងចំណុច ៨.១៩.៥.២ ខាងលើ ។

៨.១៩.៧ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ត្រូវកត់ចម្លងឱ្យបានត្រឹមត្រូវនូវតួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធពីកំណត់ហេតុ ដែលបានបិទផ្សាយ ដូចចែងក្នុងចំណុច ៨.១៩.៥.១ ខាងលើ ។

ប្រការ ៨.២០.-

ក្នុងករណីឃុំ សង្កាត់ណាមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលត្រូវបានដាក់ក្នុងអំឡុងពេលកំណត់ ដូចចែងក្នុងប្រការ ៨.១៦ និង ៨.១៧ ខាងលើ គឃ.សប ក៏ត្រូវធ្វើការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការរាប់សន្លឹកឆ្នោតរបស់ការិយាល័យរាប់សន្លឹកឆ្នោតទាំងអស់ ចំណុះឃុំ សង្កាត់បញ្ចូលគ្នា

ជាលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ផងដែរ ដោយត្រូវអនុវត្តនីតិវិធីក្នុងជំពូកនេះ ចាប់ពីចំណុច ៨.១៩.១ ដល់ ៨.១៩.៦ ខាងលើ ។ ប្រសិនបើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់គ្មានភស្តុតាងបញ្ជាក់ពីកំហុសនៅក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីណាមួយ ដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់នោះទេ គយ.សប ត្រូវចាត់ចែងត្រួតពិនិត្យលទ្ធផលនៃការរាប់សន្លឹកឆ្នោត នៅការិយាល័យបោះឆ្នោតពាក់ព័ន្ធតាមនីតិវិធីជាធម្មតា ដោយមិនចាំបាច់បើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតឡើយ ។

៨.២០.១ ប្រសិនបើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ មានភស្តុតាងបញ្ជាក់ថា មានអំពើរំលោភ ឬមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន គយ.សប អាចបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតផង ។ ក្នុងករណីនេះ នៅពេលកំពុងអនុវត្តនីតិវិធីដូចមានចែងក្រោមចំណុច ៨.១៩.១ ខាងលើ ប្រធាន គយ.សប ត្រូវ ៖

៨.២០.១.១ ដកយកកញ្ចប់សុវត្ថិភាព " ក " ពីក្នុងស្បោង " ខ " មកដាក់នៅលើតុ។

៨.២០.១.២ បើកកញ្ចប់សុវត្ថិភាព " ក " រួចដកយកវាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុងមកដាក់ដោយឡែកពីគ្នានៅលើតុមុខគាត់។

៨.២០.១.៣ ប្រគល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងតារាងកត់ត្រាសំឡេងឆ្នោត ឱ្យទៅសមាជិកទទួលបន្ទុករដ្ឋបាលសម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។

៨.២០.១.៤ បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីពិនិត្យផ្ទៀងផ្ទាត់តាមនីតិវិធី ដូចចែងក្រោមចំណុច ៨.២០.២ ខាងក្រោម ។

៨.២០.២ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់

ហើយ ប្រធាន គយ.សប ត្រូវចាត់ចែងឱ្យត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារ បោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យនោះ (តែមិនត្រូវផ្តល់សុពលភាពជាសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការឡើងវិញទេ) ដូចខាងក្រោម ៖

ជ.២០.២.១ ពិនិត្យផ្ទៀងផ្ទាត់លេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

ជ.២០.២.២ ពិនិត្យផ្ទៀងផ្ទាត់ត្រាសម្ងាត់ ដែលប្រើសម្រាប់បោះលើខ្នងសន្លឹកឆ្នោតនៃការិយាល័យបោះឆ្នោតនោះ ។

ជ.២០.២.៣ ពិនិត្យ និងរាប់ចំនួនអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត ដែលបានមកបោះឆ្នោត ។

ជ.២០.២.៤ ពិនិត្យផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត និងលេខរៀងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រគល់ឱ្យការិយាល័យបោះឆ្នោតនោះ ជាមួយលេខរៀងគល់បញ្ជីសន្លឹកឆ្នោត ដែលទទួលពីការិយាល័យបោះឆ្នោតនោះវិញ។

ជ.២០.២.៥ រាប់ចំនួនសន្លឹកឆ្នោតខូច (បើមាន) ។

ជ.២០.២.៦ រាប់ចំនួនសន្លឹកឆ្នោតមិនបានប្រើ ។

ជ.២០.២.៧ ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតមិនបានការ ។

ជ.២០.២.ជ ពិនិត្យផ្ទៀងផ្ទាត់ និងរាប់ចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះគាំទ្រគណបក្សនយោបាយនីមួយៗ ។

ជ.២០.២.៩ ពិនិត្យមើលថា តើនៅក្នុង ទ.១១០១ និង ១១០២ មានចុះអំពីភាពមិនប្រក្រតី ដែលអាចធ្វើឱ្យបះពាល់ដល់លទ្ធផលនៃការបោះឆ្នោតដែរ ឬទេ ។

ជ.២០.២.១០ពិនិត្យមើលថា តើនៅក្នុង ទ.១១០១ និង ១១០២ ភ្នាក់ងារគណបក្សនយោបាយបានចុះហត្ថលេខាជាសាក្សីដែរ ឬទេ ។

ជ.២០.៣ បន្ទាប់ពីអនុវត្តការត្រួតពិនិត្យផ្ទៀងផ្ទាត់ដូចមានចែងក្រោមចំណុច ជ.២០.២ ខាងលើរួចរាល់ហើយ ប្រធាន គយ.សប ត្រូវ ៖

ជ.២០.៣.១ ធ្វើរបាយការណ៍ និងលើកយោបល់ពាក់ព័ន្ធនឹងលទ្ធផលនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតខាងលើ ដោយស្នើសុំ គធ.ខប ពិនិត្យសម្រេចព្យួរលទ្ធផលបោះឆ្នោតជាបណ្តោះអាសន្ន ឬយល់ព្រមទទួលយកលទ្ធផលបោះឆ្នោតនៃការិយា-

លយ័យបោះឆ្នោតនោះ ឬទាំងនោះ ។ របាយការណ៍នេះត្រូវធ្វើជា ២ (ពីរ) ច្បាប់ និងចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុករដ្ឋបាល និងប្រធាន គយ.សប ។

ជ.២០.៣.២ ដាក់រាល់របាយការណ៍ដូចចែងក្នុងចំណុច ជ.២០.៣.១ ខាងលើ ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្ររួចកាខ្ជងថា " របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ផ្ញើជូន គធ.ខប " ដែលត្រូវកិបភ្ជាប់ទៅនឹងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដូចចែងក្នុងចំណុច ជ.១ជ.ជ.២ ខាងលើ ហើយដែលត្រូវដាក់ទៅក្នុងកញ្ចប់ " គ ពិសេស " ដូចបញ្ជាក់ក្នុងចំណុច ជ.២១.១ ខាងក្រោម ។

ជ.២០.៣.៣ រក្សាទុករបាយការណ៍ដូចចែងក្នុងចំណុច ជ.២០.៣.១ ខាងលើ ១ (មួយ) ច្បាប់ ជាឯកសារ ។

ជ.២០.៣.៤ ដាក់សម្ភារ ឯកសារបោះឆ្នោត ដែលបានពិនិត្យផ្ទៀងផ្ទាត់ទៅក្នុងស្រោមសំបុត្រ និងស្បោងប្លាស្ទិកនានា រួចវេចខ្ចប់ក្នុងកញ្ចប់សុវត្ថិភាព " ក " ឡើងវិញ តាមលំនាំដើមដូចចែងក្នុងចំណុច ជ.១២.២ ខាងលើ។

ជ.២០.៣.ជ វេចខ្ចប់ដាក់ក្នុងស្បោង " ខ " ឡើងវិញ ដែលមានតែកញ្ចប់សុវត្ថិភាព " ក " និងស្រោមសំបុត្រដាក់ត្រា គ.ក.ប រួចនាំយកទៅរក្សាទុកនៅកន្លែងដើមត្រៀមសម្រាប់ការវេចខ្ចប់ និងបញ្ជូនទៅ គធ.ខប ។

ជ.២០.ជ នៅពេលបញ្ចប់ការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោត ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់រួចរាល់ហើយ ប្រធាន គយ.សប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹង ដោយត្រូវអនុវត្តនីតិវិធីដូចចែងក្រោមចំណុច ជ.១៦.៦ និង ជ.១៦.៧ ខាងលើ ។

ប្រការ ជ.២១.-

បន្ទាប់ពីបានអនុវត្តនីតិវិធីដូចចែងក្នុងប្រការ ជ.១ជ និង ជ.២០ នៃជំពូកនេះចប់សព្វគ្រប់ហើយ ប្រធាន គយ.សប ត្រូវធានាថា កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ និង

រាល់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតពីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ត្រូវតែបានវេចខ្ចប់ក្នុងកញ្ចប់ " គ ពិសេស " ស្បោង " គ " និងស្បោង " គ មានបណ្តឹង " រួចប្រគល់ជូន គធ.ខប បានយ៉ាងត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃបន្ទាប់ពីបានទទួលកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារបោះឆ្នោតពីគ្រប់ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ ។

៨.២១.១ ប្រធាន គយ.សប ត្រូវធានាដាក់ទៅក្នុងកញ្ចប់ " គ ពិសេស " ឱ្យបានគ្រប់គ្រាន់ និងត្រឹមត្រូវ នៅមុនពេលបិទភ្ជិត នូវរាល់ស្រោមសំបុត្រផ្ទុកកំណត់ហេតុ របាយការណ៍ និងឯកសារបោះឆ្នោត ដែលត្រូវផ្ញើជូន គធ.ខប និង គ.ជ.ប ដូចខាងក្រោម៖

- ៨.២១.១.១ ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ១ (មួយ) ច្បាប់ តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ១ (មួយ) ច្បាប់ និងកំណត់ហេតុស្តីពីការបិទផ្សាយកំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ។
- ៨.២១.១.២ ស្រោមសំបុត្រដាក់របាយការណ៍របស់ គយ.សប ស្តីពីការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចមានចែងក្នុងចំណុច ៨.២០.៣.២ ខាងលើ (បើមាន) ។
- ៨.២១.១.៣ ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) ១ (មួយ) ច្បាប់ និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ។
- ៨.២១.១.៤ រាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តាមការិយាល័យបោះឆ្នោតនីមួយៗ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ដែលត្រូវបានដកចេញពីក្នុងស្បោង " ខ " ។
- ៨.២១.១.៥ រាល់ឯកសារពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ (បើមាន) ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រតែមួយ និងកាខ្ទងថា ផ្ញើជូន គធ.ខប ។
- ៨.២១.១.៦ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ. ១១០៧) ១ (មួយ) ច្បាប់ ។

៨.២១.២ ប្រធាន គយ.សប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយមានសរសេររាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងកញ្ចប់ " គ ពិសេស " ខាងលើ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងកញ្ចប់ " គ ពិសេស " ដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ " គ ពិសេស " និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គធ.ខប ។

៨.២១.៣ ប្រធាន គយ.សប ត្រូវបិទភ្ជិតកញ្ចប់ " គ ពិសេស " រួចហើយត្រូវសរសេរសម្គាល់លេខកូដឃុំ សង្កាត់របស់ខ្លួន នៅលើផ្នែកខាងក្រៅនៃកញ្ចប់ " គ ពិសេស " ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ រួចត្រៀមទុកសម្រាប់បញ្ជូនទៅ គធ.ខប ។

៨.២១.៤ បន្ទាប់មក ប្រធាន គយ.សប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់ស្បោង " ខ " នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬ/និង ពាក្យបណ្តឹងជំទាស់ ដាក់ទៅក្នុងស្បោង " គ " តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង " ខ " ទាំងនោះ ។ ក្នុងការវេចខ្ចប់នេះ គយ.សប ត្រូវ ៖

- ៨.២១.៤.១ ដាក់ស្បោង " ខ " តាមលំដាប់លេខរៀងនៃលេខកូដការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទៅក្នុងស្បោង " គ " នីមួយៗ ។
- ៨.២១.៤.២ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញ ដោយមានរាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងស្បោង " គ " នីមួយៗ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង " គ " ដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោប៉ៅក្រៅនៃស្បោង " គ " និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គធ.ខប ។
- ៨.២១.៤.៣ ចងភ្ជិតស្បោង " គ " នីមួយៗ និងចាក់សោយ៉ូមានលេខ និងសរសេរសម្គាល់ពីក្រៅស្បោង " គ " នីមួយៗ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដការិយាល័យពាក់ព័ន្ធពីលេខប៉ុន្មាន ដល់លេខប៉ុន្មាន និងពាក្យថា " ពិនិត្យរួច " ។

៨.២១.៥ បន្ទាប់មក ប្រធាន គយ.សប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់ស្បោង " ខ " នៃការិ-យាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ និងដែលមានការបើក ឬមិនបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចចែងក្រោមប្រការ ៨.២០ ខាងលើ ដោយដាក់ទៅក្នុងស្បោង " គ មានបណ្តឹង " តាមចំនួនចាំបាច់ ដើម្បីដាក់ឱ្យអស់ស្បោង " ខ " ទាំងនោះ ។ ក្នុងការវេចខ្ចប់នេះ គយ.សប ត្រូវ ៖

៨.២១.៥.១ ដាក់ស្បោង " ខ " នៃការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតដែលមានបណ្តឹង និងមានការបើក ឬមិនបើកកញ្ចប់សុវត្ថិភាព " ក " ទៅក្នុងស្បោង " គ មានបណ្តឹង " ។

៨.២១.៥.២ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញដោយមានរាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងស្បោង " គ មានបណ្តឹង " ពាក់ព័ន្ធ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង " គ មានបណ្តឹង " ដាក់ ១ (មួយ) ច្បាប់ទៀត ទៅក្នុងហោចៅខាងក្រៅនៃស្បោង " គ មានបណ្តឹង " និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គធ.ខប ។

៨.២១.៥.៣ ចងភ្ជិតស្បោង " គ " និងចាក់សោឃ្លុំមានលេខ រួចសរសេរសម្គាល់ពីក្រៅស្បោង " គ មានបណ្តឹង " ដោយបិកហ្ជីតលុបមិនជ្រះ នូវលេខកូដការិយាល័យពាក់ព័ន្ធ ។

៨.២១.៦ ក្នុងករណីមានស្បោង " គ " ដូចចែងក្នុងចំណុច ៨.២១.៤ ឬ/និង ៨.២១.៥ ខាងលើ សរុបលើសពីមួយ ប្រធាន គយ.សប ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង " គ " ទាំងនោះ នូវលេខរៀងនៃស្បោង " គ " នីមួយៗ ។ ឧទាហរណ៍: ប្រសិនបើមានស្បោង " គ " សរុបចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀង ១/៣ ២/៣ និង ៣/៣ ។

ប្រការ ៨.២២.-

ប្រធាន គយ.សប ត្រូវធានាថា រាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដូចជា ហិបឆ្នោត បន្ទប់សម្ងាត់ កេសស័ង្កសី ត្រា គយ.សប ម៉ាស៊ីនគិតលេខ គ្រឿងបរិក្ខារ វិទ្យុទាក់ទង ទឹកខ្មៅលុបមិនជ្រះ ។ល។ ដែលបានទទួលពីការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ឬ/និងមាននៅ

ទីស្នាក់ការ គឃ.សប ត្រូវតែបានវេចខ្ចប់ និងបញ្ជូនទន្ទឹមគ្នានឹងការបញ្ជូនកញ្ចប់ " គ ពិសេស " និងស្បោង " គ " និងស្បោង " គ មានបណ្តឹង " ទៅ គធ.ខប ។ សម្រាប់ការបញ្ជូនសម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតខាងលើនេះ ប្រធានត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវតែបានបំពេញដោយឡែក និងអនុវត្តយ៉ាងត្រឹមត្រូវតាមលក្ខការណ៍នៃការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត។

ជ.២២.១ ប្រធាន គឃ.សប ត្រូវប្រគល់ជូន គធ.ខប ស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) ក្នុងឃុំ សង្កាត់ ស្របពេលបញ្ជូនលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារ (ទ.១១០៧) ។

ជ.២២.២ ប្រធាន គឃ.សប ត្រូវអញ្ជើញភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ ដែលមានវត្តមានឱ្យចូលរួមជាសាក្សី ក្នុងការបញ្ជូន និងការប្រគល់ ទទួលកញ្ចប់ " គ ពិសេស " រាល់ស្បោង " គ " ឬស្បោង " គ មានបណ្តឹង " និងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតខាងលើនេះ ហើយត្រូវជូនដំណឹងអំពីពេលវេលានៃការចេញដំណើរការបញ្ជូន ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ ទទួលនៅលេខាធិការដ្ឋាននៃ គធ.ខប ផង ។

ការបង្កើតមជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប

ប្រការ ជ.២៣.

គធ.ខប ត្រូវបង្កើតមជ្ឈមណ្ឌលមួយសម្រាប់ត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន ដើម្បីផ្ញើជូន គ.ជ.ប ពិនិត្យសម្រេចជាលទ្ធផលបោះឆ្នោតផ្លូវការ ។

ជ.២៣.១ មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងរាជធានី ខេត្ត អាចមានទីតាំងនៅលេខាធិការដ្ឋាន គធ.ខប ឬនៅអគារមួយផ្សេង ឬផ្ទៃកណាមួយ ដែលមានទំហំទូលាយល្មមអាចរៀបចំឱ្យមានកន្លែងបម្រុង ដូចខាងក្រោម ៖

ជ.២៣.១.១ កន្លែងសម្រាប់ទទួលកញ្ចប់ " គ ពិសេស " និងស្បោង " គ " ឬស្បោង " គ មានបណ្តឹង " និងសម្ភារ ឯកសារបោះឆ្នោតនៅសល់ពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្ត៣ក់ព័ន្ធ ដែលត្រូវស្ថិតនៅក្បែរផ្លូវចូល ។

ជ.២៣.១.២ បន្ទប់មួយទូលាយល្មមដែលអាចស្តុកកញ្ចប់ " គ ពិសេស " និងស្បោង " គ " ឬស្បោង " គ មានបណ្តឹង " ដាច់ដោយឡែកពីគ្នាទៅតាមឃុំ សង្កាត់ និងមានសរសេរសម្គាល់លេខកូដឃុំ សង្កាត់នីមួយៗផង ។

៨.២៣.១.៣ បន្ទប់មួយដោយឡែកដាក់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ដែល គយ.សប បានប្រគល់ឱ្យ ។

៨.២៣.១.៤ បន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើន ដែលត្រូវមានតុ និងកៅអីគ្រប់គ្រាន់សម្រាប់ប្រើក្នុងពេលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ហើយដែលអាចទទួលបានទាំងក្រុមត្រួតពិនិត្យលទ្ធផលរបស់ គធ.ខប ទាំងភ្នាក់ងារគណបក្សនយោបាយ ពាក់ព័ន្ធ អ្នកសង្កេតការណ៍ ទាំងអ្នកប្តឹងពាក់ព័ន្ធ ឬតំណាង ។

៨.២៣.១.៥ បន្ទប់ស្អាតតូចមួយ (បើមាន) សម្រាប់ដាក់គ្រឿងបរិក្ខារ កុំព្យូទ័រមួយ សម្រាប់បំពាក់ដោយកម្មវិធី និងទម្រង់ឯកភាពមួយ សម្រាប់បញ្ជូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងមានភ្ជាប់ប្រព័ន្ធអ៊ីនធឺណែត ដើម្បីបញ្ជូនលទ្ធផលទៅ គ.ជ.ប ។

៨.២៣.២ គធ.ខប ត្រូវធានាអំពីសន្តិសុខ សុវត្ថិភាពនៃអគារមជ្ឈមណ្ឌលរបស់ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ។ ទ្វារ និងបង្អួចទាំងអស់ត្រូវបិទ និងចាក់សោយ៉ាងត្រឹមត្រូវ នៅពេលផុតម៉ោងធ្វើការងារ។ នៅក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត គធ.ខប ត្រូវចាត់ឱ្យមានមន្ត្រីម្នាក់ទទួលបន្ទុកសណ្តាប់ធ្នាប់ក្នុងមជ្ឈមណ្ឌល និងមានមន្ត្រីម្នាក់ប្រចាំការនៅមាត់ទ្វារចេញចូល ដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ប្រធាន គធ.ខប ។

៨.២៣.៣ គធ.ខប ត្រូវតែរៀបចំឱ្យមានបរិវេណសន្តិសុខមួយនៅអគារមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដោយនៅបរិវេណខាងក្រៅ ត្រូវស្នើសុំកិច្ចសហការពីគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់កម្លាំងការពារ និងនៅបរិវេណខាងក្នុងត្រូវរៀបចំចាត់កម្លាំងសន្តិសុខផ្ទាល់របស់ គធ.ខប ដើម្បីការពារ ។

៨.២៣.៤ គធ.ខប ត្រូវទទួលបន្ទុកគ្រប់គ្រងការចេញចូលមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងមានសិទ្ធិអំណាចចេញចូលមជ្ឈមណ្ឌលនេះ ។ ជនគ្រប់រូបដែលមានវត្តមាន នៅក្នុងបរិវេណសន្តិសុខ

និងក្នុងមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងរាជធានី ខេត្ត ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំរបស់ប្រធាន គធ.ខប ។

៨.២៣.៥ ហាមជនគ្រប់រូបចូលក្នុងមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។

ត្រូវបានអនុញ្ញាតឱ្យចូលក្នុងមជ្ឈមណ្ឌលនេះ នូវជនទាំងឡាយ ដូចខាងក្រោម ៖

៨.២៣.៥.១ ថ្នាក់ដឹកនាំ និងមន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដែលបានទទួលការតែងតាំង ។

៨.២៣.៥.២ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកយកព័ត៌មាន និងអ្នកប្តឹង ដូចបញ្ជាក់ក្រោមចំណុច ៨.១៦.១ ខាងក្រោម ។

៨.២៣.៥.៣ ភ្នាក់ងារសន្តិសុខ និងភ្នាក់ងារសង្គ្រោះនៅពេលដែលប្រធាន ឬតំណាង គធ.ខប សំណូមពរក្នុងករណីចាំបាច់ ។

៨.២៣.៥.៤ មន្ត្រីនៃ គ.ជ.ប ដែលកំពុងបំពេញការកិច្ចស៊ើបអង្កេតអំពើល្មើសដែលគេបានចោទប្រកាន់ចំពោះសមាជិក ឬមន្ត្រីនៃ គធ.ខប ដែលចាត់ឱ្យជួយក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងរាជធានី ខេត្ត ។

៨.២៣.៦ សកម្មភាពទាំងឡាយដូចខាងក្រោមត្រូវហាមឃាត់នៅក្នុងមជ្ឈមណ្ឌលនៃ គធ.ខប សម្រាប់ត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ៖

៨.២៣.៦.១ ការស្លៀកពាក់ ឬការដាក់បង្ហាញអ្វីមួយ ដែលពាក់ព័ន្ធជាមួយគណបក្សនយោបាយ ឬបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឬបេក្ខជននៃបញ្ជីណាមួយ ។

៨.២៣.៦.២ ការផ្សព្វផ្សាយ ឬការនិយាយអ្វីដែលមានឥទ្ធិពល ធ្វើឱ្យមន្ត្រីត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃ គធ.ខប បំពេញចិត្ត ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

៨.២៣.៧ គធ.ខប ត្រូវតែងតាំងក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប មួយក្រុម ឬច្រើនក្រុម ដោយយោងតាមចំនួនតិច ឬច្រើននៃឃុំ សង្កាត់ ក្នុងរាជធានី ខេត្តនីមួយៗ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងតែងតាំងមួយក្រុមផ្សេងទៀត ដើម្បីបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន ។ គធ.ខប ត្រូវធានាថា ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗដែលត្រូវបានតែងតាំង អាចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ចំនួន ១០ (ដប់) ។ ដោយឡែកចំពោះរាជធានី ខេត្តដែលមានចំនួនឃុំ សង្កាត់តិចពេក ដូចជា ខេត្តកែប ប៉ៃលិន ព្រះសីហនុ... ឬច្រើនពេក ដូចជា ខេត្តបាត់ដំបង កំពង់ចាម កណ្តាល រាជធានីភ្នំពេញ ព្រៃវែង សៀមរាប តាកែវ... ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ដែលត្រូវបានតែងតាំង អាចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ចំនួនតិចជាង ១០ (ដប់) ឬច្រើនជាង ១០ (ដប់) ។ គធ.ខប អាចបែងចែកឱ្យក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ទទួលបន្ទុកឃុំ សង្កាត់ ក្នុងក្រុង ស្រុក ខណ្ឌមួយ ឬលើសពីមួយ ។

៨.២៣.៧.១ សមាសភាពនៃក្រុមត្រួតពិនិត្យលទ្ធផល ត្រូវជ្រើសតាំងពីក្នុងចំណោមសមាសភាពអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងមន្ត្រីនៃ លគធ.ខប ក្នុងនោះត្រូវយកចិត្តទុកដាក់ ចំពោះមន្ត្រីណាដែលពេលនោះមិនសូវមានការងារមមាញឹកដូចជា គ្រូបង្ហាត់ជាដើម ។ ប្រសិនបើ លគធ.ខប ពុំមានមន្ត្រីបុគ្គលិកគ្រប់គ្រាន់ គធ.ខប អាចលើកសំណើសុំតែងតាំងសមាជិកនៃ គយ.សប ដែលស្ថិតនៅជិត លគធ.ខប បញ្ចូលក្នុងក្រុមត្រួតពិនិត្យលទ្ធផលទាំងនេះ ។

៨.២៣.៧.២ សមាសភាពក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗត្រូវមាន ៤ (បួន) រូប ដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលជាសមាជិកអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប ឬមន្ត្រីនៃ លគធ.ខប និងមានអនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងជំនួយការ ១ (មួយ) រូប ។

៨.២៣.៧.៣ ក្រុមត្រួតពិនិត្យលទ្ធផល ដូចមានចែងក្នុងចំណុច ៨.២៣.៧.១ ខាងលើ មានភារកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ តាមចំនួនឃុំ សង្កាត់ ដែលក្រុមទទួលបន្ទុកប៉ុណ្ណោះ ។

៨.២៣.៨ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗរបស់ គធ.ខប មានភារកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗទៅតាមករណីដោយឡែកពីគ្នា និងតាមការណែនាំរបស់ប្រធាន គធ.ខប ដោយផ្អែកលើ ៖

៨.២៣.៨.១ កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុង ឃុំ សង្កាត់ពាក់ព័ន្ធ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ.១១០៩) ។

៨.២៣.៨.២ របាយការណ៍របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមានការបើកកញ្ចប់សុវត្ថិភាព " ក ") ។

៨.២៣.៨.៣ សម្រង់សេចក្តីសម្រេចរបស់ គយ.សប យល់ព្រម ឬបដិសេធលើពាក្យបណ្តឹងតវ៉ ឬពាក្យបណ្តឹងជំទាស់ (បើមាន) ។

៨.២៣.៨.៤ ពាក្យបណ្តឹងតវ៉ ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គធ.ខប ដូចចែងក្នុងចំណុច ៨.២៥.៦ ខាងក្រោម (បើមាន) ។

៨.២៣.៨.៥ របាយការណ៍បើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប (ប្រសិនបើ គធ.ខប សម្រេចឱ្យធ្វើដូច្នេះ) ។

៨.២៣.៩ បន្ទាប់ពីទទួលបានរបាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ពីក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗមក គធ.ខប ត្រូវត្រួតពិនិត្យឡើងវិញ និងបូកសរុបលទ្ធផលទាំងនោះបញ្ចូលគ្នាជាលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត បន្ទាប់មកត្រូវបំពេញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលត្រូវចុះហត្ថលេខា ដោយប្រធាន លគធ.ខប និងប្រធាន គធ.ខប រួច ត្រូវរៀបចំវេចខ្ចប់បញ្ជូន និងប្រគល់កំណត់ហេតុនេះ ព្រមទាំងរាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធជូន គ.ជ.ប ។

៨.២៣.១០ ក្នុងករណី គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬ/និងលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើនក្នុងឃុំ សង្កាត់នោះ គធ.ខប ត្រូវវេចខ្ចប់ និងបញ្ជូនសម្រង់សេចក្តីសម្រេចព្យួរលទ្ធផលនោះ ព្រមទាំងកំណត់ហេតុនៃការបោះឆ្នោត កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងសម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធជូន គ.ជ.ប ក្នុងអំឡុងពេលយ៉ាងយូរម្តងបួន (២៤) ម៉ោង គិតចាប់ពីពេលដែល គធ.ខប ចេញសម្រង់សេចក្តីសម្រេចព្យួរលទ្ធផលនោះ ។

៨.២៣.១១ ក្នុងការបូកសរុបលទ្ធផល និងបំពេញកំណត់ហេតុ ដូចចែងក្នុងចំណុច ៨.២៣.៩ ខាងលើ ប្រធាន លគធ.ខប ត្រូវទទួលបន្ទុកដឹកនាំក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តដោយផ្ទាល់ ។ ក្រុមបូកសរុបនេះមានការកិច្ចរៀបចំតារាងបូកសរុបលទ្ធផល កំណត់ហេតុបូកសរុបលទ្ធផល និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនៅក្នុងកុំព្យូទ័រ រៀបចំឯកសារផ្លូវការរបស់ គធ.ខប និងបញ្ជូនតាមអ៊ីមែលជាបន្ទាន់នូវតារាង និងកំណត់ហេតុផ្លូវការទាំងនេះជូន គ.ជ.ប ។ ក្រុមបូកសរុបលទ្ធផលនេះត្រូវមានសមាសភាព ១ (មួយ) រូប ជាប្រធានផ្នែករដ្ឋបាល ១ (មួយ) រូប ជាប្រធានផ្នែកប្រតិបត្តិការ និងមួយចំនួនតាមការចាំបាច់ជាមន្ត្រីចេះប្រើប្រាស់កុំព្យូទ័រ និង ១ (មួយ) រូប ជាការីកុំព្យូទ័រ ឬជាមន្ត្រីដែលមានចំណេះដឹងខាងការប្រើប្រាស់អ៊ីម៉ែលជាសមាជិក ។

៨.២៣.១២ គ.ជ.ប ត្រូវផ្គត់ផ្គង់កុំព្យូទ័រ ម៉ាស៊ីនស្កេន ម៉ាស៊ីនបោះពុម្ព ព្រមទាំងប្រព័ន្ធអ៊ីមែល ជូន គធ.ខប ឱ្យបានទាន់ពេលវេលា ។

- ៨.២៣.១២.១ អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប ត្រូវទទួលបន្ទុកណែនាំមន្ត្រីជំនាញកុំព្យូទ័រនៃ គធ.ខប អំពីចំណេះដឹងនៃការប្រើប្រាស់អ៊ីមែល ។
- ៨.២៣.១២.២ គធ.ខប ត្រូវប្រើប្រាស់អ៊ីមែល សម្រាប់តែការបញ្ជូនសារ លិខិតស្នាម ព័ត៌មានបន្ទាន់ របាយការណ៍ និងទិន្នន័យបច្ចេកទេសក្នុងការបោះឆ្នោតប៉ុណ្ណោះ ។

ការប្រគល់ និងការទទួលកញ្ចប់ " ត ពិសេស " និងស្បោង " ត " ឬ/និងស្បោង " ត មានបណ្តឹង " និងសម្ភារៈឯកសារបោះឆ្នោតពាក់ព័ន្ធនៅ គធ.ខប

ប្រការ ៨.២៤.-

នៅពេលមកដល់មជ្ឈមណ្ឌលត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៃ គធ.ខប ភ្លាម ប្រធាន គយ.សប ត្រូវប្រគល់ទៅឱ្យមន្ត្រីទទួលបន្ទុកទទួលសម្ភារ ឯកសារនៃ គធ.ខប នូវកញ្ចប់ " ត ពិសេស " រាល់ស្បោង " ត " និងស្បោង " ត មានបណ្តឹង " និងរាល់កញ្ចប់ដែលមានវេចខ្ចប់សម្ភារឯកសារបោះឆ្នោតនៅសល់ផ្សេងទៀត ។ ប្រធាន គយ.សប ត្រូវប្រគល់ទៅឱ្យមន្ត្រី គធ.ខប ផងដែរនូវលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ពាក់ព័ន្ធ ។

- ៨.២៤.១ នៅពេលប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត មន្ត្រី គធ.ខប ត្រូវធានាថា កញ្ចប់ " ត ពិសេស " ស្បោង " ត " ឬស្បោង " ត មានបណ្តឹង " ទាំងអស់ និងស្បោងសម្ភារ

ឯកសារផ្សេងទៀត ដូចមានបញ្ជាក់ក្រោមប្រការ ៨.២១ ខាងលើ ត្រូវបានពិនិត្យ និងផ្ទៀងផ្ទាត់ត្រឹមត្រូវ ដោយផ្អែកលើ ទ.១១០៧ ដែលមានក្នុងកញ្ចប់ " គ ពិសេស " ស្បោង " គ " ឬស្បោង " គ មានបណ្តឹង " ក្នុងហោប៉ៅខាងក្រៅនៃកញ្ចប់ ឬស្បោងទាំងនោះ និងដែលប្រធាន គយ.សប បានប្រគល់ជូន ដូចមានចែងក្នុងប្រការ ៨.២៤ ខាងលើ ។ បន្ទាប់ពីបានត្រួតពិនិត្យឃើញថាត្រឹមត្រូវហើយ មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារ ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលទាំងនេះ បញ្ជាក់ថា បានទទួលគ្រប់ចំនួនហើយ ។

៨.២៤.១.១ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធអាចចូលរួមចុះហត្ថលេខា ជាសាក្សីលើលិខិតបញ្ជូន និងប្រគល់ ទទួលខាងលើ ។

៨.២៤.១.២ ការមិនព្រមចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ទទួលខាងលើ ពីភ្នាក់ងារគណបក្សនយោបាយ មិនអាចចាត់ទុកលិខិតនេះជាមោឃៈ បានឡើយ ។

៨.២៤.២ មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារនៃ គធ.ខប ត្រូវកត់ត្រាមុខសម្ភារ ឯកសារដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួន និងត្រូវចារសម្គាល់ថា " ការប្រគល់គ្រប់ចំនួន " បន្ទាប់មកត្រូវចាត់ចែងប្រើប្រាស់លិខិតបញ្ជូន និងប្រគល់ទទួលដែលបានចុះហត្ថលេខារួច ដូចមានចែងក្នុងចំណុច ៨.២៤.១ ខាងលើ ដូចខាងក្រោម ៖

៨.២៤.២.១ ប្រគល់ជូនប្រធាន គយ.សប វិញ ១ (មួយ) ច្បាប់ ។

៨.២៤.២.២ ដក ១ (មួយ) ច្បាប់ ចងក្រងទុកជាឯកសារ ។

៨.២៤.២.៣ ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅកញ្ចប់ " គ ពិសេស " ឬស្បោង " គ " ឬស្បោង " គ មានបណ្តឹង " ពាក់ព័ន្ធ ។

៨.២៤.៣ បន្ទាប់ពីបានអនុវត្តចំណុច ៨.២៤.២ រួច មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារនៃ គធ.ខប ត្រូវប្រគល់រាល់សម្ភារ ឯកសារបោះឆ្នោតដែលបានទទួលទាំងអស់ ឱ្យសហការីរបស់ខ្លួនដែលទទួលបន្ទុករក្សាស្តុកនាំយកកញ្ចប់ " គ ពិសេស " ស្បោង " គ " ឬស្បោង " គ មានបណ្តឹង " ទៅរក្សាទុកនៅក្នុងបន្ទប់ ដូចបញ្ជាក់ក្នុងចំណុច ៨.២៣.១.២ និងនាំយកសម្ភារ ឯកសារបោះឆ្នោតនៅសល់ទៅរក្សាទុកនៅក្នុងបន្ទប់ ដូចបញ្ជាក់ក្នុងចំណុច ៨.២៣.១.៣ ខាងលើ ។ មន្ត្រីទទួលបន្ទុករក្សាស្តុកត្រូវបែងចែក និងរក្សាមុខសម្ភារ ឯកសារដោយឡែកពីគ្នាតាមឃុំ សង្កាត់ ព្រមទាំងត្រូវសរសេរសម្គាល់ លេខកូដឃុំ សង្កាត់នីមួយៗផង ។

៨.២៤.៤ ប្រសិនបើនៅក្នុងការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតពី គយ.សប ណាមួយ ដូចមានចែងក្នុងប្រការ ៨.២៤ ខាងលើ មានស្បោង " គ " ណាមួយ ឬច្រើន ត្រូវបានសរសេរសម្គាល់ថា " មានបណ្តឹង " នោះនៅពេលកំពុងអនុវត្តនីតិវិធីចំណុច ៨.២៤.២ ខាងលើ មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារនៃ គធ.ខប ត្រូវចារបន្ថែមក្នុងបញ្ជីទទួលសម្ភារ ឯកសាររបស់ខ្លួនថា " មានបណ្តឹង " ។ ក្នុងករណីនេះ មន្ត្រីនៃ គធ.ខប ទទួលបន្ទុកការទទួលសម្ភារ ឯកសារបោះឆ្នោតត្រូវ ៖

- ៨.២៤.៤.១ ស្រង់កត់ត្រាឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ។
- ៨.២៤.៤.២ យកកញ្ចប់ " គ ពិសេស " និងស្បោង " គ " ដែលមានសរសេរសម្គាល់ថា " គ មានបណ្តឹង " នៃឃុំ សង្កាត់ពាក់ព័ន្ធ ទៅរក្សាទុកដោយឡែកនៅក្នុងបន្ទប់ស្តុក ដើម្បីងាយស្រួលរក ។

៨.២៤.៥ មន្ត្រីទទួលបន្ទុកការទទួលសម្ភារ ឯកសារ ត្រូវរាយការណ៍អំពីចំនួនកញ្ចប់ " គ ពិសេស " ស្បោង " គ " ឬស្បោង " គ មានបណ្តឹង " និងកញ្ចប់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលបានទទួលពីគ្រប់ឃុំ សង្កាត់ចំណុះរាជធានី ខេត្តរួចហើយ និងបញ្ជាក់ច្បាស់នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានពាក្យបណ្តឹង ដូចមានចែងក្នុងចំណុច ៨.២៤.៤.១ ខាងលើ ជូន គធ.ខប ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផលឱ្យត្រួតពិនិត្យលទ្ធផលទៅតាមករណីជាក់ស្តែងនីមួយៗ ។

៨.២៤.៦ មន្ត្រីទទួលបន្ទុកទទួលសម្ភារ ឯកសារបោះឆ្នោត ត្រូវយកស្រោមសំបុត្រដាក់បញ្ជីវត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត (ទ.១១២០) តាមឃុំ សង្កាត់ ដើម្បីបញ្ជូនឱ្យប្រធាន គធ.ខប ចាត់ចែងបូកសរុបចំនួនអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន រួចបញ្ជូនទៅ គ.ជ.ប ។

ការដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់ គយ.សប នៅ គធ.ខប

ប្រការ ៨.២៥.

ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ដែលទទួលបានការអនុញ្ញាតឱ្យសង្កេតមើលការបោះឆ្នោត នៅការិយាល័យបោះឆ្នោតនៃឃុំ សង្កាត់ណាមួយ ឬតំណាង ដែលមិនពេញចិត្តនឹងសេចក្តីសម្រេចរបស់ គយ.សប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដូចមានចែងក្នុងចំណុច ៨.១៦.៦ និង ៨.១៧.៨ មានសិទ្ធិប្តឹងតវ៉ា ឬប្តឹងជំទាស់ទៅ គធ.ខប ។

៨.២៥.១ រាល់ការប្តឹងតវ៉ា ឬប្តឹងជំទាស់ដូចបញ្ជាក់ក្នុងប្រការ ៨.២៥ ខាងលើ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបាន ទ.១២០៣ របស់ គយ.សប ដែលបដិសេធលើពាក្យបណ្តឹង ដូចមានចែងក្នុងចំណុច ៨.១៦.៦.២ និង ៨.១៧.៨.២ ។ គធ.ខប ត្រូវសម្រេចលើពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ទាំងនេះ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

៨.២៥.២ ប្រសិនបើនៅក្នុងរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ៨.២៥.១ ខាងលើ គធ.ខប មិនបានទទួលពាក្យបណ្តឹងណាមួយទេ ប្រការនេះត្រូវបានចាត់ទុកថាគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ គយ.សប។

៨.២៥.៣ ភ្នាក់ងារគណបក្សនយោបាយ ឬតំណាង ដែលមានបំណងប្តឹង ដូចក្នុងប្រការ ៨.២៥ ខាងលើ ត្រូវបំពេញ និងចុះហត្ថលេខា ឬផ្ទិតមេដៃលើពាក្យបណ្តឹង ទ.១២០២ ចំនួន ៣ (បី) ច្បាប់ ក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចខាងក្រោម ៖

- ៨.២៥.៣.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង ។
- ៨.២៥.៣.២ លក្ខណៈសម្គាល់នៃ គយ.សប ឬ/និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។
- ៨.២៥.៣.៣ ពេលវេលានៃការកើតឡើង និងប្រភេទនៃកំហុស ឬភាពមិនប្រក្រតី។
- ៨.២៥.៣.៤ កម្មវត្ថុនៃការប្តឹងតវ៉ា ឬជំទាស់នឹងសេចក្តីសម្រេចរបស់ គយ.សប ។
- ៨.២៥.៣.៥ ប្រសិនបើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ត.រ ឬ ប.ន.ត.រ ដែលត្រូវបានរំលោភ ។
- ៨.២៥.៣.៦ មនុស្សដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តកំហុស ឬភាពមិនប្រក្រតីនេះ ។
- ៨.២៥.៣.៧ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន ។
- ៨.២៥.៣.៨ សេចក្តីអះអាងគាំទ្រ ឬភស្តុតាងផ្សេងទៀត បើមាន ។
- ៨.២៥.៣.៩ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកសង្កេតការណ៍ ដែលមានវត្តមានក្នុងពេលហេតុការណ៍កើតឡើង បើមាន ។

៨.២៥.៤ គធ.ខប មិនត្រូវទទួលដោះស្រាយពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលបានដាក់ក្រោយរយៈពេលកំណត់ ដូចមានចែងក្នុងចំណុច ៨.២៥.១ និងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលមិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ ដូចមានចែងក្រោមចំណុច ៨.២៥.៣ ខាងលើ ។

៨.២៥.៤.១ ចំពោះពាក្យបណ្តឹង ដែលបានទទួលក្រោយរយៈពេលកំណត់ ដូចចែងក្នុងចំណុច ៨.២៥.១ ខាងលើ ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងជម្រាបអ្នកប្តឹងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយរយៈពេលកំណត់ គធ.ខប មិនអាចទទួលយកមកដោះស្រាយបានទេ ។

៨.២៥.៤.២ ចំពោះពាក្យបណ្តឹង មិនមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ ដូចមានចែងក្រោមចំណុច ៨.២៥.៣ ខាងលើ គធ.ខប ត្រូវណែនាំអ្នកប្តឹង ឬតំណាង ឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត មិនឱ្យហួសអំឡុងពេលនៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាក្នុងកំណត់ហេតុ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ។

៨.២៥.៥ ចំពោះពាក្យបណ្តឹង ដែលបានទទួលក្នុងរយៈពេលកំណត់ និងមានព័ត៌មានចាំបាច់គ្រប់គ្រាន់ មន្ត្រីទទួលពាក្យបណ្តឹងនៃ គធ.ខប ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គធ.ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ នៅលគធ.ខប និងទុក ១ (មួយ) ច្បាប់ សម្រាប់ គធ.ខប ប្រើក្នុងពេលដោះស្រាយ

ពាក្យបណ្តឹង ។ បន្ទាប់មកប្រាប់អ្នកប្តឹង ឬតំណាងថា គធ.ខប នឹងសម្រេចលើពាក្យបណ្តឹងរបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ ។

៨.២៥.៦ មន្ត្រីទទួលពាក្យបណ្តឹងនៃ គធ.ខប ត្រូវរាយការណ៍អំពីករណីបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ខាងលើនេះ ជូនប្រធាន គធ.ខប ជាបន្ទាន់ ដើម្បីកំណត់បែងចែក និងណែនាំក្រុមត្រួតពិនិត្យលទ្ធផល ឱ្យត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ដែលមានពាក្យបណ្តឹងនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាង ។ ប្រសិនបើចាំបាច់ គធ.ខប ត្រូវបង្គាប់ក្រុមត្រួតពិនិត្យលទ្ធផលឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោត ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹង ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។ ការត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ត្រូវអនុវត្តតាមលំនាំនីតិវិធី ដូចមានចែងក្រោមប្រការ ៨.២០ នៃ ប.ន.ត.រ នេះ ។

ប្រតិបត្តិការរបស់ គធ.ខប ក្នុងការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ និងការបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

ប្រការ ៨.២៦.

បន្ទាប់ពីបានទទួលកញ្ចប់ " គ ពិសេស " និងស្បោង " គ " ឬ/និងស្បោង " គ មានបណ្តឹង " នៃឃុំ សង្កាត់មួយចំនួនហើយ គធ.ខប ត្រូវចាត់វិធានការជាបណ្តើរៗ ឱ្យក្រុមត្រួតពិនិត្យលទ្ធផលធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ដែលខ្លួនទទួលបន្ទុក តាមករណីនីមួយៗ ដោយឡែកពីគ្នា ទាំងឃុំ សង្កាត់គ្មានពាក្យបណ្តឹង ទាំងឃុំ សង្កាត់មានពាក្យបណ្តឹង ឱ្យរួចរាល់ឆាប់រហ័ស តាមដែលអាចធ្វើបាន ។ ផ្អែកលើលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលត្រូវបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់រួចហើយ គធ.ខប ត្រូវចាត់ចែងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ឱ្យរួចរាល់ដោយមិនត្រូវឱ្យហួសរយៈពេល ៥ (ប្រាំ) ថ្ងៃឡើយ ដោយគិតចាប់ពីថ្ងៃដែល គយ.សប បានប្រគល់កញ្ចប់ " គ ពិសេស " និងស្បោង " គ " ឬ/និងស្បោង " គ មានបណ្តឹង " នៅ គធ.ខប ។

៨.២៦.១ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកសារព័ត៌មាន និងអ្នកប្តឹង ឬតំណាង ត្រូវបាន អនុញ្ញាតឱ្យចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ចំណុះរាជធានី ខេត្ត នៅមជ្ឈមណ្ឌលត្រួតពិនិត្យនៃ គធ.ខប ។

៨.២៦.១.១ ភ្នាក់ងារនៃគណបក្សនយោបាយនីមួយៗ និងអ្នកសង្កេតការណ៍នៃអង្គការនីមួយៗ ប្រចាំការតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ត្រូវជ្រើសតាំងឱ្យមានតំណាងពេញសិទ្ធិ និងតំណាងបម្រុងតាមចំនួនដែល គធ.ខប បានកំណត់ដែលអាចចូលរួមគ្រប់គ្រាន់ល្មម ក្នុងការសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប។

៨.២៦.១.២ ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលកិច្ចប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប នីមួយៗ អាចផ្លាស់ប្តូរតំណាងបម្រុងឱ្យបំពេញភារកិច្ចជំនួសខ្លួន ។

៨.២៦.១.៣ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬតំណាង ត្រូវបានរៀបចំឱ្យស្ថិតនៅទីជិត ល្មមដែលអាចសង្កេតមើលឃើញនូវសកម្មភាពទាំងឡាយនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ។

៨.២៦.១.៤ ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ អ្នកប្តឹង ឬតំណាងអាចថតយករូបភាពនៃការត្រួតពិនិត្យ និងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តបាន ប៉ុន្តែមិនត្រូវរំខាន ឬជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់ដំណើរការនេះឡើយ ។

៨.២៦.២ កិច្ចប្រតិបត្តិការត្រួតពិនិត្យ ផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ ប្រសិនបើចាប់ដំណើរការហើយ ត្រូវធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ជាពិសេសចំពោះឃុំ សង្កាត់មានពាក្យបណ្តឹងទាក់ទងនឹងភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលតម្រូវឱ្យក្រុមត្រួតពិនិត្យលទ្ធផលបើកកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។

៨.២៦.៣ គធ.ខប ត្រូវចាត់ចែងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតតាមឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត នៅបន្ទប់ធំទូលាយមួយ ឬបន្ទប់តូចៗច្រើននៃមជ្ឈមណ្ឌលត្រួតពិនិត្យលទ្ធផល ដែលបានបង្កើតឡើងក្រោមប្រការ ៨.២៣ នៃជំពូកនេះ ។ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ពីរ ឬច្រើនក្រុម អាចបំពេញការងារនៅតាមតុរៀងខ្លួន ក្នុងបន្ទប់តែមួយ ឬនៅតាមបន្ទប់ដោយឡែកពីគ្នា ដោយយោងតាមលទ្ធភាពជាក់ស្តែងរបស់រាជធានី ខេត្ត ។ ក្រុមត្រួតពិនិត្យ

លទ្ធផលនីមួយៗ ត្រូវរៀបចំគំរូប្លង់បន្ទប់ តាមលំនាំបន្ទប់រាប់សន្លឹកឆ្នោត ដូចមានចែងក្រោមចំណុច ៨.១០.១ ខាងលើ និងត្រូវមានសម្ភារ ឯកសារ និងទម្រង់បែបបទគ្រប់គ្រាន់សម្រាប់បំពេញការងារ ។

៨.២៦.៣.១ ក្នុងការត្រួតពិនិត្យលទ្ធផលខាងលើនេះ ប្រធានក្រុមត្រូវអង្គុយនៅចុងតុម្ខាង និងឱ្យលេខាធិការអង្គុយនៅចុងតុម្ខាងទៀតទល់មុខប្រធាន ហើយឱ្យអនុប្រធានក្រុម និងជំនួយការអង្គុយនៅអមសងខាងតុទល់មុខគ្នា ។

៨.២៦.៣.២ ប្រធានក្រុមត្រូវត្រៀមនៅក្បែរខ្លួនគាត់នូវ ទ.១២០២ សម្រាប់ប្រគល់ជូនភ្នាក់ងារគណបក្សនយោបាយ ឬអ្នកប្តឹង ដើម្បីបំពេញពាក្យបណ្តឹង ប្រសិនបើមានការស្នើសុំ និងរាល់ទម្រង់បែបបទចាំបាច់ផ្សេងទៀត សម្រាប់ប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ ។

៨.២៦.៣.៣ ប្រធានក្រុមត្រូវប្រគល់ឱ្យអនុប្រធាន និងលេខាធិការនូវ ទ.១១១៦តព សម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផល របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ។

៨.២៦.៣.៤ ប្រធានក្រុមត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង សម្រាប់ប្រើក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនេះ ។

ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ប្រការ ៨.២៧.-

ក្នុងករណីឃុំ សង្កាត់ណាគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គឃ.សប និងនៅ គធ.ខប ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប មិនត្រូវបើកកញ្ចប់សុវត្ថិភាព " ក " ណាមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតទេ ។ ក្នុងករណីនេះ ក្រុមត្រួតពិនិត្យលទ្ធផលគ្រាន់តែធ្វើការត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ប៉ុណ្ណោះ ។

៨.២៧.១ ក្នុងដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល ដូចករណីខាងលើ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវចាត់ចែងអនុវត្តតាមនីតិវិធី ដូចខាងក្រោម ដោយត្រូវ ៖

៨.២៧.១.១ បង្គាប់ជំនួយការឱ្យនាំយកកញ្ចប់ " គ ពិសេស " នៃឃុំ សង្កាត់ ដែលគ្មានពាក្យបណ្តឹងម្តងមួយៗ ពីកន្លែងរក្សាស្តុកមកដាក់នៅលើតុចំពីមុខប្រធានក្រុម ។

៨.២៧.១.២ បើកកញ្ចប់ " គ ពិសេស " រួចដកយកស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) និងរាល់ស្រោមសំបុត្រដាក់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលផ្ញើជូន គធ.ខប មកដាក់នៅលើតុ។

៨.២៧.១.៣ ដកយកស្រោមសំបុត្រ ដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ផ្ញើជូន គ.ជ.ប ពីក្នុងកញ្ចប់ " គ ពិសេស " យកទៅប្រគល់ជូនប្រធាន លគធ.ខប ដើម្បីប្រមូលដាក់ទៅក្នុងកញ្ចប់ " ឃ ពិសេស " បន្ទាប់មកប្រធានក្រុមត្រូវដាក់កញ្ចប់ " គ ពិសេស " ទទេនៅក្បែរខ្លួនគាត់ ។

៨.២៧.១.៤ ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ និងគណនាផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ដោយផ្អែកលើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ដូចបញ្ជាក់ក្នុងចំណុច ៨.២៧.១.២ ខាងលើ ។ ក្នុងករណី មានភាពមិនច្បាស់លាស់ក្នុងការត្រួតពិនិត្យ ក្រុមត្រួតពិនិត្យត្រូវផ្ទៀងផ្ទាត់បន្ថែមជាមួយនឹងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៨.២៧.១.៥ ធានាថា តារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យនៃ គធ.ខប (ទ.១១១៦គព) ទាំង ២ (ពីរ) ច្បាប់ ដែលអនុប្រធាន និងលេខាធិការបានបំពេញ ត្រូវបានផ្ទៀងផ្ទាត់ត្រឹមត្រូវជាមួយគ្នា និងត្រូវមានបញ្ជាក់ឈ្មោះ និងលេខកូដឃុំ សង្កាត់ពាក់ព័ន្ធផង ។

៨.២៧.១.៦ ធានាថាតារាងត្រួតពិនិត្យលទ្ធផលខាងលើទាំង ២ (ពីរ) ច្បាប់ មានបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោម ប្រសិនបើរកឃើញថា ៖

- តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលបានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់មានភាពត្រឹមត្រូវ ។
- គយ.សប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ហើយកំហុសនោះត្រូវបានកែតម្រូវដោយក្រុមត្រួតពិនិត្យលទ្ធផល ។

៨.២៧.១.៧ ក្នុងករណីក្រុមត្រួតពិនិត្យលទ្ធផលបានរកឃើញកំហុសក្នុងការគណនាបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ប្រធានក្រុមត្រូវបង្ហាញកំហុស និងការកែតម្រូវកំហុស ព្រមទាំងហេតុផលនៃការកែតម្រូវនោះ នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដែលមានវត្តមាន ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវគូសឆ្លងលើតួលេខដែលខុស តែមិនត្រូវធ្វើឱ្យបាត់លក្ខណៈសម្គាល់នៃតួលេខដើមនោះទេ រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង ។ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ក្នុងករណីមិនពេញចិត្តនឹងការកែតម្រូវរបស់ប្រធានក្រុម ។

៨.២៧.១.៨ ធានាថាតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦គ៣) ខាងលើ ត្រូវបានចុះហត្ថលេខា ដោយសមាសភាពទាំងអស់ នៃក្រុមត្រួតពិនិត្យលទ្ធផលពាក់ព័ន្ធ ។

៨.២៧.១.៩ ធានាថា តារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦គ៣) ខាងលើ ត្រូវបានដាក់ភ្ជាប់ទៅនឹងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) រួចដាក់ក្នុងស្រោមសំបុត្រដដែល ត្រៀមដាក់ជូន គធ.ខប ពិនិត្យសម្រេច តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ។

៨.២៧.២ គធ.ខប ត្រូវពិនិត្យសម្រេចលើតារាងត្រួតពិនិត្យលទ្ធផល របស់ក្រុមត្រួតពិនិត្យលទ្ធផលដែលបានដាក់ជូនដូចមានចែងក្នុងចំណុច ៨.២៧.១.៩ ខាងលើ ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ ប្រធាន គធ.ខប ត្រូវចារយល់ព្រម រួចចុះហត្ថលេខា

បោះត្រា និងកាលបរិច្ឆេទ និងដាក់បង្ហាញជូនភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។ បន្ទាប់មក ប្រធាន គធ.ខប ត្រូវត្រៀមតារាងត្រួតពិនិត្យលទ្ធផល ដែលចារយល់ព្រម ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ដែលនឹងត្រូវដាក់ក្នុងកញ្ចប់ " ឃ ពិសេស " ដូចមានចែងក្នុងចំណុច ៨.៣០.២ ខាងក្រោម និងប្រគល់តារាងត្រួតពិនិត្យលទ្ធផលដែលចារយល់ព្រម ១ (មួយ) ច្បាប់ និងរាល់សំណុំឯកសារភ្ជាប់ជាមួយ ជូនក្រុមបូកសរុបលទ្ធផលដែលនឹងត្រូវអនុវត្តការកិច្ចរបស់ខ្លួន ដូចមានចែងក្រោមប្រការ ៨.២៩ ខាងក្រោម ។

៨.២៧.៣ ប្រធាន គធ.ខប ត្រូវធានាថា នៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលបានប្រគល់ឱ្យខ្លួននូវស្រោមសំបុត្រ ដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុង ឃុំ សង្កាត់ ផ្ញើជូន គ.ជ.ប (ទ.១១០៩) ដើម្បីប្រមូលផ្តុំ ដាក់ទៅក្នុងកញ្ចប់ " ឃ ពិសេស " ដែលត្រៀមបម្រុងជាស្រេចដូចមានចែងក្នុងចំណុច ៨.៣០.២ ខាងក្រោម ។

៨.២៧.៤ ប្រធាន គធ.ខប ត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផល ១ (មួយ) ច្បាប់ និងរាល់ឯកសារ ដូចបញ្ជាក់ក្នុងចំណុច ៨.២៧.១.៤ ខាងលើដែលបានប្រើក្នុងការត្រួតពិនិត្យលទ្ធផល និងដាក់ជូន គធ.ខប ពិនិត្យសម្រេចរួចហើយ ត្រូវបានក្រុមត្រួតពិនិត្យលទ្ធផលដាក់ទៅក្នុងស្រោមសំបុត្រដើម និងវេចខ្ជាប់ក្នុងកញ្ចប់ " គ ពិសេស " រួចយកទៅរក្សាទុកនៅកន្លែងស្ពុកវិញ ដែលត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប ។

៨.២៧.៥ គធ.ខប ត្រូវធានាថា ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលគ្មានបណ្តឹងទាំងអស់ចំណុះរាជធានី ខេត្ត ត្រូវបានអនុវត្តម្តងមួយឃុំ សង្កាត់ៗ ហើយរាល់នីតិវិធី ដូចមានចែងចាប់ពីចំណុច ៨.២៧.១ ដល់ ៨.២៧.៤ ខាងលើ ត្រូវតែបានអនុវត្ត ។

ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ដាក់នៅ គយ.សប និងនៅ គធ.ខប

ប្រការ ៨.២៨.-

ក្នុងករណីឃុំ សង្កាត់ណាដែលមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប ដូចចែងក្នុងប្រការ ៨.១៦ និងប្រការ ៨.១៧ ខាងលើ ហើយបណ្តឹងនោះត្រូវបានដាក់ប្តឹងបន្តនៅ

គធ.ខប ដូចចែងក្នុងចំណុច ៨.២៥.១ ខាងលើ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ក៏ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះផងដែរ ។ ក្នុងករណីនេះ នីតិវិធីដូចមានចែងក្រោមចំណុច ៨.២៧.១ និង ៨.២៧.៣ ខាងលើ ត្រូវតែបានអនុវត្ត ប៉ុន្តែក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ត្រូវអនុវត្ត បន្ថែមតាមលក្ខខណ្ឌដូចខាងក្រោម ៖

៨.២៨.១ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវត្រួតពិនិត្យជាមុន នូវសេចក្តីសម្រេចរបស់ គយ.សប លើពាក្យបណ្តឹងពាក់ព័ន្ធ របាយការណ៍របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន) និងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់នោះ ដែលបានដាក់នៅ គធ.ខប ហើយត្រូវស្នើសុំយោបល់សម្រេចពី គធ.ខប អំពីការអនុញ្ញាតឱ្យបើក ឬមិនឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតពាក់ព័ន្ធ ។

៨.២៨.១.១ ផ្អែកតាមឯកសារខាងលើ ក្នុងករណីគ្មានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬពុំមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត គធ.ខប មិនចាំបាច់តម្រូវឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតឡើយ ។

៨.២៨.១.២ ផ្អែកតាមឯកសារខាងលើ ក្នុងករណីមានកំហុសក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យប៉ះពាល់លទ្ធផលនៃការបោះឆ្នោត គធ.ខប ត្រូវសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។

៨.២៨.២ ប្រសិនបើ គធ.ខប សម្រេចមិនឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចមានចែងក្នុងចំណុច ៨.២៨.១.១ ខាងលើទេ នីតិវិធីចាប់ពីចំណុច ៨.២៧.១ ដល់ ៨.២៧.៤ ខាងលើ ត្រូវតែបានអនុវត្ត។

៨.២៨.៣ ប្រសិនបើ គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ដូចមានចែងក្នុងចំណុច ៨.២៨.១.២ ខាងលើ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តនីតិវិធីចំណុច ៨.២៧.១ និង ៨.២៧.៣ ខាងលើ ហើយបន្ទាប់មកប្រធានក្រុមត្រូវ ៖

៨.២៨.៣.១ បង្គាប់ជំនួយការឱ្យទៅនាំយកស្បោង " គ មានបណ្តឹង " នៃឃុំ សង្កាត់ ពាក់ព័ន្ធពីបន្ទប់ក្សាស្តុក មកដាក់នៅលើតុចំពីមុខប្រធានក្រុម ។

៨.២៨.៣.២ បើកស្បោង " គ " នោះ ដកយកស្បោង " ខ " ចេញមកក្រៅ រួចបើក និងដកយកកញ្ចប់សុវត្ថិភាព " ក " មកដាក់នៅលើតុ ។

៨.២៨.៣.៣ បើកកញ្ចប់សុវត្ថិភាព " ក " រួចដកយករាល់ស្រោមសំបុត្រ និងស្បោងប្លាស្ទិក ដាក់សម្ភារ ឯកសារបោះឆ្នោតទាំងអស់ ដែលមាននៅខាងក្នុង មកដាក់ដោយឡែកពីគ្នានៅលើតុខាងមុខគាត់ ។

៨.២៨.៣.៤ ប្រគល់កំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ឱ្យទៅលេខាធិការ សម្រាប់តាមដានពិនិត្យ ដោយប្រៀបធៀបទៅនឹងលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ។

៨.២៨.៣.៥ បើកស្រោមសំបុត្រ ឬស្បោងប្លាស្ទិកដាក់សម្ភារ ឯកសារបោះឆ្នោតម្តងមួយៗ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់តាមនីតិវិធី ដូចមានចែងក្រោមចំណុច ៨.២៨.៤ ខាងក្រោម ។

៨.២៨.៤ នៅពេលមានកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) កំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) និងតារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតនៃការិយាល័យបោះឆ្នោតពាក់ព័ន្ធគ្រប់គ្រាន់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យនោះ តាមលំនាំនីតិវិធីដូចមានចែងក្រោមចំណុច ៨.២០.២ ខាងលើ ដោយត្រូវយកចិត្តទុកដាក់ចំពោះបញ្ហាក្នុងកម្មវត្ថុនៃពាក្យបណ្តឹងពាក់ព័ន្ធ ។

៨.២៨.៥ ក្នុងករណី គធ.ខប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតលើសពីមួយ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តតាមលំនាំនីតិវិធីដដែល ដូចមានចែងក្នុងចំណុច ៨.២៨.៣ និង ៨.២៨.៤ ខាងលើ សម្រាប់កញ្ចប់សុវត្ថិភាព " ក " នីមួយៗរហូតទាល់តែអស់កញ្ចប់សុវត្ថិភាព " ក " ដែលត្រូវបើក ។

៨.២៨.៦ បន្ទាប់ពីបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតណាមួយ ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ដូចមានចែងក្រោមចំណុច ៨.២៨.៣ និង ៨.២៨.៤ ខាងលើ រួចរាល់ហើយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលត្រូវចាត់ចែងអនុវត្តដូចខាងក្រោម ៖

៨.២៨.៦.១ ធ្វើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ចំនួន ២ (ពីរ) ច្បាប់ ដែលត្រូវចុះហត្ថលេខាដោយសមាសភាពទាំងអស់នៃក្រុមត្រួតពិនិត្យ លទ្ធផល ។ ក្នុងរបាយការណ៍នេះ ត្រូវតែមានលើកយោបល់ស្នើសុំ គធ.ខប ពិនិត្យសម្រេច តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ៖

- យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត នៅការិយាល័យ បោះឆ្នោតពាក់ព័ន្ធ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ពាក់ព័ន្ធ ឬ
- យល់ព្រមកែតម្រូវតួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ករណីរកឃើញកំហុសឆ្គងក្នុងការគណនាលេខ ឬ
- ព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ពាក់ព័ន្ធ (រាប់សន្លឹកឆ្នោតឡើងវិញ ឬបោះឆ្នោតសាជាថ្មី) ។

៨.២៨.៦.២ ចារលើរបាយការណ៍របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និង សន្លឹកឆ្នោត ដោយបញ្ជាក់ខ្លឹមសារស្របទៅនឹងរបាយការណ៍របស់ ក្រុមត្រួតពិនិត្យលទ្ធផល ដូចមានចែងក្នុងចំណុច ៨.២៨.៦.១ ខាងលើ។

៨.២៨.៦.៣ ដាក់របាយការណ៍ ដូចចែងក្នុងចំណុច ៨.២៨.៦.១ ខាងលើ សេចក្តី សម្រេចរបស់ គយ.សប លើពាក្យបណ្តឹងពាក់ព័ន្ធ របាយការណ៍ របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួត ពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន) ភ្ជាប់ទៅនឹងតារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារពាក់ព័ន្ធ ដែលក្រុមត្រួតពិនិត្យលទ្ធផលត្រូវដាក់ជូន គធ.ខប ពិនិត្យសម្រេច តាមរយៈប្រធានអនុគណៈកម្មការបច្ចេកទេស ដូចបញ្ជាក់ក្នុងចំណុច ៨.២៧.១.៩ ខាងលើ ។

៨.២៨.៦.៤ ដាក់សម្ភារ ឯកសារបោះឆ្នោតទៅក្នុងស្បោងធ្លាស្វិក និងស្រោមសំបុត្រពាក់ព័ន្ធនានា រួចវេចខ្ជប់ក្នុងកញ្ចប់សុវត្ថិភាព " ក " វិញ តាមលំនាំដើម ។

៨.២៨.៦.៥ ដាក់កញ្ចប់សុវត្ថិភាព " ក " ទៅក្នុងស្បោង " ខ " រួចចងភ្ជិត និងដាក់ស្បោង " ខ " ទៅក្នុងស្បោង " គ មានបណ្តឹង " តាមលំនាំដើម និងចាក់សោឃ្លុំមានលេខ ដែលត្រូវនាំយកទៅរក្សាទុកនៅកន្លែងដើម ត្រៀមសម្រាប់ការវេចខ្ជប់ និងបញ្ជូនទៅ គ.ជ.ប ។

៨.២៨.៧ ផ្អែកលើរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផល ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត និងសំណុំឯកសារ ដូចចែងក្នុងចំណុច ៨.២៨.៦.៣ ខាងលើ ព្រមទាំងផ្អែកលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែល គធ.ខប បានទទួល គធ.ខប ត្រូវប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ ដោយត្រូវអនុវត្តតាមចំណុច ៨.២៨.១១ ៨.២៨.១២ និង ៨.២៨.១៣ ខាងក្រោម ។

៨.២៨.៨ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដូចចែងក្រោមចំណុច ៨.២៥.៥ ខាងលើ ត្រូវបានដាក់នៅ គធ.ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ ដូចចែងក្រោមប្រការ ៨.២៨ គធ.ខប ត្រូវផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យរួចហើយនោះ ដើម្បីប្រជុំសម្រេចលើពាក្យបណ្តឹងពាក់ព័ន្ធ ។

៨.២៨.៩ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដូចចែងក្រោមចំណុច ៨.២៥.៥ ខាងលើ ត្រូវបានដាក់នៅ គធ.ខប នៅក្រោយពេលដែលក្រុមត្រួតពិនិត្យលទ្ធផលបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ ដូចចែងក្រោមប្រការ ៨.២៧ គធ.ខប ត្រូវធានាថា រាល់នីតិវិធីដូចចែងក្នុងចំណុច ៨.២៨.៣ ៨.២៨.៤ ៨.២៨.៥ ៨.២៨.៦ និង ៨.២៨.៧ ត្រូវតែបានអនុវត្ត នៅមុនពេល គធ.ខប ប្រជុំសម្រេចលើពាក្យបណ្តឹង ។

៨.២៨.១០ ក្នុងករណីពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដូចចែងក្រោមចំណុច ៨.២៥.៥ ខាងលើ ពាក់ព័ន្ធនឹងឃុំ សង្កាត់ ដែលមិនទាន់ត្រូវបានត្រួតពិនិត្យ គធ.ខប ត្រូវធានា

ថារាល់នីតិវិធី ដូចចែងក្នុងចំណុច ៨.២៧.១ ៨.២៧.៣ ៨.២៨.៣ ៨.២៨.៤ ៨.២៨.៥ ៨.២៨.៦ និង ៨.២៨.៧ ខាងលើ ត្រូវតែបានអនុវត្តនៅមុនពេល គធ.ខប ប្រជុំសម្រេចលើពាក្យបណ្តឹង ។

ការប្រជុំសម្រេចរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់

៨.២៨.១១ ប្រសិនបើ គធ.ខប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ គធ.ខប ត្រូវចារយល់ព្រមលើសេចក្តីសម្រេចរបស់ គយ.សប ដែលបានទទួលយកលទ្ធផលនៃការបោះឆ្នោត និងចារបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលបានដាក់នៅ គធ.ខប ឬចារបដិសេធលើសេចក្តីសម្រេចរបស់ គយ.សប ដែលយល់ព្រមកែតម្រូវលទ្ធផលនៃការបោះឆ្នោត ឬបដិសេធលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ។ ក្នុងករណីនេះ ប្រធាន គធ.ខប ត្រូវ ៖

- ៨.២៨.១១.១ ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល ដែលស្នើសុំឱ្យ គធ.ខប សម្រេចទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ។
- ៨.២៨.១១.២ ចារយល់ព្រមលើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ។
- ៨.២៨.១១.៣ ចារយល់ព្រមលើសម្រង់សេចក្តីសម្រេចរបស់ គយ.សប ដែលបានបដិសេធពាក្យបណ្តឹងពាក់ព័ន្ធ និងទទួលយកលទ្ធផលនៃការបោះឆ្នោត ឬចារបដិសេធលើសម្រង់សេចក្តីសម្រេចរបស់ គយ.សប ដែលបានយល់ព្រមតាមពាក្យបណ្តឹងពាក់ព័ន្ធ ដោយធ្វើការកែតម្រូវលទ្ធផលនៃការបោះឆ្នោត ឬបដិសេធលទ្ធផលនៃការបោះឆ្នោត រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ខប ។
- ៨.២៨.១១.៤ ធានាថា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ បានបំពេញសម្រង់សេចក្តីសម្រេចរបស់ គធ.ខប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលត្រូវបដិសេធពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលដាក់នៅ គធ.ខប ដោយបញ្ជាក់ច្បាស់ពីមូលហេតុ ហើយត្រូវចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងប្រធាន គធ.ខប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប ។

៨.២៨.១១.៥ ប្រគល់សម្រង់សេចក្តីសម្រេចរបស់ គធ.ខប បដិសេធលើពាក្យបណ្តឹង ដោយយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.២៨.១១.៦ ជម្រាបអ្នកប្តឹង ឬតំណាងថា គាត់មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់ គធ.ខប ទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចរបស់ គធ.ខប ។

៨.២៨.១១.៧ ប្រគល់ ទ.១២០២ សម្រាប់បំពេញពាក្យបណ្តឹង ចំនួន ៣ (បី) ច្បាប់ ជូនអ្នកប្តឹង ឬតំណាង ប្រសិនបើគាត់ស្នើសុំ ។

៨.២៨.១១.៨ ប្រគល់រាល់ឯកសារដូចចែងក្នុងចំណុច ៨.២៨.១១.១ ៨.២៨.១១.២ ៨.២៨.១១.៣ និង ៨.២៨.១១.៥ មួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមបូកសរុបលទ្ធផលនៃ គធ.ខប ដែលនឹងត្រូវអនុវត្តការកិច្ចរបស់ខ្លួន ដូចចែងក្រោមប្រការ ៨.២៩ ខាងក្រោម និងត្រៀមឯកសារទាំងនេះ មួយមុខ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ដែលត្រូវដាក់ក្នុងកញ្ចប់ " ឃ ពិសេស " ដូចចែងក្នុងចំណុច ៨.៣០.២ ខាងក្រោម ។

៨.២៨.១២ ប្រសិនបើ គធ.ខប សម្រេចយល់ព្រមកែតម្រូវលទ្ធផលនៃការបោះឆ្នោតនៅការិ-យាល័យបោះឆ្នោតណាមួយ ឬលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ណាមួយ គធ.ខប ត្រូវចារបដិសេធលើសម្រង់សេចក្តីសម្រេចរបស់ គយ.សប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងចារយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលបានដាក់នៅ គធ.ខប ។ ក្នុងករណីនេះ ប្រធាន គធ.ខប ត្រូវ ៖

៨.២៨.១២.១ ចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល ដែលស្នើសុំឱ្យ គធ.ខប សម្រេចកែតម្រូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ។

៨.២៨.១២.២ ចារយល់ព្រមលើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ។

៨.២៨.១២.៣ ចារបដិសេធលើសម្រង់សេចក្តីសម្រេចរបស់ គយ.សប ដែលបានបដិសេធពាក្យបណ្តឹងពាក់ព័ន្ធ ដែលបានទទួលយកលទ្ធផលនៃការបោះឆ្នោត រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ខប ។

៨.២៨.១២.៤ ធានាថា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់បានបំពេញសម្រង់សេចក្តីសម្រេចរបស់ គធ.ខប យល់ព្រមកែតម្រូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលត្រូវយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលដាក់នៅ គធ.ខប ដោយបញ្ជាក់ច្បាស់លាស់ពីមូលហេតុ ហើយត្រូវចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងប្រធាន គធ.ខប បន្ទាប់មកចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប ។

៨.២៨.១២.៥ ប្រគល់សម្រង់សេចក្តីសម្រេចរបស់ គធ.ខប យល់ព្រមតាមពាក្យបណ្តឹង ដោយធ្វើការកែតម្រូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.២៨.១២.៦ ប្រគល់រាល់ឯកសារដូចចែងក្នុងចំណុច ៨.២៨.១២.១ ៨.២៨.១២.២ ៨.២៨.១២.៣ និង ៨.២៨.១២.៥ មួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមបូកសរុបលទ្ធផលនៃ គធ.ខប ដែលនឹងត្រូវអនុវត្តការកិច្ចរបស់ខ្លួនដូចចែងក្រោមប្រការ ៨.២៩ ខាងក្រោម និងត្រៀមឯកសារទាំងនេះ មួយមុខ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ដែលត្រូវដាក់ក្នុងកញ្ចប់ " ឃ ពិសេស " ដូចចែងក្នុងចំណុច ៨.៣០.២ ខាងក្រោម ។

៨.២៨.១៣ ប្រសិនបើ គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ គធ.ខប ត្រូវចារយល់ព្រមលើសេចក្តីសម្រេចរបស់ គយ.សប ដែលបដិសេធលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ឬចារបដិសេធលើសេចក្តីសម្រេចរបស់ គយ.សប ដែលយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ និងចារយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ដែលបានដាក់នៅ គធ.ខប ។ ក្នុងករណីនេះ ប្រធាន គធ.ខប ត្រូវ ៖

៨.២៨.១៣.១ ចារឲ្យរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ លើតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលស្នើឡើងដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ។

៨.២៨.១៣.២ ចារយល់ព្រមលើរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត របស់ក្រុមត្រួតពិនិត្យលទ្ធផល ដែលបានដាក់ជូន គធ.ខប ពិនិត្យ សម្រេច ដូចចែងក្នុងចំណុច ៨.២៨.៦.៣ ខាងលើ ។

៨.២៨.១៣.៣ ចារយល់ព្រមលើសម្រង់សេចក្តីសម្រេចរបស់ គយ.សប ដែល បានបដិសេធលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ឬ ចារបដិសេធលើសម្រង់សេចក្តីសម្រេចរបស់ គយ.សប ដែលបាន ទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះ ហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គធ.ខប ។

៨.២៨.១៣.៤ ធានាថា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់បានបំពេញសម្រង់ សេចក្តីសម្រេចរបស់ គធ.ខប បដិសេធលទ្ធផលនៃការបោះឆ្នោត នៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ពាក់ព័ន្ធ ដោយត្រូវយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹង ជំទាស់ ដែលបានដាក់នៅ គធ.ខប ដោយបញ្ជាក់ច្បាស់ពីមូលហេតុ ហើយដែលត្រូវចុះហត្ថលេខា ដោយសមាជិកទទួលបន្ទុកសេវាកម្ម ច្បាប់ និងប្រធាន គធ.ខប បន្ទាប់មក ចុះកាលបរិច្ឆេទ និងបោះត្រា គធ.ខប ។

៨.២៨.១៣.៥ ប្រគល់សម្រង់សេចក្តីសម្រេចរបស់ គធ.ខប បដិសេធលទ្ធផល នៃការបោះឆ្នោតខាងលើ ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ។

៨.២៨.១៣.៦ ប្រកាសថា លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិ-យាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ត្រូវបានបដិសេធ ដោយ គធ.ខប ហើយសេចក្តីសម្រេចនេះស្ថិតក្រោមការត្រួតពិនិត្យ ឡើងវិញរបស់ គ.ជ.ប ។

៨.២៨.១៣.៧ ធានាថា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ បានដាក់ទៅក្នុងស្រោមសំបុត្រដោយឡែកពីគ្នាសម្រាប់ផ្ញើជូន គ.ជ.ប នូវសម្រង់សេចក្តីសម្រេចរបស់ គធ.ខប បដិសេធលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ១ (មួយ) ច្បាប់ ព្រមទាំងរបាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ១ (មួយ) ច្បាប់ តារាងត្រួតពិនិត្យលទ្ធផល ដែលត្រូវបាន គធ.ខប ចារឲ្យជាបណ្តោះអាសន្ន ១ (មួយ) ច្បាប់ និងរបាយការណ៍របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ១ (មួយ) ច្បាប់ (បើមាន) ។

៨.២៨.១៣.៨ ប្រគល់រាល់ឯកសារដូចចែងក្នុងចំណុច ៨.២៨.១៣.១ ៨.២៨.១៣.២ ៨.២៨.១៣.៣ និង ៨.២៨.១៣.៥ ខាងលើ ក្នុងមួយមុខ ១ (មួយ) ច្បាប់ ទៅឱ្យក្រុមបូកសរុបលទ្ធផលនៃ គធ.ខប ដែលនឹងត្រូវអនុវត្តការកិច្ចរបស់ខ្លួន ដូចចែងក្រោមប្រការ ៨.២៩ ខាងក្រោម និងត្រៀមឯកសារទាំងនេះ មួយមុខ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ដែលនឹងត្រូវដាក់ក្នុងស្បោង " ឃ ព្យួរលទ្ធផល " ដូចក្នុងចំណុច ៨.២៨.១៤ ខាងក្រោម ។

៨.២៨.១៤ ក្នុងករណី គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ប្រធាន គធ.ខប ត្រូវបញ្ជូនសម្រង់សេចក្តីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ និងសម្ភារឯកសារបោះឆ្នោតពាក់ព័ន្ធជូន គ.ជ.ប មិនឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង គិតចាប់ពីពេលចេញសម្រង់សេចក្តីសម្រេចព្យួរលទ្ធផល ។ ប្រធាន គធ.ខប ត្រូវធានាថា សម្ភារឯកសារបោះឆ្នោតនៃឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវបានវេចខ្ចប់ដូចខាងក្រោមសម្រាប់បញ្ជូនទៅ គ.ជ.ប ។

៨.២៨.១៤.១ ដាក់ទៅក្នុងស្រោមសំបុត្រធំមួយ នូវរាល់ស្រោមសំបុត្រដាក់ឯកសារ និងទម្រង់បែបបទនានា ដូចក្នុងចំណុច ៨.២៨.១៣.៨ ខាងលើ និងស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោត

ក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោត (ទ.១១០៤) នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលត្រូវផ្ញើជូន គ.ជ.ប ហើយត្រូវសរសេរសម្គាល់ពីក្រៅថា " សេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់លេខ... (បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ) " ។

ជ.២ជ.១៤.២ ដាក់រាល់ស្បោង " គ " ផ្ទុកស្បោង " ខ " នៃឃុំ សង្កាត់ពាក់ព័ន្ធទៅក្នុងស្បោង " ឃ " ទៅតាមចំនួនដែលអាចដាក់ឱ្យអស់ស្បោង " គ " រួចចងភ្ជិត ចាក់សោឃ្លុំ និងត្រូវសរសេរសម្គាល់ពីក្រៅស្បោង " ឃ " ថា " ព្យួរលទ្ធផលឃុំ សង្កាត់លេខ... (បំពេញលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ) " ។

ជ.២ជ.១៤.៣ ចាត់ចែងបំពេញលិខិតបញ្ជូន និងប្រគល់ ទទួល (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយរាយមុខសម្ភារៈឯកសារ ដែលមាននៅក្នុងស្រោមសំបុត្រធំ និងក្នុងស្បោង " ឃ ព្យួរលទ្ធផល " ។

ជ.២ជ.១៤.៤ ដាក់លិខិតបញ្ជូន និងប្រគល់ ទទួល ១ (មួយ) ច្បាប់ ទៅក្នុងស្រោមសំបុត្រ ដូចចែងក្នុងចំណុច ជ.២ជ.១៤.១ រួចកិបភ្ជាប់ ១ (មួយ) ច្បាប់ ទៅនឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រនេះ និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលនៅ គ.ជ.ប ។

ការបូកសរុប និងការបំពេញលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត

ប្រការ ជ.២៥.-

បន្ទាប់ពីបានទទួលសំណុំឯកសាររបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលប្រធាន គធ.ខប បានចារយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ឬយល់ព្រមកែតម្រូវកូលេខ ឬសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ដូចចែងក្នុងចំណុច ជ.២ជ.២ ជ.២ជ.១១ ជ.២ជ.១២ និង ជ.២ជ.១៣ ខាងលើ ប្រធាន លគធ.ខប ដែលទទួលបន្ទុកជាប្រធានក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ត្រូវចាត់ចែងសមាជិកក្រុមរបស់ខ្លួន ដែលត្រូវបានតែងតាំង និងប្រគល់ភារកិច្ច ដូចបានកំណត់ក្នុងចំណុច ជ.២៣.១១ ខាងលើ ឱ្យគណនាសរុបបញ្ចូលគ្នានូវលទ្ធផលនៃការបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ទាំងអស់ក្នុងរាជធានី ខេត្ត ដោយធ្វើការគណនាដោយដៃ ឬ/និងដោយម៉ាស៊ីនគិតលេខ និងឱ្យបញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតពីគ្រប់ឃុំ សង្កាត់ទាំងអស់ ទៅក្នុងតារាងបូកសរុបលទ្ធផល

នៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ដែលមានត្រៀមស្រាប់ក្នុងកុំព្យូទ័រ ហើយដែលនឹងគណនាដោយស្វ័យប្រវត្តិនូវលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ។ ផ្អែកលើលទ្ធផលនៃការគណនាដោយដៃ និងដោយកុំព្យូទ័រខាងលើ ដែលមានលក្ខណៈត្រឹមត្រូវដូចគ្នា ប្រធានក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ត្រូវចាត់ចែងសមាជិកក្រុមរបស់ខ្លួនឱ្យស្រង់តួលេខលទ្ធផលសរុបពីតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) បញ្ចូលទៅក្នុងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៥) ដើម្បីដាក់ជូនប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប និងប្រធាន គធ.ខប ចុះហត្ថលេខាជាឯកសារផ្លូវការ ។

៨.២៩.១ ប្រធាន គធ.ខប ត្រូវធានាថា កុំព្យូទ័រមួយគ្រឿងមានភ្ជាប់បរិក្ខារប្រើប្រាស់គ្រប់គ្រាន់ រួមនឹងទម្រង់បែបបទជាតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ចងរូបមន្តធ្វើប្រមាណវិធីរួចជាស្រេច និងបណ្តាញប្រើប្រាស់អ៊ីមែល ដែល គ.ជ.ប បានផ្តត់ផ្តង់ត្រូវបានដំឡើង និងអាចដំណើរការបានល្អ និងត្រឹមត្រូវ ក្នុងនោះ ៖

- ៨.២៩.១.១ ត្រូវថែរក្សាទុកកម្មវិធីបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងរាជធានី ខេត្ត (ទ.១១១០) ដែលចងរូបមន្តធ្វើប្រមាណវិធីរួចជាស្រេចក្នុងកុំព្យូទ័រឱ្យបានល្អ ។
- ៨.២៩.១.២ ត្រូវតាមដានត្រួតពិនិត្យជាប្រចាំរាល់ការងារអនុវត្ត របស់ក្រុមបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ។

៨.២៩.២ ប្រធានអនុគណៈកម្មការបច្ចេកទេសនៃ គធ.ខប ត្រូវត្រួតពិនិត្យសុពលភាព រាល់សំណុំឯកសាររបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលប្រធាន គធ.ខប បានចារយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោត ឬយល់ព្រមកែតម្រូវតួលេខ ឬសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ដូចចែងក្នុងប្រការ ៨.២៩ ខាងលើ និងត្រូវរៀបចំដោយឡែកតាមលំដាប់លំដោយនៃលេខកូដឃុំ សង្កាត់ ។

- ៨.២៩.២.១ ផ្អែកតាមតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦គព) ដែលបានចារយល់ព្រមទទួលយក ឬយល់ព្រមកែតម្រូវតួលេខ ឬព្យួរលទ្ធផលដោយប្រធាន គធ.ខប ប្រធានអនុគណៈកម្មការបច្ចេកទេស ត្រូវចាត់ចែងធ្វើការផ្ទៀងផ្ទាត់តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់

នីមួយៗ ដោយការធ្វើប្រមាណវិធីដោយដៃ ឬ/និងដោយម៉ាស៊ីនគិតលេខ បន្ទាប់មកត្រូវស្រង់តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ មកបូកសរុបបញ្ចូលគ្នាជាលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ។

៨.២៩.២.២ ប្រធានអនុគណៈកម្មការបច្ចេកទេស ត្រូវចាត់ចែងស្រង់តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នីមួយៗ ពីតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦តព) ដែលបានចារយល់ព្រមទទួលយក ឬយល់ព្រមកែតម្រូវតួលេខ ឬព្យួរលទ្ធផល ដោយប្រធាន គធ.ខប បញ្ចូលទៅក្នុងតារាងបូកសរុបលទ្ធផលក្នុងរាជធានី ខេត្ត (ទ.១១១០) នៅក្នុងកុំព្យូទ័រ ។

៨.២៩.៣ បន្ទាប់ពីបានអនុវត្តចំណុច ៨.២៩.២.១ និង ៨.២៩.២.២ ខាងលើរួចហើយ ប្រធានអនុគណៈកម្មការបច្ចេកទេស ត្រូវចាត់ឱ្យផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលក្រុមខ្លួនបានគណនាឃើញ ហើយត្រូវរាយការណ៍ជូនប្រធាន គធ.ខប ។

៨.២៩.៤ ប្រសិនបើតួលេខលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលបានផ្ទៀងផ្ទាត់ខាងលើ នៅមានភាពខុសគ្នា ប្រធាន លគធ.ខប ត្រូវចាត់ចែងសមាជិកក្រុម ឱ្យត្រួតពិនិត្យផ្ទៀងផ្ទាត់ការធ្វើប្រមាណវិធីដោយដៃ និងការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ ដូចចែងក្នុងចំណុច ៨.២៩.២.១ និង ៨.២៩.២.២ ខាងលើម្តងទៀត ។

៨.២៩.៥ ប្រសិនបើ តួលេខលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តដែលបានផ្ទៀងផ្ទាត់ខាងលើ មានលក្ខណៈត្រឹមត្រូវហើយ ប្រធានអនុគណៈកម្មការបច្ចេកទេសត្រូវចាត់ចែងឱ្យបោះពុម្ពតារាងបូកសរុបលទ្ធផលក្នុងរាជធានី ខេត្ត (ទ. ១១១០) បំពេញ និងរៀបចំកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ. ១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ដើម្បីដាក់ជូន គធ.ខប ពិនិត្យសម្រេចជាឯកសារផ្លូវការត្រៀមសម្រាប់បញ្ជូនទៅ គ.ជ.ប ។

៨.២៩.៦ ប្រធាន គធ.ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការ បោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ដែលបានបោះពុម្ពចំនួន ២ (ពីរ) ច្បាប់ ត្រូវបានចុះហត្ថលេខា

ដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប ក្នុងនោះ ត្រូវផ្ញើជូន គ.ជ.ប មួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។ ប្រធាន គធ.ខប ត្រូវធានាថា តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ក្នុងកុំព្យូទ័រ ដែលមានទិន្នន័យដូចគ្នានឹងតារាងបូកសរុបលទ្ធផល ក្នុងរាជធានី ខេត្ត (ទ.១១១០) ដែលបានចុះហត្ថលេខាជាផ្លូវការរួចហើយ ត្រូវបានបញ្ជូនតាមអ៊ីមែល ឬតាមមធ្យោបាយផ្សេងទៀតជាបន្ទាន់ទៅ គ.ជ.ប ។

៨.២៩.៧ ប្រធាន គធ.ខប ត្រូវធានាថា កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ចំនួន ៣ (បី) ច្បាប់ ត្រូវបានស្រង់តួលេខលទ្ធផលសរុបពីតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) និងបានចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប ហើយត្រូវបានដាក់បង្ហាញចំពោះតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចូលរួមចុះហត្ថលេខាជាសាក្សី ។ ប្រធាន គធ.ខប ត្រូវបែងចែកប្រើប្រាស់កំណត់ហេតុនេះដូចខាងក្រោម ។

- ៨.២៩.៧.១ បិទផ្សាយ ១ (មួយ) ច្បាប់ នៅលេខាធិការដ្ឋាន គធ.ខប ។
- ៨.២៩.៧.២ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ។
- ៨.២៩.៧.៣ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- ៨.២៩.៧.៤ ថតចម្លង និងចែកជូនតំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងមណ្ឌលរាជធានី ខេត្តមួយច្បាប់ៗ ។

៨.២៩.៨ ប្រធាន គធ.ខប ត្រូវធានាថាក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ត្រូវបានបំពេញ ដោយស្រង់តួលេខលទ្ធផលសរុបពីកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងបានចុះហត្ថលេខាដោយប្រធានអនុគណៈកម្មការបច្ចេកទេស និងប្រធាន គធ.ខប រួចដាក់បង្ហាញជូនតំណាងគណបក្សនយោបាយពាក់ព័ន្ធ និងអ្នកសង្កេតការណ៍ ។ ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនេះ ត្រូវតែបានរៀបចំ និងថតចម្លងតាមចំនួនគ្រប់គ្រាន់សម្រាប់បែងចែក និងប្រើប្រាស់ដូចខាងក្រោម ។

- ៨.២៩.៨.១ បិទផ្សាយ ១ (មួយ) ច្បាប់ នៅលេខាធិការដ្ឋាន គធ.ខប ។
- ៨.២៩.៨.២ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ ។

៨.២៩.៨.៣ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.២៩.៨.៤ ប្រគល់ជូនភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរាជធានី ខេត្ត និងអ្នកសង្កេតការណ៍ប្រចាំរាជធានី ខេត្ត ១ (មួយ) ច្បាប់ៗ ។

៨.២៩.៩ ប្រធាន គធ.ខប ត្រូវធានាថា រាល់សំណុំឯកសាររបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ដែលត្រូវបានចារយល់ព្រមទទួលយក ឬយល់ព្រមកែតម្រូវតួលេខ ឬ សម្រេចព្យួរលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ និងដែលត្រូវបានប្រគល់ជូនក្រុមបូកសរុបលទ្ធផលនៃ គធ.ខប ប្រើប្រាស់ដូចចែងក្រោមប្រការ ៨.២៩ ខាងលើ ត្រូវតែបានរៀបចំ ឬថតចម្លងបន្ថែមសម្រាប់បែងចែក និងប្រគល់តាមគោលដៅដូចខាងក្រោម ។

៨.២៩.៩.១ រៀបចំតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦ត០) ច្បាប់ដើមមួយ (១) ច្បាប់ របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ គយ.សប (បើមាន) ១ (មួយ) ច្បាប់ និងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់ សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប (បើមាន) ១ (មួយ) ច្បាប់ សម្រង់សេចក្តីសម្រេចរបស់ គធ.ខប ច្បាប់ដើម ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ដែលនឹងត្រូវដាក់ក្នុងកញ្ចប់ " ឃ ពិសេស " ដូចមានចែងក្នុងចំណុច ៨.៣០.២ ខាងក្រោម ឬ ដាក់ក្នុងស្រោមសំបុត្រធំ ដូចមានចែងក្នុងចំណុច ៨.២៨.១៤.១ ខាងលើ ។

៨.២៩.៩.២ រក្សាទុករាល់ឯកសារ ដូចចែងក្នុងចំណុច ៨.២៩.៩.១ ខាងលើ និងរាល់ពាក្យបណ្តឹងតវ៉ា មួយមុខ ១ (មួយ) ច្បាប់ ជាឯកសាររបស់ គធ.ខប ។

៨.២៩.៩.៣ ច្រកទៅក្នុងស្រោមសំបុត្រវិញ នូវកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ. ១១០៣) ១ (មួយ) ច្បាប់ និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) ១ (មួយ) ច្បាប់ ដែលត្រូវរក្សាទុកជាឯកសាររបស់ គធ.ខប ។

៨.២៩.១០ ប្រធាន គធ.ខប ត្រូវធានាថា រាល់សំណុំឯកសារត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ច្បាប់ដើម និងច្បាប់ថតចម្លងបន្ថែម ដូចចែងក្រោមចំណុច ៨.២៩.៩ ខាងលើ ត្រូវបានរៀបចំបំបែក ឬ/និងដាក់ភ្ជាប់តាមការណែនាំ រួចប្រគល់ជូនមន្ត្រីទទួលបន្ទុកស្តុកឯកសារ ដើម្បីត្រៀមសម្រាប់ការវេចខ្ចប់បញ្ជូនទៅ គ.ជ.ប ក្នុងអំឡុងពេលយ៉ាងយូរ ២៤ (ម្តៃបួន) ម៉ោង ក្នុងករណីមានព្យួរលទ្ធផល ឬការវេចខ្ចប់បញ្ជូនតាមការកំណត់ធម្មតាទៅ គ.ជ.ប ឬ/និងសម្រាប់រក្សាទុកជាឯកសាររបស់ គធ.ខប ។

ការវេចខ្ចប់ និងបញ្ជូនលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងរាល់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ទៅ គ.ជ.ប

ប្រការ ៨.៣០.-

បន្ទាប់ពីបានអនុវត្តចប់សព្វគ្រប់នូវរាល់នីតិវិធីដូចចែងចាប់ពីប្រការ ៨.២៦ ដល់ ៨.២៩ នៃជំពូកនេះ គធ.ខប ត្រូវធានាថា កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ. ១១១៤) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ព្រមទាំងរាល់ស្បោង " គ " ដាក់សម្ភារ ឯកសារបោះឆ្នោតនៃឃុំ សង្កាត់ទាំងអស់ចំណុះរាជធានី ខេត្ត ត្រូវតែបានវេចខ្ចប់ទៅក្នុងកញ្ចប់ " ឃ ពិសេស " និងស្បោង " ឃ " បញ្ជូន និងប្រគល់ជូន គ.ជ.ប យ៉ាងត្រឹមត្រូវក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ ក្រោយពេលទទួលកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ។ ក្នុងករណីមានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ពាក់ព័ន្ធនឹងឃុំ សង្កាត់មួយ ឬច្រើនត្រូវបានដាក់នៅ គធ.ខប ប្រធាន គធ.ខប អាចចាត់ចែងវេចខ្ចប់រាល់ក្រដាសលទ្ធផល និងសម្ភារ ឯកសារបោះឆ្នោត ដូចបញ្ជាក់ខាងលើ ដើម្បីបញ្ជូន និងប្រគល់ជូន គ.ជ.ប នៅក្រោយពេលដែល គធ.ខប បានដោះស្រាយពាក្យបណ្តឹងចប់សព្វគ្រប់ ។

៨.៣០.១ ប្រធាន គធ.ខប ត្រូវធានាថា រាល់សេចក្តីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើនក្នុងឃុំ សង្កាត់ និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងឃុំ សង្កាត់នោះ ឬទាំងនោះ ដែលលទ្ធផលនៃការបោះឆ្នោត ត្រូវបានសម្រេចព្យួរជាបណ្តោះអាសន្ន ដូចបញ្ជាក់ក្នុងចំណុច ៨.២៨.១៣ ខាងលើ ត្រូវតែបានវេចខ្ចប់ដោយឡែកតាមឃុំ សង្កាត់ និងបញ្ជូនទៅ គ.ជ.ប ដូចចែងក្រោមចំណុច ៨.២៨.១៤ ខាងលើ ។

៨.៣០.២ ចំពោះករណី ឃុំ សង្កាត់ណា ដែលលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងនោះ ត្រូវបាន គធ.ខប សម្រេចយល់ព្រមទទួលយក ប្រធាន គធ.ខប ត្រូវត្រៀមកញ្ចប់ " ឃ ពិសេស " មួយសម្រាប់ដាក់រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោត ដែល

នឹងត្រូវផ្ញើជូន គ.ជ.ប និងត្រូវធានាថា រាល់ស្រោមសំបុត្រដាក់ឯកសារបោះឆ្នោត ទាំងនោះត្រូវតែបានត្រួតពិនិត្យឡើងវិញ និងរៀបចំចងជាបាច់ដោយឡែកពីគ្នា ទៅតាមប្រភេទឯកសារក្នុងស្រោមសំបុត្រ ។ នៅរៀងរាល់ពេលនៃកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នីមួយៗ ប្រធាន គធ.ខប ត្រូវប្រមូល និងរៀបចំដាក់ទៅក្នុងកញ្ចប់ " ឃ ពិសេស " នូវ ៖

ជ.៣០.២.១ ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៤) ផ្ញើជូន គ.ជ.ប ដែលប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប បានប្រគល់ជូន ដូចបញ្ជាក់ក្នុងចំណុច ជ.២៧.១.៣ និង ជ.២៧.៣ ខាងលើ ។

ជ.៣០.២.២ រាល់ស្រោមសំបុត្រដាក់តារាងបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) កំណត់ហេតុបូកសរុបលទ្ធផល នៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) ដូចចែងក្នុងចំណុច ជ.២៩.៦ ជ.២៩.៧ និង ជ.២៩.ជ ខាងលើ ។

ជ.៣០.២.៣ រាល់តារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៦គព) ដូចចែងក្នុងចំណុច ជ.២ជ.១១.១ និង ជ.២ជ.១២.១ ខាងលើ របាយការណ៍របស់ក្រុមត្រួតពិនិត្យលទ្ធផលស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត ឬ/និងរបាយការណ៍របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន) ដូចមានចែងក្នុងចំណុច ជ.២ជ.១១.២ និង ជ.២ជ.១២.២ ខាងលើ ។

ជ.៣០.២.ជ រាល់សម្រង់សេចក្តីសម្រេចរបស់ គធ.ខប ពាក់ព័ន្ធនឹងពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ដែលត្រូវប្រមូលដាក់ក្នុងស្រោមសំបុត្រមួយ និងកាខ្ទងថាផ្ញើជូន គ.ជ.ប ។

ជ.៣០.២.៥ ស្រោមសំបុត្រដាក់លិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ១ (មួយ) ច្បាប់ ។

៨.៣០.៣ ប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យបំពេញលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ដោយមានសរសេរពាយមុខ សម្ភារ ឯកសារដែលបានដាក់ក្នុងកញ្ចប់ " ឃ ពិសេស " ខាងលើ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងកញ្ចប់ " ឃ ពិសេស " ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោចៅ ខាងក្រៅនៃកញ្ចប់ " ឃ ពិសេស " និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការ ប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។

៨.៣០.៤ ប្រធាន គធ.ខប ត្រូវបិទភ្ជិតកញ្ចប់ " ឃ ពិសេស " រួចហើយត្រូវសរសេរសម្គាល់ លេខកូដរាជធានី ខេត្តរបស់ខ្លួននៅលើផ្នែកខាងក្រៅនៃកញ្ចប់ " ឃ ពិសេស " ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ ។

៨.៣០.៥ បន្ទាប់មកប្រធាន គធ.ខប ត្រូវចាត់ចែងឱ្យវេចខ្ចប់រាល់ស្បោង " គ " នៃឃុំ សង្កាត់ គ្មានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ដែលត្រូវបានត្រួតពិនិត្យផ្ទៀងផ្ទាត់ លទ្ធផល ដូចចែងក្រោមប្រការ ៨.២៧ ខាងលើ ហើយដែលត្រូវដាក់ឱ្យអស់ទៅក្នុងស្បោង " ឃ " តាមចំនួនចាំបាច់ ។ ក្នុងការវេចខ្ចប់នេះ គធ.ខប ត្រូវ ៖

- ៨.៣០.៥.១ ដាក់ស្បោង " គ " តាមលំដាប់លេខរៀងនៃលេខកូដឃុំ សង្កាត់ ប្រសិនបើអាច ទៅក្នុងស្បោង " ឃ " នីមួយៗ ។
- ៨.៣០.៥.២ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញ ដោយមានពាយមុខ សម្ភារ ឯកសារ ដែលបានដាក់ក្នុងស្បោង " ឃ " នីមួយៗ ហើយ ត្រូវបានដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង " ឃ " ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោចៅនៃស្បោង " ឃ " និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។
- ៨.៣០.៥.៣ ចងមាត់ស្បោង " ឃ " នីមួយៗ និងចាក់សោឃ្លុំមានលេខ រួចសរសេរ សម្គាល់ពីក្រៅស្បោង " ឃ " នីមួយៗ ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដឃុំ សង្កាត់ពាក់ព័ន្ធដែលបានដាក់ក្នុងស្បោង " ឃ " នោះ និងពាក្យថា " ពិនិត្យរួច " ។

៨.៣០.៦ ប្រសិនបើក្នុងរាជធានី ខេត្តណាមួយ មានឃុំ សង្កាត់មួយចំនួនមាន៣ក្យបណ្តឹងតវ៉ា ឬ៣ក្យបណ្តឹងជំទាស់ ដែលមាន ឬគ្មានការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតនៅការិយាល័យមួយ ឬច្រើន ប្រធាន គធ.ខប ត្រូវធានាថា រាល់ស្បោង " គ មានបណ្តឹង " នៃឃុំ សង្កាត់ពាក់ព័ន្ធ ត្រូវបានវេចខ្ជប់ដាក់ក្នុងស្បោង " ឃ មានបណ្តឹង " ។ ក្នុងការវេចខ្ជប់នេះ ប្រធាន គធ.ខប ត្រូវ ៖

- ៨.៣០.៦.១ ដាក់រាល់ស្បោង " គ មានបណ្តឹង " នៃឃុំ សង្កាត់ពាក់ព័ន្ធដែលមានការបើកកញ្ចប់សុវត្ថិភាព " ក " ទៅក្នុងស្បោង " ឃ " ។
- ៨.៣០.៦.២ ធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ចំនួន ៣ (បី) ច្បាប់ ត្រូវបានបំពេញ ដោយមានរាយមុខសម្ភារ ឯកសារដែលបានដាក់ក្នុងស្បោង " ឃ " ពាក់ព័ន្ធ ហើយត្រូវដាក់ ១ (មួយ) ច្បាប់ ទៅក្នុងស្បោង " ឃ " ដាក់ ១ (មួយ) ច្បាប់ ទៅក្នុងហោប៉ៅនៃស្បោង " ឃ " និងរក្សាទុក ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការប្រគល់ទទួល សម្ភារ ឯកសារបោះឆ្នោតនៅ គ.ជ.ប ។
- ៨.៣០.៦.៣ ចងភ្ជិតស្បោង " ឃ " និងចាក់សោឃ្លុំមានលេខ រួចសរសេរសម្គាល់ពីក្រៅស្បោង " ឃ " ដោយប្រើប៊ិកហ្វឺតលុបមិនជ្រះ នូវលេខកូដឃុំ សង្កាត់ពាក់ព័ន្ធ និងពាក្យថា " មានបណ្តឹង " ។

៨.៣០.៧ ក្នុងករណីមានស្បោង " ឃ " ដូចចែងក្នុងចំណុច ៨.៣០.៥ ឬ/និង ៨.៣០.៦ ខាងលើ មានចំនួនលើសពីមួយ ប្រធាន គធ.ខប ត្រូវសរសេរសម្គាល់បន្ថែមនៅលើផ្នែកខាងក្រៅនៃស្បោង " ឃ " ទាំងនោះ នូវលេខរៀងនៃស្បោង " ឃ " នីមួយៗ។ ឧទាហរណ៍ ប្រសិនបើមានស្បោង " ឃ " ចំនួន ៣ ត្រូវសរសេរសម្គាល់លេខរៀង ១/៣ ២/៣ និង ៣/៣ ។

៨.៣០.៨ ប្រធាន គធ.ខប ត្រូវធានាថារាល់កញ្ចប់សន្លឹកឆ្នោតបម្រុងសម្រាប់រាជធានី ខេត្ត នីមួយៗ (បើមាន) ដែលមិនត្រូវបានប្រើប្រាស់ ត្រូវតែបានវេចខ្ជប់ដោយឡែក និងមិនត្រូវដាក់ក្នុង " ឃ " ហើយត្រូវបញ្ជូន និងប្រគល់ជូន គ.ជ.ប ស្របពេលជាមួយនឹងការបញ្ជូនកញ្ចប់ " ឃ ពិសេស " និងស្បោង " ឃ " ។ នៅក្នុងការវេចខ្ជប់បញ្ជូន និងប្រគល់ទទួលសន្លឹកឆ្នោតបម្រុង ប្រធាន គធ.ខប ត្រូវធានាថា លិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត (ទ.១១០៧) ត្រូវតែបានបំពេញ និងប្រើប្រាស់តាមការកំណត់ក្នុងការបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ។

៨.៣០.៩ ប្រធាន គធ.ខប ត្រូវប្រកាសអញ្ជើញភ្នាក់ងារគណបក្សនយោបាយ ព្រមទាំងអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងអ្នកសារព័ត៌មាន ដែលមានវត្តមានឱ្យចូលរួមជាសាក្សីក្នុងការបញ្ជូន និងការប្រគល់ទទួលកញ្ចប់ " យ ពិសេស " រាល់ស្បោង " យ " ឬស្បោង " យ មានបណ្តឹង " និងកញ្ចប់សន្លឹកឆ្នោតបម្រុងដែលមិនបានប្រើប្រាស់ខាងលើនេះ ហើយត្រូវជូនដំណឹងអំពីពេលវេលាចេញដំណើរនៃការបញ្ជូន ព្រមទាំងគោលដៅ និងពេលវេលានៃការប្រគល់ ទទួលនៅទីស្តីការ គ.ជ.ប ។

៨.៣០.១០ ប្រធាន គធ.ខប ត្រូវធានាថារាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ផ្សេងទៀតដែលបានទទួលពី គយ.សប ចំណុះរាជធានី ខេត្ត ឬ/និងមាននៅលេខាធិការដ្ឋាន គធ.ខប ត្រូវតែបានវេចខ្ចប់ និងបញ្ជូនដោយឡែកទៅ គ.ជ.ប នៅពេលក្រោយ ។ នៅក្នុងការវេចខ្ចប់បញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតនៅសល់ ប្រធាន គធ.ខប ត្រូវធានាថា ទ.១១០៧ ត្រូវតែបានបំពេញ និងប្រើប្រាស់តាមគោលការណ៍នៃការប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោត ។

ការដាក់ពាក្យបណ្តឹងតវ៉ានឹងសេចក្តីសម្រេចរបស់ គធ.ខប នៅ គ.ជ.ប

ប្រការ ៨.៣១.

ភ្នាក់ងារគណបក្សនយោបាយ ឬតំណាង ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចបដិសេធរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ារបស់គាត់ពាក់ព័ន្ធនឹងកំហុសក្នុងប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដូចចែងក្នុងចំណុច ៨.២៨.១១.៥ ខាងលើ មានសិទ្ធិប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលសម្រង់សេចក្តីសម្រេចបដិសេធលើពាក្យបណ្តឹង ។

៨.៣១.១ រាល់ពាក្យបណ្តឹងតវ៉ា ដូចបញ្ជាក់ក្នុងប្រការ ៨.៣១ ខាងលើ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងដាក់ពាក្យប្តឹងនេះនៅទីស្តីការ គ.ជ.ប ហើយ គ.ជ.ប ត្រូវសម្រេចលើពាក្យបណ្តឹងទាំងនេះ ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

៨.៣១.២ ប្រសិនបើ នៅក្នុងរយៈពេលកំណត់ខាងលើ គ.ជ.ប មិនបានទទួលពាក្យបណ្តឹងតវ៉ាណាមួយទេនោះ ត្រូវបានចាត់ទុកថាគ្មានការប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចបដិសេធរបស់ គធ.ខប លើបណ្តឹងពាក់ព័ន្ធនឹងកំហុសធ្ងន់ធ្ងរក្នុងប្រតិបត្តិការបោះឆ្នោត ឬ/និងរាប់សន្លឹកឆ្នោត ឬ/និងអំពើរំលោភ ឬការសន្និដ្ឋានអំពីភាពមិនប្រក្រតីដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ។

៨.៣១.៣ ភ្នាក់ងារគណបក្សនយោបាយ ឬតំណាង ដែលមានបំណងប្តឹងតវ៉ា ដូចបញ្ជាក់ក្នុងប្រការ ៨.៣១ ខាងលើ ត្រូវបំពេញ និងចុះហត្ថលេខាលើពាក្យបណ្តឹង (ទ.១២០២) ដែលក្នុងនោះត្រូវផ្តល់ព័ត៌មានចាំបាច់មួយចំនួន ដូចចែងចាប់ពីចំណុច ៨.២៥.៣.១ ដល់ ៨.២៥.៣.៩ ខាងលើ ។

៨.៣១.៤ ចំពោះពាក្យបណ្តឹងតវ៉ា ដែលត្រូវបានដាក់ក្រោយពេលវេលា ដូចចែងក្នុងប្រការ ៨.៣១ ខាងលើ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវចុះពេលវេលាកាលបរិច្ឆេទ ឱ្យបានច្បាស់លាស់ រួចដាក់ជូន គ.ជ.ប ចារបញ្ជាក់ពីការហួសពេលទទួលពាក្យបណ្តឹង ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្តឹងនោះ ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ និងជម្រាបអ្នកប្តឹង ឬតំណាងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គ.ជ.ប មិនអាចទទួលដោះស្រាយបានទេ ។

៨.៣១.៥ ចំពោះពាក្យបណ្តឹងតវ៉ា ដែលគ្មានបញ្ជាក់ព័ត៌មានច្បាស់លាស់គ្រប់គ្រាន់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង រួចកត់ត្រាក្នុងកំណត់ហេតុ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតនោះទេ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ ព្រមទាំង ចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាង ចំនួន ១ (មួយ) ច្បាប់ និងរក្សាទុកឯកសារចំនួន ២ (ពីរ) ច្បាប់។

៨.៣១.៦ ចំពោះពាក្យបណ្តឹងតវ៉ា ដែលបានដាក់ក្នុងរយៈពេលដូចចែងក្នុងប្រការ ៨.៣១ ខាងលើ និងមានបញ្ជាក់ព័ត៌មានចាំបាច់គ្រប់គ្រាន់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវធ្វើកំណត់ហេតុសួរព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាង ចុះហត្ថលេខា ឬផ្ទិតមេដៃលើកំណត់ហេតុ ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ទិតមេដៃ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹង ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ទិតមេដៃលើកំណត់ហេតុនេះ ។ បន្ទាប់មក ត្រូវចុះកាលបរិច្ឆេទ និងពេលវេលានៃការទទួលពាក្យបណ្តឹង ហើយត្រូវ ៖

៨.៣១.៦.១ ប្រគល់ពាក្យបណ្តឹងនោះ ១ (មួយ) ច្បាប់ជូនអ្នកប្តឹង ឬតំណាង។

៨.៣១.៦.២ ប្រាប់អ្នកប្តឹង ឬតំណាងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្តឹងតវ៉ារបស់គាត់ បន្ទាប់ពីក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប បានបញ្ចប់ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ ។

៨.៣១.៦.៣ បិទផ្សាយពាក្យបណ្តឹងនេះ ១ (មួយ) ច្បាប់ ជាសាធារណៈ ។

៨.៣១.៦.៤ ត្រៀមពាក្យបណ្តឹង ១ (មួយ) ច្បាប់ សម្រាប់ គ.ជ.ប ប្រើក្នុងពេលសវនាការ ។

៨.៣១.៧ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ អំពីករណីនៃពាក្យបណ្តឹង ដោយភ្ជាប់ពាក្យបណ្តឹងតវ៉ាដែលបានទទួល និងសម្រង់សេចក្តីសម្រេចរបស់ គធ.ខប បដិសេធលើពាក្យបណ្តឹងតវ៉ ឬពាក្យបណ្តឹងជំទាស់ ដូចមានចែងក្នុងចំណុច ៨.២៨.១១.៥ ដែលត្រូវដកចេញពីកញ្ចប់ " យ ពិសេស " និងដើម្បីសុំការណែនាំពី គ.ជ.ប អំពីករណីនៃការត្រួតពិនិត្យលទ្ធផល និងភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។ ផ្អែកតាមការណែនាំខាងលើនេះ អគ្គលេខាធិការ ត្រូវចាត់ចែងក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធនឹងពាក្យបណ្តឹងនោះ នៅចំពោះមុខតំណាងគណបក្សនយោបាយពាក់ព័ន្ធ អ្នកប្តឹង ឬតំណាង និងអ្នកសង្កេតការណ៍ ។

ការបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប និងការត្រៀមលក្ខណៈសម្បត្តិបម្រើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ប្រការ ៨.៣២.

ក្នុងគោលបំណងត្រួតពិនិត្យឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប ត្រូវបង្កើតក្រុមទទួលសម្ភារ ឯកសារបោះឆ្នោត ១ (មួយ) ក្រុមត្រួតពិនិត្យលទ្ធផលឡើងវិញមួយចំនួនតាមការចាំបាច់ និងក្រុមកំណត់បែងចែកអាសនៈ ១ (មួយ) ព្រមទាំងត្រូវត្រៀមលក្ខណៈសម្បត្តិជាមុន ដើម្បីបម្រើឱ្យការងារត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្ត ។

៨.៣២.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតមួយត្រូវបានបង្កើតឡើងនៅ គ.ជ.ប ដើម្បីធានាការទទួលកញ្ចប់ " យ ពិសេស " ស្បោង " យ " ឬស្បោង " យ មានបណ្តឹង " កញ្ចប់ដាក់សន្លឹកឆ្នោតបម្រុងដែលមិនបានប្រើប្រាស់ និងកញ្ចប់ដាក់សម្ភារ ឯកសារបោះឆ្នោត៣ក់ព័ន្ធដែល គធ.ខប បានបញ្ជូន និងប្រគល់ជូន គ.ជ.ប ព្រមទាំងធានាការបែងចែក និងរក្សាទុកសម្ភារ ឯកសារទាំងនោះនៅបន្ទប់ស្តុកតាមរាជធានី ខេត្ត នីមួយៗ ។

៨.៣២.១.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតត្រូវដឹកនាំដោយ ប្រធាននាយកដ្ឋានរដ្ឋបាល និងមានមន្ត្រីនាយកដ្ឋានប្រតិបត្តិការ ២ (ពីរ) រូប មន្ត្រីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ១ (មួយ) រូប មន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុ ១ (មួយ) រូប និងមន្ត្រីលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន ១ (មួយ) រូប ជាសមាជិក ។

៨.៣២.១.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ។

៨.៣២.២ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប មួយចំនួនត្រូវបានបង្កើតឡើងតាមការចាំបាច់ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមរាជធានី ខេត្តទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ។ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ រួមមានសមាសភាព ដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋាននានា ចំណុះអគ្គលេខាធិការដ្ឋាន គ.ជ.ប និងត្រូវបានបែងចែកឱ្យទទួលបន្ទុកត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុង រាជធានី ខេត្តមួយ ឬច្រើន ។

៨.៣២.២.១ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ត្រូវមានសមាសភាព ៤ (បួន) រូប ដែលដឹកនាំដោយប្រធាន ១ (មួយ) រូប អនុប្រធាន ១ (មួយ) រូប លេខាធិការ ១ (មួយ) រូប និងជំនួយការ ១ (មួយ) រូប ។

៨.៣២.២.២ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ។

៨.៣២.៣ ក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗរបស់ គ.ជ.ប មានការកិច្ចត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមរាជធានី ខេត្តនីមួយៗដោយឡែកពីគ្នា រួចត្រូវបំពេញតួលេខលទ្ធផលនៃការត្រួតពិនិត្យនេះ នៅលើតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧គព) ។ ក្នុងករណីឃុំ សង្កាត់ណាមួយមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គ.ជ.ប ឬលទ្ធផលបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយ

ឬច្រើនក្នុងឃុំ សង្កាត់ត្រូវបានព្យួរដាបណ្តោះអាសន្នដោយ គធ.ខប ក្រុមត្រួតពិនិត្យ លទ្ធផលត្រូវអនុវត្តបន្ថែម ដោយធ្វើរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតពាក់ព័ន្ធនោះ ឬទាំងនោះ ។ ប្រធានក្រុមត្រូវធានាថា តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោត ក្នុងរាជធានី ខេត្ត ឬ/និងរបាយការណ៍ខាងលើ ត្រូវចុះហត្ថលេខា ដោយសមាជិកទាំងអស់នៃក្រុមពាក់ព័ន្ធ និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។ បន្ទាប់មក គ.ជ.ប ត្រូវប្រគល់សំណុំឯកសារដែលបានសម្រេចរួចនេះ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈដើម្បីមុខការ ។ ការត្រួតពិនិត្យលទ្ធផលនេះ ត្រូវអនុវត្តដោយផ្អែកលើ ៖

- ៨.៣២.៣.១ កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៨) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងរាជធានី ខេត្ត (ទ. ១១១០) ។
- ៨.៣២.៣.២ កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោត ក្នុងឃុំ សង្កាត់ (ទ.១១០៩) ។
- ៨.៣២.៣.៣ តារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប (ទ.១១១៦តព) ព្រមទាំងរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោតរបស់ក្រុមត្រួតពិនិត្យនៃ គធ.ខប ឬ/និងរបាយការណ៍របស់ គយ.សប ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងសន្លឹកឆ្នោត (បើមាន) ។
- ៨.៣២.៣.៤ សេចក្តីសម្រេចរបស់ គធ.ខប លើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ និងរាល់ឯកសារពាក់ព័ន្ធនឹងពាក្យបណ្តឹង (បើមាន) ។
- ៨.៣២.៣.៥ ពាក្យបណ្តឹងដែលបានដាក់នៅ គ.ជ.ប ដូចចែងក្រោមប្រការ ៨.៣១ ខាងលើ (បើមាន) ។
- ៨.៣២.៣.៦ លទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ

នៅ គ.ជ.ប (ប្រសិនបើ គ.ជ.ប សម្រេចឱ្យធ្វើដូច្នេះ) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) តារាងកត់ត្រាសំឡេងឆ្នោត (ទ.១១០៨) និងកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) ដែលមានក្នុងកញ្ចប់សុវត្ថិភាព " ក " ។

៨.៣២.៤ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបានបង្កើតឡើងនៅ គ.ជ.ប ដើម្បីបញ្ចូលទិន្នន័យ ដែលជាលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនីមួយៗ ទៅក្នុងកុំព្យូទ័រ រួចធ្វើការផ្ទៀងផ្ទាត់លទ្ធផលដែលបូកសរុបឃើញ ទៅនឹងតួលេខលទ្ធផលដែលមានក្នុងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ (ទ.១១១១) បន្ទាប់មកបោះពុម្ពសេចក្ដីព្រាងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោត និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច និងផ្សព្វផ្សាយ ។ ក្នុងករណីគ្មានពាក្យបណ្ដឹងតវ៉ា ឬរាល់ពាក្យបណ្ដឹងតវ៉ាត្រូវបានដោះស្រាយចប់ជាស្ថាពរ ក្រុមកំណត់បែងចែកអាសនៈនឹងរៀបចំសេចក្ដីព្រាងលទ្ធផលផ្លូវការនៃការបោះឆ្នោត និងសេចក្ដីព្រាងតារាងលទ្ធផលនៃការបែងចែកអាសនៈ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចជាផ្លូវការ ។

៨.៣២.៤.១ ក្រុមកំណត់បែងចែកអាសនៈត្រូវមានសមាសភាពមួយចំនួន តាមការចាំបាច់ ដែលត្រូវបានតែងតាំងពីក្នុងចំណោមមន្ត្រីនៃនាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ។

៨.៣២.៤.២ ក្រុមនេះត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលជាប្រធាននាយកដ្ឋានប្រតិបត្តិការ អនុប្រធាន ១ (មួយ) រូប ដែលជាប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម អនុប្រធាន ១ (មួយ) រូប ទៀតដែលជាអនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវចាត់តាំងឱ្យមានលេខាធិការ ១ (មួយ) រូប ជាជំនួយការ ។

៨.៣២.៤.៣ ក្រុមនេះត្រូវរាយការណ៍ជាប្រចាំជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ។

៨.៣២.៥ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួននៅបន្ទប់កុំព្យូទ័រនៃនាយកដ្ឋានប្រតិបត្តិការ និងត្រូវមានការទទួលខុសត្រូវ និងភារកិច្ចដូចខាងក្រោម ៖

៨.៣២.៥.១ បញ្ជូលជាបណ្តើរៗ នូវទិន្នន័យដែលជាលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ដែល គធ.ខប បានផ្ញើជូនតាមអ៊ីមែល ឬ/និងទូរសារ បន្ទាប់មកកែតម្រូវ និងផ្ទៀងផ្ទាត់លទ្ធផល ដែលបានបូកសរុបឃើញទៅនឹងក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) តារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប (ទ.១១១៧ត) និងតួលេខលទ្ធផលដែលមានក្នុងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត៣ក់ព័ន្ធ (ទ.១១១១) ។

៨.៣២.៥.២ បោះពុម្ពសេចក្តីព្រាងតារាងលទ្ធផលនៃការបោះឆ្នោតតាមរាជធានី ខេត្ត និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចជាផ្លូវការ និងផ្សព្វផ្សាយជាសាធារណៈ ។

៨.៣២.៥.៣ កែតម្រូវតួលេខលទ្ធផល ដោយយោងតាមសេចក្តីសម្រេចរបស់ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញលើពាក្យបណ្តឹងតវ៉ា (បើមាន) និងរៀបចំបោះពុម្ពសេចក្តីព្រាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចជាផ្លូវការ និងផ្សព្វផ្សាយជាសាធារណៈ ។

៨.៣២.៥.៤ កំណត់បែងចែកអាសនៈតាមរូបមន្ត ដែលកំណត់ដោយច្បាប់ ដោយគណនាតាមការធ្វើប្រមាណវិធីដោយដៃ ដូចចែងក្នុងឧបសម្ព័ន្ធទី ៩ ស្តីពីការបែងចែកអាសនៈ និងដោយប្រើកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ដោយយោងតាមតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៨.៣២.៥.៥ បោះពុម្ពតារាងលទ្ធផលនៃការកំណត់បែងចែកអាសនៈ តាមរាជធានី ខេត្ត ដែលគណបក្សនយោបាយនីមួយៗត្រូវទទួលបាន រួចផ្ទៀងផ្ទាត់ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតតាមចំនួនអាសនៈ និងលំដាប់លេខរៀងពីក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈ បំពេញទៅក្នុងសេចក្តីព្រាងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ។

៨.៣២.៥.៦ រៀបចំតារាងលទ្ធផលនៃការកំណត់បែងចែកអាសនៈ និងសេចក្តីព្រាងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេចជាផ្លូវការ ។

៨.៣២.៦ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវណែនាំ និងចាត់ចែងក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប នៅក្នុងកិច្ចប្រតិបត្តិការពិនិត្យឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងកិច្ចប្រតិបត្តិការបែងចែកអាសនៈតាមរាជធានី ខេត្ត ។ អគ្គលេខាធិការត្រូវពិនិត្យរាល់សំណុំឯកសាររបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈ ដើម្បីដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

៨.៣២.៧ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវត្រៀមបន្ទប់មួយចំនួននៅទីស្តីការ គ.ជ.ប សម្រាប់ធ្វើជាឃ្លាំងស្តុកកញ្ចប់ " ឃ ពិសេស " ស្បោង " ឃ " ឬស្បោង " ឃ មានបណ្តឹង " ដាក់សម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធ ក្នុងនោះត្រូវ ៖

៨.៣២.៧.១ ត្រៀមបន្ទប់មួយដោយឡែកនៅជាន់ផ្ទាល់ដី សម្រាប់រក្សាទុករាល់ស្រោមសំបុត្រធំដាក់សម្រង់សេចក្តីសម្រេចរបស់ គធ.ខប ព្យួរជាបណ្តោះអាសន្នលទ្ធផលនៃការបោះឆ្នោត ស្បោង " ឃ ព្យួរលទ្ធផល " និងរាល់ស្បោង " ឃ មានបណ្តឹង " ដាក់ស្បោង " គ " នៃឃុំ សង្កាត់ ពាក់ព័ន្ធ ។

៨.៣២.៧.២ ត្រៀមបន្ទប់មួយដោយឡែក សម្រាប់ដាក់រាល់កញ្ចប់ " ឃ ពិសេស " នៃ គធ.ខប ទាំងអស់ ។

៨.៣២.៧.៣ ត្រៀមបន្ទប់មួយចំនួន សម្រាប់ស្តុកស្បោង " ឃ " ដែលមានដាក់ស្បោង " គ " ហើយដែលត្រូវដាក់ដោយឡែកពីគ្នាទៅតាមរាជធានី ខេត្តនីមួយៗ ។

៨.៣២.៨ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវត្រៀមបន្ទប់ធំទូលាយមួយចំនួន ឬបន្ទប់តូចៗច្រើនដែលអាចឱ្យក្រុមត្រួតពិនិត្យលទ្ធផលបំពេញការងាររបស់ខ្លួនបានល្អ ។

៨.៣២.៨.១ ក្រុមត្រួតពិនិត្យលទ្ធផលពីរ ឬច្រើនក្រុមអាចបំពេញការងាររបស់ខ្លួនក្នុងបន្ទប់តែមួយ ឬនៅបន្ទប់ដោយឡែកពីគ្នា ដោយផ្អែកតាមលទ្ធភាពជាក់ស្តែង ។

៨.៣២.៨.២ សេចក្ដីជូនដំណឹងស្ដីពី ពេលវេលា កាលបរិច្ឆេទ ទីកន្លែង ឈ្មោះ និងលេខកូដរាជធានី ខេត្ត ដែលត្រូវធ្វើការត្រួតពិនិត្យលទ្ធផលឡើងវិញ ព្រមទាំងលេខក្រុម និងឈ្មោះប្រធានក្រុមត្រួតពិនិត្យលទ្ធផល ដែលទទួលបន្ទុក ត្រូវតែបានបិទផ្សាយជាសាធារណៈ នៅមុខទីស្ដីការ គ.ជ.ប ដើម្បីជាដំណឹងដល់ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ និងអ្នកប្តឹង ឬអ្នកតំណាង ព្រមទាំងអ្នកសារព័ត៌មាន ដែលទទួលបានការអនុញ្ញាត ឱ្យចូលរួមសង្កេតមើលក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនោះ ។

៨.៣២.៩ ក្នុងអំឡុងពេលនៃដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញនៅ គ.ជ.ប លក្ខខណ្ឌសន្តិសុខនៅជុំវិញបរិវេណ និងក្នុងទីស្ដីការ គ.ជ.ប ព្រមទាំងសណ្ដាប់ធ្នាប់ និងរបៀបរៀបរយត្រូវតែបានពង្រឹងតាមវិធានការរដ្ឋបាលដែលគ្រប់គ្រង និងចាត់ចែងដោយអគ្គលេខាធិការ ។

៨.៣២.៩.១ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ អ្នកប្តឹង ឬអ្នកតំណាង ព្រមទាំងអ្នកសារព័ត៌មាន ដែលទទួលបានការអនុញ្ញាត ឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ នៅទីស្ដីការ គ.ជ.ប ត្រូវស្ថិតនៅក្រោមអំណាចគ្រប់គ្រង និងការណែនាំ របស់អគ្គលេខាធិការនៃ គ.ជ.ប ឬមន្ត្រីដែលត្រូវបានប្រគល់សិទ្ធិ ។

៨.៣២.៩.២ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ អ្នកប្តឹង ឬអ្នកតំណាង ព្រមទាំងអ្នកសារព័ត៌មាន ដែលទទួលបានការអនុញ្ញាត ឱ្យចូលរួមសង្កេតមើលការត្រួតពិនិត្យនិងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ នៅទីស្ដីការ គ.ជ.ប ត្រូវគោរពក្រមសីលធម៌ សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ក្រមសីលធម៌ សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ក្រមសីលធម៌សម្រាប់ប្រព័ន្ធផ្សព្វផ្សាយក្នុងដំណើរការបោះឆ្នោត និង ប.ន.ត.រ នេះ ហើយមិនត្រូវធ្វើសកម្មភាព ឬអំពើអ្វីមួយដែលរំខានអុកឡុក ឬរាំងដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ឬបំពានលើសិទ្ធិអំណាច និងឯករាជភាពរបស់ គ.ជ.ប ឡើយ ។

៨.៣២.១០ ហាមជនគ្រប់រូបចូលក្នុងបន្ទប់ ដែលក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់ បែងចែកអាសន:នៃ គ.ជ.ប កំពុងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផល នៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ។ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងបន្ទប់ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល ខាងលើនេះ នូវជនទាំងឡាយដូចខាងក្រោម ៖

៨.៣២.១០.១ មន្ត្រីក្នុងក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសន: ដែលបានទទួលការតែងតាំងពី គ.ជ.ប ។

៨.៣២.១០.២ ភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត ពាក់ព័ន្ធដែលបានអនុញ្ញាត អ្នកប្តឹងពាក់ព័ន្ធ ឬតំណាង ព្រមទាំង អ្នកសង្កេតការណ៍ និងអ្នកសារព័ត៌មាន ដែលមានបណ្ណសម្គាល់ផ្តល់ឱ្យដោយ គ.ជ.ប ។

៨.៣២.១០.៣ ប្រធាន អនុប្រធាន សមាជិកនៃ គ.ជ.ប និងអគ្គលេខាធិការនៃ គ.ជ.ប ឬមន្ត្រីដែលបានប្រគល់សិទ្ធិ ដែលមានបំណងត្រួតពិនិត្យ តាមដាន និងណែនាំក្នុងដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផល របស់ក្រុមនីមួយៗ ។

ការប្រគល់ និងការធន្ទូលកញ្ចប់ " យពិសេស " ជាក់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ស្បោង " យ " និងស្បោង " យ មានបណ្តឹង " និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនៅទីស្តីការ គ.ជ.ប

ប្រការ ៨.៣៣.-

សមាសភាពក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ដែលបានតែងតាំងក្រោមចំណុច ៨.៣២.១ ខាងលើ ត្រូវមានវត្តមានជាប្រចាំនៅទីស្តីការ គ.ជ.ប ចាប់ពីពេលដែល គធ.ខប ចាប់ផ្តើម ធ្វើការត្រួតពិនិត្យលទ្ធផល ដើម្បីរង់ចាំទទួលសម្ភារ ឯកសារបោះឆ្នោតដែល គធ.ខប ត្រូវបញ្ជូន និង ប្រគល់ជូន គ.ជ.ប ។

៨.៣៣.១ ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវត្រៀមលក្ខណសម្បត្តិជាមុន ដើម្បីទទួលសម្ភារ ឯកសារបោះឆ្នោត ដោយផ្អែកតាមករណីដោយឡែកនៃរាជធានី ខេត្ត នីមួយៗ ដែល គធ.ខប ពាក់ព័ន្ធ អាចវេចខ្ចប់ និងបញ្ជូនសម្ភារ ឯកសារបោះឆ្នោត ជូន គ.ជ.ប ជា ៤ (បួន) ផ្នែក ដូចខាងក្រោម ៖

៨.៣៣.១.១ រាល់សម្រង់សេចក្តីសម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោត នៅ ឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់

និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធនឹងឃុំ សង្កាត់ដែលត្រូវបាន គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៨.៣០.១ ខាងលើ ។

៨.៣៣.១.២ រាល់ស្បោង " ឃ " និងកញ្ចប់ " ឃ ពិសេស " ដាក់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត និងសម្ភារ ឯកសារបោះឆ្នោតពាក់ព័ន្ធដែលលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តទាំងនោះត្រូវបាន គធ.ខប សម្រេចយល់ព្រម ដូចមានបញ្ជាក់ក្នុងចំណុច ៨.៣០.២ ៨.៣០.៥ និង ៨.៣០.៦ ខាងលើ ។

៨.៣៣.១.៣ រាល់កញ្ចប់សន្លឹកឆ្នោតបម្រុងសម្រាប់រាជធានី ខេត្តដែលនៅសល់ មិនបានប្រើប្រាស់ ។

៨.៣៣.១.៤ រាល់សម្ភារ ឯកសារបោះឆ្នោត នៅសល់ដែលត្រូវបានវេចខ្ចប់ និងបញ្ជូនដោយឡែកមក គ.ជ.ប នៅពេលក្រោយ ដូចចែងក្នុងចំណុច ៨.៣០.១០ ខាងលើ ។

៨.៣៣.២ ក្នុងករណីមន្ត្រីនៃ គធ.ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៨.៣៣.១.១ ខាងលើ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងស្រោមសំបុត្រធំ និងរាល់ស្បោង " ឃ ព្យួរលទ្ធផល " ដាក់ស្បោង " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ន ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារ (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ ដែល ១ (មួយ) ច្បាប់ នៅក្នុងស្រោមសំបុត្រធំ ១ (មួយ) ច្បាប់ ភ្ជាប់ជាប់នឹងផ្នែកខាងក្រៅនៃស្រោមសំបុត្រធំ និង ១ (មួយ) ច្បាប់ នៅនឹងមន្ត្រី គធ.ខប ដែលបញ្ជូនសម្ភារ ឯកសារមក។

៨.៣៣.២.១ មន្ត្រីក្នុងក្រុមទទួលសម្ភារ ឯកសារ ត្រូវកត់ត្រាមុខសម្ភារ ឯកសារដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ប្រសិនបើគ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា " គ្រប់ចំនួន " ។

៨.៣៣.២.២ ប្រធានក្រុមទទួលសម្ភារ ឯកសារត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារ ដូចបញ្ជាក់ក្នុងចំណុច ៨.៣៣.២ ខាងលើ រួចប្រគល់ ១ (មួយ) ច្បាប់ ជូនមន្ត្រី គធ.ខប ទទួលបន្ទុកការបញ្ជូនវិញ រក្សា ១ (មួយ) ច្បាប់ ភ្ជាប់ទៅនឹងស្រោមសំបុត្រធំ និងដក ១ (មួយ) ច្បាប់ ចងក្រងទុកជាឯកសារ ។

៨.៣៣.២.៣ មន្ត្រីក្នុងក្រុមទទួលសម្ភារ ឯកសារត្រូវនាំយកស្រោមសំបុត្រធំ និងស្បោង " ឃ ព្យួរលទ្ធផល " ដាក់រាល់ស្បោង " គ " នៃឃុំ សង្កាត់ ដែលត្រូវបានព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនោះ ទៅរក្សាទុកនៅក្នុងបន្ទប់ ដែលបានត្រៀមបម្រុងទុក ដូចចែងក្នុងចំណុច ៨.៣២.៧.១ ខាងលើ និងត្រូវសរសេរសម្គាល់លេខកូដឃុំ សង្កាត់ និងរាជធានី ខេត្តពាក់ព័ន្ធផង ។

៨.៣៣.២.៤ ប្រធានក្រុមទទួលសម្ភារ ឯកសារត្រូវរាយការណ៍ជាបន្ទាន់ ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការនូវឈ្មោះ និងលេខកូដឃុំ សង្កាត់ ដែលត្រូវ គធ.ខប សម្រេចព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនោះ ដោយដាក់អមទៅជាមួយនូវស្រោមសំបុត្រធំ ពាក់ព័ន្ធផង ។

៨.៣៣.៣ ក្នុងករណីមន្ត្រីនៃ គធ.ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោត ដូចបញ្ជាក់ក្នុងចំណុច ៨.៣៣.១.២ ខាងលើ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើក និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតដែលមាននៅក្នុងកញ្ចប់ " ឃ ពិសេស " និងរាល់ស្បោង " ឃ " ស្បោង " ឃ មានបណ្តឹង " ដាក់ស្បោង " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធទាំងអស់ដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះ ត្រូវបាន គធ.ខប សម្រេចយល់ព្រម ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយនឹងលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារ (ទ.១១០៧) ទាំង ៣ (បី) ច្បាប់ ដោយឡែកពីគ្នា ដែល ១ (មួយ) ច្បាប់ នៅក្នុងកញ្ចប់ " ឃ ពិសេស " ឬស្បោង " ឃ " ឬស្បោង " ឃ មានបណ្តឹង " ១ (មួយ) ច្បាប់ នៅក្នុងហោប៉ៅនៃកញ្ចប់ " ឃ ពិសេស " ឬស្បោង " ឃ " ឬស្បោង " ឃ មានបណ្តឹង " និង ១ (មួយ) ច្បាប់ទៀត នៅនឹងមន្ត្រី គធ.ខប ដែលបញ្ជូនសម្ភារ ឯកសារមក ។

៨.៣៣.៣.១ មន្ត្រីក្នុងក្រុមទទួលសម្ភារ ឯកសារ ត្រូវកត់ត្រាមុខសម្ភារ ឯកសារ ដែលបានទទួលទាំងអស់ចូលក្នុងបញ្ជីរបស់ខ្លួន ដែលប្រសិនបើគ្រប់គ្រាន់ហើយ ត្រូវចារសម្គាល់ថា " គ្រប់ចំនួន " ។

៨.៣៣.៣.២ ប្រធានក្រុមទទួលសម្ភារ ឯកសារ ត្រូវចុះហត្ថលេខាលើលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារ ដូចបញ្ជាក់ក្នុងចំណុច ៨.៣៣.៣ ខាងលើ រួចប្រគល់ ១ (មួយ) ច្បាប់ ជូនមន្ត្រី គធ.ខប ទទួលបន្ទុកការបញ្ជូនវិញ ដាក់ ១ (មួយ) ច្បាប់ ក្នុងហោប៉ៅកញ្ចប់ " ឃពិសេស " ឬស្បោង " ឃ " ឬស្បោង " ឃ មានបណ្តឹង " វិញ និងដក ១ (មួយ) ច្បាប់ៗ ចងក្រងទុកជាឯកសារ ។

៨.៣៣.៣.៣ មន្ត្រីក្នុងក្រុមទទួលសម្ភារ ឯកសារត្រូវនាំយកកញ្ចប់ " ឃពិសេស " និងស្បោង " ឃ មានបណ្តឹង " នៃរាជធានី ខេត្តពាក់ព័ន្ធ ទៅរក្សាទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុក ដូចចែងក្នុងចំណុច ៨.៣២.៧ ខាងលើ ដោយត្រូវដាក់តាមលំដាប់លេខរៀងនៃលេខកូដរាជធានី ខេត្តនីមួយៗ ។

៨.៣៣.៣.៤ មន្ត្រីក្នុងក្រុមទទួលសម្ភារ ឯកសារត្រូវនាំយករាល់ស្បោង " ឃ " នៃរាជធានី ខេត្តពាក់ព័ន្ធ ទៅរក្សាទុកនៅក្នុងបន្ទប់ដែលបានត្រៀមបម្រុងទុក ដូចចែងក្នុងចំណុច ៨.៣២.៧.៣ ខាងលើ និងត្រូវសរសេរសម្គាល់លេខកូដរាជធានី ខេត្តនីមួយៗផង ។

៨.៣៣.៣.៥ ប្រធានក្រុមទទួលសម្ភារ ឯកសារត្រូវរាយការណ៍ជាបន្ទាន់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការនៃ គ.ជ.ប នូវរាជធានី ខេត្តដែលបានប្រគល់កញ្ចប់ " ឃ ពិសេស " រាល់ស្បោង " ឃ " និងស្បោង " ឃ មានបណ្តឹង " ដាក់ស្បោង " គ " នៃឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ទាំងនោះ ត្រូវបាន គធ.ខប សម្រេចយល់ព្រម ។ ប្រសិនបើក្នុងរាជធានី ខេត្តពាក់ព័ន្ធមានឃុំ សង្កាត់ណាដែលមានបណ្តឹង ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប និងដែលមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើនត្រូវបានបើក ប្រធានក្រុមត្រូវបញ្ជាក់បន្ថែមក្នុងរបាយការណ៍ខាងលើផងដែរ នូវឈ្មោះ និងលេខកូដឃុំ សង្កាត់ដែលមានបណ្តឹងទាំងនោះ និងត្រូវដកយករាល់ស្រោមសំបុត្រ ដាក់សម្រង់សេចក្តីសម្រេចពាក់ព័ន្ធរបស់ គធ.ខប ពីក្នុងកញ្ចប់ " ឃ ពិសេស " ដាក់អមទៅជាមួយផង។

៨.៣៣.៤ ក្នុងករណី គធ.ខប បានបញ្ជូន និងប្រគល់សន្លឹកឆ្នោតបម្រុងសម្រាប់រាជធានី ខេត្ត ដែលនៅសល់មិនបានប្រើប្រាស់ ដូចចែងក្នុងចំណុច ៨.៣០.៨ ខាងលើ ជូន គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវណែនាំមន្ត្រី គធ.ខប ទទួលបន្ទុកការបញ្ជូនឱ្យដឹកជញ្ជូនសន្លឹកឆ្នោតបម្រុង ដែលនៅសល់ទាំងនោះទៅឃ្លាំង គ.ជ.ប។ អនុប្រធាននាយកដ្ឋានប្រតិបត្តិការទទួលបន្ទុកកស្តុការ ត្រូវចាត់ចែងមន្ត្រីក្រោមឱវាទឱ្យត្រួតពិនិត្យ ទទួល និងរក្សាទុកសន្លឹកឆ្នោតបម្រុងនៅសល់ទាំងនោះនៅក្នុងឃ្លាំង គ.ជ.ប ដោយអនុវត្តតាមលក្ខការណ៍នៃការងារជំនាញដែលក្នុងនោះ ត្រូវយកចិត្តទុកដាក់ជាពិសេសអំពីបរិមាណ គុណភាព និងបែបបទប្រគល់ ទទួល និងបញ្ជូលឃ្លាំង ។

- ៨.៣៣.៤.១ ការត្រួតពិនិត្យបរិមាណ និងគុណភាពនៃសន្លឹកឆ្នោតបម្រុងសម្រាប់រាជធានី ខេត្ត ដែលនៅសល់មិនប្រើប្រាស់ ត្រូវអនុវត្តយ៉ាងហ្មត់ចត់ ប៉ុន្តែមិនចាំបាច់តម្រូវឱ្យហែកកញ្ចប់សន្លឹកឆ្នោតទាំងនោះទេ ។
- ៨.៣៣.៤.២ សន្លឹកឆ្នោតបម្រុងដែលនៅសល់មិនប្រើប្រាស់ ត្រូវតែរក្សាទុកឱ្យបានល្អ ដោយត្រូវដាក់តាមរាជធានី ខេត្ត ។

៨.៣៣.៥ ក្នុងករណីមន្ត្រីនៃ គធ.ខប បានបញ្ជូនសម្ភារ ឯកសារបោះឆ្នោតនៅសល់ ដូចបញ្ជាក់ក្នុងចំណុច ៨.៣៣.១.៤ ខាងលើ មកដល់ទីស្តីការ គ.ជ.ប ក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវបើកកញ្ចប់ និងត្រួតពិនិត្យមើលរាល់សម្ភារ ឯកសារបោះឆ្នោតនៅសល់ ដែលបានប្រគល់ជូន គ.ជ.ប ។ ក្នុងការត្រួតពិនិត្យនេះ មន្ត្រីនៃក្រុមទទួលសម្ភារ ឯកសារត្រូវផ្ទៀងផ្ទាត់ជាមួយ នឹងលិខិតបញ្ជូន និងប្រគល់ទទួលសម្ភារ ឯកសារ (ទ.១១០៧) ដែលប្រសិនបើត្រឹមត្រូវគ្រប់ចំនួនហើយ ប្រធានក្រុមត្រូវចុះហត្ថលេខា លើលិខិតបញ្ជូន និងប្រគល់ ទទួលនោះ រួចប្រគល់ជូនមន្ត្រី គធ.ខប ទទួលបន្ទុកការបញ្ជូនវិញ ១ (មួយ) ច្បាប់ ។ ប្រធានក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតនៃ គ.ជ.ប ត្រូវផ្ទេររាល់សម្ភារ ឯកសារនៅសល់ដែលបានទទួលខាងលើ ដោយភ្ជាប់ជាមួយលិខិតបញ្ជូន និងប្រគល់ទទួល ១ (មួយ) ច្បាប់ ទៅឱ្យនាយកដ្ឋានប្រតិបត្តិការទទួលគ្រប់គ្រង និងរក្សាទុកនៅឃ្លាំង គ.ជ.ប ឬបន្ទប់ស្តុកដែលបានកំណត់ ។

ប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈក្នុងការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ប្រការ ៨.៣៤.

ក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប មានការកិច្ចត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញនូវលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តទាំងអស់ ក្នុងគោលបំណងបញ្ជាក់ជាចុងក្រោយអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការបូកសរុបលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រពីគ្រប់រាជធានី ខេត្ត ការកំណត់បែងចែកចំនួនអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តទទួលបាន និងការស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ។ ប្រសិនបើក្នុងការត្រួតពិនិត្យឡើងវិញនេះ ក្រុមត្រួតពិនិត្យលទ្ធផលយល់ព្រមតាមលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តណាមួយ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវបំពេញតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧តព) ហើយក្រុមកំណត់បែងចែកអាសនៈត្រូវរៀបចំ និងបោះពុម្ពតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត រួចត្រូវដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច និងប្រកាសផ្សាយជាលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សម្រាប់បម្រើគោលដៅនៃការប្តឹងតវ៉ារបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មុនពេលប្រកាសផ្សាយជាលទ្ធផលផ្លូវការ ។

៨.៣៤.១ នៅពេលដែល គ.ជ.ប បានទទួលតាមរយៈអគ្គលេខាធិការនៃ គ.ជ.ប នូវរបាយការណ៍ពីក្រុមទទួលសម្ភារ ឯកសារបោះឆ្នោតដូចចែងក្នុងចំណុច ៨.៣៣.២.៤ និង ៨.៣៣.៣.៥ និងពីនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដូចមានចែងក្នុងចំណុច ៨.៣១.៧ ខាងលើ គ.ជ.ប ត្រូវសម្រេចអំពីករណីដែលនឹងត្រូវធ្វើការត្រួតពិនិត្យលទ្ធផលបោះឆ្នោតក្នុងរាជធានី ខេត្ត និងអំពីភាពចាំបាច់ ឬមិនចាំបាច់ឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ។

៨.៣៤.២ ផ្អែកតាមការសម្រេចរបស់ គ.ជ.ប ដូចក្នុងចំណុច ៨.៣៤.១ ខាងលើ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផល ឱ្យអនុវត្តការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលក្រុមនីមួយៗទទួលបន្ទុក ដោយត្រូវបំពេញការងារពាក់ព័ន្ធតាមការចាំបាច់ និងតាមករណី ដូចខាងក្រោម ៖

៨.៣៤.២.១ ករណីនៅរាជធានី ខេត្តណាមួយ មានលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ន និងដែលបានបញ្ជូនមក គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.២៨.១៤ ខាងលើ ដើម្បីត្រួតពិនិត្យឡើងវិញ ។

៨.៣៤.២.២ ករណីរាជធានី ខេត្តណា គ្មានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ។

៨.៣៤.២.៣ ករណីរាជធានី ខេត្តណា មានបណ្តឹងតវ៉ា ឬ/និងបណ្តឹងជំទាស់អំពីលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬ ច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប និងបានបន្តប្តឹងនៅ គ.ជ.ប ដូចចែងក្នុងលក្ខខណ្ឌក្រោមប្រការ ៨.៣១ ខាងលើ ដែលក្នុងនោះមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ត្រូវបានបើក ប៉ុន្តែ គធ.ខប បានសម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតនៅការិយា-ល័យបោះឆ្នោតនោះ ឬទាំងនោះ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

៨.៣៤.៣ ភ្នាក់ងារគណបក្សនយោបាយពាក់ព័ន្ធ អ្នកសង្កេតការណ៍ អ្នកប្តឹង ឬតំណាង និងអ្នកសារព័ត៌មាន ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពី គ.ជ.ប ត្រូវបានអញ្ជើញឱ្យចូលរួមសង្កេតមើលរាល់ដំណើរការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនៅទីស្តីការ គ.ជ.ប ។ ប្រសិនបើបន្ទប់ចង្អៀតការចូលរួមសង្កេតមើលរបស់អ្នកទាំងនោះ ត្រូវស្ថិតក្រោមការគ្រប់គ្រង និងចាត់ចែងរបស់ប្រធានក្រុមត្រួតពិនិត្យលទ្ធផល ឬក្រុមកំណត់បែងចែកអាសន:តាមរបៀបប្តូរវេនគ្នា ។ គ.ជ.ប ត្រូវផ្សព្វផ្សាយជាសាធារណ:អំពីដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតដល់ភាគីពាក់ព័ន្ធ យ៉ាងតិច ៤៨ (សែសិបប្រាំបី) ម៉ោងមុនដំណើរការត្រួតពិនិត្យ នៅលើគេហទំព័ររបស់ គ.ជ.ប ។

៨.៣៤.៤ ប្រតិបត្តិការរបស់ក្រុមត្រួតពិនិត្យលទ្ធផល ក្នុងការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមរាជធានី ខេត្តណាមួយ ប្រសិនបើចាប់ដំណើរការហើយ ត្រូវតែធ្វើឱ្យចប់ចុងចប់ដើម ដោយមិនគិតពីពេលវេលាឡើយ ។

៨.៣៤.៥ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវបើកប្រតិបត្តិការ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតតាមរាជធានី ខេត្ត ដែលក្រុមទទួលបន្ទុកម្តងមួយៗ នៅបន្ទប់ធំទូលាយណាមួយ ឬបន្ទប់តូចៗដោយឡែកពីគ្នា ដែលបានត្រៀមបម្រុង ដូចចែងក្នុងចំណុច ៨.៣២.៨ ខាងលើ ។ ក្នុងការត្រួតពិនិត្យលទ្ធផលនេះ ប្រធានក្រុម

ត្រូវធានាឱ្យមានម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង និងទម្រង់បែបបទសម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផល ព្រមទាំងរាល់សំណុំឯកសារយោង ដូចចែងចាប់ពីចំណុច ៨.៣២.៣.១ ដល់ ៨.៣២.៣.៦ ខាងលើ ។

៨.៣៤.៦ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបើកប្រតិបត្តិការ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រម្តងមួយរាជធានី ខេត្ত បន្ទាប់ពីបានទទួលតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧តព) ដែល គ.ជ.ប បានពិនិត្យសម្រេចរួច ។

ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដែល គធ.ខប បានសម្រេចព្យួរជាបណ្តោះអាសន្ន

ប្រការ ៨.៣៥.

យោងតាមការសម្រេចរបស់ គ.ជ.ប ដូចចែងក្នុងចំណុច ៨.៣៤.១ ខាងលើ ប្រសិនបើ រាជធានី ខេត្តនីមួយៗ ដែលនឹងត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីដែលលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ន ដូចមានចែងក្នុងចំណុច ៨.៣៤.២.១ ខាងលើ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលដែលទទួលបន្ទុកឱ្យត្រួតពិនិត្យ និងផ្ទៀងផ្ទាត់តាមនីតិវិធី ដូចខាងក្រោម ៖

៨.៣៥.១ ក្រុមត្រួតពិនិត្យត្រូវធានាថា ការត្រួតពិនិត្យឡើងវិញ នូវលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ណាមួយចំណុះរាជធានី ខេត្ত ដែលត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ន ត្រូវតែបានអនុវត្តយ៉ាងរួសរាន់ និងដាក់ជូន គ.ជ.ប ដើម្បីពិនិត្យសម្រេចក្នុងរយៈពេល យ៉ាងយូរ ៤ (បួន) ថ្ងៃបន្ទាប់ពីថ្ងៃទទួលសម្រង់សេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។

៨.៣៥.២ ក្នុងករណី គ.ជ.ប សម្រេចមិនឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេ ក្រុមត្រួតពិនិត្យត្រូវធ្វើការត្រួតពិនិត្យលទ្ធផល ដោយគ្រាន់តែផ្អែកលើរាល់សម្ភារឯកសារ ដែលមានក្នុងស្រោមសំបុត្រធំនៃឃុំ សង្កាត់ពាក់ព័ន្ធ ដូចមានចែងក្នុងចំណុច ៨.២៨.១៤.១ ខាងលើ ប៉ុណ្ណោះ ។

៨.៣៥.៣ ក្នុងករណី គ.ជ.ប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញនោះ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវធ្វើការត្រួតពិនិត្យ ដោយផ្អែកលើរាល់សំណុំឯកសារដែលមានក្នុងស្រោមសំបុត្រធំ ដាក់សម្រង់សេចក្តីសម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ដូចមានចែងក្នុងចំណុច ៨.២៨.១៤.១ ខាងលើផង និងត្រូវអនុវត្តបន្ថែមការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញតាមលំនាំនីតិវិធីទាំងឡាយ ដូចមានចែងចាប់ពីចំណុច ៨.២៨.៣.១ ដល់ចំណុច ៨.២៨.៣.៥ និងចំណុច ៨.២៨.៤ ខាងលើ រួមទាំងត្រូវពិនិត្យផ្ទៀងផ្ទាត់សុពលភាព និងកំណត់ជាសន្លឹកឆ្នោតបានការ ឬសន្លឹកឆ្នោតមិនបានការ ដោយត្រូវអនុវត្តតាមលំនាំនីតិវិធីចាប់ពីចំណុច ៨.១០.៧ ដល់ ៨.១០.១៣ នៃ ប.ន.ត.រ ។

៨.៣៥.៤ ក្នុងករណី គ.ជ.ប សម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតលើសពីមួយក្នុងឃុំ សង្កាត់ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវអនុវត្តតាមលំនាំនីតិវិធីដដែល ដូចចែងក្នុងចំណុច ៨.៣៥.៣ ខាងលើ សម្រាប់កញ្ចប់សុវត្ថិភាព " ក " នីមួយៗរហូតដល់អស់កញ្ចប់សុវត្ថិភាព " ក " នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលត្រូវបានសម្រេចឱ្យបើក ។

៨.៣៥.៥ បន្ទាប់ពីបានបញ្ចប់ការត្រួតពិនិត្យលទ្ធផលឡើងវិញ តាមនីតិវិធីដូចចែងក្នុងចំណុច ៨.៣៥.៣ និង ៨.៣៥.៤ ខាងលើ ប្រធានក្រុមត្រូវធានាថា របាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ ១ (មួយ) ច្បាប់ តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតនៅរាជធានី ខេត្តនោះ (ទ.១១១៧តព) ចំនួន ១ (មួយ) ច្បាប់ និងរបាយការណ៍លើកយោបល់យល់ព្រមទទួលយក ឬបដិសេធលទ្ធផលនៃការបោះឆ្នោតចំនួន ១ (មួយ) ច្បាប់ ត្រូវតែបានធ្វើ និងចុះហត្ថលេខាដោយសមាជិកទាំងអស់ នៃក្រុមត្រួតពិនិត្យលទ្ធផល រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។

៨.៣៥.៦ អគ្គលេខាធិការត្រូវចារយោបល់លើតារាងត្រួតពិនិត្យលទ្ធផល និងរបាយការណ៍ដែលបានដាក់ជូនពិនិត្យដូចមានចែងក្នុងចំណុច ៨.៣៥.៥ ខាងលើ រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ដើម្បីពិនិត្យសម្រេច ។ ក្នុងនោះអគ្គលេខាធិការត្រូវ ៖

៨.៣៥.៦.១ លើកយោបល់ស្នើសុំការយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ដែលព្យួរលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ក្នុងករណីរកឃើញមានភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលនាំឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ។

៨.៣៥.៦.២ លើកយោបល់ស្នើសុំបដិសេធសេចក្ដីសម្រេចរបស់ គធ.ខប ដែលព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដោយត្រូវយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រសិនបើរកឃើញថា ពុំមានភាពមិនប្រក្រតី ឬភាពមិនប្រក្រតីតែមិនធ្ងន់ធ្ងរ ដែលមិនធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ។

៨.៣៥.៧ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ដែលបានព្យួរជាបណ្ដោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត (រាប់សន្លឹកឆ្នោតឡើងវិញ ឬ បោះឆ្នោតសាជាថ្មី) ហើយក្នុងករណីរៀបចំការបោះឆ្នោតសាជាថ្មី ប្រធាន គ.ជ.ប ត្រូវ ៖

៨.៣៥.៧.១ ចារយល់ព្រមលើសម្រង់សេចក្ដីសម្រេចរបស់ គធ.ខប ដែលបានបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៨.៣៥.៧.២ ចារយល់ព្រមលើរបាយការណ៍លើកយោបល់របស់អគ្គលេខាធិការ និងចារបដិសេធលើតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧តព) របស់ក្រុមត្រួតពិនិត្យលទ្ធផល ដូចមានចែងក្នុងចំណុច ៨.៣៥.៦ និង ៨.៣៥.៦.១ ខាងលើ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៨.៣៥.៧.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការសម្រេចផង និងត្រូវចុះហត្ថលេខា កាលបរិច្ឆេទ ដោយប្រធាន គ.ជ.ប និងបោះត្រា គ.ជ.ប ។

៨.៣៥.៧.៤ ធានាថា សម្រង់សេចក្តីសម្រេច ដូចក្នុងចំណុច ៨.៣៥.៧.៣ ខាងខាងលើ ត្រូវបានត្រៀមក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយ ឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.៣៥.៧.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះ ជាសេចក្តីសម្រេចចុងក្រោយ ហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ក្នុងរយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃបន្ទាប់ពីថ្ងៃចេញសេចក្តីសម្រេចបដិសេធ ។

៨.៣៥.៧.៦ ប្រគល់របាយការណ៍លើកយោបល់ តារាងត្រួតពិនិត្យលទ្ធផលសម្រង់សេចក្តីសម្រេចរបស់ គធ.ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេចរបស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ មួយមុខ ១ (មួយ) ច្បាប់ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុកដាក់ក្នុងស្រោមសំបុត្រធំ រួចដាក់ទៅក្នុងកញ្ចប់ " ឃ ពិសេស " នៃរាជធានី ខេត្តពាក់ព័ន្ធ ។

៨.៣៥.៧.៧ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផលបានវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធ ដាក់ក្នុងស្បោង " ខ " រួចចងភ្ជិត ដាក់ស្បោង " ខ " ទៅក្នុងស្បោង " គ " និងដាក់ស្បោង " គ " ទៅក្នុងស្បោង " ឃ ព្យួរលទ្ធផល " តាមលំនាំដើម និងចាក់សោឃ្លុំ រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្គាល់ឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ។

៨.៣៥.៨ យោងសម្រង់សេចក្ដីសម្រេចរបស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោត ដូចចែងក្នុងចំណុច ៨.៣៥.៧.៣ ខាងលើ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឱ្យរៀបចំការបោះឆ្នោតសាជាថ្មី នៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដែលលទ្ធផលនៃការបោះឆ្នោតត្រូវបានបដិសេធ ដោយត្រូវអនុវត្តតាមលំនាំនីតិវិធី និងលក្ខខ័ណ្ឌ ដូចចែងក្រោមប្រការ ៨.៩ នៃ ប.ន.ត.រ នេះ ។ ការបោះឆ្នោតសាជាថ្មី ត្រូវអនុវត្តដោយផ្អែកលើបញ្ជីបោះឆ្នោតដដែល បញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តដដែល និងសន្លឹកឆ្នោតដែលមានទម្រង់ និងខ្លឹមសារដដែល ប៉ុន្តែត្រូវបោះពុម្ពថ្មីលើក្រដាសពណ៌ផ្សេង ។

៨.៣៥.៩ ប្រសិនបើ គ.ជ.ប សម្រេចទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយ ឬនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ក្នុងឃុំ សង្កាត់ ដែលត្រូវបាន គធ.ខប សម្រេចព្យួរជាបណ្តោះអាសន្ននូវលទ្ធផលនៃការបោះឆ្នោត ប្រធាន គ.ជ.ប ត្រូវ ៖

- ៨.៣៥.៩.១ ចារបដិសេធលើសម្រង់សេចក្ដីសម្រេចរបស់ គធ.ខប ដែលបានព្យួរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។
- ៨.៣៥.៩.២ ចារយល់ព្រមលើរបាយការណ៍លើកយោបល់របស់អគ្គលេខាធិការ និងចារយល់ព្រមលើតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧តព) របស់ក្រុមត្រួតពិនិត្យ ដូចមានចែងក្នុងចំណុច ៨.៣៥.៦ និង ៨.៣៥.៦.២ ខាងលើ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។
- ៨.៣៥.៩.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្ដីសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ.១២០៣) ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការសម្រេចយល់ព្រមរបស់ គ.ជ.ប និងត្រូវចុះហត្ថលេខា កាលបរិច្ឆេទ ដោយប្រធាន គ.ជ.ប និងបោះត្រា គ.ជ.ប ។

៨.៣៥.៩.៤ ធានាថា សម្រង់សេចក្តីសម្រេចយល់ព្រមខាងលើ ត្រូវបានរៀបចំគ្រប់ចំនួន សម្រាប់ប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជូនគ្រប់តំណាងគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.៣៥.៩.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្តីសម្រេចចុងក្រោយ ។

៨.៣៥.៩.៦ ប្រគល់របាយការណ៍លើកយោបល់ តារាងត្រួតពិនិត្យលទ្ធផល សម្រង់សេចក្តីសម្រេចរបស់ គធ.ខប ដែលមានចំណាររបស់ប្រធាន គ.ជ.ប និងសម្រង់សេចក្តីសម្រេចរបស់ គ.ជ.ប យល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ មួយមុខ ១ (មួយ) ច្បាប់ ព្រមទាំងរាល់ឯកសារក្នុងស្រោមសំបុត្រធំតាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈដើម្បីមុខការ ។

៨.៣៥.៩.៧ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផលបានវេចខ្ចប់កញ្ចប់សុវត្ថិភាព "ក" ពាក់ព័ន្ធដាក់ក្នុងស្បោង "ខ" រួចចងភ្ជិត ដាក់ស្បោង "ខ" ទៅក្នុងស្បោង "គ" និងដាក់ស្បោង "គ" ទៅក្នុងស្បោង "ឃ ព្យួរលទ្ធផល" តាមលំនាំដើម និងចាក់សោឃ្លុំ រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារឯកសារ ដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

៨.៣៥.១០ នៅពេលទទួលបានសំណុំឯកសារ ដូចមានចែងក្នុងចំណុច ៨.៣៥.៩.៦ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងបូកសរុបលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់នោះបញ្ចូលទៅក្នុងតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងរាជធានី ខេត្តពាក់ព័ន្ធ និងបន្តអនុវត្តភារកិច្ចរបស់ខ្លួន ដូចមានចែងក្រោមចំណុច ៨.៣២.៥ ខាងលើ និងប្រការ ៨.៣៨ ខាងក្រោម ។

ការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប

ប្រការ ៨.៣៦.-

យោងតាមការសម្រេចរបស់ គ.ជ.ប ដូចចែងក្នុងចំណុច ៨.៣៤.១ ខាងលើ ប្រសិនបើរាជធានី ខេត្ត ដែលត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីរាជធានី ខេត្ត ដែលគ្មានពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ដូចមានចែងក្នុងចំណុច ៨.៣៤.២.២ ខាងលើ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលដែលទទួលបន្ទុកឱ្យអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

៨.៣៦.១ ផ្អែកតាមការណែនាំរបស់អគ្គលេខាធិការ ក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលក្រុមត្រូវទទួលបន្ទុកដោយឡែកពីគ្នា ម្តងមួយរាជធានី ខេត្ត ដោយផ្អែកលើឯកសារពាក់ព័ន្ធ ដែលមាននៅក្នុងកញ្ចប់ " ឃពិសេស " ប៉ុណ្ណោះ និងមិនត្រូវបើកកញ្ចប់សុវត្ថិភាព " ក " ណាមួយឡើយ ។ ក្នុងដំណើរការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តណាមួយ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ត្រូវ ៖

៨.៣៦.១.១ ចាត់សមាជិកក្រុម ឱ្យទៅនាំយកកញ្ចប់ " ឃពិសេស " នៃរាជធានី ខេត្ត ដែលក្រុមទទួលបន្ទុក ម្តងមួយរាជធានី ខេត្ត ពីកន្លែងរក្សាស្តុកមកដាក់នៅលើតុចំពីមុខប្រធាន ។

៨.៣៦.១.២ បើកកញ្ចប់ " ឃពិសេស " រួចដកយកកាល់ស្រោមសំបុត្រដាក់កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) ក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៤) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) មកដាក់នៅលើតុ ។

៨.៣៦.១.៣ រក្សាទុកនៅក្បែរខ្លួនគាត់នូវកញ្ចប់ " ឃពិសេស " ដែលមានកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៣) តារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ (ទ.១១០៩) តារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១៦គ) របស់ក្រុមត្រួតពិនិត្យលទ្ធផលនៃ គធ.ខប ។

៨.៣៦.១.៤ ចាត់ចែងសមាជិកក្នុងក្រុមឱ្យត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនោះ ដោយផ្អែកលើកំណត់ហេតុ

ក្រដាសលទ្ធផល និងតារាងបូកសរុបលទ្ធផល ដូចចែងក្នុងចំណុច ៨.៣៦.១.២ ខាងលើ ហើយប្រសិនបើមានភាពមិនច្បាស់លាស់ ត្រូវឱ្យពិនិត្យបន្ថែម នូវឯកសារផ្សេងទៀត ដូចចែងក្នុងចំណុច ៨.៣៦.១.៣ ខាងលើ ។

៨.៣៦.១.៥ ធានាថា របាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យខាងលើ ត្រូវបានបំពេញចំនួន ១ (មួយ) ច្បាប់ សម្រាប់រាជធានី ខេត្តនីមួយៗ និងចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យ ដោយត្រូវបញ្ជាក់ច្បាស់នូវខ្លឹមសារដូចខាងក្រោម ប្រសិនបើរកឃើញថា ៖

- តួលេខនៃលទ្ធផលដែលបានត្រួតពិនិត្យ មានភាពត្រឹមត្រូវ
- គធ.ខប មានកំហុសក្នុងការផ្ទៀងផ្ទាត់ និងគណនាលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនោះ ហើយកំហុសនោះត្រូវបានកែតម្រូវ ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គ.ជ.ប ។ ក្នុងការកែតម្រូវកំហុសនេះ ប្រធានក្រុមត្រូវគូសឆ្លងលើលេខដែលខុស ដោយរក្សាឱ្យឃើញតួលេខដែលខុស រួចសរសេរតួលេខថ្មីក្បែរនោះ ដោយមានចុះហត្ថលេខារបស់ប្រធានក្រុមផង ។

៨.៣៦.១.៦ ធានាថា តារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧តព) ចំនួន ១ (មួយ) ច្បាប់ ត្រូវបានបំពេញ ដោយមានបញ្ជាក់ច្បាស់នូវឈ្មោះ និងលេខកូដរាជធានី ខេត្តពាក់ព័ន្ធ និងចុះហត្ថលេខាដោយសមាជិកទាំងអស់នៃក្រុមត្រួតពិនិត្យលទ្ធផល ។

៨.៣៦.១.៧ ធានាថា របាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច ៨.៣៦.១.៥ និង ៨.៣៦.១.៦ ខាងលើ ដែលដាក់អមដោយសំណុំឯកសារលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដូចចែងក្នុងចំណុច ៨.៣៦.១.២ ខាងលើ ត្រូវតែបានដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។

៨.៣៦.១.៨ ធានាថា ទម្រង់បែបបទដូចបានបញ្ជាក់ក្នុងចំណុច ៨.៣៦.១.៣ ខាងលើ ដែលបានប្រើក្នុងការត្រួតពិនិត្យលទ្ធផលនេះ ត្រូវតែបានច្រកក្នុងស្រោមសំបុត្រដូចដើម និងដាក់ទៅក្នុងកញ្ចប់ "ឃ ពិសេស" វិញ ។

៨.៣៦.២ ក្រុមត្រួតពិនិត្យលទ្ធផលត្រូវធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលគ្មានពាក្យបណ្តឹង ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ដោយត្រូវត្រួតពិនិត្យផ្ទៀងផ្ទាត់ម្តងមួយរាជធានី ខេត្ត រហូតដល់អស់ និងត្រូវអនុវត្តតាមនីតិវិធី ដូចចែងចាប់ពីចំណុច ៨.៣៦.១.១ ដល់ ៨.៣៦.១.៨ ខាងលើ ។

៨.៣៦.៣ អគ្គលេខាធិការនៃ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផលរបស់ក្រុមត្រួតពិនិត្យ និងសំណុំឯកសារភ្ជាប់ជាមួយ ដែលបានដាក់ជូន ដូចចែងក្នុងចំណុច ៨.៣៦.១.៧ ខាងលើ ។ ប្រសិនបើ ពិនិត្យឃើញថាត្រឹមត្រូវ ហើយអគ្គលេខាធិការត្រូវចារលើកយោបល់ស្នើសុំការយល់ព្រមពី គ.ជ.ប រួចចុះហត្ថលេខា និងកាលបរិច្ឆេទលើរបាយការណ៍សរសេរដោយដៃ ស្តីពីលទ្ធផលនៃការត្រួតពិនិត្យ និងលើតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៧គព) មុននឹងដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

៨.៣៦.៤ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនោះ ប្រធាន គ.ជ.ប ត្រូវចារយល់ព្រមលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដែលបានដាក់ជូន ដូចមានចែងក្នុងចំណុច ៨.៣៦.៣ ខាងលើ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ បន្ទាប់មកប្រគល់របាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ព្រមទាំងសំណុំឯកសារដែលដាក់ភ្ជាប់ជាមួយ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈ ដើម្បីមុខការ ។

៨.៣៦.៥ នៅពេលទទួលបានសំណុំឯកសារ ដូចមានចែងក្នុងចំណុច ៨.៣៦.៤ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តការកិច្ចរបស់ខ្លួន ដូចមានចែងក្រោមចំណុច ៨.៣២.៥ ខាងលើ និងប្រការ ៨.៣៨ ខាងក្រោម ។

ការត្រួតពិនិត្យ និងការផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែលមានពាក្យបណ្តឹងតវ៉ា ឬ/និងពាក្យបណ្តឹងជំទាស់ ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ហើយដែលក្នុងនោះមានកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើន ត្រូវបានបើក

ប្រការ ៨.៣៧.-

យោងតាមការសម្រេចរបស់ គ.ជ.ប ដូចចែងក្នុងចំណុច ៨.៣៤.១ ខាងលើ ប្រសិនបើរាជធានី ខេត្តដែលត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលឡើងវិញ ស្ថិតក្នុងករណីដូចមានចែងក្នុងចំណុច ៨.៣៤.២.៣ ខាងលើ អគ្គលេខាធិការត្រូវណែនាំក្រុមត្រួតពិនិត្យលទ្ធផលនីមួយៗ ឱ្យធ្វើការត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ចំណុះរាជធានី ខេត្តនោះ តាមនីតិវិធីដូចខាងក្រោម ៖

៨.៣៧.១ ផ្អែកតាមការសម្រេចរបស់ គ.ជ.ប មិនឱ្យបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញទេនោះ ក្រុមត្រួតពិនិត្យលទ្ធផលដែលទទួលបន្ទុក ត្រូវពិនិត្យជាមុននូវសម្រង់សេចក្តីសម្រេចរបស់ គធ.ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ និងត្រូវធានាថាផ្អែកលើឯកសារបោះឆ្នោតពាក់ព័ន្ធដែលមាននៅក្នុងកញ្ចប់ " ឃ ពិសេស " ដូចបញ្ជាក់ក្នុងចំណុច ៨.៣០.២ ខាងលើ នីតិវិធីចាប់ពីចំណុច ៨.៣៦.១.១ ដល់ ៨.៣៦.១.៨ ខាងលើ ត្រូវតែបានអនុវត្ត ។

៨.៣៧.២ បន្ទាប់ពីបានអនុវត្តតាមចំណុច ៨.៣៧.១ ខាងលើរួច អគ្គលេខាធិការនៃ គ.ជ.ប ត្រូវពិនិត្យរបាយការណ៍ តារាងត្រួតពិនិត្យលទ្ធផល និងសំណុំឯកសារភ្ជាប់ជាមួយដែលក្រុមត្រួតពិនិត្យបានដាក់ជូន ដូចមានចែងក្នុងចំណុច ៨.៣៦.១.៧ ខាងលើ។ ប្រសិនបើពិនិត្យឃើញថាត្រឹមត្រូវហើយ អគ្គលេខាធិការត្រូវចារលើកយោបល់ស្នើសុំការយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនោះពី គ.ជ.ប រួចចុះហត្ថលេខា និងកាលបរិច្ឆេទលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧គព) ហើយដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។

៨.៣៧.៣ ផ្អែកលើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ព្រមទាំងសំណុំឯកសារភ្ជាប់ជាមួយ ក្នុងករណីមានបណ្តឹងដាក់នៅ គយ.សប ឬ/និង គធ.ខប ក្តីប៉ុន្តែគ្មានបណ្តឹងបន្តដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវពិនិត្យសម្រេចយល់ព្រមតាមយោបល់របស់អគ្គលេខាធិការ ដូចចែងក្នុងចំណុច ៨.៣៧.២ ខាងលើ ។ ក្នុងករណីមានបណ្តឹងដាក់នៅ គ.ជ.ប នោះ គ.ជ.ប ត្រូវសម្រេចលើបណ្តឹងពាក់ព័ន្ធ ។ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ចំណុះរាជធានី ខេត្ត ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវ ៖

- ៨.៣៧.៣.១ ចារយល់ព្រមលើសម្រង់សេចក្តីសម្រេចរបស់ គធ.ខប (ទ.១២០៣) ដែលបានយល់ព្រមទទួលយកលទ្ធផល នៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។
- ៨.៣៧.៣.២ ចារយល់ព្រមលើរបាយការណ៍ត្រួតពិនិត្យលទ្ធផល និងតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧គព) រួចចុះហត្ថលេខា និងកាលបរិច្ឆេទ។

៨.៣៧.៣.៣ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេចយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ (ទ.១២០៣) ហើយដែលត្រូវចុះហត្ថលេខាដោយប្រធាន គ.ជ.ប រួចបោះត្រា និងចុះកាលបរិច្ឆេទ ។

៨.៣៧.៣.៤ ធានាថា សម្រង់សេចក្តីសម្រេចយល់ព្រមខាងលើ ត្រូវបានរៀបចំគ្រប់ចំនួន សម្រាប់ប្រគល់ជូនដើមបណ្តឹង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងដាក់នៅ គ.ជ.ប) ជូនភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.៣៧.៣.៥ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្តីសម្រេចចុងក្រោយ ។

៨.៣៧.៣.៦ ប្រគល់សំណុំឯកសារដូចមានចែងក្នុងចំណុច ៨.៣៧.៣ ខាងលើ ដែលមានរបាយការណ៍ត្រួតពិនិត្យលទ្ធផល និងតារាងត្រួតពិនិត្យលទ្ធផល (ទ. ១១១៧ត៣) ដែលមានចំណារយល់ព្រមរបស់ប្រធាន គ.ជ.ប ដូចចែងក្នុងចំណុច ៨.៣៧.៣.២ ខាងលើ មួយមុខ ១ (មួយ) ច្បាប់ ព្រមទាំងឯកសារភ្ជាប់ជាមួយតាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីបន្តអនុវត្តការកិច្ចរបស់ខ្លួន ដូចមានចែងក្រោមចំណុច ៨.៣២.៥ ខាងលើ និងប្រការ ៨.៣៨ ខាងក្រោម ។

៨.៣៧.៤ ប្រសិនបើ ផ្អែកតាមសំណុំឯកសារដែលបានដាក់ជូន ដូចចែងក្នុងចំណុច ៨.៣១.៧ និង ៨.៣៣.៣.៥ ខាងលើ គ.ជ.ប យល់ឃើញថា អាចមានភាពមិនប្រក្រតីធ្ងន់ធ្ងរដែលនាំឱ្យមានការផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ណាមួយចំណុះរាជធានី ខេត្តនោះ គ.ជ.ប ត្រូវសម្រេចឱ្យបើកកញ្ចប់សុវត្ថិភាព " ក " មួយ ឬច្រើនតាមការចាំបាច់ ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹក

ឆ្នោតឡើងវិញ ។ ក្នុងករណីនេះ ប្រធានក្រុមត្រួតពិនិត្យលទ្ធផលដែលទទួលបន្ទុក ត្រូវពិនិត្យជាមុននូវពាក្យបណ្តឹងពាក់ព័ន្ធ ដែលបានដាក់នៅ គ.ជ.ប និងសម្រង់សេចក្តីសម្រេចរបស់ គធ.ខប ពាក់ព័ន្ធនឹងលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់នោះ ហើយផ្អែកលើឯកសារដែលមាននៅក្នុងកញ្ចប់ " ឃពិសេស " និងស្បោង " ឃ " ឬស្បោង " ឃ មានបណ្តឹង " ដូចបានបញ្ជាក់ក្នុងចំណុច ៨.៣០.២ ៨.៣០.៥ និង ៨.៣០.៦ ខាងលើ ត្រូវគូបផ្ទាំអនុវត្តឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយនៃនីតិវិធីចាប់ពីចំណុច ៨.៣៥.៣ ដល់ ៨.៣៥.៥ និងពីចំណុច ៨.៣៦.១.១ ដល់ ៨.៣៦.១.៨ ខាងលើ ។

៨.៣៧.៥ បន្ទាប់ពីបានបញ្ចប់ការអនុវត្តនីតិវិធី ដូចក្នុងចំណុច ៨.៣៧.៤ ខាងលើ អគ្គលេខាធិការ ត្រូវត្រួតពិនិត្យរបាយការណ៍ស្តីពីការបើកកញ្ចប់សុវត្ថិភាព " ក " ដើម្បីត្រួតពិនិត្យផ្ទៀងផ្ទាត់សម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោតឡើងវិញ និងចារលើកយោបល់លើរបាយការណ៍ និងតារាងត្រួតពិនិត្យលទ្ធផល ដូចចែងក្នុងចំណុច ៨.៣៥.៥ ខាងលើ ដែលក្រុមត្រួតពិនិត្យលទ្ធផលបានដាក់ជូន រួចចុះហត្ថលេខា និងដាក់ជូន គ.ជ.ប ពិនិត្យសម្រេច ។ ករណីនេះអគ្គលេខាធិការត្រូវ ៖

៨.៣៧.៥.១ លើកយោបល់ស្នើសុំបដិសេធសេចក្តីសម្រេចរបស់ គធ.ខប ដែលបានទទួលយកលទ្ធផលនៃការបោះឆ្នោត ដោយយល់ព្រមតាមពាក្យបណ្តឹងដែលដាក់នៅ គ.ជ.ប សុំបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ករណីពិនិត្យឃើញមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ឬ

៨.៣៧.៥.២ លើកយោបល់ស្នើសុំការយល់ព្រមតាមសេចក្តីសម្រេចរបស់ គធ.ខប ដែលបានទទួលយកលទ្ធផលនៃការបោះឆ្នោត ដោយត្រូវបដិសេធពាក្យបណ្តឹងដែលដាក់នៅ គ.ជ.ប សុំបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ ករណីពិនិត្យឃើញពុំមានភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ ដែលនាំឱ្យផ្លាស់ប្តូរលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ពាក់ព័ន្ធ ។

៨.៣៧.៦ ផ្អែកលើសំណុំឯកសារដូចចែងក្រោមចំណុច ៨.៣៧.៥ ខាងលើ ក្នុងករណីគ្មានពាក្យបណ្តឹងដាក់នៅ គ.ជ.ប ទេ ទោះបីមានបណ្តឹងដាក់នៅ គយ.សប ឬ/និង គធ.ខប ក្តី គ.ជ.ប ត្រូវពិនិត្យសម្រេចដោយផ្អែកលើសំណើរបស់អគ្គលេខាធិការ ដូចមានចែងក្នុងចំណុច ៨.៣៧.៥.១ និង ៨.៣៧.៥.២ ខាងលើ ។ ប្រសិនបើ មានការដាក់ពាក្យបណ្តឹងបន្តនៅ គ.ជ.ប នោះ ក្នុងករណីដែល គ.ជ.ប សម្រេចបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ គ.ជ.ប ត្រូវចេញសេចក្តីសម្រេចបដិសេធលើសេចក្តីសម្រេចរបស់ គធ.ខប ដែលទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ និងត្រូវយល់ព្រមតាមពាក្យបណ្តឹងដាក់នៅ គ.ជ.ប សុំបដិសេធលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ។ ករណីនេះ ប្រធាន គ.ជ.ប ត្រូវ ៖

- ៨.៣៧.៦.១ ចារបដិសេធលើសម្រង់សេចក្តីសម្រេចរបស់ គធ.ខប ដែលបានយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។
- ៨.៣៧.៦.២ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ដោយបញ្ជាក់ច្បាស់ពីមូលហេតុនៃការសម្រេចនេះផង និងត្រូវចុះហត្ថលេខាដោយប្រធាន គ.ជ.ប រួចបោះត្រា និងចុះកាលបរិច្ឆេទ ។
- ៨.៣៧.៦.៣ ធានាថា សម្រង់សេចក្តីសម្រេច ដូចចែងក្នុងចំណុច ៨.៣៧.៦.២ ខាងលើ ត្រូវបានរៀបចំក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនដើមបណ្តឹង ១ (មួយ) ច្បាប់ (សម្រាប់បណ្តឹងដាក់នៅ គ.ជ.ប) ជូនគ្រប់ភ្នាក់ងារគណបក្សឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- ៨.៣៧.៦.៤ ប្រកាសថា សេចក្តីសម្រេចរបស់ គ.ជ.ប ដែលបានបដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោត

ណាមួយក្នុងឃុំ សង្កាត់នោះ ជាសេចក្ដីសម្រេចចុងក្រោយហើយ គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតមួយ ឬច្រើន ឬនៅការិយាល័យបោះឆ្នោតទាំងអស់នៃឃុំ សង្កាត់នោះ ក្នុងរយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃ គិតចាប់ពីថ្ងៃចេញសម្រង់សេចក្ដីសម្រេចនេះ ។

៨.៣៧.៦.៥ ប្រគល់របាយការណ៍លើកស្នើយោបល់ តារាងត្រួតពិនិត្យលទ្ធផល និងសម្រង់សេចក្ដីសម្រេចរបស់ គធ.ខប ដែលមានចំណារប្រធាន គ.ជ.ប និងសម្រង់សេចក្ដីសម្រេចរបស់ គ.ជ.ប បដិសេធលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់នោះ មួយមុខ ១ (មួយ) ច្បាប់ តាមរយៈអគ្គលេខាធិការ ទៅឱ្យក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុក ដែលត្រូវដាក់ទៅក្នុងកញ្ចប់ " ឃ ពិសេស " នៃរាជធានី ខេត្ត ពាក់ព័ន្ធ ។

៨.៣៧.៦.៦ ធានាថា ក្រុមត្រួតពិនិត្យលទ្ធផលបានវេចខ្ចប់កញ្ចប់សុវត្ថិភាព " ក " ពាក់ព័ន្ធដាក់ក្នុងស្បោង " ខ " រួចចងភ្ជិត ដាក់ស្បោង " គ " នៃឃុំ សង្កាត់នោះទៅក្នុងស្បោង " ឃ " ពាក់ព័ន្ធ តាមលំនាំដើម រួចនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារ ឯកសារដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

៨.៣៧.៧ យោងសេចក្ដីសម្រេចរបស់ គ.ជ.ប យល់ព្រមតាមពាក្យបណ្ដឹងបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយ ឬ/និងលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ដូចចែងក្នុងចំណុច ៨.៣៧.៦.៤ ខាងលើ គ.ជ.ប ត្រូវចាត់ចែង និងណែនាំគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះ ឬទាំងនោះ ឬនៅការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់នោះ ដោយត្រូវអនុវត្តតាមលំនាំនីតិវិធី និងលក្ខខ័ណ្ឌ ដូចចែងក្រោមប្រការ ៨.៩ នៃ ប.ន.ត.រ នេះ ។

៨.៣៧.៨ ផ្អែកលើសំណុំឯកសារត្រួតពិនិត្យលទ្ធផលដូចចែងក្រោមចំណុច ៨.៣៧.៥ ខាងលើ ប្រសិនបើ គ.ជ.ប សម្រេចយល់ព្រមតាមសេចក្ដីសម្រេចរបស់ គធ.ខប ដែលបានទទួលយកលទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ឬនៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ពាក់ព័ន្ធ ប្រធាន គ.ជ.ប ត្រូវធានាថា បញ្ញត្ដិ និងនីតិវិធីដូចចែងក្រោមចំណុច ៨.៣៧.៣ ខាងលើត្រូវតែបានអនុវត្ត ។

៨.៣៧.៩ ក្នុងការអនុវត្តចំណុច ៨.៣៧.៨ ខាងលើ និងនៅពេលទទួលបានសំណុំឯកសារត្រួតពិនិត្យលទ្ធផលដែលមានចំណារប្រធាន គ.ជ.ប ដូចចែងក្នុងចំណុច ៨.៣៧.៣.៦ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តការទទួលខុសត្រូវ និងភារកិច្ចរបស់ខ្លួនដូចមានចែងក្រោមចំណុច ៨.៣២.៥ ខាងលើ និងប្រការ ៨.៣៨ ខាងក្រោម ។

៨.៣៧.១០ នៅពេលដែលក្រុមត្រួតពិនិត្យលទ្ធផល និងក្រុមកំណត់បែងចែកអាសនៈបានបញ្ចប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការបោះឆ្នោតនៅឃុំ សង្កាត់ ដែលមានបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានដាក់នៅ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ហើយដែលត្រូវបាន គ.ជ.ប សម្រេចបដិសេធ ឬយល់ព្រមទទួលយកលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទាំងនោះរួចហើយ អគ្គលេខាធិការត្រូវធានាថាក្រុមត្រួតពិនិត្យលទ្ធផលទទួលបន្ទុកតាមរាជធានី ខេត្តនីមួយៗ និងក្រុមកំណត់បែងចែកអាសនៈបានរៀបចំទុកដាក់រាល់របាយការណ៍ ទម្រង់បែបបទ និងឯកសារពាក់ព័ន្ធដែលបានប្រើក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ខាងលើ ដោយត្រូវច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ " ឃពិសេស " ឬ/និងក្នុងកញ្ចប់សុវត្ថិភាព " ក " ស្បោង " ខ " ស្បោង " គ " និងស្បោង " ឃ " ពាក់ព័ន្ធតាមលំនាំដូចដើម និងនាំយកទៅប្រគល់ឱ្យក្រុមទទួលសម្ភារ ឯកសារដើម្បីរក្សាទុកនៅកន្លែងដើមវិញ ។

ការបញ្ជូល និងការផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលក្នុងកុំព្យូទ័រ និងការកំណត់បែងចែកអាសនៈ សម្រាប់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមមណ្ឌលរាជធានី ខេត្ត

ប្រការ ៨.៣៨.

នៅពេលបានទទួលសំណុំឯកសារត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ដែល គ.ជ.ប បានចារយល់ព្រមទទួលយករួចហើយដូចចែងក្នុងចំណុច ៨.៣៥.៩.៦ ៨.៣៦.៤ ៨.៣៧.៣.៦ និង ៨.៣៧.៩ ខាងលើ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងអនុវត្តភារកិច្ចរបស់ខ្លួនដែលបានកំណត់ដូចចែងក្រោមចំណុច ៨.៣២.៥ ខាងលើ ដើម្បីរៀបចំសេចក្តីព្រាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ សេចក្តីព្រាងតារាងលទ្ធផលនៃការបែងចែកអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្ត ត្រូវបានទទួល និងសេចក្តីព្រាងសេចក្តីប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ដែលត្រូវដាក់ជូន គ.ជ.ប ដើម្បីពិនិត្យសម្រេច ។

៨.៣៨.១ ក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវបំពេញការងាររបស់ខ្លួននៅបន្ទប់កុំព្យូទ័រ នៃនាយកដ្ឋានប្រតិបត្តិការ ដែលមានកុំព្យូទ័រ និងបណ្តាញបរិក្ខារអេឡិចត្រូនិកគ្រប់គ្រាន់ ហើយដែលត្រូវបានបំពាក់កម្មវិធីប្រតិបត្តិការបញ្ចូល និងបូកសរុបលទ្ធផលនៃការបោះឆ្នោតតាមរាជធានី ខេត្ត កម្មវិធីប្រតិបត្តិការបែងចែកអាសនៈ ដោយផ្អែកតាមរូបមន្ត និងនីតិវិធីដូចចែងក្នុងឧបសម្ព័ន្ធទី ៩ នៃ ប.ន.ត.រ នេះ ស្តីពីប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ និងមានរក្សាទុកទិន្នន័យបញ្ជីបេក្ខជននៃគណបក្សនយោបាយ ឈរឈ្មោះបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្តទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

៨.៣៨.២ ប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ដែលជាអនុប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវធានាឱ្យមានបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្តទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា (បញ្ជីផ្លូវការ) ១ (មួយ) ច្បាប់ សម្រាប់ប្រើក្នុងការផ្ទៀងផ្ទាត់ និងស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវជាប់ឆ្នោតជាអ្នកតំណាងរាស្ត្រ ។

៨.៣៨.៣ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវចាត់ចែងសមាជិករបស់ខ្លួន ឱ្យបញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តទាំងអស់ ទៅក្នុងកុំព្យូទ័រ ដោយផ្អែកតាមតារាងត្រួតពិនិត្យលទ្ធផល (ទ.១១១៧តព) នៃរាជធានី ខេត្តនីមួយៗ ដែលត្រូវបាន គ.ជ.ប ចារយល់ព្រម កំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១១) និងតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត (ទ.១១១០) ដែល គធ.ខប បានផ្ញើជូនជាឯកសារផ្លូវការ និងតាមអ៊ីមែល ។

៨.៣៨.៤ បន្ទាប់ពីបានបញ្ចូល និងផ្ទៀងផ្ទាត់ទិន្នន័យលទ្ធផលនៃការបោះឆ្នោតពីគ្រប់រាជធានី ខេត្ត រួចរាល់ហើយ ប្រធានក្រុមត្រូវធានាថា សេចក្តីព្រាងតារាងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានផ្ទៀងផ្ទាត់ឡើងវិញ ដោយប្រៀបធៀបទៅនឹងតួលេខលទ្ធផល ដែលមានក្នុងតារាងត្រួតពិនិត្យលទ្ធផល និងកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តទាំង ២៥ ដើម្បីឱ្យដឹងប្រាកដថា មានលក្ខណៈត្រឹមត្រូវហើយ ។

៨.៣៨.៤.១ ប្រធានក្រុមត្រូវធានាថា សេចក្តីព្រាងតារាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានបោះពុម្ព រួចចារ បញ្ជាក់ថា ត្រឹមត្រូវ និងចុះហត្ថលេខាដោយលេខាធិការ អនុប្រធាន និងប្រធានក្រុម ដើម្បីដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ពិនិត្យសម្រេច ។

៨.៣៨.៤.២ ប្រធានក្រុម ត្រូវបោះពុម្ពសេចក្តីព្រាងតារាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលត្រូវចុះហត្ថលេខា ដោយប្រធាន គ.ជ.ប ចំនួន ៥ (ប្រាំ) ច្បាប់ ដើម្បីដាក់អមជាមួយ សេចក្តីព្រាងតារាងលទ្ធផលបណ្តោះអាសន្ន ដូចមានចែងក្នុងចំណុច ៨.៣៨.៤.១ ខាងលើ ។

៨.៣៨.៥ នៅពេលក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប បានបញ្ចប់ការងាររបស់ខ្លួន ប្រធានក្រុមត្រូវធានាថា រាល់របាយការណ៍ កំណត់ហេតុ តារាងលទ្ធផល និងឯកសារពាក់ព័ន្ធ ដែលបានប្រើក្នុងការបញ្ចូលទិន្នន័យលទ្ធផលនៃការបោះឆ្នោត និងក្នុងការគណនាបែងចែកអាសនៈ ដូចចែងក្រោមប្រការនេះ ត្រូវតែបានច្រកទៅក្នុងស្រោមសំបុត្រ និងដាក់ទៅក្នុងកញ្ចប់ " យពិសេស " តាមលំនាំដូចដើម រួចយកទៅរក្សាទុកក្នុងបន្ទប់ស្តុកវិញ ។

៨.៣៨.៦ ផ្អែកលើសេចក្តីព្រាងតារាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូចមានចែងក្រោមចំណុច ៨.៣៨.៤ ខាងលើ ប្រសិនបើ គ.ជ.ប ពិនិត្យឃើញថា លទ្ធផលទាំងនោះមានលក្ខណៈត្រឹមត្រូវហើយ គ.ជ.ប ត្រូវចារឯកភាពលើសេចក្តីព្រាងតារាងលទ្ធផល ដូចមានចែងក្នុងចំណុច ៨.៣៨.៤.១ ខាងលើ និងត្រូវផ្តល់សុពលភាពលើតារាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទាំង ៥ (ប្រាំ) ច្បាប់ ដូចមានចែងក្នុងចំណុច ៨.៣៨.៤.២ ខាងលើ។

៨.៣៨.៧ គ.ជ.ប ត្រូវចាត់ចែងបិទផ្សាយនៅទីស្តីការ គ.ជ.ប និងផ្សព្វផ្សាយជាសាធារណៈ តាមគ្រប់រូបភាព នូវតារាងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូចមានចែងក្នុងចំណុច ៨.៣៨.៦ ខាងលើ និងត្រូវផ្ញើ ១ (មួយ) ច្បាប់ ថ្វាយព្រះមហាក្សត្រ និងផ្ញើ ១ (មួយ) ច្បាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ។ គណបក្សនយោបាយដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិស្នើសុំសេចក្តីចម្លងលទ្ធផលបណ្តោះអាសន្ននេះបាន ។

៨.៣៨.៨ បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្នក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ។

ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង ទាក់ទងនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ប្រការ ៨.៣៩.

អនុលោមតាមមាត្រា ១៣១ នៃ ច.ប.ត.រ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ឬតំណាង អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទៅ គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏បាន ដោយត្រូវបញ្ជាក់អំពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទ ដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ។

៨.៣៩.១ គណបក្សនយោបាយ ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត ពាក់ព័ន្ធ ឬតំណាង ដែលមានបំណងប្តឹង ដូចចែងក្នុងប្រការ ៨.៣៩ ខាងលើ ត្រូវបំពេញ ទ.១២០២ ចំនួន ៣ (បី) ច្បាប់ និងចុះហត្ថលេខាលើពាក្យបណ្តឹង ដែលក្នុងនោះត្រូវផ្តល់ព័ត៌មានច្បាស់លាស់មួយចំនួន ដូចខាងក្រោម ៖

៨.៣៩.១.១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ។

៨.៣៩.១.២ លក្ខណៈសម្គាល់នៃគណៈកម្មការរៀបចំការបោះឆ្នោតពាក់ព័ន្ធ ។

៨.៣៩.១.៣ ឈ្មោះ និងអាសយដ្ឋានរបស់សមាជិកនៃគណៈកម្មការ ដែលប្រព្រឹត្តខុស ។

៨.៣៩.១.៤ កាលបរិច្ឆេទ ឬទីកន្លែង ដែលបានប្រព្រឹត្តខុស ។

៨.៣៩.១.៥ ប្រភេទនៃភាពមិនប្រក្រតី ដែលជាកម្មវត្ថុនៃបណ្តឹង ។

៨.៣៩.១.៦ ពាក្យបណ្តឹង ដែលធ្លាប់បានដាក់ប្តឹងនៅ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ។

៨.៣៩.១.៧ ប្រសិនបើអាចធ្វើបាន ត្រូវបញ្ជាក់អំពីមាត្រានៃ ច.ប.ត.រ ឬ ប.ន.ត.រ ដែលត្រូវបានរំលោភ ។

៨.៣៩.១.៨ មនុស្សផ្សេងទៀតដែលពាក់ព័ន្ធក្នុងភាពមិនប្រក្រតីនេះ ។

៨.៣៩.១.៩ ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន ។

៨.៣៩.១.១០ ឯកសារភស្តុតាងបញ្ជាក់អំពីភាពមិនប្រក្រតីផ្សេងទៀត បើមាន ។

៨.៣៩.២ ចំពោះពាក្យបណ្តឹងតវ៉ា ដែលបានដាក់ក្រោយពេលវេលាកំណត់ ដូចមានចែងក្នុងប្រការ ៨.៣៩ ខាងលើ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវចុះពេលវេលា និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ រួចដាក់ជូន គ.ជ.ប ចារបញ្ជាក់ពីការហួសពេលកំណត់នៃការទទួលពាក្យបណ្តឹង ព្រមទាំងចុះហត្ថលេខា និងបោះត្រា គ.ជ.ប លើពាក្យបណ្តឹងនោះ ហើយប្រគល់ជូនអ្នកប្តឹង ឬអ្នកតំណាង ១ (មួយ) ច្បាប់ រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងប្រាប់អ្នកប្តឹង ឬតំណាងថា ពាក្យបណ្តឹងរបស់គាត់ដែលបានដាក់នៅក្រោយពេលកំណត់ គ.ជ.ប មិនអាចទទួលដោះស្រាយទេ ។ អ្នកប្តឹង ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីបានទទួលលិខិតជូនដំណឹងបដិសេធ ។

៨.៣៩.៣ ចំពោះពាក្យបណ្តឹងតវ៉ា ដែលគ្មានបញ្ជាក់ព័ត៌មានច្បាស់លាស់គ្រប់គ្រាន់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង រួចកត់ត្រាក្នុងកំណត់ហេតុ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាតនោះទេ គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ រួចចុះហត្ថលេខា កាលបរិច្ឆេទ និងបោះត្រា គ.ជ.ប ហើយប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។ អ្នកប្តឹង ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីបានទទួលលិខិតជូនដំណឹងបដិសេធ ។

៨.៣៩.៤ ចំពោះពាក្យបណ្តឹងតវ៉ា ដែលបានដាក់ប្តឹងស្របតាមរយៈពេលកំណត់ និងមានបញ្ជាក់ព័ត៌មានច្បាស់លាស់គ្រប់គ្រាន់ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹងនៅ គ.ជ.ប ត្រូវធ្វើកំណត់ហេតុសាកសួរព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងចុះហត្ថលេខា ឬផ្ទិតមេដៃលើកំណត់ហេតុ ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមចុះហត្ថលេខា ឬផ្ទិតមេដៃ មន្ត្រីទទួល និងពិនិត្យពាក្យបណ្តឹង ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមចុះហត្ថលេខា ឬផ្ទិតមេដៃលើកំណត់ហេតុនេះ បន្ទាប់មកត្រូវចុះកាលបរិច្ឆេទ និងពេលវេលានៃការទទួលពាក្យបណ្តឹង រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ បិទផ្សាយជាសាធារណៈនៅទីស្តីការ គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុក ១ (មួយ) ច្បាប់ ប្រើប្រាស់ក្នុងពេលដោះស្រាយពាក្យបណ្តឹង ហើយជម្រាបអ្នកប្តឹងថា គ.ជ.ប នឹងសម្រេចលើពាក្យបណ្តឹងតវ៉ានោះ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង គិតចាប់ពីពេលបានទទួលពាក្យបណ្តឹងតវ៉ា ។ ក្នុងករណីនេះ គ.ជ.ប ត្រូវចាត់អគ្គលេខាធិការ ដែលមាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម និងនាយកដ្ឋានប្រតិបត្តិការ ជាជំនួយការ រៀបចំឱ្យមានឯកសារដូចខាងក្រោម ៖

- ៨.៣៩.៤.១ ប្រមូលផ្តុំរាល់ពាក្យបណ្តឹងអំពីភាពមិនប្រក្រតី ដែលកើតមានឡើងនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត ដែលមានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ។
- ៨.៣៩.៤.២ ប្រមូលផ្តុំរាល់សម្រង់សេចក្តីសម្រេចលើពាក្យបណ្តឹង អំពីភាពមិនប្រក្រតី ដែលកើតមានឡើងនៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដែលមានដាក់នៅ គឃ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប ។
- ៨.៣៩.៤.៣ ប្រមូលផ្តុំរាល់ ទ.១១០១ និង ទ.១១០២ នៃការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ទាំងអស់ចំណុះរាជធានី ខេត្ត ៣ក់ព័ន្ធ ។
- ៨.៣៩.៤.៤ ធ្វើកំណត់ហេតុសាកសួរបន្ថែមពីគណបក្សនយោបាយ ឬតំណាងដែលដាក់ពាក្យបណ្តឹង ។
- ៨.៣៩.៤.៥ ឯកសារ ភស្តុតាងនានា ដែលដាក់ភ្ជាប់ជាមួយនឹងពាក្យបណ្តឹង ។
- ៨.៣៩.៤.៦ ចាត់មន្ត្រីនៃអគ្គលេខាធិការដ្ឋាន ចុះអង្កេតស្រាវជ្រាវដល់ទីកន្លែងក្នុងករណីចាំបាច់ ។

៨.៣៩.៥ ផ្អែកលើឯកសារ ដូចមានចែងក្នុងចំណុច ៨.៣៩.៤ ខាងលើ អគ្គលេខាធិការត្រូវណែនាំ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ឱ្យត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ ដូចខាងក្រោម ៖

៨.៣៩.៥.១ ពិនិត្យពាក្យបណ្តឹង ដែលបានដាក់នៅ គយ.សប ឬ/និងនៅ គធ.ខប ឬ/និងនៅ គ.ជ.ប ។

៨.៣៩.៥.២ ពិនិត្យសម្រង់សេចក្តីសម្រេចរបស់ គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប លើពាក្យបណ្តឹងអំពីភាពមិនប្រក្រតីរបស់គណបក្សនយោបាយ ឬតំណាងពាក់ព័ន្ធ ។

៨.៣៩.៥.៣ ពិនិត្យមើលកំណត់ហេតុនៃការបោះឆ្នោត (ទ.១១០១) និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត (ទ.១១០២) ដែលមានចុះអំពីព្រឹត្តិការណ៍ផ្សេងៗក្នុងដំណើរការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨.៣៩.៥.៤ ពិនិត្យឯកសារ ភស្តុតាងនានា ដែលបានដាក់ភ្ជាប់ជាមួយពាក្យបណ្តឹងពាក់ព័ន្ធ ។

៨.៣៩.៥.៥ ធ្វើរបាយការណ៍ត្រួតពិនិត្យផ្ទៀងផ្ទាត់ និងលើកយោបល់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ អំពីការសម្រេចទទួលយក ឬបដិសេធលើពាក្យបណ្តឹង ។

៨.៣៩.៦ គ.ជ.ប ត្រូវសម្រេចបដិសេធលើពាក្យបណ្តឹង ដូចចែងក្នុងចំណុច ៨.៣៩.៤ ខាងលើ ប្រសិនបើ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ ដូចចែងក្រោមចំណុច ៨.៣៩.៥ ខាងលើ គ.ជ.ប រកឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីការកើតមានឡើងនូវភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលប្រព្រឹត្តដោយគណៈកម្មការ ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតណាមួយ ធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត និងពុំមានការប្តឹងតវ៉ាអំពីភាពមិនប្រក្រតីណាមួយកើតមានឡើងនៅការិយាល័យបោះឆ្នោត ឬ/និងការិយាល័យរាប់សន្លឹកឆ្នោត ដែលអ្នកប្តឹង ឬតំណាងត្រូវប្តឹងទៅ គយ.សប យ៉ាងយូរត្រឹមម៉ោង ១១:៣០ (ដប់មួយសាមសិប) នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត ឬបណ្តឹងនោះ ឬទាំងនោះត្រូវបានដាក់ ប៉ុន្តែត្រូវបាន គយ.សប ឬ/និង គធ.ខប ឬ/និង គ.ជ.ប សម្រេចបដិសេធ ។ ក្នុងករណីនេះ គ.ជ.ប ត្រូវ ៖

៨.៣៩.៦.១ ចារបដិសេធលើពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដូចចែងក្នុងចំណុច ៨.៣៩.៤ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៨.៣៩.៦.២ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្ដីសម្រេច (ទ.១២០៣) បដិសេធពាក្យបណ្ដឹងតវ៉ាអំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ និងត្រូវចុះហត្ថលេខាដោយប្រធាន គ.ជ.ប រួចបោះត្រា និងកាលបរិច្ឆេទ ។

៨.៣៩.៦.៣ ធានាថា សម្រង់សេចក្ដីសម្រេច ដូចចែងក្នុងចំណុច ៨.៣៩.៦.២ ខាងលើ ត្រូវបានរៀបចំក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនដើមបណ្ដឹង ១ (មួយ) ច្បាប់ ជូនគ្រប់ភ្នាក់ងារគណបក្សឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.៣៩.៦.៤ ប្រកាសថា គណបក្សនយោបាយ ឬតំណាង ដែលមិនពេញចិត្តនឹងសេចក្ដីសម្រេចបដិសេធរបស់ គ.ជ.ប មានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីទទួលបានសម្រង់សេចក្ដីសម្រេចនេះ ។

៨.៣៩.៦.៥ ប្រគល់របាយការណ៍ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងលើកយោបល់ ដូចក្នុងចំណុច ៨.៣៩.៤.៥ រួមនឹងឯកសារពាក់ព័ន្ធផ្សេងទៀត ដូចចែងក្រោមចំណុច ៨.៣៩.៤ ជូនអគ្គលេខាធិការដ្ឋាន ដើម្បីមុខការ ។

៨.៣៩.៧ ផ្អែកតាមលទ្ធផលនៃការពិនិត្យ ផ្ទៀងផ្ទាត់ និងតាមរបាយការណ៍ ដូចចែងក្នុងចំណុច ៨.៣៩.៥ ខាងលើ ប្រសិនបើ គ.ជ.ប រកឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់អំពីការកើតមានឡើងនូវភាពមិនប្រក្រតីធ្ងន់ធ្ងរ ដែលប្រព្រឹត្តដោយគណៈកម្មការ ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតណាមួយ ធ្វើឱ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត និងមានបណ្ដឹងអំពីភាពមិនប្រក្រតីកើតមាននៅការិយាល័យបោះឆ្នោត ឬ/និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវបានដាក់នៅ គយ.សប ត្រឹមម៉ោង ១១:៣០ (ដប់មួយសាមសិប) នាទីព្រឹកនៃថ្ងៃបន្ទាប់ពីថ្ងៃបោះឆ្នោត គ.ជ.ប ត្រូវសម្រេចយល់ព្រមតាមពាក្យបណ្ដឹង ដោយត្រូវបដិសេធលទ្ធផលនៅការិយាល័យបោះឆ្នោតនោះ ឬការិយាល័យបោះឆ្នោតទាំងនោះក្នុងរាជធានី ខេត្តពាក់ព័ន្ធ ។ ក្នុងករណីនេះ ប្រធាន គ.ជ.ប ត្រូវ ៖

៨.៣៩.៧.១ ចារយល់ព្រមលើពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោត ដូចមានចែងក្នុងចំណុច ៨.៣៩.៤ រួចចុះហត្ថលេខា និងកាលបរិច្ឆេទ ។

៨.៣៩.៧.២ ធានាថា មន្ត្រីជំនាញបានបំពេញសម្រង់សេចក្តីសម្រេច (ទ.១២០៣) បដិសេធលទ្ធផលនៅការិយាល័យបោះឆ្នោតនោះ ឬការិយាល័យបោះឆ្នោតទាំងនោះក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ និងត្រូវចុះហត្ថលេខាដោយប្រធាន គ.ជ.ប រួចបោះត្រា និងចុះកាលបរិច្ឆេទ ។

៨.៣៩.៧.៣ ធានាថា សម្រង់សេចក្តីសម្រេច ដូចមានចែងក្នុងចំណុច ៨.៣៩.៧.២ ខាងលើ ត្រូវបានរៀបចំក្នុងចំនួនគ្រប់គ្រាន់ សម្រាប់ប្រគល់ជូនដើមបណ្តឹង ១ (មួយ) ច្បាប់ ជូនគ្រប់ភ្នាក់ងារគណបក្សឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្តពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

៨.៣៩.៧.៤ ប្រកាសថា គ.ជ.ប នឹងចាត់ចែងឱ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅការិយាល័យបោះឆ្នោតនោះ ឬការិយាល័យបោះឆ្នោតទាំងនោះ ក្នុងឃុំ សង្កាត់ពាក់ព័ន្ធចំណុះរាជធានី ខេត្តពាក់ព័ន្ធ ក្នុងរយៈពេលយ៉ាងយូរ ៨ (ប្រាំបី) ថ្ងៃ គិតចាប់ពីថ្ងៃចេញសម្រង់សេចក្តីសម្រេចនេះ ។

៨.៣៩.៧.៥ ប្រគល់របាយការណ៍ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងលើកយោបល់ ដូចមានចែងក្នុងចំណុច ៨.៣៩.៥.៥ រួមនឹងឯកសារពាក់ព័ន្ធផ្សេងទៀត ដូចមានចែងក្រោមចំណុច ៨.៣៩.៤ ជូនអគ្គលេខាធិការដ្ឋាន ដើម្បីមុខការ ។

៨.៣៩.៨ ចំពោះពាក្យបណ្តឹងតវ៉ា ដែលបានដាក់ប្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ ស្របតាមរយៈពេលកំណត់ដូចមានចែងក្នុងចំណុច ៨.៣៨.៨ ឬ ៨.៣៩.២ ឬ ៨.៣៩.៣ ឬ ៨.៣៩.៦.៤ ខាងលើ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបើកសវនាការដោះស្រាយពាក្យបណ្តឹងតវ៉ានោះ ក្នុងរយៈពេលពី ១០ (ដប់) ថ្ងៃទៅ ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង។ នីតិវិធីសម្រាប់ការទទួល និងការដោះស្រាយពាក្យបណ្តឹងតវ៉ានៅក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកំណត់ដោយក្រុមប្រឹក្សាធម្មនុញ្ញ ។

៨.៣៩.៩ បន្ទាប់ពីរាល់ពាក្យបណ្តឹងតវ៉ាដែលបានដាក់នៅ គ.ជ.ប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរ គ.ជ.ប ត្រូវចាត់ចែងកែតម្រូវតួលេខលទ្ធផល ឬ/និងចាត់ចែងឱ្យបោះឆ្នោតសាជាថ្មី ដោយផ្អែកតាមសេចក្តីសម្រេចរបស់ គ.ជ.ប ឬ/និងក្រុមប្រឹក្សាធម្មនុញ្ញ ។ បន្ទាប់មក គ.ជ.ប ត្រូវផ្តល់សុពលភាពលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទៅជាលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ គ.ជ.ប ត្រូវចាត់ចែងបិទផ្សាយនៅទីស្តីការ គ.ជ.ប និងផ្សព្វផ្សាយជាសាធារណៈតាមគ្រប់រូបភាព នូវតារាងលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ការរៀបចំ និងប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

ប្រការ ៨.៤០.-

ផ្អែកតាមលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដូចមានចែងក្នុងចំណុច ៨.៣៩.៨ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ត្រូវធានាថា សមាជិកក្រុមត្រូវបានចាត់ចែងឱ្យបញ្ជូលតួលេខលទ្ធផលគាំទ្រគណបក្សនយោបាយនីមួយៗ ដែលឈរឈ្មោះបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្ត ទៅក្នុងកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ឬ/និងឱ្យគណនាតាមការធ្វើប្រមាណវិធីដោយដៃ ដោយផ្អែកតាមរូបមន្តកំណត់បែងចែកអាសនៈ ដែលកំណត់ដោយច្បាប់ និងដូចមានចែងក្នុងឧបសម្ព័ន្ធទី ៩ នៃ ប.ន.ត.រ នេះ ស្តីពីប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ ។ ប្រធានក្រុមត្រូវពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលនៃការគណនាការបែងចែកអាសនៈខាងលើ រវាងការគណនាដោយដៃ និងការគណនាដោយប្រើកម្មវិធីប្រតិបត្តិការបែងចែកអាសនៈក្នុងកុំព្យូទ័រ ដើម្បីឱ្យដឹងប្រាកដថា លទ្ធផលនោះមានលក្ខណៈត្រឹមត្រូវដូចគ្នា ។ ប្រធានក្រុមត្រូវធានាថា តារាងលទ្ធផលនៃការបែងចែកអាសនៈដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្តបានទទួល ត្រូវបានបោះពុម្ពរួចចារបញ្ជាក់ថា ត្រឹមត្រូវ និងចុះហត្ថលេខា ដោយលេខាធិការ អនុប្រធាន និងប្រធានក្រុម និងដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ។

៨.៤០.១ ផ្អែកលើលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងលទ្ធផលនៃការបែងចែកអាសនៈ ដែលគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតតាមមណ្ឌលរាជធានី ខេត្តត្រូវបានទទួល ដូចមានចែងក្នុងចំណុច ៨.៣៩.៩ និងប្រការ ៨.៤០ ខាងលើ ប្រធានក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប រួមជាមួយអនុប្រធានក្រុម ត្រូវផ្ទៀងផ្ទាត់ និងស្រង់ឈ្មោះបេក្ខជននៃគណបក្សនយោបាយ ដែលត្រូវជាប់ឆ្នោតជាតំណាងរាស្ត្រ តាមនីតិវិធីដូចមានចែងក្រោមចំណុច ៧ នៃ ឧបសម្ព័ន្ធទី ៩ ស្តីពី

ប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសន: និងត្រូវរៀបចំសេចក្ដីព្រាងសេចក្ដីប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ រួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការ ដើម្បីពិនិត្យសម្រេច ព្រមទាំងចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទជាផ្លូវការ ។

៨.៤០.២ គ.ជ.ប ត្រូវប្រកាសផ្សាយសេចក្ដីប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ដូចមានចែងក្នុងចំណុច ៨.៤០.១ ខាងលើ ជាសាធារណ: និងត្រូវបែងចែកដូចខាងក្រោម ។

- ៨.៤០.២.១ ថ្វាយព្រះមហាក្សត្រ ១ (មួយ) ច្បាប់ ។
- ៨.៤០.២.២ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ ។
- ៨.៤០.២.៣ ផ្ញើជូនអគ្គលេខាធិការដ្ឋាននៃព្រឹទ្ធសភា ១ (មួយ) ច្បាប់ ។
- ៨.៤០.២.៤ ផ្ញើជូនអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ១ (មួយ) ច្បាប់ ។
- ៨.៤០.២.៥ ផ្ញើជូនទីស្ដីការគណៈរដ្ឋមន្ត្រី ១ (មួយ) ច្បាប់ ។
- ៨.៤០.២.៦ ផ្ញើជូនគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ១ (មួយ) ច្បាប់ៗ ។
- ៨.៤០.២.៧ ផ្ញើជូនបណ្ណាសារដ្ឋានជាតិ ១ (មួយ) ច្បាប់ ។
- ៨.៤០.២.៨ រក្សាទុកជាឯកសាររបស់ គ.ជ.ប ១ (មួយ) ច្បាប់ ។

ជំពូកទី៩

ការបាត់បង់អាសនៈនៃរដ្ឋសភា និងការជ្រើសតាំងជំនួស ព្រមទាំងការបែងចែកអាសនៈដែលនៅទំនេរ

ប្រការ ៩.១.-

បន្ទាប់ពីរាល់ពាក្យបណ្តឹងតវ៉ាត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរ គ.ជ.ប ត្រូវផ្តល់សុពលភាពលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ទៅជាលទ្ធផលផ្លូវការនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៩.១.១ អនុលោមតាមមាត្រា ១៣៨ នៃ ច.ប.ត.រ បន្ទាប់ពីដំណើរការនៃការបោះឆ្នោត បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយបន្ទាប់ពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយ គ.ជ.ប រួច គណបក្សនយោបាយណាមួយ ដែលទទួលបានអាសនៈមួយ ឬច្រើនក្នុងរដ្ឋសភា ត្រូវចាត់ទុកថាបានបោះបង់ចោលអាសនៈរបស់ខ្លួនក្នុងករណីណាមួយ ដូចខាងក្រោម ៖

- ៩.១.១.១ គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមចូលរួមសម័យប្រជុំដំបូងតាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។
- ៩.១.១.២ គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមចូលរួមប្រជុំរដ្ឋសភាសម្រាប់ការប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។
- ៩.១.១.៣ គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមធ្វើសច្ចាប្រណិធានចូលកាន់តំណែង ។

៩.១.២ ក្នុងករណីដូចចែងក្នុងចំណុច ៩.១.១ ខាងលើ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថាជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

៩.១.៣ រដ្ឋសភា ត្រូវជូនដំណឹងទៅ គ.ជ.ប ជាបន្ទាន់ ឬក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្តៃបួន) ម៉ោង ។ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីរដ្ឋសភា ទៅឱ្យគណបក្សនយោបាយផ្សេងដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ក្នុងរាជធានី ខេត្តជាមួយគ្នា ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបាត់បង់អាសនៈ ដូចមានចែងក្នុងចំណុច ៩.១.១ ខាងលើ តាមជំហានទាំងឡាយដូចខាងក្រោម ៖

ការរកកូតានៃអាសនៈដែលបោះបង់ចោល

៩.១.៣.១ **ជំហានទីមួយ ៖** កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួល ១ (មួយ) អាសនៈ តាមរូបមន្តខាងក្រោម ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ ៖

- $ក'_{ត}$ ៖ តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក ។
- $ស'_{ស}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយផ្សេងដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្តដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងរាជធានី ខេត្ត។
- $អ'_{ប}$ ៖ តាងឱ្យអាសនៈ ដែលបានបោះបង់ចោលនៅក្នុងរាជធានីខេត្ត។

<u>**ឧទាហរណ៍**</u> នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **B** ដែលមានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចំនួន ១២ ក្នុងនោះ ៖

១	គណបក្ស	ក	មានសន្លឹកឆ្នោតបានការ	$ស_{ក}$	=	៤៩.៦៨២	សន្លឹក
២	គណបក្ស	ខ	មានសន្លឹកឆ្នោតបានការ	$ស_{ខ}$	=	៤៨.៧៥៤	សន្លឹក
៣	គណបក្ស	គ	មានសន្លឹកឆ្នោតបានការ	$ស_{គ}$	=	១១២.៩៧៨	សន្លឹក
៤	គណបក្ស	ឃ	មានសន្លឹកឆ្នោតបានការ	$ស_{ឃ}$	=	១០៨.៣៣៤	សន្លឹក

៥	គណបក្ស	ង	មានសន្លឹកឆ្នោតបានការ	ស$_{ប}$ង	=	១៥.១៦២	សន្លឹក
៦	គណបក្ស	ច	មានសន្លឹកឆ្នោតបានការ	ស$_{ប}$ច	=	២៥.២៨៦	សន្លឹក
៧	គណបក្ស	ឆ	មានសន្លឹកឆ្នោតបានការ	ស$_{ប}$ឆ	=	២៨.២៤៥	សន្លឹក
៨	គណបក្ស	ជ	មានសន្លឹកឆ្នោតបានការ	ស$_{ប}$ជ	=	៥០.៥២៣	សន្លឹក
៩	គណបក្ស	ឈ	មានសន្លឹកឆ្នោតបានការ	ស$_{ប}$ឈ	=	១១.៥៧៦	សន្លឹក
១០	គណបក្ស	ញ	មានសន្លឹកឆ្នោតបានការ	ស$_{ប}$ញ	=	៤៨.៧៥១	សន្លឹក
១១	គណបក្ស	ដ	មានសន្លឹកឆ្នោតបានការ	ស$_{ប}$ដ	=	១៨.៦៩៤	សន្លឹក
១២	គណបក្ស	ឋ	មានសន្លឹកឆ្នោតបានការ	ស$_{ប}$ឋ	=	១៥.៣៩៣	សន្លឹក

តាមការបញ្ជាក់ក្នុងលិខិតជូនដំណឹងរបស់រដ្ឋសភា គណបក្សនយោបាយ **ឃ** ដែលបានប្រកាសថាជាប់ឆ្នោតរូចហើយ បានបោះបង់ចោលអាសនៈរបស់ខ្លួនចំនួន ៣(បី) ។ ដូចនេះបញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយ **ឃ** មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀត គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ទៅឱ្យគណបក្សនយោបាយផ្សេងទៀតដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតក្នុងខេត្តជាមួយគ្នា ដោយមិនគិតបញ្ចូលគណបក្សនយោបាយ ដែលបាត់បង់អាសនៈឡើយ ។

អនុវត្តតាមរូបមន្ត ដូចចែងក្នុងចំណុច ៩.១.៣.១ ខាងលើ យើងបាន ៖

$$\text{ស'}_{ស} = (\text{៤៩.៦៨២} + \text{៤៨.៧៥៤} + \text{១១២.៩៧៨} + \text{១០៨.៣៣៤} + \text{១៥.១៦២} + \text{២៥.២៨៦} + \text{២៨.២៤៥} + \text{៥០.៥២៣} + \text{១១.៥៧៦} + \text{៤៨.៧៥១} + \text{១៨.៦៩៤} + \text{១៥.៣៩៣}) - \text{១០៨.៣៣៤} = \text{៤២៥.០៤៤ សន្លឹក}$$

$$\text{អ'}_{ប} = \text{៣}$$

$$\text{ក'}_{ត} = \frac{\text{ស'}_{ស}}{\text{អ'}_{ប}} = \frac{\text{៤២៥.០៤៤}}{\text{៣}} = \text{១៤១.៦៨១}$$

ក្នតាស្មើនឹង ១៤១.៦៨១ ។

ការកំណត់ចំនួនអាសនៈបឋម

៩.១.៣.២ **ជំហានទីពីរ** ៖ ដើម្បីកំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗ បានទទួល គ.ជ.ប ត្រូវអនុវត្តតាមរូបមន្ត ខាងក្រោម ៖

$$\text{អ}'_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{ត}}}$$

ក្នុងនោះ៖

- $\text{អ}'_{\text{ទ}}$ ៖ តាងឱ្យចំនួនអាសន: ដែលគណបក្សនយោបាយមួយក្នុងខេត្តបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទីបី ។
- $\text{ស}_{\text{ប}}$ ៖ តាងឱ្យសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។
- $\text{ក}'_{\text{ត}}$ ៖ តាងឱ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទីមួយ ។

បន្ទាប់ពីបានគណនាក្នុងជំហានទីពីរ គ្រប់គណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតក្នុងរាជធានី ខេត្ត លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសន:ក្នុងរាជធានី ខេត្ត ក្នុងករណីគ្មាននៅសល់អាសន:ដើម្បីបែងចែកបន្តទៀត ចំនួនអាសន:សម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទីពីររួចហើយ ប៉ុន្តែមានអាសន:នៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសន:ដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទីបី ។

<u>ឧទាហរណ៍</u> ការបែងចែកអាសន:ដែលបោះបង់ចោលលើកទី ១ នៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត B ដដែល ។

អនុវត្តតាមការបែងចែកអាសន:ដែលបោះបង់ចោលលើកទី ១ តាមរូបមន្តក្នុងជំហានទីពីរ ចំណុច ៩.១.៣.២ យើងបាន ៖

គណបក្ស	ក	$\text{អ}'_{\text{ទ}}$១	$= \frac{\text{៥៩.៦៨២}}{\text{១៥១.៦៨១}}$	=	០,៣៥	មិនទទួលបានអាសន:
គណបក្ស	ខ	$\text{អ}'_{\text{ទ}}$ ១	$= \frac{\text{៥៨.៧៥៥}}{\text{១៥១.៦៨១}}$	=	០,៣៨	មិនទទួលបានអាសន:
គណបក្ស	គ	$\text{អ}'_{\text{ទ}}$ ១	$= \frac{\text{១១២.៩៧៨}}{\text{១៥១.៦៨១}}$	=	០,៧៩	មិនទទួលបានអាសន:
គណបក្ស	ឃ		= ១០៨.៣៣៥	=		មិនរាប់បញ្ចូលក្នុងការបែងចែកអាសន:
គណបក្ស	ង	$\text{អ}'_{\text{ទ}}$ ១	$= \frac{\text{១៥.១៦២}}{\text{១៥១.៦៨១}}$	=	០,១០	មិនទទួលបានអាសន:

$$\text{គណបក្ស ច} \quad \text{អ'}_{\text{ទ}}\ ១ = \frac{\text{២៥.២៨៦}}{\text{១៥១.៦៨១}} = \text{0,១៧} \quad \text{មិនទទួលបានអាសន:}$$

$$\text{គណបក្ស ឆ} \quad \text{អ'}_{\text{ទ}}\ ១ = \frac{\text{២៨.២៥៥}}{\text{១៥១.៦៨១}} = \text{0,១៩} \quad \text{មិនទទួលបានអាសន:}$$

$$\text{គណបក្ស ជ} \quad \text{អ'}_{\text{ទ}}\ ១ = \frac{\text{៥0.៥២៣}}{\text{១៥១.៦៨១}} = \text{0,៣៥} \quad \text{មិនទទួលបានអាសន:}$$

$$\text{គណបក្ស ឈ} \quad \text{អ'}_{\text{ទ}}\ ១ = \frac{\text{១១.៥៧៦}}{\text{១៥១.៦៨១}} = \text{0,0៨} \quad \text{មិនទទួលបានអាសន:}$$

$$\text{គណបក្ស ញ} \quad \text{អ'}_{\text{ទ}}\ ១ = \frac{\text{៥៨.៧៥១}}{\text{១៥១.៦៨១}} = \text{0,៣៥} \quad \text{មិនទទួលបានអាសន:}$$

$$\text{គណបក្ស ដ} \quad \text{អ'}_{\text{ទ}}\ ១ = \frac{\text{១៨.៦៩៥}}{\text{១៥១.៦៨១}} = \text{0,១៣} \quad \text{មិនទទួលបានអាសន:}$$

$$\text{គណបក្ស ឋ} \quad \text{អ'}_{\text{ទ}}\ ១ = \frac{\text{១៥.៣៩៣}}{\text{១៥១.៦៨១}} = \text{0,១0} \quad \text{មិនទទួលបានអាសន:}$$

ផ្អែកតាមការគណនាខាងលើ ពុំមានគណបក្សនយោបាយណាមួយទទួលបានអាសន:ដែលបានបោះបង់ចោលទេ ។ ដូចនេះមាននៅសល់អាសន:ចំនួន ៣ (បី) ដែលត្រូវបន្តបែងចែកតាមរូបមន្តកំណត់ក្នុងជំហានទីបី ។

ការបែងចែកអាសន:នៅសល់ពីការបែងចែកជំហានទីពីរ

៩.១.៣.៣ **ជំហានទីបី**: អាសន:ដែលនៅសល់ត្រូវបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តខាងក្រោម ៖

$$\text{ម'}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ'}_{\text{ទ}}+១}$$

ក្នុងនោះ៖

- ម'$_{\text{ធ}}$ ៖ តាងឱ្យមធ្យមភាគខ្ពស់បំផុត ។
- ស$_{\text{ប}}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប ដែលបានបោះឱ្យគណបក្សនយោបាយមួយក្នុងខេត្ត ។

- អ'ទ ៖ តាងឱ្យចំនួនអាសន: ដែលបានបែងចែកឱ្យទៅគណបក្សនយោបាយមួយ ។
- ១ ៖ ជាលេខនិមិត្ត

ក្នុងករណីដែលនៅសល់អាសន:ចំនួន ១ (មួយ) ដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទីបី សម្រាប់គណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសន:នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត។

ក្នុងករណីដែលនៅសល់អាសន:ច្រើនជាង ១ (មួយ) ដែលត្រូវបែងចែក គ.ជ.ប ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទីបី ហើយអាសន:ចំនួន ១ (មួយ) ត្រូវបែងចែកទៅឱ្យគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត ។

បន្ទាប់ពីកំណត់បានមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗរួចមក ត្រូវធ្វើការប្រៀបធៀបគ្នា ។ គណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតទាំងចំនួន ២(ពីរ)ខ្ទង់ ក្រោយក្បៀស) នឹងត្រូវទទួលបានអាសន: ១ (មួយ) ។

បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ អ'ទ ចំនួន ១ (មួយ) ចំពោះគណបក្សនយោបាយដែលបានទទួលអាសន:ចំនួន ១ (មួយ) ក្នុងការអនុវត្តរូបមន្តលើកទីមួយ ។ ដូច្នេះចំនួនអាសន:ចំនួន ១ (មួយ) ត្រូវផ្តល់ឱ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសន: ត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសន:ម្តងមួយអាសន:ជាបន្តបន្ទាប់រហូតដល់អស់អាសន:ដែលនៅសល់ ។

<u>ឧទាហរណ៍</u> ការបែងចែកអាសន:ដែលបោះបង់ចោលនៅសល់តាមរូបមន្តមធ្យមភាគខ្ពស់បំផុត ក្នុងជំហានទីបី នៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត B ដដែល ។ អាសន:នៅសល់ដែលត្រូវបន្តបែងចែកមានចំនួន ៣ (បី) ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទីបី យើងបាន ៖

$$\text{គណបក្ស ក ម'ធ១} = \frac{\text{៤៩.៦៨២}}{\text{0 + ១}} = \text{៤៩.៦៨២,00}$$ មិនទទួលបានអាសន:

$$\text{គណបក្ស ខ ម'ធ១} = \frac{\text{៤៨.៧៥៤}}{\text{0 + ១}} = \text{៤៨.៧៥៤,00}$$ មិនទទួលបានអាសន:

គណបក្ស	**គ**	ម'ធ១	$= \frac{១១២.៩៧៨}{0+1}$	=	១១២.៩៧៨,00	ទទួលបាន ១ អាសន:
គណបក្ស	**ឃ**		= ១0៨.៣៣៤	=	មិនរាប់បញ្ចូលក្នុងការបែងចែកអាសន:	
គណបក្ស	**ង**	ម'ធ១	$= \frac{១៥.១៦២}{0+1}$	=	១៥.១៦២,00	មិនទទួលបាន អាសន:
គណបក្ស	**ច**	ម'ធ១	$= \frac{២៥.២៨៦}{0+1}$	=	២៥.២៨៦,00	មិនទទួលបាន អាសន:
គណបក្ស	**ឆ**	ម'ធ១	$= \frac{២៨.២៤៥}{0+1}$	=	២៨.២៤៥,00	មិនទទួលបាន អាសន:
គណបក្ស	**ជ**	ម'ធ១	$= \frac{៥0.៥២៣}{0+1}$	=	៥0.៥២៣,00	មិនទទួលបាន អាសន:
គណបក្ស	**ឈ**	ម'ធ១	$= \frac{១១.៥៧៦}{0+1}$	=	១១.៥៧៦,00	មិនទទួលបាន អាសន:
គណបក្ស	**ញ**	ម'ធ១	$= \frac{៤៨.៧៥១}{0+1}$	=	៤៨.៧៥១,00	មិនទទួលបាន អាសន:
គណបក្ស	**ដ**	ម'ធ១	$= \frac{១៨.៦៩៤}{0+1}$	=	១៨.៦៩៤,00	មិនទទួលបាន អាសន:
គណបក្ស	**ឋ**	ម'ធ១	$= \frac{១៥.៣៩៣}{0+1}$	=	១៥.៣៩៣,00	មិនទទួលបាន អាសន:

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំង ១១ ខាងលើ គណបក្ស **គ** មានមធ្យមភាគធំជាងគេគឺ ១១២.៩៧៨,00 ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះ គណបក្ស **គ** ត្រូវទទួលបានអាសន: ដែលបោះបង់ចោលចំនួន ១ (មួយ) ក្នុងការបែងចែកលើកនេះ និងមានអាសន:នៅសល់ ២ (ពីរ) ទៀត ដែលត្រូវបន្តបែងចែក ។

បញ្ជីគណបក្ស	មធ្យមភាគខ្ពស់បំផុតលើកទី១					មធ្យមភាគខ្ពស់បំផុតលើកទី២					មធ្យមភាគខ្ពស់បំផុតលើកទី៣				
គណបក្ស ក	ម'ធ១	=	៤៩.៦៨២ / ០ + ១	=	៤៩.៦៨២,០០	ម'ធ២	=	៤៩.៦៨២ / ០ + ១	=	៤៩.៦៨២,០០	ម'ធ៣	=	៤៩.៦៨២ / ០ + ១	=	៤៩.៦៨២,០០
គណបក្ស ខ	ម'ធ១	=	៤៨.៧៥៤ / ០ + ១	=	៤៨.៧៥៤,០០	ម'ធ២	=	៤៨.៧៥៤ / ០ + ១	=	៤៨.៧៥៤,០០	ម'ធ៣	=	៤៨.៧៥៤ / ០ + ១	=	៤៨.៧៥៤,០០
គណបក្ស គ	ម'ធ១	=	១១២.៩៧៨ / ០ + ១	=	១១២.៩៧៨,០០	ម'ធ២	=	១១២.៩៧៨ / ១ + ១	=	៥៦.៤៨៩,០០	ម'ធ៣	=	១១២.៩៧៨ / ២ + ១	=	៣៧.៦៥៩,៣៣
គណបក្ស ឃ		=	១០៨.៣៣៤	=				១០៨.៣៣៤					១០៨.៣៣៤		
គណបក្ស ង	ម'ធ១	=	១៥.១៦២ / ០ + ១	=	១៥.១៦២,០០	ម'ធ២	=	១៥.១៦២ / ០ + ១	=	១៥.១៦២,០០	ម'ធ៣	=	១៥.១៦២ / ០ + ១	=	១៥.១៦២,០០
គណបក្ស ច	ម'ធ១	=	២៥.២៨៦ / ០ + ១	=	២៥.២៨៦,០០	ម'ធ២	=	២៥.២៨៦ / ០ + ១	=	២៥.២៨៦,០០	ម'ធ៣	=	២៥.២៨៦ / ០ + ១	=	២៥.២៨៦,០០
គណបក្ស ឆ	ម'ធ១	=	២៨.២៩៥ / ០ + ១	=	២៨.២៩៥,០០	ម'ធ២	=	២៨.២៩៥ / ០ + ១	=	២៨.២៩៥,០០	ម'ធ៣	=	២៨.២៩៥ / ០ + ១	=	២៨.២៩៥,០០
គណបក្ស ជ	ម'ធ១	=	៥០.៥២៣ / ០ + ១	=	៥០.៥២៣,០០	ម'ធ២	=	៥០.៥២៣ / ០ + ១	=	៥០.៥២៣,០០	ម'ធ៣	=	៥០.៥២៣ / ០ + ១	=	៥០.៥២៣,០០
គណបក្ស ឈ	ម'ធ១	=	១១.៥៧៦ / ០ + ១	=	១១.៥៧៦,០០	ម'ធ២	=	១១.៥៧៦ / ០ + ១	=	១១.៥៧៦,០០	ម'ធ៣	=	១១.៥៧៦ / ០ + ១	=	១១.៥៧៦,០០
គណបក្ស ញ	ម'ធ១	=	៤៨.៧៥១ / ០ + ១	=	៤៨.៧៥១,០០	ម'ធ២	=	៤៨.៧៥១ / ០ + ១	=	៤៨.៧៥១,០០	ម'ធ៣	=	៤៨.៧៥១ / ០ + ១	=	៤៨.៧៥១,០០
គណបក្ស ដ	ម'ធ១	=	១៨.៦៩៤ / ០ + ១	=	១៨.៦៩៤,០០	ម'ធ២	=	១៨.៦៩៤ / ០ + ១	=	១៨.៦៩៤,០០	ម'ធ៣	=	១៨.៦៩៤ / ០ + ១	=	១៨.៦៩៤,០០
គណបក្ស ឋ	ម'ធ១	=	១៥.៣៩៣ / ០ + ១	=	១៥.៣៩៣,០០	ម'ធ២	=	១៥.៣៩៣ / ០ + ១	=	១៥.៣៩៣,០០	ម'ធ៣	=	១៥.៣៩៣ / ០ + ១	=	១៥.៣៩៣,០០

ជាលទ្ធផលក្នុងការបែងចែកអាសន: តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទីបី យើងបាន ៖

- គណបក្ស ក មិនទទួលបានអាសន:
- គណបក្ស ខ មិនទទួលបានអាសន:
- គណបក្ស គ ទទួលបាន ២ អាសន:
- គណបក្ស ង មិនទទួលបានអាសន:
- គណបក្ស ច មិនទទួលបានអាសន:
- គណបក្ស ឆ មិនទទួលបានអាសន:
- គណបក្ស ជ ទទួលបាន ១ អាសន:
- គណបក្ស ឈ មិនទទួលបានអាសន:
- គណបក្ស ញ មិនទទួលបានអាសន:
- គណបក្ស ដ មិនទទួលបានអាសន:
- គណបក្ស ឋ មិនទទួលបានអាសន:

៩.១.៣.៤ ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សនយោបាយពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នា ដែលមិនអាចកំណត់បែងចែកអាសន:ដែលនៅសល់ទៅឱ្យគណបក្សណាមួយបាន គ.ជ.ប ត្រូវអនុវត្តតាមនីតិវិធីដូចចែងក្រោមចំណុច ៦ ឧបសម្ព័ន្ធទី ៩ នៃ ប.ន.ត.រ នេះ ស្តីពីប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសន: ។

៩.១.៣.៥ ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ គ.ជ.ប ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅគណបក្សនោះឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជន ក្នុងរយៈពេលយ៉ាងយូរ ៤៨ (សែសិបប្រាំបី) ម៉ោង ក្រោយពីបានទទួលសំណើ។

៩.១.៣.៦ ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាខាងលើ ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

ប្រការ ៩.២.-

ក្នុងនីតិកាលនៃរដ្ឋសភា ប្រសិនបើមានគណបក្សនយោបាយណាមួយប្រកាសបោះបង់ចោលអាសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងតំណាងរាស្ត្រទាំងអស់នៃគណបក្សនយោបាយនោះលែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ ។

៩.២.១ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈ ដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានលិខិតជូនដំណឹងជាផ្លូវការពីរដ្ឋសភា ឬ/និងក្រសួងមហាផ្ទៃ ទៅឱ្យគណបក្សនយោបាយនានាដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងរាជធានី ខេត្តជាមួយ ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាដែលដឹកនាំរាជរដ្ឋាភិបាល ។

៩.២.២ គ.ជ.ប ត្រូវបង្កើតក្រុមកំណត់បែងចែកអាសនៈនៃ គ.ជ.ប ដើម្បីផ្ទៀងផ្ទាត់ទិន្នន័យសំឡេងឆ្នោត បែងចែកអាសនៈ និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្ររួចដាក់ជូន គ.ជ.ប តាមរយៈអគ្គលេខាធិការដើម្បីពិនិត្យសម្រេច ។

៩.២.៣ នៅមុនការបែងចែកអាសនៈ ដែលនៅទំនេរតាមករណីដូចខាងលើ គ.ជ.ប ត្រូវធ្វើលិខិតជាផ្លូវការទៅគណបក្សនយោបាយនានា ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងរាជធានី ខេត្តជាមួយ លើកលែងតែគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ

ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងគណបក្សនយោបាយ មានអាសនៈក្នុងរដ្ឋសភាដែលដឹកនាំរាជរដ្ឋាភិបាល ដើម្បីសម្របសម្រួល និងកំណត់បញ្ហាមួយចំនួនដូចខាងក្រោម ។

ទី១-ការពិនិត្យបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួន ដែលត្រូវបានយល់ព្រមដោយ គ.ជ.ប ឱ្យចុះបញ្ជីក្នុងនីតិកាលនៃរដ្ឋសភា ដោយត្រូវលុបចេញឈ្មោះបេក្ខជនដែល ៖

- ទទួលមរណភាព ឬ
- បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ឬ
- លាឈប់ជាលាយលក្ខណ៍អក្សរ ឬ
- ត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ ឬ
- បាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

ទី២-ករណីគណបក្សនយោបាយណាមួយពុំបានឆ្លើយតបតាមលិខិតផ្លូវការរបស់ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៤ (បួន)ថ្ងៃ តាមកាលបរិច្ឆេទកំណត់ដោយ គ.ជ.ប នោះ ចាត់ទុកថាគណបក្សនយោបាយនោះ បានយល់ព្រមរក្សាទុកជាបានការនូវបញ្ជីបេក្ខជននៃគណបក្សនយោបាយរបស់ខ្លួន ដែលត្រូវបានយល់ព្រមឱ្យចុះបញ្ជីក្នុងនីតិកាលរដ្ឋសភា ។

ប្រការ ៩.៣.-

ការបែងចែកអាសនៈដែលនៅទំនេរត្រូវអនុវត្តតាមករណី និងជំហានទាំងឡាយដូចខាងក្រោម។

៩.៣.១ ករណីដូចមានចែងក្នុងចំណុច ៩.២.១ នៃប្រការ ៩.២ ខាងលើ ការបែងចែកអាសនៈដែលនៅទំនេរត្រូវអនុវត្តតាមជំហានទាំងឡាយដូចខាងក្រោម ៖

ជំហានទីមួយ : កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួល ១ (មួយ) អាសនៈ

៩.៣.១.១ ការកំណត់ចំនួនកូតាត្រូវអនុវត្តតាមរូបមន្តខាងក្រោម ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ ៖

- $ក'_{ត}$: តាងឱ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក។

- $ស'_{ស}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឱ្យគណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ និងដកចេញនូវសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យគណបក្សនយោបាយមានអាសនៈក្នុងរដ្ឋសភាដែលដឹកនាំរាជរដ្ឋាភិបាល។
- $អ'_{ប}$: តាងឱ្យអាសនៈដែលនៅទំនេរក្នុងរាជធានី ខេត្ត។

<u>**ឧទាហរណ៍**</u>

នៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** មានអាសនៈចំនួន ៦ មានគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតចំនួន ៧ ដែលក្នុងនោះ ៖

- គណបក្សនយោបាយ	**ក**	មាន	$ស_{ប}ក$	១២០.៦២២	ទទួលបាន	៣ អាសនៈ
- គណបក្សនយោបាយ	**ខ**	មាន	$ស_{ប}ខ$	១១១.៩៦៣	ទទួលបាន	៣ អាសនៈ
- គណបក្សនយោបាយ	**គ**	មាន	$ស_{ប}គ$	២.១៥៣	ទទួលបាន	០ អាសនៈ
- គណបក្សនយោបាយ	**ឃ**	មាន	$ស_{ប}ឃ$	១៤.៥៣២	ទទួលបាន	០ អាសនៈ
- គណបក្សនយោបាយ	ង	មាន	$ស_{ប}ង$	២.១១៦	ទទួលបាន	០ អាសនៈ
- គណបក្សនយោបាយ	**ច**	មាន	$ស_{ប}ច$	៣៧.២៥០	ទទួលបាន	០ អាសនៈ
- គណបក្សនយោបាយ	**ឆ**	មាន	$ស_{ប}ឆ$	៧.២៦៦	ទទួលបាន	០ អាសនៈ

ករណីគណបក្ស ខ បានបោះបង់ចោលអាសនៈ ឬត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ អនុវត្តតាមចំណុច ៩.២.១ ខាងលើ អាសនៈដែលទំនេរចំនួន ៣ (បី) នេះ ត្រូវបែងចែកឱ្យទៅបញ្ជីបេក្ខជននៃគណបក្ស **គ ឃ ង ច** និង **ឆ** ដែលបានចូលរួមក្នុងការបោះឆ្នោតនៅខេត្តនោះ ។

ដូចនេះអនុវត្តតាមរូបមន្តក្នុងចំណុច ៩.៣.១.១ ខាងលើ យើងកំណត់កូតាដែលតម្រូវឱ្យទទួលបានអាសនៈដែលទំនេរ ១ (មួយ) អាសនៈ ៖

$ស'_{ប}$ = (១២០.៦២២+១១១.៩៦៣+២.១៥៣+១៤.៥៣២+២.១១៦+៣៧.២៥០+៧.២៦៦) - (១២០.៦២២ + ១១១.៩៦៣) = ៦៣.៣១៧

$អ'_{ប}$ = ៣

$$ក'_{ត} = \frac{ស'_{ប}}{អ'_{ប}} = \frac{៦៣.៣១៧}{៣} = \underline{\underline{២១.១០៥}}$$

ក្លូតាស្មើនឹង ២១.១០៥ ។

ជំហានទីពីរ : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួល

៩.៣.១.២ ការកំណត់ចំនួនអាសនៈជាបឋមដែលគណបក្សនយោបាយនីមួយៗបានទទួលត្រូវអនុវត្តតាមរូបមន្តខាងក្រោម ៖

$$អ'_{ទ} = \frac{ស_{ប}}{ក'_{ត}}$$

ក្នុងនោះ ៖

- $អ'_{ទ}$: តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងរាជធានីខេត្តបានទទួល មុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទីបី។
- $ស_{ប}$: តាងឱ្យសន្លឹកឆ្នោតបានការសរុបបោះឱ្យគណបក្សនយោបាយមួយក្នុងរាជធានីខេត្ត ។
- $ក'_{ត}$: តាងឱ្យចំនួនក្លូតាដែលបានកំណត់ក្នុងជំហានទីមួយ ។

<u>ឧទាហរណ៍</u>

ការបែងចែកអាសនៈដែលទំនេរលើកទី ១ នៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** ដដែល ។ អនុវត្តតាមការបែងចែកអាសនៈដែលទំនេរលើកទី ១ តាមរូបមន្តក្នុងជំហានទីពីរ ចំណុច ៩.៣.១.២ យើងបាន ៖

គណបក្សនយោបាយ	**ค**	$អ'_{ទ}ค$	=	$\frac{២.១៥៣}{២១.១០៥}$	=	0,90
គណបក្សនយោបាយ	**ย**	$អ'_{ទ}ย$	=	$\frac{១៤.៥៣២}{២១.១០៥}$	=	0,68
គណបក្សនយោបាយ	**ง**	$អ'_{ទ}ง$	=	$\frac{២.១១៦}{២១.១០៥}$	=	0,90
គណបក្សនយោបាយ	**จ**	$អ'_{ទ}จ$	=	$\frac{៣៧.២៥០}{២១.១០៥}$	=	1,76

$$\text{គណបក្សនយោបាយ} \quad ឆ \quad អ'_{ទ}ឆ = \frac{๗.๒๖๖}{๒๑.๑๐๕} = ๐,๓๔$$

តាមលទ្ធផលនៃការគណនាខាងលើ គណបក្សនយោបាយ ច ទទួលបាន ១ (មួយ) អាសន: រីងគណបក្ស **ត យ ង** និង **ឆ** ពុំទទួលបានអាសន:ដែលទំនេរនេះទេ ។ បន្ទាប់ពីការបែងចែកអាសន:ដែលទំនេរលើកទី ១ តាមរូបមន្តជំហានទីពីរ ឃើញថាមាននៅសល់អាសន:ចំនួន ២ (ពីរ) ដែលត្រូវបែងចែកទៀត ។ ដូចនេះអាសន:ទាំងនោះត្រូវយកមកបែងចែកបន្តទៀតដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តដូចខាងក្រោម ៖

ជំហានទីបី : ការកំណត់មធ្យមភាគខ្ពស់បំផុត និងការបែងចែកអាសន:ដែលទំនេរ (លើកទី ២)

៩.៣.១.៣ ដើម្បីកំណត់មធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ ត្រូវធ្វើការគណនា ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួល ចែកនឹងចំនួនអាសន:ដែលគណបក្សនយោបាយមួយបានទទួលបន្ទាប់ពីការបែងចែកអាសន:ដែលទំនេរលើកទី ១ បូកនឹងលេខនិមិត្តចំនួន ១ តាមរូបមន្តខាងក្រោម ៖

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ទ} + ១}$$

ក្នុងនោះ

- $ម'_{ធ}$: តាងឱ្យមធ្យមភាគខ្ពស់បំផុត ។
- $ស_{ប}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។
- $អ'_{ទ}$: តាងឱ្យចំនួនអាសន: ដែលបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។
- ១ : ជាលេខនិមិត្ត ។

៩.៣.១.៤ ការរកមធ្យមភាគរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ត្រូវគណនាឱ្យដល់ចំនួន ២ (ពីរ) ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់គណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ ។

៩.៣.១.៥ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗរួចមក ត្រូវធ្វើការប្រៀបធៀបគ្នា ។ គណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត (គិតដល់ចំនួន ២ (ពីរ) ខ្ទង់ក្រោយក្បៀស) នឹងត្រូវទទួលបានអាសន: ១ (មួយ) ។

<u>ឧទាហរណ៍</u>

ការបែងចែកអាសន:ដែលទំនេរ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតនៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** ដដែល ។

បន្ទាប់ពីការបែងចែកអាសន:ដែលទំនេរ (លើកទី ១) តាមរូបមន្តជំហានទីពីរ រួចមកឃើញថាមាននៅសល់អាសន:ចំនួន ២ (ពីរ) ត្រូវបែងចែកបន្ត ។

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទីបី យើងបាន ៖

គណបក្សនយោបាយ	**ត**	ម'ធ$_{ត}$	=	$\frac{\text{២.១៥៣}}{\text{0+១}}$	= ២.១៥៣,00
គណបក្សនយោបាយ	**ឃ**	ម'ធ$_{ឃ}$	=	$\frac{\text{១៤.៥៣១}}{\text{0+១}}$	= ១៤.៥៣១,00
គណបក្សនយោបាយ	**ង**	ម'ធ$_{ង}$	=	$\frac{\text{២.១១៦}}{\text{0+១}}$	= ២.១១៦,00
គណបក្សនយោបាយ	**ច**	ម'ធ$_{ច}$	=	$\frac{\text{៣៧.២៥0}}{\text{១+១}}$	= <u>**១៨.៦២៥,00**</u>
គណបក្សនយោបាយ	**ឆ**	ម'ធ$_{ឆ}$	=	$\frac{\text{៧.២៦៦}}{\text{0+១}}$	= ៧.២៦៦,00

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងប្រាំខាងលើ គណបក្ស **ច** មានមធ្យមភាគធំជាងគេគឺ <u>**១៨.៦២៦៥,00**</u> ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះបញ្ជីបេក្ខជននៃគណបក្ស ច ត្រូវទទួលបានអាសន:ដែលទំនេរចំនួន ១(មួយ) ក្នុងការបែងចែកលើកនេះ ។

៩.៣.១.៦ ប្រសិនបើមាននៅសល់អាសន:ទៀត អាសន:ដែលនៅសល់នោះ ត្រូវបន្តបែងចែកម្តងមួយអាសន:ៗ រហូតដល់អស់អាសន:តាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទីបីដដែល ដោយត្រូវបង្កើនតម្លៃ អ$_{ទ}$ ចំនួន ១ (មួយ) ចំពោះគណបក្សនយោបាយណាដែលទើបទទួលបានអាសន:បន្ថែមចំនួន ១ (មួយ) ។

ឧទាហរណ៍

អនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទីបី យើងបាន ៖

គណបក្សនយោបាយ	សប	អ'ទ លើកទី១	ម'ធ ១		អ'ទ លើកទី២	ម'ធ ២		អ'ទ លើកទី៣
ត	២.១៥៣	០	២.១៥៣ / ០+១	= ២.១៥៣	០	២.១៥៣ / ០+១	= ២.១៥៣	០
យ	១៤.៥៣១	០	១៤.៥៣១ / ០+១	= ១៤.៥៣១	០	១៤.៥៣១ / ០+១	= ១៤.៥៣១	១
ង	២.១១៦	០	២.១១៦ / ០+១	= ២.១១៦	០	២.១១៦ / ០+១	= ២.១១៦	០
ច	៣៧.២៥០	១	៣៧.២៥០ / ១+១	= ១៨.៦២៥	១	៣៧.២៥០ / ២+១	= ១២.៤១៦,៦៦	០
ឆ	៧.២៦៦	០	៧.២៦៦ / ០+១	= ៧.២៦៦	០	៧.២៦៦ / ០+១	= ៧.២៦៦	០

តាមឧទាហរណ៍ក្នុងតារាងខាងលើ ៖

- **សប** : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។
- **អ'ទ** : (លើកទី១) តាងឱ្យចំនួនអាសន:ដែលគណបក្សនយោបាយមួយទទួលបានក្នុងការបែងចែកក្នុងជំហានទីពីរ ដែលបង្ហាញថា គណបក្ស ច បានទទួល ១ (មួយ) អាសន:។
- **ម'ធ ១** : តាងឱ្យលទ្ធផលនៃការគណនាមធ្យមភាគលើកទី ១ (ការបែងចែកអាសន:លើកទី២) សម្រាប់គណបក្សនយោបាយនីមួយៗ ដែលលទ្ធផលបង្ហាញថា គណបក្ស ច មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- **អ'ទ** : (លើកទី២) គណបក្ស ច ទទួលបាន ១ (មួយ) អាសន: ។
- **ម'ធ២** : លទ្ធផលបង្ហាញថា គណបក្ស **យ** មធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- **អ'ទ** : (លើកទី៣) គណបក្ស **យ** ទទួលបាន ១ (មួយ) អាសន: ។

ក្នុងការបែងចែកអាសន:ដែលទំនេរ ក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** គឺគណបក្ស **យ** បានទទួល ១ អាសន: និង គណបក្ស ច បានទទួល ២ អាសន:។

បន្ទាប់ពីការបែងចែកអាសន:ដែលទំនេរ នៅក្នុងមណ្ឌលបោះឆ្នោតនៃខេត្ត **A** យើងបាន ៖

គណបក្សនយោបាយ	ក	បានទទួលអាសន:	៣
គណបក្សនយោបាយ	គ	បានទទួលអាសន:	០
គណបក្សនយោបាយ	ឃ	បានទទួលអាសន:	១
គណបក្សនយោបាយ	ង	បានទទួលអាសន:	០
គណបក្សនយោបាយ	ច	បានទទួលអាសន:	២
គណបក្សនយោបាយ	ឆ	បានទទួលអាសន:	០

៩.៣.២ ក្នុងករណីគណនាតាមរូបមន្តដូចចែងក្នុងចំណុច ៩.៣.១.៣ ខាងលើ មានគណបក្ស ពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នាដែលមិនអាចកំណត់បែងចែកអាសន: ដែលនៅ សល់ ទៅឱ្យគណបក្សនយោបាយណាមួយបាន អាសន:នោះត្រូវផ្តល់ជូនទៅ គណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ ។ ក្នុង ករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសន: ដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែល កំណត់ដោយបទបញ្ជា និងនីតិវិធីនេះ ។

៩.៣.៣ ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសន:បន្ថែមមួយ ឬច្រើន ប៉ុន្តែ បញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសន:នោះ គ.ជ.ប ត្រូវស្នើជាលាយ លក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេល យ៉ាងយូរ ៥ (ប្រាំ) ថ្ងៃ ក្រោយពីបានទទួលសំណើ ។ បែបបទនៃការទទួលពិនិត្យ និងការអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុង មាត្រា២៣ មាត្រា២៤ មាត្រា២៥ មាត្រា២៦ មាត្រា២៨ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ និងមាត្រា៣៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាង រាស្ត្រ និងនីតិវិធីនៃការដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែម ដូចបានកំណត់ខាងក្រោម។

៩.៣.៣.១ ដើម្បីដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែម គណបក្សនយោបាយដូចមាន ចែងក្នុងចំណុច ៩.៣.៣ ខាងលើ ត្រូវធ្វើពាក្យសុំតាមបែបបទដែល កំណត់ដោយ គ.ជ.ប ។ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះ បញ្ជីបេក្ខជនបន្ថែមជាពីរ (២) ច្បាប់។ ពាក្យសុំត្រូវចុះហត្ថលេខាដោយ ប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិ ជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។ ការផ្ទេរ

សិទ្ធិបន្តត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រធានគណបក្ស
នយោបាយ ។ ពាក្យសុំចុះបញ្ជីនេះ ត្រូវភ្ជាប់ជាមួយនូវ ៖

- ឈ្មោះមណ្ឌលដែលគណបក្សនយោបាយ ត្រូវចុះបញ្ជីបេក្ខជនបន្ថែម និងបញ្ជីបេក្ខជនបន្ថែមឈរឈ្មោះតាមមណ្ឌលទាំងនោះ។
- បញ្ជីបេក្ខជនបន្ថែមឈរឈ្មោះតាមមណ្ឌល ត្រូវមានបេក្ខជនយ៉ាងតិចស្មើនឹងចំនួនអាសនៈនៅក្នុងមណ្ឌលនោះ ។

៩.៣.៣.២ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបន្ថែម ពលរដ្ឋម្នាក់ៗត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត ។
- មានអាយុម្ភៃប្រាំ (២៥) ឆ្នាំឡើងទៅ គិតដល់ថ្ងៃដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែម ។
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។
- មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៩.៣.៣.៣ គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺ ៖

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា ឬ
- ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ
- ជនដែលត្រូវផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត
- ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ
- ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោតដោយ គ.ជ.ប ឬ
- សមាជិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ

- សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

៩.៣.៣.៤ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនា ដែលមានបំណងឈរឈ្មោះបេក្ខជនបន្ថែម ប្រសិនបើជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមហានានុក្រមទៅក្រសួង ឬអង្គភាពរបស់ខ្លួនទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីជនត្រូវមានសិទ្ធិឡើងឋានន្តរស័ក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារ សម្រាប់ទទួលសោធននិវត្តន៍ ។ នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

៩.៣.៣.៥ គណបក្សនយោបាយ ដែលបានតែងតាំងបេក្ខជនបន្ថែម ត្រូវបំពេញបែបបទសេចក្តីប្រកាសបេក្ខភាពដែលផ្តល់ដោយ គ.ជ.ប ។ បញ្ជីបេក្ខជនបន្ថែមតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗត្រូវ ៖

- ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។
- មានសេចក្តីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត ។
- ភ្ជាប់សេចក្តីប្រកាសរបស់បេក្ខជន យល់ព្រមទទួលការតែងតាំងជាបេក្ខជនតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗរបស់គណបក្សនយោបាយ ។

៩.៣.៣.៦ គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែមជាបន្ទាន់ សមស្រប បន្ទាប់ពីថ្ងៃទទួលបានពាក្យសុំ ។

- ក្នុងករណីយល់ព្រមលើបញ្ជីបេក្ខជនបន្ថែម គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនបន្ថែមជូនគណបក្សនយោបាយ ។
- ប្រសិនបើបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនណាមួយត្រូវបានបដិសេធ ស្របតាមចំណុច ៩.៣.៣.២ ៩.៣.៣.៣ ៩.៣.៣.៤ និងចំណុច ៩.៣.៣.៥ ខាងលើ គ.ជ.ប ត្រូវ ៖

- ▪ បំពេញបែបបទបដិសេធបេក្ខភាព ឬបញ្ជីបេក្ខជនបន្ថែម ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្ដីសម្រេចបដិសេធចំនួនបី (៣) ច្បាប់ រួចផ្ញើជូនសាមីខ្លួន និងសាមីគណបក្សនយោបាយមួយ (១) ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញមួយ (១) ច្បាប់ និងរក្សាទុកឯកសារមួយ (១) ច្បាប់ ។
- ▪ ផ្ដល់ព័ត៌មានទៅសាមីខ្លួន ឬសាមីគណបក្សនយោបាយថា គាត់អាចប្ដឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរប្រាំ (៥) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធ។

៩.៣.៣.៧ បេក្ខភាពណាដែលត្រូវបានបដិសេធ ឬបញ្ជីបេក្ខជនបន្ថែមរបស់គណបក្សនយោបាយណាដែលត្រូវបានបដិសេធដោយ គ.ជ.ប សាមីខ្លួន ឬសាមីគណបក្សនយោបាយ ឬតំណាង អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្ដីសម្រេចបដិសេធ ។

- ក្នុងករណីទទួលសេចក្ដីសម្រេចបដិសេធ និងទម្រង់បែបបទសម្រាប់ប្ដឹងតវ៉ាហើយ ប៉ុន្តែសាមីគណបក្ស ឬតំណាង ពុំបានដាក់ពាក្យប្ដឹងតវ៉ាទៅតាមពេលវេលា ដូចចែងក្នុងចំណុច ៩.៣.៣.៧ ទេនោះ ត្រូវចាត់ទុកថាមិនបានប្ដឹងតវ៉ា ។
- ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្ដឹង។

៩.៣.៣.៨ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមលើពាក្យបណ្ដឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្ដីសម្រេចយល់ព្រម និងជូនដំណឹងទៅអ្នកប្ដឹងតវ៉ា ហើយបង្គាប់ឱ្យ គ.ជ.ប ចុះបញ្ជីបេក្ខជនបន្ថែមជូនសាមីគណបក្សនយោបាយជាបន្ទាន់ ។

- បន្ទាប់ពីបានទទួលសេចក្ដីសម្រេចពីក្រុមប្រឹក្សាធម្មនុញ្ញ គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីបេក្ខជនបន្ថែម ។
- គ.ជ.ប ត្រូវផ្ញើលិខិតបញ្ជាក់នេះ ១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

៩.៣.៣.៩ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធបណ្ដឹងតវ៉ា សេចក្ដីសម្រេចនេះ គឺជាសេចក្ដីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

- ផ្តល់សេចក្តីសម្រេចបដិសេធនេះ ១ (មួយ) ច្បាប់ ទៅសាមីគណបក្ស នយោបាយ ឬតំណាង ។
- ផ្ញើសេចក្តីសម្រេចបដិសេធ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ។

៩.៣.៣.១០ ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាដូចចែងក្នុងចំណុច ៩.៣.៣ ខាងលើ ដែលធ្វើឱ្យគណបក្ស នយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះ បោះបង់ចោលអាសនៈឱ្យ នៅទំនេរ ។ ករណីនេះ គ.ជ.ប ត្រូវបែងចែកអាសនៈដែលនៅទំនេរ នេះ តាមបទប្បញ្ញត្តិនៃបទបញ្ជា និងនីតិវិធីនេះ ។

៩.៣.៤ ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈ ដែលនៅទំនេររបស់គណ បក្សនយោបាយដែលប្រកាសបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពី បញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបែងចែកអាសនៈដែលនៅទំនេរនោះឱ្យ ទៅគណបក្សនយោបាយដែលមានអាសនៈនៅក្នុងរដ្ឋសភា តាមបទប្បញ្ញត្តិដូចមាន ចែងក្នុងបទបញ្ជា និងនីតិវិធីនេះ ។

ការជ្រើសតាំងជំនួស

ប្រការ ៩.៤.-

ក្នុងករណីមានសមាជិករដ្ឋសភាត្រូវបាត់បង់សមាជិកភាពក្នុងរយៈពេល ៦ (ប្រាំមួយ) ខែ យ៉ាងតិចមុនចប់នីតិកាលនៃរដ្ឋសភា សាមីគណបក្សនយោបាយអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួស តាមកំណត់ច្បាប់ ដោយមិនបាច់បោះឆ្នោតឡើងវិញឡើយ ។

៩.៤.១ សមាជិករដ្ឋសភា ត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយ ដូច ខាងក្រោម ៖

- សាមីខ្លួនទទួលមរណភាព។
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមាន សមត្ថកិច្ច។
- សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា។
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

៩.៤.២ កាលបើសមាជិករដ្ឋសភារូបណាមួយត្រូវបាត់បង់សមាជិកភាពមានរយៈពេល ៦ (ប្រាំមួយ) ខែយ៉ាងតិចមុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជន ដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ។

ជំពូកទី១០
នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ
និងសមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច និងសវនាការដោះស្រាយពាក្យបណ្តឹង

ផ្នែកទី១
នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹង
ចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ

ប្រការ ១០.១.-

បទប្បញ្ញត្តិនៃផ្នែកនេះ កំណត់អំពីនីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងចំពោះគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ នៃ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្រព្រឹត្តដោយជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬប្រព្រឹត្តដោយគណបក្សនយោបាយ ឬប្រព្រឹត្តដោយជនដែលជាមន្ត្រីបោះឆ្នោតដែលអាចនាំឱ្យមានការជាកពិន័យ និងដែលអាចកើតឡើងនៅគ្រប់ដំណាក់កាលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ រួមទាំងនៅមួយថ្ងៃមុនថ្ងៃបោះឆ្នោត និងនៅថ្ងៃបោះឆ្នោតផង ។

ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយ

ប្រការ ១០.២.-

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិដាក់ពាក្យបណ្តឹងចំពោះជនដែលមិនមែនជាមន្ត្រីបោះឆ្នោត ឬគណបក្សនយោបាយទៅ គយ.សប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។ អ្នកប្តឹង ឬតំណាងអាចបន្តប្តឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬផ្សះផ្សានៅ គយ.សប ឬបន្តប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ឬបន្តប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គ.ជ.ប ។ ពាក្យបណ្តឹងត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួនដូចចែងក្នុងចំណុច ១០.៦.៥ នៃផ្នែកទី២ ។

នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គយ.សប

ការដាក់ ការទទួលពាក្យបណ្តឹងនៅ គយ.សប

១០.២.១ អ្នកប្តឹង ត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់ ។ អ្នកប្តឹងដំបូងអាចថតចម្លងទម្រង់បែបបទដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ទិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹង ឬតវ៉ាជូនខ្លួនបាន។

១០.២.២ នៅពេលបានទទួលពាក្យបណ្តឹង សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទិ៍ ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង ទី២ កម្មវត្ថុនៃបណ្តឹង និងការគោរពរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ។

១០.២.៣ បន្ទាប់មកសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងនោះ ផ្ទិតមេដៃ ឬចុះហត្ថលេខា លើកំណត់ហេតុ ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្ទិតមេដៃ ឬចុះហត្ថលេខា សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ទិតមេដៃ ឬចុះហត្ថលេខាលើកំណត់ហេតុនេះ ។

១០.២.៤ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុ ហើយឃើញថា ៖

- ពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃកើតហេតុ ប្រធាន គយ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា សរសេរឈ្មោះ ពោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។
- ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចចែងក្នុងចំណុច ១០.៦.៥ ផ្នែកទី២ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គយ.សប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា សរសេរឈ្មោះ ពោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។

- ពាក្យបណ្តឹងគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ និងមានព័ត៌មានចាំបាច់ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា និងបោះត្រា គយ.សប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

ការដោះស្រាយពាក្យបណ្តឹងនៅ គយ.សប

១០.២.៥ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គយ.សប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើបណ្តឹង។ ក្នុងករណី គយ.សប ពិនិត្យ និងយល់ឃើញថា ៖

- ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើ ច.ប.ត.រ ឬ ប.ន.ត.រ ឬ បទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គយ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- កម្មវត្ថុ និងមូលហេតុនៃបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើ ច.ប.ត.រ គយ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គយ.សប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវ ដែលអាចមានសមាសភាពដូចខាងក្រោម ៖
  - ប្រធាន គយ.សប ឬតំណាងជាប្រធានក្រុម
  - សមាជិក គយ.សប ១ (មួយ) នាក់ ជាសមាជិក
  - សមាជិក គយ.សប ១ (មួយ) នាក់ ជាលេខាធិការ។

១០.២.៦ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្តឹង ឬតំណាង ។

១០.២.៧ បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើ ច.ប.ត.រ និង ប.ន.ត.រ គយ.សប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាល ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គយ.សប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

១០.២.៨ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើ ច.ប.ត.រ និង ប.ន.ត.រ គយ.សប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មកធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់កំណត់ដោយ គយ.សប ។

១០.២.៩ គយ.សប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យគូភាគីផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ ។

១០.២.១០ ក្នុងការផ្សះផ្សា ប្រសិនបើគូភាគីទំនាស់ ៖

- ព្រមព្រៀងគ្នា គយ.សប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថាភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គធ.ខប ពាក់ព័ន្ធ ។
- មិនព្រមព្រៀងគ្នាទេ គយ.សប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថាភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ ។ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គធ.ខប ពាក់ព័ន្ធ ទោះបីភាគីណាមួយ

មិនព្រមផ្ដិតមេដៃក៏ដោយ ។ គយ.សប ត្រូវប្រាប់ភាគីថា ភាគីណាមួយមិនសុខចិត្តនឹងលទ្ធផលនៃការផ្សះផ្សា អាចដាក់ពាក្យបណ្ដឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សារួច។

១០.២.១១ គយ.សប ត្រូវបើកការប្រជុំផ្សះផ្សាចំពោះរាល់ពាក្យបណ្ដឹងគ្រប់អំពើបំពានលើបទប្បញ្ញត្តិនៃជំពូកទី១០ (ទោសប្បញ្ញត្តិ) នៃ ច.ប.ត.រ ប៉ុន្តែមិនមានអំណាចបើកអង្គប្រជុំសម្រេច និងចេញ ទ.១២០៣ ឡើយ ។

១០.២.១២ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គយ.សប ត្រូវអនុវត្ត តាមលក្ខខណ្ឌដូចក្នុងផ្នែកទី២ នៃជំពូកទី១០ នេះ ។

នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹងនៅ គធ.ខប

ការដាក់ ការទទួលពាក្យបណ្ដឹងនៅ គធ.ខប

១០.២.១៣ ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬការផ្សះផ្សានៅថ្នាក់ គយ.សប ហើយដែលមានបំណងប្ដឹងទៅ គធ.ខប អាចប្ដឹងទៅ គធ.ខប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា ។

១០.២.១៤ អ្នកប្ដឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់ ។

១០.២.១៥ នៅពេលបានទទួលពាក្យបណ្ដឹង សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួនជាអាទ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្ដឹង ឬតំណាង ទី២ កម្មវត្ថុនៃបណ្ដឹង និងការគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា ។

១០.២.១៦ បន្ទាប់មកសមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធ្វើកំណត់ហេតុសួរយកព័ត៌មានបន្ថែមពីអ្នកប្ដឹង ឬតំណាងដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់រួចឱ្យអ្នកប្ដឹង ឬតំណាងនោះចុះហត្ថលេខា ឬផ្ដិតមេដៃលើកំណត់ហេតុ។ ក្នុងករណីអ្នកប្ដឹង ឬតំណាងមិនព្រមផ្ដិតមេដៃ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនេះ ។

๑๐.๒.๑๗ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុ ហើយឃើញថា ៖

- ពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៣ (បី) ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។
- ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចចែងក្នុងចំណុច ១០.៦.៥ ផ្នែកទី២ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាង ឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត ប្រធាន គធ.ខប ឬសមាជិកដែលបានទទួលសិទ្ធិជាលាយលក្ខណ៍អក្សរ ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ ដោយបញ្ជាក់ពីមូលហេតុ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។
- ពាក្យបណ្តឹងគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬថ្ងៃផ្សះផ្សា និងមានព័ត៌មានចាំបាច់ សមាជិកទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទ ពេលវេលា ហើយចុះហត្ថលេខា សរសេរឈ្មោះ និងបោះត្រា គធ.ខប លើពាក្យបណ្តឹងគ្រប់ច្បាប់ រួចត្រូវប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកក្នុងពេលប្រជុំផ្សះផ្សា ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

ការដោះស្រាយពាក្យបណ្តឹងនៅ គធ.ខប

๑๐.๒.๑๘ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គធ.ខប ត្រូវប្រជុំពិភាក្សាដើម្បីពិនិត្យជាបន្ទាន់លើបណ្តឹង។ ក្នុងករណី គធ.ខប ពិនិត្យ និងយល់ឃើញថា ៖

- ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ប.ន.ត.រ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- កម្មវត្ថុ និងមូលហេតុនៃបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- ពាក្យបណ្តឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នាហើយនៅថ្នាក់ គយ.សប គធ.ខប ត្រូវពិនិត្យសម្រេចថា ត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ ។ ក្នុងករណីបដិសេធ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ បោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ គធ.ខប ត្រូវបង្កើតក្រុមត្រួតពិនិត្យ និងស្រាវជ្រាវដែលអាចមានសមាសភាពដូចខាងក្រោម ៖
  - ប្រធាន គធ.ខប ឬតំណាងជាប្រធានក្រុម
  - សមាជិក គធ.ខប ១ (មួយ) នាក់ ជាសមាជិក
  - មន្ត្រីសេវាកម្មច្បាប់ និងវិវាទកម្ម ១ (មួយ) នាក់ ជាលេខាធិការ ។

១០.២.១៩ ក្រុមត្រួតពិនិត្យ និងស្រាវជ្រាវត្រូវបើកការស៊ើបអង្កេតជាបន្ទាន់ ដោយសហការយ៉ាងជិតស្និទ្ធជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត និងអាជ្ញាធរពាក់ព័ន្ធនានា

ដើម្បីចុះពិនិត្យ និងកត់ត្រាកំណត់ហេតុដល់ទីកន្លែងកើតហេតុ ប្រមូលភស្តុតាង សាកសួរសាក្សី និងជនដែលពាក់ព័ន្ធក្នុងពាក្យបណ្តឹង ។ ប្រធានក្រុមត្រួតពិនិត្យ និងស្រាវជ្រាវនេះ អាចស្នើសុំ និងអនុញ្ញាតឱ្យអ្នកប្តឹង ឬតំណាងអមដំណើរជាមួយ បើមានការយល់ព្រមពីអ្នកប្តឹង ឬតំណាង ។

១០.២.២០ បន្ទាប់ពីក្រុមត្រួតពិនិត្យ និងស្រាវជ្រាវស៊ើបអង្កេតចប់សព្វគ្រប់ហើយ លទ្ធផលបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់នោះមិនបានបំពានលើ ច.ប.ត.រ និង ប.ន.ត.រ គធ.ខប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ហើយចុះហត្ថលេខា សរសេរឈ្មោះ ចុះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

១០.២.២១ ក្នុងករណីលទ្ធផលនៃការស៊ើបអង្កេតបង្ហាញថា ជនដែលត្រូវគេប្តឹងចោទប្រកាន់បានបំពានលើ ច.ប.ត.រ ប.ន.ត.រ ឬបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប គធ.ខប ត្រូវអញ្ជើញភាគីទំនាស់ទាំងអស់មក ធ្វើការផ្សះផ្សាតាមថ្ងៃ និងពេលវេលាសមស្របជាបន្ទាន់ កំណត់ដោយ គធ.ខប ។

១០.២.២២ គធ.ខប ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ដោយឱ្យគូភាគីផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ ។

១០.២.២៣ ក្នុងការផ្សះផ្សា ប្រសិនបើគូភាគីទំនាស់ ៖

- ព្រមព្រៀងគ្នា គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់យល់ព្រមសះជានឹងគ្នា ដោយឱ្យភាគីទំនាស់ផ្តិតមេដៃលើកំណត់ហេតុផ្សះផ្សានោះ បន្ទាប់មកត្រូវបញ្ជូនកំណត់ហេតុផ្សះផ្សានោះជាបន្ទាន់មក គ.ជ.ប។
- មិនព្រមព្រៀងគ្នាទេ គធ.ខប ត្រូវកត់ត្រាក្នុងកំណត់ហេតុផ្សះផ្សានោះឱ្យបានច្បាស់ថា ភាគីទំនាស់មិនព្រមសះជានឹងគ្នាទេ ។ គធ.ខប ត្រូវកំណត់ពេលវេលា និងកាលបរិច្ឆេទបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១ (មួយ) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីពេលវេលា កាលបរិច្ឆេទ និងទីកន្លែងបើកសវនាការតែម្តង ។

១០.២.២៤ គធ.ខប ត្រូវបើកសវនាការជាសាធារណៈសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយមានកំណត់ហេតុសវនាការ សេចក្តីសម្រេច និង ទ.១២០៣ ចំនួន ៥ (ប្រាំ) ច្បាប់ ដោយមានការចុះហត្ថលេខារបស់លេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយបោះត្រា គធ.ខប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ប្រគល់ជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១០.២.២៥ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះ នៃ គធ.ខប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងផ្នែកទី២ នៃជំពូកទី ១០ នេះ ។

នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

ការដាក់ ការទទួលពាក្យបណ្តឹងនៅ គ.ជ.ប

១០.២.២៦ ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គធ.ខប អាចប្តឹងទៅ គ.ជ.ប ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

១០.២.២៧ អ្នកប្តឹង ឬតំណាងត្រូវបំពេញ ទ.១២០២ ចំនួន ៤ (បួន) ច្បាប់ ។

១០.២.២៨ នៅពេលបានទទួលពាក្យបណ្តឹង មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវពិនិត្យជាសំខាន់លើព័ត៌មានចាំបាច់មួយចំនួន ជាអាទ៍ទី១ ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង ទី២ កម្មវត្ថុនៃបណ្តឹង និងការគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប ។

១០.២.២៩ បន្ទាប់មកមន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវធ្វើកំណត់ហេតុសាកសួរយកព័ត៌មានបន្ថែមពីអ្នកប្តឹង ឬតំណាង ដោយត្រូវកត់ត្រាឱ្យបានច្បាស់លាស់ រួចឱ្យអ្នកប្តឹង ឬតំណាងផ្តិតមេដៃលើកំណត់ហេតុសាកសួរនោះ ។ ក្នុងករណីអ្នកប្តឹង ឬតំណាងមិនព្រមផ្តិតមេដៃ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមផ្តិតមេដៃលើកំណត់ហេតុនេះ ។

១០.២.៣០ បន្ទាប់ពីបានពិនិត្យលើពាក្យបណ្តឹង និងកំណត់ហេតុ ហើយឃើញថា ៖

- ពាក្យបណ្តឹងមិនគោរពអំឡុងពេលកំណត់នៃការដាក់ពាក្យបណ្តឹង ៣ (បី) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ព្រមទាំងចុះហត្ថលេខា ពោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។
- ពាក្យបណ្តឹងមិនមានបញ្ជាក់ព័ត៌មានចាំបាច់ដូចចែងក្នុងចំណុច ១០.៦.៥ នៃផ្នែកទី២ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មត្រូវណែនាំអ្នកប្តឹង ឬតំណាងឱ្យបំពេញបន្ថែមនូវចំណុចខ្វះខាត ដោយមិនឱ្យហួសពេលកំណត់នៃការដាក់ពាក្យបណ្តឹង ហើយកត់ត្រាបន្ថែមក្នុងកំណត់ហេតុសាកសួរ ។ ក្នុងករណីដែលដល់ពេលកំណត់ អ្នកប្តឹង ឬតំណាងមិនបានបំពេញបន្ថែមនូវចំណុចខ្វះខាត គ.ជ.ប ត្រូវចារបដិសេធលើពាក្យបណ្តឹងគ្រប់ច្បាប់ដោយបញ្ជាក់អំពីមូលហេតុ ព្រមទាំងចុះហត្ថលេខា ពោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ២ (ពីរ) ច្បាប់ ។
- ពាក្យបណ្តឹងគោរពអំឡុងពេលកំណត់ ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គធ.ខប និងមានព័ត៌មានចាំបាច់ មន្ត្រីជំនាញនៃនាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវចុះកាលបរិច្ឆេទពេលវេលា ហើយចុះហត្ថលេខាលើពាក្យបណ្តឹងគ្រប់ច្បាប់ រួចប្រគល់ជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ រក្សាទុកប្រើក្នុងពេលសវនាការ ១ (មួយ) ច្បាប់ និងទុកបិទផ្សាយជាសាធារណៈ ១ (មួយ) ច្បាប់ ។

ការដោះស្រាយពាក្យបណ្តឹងនៅ គ.ជ.ប

១០.២.៣១ បន្ទាប់ពីបានទទួលពាក្យបណ្តឹងហើយ គ.ជ.ប ត្រូវពិនិត្យជាបន្ទាន់លើពាក្យបណ្តឹង។ ក្នុងករណី គ.ជ.ប ពិនិត្យ និងយល់ឃើញថា ៖

- ពាក្យបណ្តឹងគ្មានមូលដ្ឋានពាក់ព័ន្ធនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ឬ ប.ន.ត.រ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ព្រមទាំងចុះហត្ថលេខា

ចោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

- កម្មវត្ថុ និងមូលហេតុនៃបណ្តឹងមានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌសុទ្ធសាធ មិនពាក់ព័ន្ធទៅនឹងការបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ព្រមទាំងចុះហត្ថលេខា ចោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- ពាក្យបណ្តឹងដែលត្រូវបានភាគីទំនាស់សះជានឹងគ្នារួចហើយនៅ គធ.ខប គ.ជ.ប ត្រូវពិនិត្យសម្រេចថាត្រូវដោះស្រាយសាជាថ្មី ឬសម្រេចបដិសេធ ។ ក្នុងករណីបដិសេធ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងបដិសេធតាមលិខិតរដ្ឋបាលទៅអ្នកប្តឹង ដោយបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់ ព្រមទាំងចុះហត្ថលេខា ចោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។
- ពាក្យបណ្តឹងមានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងមានព័ត៌មានចាំបាច់ដូចចំណុច ១០.៦.៥ នៃផ្នែកទី២ គ.ជ.ប ត្រូវកំណត់នីតិវិធីដោះស្រាយ ។

១០.២.៣២ គ.ជ.ប អាចបើកការស៊ើបអង្កេតជាបន្ទាន់ចំពោះករណីណាដែលយល់ថាជាការចាំបាច់ និងស្មុគស្មាញ ។

១០.២.៣៣ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ គ.ជ.ប មានសិទ្ធិមិនយកបណ្តឹងនោះមកបើកសវនាការដោះស្រាយ ប្រសិនបើយល់ឃើញថាពាក្យបណ្តឹងផ្ទុយនឹងទម្រង់ ឬគតិច្បាប់ ឬ/និងមិនមានអំណះអំណាងណាមួយពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹងដែលអាចយកមកដោះស្រាយបាន ឬ/និងអំណះអំណាងមិនច្បាស់លាស់ ឬ/និងតាមការ

ស៊ើបអង្កេតស្រាវជ្រាវរបស់ គ.ជ.ប ឃើញថាផ្ទុយពីការអះអាងក្នុងពាក្យបណ្តឹង ។ ការបដិសេធមិនទទួលដោះស្រាយរបស់ គ.ជ.ប ត្រូវធ្វើតាមរយៈលិខិតជូនដំណឹងបដិសេធតាមបែបបទរដ្ឋបាល ក្នុងរយៈពេលសមស្របមួយទៅដើមបណ្តឹងដើម្បីជូនជ្រាបថា បណ្តឹងរបស់គាត់មិនត្រូវបានយកមកដោះស្រាយ ព្រមទាំងចុះហត្ថលេខា បោះត្រា គ.ជ.ប និងចុះកាលបរិច្ឆេទ រួចផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូនអ្នកត្រូវគេប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់ ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

១០.២.៣៤ បន្ទាប់ពីបានធ្វើការស៊ើបអង្កេតចប់សព្វគ្រប់ ប្រសិនបើ គ.ជ.ប រកឃើញកស្តុតាងពាក់ព័ន្ធនឹងកម្មវត្ថុនៃបណ្តឹង គ.ជ.ប ត្រូវដោះស្រាយបណ្តឹងតាមពេលវេលាសមស្របជាបន្ទាន់ ។

១០.២.៣៥ គ.ជ.ប ត្រូវសម្រេចយល់ព្រម ឬបដិសេធលើពាក្យបណ្តឹងដោយមានកំណត់ហេតុសេចក្តីសម្រេច និង ទ.១២០៣ ។

១០.២.៣៦ សមាសភាព និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវអនុវត្តតាមលក្ខខណ្ឌដូចក្នុងផ្នែកទី២ នៃជំពូកទី១០ នេះ។

នីតិវិធីនៃការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

ការដាក់ ការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

១០.២.៣៧ ភាគីវិវាទ ឬតំណាងដែលមិនសុខចិត្តនឹងលិខិតជូនដំណឹង ឬសេចក្តីសម្រេចរបស់ គ.ជ.ប មានសិទ្ធិប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលលិខិតជូនដំណឹង ឬ ទ.១២០៣ របស់ គ.ជ.ប ។

១០.២.៣៨ នីតិវិធីនៃការដាក់ ទទួលពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

ការដោះស្រាយពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញ

១០.២.៣៩ ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការជាសាធារណៈដើម្បីពិនិត្យ និងសម្រេចលើពាក្យបណ្តឹងក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង។

១០.២.៤០ នីតិវិធីដោះស្រាយពាក្យបណ្តឹងត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

១០.២.៤១ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា។

ពាក្យបណ្តឹងពាក់ព័ន្ធនឹងជនដែលជាមន្ត្រីបោះឆ្នោត

ប្រការ ១០.៣..

គ្រប់ពាក្យបណ្តឹងពាក់ព័ន្ធនឹងអំពើបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ដែលប្តឹង គ.ក.ប/គ.ក.រ ឬ គយ.សប ឬ គធ.ខប ឬមន្ត្រីបោះឆ្នោត ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ។

១០.៣.១ បណ្តឹងពាក់ព័ន្ធនឹងសមាសភាព គ.ក.ប/គ.ក.រ ដំបូងត្រូវប្តឹងទៅ គយ.សប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងប្រការ ១០.២.១ រហូតដល់ចំណុច ១០.២.៤១ នៃផ្នែកទី១។

១០.៣.២ បណ្តឹងពាក់ព័ន្ធនឹងសមាជិក គយ.សប ត្រូវប្តឹងទៅ គធ.ខប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១០.២.១៣ រហូតដល់ចំណុច ១០.២.៤១ នៃផ្នែកទី១ ។

១០.៣.៣ បណ្តឹងពាក់ព័ន្ធនឹងសមាសភាព គធ.ខប ឬមន្ត្រី លគធ.ខប ឬមន្ត្រី គ.ជ.ប ត្រូវប្តឹងទៅ គ.ជ.ប តាមលក្ខខណ្ឌដូចបានកំណត់ក្នុងចំណុច ១០.២.២៦ រហូតដល់ចំណុច ១០.២.៤១ នៃផ្នែកទី១ ។

១០.៣.៤ បណ្តឹងពាក់ព័ន្ធនឹងសមាជិក គ.ជ.ប ត្រូវប្តឹងទៅរដ្ឋសភា ដោយអនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ។

១០.៣.៥ បណ្តឹងចោទប្រកាន់សមាជិក ឬមន្ត្រីដែលបដិសេធមិនទទួលពាក្យបណ្តឹង ដោយគ្មានមូលហេតុ និងគតិច្បាប់ត្រឹមត្រូវ និងមិនព្រមដោះស្រាយបណ្តឹងដែលសមាជិក ឬមន្ត្រីនោះបានទទួលពាក្យបណ្តឹងរួចហើយ ត្រូវដាក់ទៅថ្នាក់លើមួយថ្នាក់ ក្នុងរយៈពេល ៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃកើតហេតុ ។ ក្នុងករណីដែលរកឃើញថា៖

- សមាជិក ឬមន្ត្រីនោះ ពិតជាបានបំពានលើបទប្បញ្ញត្តិនៃ ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ប្រាកដមែន សមាជិក ឬមន្ត្រីនោះត្រូវទទួលទណ្ឌកម្មស្របតាម ច.ប.ត.រ ។

- សមាជិក ឬមន្ត្រីនោះ បានគោរពតាម ច.ប.ត.រ ប.ន.ត.រ និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ត្រឹមត្រូវហើយ ត្រូវបដិសេធពាក្យបណ្តឹងនោះ ហើយពាក្យបណ្តឹងដែលត្រូវបានបដិសេធ និងមិនដោះស្រាយនោះ ក៏ត្រូវបានបដិសេធផងដែរ ។

ផ្នែកទី២
សមត្ថកិច្ច និងនីតិវិធីប្រជុំផ្សះផ្សា ប្រជុំសម្រេច
និងសវនាការដោះស្រាយពាក្យបណ្តឹង

សមត្ថកិច្ចដោះស្រាយពាក្យបណ្តឹងក្នុងការបោះឆ្នោត

ប្រការ ១០.៤.-

គយ.សប គធ.ខប គ.ជ.ប និងក្រុមប្រឹក្សាធម្មនុញ្ញ មានសិទ្ធិអំណាច និងភារកិច្ចសម្រេចលើពាក្យបណ្តឹងដែលពាក់ព័ន្ធនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ គយ.សប បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច គធ.ខប បើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬ/និងបើកសវនាការ និង គ.ជ.ប ប្រជុំសម្រេច ឬបើកសវនាការលើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោតនេះ លើកលែងតែពាក្យបណ្តឹងដែលទាក់ទងនឹងសមត្ថកិច្ចរបស់តុលាការ ។

១០.៤.១ នីតិវិធីប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹងដូចបានចែងក្នុងផ្នែកនេះ ត្រូវយកមកអនុវត្តក្នុងគ្រប់ដំណាក់កាលទាំងអស់នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរួមមានដំណាក់កាលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដំណាក់កាលយោសនាបោះឆ្នោត និងដំណាក់កាលនៃការបោះឆ្នោត រាប់សន្លឹកឆ្នោត និងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ។

១០.៤.២ ការរាប់ចំនួនថ្ងៃតវ៉ា និងការសម្រេចលើបណ្តឹងតវ៉ា ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

១០.៤.៣ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

ប្រការ ១០.៥.-

ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាដែលត្រូវបានចាត់តាំងឱ្យចូលរួមដោយ គយ.សប ឬ គធ.ខប ឬ គ.ជ.ប ។

១០.៥.១ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចដែលចាត់តាំងដោយ គឃ.សប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេចរបស់ខ្លួន ស្របតាមនីតិវិធីដោះស្រាយបណ្តឹង ដូចមានចែងក្នុងប្រការ ១០.១១ នៃ ប.ន.ត.រ ។

១០.៥.២ ប្រធាន និងសមាជិក គឃ.សប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សា ហៅថា ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេច ហៅថា ក្រុមប្រឹក្សាប្រជុំសម្រេច ។

១០.៥.២.១ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច នៃ គឃ.សប រួមមាន ៖

- ប្រធាន គឃ.សប ឬតំណាងជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច
- សមាជិក គឃ.សប ជាសមាជិក
- សមាជិក គឃ.សប ១ (មួយ) រូប ទទួលការកិច្ចបន្ថែម ជា លេខាធិការ ។

១០.៥.២.២ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាត នៃចំនួនសមាជិក គឃ.សប ទាំងមូល ។

១០.៥.២.៣ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប មិនត្រូវមានសំឡេងអនុបវាទឡើយ ។

១០.៥.២.៤ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប មានអំណាចកោះហៅគូភាគី ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬ ប្រជុំសម្រេច ។ ដោយឡែកការប្រជុំសម្រេច អាចកោះហៅសាក្សីបាន ។

១០.៥.៣ សមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ដែលចាត់តាំងដោយ គធ.ខប ត្រូវអនុវត្តការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬ សវនាការ និងការសម្រេចរបស់ខ្លួន តាមបទបញ្ជាផ្ទៃក្នុង គ.ជ.ប ។

១០.៥.៤ ប្រធាន អនុប្រធាន និងសមាជិក គធ.ខប ដែលត្រូវបានចាត់តាំងឱ្យចូលរួមប្រជុំផ្សះផ្សា ហៅថាក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬដែលបានចាត់តាំងឱ្យចូលរួមប្រជុំសម្រេច ហៅថាក្រុមប្រឹក្សាប្រជុំសម្រេច ឬដែលត្រូវបានចាត់តាំងឱ្យចូលរួមសវនាការ ហៅថាក្រុមប្រឹក្សាជំនុំជម្រះ ។

១០.៥.៤.១ សមាសភាពរបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប រួមមាន ៖

- ប្រធាន គធ.ខប ឬតំណាង ជាប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គធ.ខប ជាសមាជិក
- មន្ត្រី គធ.ខប ដែលត្រូវបានចាត់តាំង ជាលេខាធិការ ។

១០.៥.៤.២ កូរ៉ុម និងលក្ខខណ្ឌសុពលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ត្រូវអនុវត្តតាមសំឡេងភាគច្រើនដាច់ខាតនៃចំនួនសមាជិក គធ.ខប ទាំងមូល ។

១០.៥.៤.៣ រាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មិនត្រូវមានសំឡេងអនុបវាទឡើយ ។

១០.៥.៤.៤ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប មានសិទ្ធិអំណាចកោះហៅគូភាគី ឱ្យចូលខ្លួនមកបំភ្លឺក្នុងពេលប្រជុំផ្សះផ្សា ឬជំនុំជម្រះ ។ ដោយឡែកសវនាការ អាចកោះហៅសាក្សីបាន ។

១០.៥.៥ សមាសភាពក្រុមប្រឹក្សាជំនុំជម្រះដែលចាត់តាំងដោយ គ.ជ.ប ត្រូវអនុវត្តតាមការសម្រេចរបស់ គ.ជ.ប អនុលោមតាមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

១០.៥.៦ ប្រធាន អនុប្រធាន និងសមាជិក គ.ជ.ប ដែលត្រូវបានចាត់តាំងឱ្យចូលរួមធ្វើសវនាការដោះស្រាយពាក្យបណ្តឹងហៅថា ក្រុមប្រឹក្សាជំនុំជម្រះ ។

១០.៥.៦.១ សមាសភាពរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប រួមមាន ៖

- ប្រធាន គ.ជ.ប ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
- អនុប្រធាន និងសមាជិក គ.ជ.ប ជាសមាជិក
- មន្ត្រីអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានតែងតាំងជាគណៈលេខាធិការសវនាការ ។

១០.៥.៦.២ លក្ខខណ្ឌសុពលភាព នៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវគោរពតាមបទប្បញ្ញត្តិនៃមាត្រា៥០ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប ។

១០.៥.៦.៣ ការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មិនត្រូវមានសំឡេងអនុបវាទឡើយ ។

១០.៥.៦.៤ ក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប មានសិទ្ធិអំណាចកោះហៅគូភាគី និងសាក្សីឱ្យចូលខ្លួនមកបំភ្លឺក្នុងសវនាការ ។

ការប្តឹងតវ៉ា ឬការប្តឹងជំទាស់

ប្រការ ១០.៦.-

ជនណាក៏ដោយ ឬតំណាងមានសិទ្ធិប្តឹងតវ៉ា ឬ/និងប្តឹងជំទាស់តាមហានានុក្រមទៅ គយ.សប ឬ គធ.ខប ឬ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញ អំពីបញ្ហាទាំងឡាយដែលទាក់ទងនឹងការបោះឆ្នោត ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមានភាពមិនត្រឹមត្រូវតាមបទប្បញ្ញត្តិនៃ ច.ប.ត.រ និង ប.ន.ត.រ ឬ/និងបទបញ្ជាផ្ទៃក្នុងរបស់ គ.ជ.ប លើកលែងតែការប្តឹងទាក់ទងនឹងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ដែលត្រូវប្តឹងដោយសាមីខ្លួន ឬសាមីគណបក្សនយោបាយ និងការប្តឹងទាក់ទងនឹងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ព្រមទាំងការប្រកាសលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត ដែលត្រូវប្តឹងដោយតំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះ។

១០.៦.១ ពាក្យបណ្តឹងអនាមិក ពុំត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងមិនត្រូវលើកយកមកដោះស្រាយ ប៉ុន្តែត្រូវបានចាត់ទុកជាឯកសារព័ត៌មានសម្រាប់ការពិចារណា។

១០.៦.២ ពាក្យបណ្តឹងប្តឹងពីអញ្ញាតជន ត្រូវបានចាត់ទុកជាពាក្យបណ្តឹងស្របច្បាប់ និងត្រូវបានសហការជាមួយអាជ្ញាធរទទួលបន្ទុកសន្តិសុខបោះឆ្នោត ដើម្បីស្វែងរកអត្តសញ្ញាណរបស់អ្នកប្រព្រឹត្តល្មើសនោះ និងពង្រឹងការការពារ និងទប់ស្កាត់បន្ថែម ។ ក្នុងករណីដែលស្វែងរកអត្តសញ្ញាណអញ្ញាតជនមិនឃើញ គយ.សប ឬ គធ.ខប ឬ គ.ជ.ប ត្រូវធ្វើលិខិតជូនដំណឹងទៅអ្នកប្តឹងវិញអំពីករណីនេះ ក្នុងរយៈពេលសមស្រប ។

១០.៦.៣ ពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរតាម ទ.១២០២ ចំនួន ៣ (បី) ច្បាប់ (ចំពោះបណ្តឹងតវ៉ា) ឬចំនួន ៤ (បួន) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ។ អ្នកប្តឹងដំបូងអាចថតចម្លងទម្រង់បែបបទដែលខ្លួនបានបំពេញ រួចចុះហត្ថលេខា ឬផ្ទិតមេដៃលើច្បាប់ចម្លងទាំងនោះដោយខ្លួនឯង ហើយអាចដាក់ពាក្យបណ្តឹងដោយផ្ទាល់ ឬអាចប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរឱ្យតំណាងដាក់ពាក្យបណ្តឹងជូនខ្លួនបាន។

១០.៦.៤ គយ.សប ឬមន្ត្រីបោះឆ្នោត ត្រូវប្រគល់ ទ.១២០២ ដល់អ្នកប្តឹងដើម្បីប្តឹង ឬប្តឹងបន្ត ប្រសិនបើមានការស្នើសុំ ។

១០.៦.៥ ពាក្យបណ្តឹង ត្រូវបញ្ជាក់នូវព័ត៌មានចាំបាច់មួយចំនួន ដូចខាងក្រោម ៖
- ឈ្មោះ និងអាសយដ្ឋានរបស់អ្នកប្តឹង ឬតំណាង
- កម្មវត្ថុនៃបណ្តឹង
- ប្រភេទនៃអំពើល្មើស
- ពេលវេលា និងទីកន្លែងនៃការប្រព្រឹត្តអំពើល្មើស ឬភាពមិនប្រក្រតីកើតឡើង
- បើអាចធ្វើបាន បញ្ជាក់អំពីមាត្រាច្បាប់បោះឆ្នោត ដែលត្រូវបានរំលោភ
- អត្តសញ្ញាណរបស់ជនដែលពាក់ព័ន្ធនឹងការប្តឹងតវ៉ា ឬការប្តឹងជំទាស់
- ឈ្មោះ និងអាសយដ្ឋានរបស់សាក្សី បើមាន
- ភស្តុតាងផ្សេងៗទៀត បើមាន ។

១០.៦.៦ ពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ហើយជាបន្ទាន់ ។

១០.៦.៧ ការដាក់ និងការទទួលពាក្យបណ្តឹងនៅក្រុមប្រឹក្សាធម្មនុញ្ញត្រូវអនុវត្តតាមនីតិវិធីរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ។

ការដកពាក្យបណ្តឹង

ប្រការ ១០.៧.

ដើមបណ្តឹងអាចដកពាក្យបណ្តឹងទាំងមូល ឬមួយផ្នែកបាន រហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គយ.សប ឬក្រុមប្រឹក្សាប្រជុំផ្សះផ្សានៃ គធ.ខប បញ្ចប់កំណត់ហេតុប្រជុំផ្សះផ្សា ឬរហូតដល់ពេលដែលក្រុមប្រឹក្សាប្រជុំសម្រេចនៃ គយ.សប ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ថយទៅពិភាក្សាពិចារណា ។

១០.**៧**.១ ការដកពាក្យបណ្តឹងត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជូនទៅ គយ.សប ឬ គធ.ខប ឬ គ.ជ.ប លើកលែងតែនៅពេលកំពុងប្រជុំផ្សះផ្សា ឬកំពុងប្រជុំសម្រេច ឬកំពុងសវនាការ នោះការដកពាក្យបណ្តឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន ។

១០.**៧**.២ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹង ធ្វើឡើងមុនពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ គយ.សប ឬ គធ.ខប ឬ គ.ជ.ប ត្រូវសម្រេចលើកពាក្យបណ្តឹងនោះចោល ហើយត្រូវជូនដំណឹងទៅភាគីចុងចម្លើយ ។

១០.៧.៣ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹងធ្វើឡើងនៅពេលកំពុងប្រជុំផ្សះផ្សា ក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សាថា ភាគីដើមបណ្តឹងដកពាក្យបណ្តឹង ហើយពាក្យបណ្តឹងនោះត្រូវបានលើកចោលតាមការស្នើសុំ ។

១០.៧.៤ ប្រសិនបើដើមបណ្តឹងដកពាក្យបណ្តឹងធ្វើឡើងនៅពេលកំពុងប្រជុំសម្រេច ឬកំពុងសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចលើកពាក្យបណ្តឹងចោលដោយចេញ ទ.១២០៣ ។

ការរួមបញ្ចូលរឿងក្តី

ប្រការ ១០.៨.-

គ.ជ.ប ឬក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប អាចបញ្ចូលរឿងក្តី ក្នុងករណីដែលមានបណ្តឹងច្រើន ប៉ុន្តែកម្មវត្ថុនៃបណ្តឹងតែមួយ អ្នកប្រព្រឹត្តល្មើសជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ហើយអ្នកប្តឹងជារូបវន្តបុគ្គលតែម្នាក់ ឬនីតិបុគ្គលតែមួយ ទោះទីកន្លែងប្រព្រឹត្តល្មើសមាននៅទូទាំងប្រទេសក៏ដោយ ។ ប៉ុន្តែក្រោយពេលដែលក្រុមប្រឹក្សាជំនុំជម្រះចេញសេចក្តីសម្រេចជាស្ថាពរ អ្នកប្រព្រឹត្តល្មើសមិនរាងចាល ដោយនៅតែប្រព្រឹត្តល្មើសដដែលបន្តទៀត ហើយបើមានបណ្តឹងថ្មីទៀតនោះ គ.ជ.ប នឹងត្រូវលើកយកមកដោះស្រាយដោយចាត់ទុកជាករណីថ្មីទៀត ។

សិទ្ធិ និងភាពកាតព្វកិច្ចរបស់គូភាគី ដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាង

ប្រការ ១០.៩.-

ក្នុងករណីគូភាគីមានមេធាវី ឬតំណាងដើម្បីធ្វើជាតំណាង ឬអ្នកការពារក្តី ឬសាក្សី ឬអ្នកដែលពាក់ព័ន្ធនឹងបណ្តឹងដែលត្រូវចូលរួមបំភ្លឺក្នុងអង្គប្រជុំសម្រេច ឬសវនាការនោះ ត្រូវសុំការអនុញ្ញាតជាមុនពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ មុនពេលបើកការប្រជុំសម្រេច ឬសវនាការ។ ចំពោះការប្រជុំផ្សះផ្សា គូភាគីអាចមកចូលរួមដោយផ្ទាល់ ឬចាត់តំណាងដែលត្រូវបានប្រគល់សិទ្ធិ តែមិនតម្រូវឱ្យមានសាក្សីទេ ។

១០.៩.១ គូភាគីត្រូវធ្វើលិខិតប្រគល់សិទ្ធិជូនមេធាវី ឬតំណាងដោយមានចុះហត្ថលេខា ឬផ្ទិតមេដៃ និងត្រូវមានការយល់ព្រមចុះហត្ថលេខា និងបោះត្រាពីមេធាវី ឬស្នាមមេដៃនៃតំណាងនោះ។ តំណាងត្រូវតែជានីតិជន ។

១០.៩.២ លិខិតប្រគល់សិទ្ធិត្រូវបញ្ជាក់ច្បាស់ពីសិទ្ធិរបស់មេធាវី ឬតំណាង ហើយត្រូវដាក់ជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ តាមរយៈ

លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ យ៉ាងតិច ២ (ពីរ) ម៉ោង មុនពេលបើកការប្រជុំផ្សះផ្សា ឬបើកការប្រជុំសម្រេច ឬបើកសវនាការ ។

១០.៩.៣ មេធាវី ឬតំណាងមិនអាចប្រគល់សិទ្ធិបន្តទៅមេធាវី ឬតំណាងដទៃទៀតដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីអ្នកប្រគល់សិទ្ធិដំបូងបានឡើយ ។

១០.៩.៤ ដើមបណ្តឹងអាចរាយការណ៍ជាលាយលក្ខណ៍អក្សរ អំពីបញ្ហាដែលកើតមានឡើងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ ។

១០.៩.៥ ដើមបណ្តឹងត្រូវបានអនុញ្ញាតឱ្យបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងក្នុងរឿងក្តីរបស់ខ្លួន ។

១០.៩.៦ ដើមបណ្តឹង ឬ/និងជនរងគ្រោះមានវិសមិតភាពរវាងហាន:ជាដើមបណ្តឹង ឬជនរងគ្រោះនឹងហាន:ជាសាក្សី ។ ដើមបណ្តឹង ឬ/និងជនរងគ្រោះមិនអនុញ្ញាតឱ្យផ្តល់ចម្លើយក្នុងហាន:ជាសាក្សីបានទេ ។

១០.៩.៧ ចុងចម្លើយអាចធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីបញ្ហានានា ដែលទាក់ទងនឹងបណ្តឹងដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដែលបានទទួលសិទ្ធិ។

១០.៩.៨ ចុងចម្លើយត្រូវបង្ហាញឯកសារភស្តុតាង ឬសាក្សីដើម្បីជាសំអាងការពាររឿងក្តីរបស់ខ្លួន ។

១០.៩.៩ ចុងចម្លើយអាចបង្ហាញភស្តុតាងជាទម្លាក់ករណ៍ចុងក្រោយរបស់ខ្លួន ដោយខ្លួនឯង ឬតាមរយៈមេធាវី ឬតំណាងដើម្បីឆ្លើយតបទៅនឹងទម្លាក់ករណ៍របស់ដើមបណ្តឹង ។

១០.៩.១០ មធ្យោបាយបង្ហាញភស្តុតាង ដែលប្រើប្រាស់ក្នុងតុលាការជំនុំជម្រះក្តី ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកប្រើប្រាស់ក្នុងអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការនេះ ។ ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ និងត្រូវគោរពតាម ច.ប.ត.រ និង ប.ន.ត.រ នេះ ។

១០.៩.១១ ជនណាបានប្រព្រឹត្តអំពើក្លែងលិខិត ឬឯកសារដោយក្លែងហត្ថលេខា ឬស្នាមមេដៃ ឬតាមមធ្យោបាយណាក៏ដោយ និងជនណាដែលបានប្រើប្រាស់ដោយដឹងខ្លួននូវលិខិត ឬឯកសារក្លែងនោះ ជននោះនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

១០.៩.១២ ដើមបណ្តឹង និងចុងចម្លើយមិនតម្រូវឱ្យធ្វើសម្បថទេ ។

១០.៩.១៣ នៅក្នុងនីតិវិធីសវនាការតទល់ ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើមបណ្តឹងអាចតាំងសំណួរទៅចុងចម្លើយ ឬសាក្សីរបស់ចុងចម្លើយ ។ ចុងចម្លើយក៏អាចចោទសំណួរទៅដើមបណ្តឹង ឬសាក្សីរបស់ដើមបណ្តឹង ។

១០.៩.១៤ មុនពេលក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ថយទៅពិភាក្សាពិចារណា គូភាគីអាចត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ ឬជូនឯកសារទាំងឡាយដែលខ្លួនយល់ថា មានប្រយោជន៍ដល់ខ្លួនជូនទៅក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះដើម្បីពិចារណា ។

១០.៩.១៥ គូភាគីមានសិទ្ធិប្តឹងតវ៉ា ចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះតាមការកំណត់ក្នុង ច.ប.ត.រ និង ប.ន.ត.រ នេះ ។

១០.៩.១៦ ដើមបណ្តឹង ឬចុងចម្លើយ ឬមេធាវី ឬតំណាងរបស់ភាគីអាចស្នើសុំឱ្យ គធ.ខប ឬ គ.ជ.ប ថតចម្លងសំណុំរឿងពាក់ព័ន្ធឱ្យខ្លួនដោយត្រូវបង់ប្រាក់ត្រឹមថ្លៃផលិតប៉ុណ្ណោះ។

សិទ្ធិ និងភាពកាតព្វកិច្ចរបស់សាក្សី

ប្រការ ១០.១០.-

សាក្សីត្រូវធ្វើសម្បថជាមុនហើយត្រូវឆ្លើយបំភ្លឺជូនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ នៅចំពោះមុខក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងសន្យាទទួលខុសត្រូវនៅចំពោះមុខច្បាប់ អំពីការផ្តន្ទាទោសចំពោះការផ្តល់សក្ខីកម្មក្លែងក្លាយ ប្រសិនបើខ្លួនឆ្លើយបំផ្លើសការពិត។ ទម្រង់នៃសម្បថត្រូវធ្វើដូចមានកំណត់នៅក្នុងនីតិវិធី និងខ្លឹមសារនៃសម្បថ ។

១០.១០.១ សាក្សីមានសិទ្ធិឆ្លើយបំភ្លឺនូវការពិតដែលខ្លួនបានឃើញ បានដឹង បានឮ និងបានចាំ ដោយគ្មានការបង្ខិតបង្ខំពីបុគ្គលណាមួយឡើយ។

១០.១០.២ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយត្រូវស្ថិតក្នុងបន្ទប់ផ្សេងគ្នា រង់ចាំការអញ្ជើញឱ្យមកបំភ្លឺដោយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ។

១០.១០.៣ សាក្សីដើមបណ្តឹង និងសាក្សីចុងចម្លើយមិនត្រូវបានអនុញ្ញាតឱ្យទាក់ទងគ្នា ទោះតាមមធ្យោបាយណាក៏ដោយ ក្នុងថ្ងៃដែលបានអញ្ជើញឱ្យចូលរួមប្រជុំសម្រេច ឬសវនាការ ។

១០.១០.៤ សាក្សីពុំត្រូវបានអនុញ្ញាតឱ្យឃើញ ឬស្តាប់ការសួរដេញដោលនៅក្នុងបន្ទប់ប្រជុំសម្រេច ឬបន្ទប់ជំនុំជម្រះឡើយលើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

នីតិវិធីប្រជុំផ្សះផ្សា ឬនីតិវិធីប្រជុំសម្រេច ឬនីតិវិធីសវនាការ

ប្រការ ១០.១១.

ដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការត្រូវដឹកនាំនិងចាត់ចែងដោយប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។ ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចអនុញ្ញាតឱ្យជនណាម្នាក់ឆ្លើយបំភ្លឺ ឬហាមឆ្លើយបំភ្លឺចំពោះមុខអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ហើយមានសិទ្ធិបណ្តេញឱ្យចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការចំពោះជនណា ឬជនទាំងឡាយណាដែលមិនគោរពបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង (មានចែងក្នុងបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការដោះស្រាយបណ្តឹង) ។

ប្រភេទសវនាការ

១០.១១.១ ក្រុមប្រឹក្សាជំនុំជម្រះអាចធ្វើសវនាការសង្ខេប ឬសវនាការតទល់ ឬសវនាការសួរដេញដោល ។

១០.១១.១.១ សវនាការសង្ខេបជាសវនាការដែលគ្មានទម្រង់ការច្រើន ។ ក្រុមប្រឹក្សាជំនុំជម្រះគ្រាន់តែធ្វើសេចក្តីសម្រេចមួយឆ្លើយតប នៅពេលយល់ឃើញថាមានតែចំណោទខាងច្បាប់ប៉ុណ្ណោះ ហើយគ្មានចំណោទខាងអង្គហេតុ ។

១០.១១.១.២ សវនាការតទល់ ជាសវនាការដែលបើកឱ្យភាគីទំនាស់ជជែកតទល់គ្នាអំពីរឿងវិវាទ ។ ភាគីទំនាស់កំណត់អំពីអង្គហេតុ និងត្រូវប្រមូលភស្តុតាង ដើម្បីដាក់ជូនសវនាការ ។

១០.១១.១.៣ សវនាការសួរដេញដោល ជាសវនាការដែលក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីយ៉ាងសំខាន់ក្នុងការសួរដេញដោលរកហេតុផល ក្នុងរឿងក្តី ។ ក្នុងសវនាការប្រភេទនេះទាំងក្រុមប្រឹក្សាជំនុំជម្រះ ទាំងគូក្តី ជាអ្នកទទួលខុសត្រូវក្នុងការប្រមែប្រមូលភស្តុតាងផ្សេងៗដែលត្រូវដាក់បង្ហាញក្នុងសវនាការ ប៉ុន្តែក្រុមប្រឹក្សាជំនុំជម្រះមានតួនាទីទទួលខុសត្រូវ សំខាន់ជាអ្នកតាំងសំណួរដល់សាក្សី ចំណែកឯគូក្តីមានតួនាទីបន្ទាប់បន្សំតែប៉ុណ្ណោះ។ ការចោទសួរដេញដោលនេះ អាចធ្វើទៅបានដោយមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

១០.១១.២ ភាសាដែលប្រើក្នុងការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការគឺភាសាខ្មែរ ។ ភាគីដែលមិនអាចយល់ភាសាខ្មែរ អាចរកអ្នកបកប្រែភាសាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដោយខ្លួនឯង ។

ការរៀបចំកន្លែង និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ

១០.១១.៣ នៅថ្ងៃប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវអញ្ជើញចូលអង្គុយតាមទីកន្លែង ដែលបានរៀបចំទុក ។ ប្រធានអង្គុយនៅកណ្តាល សមាជិកអង្គុយអមសងខាង និងលេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ត្រូវអង្គុយនៅនឹងតុដែលនៅខាងឆ្វេងដៃ ឬស្តាំដៃនៃក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ។

១០.១១.៣.១ ក្រោយពីបានអញ្ជើញអង្គុយតាមទីកន្លែងរួចមក ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវ ៖

- ប្រកាសសមាសភាពក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ
- ប្រកាសសំណុំរឿង និងប្រកាសបើកការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ
- បង្គាប់លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការឱ្យរាយការណ៍អំពីវត្តមានដើមបណ្តឹងចុងចម្លើយ និងសាក្សី (ករណីប្រជុំសម្រេច ឬសវនាការ) ។

១០.១១.៣.២ មុននឹងចាប់ផ្តើមផ្សះផ្សា ឬសួរដេញដោល ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរទៅដើមបណ្តឹងថាតើលោក ឬលោកស្រី នៅតែបន្តប្តឹងដូចចែង ក្នុងកម្មវត្ថុនៃបណ្តឹង ឬមានការកែប្រែឬទេ? ប្រសិនបើ ៖

- ដើមបណ្តឹងឆ្លើយថា ខ្លួនដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវបង្គាប់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ឱ្យកត់ត្រាក្នុងកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ហើយឱ្យដើមបណ្តឹងផ្ទិតមេដៃលើកំណត់ហេតុនោះ ។ បន្ទាប់មកក្រុមប្រឹក្សាប្រជុំផ្សះផ្សាអាចផ្សះផ្សារឿងក្តីផ្សេងទៀត (បើមាន) ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចថយទៅពិភាក្សាពិចារណា ឬបន្តទៅប្រជុំសម្រេច ឬសវនាការរឿងក្តីផ្សេងទៀត (បើមាន) ។
- ដើមបណ្តឹងនៅតែបន្តប្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាប់ផ្តើមដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ។

១០.១១.៣.៣ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវសួរដេញដោលទៅដើមបណ្តឹងមុន រួចត្រូវសួរទៅចុងចម្លើយ។ បន្ទាប់មកប្រធានត្រូវសួរសាក្សីដើមបណ្តឹង សាក្សីចុងចម្លើយ និងអ្នកពាក់ព័ន្ធ រួចឱ្យកាគីដើមបណ្តឹង និងកាគីចុងចម្លើយធ្វើសំណូមពរចុងក្រោយ។

១០.១១.៣.៤ ប្រសិនបើមានមេធាវីការពារក្តី ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្តល់ពេលវេលាឱ្យមេធាវីនិយាយ ការពារកូនក្តី សូរភាគី និងធ្វើសេចក្តីសន្និដ្ឋានចុងក្រោយ មុនក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះថយទៅពិភាក្សាពិចារណា ។

១០.១១.៣.៥ ក្នុងពេលដំណើរការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ប្រសិនបើដើមបណ្តឹងសុំដកពាក្យបណ្តឹង ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះត្រូវបញ្ចប់ការផ្សះផ្សា ឬសូរដេញដោលនោះភ្លាម រួចត្រូវអនុវត្តដូចគ្នានឹងករណីដើមបណ្តឹងដកពាក្យបណ្តឹង ពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះសូរពេលដំបូងដែរ ។

១០.១១.៣.៦ ក្រោយពីបានដំណើរការប្រជុំសម្រេច ឬសវនាការតាមលំដាប់លំដោយ រួចហើយក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវថយទៅពិភាក្សាពិចារណានៅក្នុងបន្ទប់សម្ងាត់ ។ រាល់ការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់ ។

ការកិច្ចរបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬ គណៈលេខាធិការសវនាការ

១០.១១.៤ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ មានការកិច្ចដូចខាងក្រោម ៖

- បិទផ្សាយ និងអានបទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការឱ្យអ្នកចូលរួមបានជ្រាប ។
- នាំសាក្សីទៅស្បថ (ករណីប្រជុំសម្រេច ឬសវនាការ) ។
- ប្រាប់ទៅអ្នកចូលរួមទាំងអស់ ឱ្យក្រោកឈរនៅពេលដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអញ្ជើញមកដល់ ។
- ពិនិត្យ និងស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងចម្លើយ មេធាវី ឬតំណាងដែលត្រូវចូលរួមប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ លើកលែងតែការប្រជុំសម្រេច ឬសវនាការ ដែលត្រូវស្រង់វត្តមានសាក្សី ។

- រាយការណ៍អំពីវត្តមាន ឬអវត្តមានភាគីពាក់ព័ន្ធជូនក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ។
- ត្រូវធ្វើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការដោយដៃ ឬដោយវាយកុំព្យូទ័រ ។ ការកត់ត្រាកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការមិនត្រូវទុកឱ្យមានចន្លោះបន្ទាត់ទំនេរទេ ពាក្យឆ្លងលុបចោល និងពាក្យសរសេរយោងត្រូវមានសេចក្តីបញ្ជាក់ និងមានហត្ថលេខារបស់លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ ប្រធាន និងសមាជិកក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ និងភាគីពាក់ព័ន្ធ។
- អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការបង្គាប់ពី ប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។
- រៀបចំ ទ.១២០៣ រួចចុះហត្ថលេខា ហើយដាក់ជូនប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ចុះហត្ថលេខា បោះត្រា និងចុះកាលបរិច្ឆេទ ។
- អញ្ជើញភាគីផ្ដិតមេដៃលើកំណត់ហេតុប្រជុំផ្សះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ក្នុងករណីដែលភាគីណាមួយមិនព្រមផ្ដិតមេដៃ លេខាធិការអង្គប្រជុំផ្សះផ្សា ឬលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ ត្រូវចុះនិទ្ទេសអំពីការមិនព្រមផ្ដិតមេដៃលើកំណត់ហេតុនោះ ។

ពេលវេលាដោះស្រាយបណ្ដឹង

១០.១១.៥ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ អាចធ្វើជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៨:០០នាទីព្រឹក ដល់ម៉ោង ១១:៣០នាទីថ្ងៃត្រង់ និងរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:៣០នាទី ។ ក្នុងករណីចាំបាច់ ការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការអាចបន្ដធ្វើទៅតាមស្ថានភាពជាក់ស្ដែង ឬធ្វើនៅម៉ោងផ្សេងក្រៅពីការកំណត់នេះ។ ក្នុងកម្មវិធីមួយពេលនៃការបើកប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ លើពាក្យបណ្ដឹងអាចកំណត់ធ្វើការប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការច្រើនករណីនៃបណ្ដឹងបាន ។

ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេច ឬបើកសវនាការ

ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកអង្គប្រជុំសម្រេចនៅ គយ.សប

១០.១១.៦ គយ.សប ត្រូវពិភាក្សាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីកំណត់ប្រតិទិនសម្រាប់ប្រជុំផ្សះផ្សា ឬ/និងប្រជុំសម្រេចនៅថ្នាក់របស់ខ្លួនទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចចែងនៅក្នុង ច.ប.ត.រ និង ប.ន.ត.រ និងត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការប្រជុំផ្សះផ្សា ឬប្រជុំសម្រេចដល់គូភាគីបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ។

ការជូនដំណឹងបើកអង្គប្រជុំផ្សះផ្សា ឬបើកសវនាការនៅ គធ.ខប

១០.១១.៧ គធ.ខប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គធ.ខប ទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចចែងនៅក្នុង ច.ប.ត.រ និង ប.ន.ត.រ ។ លគធ.ខប ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកការប្រជុំផ្សះផ្សា ឬបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលបើកការប្រជុំផ្សះផ្សា ហើយត្រូវជូនដំណឹងភ្លាមនៅនឹងកន្លែងប្រជុំផ្សះផ្សាទៅភាគីពាក់ព័ន្ធឱ្យបានដឹងពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងបើកសវនាការ (ករណីពាក្យបណ្តឹងដែលអាចនាំឱ្យមានការផ្ទាកពិន័យ) ឬបើកសវនាការ។

ការជូនដំណឹងបើកសវនាការនៅ គ.ជ.ប

១០.១១.៨ គ.ជ.ប ត្រូវកំណត់ប្រតិទិនសម្រាប់ដោះស្រាយបណ្តឹង ឬ/និងបើកសវនាការនៅថ្នាក់ គ.ជ.ប ទៅតាមករណីនៃបណ្តឹង និងទៅតាមរយៈពេលកំណត់ដូចចែងនៅក្នុង ច.ប.ត.រ និង ប.ន.ត.រ ។ នាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម ត្រូវធានាប្រគល់លិខិតអញ្ជើញអំពីការបើកសវនាការដល់គូភាគីឱ្យបានទាន់ពេលវេលាយ៉ាងតិច ២៤ (ម្ភៃបួន) ម៉ោងមុនពេលបើកសវនាការ ។

ការបង្ហាញខ្លួននៅពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ

១០.១១.៩ ប្រសិនបើ ភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សាទេ នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សាត្រូវសម្រេចលើកពាក្យបណ្តឹងចោលដោយធ្វើលិខិតជូនដំណឹងទៅភាគីដើមបណ្តឹង ។

១០.១១.១០ ប្រសិនបើ ភាគីដើមបណ្តឹងបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែភាគីនោះមិនបានមកបង្ហាញខ្លួននៅថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការទេ នោះក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះត្រូវសម្រេចកំចាំងមុខដើមបណ្តឹង ប៉ុន្តែចាត់ទុកជាចំពោះមុខ ដោយបញ្ជាក់ពីមូលហេតុលើសេចក្តីសម្រេច ។

១០.១១.១១ ប្រសិនបើ ភាគីដើមបណ្តឹងស្លាប់នោះក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល ។

១០.១១.១២ ប្រសិនបើ ភាគីចុងចម្លើយស្លាប់មុនពេលបើកប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវលុបពាក្យបណ្តឹងចេញពីបញ្ជី ហើយត្រូវជូនដំណឹងទៅភាគីដើមបណ្តឹងឱ្យបានជ្រាប ។

១០.១១.១៣ ប្រសិនបើ ចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ប៉ុន្តែមិនមកបង្ហាញខ្លួននៅថ្ងៃប្រជុំផ្សះផ្សា ឬថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះនៅតែបន្តនីតិវិធីរបស់ខ្លួនដដែល ។

១០.១១.១៤ ប្រសិនបើ ដើមបណ្តឹង ឬចុងចម្លើយមិនបានបង្ហាញខ្លួននាថ្ងៃប្រជុំសម្រេច ឬថ្ងៃសវនាការ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវចាត់លេខាធិការអង្គប្រជុំសម្រេច ឬគណៈលេខាធិការសវនាការ ព្រមទាំងស្នើសុំកិច្ចសហការពីអាជ្ញាធរឃុំ សង្កាត់អមដំណើរជាមួយ ដើម្បីបញ្ជូន ទ.១២០៣ ទៅជូនដើមបណ្តឹង ឬចុងចម្លើយនៅអាសយដ្ឋានរបស់ដើមបណ្តឹង ឬចុងចម្លើយ ឬទីស្នាក់ការគណបក្សនយោបាយរបស់ដើមបណ្តឹង ឬចុងចម្លើយនោះ ។ ប្រសិនបើដើមបណ្តឹង ឬចុងចម្លើយបដិសេធមិនទទួលយក ទ.១២០៣ នោះ លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការ សវនាការ ឬមន្ត្រី គ.ជ.ប ត្រូវចារលើ ទ.១២០៣ នោះ ដោយបញ្ជាក់ឱ្យបានច្បាស់ថា " ដើមបណ្តឹង ឬតំណាង ឬចុងចម្លើយ ឬតំណាងមិនព្រមទទួល ទ.១២០៣ " ហើយចុះកាលបរិច្ឆេទ និងហត្ថលេខា និងមានហត្ថលេខារបស់អាជ្ញាធរឃុំ សង្កាត់ ដែលអមដំណើរទៅជាមួយដើម្បីបញ្ជាក់ថាភាគីវិវាទពិតជាមិនព្រមទទួលយក ទ.១២០៣ រួចបិទ ទ.១២០៣ នោះ នៅមុខលំនៅឋាន ឬទីសំណាក់ ឬទីស្នាក់ការគណបក្សនយោបាយរបស់ភាគីវិវាទ ហើយចាត់ទុកថាភាគីវិវាទបានទទួល ទ.១២០៣ រួចហើយ ។

ការប្រកាសសេចក្តីសម្រេច

១០.១១.១៥ ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ត្រូវប្រកាសសេចក្តីសម្រេចភ្លាមបន្ទាប់ពីពិភាក្សាគ្នារួចរាល់។ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយចំពោះរឿងពាក្យបណ្តឹងដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត

ប៉ុន្តែមិនត្រូវឱ្យហួសរយៈពេលកំណត់នៃការដោះស្រាយបណ្តឹងឡើយ ។ ការប្រកាសសេចក្តីសម្រេច ត្រូវធ្វើឡើងដោយប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះជាអ្នកអានសេចក្តីសម្រេច ដោយផ្អែកលើច្បាប់ដើមនៃសេចក្តីសម្រេច។ ប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ អាចចាត់តាំងសមាជិកក្រុមប្រឹក្សាប្រជុំសម្រេច ឬសមាជិកក្រុមប្រឹក្សាជំនុំជម្រះណាម្នាក់អានជំនួសបាន ។

ការបំពេញ និងប្រើប្រាស់ ទ.១២០៣

១០.១១.១៦ ទ.១២០៣ របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គឃ.សប ត្រូវធ្វើឡើងផ្អែកតាមកំណត់ហេតុប្រជុំសម្រេច ហើយចុះហត្ថលេខាដោយលេខាធិការអង្គប្រជុំសម្រេច និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេច។ ការបំពេញ ទ.១២០៣ នៅ គឃ.សប ត្រូវធ្វើជា ៣ (បី) ច្បាប់សម្រាប់បណ្តឹងតវ៉ា ឬ ៤ (បួន) ច្បាប់ សម្រាប់បណ្តឹងជំទាស់ដើម្បី ៖

- ជូន ឬផ្ញើជូនសាមីអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

១០.១១.១៧ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវធ្វើឡើងដោយផ្អែកតាមកំណត់ហេតុសវនាការ ហើយត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។ សេចក្តីសម្រេចនេះ ត្រូវស្រង់ដាក់ក្នុង ទ.១២០៣ ហើយត្រូវចុះហត្ថលេខាដោយលេខាធិការសវនាការ ឬប្រធានគណៈលេខាធិការសវនាការ និងប្រធានក្រុមប្រឹក្សាជំនុំជម្រះ ហើយត្រូវធ្វើឡើងតាមចំនួន និងកម្មវត្ថុនៃបណ្តឹង ឬចំនួនផ្សេងទៀតតាមការចាំបាច់។ ទ.១២០៣ របស់ក្រុមប្រឹក្សាប្រជុំសម្រេចនៃ គធ.ខប ត្រូវធ្វើឡើងដោយផ្អែកតាមលទ្ធផលនៃការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ ហើយត្រូវចុះហត្ថលេខាដោយសមាជិក គធ.ខប ទទួលបន្ទុកសេវាកម្មច្បាប់ និងវិវាទកម្ម និងសន្តសុខបោះឆ្នោត និងប្រធានក្រុមប្រឹក្សាប្រជុំសម្រេចនៃ គធ.ខប ។

១០.១១.១៨ ការបំពេញ ទ.១២០៣ នៅ គធ.ខប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់បណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់បណ្តឹងជំទាស់ដើម្បី ៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គយ.សប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូន គ.ជ.ប ១ (មួយ) ច្បាប់។
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

១០.១១.១៩ ការបំពេញ ទ.១២០៣ នៅ គ.ជ.ប ត្រូវធ្វើជា ៤ (បួន) ច្បាប់ សម្រាប់បណ្តឹងតវ៉ា ឬ ៥ (ប្រាំ) ច្បាប់ សម្រាប់បណ្តឹងជំទាស់ដើម្បី ៖

- ជូន ឬផ្ញើជូនអ្នកប្តឹង ឬតំណាង ១ (មួយ) ច្បាប់ ជាបន្ទាន់
- ជូន ឬផ្ញើជូនអ្នកដែលត្រូវគេប្តឹងជំទាស់ ឬតំណាង ១ (មួយ) ច្បាប់ (ចំពោះបណ្តឹងជំទាស់) ជាបន្ទាន់
- ផ្ញើជូន គធ.ខប ពាក់ព័ន្ធ ១ (មួយ) ច្បាប់
- ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ១ (មួយ) ច្បាប់
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

១០.១១.២០ គ.ជ.ប ត្រូវចាត់តាំងមន្ត្រីអគ្គលេខាធិការដ្ឋាន ១ (មួយ) រូប ឱ្យទទួលបន្ទុកជាមន្ត្រីប្រគល់សម្រង់សេចក្តីសម្រេច ។ ទ.១២០៣ ត្រូវប្រគល់ជូនភាគីវិវាទភ្លាមៗ បន្ទាប់ពី គ.ជ.ប បញ្ចប់សវនាការ ហើយការប្រគល់ ទទួល ទ.១២០៣ នេះ ត្រូវមានកំណត់ហេតុដែលបញ្ជាក់អំពីពេលវេលា និងកាលបរិច្ឆេទនៃការប្រគល់ ទទួលឱ្យបានច្បាស់លាស់។ កំណត់ហេតុនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប និងហត្ថលេខារបស់អ្នកទទួលជាក់ស្តែង។ ក្នុងករណី៖

- ភាគីវិវាទណាមួយបដិសេធមិនព្រមទទួលយក ទ.១២០៣ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវចុះនិទ្ទេសបញ្ជាក់ពីការមិនព្រមទទួលយកឱ្យបានច្បាស់លាស់។
- ភាគីវិវាទជាភ្នាក់ងារ ឬតំណាងគណបក្សនយោបាយ មន្ត្រីទទួលបន្ទុកប្រគល់សម្រង់សេចក្តីសម្រេចនៃ គ.ជ.ប ត្រូវបញ្ជូន ទ.១២០៣ ដោយមានដីកាអមទៅទីស្នាក់ការគណបក្សនយោបាយរបស់ភាគីនោះ។ កាលបរិច្ឆេទនៃការទទួលដីកាអម ត្រូវចាត់ទុកជាកាលបរិច្ឆេទទទួល ទ.១២០៣ ។

ទម្រង់បែបបទផ្សេងៗទៀតសម្រាប់ការប្រជុំផ្ទុះផ្សា ការប្រជុំសម្រេច និងសវនាការ

១០.១១.២១ គយ.សប គធ.ខប និង គ.ជ.ប មានទម្រង់បែបបទផ្សេងៗទៀតសម្រាប់ប្រើប្រាស់ក្នុងការប្រជុំផ្ទុះផ្សា ឬការប្រជុំសម្រេច ឬសវនាការ មានជាអាទិ៍ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្ទុះផ្សា ឬប្រជុំសម្រេច ឬសវនាការ កំណត់ហេតុសាកសួរ និងកំណត់ហេតុប្រជុំផ្ទុះផ្សា ឬកំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ។

១០.១១.២១.១ លិខិតអញ្ជើញឱ្យចូលរួមប្រជុំផ្ទុះផ្សា ឬប្រជុំសម្រេច ឬសវនាការ ត្រូវបំពេញតាមចំនួនជាក់ស្តែងនៃអ្នកពាក់ព័ន្ធ ដែលត្រូវអញ្ជើញឱ្យចូលរួមប្រជុំផ្ទុះផ្សា ឬប្រជុំសម្រេច ឬសវនាការរួចប្រគល់ជូនភាគីពាក់ព័ន្ធ ១ (មួយ) ច្បាប់។ និងរក្សាទុកជាឯកសារ ១ (មួយ) ច្បាប់។

១០.១១.២១.២ កំណត់ហេតុសាកសួរអាចធ្វើឡើងដោយដៃ ឬដោយវាយកុំព្យូទ័រ ។

១០.១១.២១.៣ កំណត់ហេតុប្រជុំផ្ទុះផ្សា ត្រូវបំពេញដោយលេខាធិការអង្គប្រជុំផ្ទុះផ្សា ចំនួន ១ (មួយ)ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធទៅនឹងបណ្តឹង និងលទ្ធផលនៃការផ្ទុះផ្សា ។

១០.១១.២១.៤ កំណត់ហេតុប្រជុំសម្រេច ឬកំណត់ហេតុសវនាការ ត្រូវបំពេញដោយលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការចំនួន ១ (មួយ) ច្បាប់ ដោយត្រូវកត់ត្រានូវរាល់ចម្លើយដាក់បន្ទុក ឬចម្លើយដោះសារបស់ភាគីពាក់ព័ន្ធទៅនឹងបណ្តឹង ព្រមទាំងការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ។

១០.១១.២១.៥ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃ គធ.ខប និងក្រុមប្រឹក្សាជំនុំជម្រះនៃ គ.ជ.ប ត្រូវសរសេរនូវចំណុច (១) រដ្ឋធម្មនុញ្ញ ច្បាប់ បទបញ្ជា និងនីតិវិធីពាក់ព័ន្ធនឹងការបោះឆ្នោត ពាក្យបណ្តឹង លិខិតប្រគល់សិទ្ធិ ឬ/និងកំណត់ហេតុ ឬ/និងរបាយការណ៍ផ្សេងៗ (២) ការយល់ឃើញ និងការសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះ ។ ច្បាប់ថតចម្លងនៃសេចក្តីសម្រេចនេះ អាចផ្តល់ជូនគូភាគីបានប្រសិនបើមានការស្នើសុំ ។

បទបញ្ជាផ្ទៃក្នុងពេលបើកអង្គប្រជុំផ្សះផ្សា ឬអង្គប្រជុំសម្រេច ឬសវនាការ ដោះស្រាយពាក្យបណ្តឹង

ដើម្បីរក្សាសណ្តាប់ធ្នាប់ រៀបរៀបរយ សុវត្ថិភាព និងសន្តិសុខក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ជនគ្រប់រូបដែលមានវត្តមានក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ត្រូវគោរព និងអនុវត្តតាមបទបញ្ជាផ្ទៃក្នុងដូចតទៅ ៖

១. ហាមជក់បារីក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ។

២. ហាមបង្កភាពអនាធិបតេយ្យក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ដូចជា ៖
   - ការដើរឆ្លងកាត់ ឬដើរចេញ ចូលរហេតរហូត ដោយគ្មានការអនុញ្ញាត
   - ការជជែកគ្នាខ្លាំងៗ ឬស្រែកឡូឡា ឬបង្កសំឡេងរំខានផ្សេងៗ ។

៣. ហាមក្មេងអាយុក្រោម១៨ ឆ្នាំ ចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ លើកលែងតែមានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះ ។

៤. ហាមយកអាវុធជាតិផ្ទុះ សារធាតុពុល និងវត្ថុគ្រោះថ្នាក់ផ្សេងៗចូលក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ។

៥. ហាមថតរូប និងអាត់សំឡេង លើកលែងតែមានការអនុញ្ញាតពីប្រធានក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬប្រធានក្រុមប្រឹក្សាប្រជុំសម្រេច ឬប្រធានក្រុមប្រឹក្សាជំនុំជម្រះ ។

៦. ហាមប្រើប្រាស់ទូរស័ព្ទដៃ វិទ្យុទាក់ទងផ្សេងៗក្នុងបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ។

៧. ក្នុងករណីជនបង្កបញ្ហាអ្វីមួយដែលក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះយល់ឃើញថា ធ្វើឱ្យមានការប៉ះពាល់ដល់រៀបរៀបរយការប្រជុំផ្សះផ្សា ឬការប្រជុំសម្រេច ឬសវនាការ ក្រុមប្រឹក្សាប្រជុំផ្សះផ្សា ឬក្រុមប្រឹក្សាប្រជុំសម្រេច ឬក្រុមប្រឹក្សាជំនុំជម្រះអាចបណ្តេញជននោះចេញពីបន្ទប់ប្រជុំផ្សះផ្សា ឬបន្ទប់ប្រជុំសម្រេច ឬបន្ទប់សវនាការ ។

ជនណាមិនគោរពបទបញ្ជានេះ ឬបង្កភាពរឹតត្បិតក្នុងពេលប្រជុំផ្សះផ្សា ឬប្រជុំសម្រេច ឬសវនាការ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

នីតិវិធី និងខ្លឹមសារនៃសម្បថ

ការធ្វើសច្ចាប្រណិធានត្រូវដឹកនាំធ្វើឡើងដោយលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការ ហើយត្រូវធ្វើនៅចំពោះមុខវត្ថុស័ក្តិសិទ្ធិនៅទីកន្លែងបើកអង្គប្រជុំសម្រេច ឬសវនាការនីមួយៗ ។

មុននឹងចាប់ផ្តើមធ្វើសម្បថ អ្នកស្បថត្រូវអុជទៀន ធូបបូជានៅចំពោះមុខវត្ថុស័ក្តិសិទ្ធិដែលខ្លួនត្រូវស្បថនោះ។ បន្ទាប់មកលេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬសមាជិកគណៈលេខាធិការសវនាការត្រូវអានប្រារព្ធវាទខ្លាំងៗ ច្បាស់ៗឱ្យអ្នកស្បថស្តាប់ រួចអានពាក្យសច្ចាប្រណិធានឱ្យអ្នកស្បថថាតាម ។

ក្រោយពីធ្វើសម្បថរួច លេខាធិការអង្គប្រជុំសម្រេច ឬលេខាធិការសវនាការ ឬគណៈលេខាធិការសវនាការត្រូវធ្វើកំណត់ហេតុនៃការធ្វើសម្បថនោះ ដោយបញ្ជាក់ថា បានធ្វើត្រឹមត្រូវ ហើយសេចក្តីបានចេញវាចាឱ្យស្បថយ៉ាងណាត្រូវកត់ក្នុងកំណត់ហេតុយ៉ាងនោះផង។

ប្រារព្ធវាទ

បពិត្រអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ មានព្រះអង្គដងកើ ព្រះអង្គក្រពុំឈូក ព្រះអង្គស្វេតច្ឆត្រ ព្រះអង្គចេក ព្រះអង្គចម អ្នកតាឃ្លាំងមឿង អ្នកតាក្រហមក លោកតាដំបងដែក លោកតាដំបងគ្រញូង លោកយាយទេព ព្រះអង្គវិហារសូគ៌ ព្រះអង្គជីវ៍វត្តបារាយណ៍ ព្រះអង្គវត្តភ្នំខ្លែងជាដើម សូមយាងអញ្ជើញមកធ្វើជាអធិបតីក្នុងពិធីសម្បថនេះ ត្បិតគូភាគីនេះបានឈ្លោះទាស់ទែងគ្នា ហើយអះអាងលើសាក្សីថា ជាអ្នកបានដឹង បានឃើញ បានឲ្ម និងបានចាំដោយជ្ជាល់ ហើយច្បាប់តម្រូវឱ្យអ្នកទាំងនេះមកធ្វើជាសាក្សីឱ្យឆ្លើយឱ្យបានទៀងត្រង់ តាមពិត។

បើអ្នកណាឆ្លើយមិនពិត តាមដែលខ្លួនបានដឹង បានឃើញ បានឲ្ម និងបានចាំទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិបំផ្លាញឱ្យលាញ ឱ្យស្លាប់តែហោងយ៉ាងវេទនា ដោយគ្រាប់កាំភ្លើង រន្ទះបាញ់ ខ្លាខាំ ពស់ចឹក លុះអនាគតជាតិឱ្យព្រាត់ប្រាសឪពុកម្តាយ បងប្អូន កូនចៅ ឱ្យក្ររហេមរហាម ខ្សត់ទ្រព្យ រងទុក្ខវេទនា អស់ប្រាំរយជាតិ។

បើអ្នកណាឆ្លើយឱ្យការណ៍ដោយពិតត្រង់ មិនវៀចវេរ មិនភូតកុហក មិនលម្អៀង ព្រោះជាញាតិសាលោហិត មិនសមគំនិត ព្រោះខ្លាច ព្រោះស្អប់ ព្រោះលាភសក្ការៈ ព្រោះស៊ីសំណូកទេ សូមអស់ទេព្រក្ស អារុក្ខអារក្ស អ្នកតា យាយទេព និងបារមីដ៏ស័ក្តិសិទ្ធិក្នុងលោកជួយឱ្យគេមានអាយុយឺនយូរ មានសុខភាពល្អ មានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ មានញាតិផៅគោរពស្រឡាញ់រាប់អាន លុះអនាគតជាតិបានជួបតែសេចក្តីល្អ ចម្រុងចម្រើន ថ្កុំថ្កើង រុងរឿង សមដូចសេចក្តីបំណងប្រាថ្នា កុំបីអាក់ខានឡើយ។

ពាក្យសច្ចាប្រណិធាន

ខ្ញុំសូមឆ្លើយតែការពិតដែលខ្ញុំបានឃើញ បានឮ បានដឹង និងបានចាំផ្ទាល់។

បើខ្ញុំឆ្លើយមិនពិត ដោយប្រការណាមួយ សូមអស់ទេព្រក្ស អារក្ស អ្នកតា និងបារមីដ៏ស័ក្តិសិទ្ធិ ទាំងអស់បរាមុខខ្ញុំឱ្យវិនាសណាញ អន្តរាយទ្រព្យសម្បត្តិ និងស្លាប់តែហោងយ៉ាងវេទនា តែបើខ្ញុំឆ្លើយពិតត្រង់ សូមទេវតាជួយឱ្យខ្ញុំមានទ្រព្យសម្បត្តិសម្បូរណ៍ហូរហៀរ និងរស់នៅប្រកបដោយសេចក្តីសុខក្សេមក្សាន្ត ជួបជុំបងប្អូន កូនចៅ ញាតិផៅសន្ធានជារៀងរហូតគ្រប់ជាតិកុំបីអាក់ខានឡើយ។

ឧបសម្ព័ន្ធទី ១

ក្រមសីលធម៌

សម្រាប់មន្ត្រីបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោតតាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់មន្ត្រីបោះឆ្នោតទាំងអស់អនុវត្តក្នុងដំណើរការបោះឆ្នោត ដើម្បីធានាបានប្រសិទ្ធភាពការងារ អព្យាក្រឹតភាព និងជំនឿទុកចិត្តលើការបោះឆ្នោត។

២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធានសំខាន់ៗ ដើម្បីគ្រប់គ្រងសកម្មភាពមន្ត្រីបោះឆ្នោត ក្នុងការអនុវត្តសមត្ថកិច្ច ភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ដើម្បីពង្រឹងអព្យាក្រឹតភាព ភាពមិនលម្អៀង សេចក្ដីថ្លៃថ្នូរ សីលធម៌បុគ្គល និងការប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ដោយឈរលើគោលការណ៍គោរពច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប ច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដោយមិនត្រូវទទួលរងនូវឥទ្ធិពលផ្សេងៗ និងធានាឱ្យដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។

ការគោរពបានល្អនូវក្រមសីលធម៌នេះ រួមចំណែកផ្ដល់លទ្ធភាពឱ្យ គ.ជ.ប និងមន្ត្រីបោះឆ្នោតទាំងអស់ សម្រេចបាននូវ៖

- ការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតដែលធ្វើឡើងទៅតាមច្បាប់ស្ដីពីការបោះឆ្នោត
- ការបោះឆ្នោតដែលមានលក្ខណៈសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដែលទទួលយកបានដោយប្រជាពលរដ្ឋកម្ពុជា ដោយគណបក្សនយោបាយចូលរួមបោះឆ្នោត និងដោយសហគមន៍អន្តរជាតិ
- ការបោះឆ្នោតដែលប្រព្រឹត្តទៅដោយគ្មានការគំរាមកំហែង គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ គ្មានការបំភិតបំភ័យ ឬការផ្ទាញ់ផ្ទាល។

៣- ទិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីបោះឆ្នោតដែលបំពេញការងាររៀបចំការបោះឆ្នោត ក្នុងដំណើរការបោះឆ្នោត នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។ មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិក្រមសីលធម៌នេះ នៅពេលបំពេញភារកិច្ចរបស់ខ្លួនទាំងក្នុងម៉ោងធ្វើការ ទាំងក្រៅម៉ោងធ្វើការ។

៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះ មានន័យដូចតទៅ៖

៤.១- **មន្ត្រីបោះឆ្នោត** សំដៅលើ៖

- អ្នករាជការនៃ គ.ជ.ប
- សមាជិកគ្រប់រូបនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីជាប់កិច្ចសន្យាដែលត្រូវបានជ្រើសរើសឱ្យបំពេញការងារបោះឆ្នោតតាមដំណាក់កាល
- មន្ត្រីដែលត្រូវបានធ្វើប្រតិភូកម្មអំណាចឱ្យដោយ គ.ជ.ប តាមច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងស្ថិតក្នុងម៉ោងបំពេញការងារចុះឈ្មោះបោះឆ្នោត។

៤.២- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៣- **ដំណើរការបោះឆ្នោត** សំដៅលើ៖

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ តួនាទីកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវជាក់លាក់ក្នុងការអនុវត្តសមត្ថកិច្ច ភារកិច្ចរបស់ខ្លួនក្នុងដំណើរការបោះឆ្នោត។

៥.១- សិទ្ធិរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានសិទ្ធិដូចខាងក្រោម៖

៥.១.១ អនុវត្តនូវគោលការណ៍ច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

៥.១.២ អនុវត្តតួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួន ដោយជំហរអព្យាក្រឹត ឥតលម្អៀង ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។

៥.១.៣ ផ្តល់ជំនួយតាមសំណូមពរ សម្រាប់ប្រជាពលរដ្ឋដែលមានពិការភាព ឬមិនចេះអក្សរ មានបំណងសុំចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោតដែលមានពិការភាពដែលមិនអាចបោះឆ្នោតដោយខ្លួនឯងបាន។

៥.១.៤ ទទួលបានការការពារសន្តិសុខ សុវត្ថិភាពផ្ទាល់ខ្លួន នៅក្នុងពេលដែលកំពុងបំពេញការងាររៀបចំការបោះឆ្នោត ក្នុងករណីចាំបាច់។

៥.២- តួនាទីកិច្ចរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតមានភារកិច្ចដូចខាងក្រោម៖

៥.២.១ ការអនុវត្តច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ដែលនៅជាធរមាន។

៥.២.២ លក្ខខណ្ឌការងារ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាមអាណត្តិ និងលក្ខខណ្ឌការងាររបស់ខ្លួនដែលកំណត់ដោយ គ.ជ.ប ដោយរាប់បញ្ចូលទាំងក្រមសីលធម៌នេះផងដែរ។

៥.២.៣ ការអនុវត្តក្រមសីលធម៌

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តប្រតិបត្តិតាម គាំទ្រ និងអនុវត្តក្រមសីលធម៌សម្រាប់មន្ត្រីបោះឆ្នោត។

៥.២.៤ ការគាំទ្រ និងការផ្សព្វផ្សាយ

មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តផ្តល់ការគាំទ្រ និងការផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវច្បាប់បោះឆ្នោត បទបញ្ជាផ្ទៃក្នុង បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការបោះឆ្នោតដែលនៅជាធរមាន និងក្រមសីលធម៌នេះ។

៥.២.៥ ការថ្កោលទោសចំពោះអំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យ

ក្នុងការអនុវត្តសិទ្ធិអំណាចរបស់ខ្លួន មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវប្តេជ្ញាចិត្តថ្កោលទោស រារាំង និងទប់ស្កាត់នូវរាល់អំពើហិង្សា ការបង្ខិតបង្ខំ និងការបំភិតបំភ័យណាមួយទាក់ទងដល់ដំណើរការបោះឆ្នោត។

៥.២.៦ បរិយាកាសការងារ

ក. ក្នុងការអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវបង្ក និងរក្សាភាពមិនលម្អៀងការបោះឆ្នោតជាសម្ងាត់ និងសេចក្តីថ្លៃថ្នូរ។

ខ. មន្ត្រីបោះឆ្នោតគ្រប់រូប ត្រូវត្រៀមលក្ខណៈចាត់វិធានការសមស្របទៅតាមស្ថានភាពជាក់ស្តែងដែលកើតមានឡើងក្នុងដំណើរការបោះឆ្នោត។ មន្ត្រីបោះឆ្នោតត្រូវ៖

- អនុវត្តការកិច្ចរបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ទោះក្នុងកាលៈទេសៈលំបាកយ៉ាងណាក៏ដោយ
- អនុវត្តកិច្ចការផ្សេងទៀតដែលត្រូវបានប្រគល់ជូន និងដែលសមស្របតាមសមត្ថភាពរបស់ខ្លួន ទោះបីកិច្ចការនោះមិនមែនជាភារកិច្ចរបស់ខ្លួនក៏ដោយ។

គ. ក្នុងករណីមានការជ្រៀតជ្រែក ឬការរំខាន មន្ត្រីបោះឆ្នោតត្រូវ៖

- បន្តអនុវត្តការកិច្ចរបស់ខ្លួនដោយប្រុងប្រយ័ត្ន និងខ្ជាប់ខ្ជួន
- រក្សាសុវត្ថិភាពសម្ភារបរិក្ខារបោះឆ្នោតទាំងអស់ដែលខ្លួនទទួលខុសត្រូវ
- រាយការណ៍ជាបន្ទាន់តាមឋានានុក្រម
- ធ្វើសកម្មភាពជាបន្ទាន់ទៅតាមសេចក្ដីណែនាំផ្សេងៗពីមន្ត្រីថ្នាក់លើរបស់ខ្លួន។

៥.២.៧ ជំនួយពិសេស

មន្ត្រីបោះឆ្នោតគ្រប់រូប ត្រូវផ្ដល់ជំនួយពិសេសក្នុងសមត្ថកិច្ចរបស់ខ្លួនតាមសំណូមពរដល់បុគ្គលដែល៖

- មិនចេះអក្សរ (ក្នុងពេលចុះឈ្មោះបោះឆ្នោត) ឬមានពិការភាព
- មិនដឹងថាខ្លួនត្រូវធ្វើអ្វី ឬមិនប្រាកដអំពីអ្វីដែលខ្លួនត្រូវធ្វើ ដើម្បីចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត
- មិនដឹងពីរបៀបដាក់ពាក្យបណ្ដឹងតវ៉ា ឬពាក្យបណ្ដឹងជំទាស់
- មិនមានឯកសារតាមលក្ខខណ្ឌតម្រូវសម្រាប់ការចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត ឬឈ្មោះរបស់គាត់បានបាត់ចេញពីបញ្ជីបោះឆ្នោត ឬសិទ្ធិចុះឈ្មោះបោះឆ្នោត ឬសិទ្ធិបោះឆ្នោតរបស់គាត់ត្រូវបានបដិសេធ។

៥.៣- ការទទួលខុសត្រូវរបស់មន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតត្រូវមានការទទួលខុសត្រូវចំពោះការកិច្ចខ្លួន តាមទីកន្លែង និងករណីដូចខាងក្រោម៖

៥.៣.១ នៅការិយាល័យចុះឈ្មោះបោះឆ្នោត

ក. មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារចុះឈ្មោះបោះឆ្នោតនៅការិយាល័យចុះឈ្មោះបោះឆ្នោត ត្រូវអនុវត្តការកិច្ចជាក់លាក់របស់ខ្លួន ដើម្បីធានាបានថា ប្រជាពលរដ្ឋគ្រប់រូប ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍បោះឆ្នោតអាចអនុវត្តសិទ្ធិ និងការកិច្ចរបស់ខ្លួនដោយសេចក្ដីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្របក្នុងការសុំចុះឈ្មោះបោះឆ្នោត។

ខ. មន្ត្រីបោះឆ្នោតត្រូវយកចិត្តទុកដាក់ ជាអាទិ៍ ចំពោះប្រជាពលរដ្ឋខ្មែរដែលមានពិការភាពណាមួយ មិនមាំមួន មានជំងឺ ចាស់ជរា ឬស្ត្រីមានផ្ទៃពោះ ឬទើបឆ្លងទន្លេ ឬមិនចេះអក្សរមានសិទ្ធិក្នុងការជ្រើសរើសយកមធ្យោបាយ ឬកម្រិតណាមួយដែលខ្លួនត្រូវការ ដើម្បីជាជំនួយក្នុងការចុះឈ្មោះបោះឆ្នោត។ មន្ត្រីបោះឆ្នោតដែលត្រូវបានចាត់ឱ្យជួយអ្នកចុះឈ្មោះនោះ ត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំតែប៉ុណ្ណោះ។

៥.៣.២ នៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

ក. នៅការិយាល័យបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់រូប ដែលទទួលខុសត្រូវលើផ្នែកណាមួយនៃការងារបោះឆ្នោត ត្រូវអនុវត្តការកិច្ចជាក់លាក់របស់ខ្លួន ដើម្បីអនុញ្ញាតឱ្យអ្នកដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទាំងអស់ អាចអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតជាសម្ងាត់ ដោយសេចក្ដីថ្លៃថ្នូរ ងាយស្រួល និងតាមពេលវេលាសមស្រប និងធានាថាសម្ភារ បរិក្ខារបោះឆ្នោតទាំងអស់ ត្រូវតែមានសុវត្ថិភាព ត្រឹមត្រូវ និងគ្រប់ចំនួន។

ខ. មន្ត្រីបោះឆ្នោតត្រូវផ្ដល់ជំនួយសម្រាប់អ្នកបោះឆ្នោតដែលមានពិការភាព មិនអាចបោះឆ្នោតដោយខ្លួនឯងបាន តាមសំណូមពរ ដោយត្រូវធ្វើទៅតាមកម្រិតដែលបានស្នើសុំដោយអ្នកបោះឆ្នោតរូបនោះតែប៉ុណ្ណោះ និងទៅតាមការកំណត់នៃបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។ កិច្ចការនេះ តម្រូវឱ្យមន្ត្រីបោះឆ្នោតដែលត្រូវបានតែងតាំងនោះសួរទៅអ្នកបោះឆ្នោតអំពីគណបក្សនយោបាយណាមួយដែលគាត់ចង់បោះឆ្នោតឱ្យ និងត្រូវគូសលើសន្លឹកឆ្នោតក្នុងនាមអ្នកបោះឆ្នោតរូបនោះ ហើយត្រូវរក្សាការសម្ងាត់នៃការបោះឆ្នោតនេះ។

គ. មន្ត្រីបោះឆ្នោតត្រូវរាយការណ៍ជាបន្ទាន់ទៅប្រធាន គ.ក.ប នូវសកម្មភាពរបស់បុគ្គលណាម្នាក់ដែលធ្វើឱ្យប៉ះពាល់ដល់ការសម្ងាត់នៃការបោះឆ្នោត។

ឃ. នៅការិយាល័យរាប់សន្លឹកឆ្នោត មន្ត្រីបោះឆ្នោតគ្រប់រូបដែលទទួលខុសត្រូវលើផ្នែកណាមួយត្រូវអនុវត្តការកិច្ចជាក់លាក់របស់ខ្លួនដែលបានកំណត់នៅក្នុងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ដើម្បីធានាថាសន្លឹកឆ្នោតទាំងអស់ត្រូវតែមានសុវត្ថិភាពត្រឹមត្រូវ និងគ្រប់ចំនួន។

៥.៣.៣ ទំនាក់ទំនងជាមួយគណបក្សនយោបាយ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍

ក. សកម្មភាព និងទំនាក់ទំនងរបស់មន្ត្រីបោះឆ្នោតជាមួយគណបក្សនយោបាយ ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍បោះឆ្នោតត្រូវបានកំណត់ដូចខាងក្រោម។

- គ្រប់ពេលវេលា មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវមានទំនាក់ទំនងជិតស្និទ្ធ និងមិនលម្អៀងជាមួយបេក្ខជន ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់។ មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវទទួលស្គាល់តួនាទីត្រឹមត្រូវតាមច្បាប់របស់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែល៖
  - មានវត្តមាននៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុងនៃការិយាល័យទាំងនេះ ដើម្បីសង្កេតមើលដំណើរការបោះឆ្នោត

- ▪ ធ្វើការតវ៉ា ឬជំទាស់ ឬធ្វើពាក្យបណ្តឹងតវ៉ា ឬពាក្យបណ្តឹងជំទាស់អំពីភាពមិនប្រក្រតីនៃការអនុវត្តច្បាប់ បទបញ្ជា និងនីតិវិធី ទៅមន្ត្រីបោះឆ្នោតដែលមានសមត្ថកិច្ច (សម្រាប់ភ្នាក់ងារគណបក្សនយោបាយតែប៉ុណ្ណោះ)។
- មន្ត្រីបោះឆ្នោតដែលមានភារកិច្ចទទួល និងដោះស្រាយពាក្យបណ្តឹង ត្រូវយកចិត្តទុកដាក់អនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប។

ខ. មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវដឹងថា៖

- គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍មិនមានសិទ្ធិផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬរំខាន ឬជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោតឡើយ
- មិនត្រូវប្រតិបត្តិតាមការណែនាំណាមួយរបស់គណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ។

៦- ២ម្រាមចំពោះមន្ត្រីបោះឆ្នោត

មន្ត្រីបោះឆ្នោតត្រូវប្រតិបត្តិឱ្យបានម៉ឹងម៉ាត់នូវបម្រាមដូចខាងក្រោម លើកលែងតែការអនុវត្តការកិច្ចរបស់ខ្លួន។

៦.១ ការបំភិតបំភ័យ ការធ្វើឱ្យខូចខាត និងការរាំងស្ទះ

មន្ត្រីបោះឆ្នោតម្នាក់ៗ ត្រូវជៀសវាងសកម្មភាពពាក់ព័ន្ធទៅនឹង៖

- ការគំរាមកំហែង
- អំពើហិង្សា ការបង្ខិតបង្ខំ ឬការបំភិតបំភ័យដល់បុគ្គលណាម្នាក់ ឬប្រឆាំងទៅនឹងបុគ្គលណាម្នាក់
- ការបដិសេធមិនចុះឈ្មោះបោះឆ្នោតឱ្យអ្នកដែលមានសិទ្ធិគ្រប់គ្រាន់ចុះឈ្មោះបោះឆ្នោត
- ការចុះឈ្មោះបោះឆ្នោតឱ្យអ្នកដែលគ្មានសិទ្ធិគ្រប់គ្រាន់ ឬបញ្ចូលឈ្មោះអ្នកដែលគ្មានសិទ្ធិពេញលេញចូលក្នុងបញ្ជីបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល
- ការអនុញ្ញាតឱ្យអ្នកគ្មានសិទ្ធិគ្រប់គ្រាន់ធ្វើការបោះឆ្នោត ឬអនុញ្ញាតឱ្យអ្នកដែលមិនបានចុះឈ្មោះបោះឆ្នោតធ្វើការបោះឆ្នោតដោយផ្ទាល់ ឬដោយប្រយោល
- ការធ្វើឱ្យខូចខាតដល់បរិវេណខាងក្នុង បរិវេណខាងក្រៅ និងការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតណាមួយ
- ការធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញសម្ភារ បរិក្ខារ ឬឯកសារបម្រើការបោះឆ្នោតណាមួយ

- ការបង្ហាក់ ឬរារាំងអ្នកមានសិទ្ធិណាម្នាក់មិនឱ្យទៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។
- ការផ្សព្វផ្សាយព័ត៌មានសម្ងាត់ទាក់ទងនឹងការងាររបស់ខ្លួនទៅកាន់តតិយជនដោយគ្មានការអនុញ្ញាត។

៦.២ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវជៀសវាងៈ

- ការជក់បារីនៅក្នុងទីស្ដីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.៣ ការហូបចុក

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវបរិភោគអាហារនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឡើយ លើកលែងតែមានការអនុញ្ញាតពីមន្ត្រីថ្នាក់លើរបស់ខ្លួន។

៦.៤ ការប្រើប្រាស់គ្រឿងស្រវឹង និងសារធាតុញៀន

មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវមានភេសជ្ជៈដែលមានផ្ទុកជាតិស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹង ឬសារធាតុញៀនណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ ឬនៅក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យទាំងនេះឡើយ។

៦.៥ អាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវយកអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗចូលក្នុងទីស្ដីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតឡើយ។

៦.៦ ល្បែង

មន្ត្រីបោះឆ្នោតគ្រប់រូបមិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងកន្លែងធ្វើការឡើយ។

៦.៧ ភាពលម្អៀងចំពោះគណបក្សនយោបាយ

មន្ត្រីបោះឆ្នោតម្នាក់ៗ៖

ក. មិនត្រូវលម្អៀងជាដាច់ខាត និងមិនត្រូវធ្វើសកម្មភាពសម្តែងអាកប្បកិរិយា ឥរិយាបថ ឬពោលពាក្យសម្តី ឬថ្លែងសុន្ទរកថា ឬថ្លែងការណ៍អ្វីមួយដែលបង្ហាញឱ្យឃើញនូវភាពលម្អៀង ឬការចូលចិត្ត ឬមិនចូលចិត្តចំពោះគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយណាមួយ ក្នុងពេលអនុវត្តការកិច្ចរបស់ខ្លួន។

ខ. មិនត្រូវធ្វើអ្វីមួយដែលជះឥទ្ធិពលទៅលើអ្នកបោះឆ្នោត ដែលអាចធ្វើឱ្យមានការបោះឆ្នោតគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

គ. មិនត្រូវពាក់ ឬបង្ហាញនូវផ្លាកសញ្ញាណាមួយ និមិត្តសញ្ញា ឬពាក្យស្លោកជាប់នឹងសម្លៀកបំពាក់ដែលមានជាប់ពាក់ព័ន្ធទៅនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយឡើយ។

ឃ. មិនត្រូវរើសអើងគ្រប់ទម្រង់ដូចជា ការរើសអើងពូជសាសន៍ ភេទ កុលសម្ព័ន្ធ ឋានៈ ឬសាសនា ដែលពាក់ព័ន្ធនឹងការបោះឆ្នោត និងសកម្មភាពនយោបាយផ្សេងៗ។

៦.៨ បម្រាមនៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត

មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវចងចាំបម្រាមចាំបាច់ពិសេសដូចខាងក្រោម៖

ក. ការប៉ះពាល់សម្ភារ ឯកសារបោះឆ្នោត

- មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតមិនត្រូវប៉ះពាល់សៀវភៅសន្លឹកឆ្នោត សន្លឹកឆ្នោត បញ្ជីបោះឆ្នោត សោឃ្លុំ ត្រាសម្ងាត់ ត្រាការិយាល័យបោះឆ្នោត ទម្រង់បែបបទ ឬសម្ភារបោះឆ្នោតផ្សេងទៀត ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ ទោះបីជាភារកិច្ចរបស់ខ្លួនក៏ដោយ
- ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មិនត្រូវ៖
  - ស្រាយចំណង ឬបើកសោឃ្លុំ សៀវភៅសន្លឹកឆ្នោត ហិបឆ្នោត កញ្ចប់ ឬស្រោមសំបុត្រ ដែលមានផ្ទុកសម្ភារបោះឆ្នោត
  - យកចេញនូវសៀវភៅសន្លឹកឆ្នោត ហិបឆ្នោត ឬកញ្ចប់ ឬស្រោមសំបុត្រដែលមានផ្ទុកសម្ភារបោះឆ្នោតនៅខាងក្នុង
  - យកសម្ភារបោះឆ្នោតណាមួយចេញពីការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬជួយឱ្យអ្នកណាម្នាក់ផ្សេងទៀតឱ្យធ្វើដូច្នេះ
  - គូសសម្គាល់ ឬសរសេរលើសម្ភារបោះឆ្នោតណាមួយ ឬលុបគំនូស ឬលុបសំណេរណាមួយចេញពីសម្ភារបោះឆ្នោតណាមួយ។

ខ. ការប៉ះពាល់សន្លឹកឆ្នោត និងហិបឆ្នោត

- ប្រសិនបើមិនមានការអនុញ្ញាតឱ្យធ្វើ មន្ត្រីបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ មិនត្រូវ៖
  - ផ្តល់សន្លឹកឆ្នោតទៅជនណាម្នាក់
  - បោះត្រាសម្ងាត់ផ្លូវការនៅលើសន្លឹកឆ្នោតណាមួយ
  - ផ្លាស់ប្តូរ ឬបំផ្លាញត្រាសម្ងាត់ផ្លូវការនៅលើសន្លឹកឆ្នោត
  - ផ្លាស់ប្តូរ ឬបំផ្លាញសន្លឹកឆ្នោត
  - គូសនៅលើសន្លឹកឆ្នោត
  - ចាប់យក ឬប៉ះពាល់ហិបឆ្នោត
  - ដាក់សន្លឹកឆ្នោត ឬរបស់ផ្សេងទៅក្នុងហិបឆ្នោត
  - យកសន្លឹកឆ្នោតចេញពីហិបឆ្នោតឡើយ។

គ. ការរក្សាការសម្ងាត់នៃការបោះឆ្នោត

- មន្ត្រីបោះឆ្នោតដែលបម្រើការងារនៅក្នុងការិយាល័យបោះឆ្នោត មិនត្រូវព្យាយាម៖
  - ចង់ដឹងពីបំណងដែលអ្នកបោះឆ្នោតចង់បោះឆ្នោត ឬបានបោះឆ្នោត
  - ធ្វើឱ្យអ្នកបោះឆ្នោតបង្ហាញ ឬប្រាប់ឱ្យដឹងអំពីរបៀបដែលអ្នកបោះឆ្នោតបានបោះឆ្នោត
  - គូសសញ្ញាសម្គាល់ណាមួយនៅលើសន្លឹកឆ្នោតដែលអាចធ្វើឱ្យគេស្គាល់ដល់អត្តសញ្ញាណនៃអ្នកបោះឆ្នោត
  - ប្រើឥទ្ធិពលទៅលើ ឬជួយអ្នកណាម្នាក់ដើម្បីបានបោះឆ្នោតដោយដឹងថា អ្នកនោះមិនមានសិទ្ធិបោះឆ្នោត
  - ដើរទៅជិតធ្វើជាសញ្ញា ឬនិយាយទៅកាន់អ្នកបោះឆ្នោតណាម្នាក់ដោយគ្មានការកិច្ចអនុញ្ញាត ចាប់ពីពេលដែលអ្នកបោះឆ្នោតដើរចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោត រហូតដល់អ្នកបោះឆ្នោតចាកចេញពីបរិវេណខាងក្នុងការិយាល័យបោះឆ្នោត
  - ដើរចូលទៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយគ្មានការកិច្ច។
- មន្ត្រីបោះឆ្នោតម្នាក់ៗនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោតដែលគ្មានការកិច្ចអនុញ្ញាតឱ្យធ្វើ មិនត្រូវព្យាយាមលាតត្រដាង៖
  - សន្លឹកឆ្នោតណាមួយដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ
  - លទ្ធផលនៃការត្រួតពិនិត្យ និងការគណនាណាមួយធ្វើឡើងដោយមន្ត្រីបោះឆ្នោត

- ▪ ចំនួនសន្លឹកឆ្នោតមិនបានការដែលកំពុងមានវិវាទ
- ▪ ចំនួនសំឡេងឆ្នោតដែលអ្នកបោះឆ្នោតបានបោះឱ្យគណបក្សនយោបាយណាមួយ។

ឃ. ការទទួលសំណូក ឬរង្វាន់

- មន្ត្រីបោះឆ្នោតម្នាក់ៗ មិនត្រូវទទួលយកទោះដោយផ្ទាល់ ឬដោយប្រយោលក្តីនូវចំនួនទឹកប្រាក់ រង្វាន់ ឬសម្ភារៈផ្សេងៗទៀត ឬការសន្យាណាមួយពីគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ណាម្នាក់ឡើយ។

ង. វិសមិតភាពការងារ

- មន្ត្រីបោះឆ្នោតម្នាក់ៗ នៅក្នុងអំឡុងពេលបោះឆ្នោត មិនត្រូវ៖
  - ▪ មានឈ្មោះជាបេក្ខជននៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ
  - ▪ ជាកងយោធពលខេមរភូមិន្ទ នគរបាលជាតិ មន្ត្រីតុលាការ បព្វជិតសាសនា អភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ មេភូមិ ជំនួយការភូមិ និងជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ។

៧- សំណូមពរ និងការអនុវត្ត

ក្នុងការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន មន្ត្រីបោះឆ្នោតគ្រប់រូបត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម។

៧.១- សំណូមពរ

- ក្នុងការងាររៀបចំការបោះឆ្នោត មន្ត្រីបោះឆ្នោតទាំងអស់ត្រូវប្រតិបត្តិតាមក្រមសីលធម៌នេះ នៅពេលដែលមន្ត្រីបុគ្គលិកទាំងនោះកំពុងស្ថិតនៅទីកន្លែងបំពេញការងាររបស់ខ្លួន ឬកំពុងបំពេញភារកិច្ចរបស់ខ្លួន
- មន្ត្រីបោះឆ្នោតម្នាក់ៗត្រូវចូលរួមរៀនសូត្រគ្រប់វគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាទាំងអស់តាមការអញ្ជើញរបស់ គ.ជ.ប។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤០ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្គាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន។

មាត្រា១៤៥ .-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២៥.000.000 (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត។

មាត្រា១៤៦ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន)រៀល ទៅ ១0.000.000 (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា ៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោតដូចបានបញ្ញត្តក្នុងមាត្រា ១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៥០ .-

ត្រូវជាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្ខាំ បញ្ជាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា ១៥១ .-

ត្រូវជាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀតចំពោះជនណាដែលមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

ខ- សម្រាប់មាត្រាអំពីទោសឫញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៦៩ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម៖

- ចេញបង្ហាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន។

មាត្រា ១៧៤ .-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត។

មាត្រា ១៧៥ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៤៨៩ (បទផលិត ឬធ្វើចរាចរណ៍ អាវុធសម្រាប់ប្រហាផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិនៃ មាត្រា ២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុ អនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូច មានចែងក្នុងកាថាខណ្ឌទី ១ នៃមាត្រានេះ។

មាត្រា ១៧៧ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់ លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោត បង្ខាប់ បញ្ជា លួងលោម បោកបញ្ឆោត ឬធ្វើ សកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយក គណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំ ការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យចូលបម្រើការងារក្នុងគណៈកម្មា ធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈ ពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែង ក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា ១៧៨ .-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀលទៅ ២៥.០០០.០០០ (ម្ភៃប្រាំ លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿង សម្គាល់ សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

ឧបសម្ព័ន្ធនី ២

ក្រមសីលធម៌

សម្រាប់

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ

ក្នុងដំណើរការបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយ សេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អនុវត្តក្នុងដំណើរការបោះឆ្នោតតាមសិទ្ធិ និងភារកិច្ចរបស់ខ្លួនតាមការកំណត់នៃច្បាប់។

២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធានសំខាន់ៗសម្រាប់គណបក្សនយោបាយ បេក្ខជនដែលឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយយកចិត្តទុកដាក់អនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួនដើម្បីឱ្យ៖

- ការបោះឆ្នោតប្រព្រឹត្តទៅស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត
- ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងតម្លាភាព គ្មានអំពើហិង្សា គ្មានការបង្ខិតបង្ខំ និងគ្មានការបំភិតបំភ័យ។

៣- ខ្លឹមសារ

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះគណបក្សនយោបាយ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយដែលបានចុះឈ្មោះ ហើយត្រូវបានទទួលស្គាល់ដោយ គ.ជ.ប។

៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **គណបក្សនយោបាយ** សំដៅដល់គណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ហើយត្រូវបានប្រកាសទទួលស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ។

៤.២- **គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត** សំដៅដល់គណបក្សនយោបាយដែលត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃ និងបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតនៅ គ.ជ.ប ឬនៅគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ហើយត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៣- **បេក្ខជន** សំដៅដល់អ្នកដែលត្រូវបានគណបក្សនយោបាយតែងតាំងឱ្យឈរឈ្មោះជាបេក្ខជនក្នុងបញ្ជីបេក្ខជនតាមមណ្ឌលបោះឆ្នោត និងត្រូវបានទទួលស្គាល់ជាផ្លូវការ។

៤.៤- **ភ្នាក់ងារគណបក្សនយោបាយ** សំដៅដល់ភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងដែលជាតំណាងរបស់គណបក្សនយោបាយ ដើម្បីចូលរួមសង្កេតការណ៍មើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោត និងត្រូវបានទទួលស្គាល់ជាផ្លូវការ។

๔.๕- ការបោះឆ្នោត សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

๔.៦- ជំណើរការបោះឆ្នោត សំដៅលើ៖

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការយោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ តារកិច្ច និងការធធួលខុសត្រូវបស់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយមានសិទ្ធិសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត។

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិពេញលេញ ស្មើភាពចូលរួមប្រកបដោយការទទួលខុសត្រូវក្នុងការបោះឆ្នោត ជាអាទ៍ ការយោសនាបោះឆ្នោត ការបោះឆ្នោត ការសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ការប្តឹងជំទាស់ ឬប្តឹងតវ៉ា និងការទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត។

បេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារគណបក្សនយោបាយសង្កេតការណ៍បោះឆ្នោតឡើយ។

៥.១- សិទ្ធិ និងតារកិច្ចរបស់គណបក្សនយោបាយ និងបេក្ខជន

គណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិ និងភារកិច្ចដូចខាងក្រោម៖

๕.១.១ គណបក្សនយោបាយមានសិទ្ធិ៖

- ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ តវ៉ាចំពោះការសម្រេចរបស់ គ.ជ.ប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- ប្តឹងតវ៉ាទៅ គ.ជ.ប ចំពោះការសម្រេចរបស់ គធ.ខប បដិសេធការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- ប្តឹងតវ៉ាទៅ គធ.ខប និងប្តឹងបន្តទៅ គ.ជ.ប ចំពោះការសម្រេចរបស់ គយ.សប បដិសេធការសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

៥.១.២ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិលើកស្លាកគណបក្សនយោបាយនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពសាធារណៈ។

៥.១.៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនមានសិទ្ធិសុំជួលរោងមហោស្រពមណ្ឌលកីឡា ឧទ្យានសាធារណៈ ឬទីធ្លាសាធារណៈ ឬសាលសាធារណៈ ពីអ្នកគ្រប់គ្រងទីកន្លែងនោះ ដើម្បីប្រើប្រាស់សម្រាប់បម្រើការយោសនាបោះឆ្នោត ដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់មុនក្រោយ។

៥.១.៤ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនមានសិទ្ធិធ្វើសកម្មភាពយោសនាបោះឆ្នោតនៅលើទីធ្លាឯកជន ឬសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងទៅគណៈកម្មការរៀបចំការបោះឆ្នោតពាក់ព័ន្ធ។

៥.១.៥ ក្នុងការយោសនាបោះឆ្នោត គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោតមានសិទ្ធិធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោត។

៥.១.៦ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ ត្រូវទទួលខុសត្រូវផ្ទាល់លើខ្លឹមសារ និងសកម្មភាពយោសនាបោះឆ្នោតរបស់ខ្លួន។

៥.១.៧ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៥.១.៨ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ ត្រូវយកចិត្តទុកដាក់គោរពឱ្យបានល្អនូវរាល់កម្មវិធីយោសនាទាំងអស់ ដែលសម្របសម្រួលដោយអាជ្ញាធរដែនដី។

៥.១.៩ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ មានសិទ្ធិធ្វើសកម្មភាពយោសនាបោះឆ្នោតដោយសេរី ក្នុងទីស្នាក់ការគណបក្សនយោបាយរបស់ខ្លួនទូទាំងប្រទេស។

៥.១.១០ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតមានសិទ្ធិសុំផ្លាស់ប្តូរភ្នាក់ងារពេញសិទ្ធិ ឬ/និង ភ្នាក់ងារបម្រុងរបស់ខ្លួនទៅតាមកាលកំណត់ចុងក្រោយរបស់ គ.ជ.ប។

៥.១.១១ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ មានសិទ្ធិប្តឹងជំទាស់ ឬ ប្តឹងតវ៉ាទៅតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញ និងមានភស្តុតាង បញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការ បោះឆ្នោត។

៥.១.១២ គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅ គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏ បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលបាន ធ្វើខុសពីកាលបរិច្ឆេទ ដែលធ្វើខុសពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយ ដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត បន្ទាប់ពីការប្រកាសលទ្ធផលបោះ ឆ្នោតបណ្តោះអាសន្នក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ។

៥.១.១៣ គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបេក្ខជនទាំងអស់ មានសិទ្ធិស្មើភាពគ្នា ក្នុងការទទួលបានការការពារសន្តិសុខ សុវត្ថិភាព ក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុង ដំណើរការបោះឆ្នោត។

៥.១.១៤ គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារយោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត។

៥.២- សិទ្ធិ និងតួនាទីកិច្ចរបស់ភ្នាក់ងារគណបក្សនយោបាយ

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិ និងការកិច្ចដូច ខាងក្រោម៖

៥.២.១ មានវត្តមាននៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និង ការិយាល័យរាប់សន្លឹកឆ្នោតដែលខ្លួនបានទទួលការអនុញ្ញាតតាមទីកន្លែង និងពេលវេលា ដែលបានកំណត់ដោយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប។

៥.២.២ ចូលទៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យ រាប់សន្លឹកឆ្នោតបានតែម្នាក់ប៉ុណ្ណោះ។ ភ្នាក់ងារបម្រុងត្រូវរង់ចាំនៅក្រៅការិយាល័យ ដើម្បី ជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីមានការផ្លាស់ប្តូរ។

៥.២.៣ ជំទាស់រាល់ការរំលោភទៅលើច្បាប់ ឬលើបទបញ្ជា និងនីតិវិធី ដែលខ្លួនបានឃើញផ្ទាល់។ ការជំទាស់ត្រូវធ្វើឡើងទៅប្រធាន ក.ច.ប ប្រធាន គ.ក.ប ប្រធាន គ.ក.រ។ នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ ការជំទាស់អាចលើកឡើងដោយផ្ទាល់មាត់ ឬ/និង ទៅតាមទម្រង់បែបបទរបស់ គ.ជ.ប។

៥.២.៤ ចុះហត្ថលេខាលើរបាយការណ៍ ឬកំណត់ហេតុផ្សេងៗដែលកំណត់ដោយ គ.ជ.ប។

៥.២.៥ ចុះហត្ថលេខា ឬផ្ទិតមេដៃនៅលើកំណត់ហេតុបោះឆ្នោត និងកំណត់ហេតុរាប់សន្លឹកឆ្នោត។

៥.២.៦ ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិទទួលបានកំណត់ហេតុរាប់សន្លឹកឆ្នោតសម្រាប់ភ្នាក់ងារដែលមានវត្តមាន។

៥.២.៧ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ គ.ជ.ប អាជ្ញាធរដែនដី អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមក។

៥.២.៨ ប្តឹងជំទាស់ ឬប្តឹងតវ៉ាទៅតាមបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ប្រសិនបើពិនិត្យឃើញថាមានកស្តុតាងបញ្ជាក់ពីអំពើណាមួយផ្ទុយនឹងច្បាប់ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ក្នុងដំណើរការបោះឆ្នោត។

៥.២.៩ ទទួលបានដោយស្មើភាពគ្នា ក្នុងការការពារសន្តិសុខ សុវត្ថិភាពក្នុងអំឡុងពេលធ្វើសកម្មភាពនានាក្នុងដំណើរការបោះឆ្នោត។

៥.៣- ការទទួលខុសត្រូវរបស់គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជនឈរឈ្មោះបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយត្រូវគោរព និងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះ។

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលបេក្ខជន និងភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួនឱ្យមានការយល់ដឹងត្រឹមត្រូវអំពីការបោះឆ្នោត អំពីតួនាទី និងភារកិច្ចរបស់ខ្លួនចូលរួមក្នុងការបោះឆ្នោត។

៦- បម្រាមចំពោះគណបក្សនយោបាយ បេក្ខជន ភ្នាក់ងារគណបក្សនយោបាយ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន ភ្នាក់ងារគណបក្សនយោបាយមិនត្រូវ៖

៦.១ ប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.២ ញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឱ្យប្រព្រឹត្តអំពើរំលោភបំពាន គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀត។

៦.៣ និយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជន អ្នកគាំទ្រ ឬលើបុគ្គលណាមួយ។

៦.៤ រិះគន់ទៅលើបុគ្គលិកលក្ខណៈផ្ទាល់របស់បុគ្គល ឬគណបក្សនយោបាយដទៃ។

៦.៥ ធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឱ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ។

៦.៦ ផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជារង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ក្នុងរយៈពេលឃោសនាបោះឆ្នោត ថ្ងៃស និងថ្ងៃបោះឆ្នោត។

៦.៧ ធ្វើសកម្មភាពឃោសនាបោះឆ្នោត នៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ៦ (ប្រាំមួយ) ព្រឹក។

៦.៨ ធ្វើសកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ២ (ពីរ) រសៀល។

៦.៩ ជ្រៀតជ្រែក ឬធ្វើឱ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.១០ ប្រើកម្លាំង ឬអំពើហិង្សាណាមួយ ដើម្បីរារាំងអ្នកមានសិទ្ធិបោះឆ្នោតមិនឱ្យទៅចុះឈ្មោះបោះឆ្នោត ទៅបោះឆ្នោត ឬឈរឈ្មោះជាបេក្ខជន។

៦.១១ រារាំងបេក្ខជន និងអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោតតាមការកំណត់របស់ គ.ជ.ប។

៦.១២ ប្រើកម្លាំង អំពើហិង្សា អំពើរំលោភ បំភិតបំភ័យ ឬប្រើពាក្យសំដីប្រមាថមើលងាយធ្វើឱ្យមានការភ័យខ្លាច ការគាន់ច្រឡំធ្វើឱ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។

៦.១៣ បង្កការរំខានផ្សេងៗ ដែលធ្វើឱ្យការបោះឆ្នោតមិនអាចប្រព្រឹត្តទៅបាន។

៦.១៤ បង្កការរំខានដល់ការងាររាប់សន្លឹកឆ្នោត។

៦.១៥ ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។

៦.១៦ ទិញសន្លឹកឆ្នោត ដោយសម្ភារ ឬដោយប្រាក់កាស។

៦.១៧ បង្ហាប់បញ្ជា ឬលួងលោមបោកបញ្ឆោតឱ្យអ្នកបោះឆ្នោតជ្រើសយកគណបក្សនយោបាយតាមការចង្អុលបង្ហាញ ឬតាមមធ្យោបាយណាមួយផ្សេងទៀតក្នុងពេលបោះឆ្នោត។

៦.១៨ ធ្វើឱ្យរបើកហិបឆ្នោត ដាច់ ឬរហែក ឬរបូតសោឃ្លុំ ឬគ្រឿងសម្គាល់សម្រាប់សុវត្ថិភាពហិបឆ្នោត ឬមានចេតនាធ្វើឱ្យបាត់ ឬលួច ឬដូរ ឬដណ្តើម ឬបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

៦.១៩ ទាមទារ ឬចូលទៅក្នុងការិយាល័យ ដើម្បីពិនិត្យមើលការបោះឆ្នោត ឬការរាប់សន្លឹកឆ្នោត បន្ថែមលើភ្នាក់ងារគណបក្សនយោបាយដែលបានអនុញ្ញាតជាផ្លូវការរួចហើយ។

៦.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត។

៦.២១ ជ្រៀតជ្រែកដល់ដំណើរការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ឬរំខានដល់ដំណើរការផ្សេងៗទៀត ដែលទាក់ទងនឹងការងារបោះឆ្នោត។

៦.២២ ញុះញង់ឱ្យមានការស្អប់ខ្ពើមប្រកាន់បក្សពួក ជាតិសាសន៍ ភេទ ឋានៈក្នុងសង្គម សាសនា និងតាមគ្រប់រូបភាពទាំងអស់។

៦.២៣ រារាំង រំខាន ឬបង្កើតពាក្យចចាមអារ៉ាមនាំឱ្យមានការភ្ញាក់ផ្អើល ឬទប់ស្កាត់ប្រជាពលរដ្ឋមិនឱ្យចូលរួមការប្រជុំ ការហែក្បួនណាមួយរបស់គណបក្ស ឬបេក្ខជនដទៃទៀត។

៦.២៤ ប្រើប្រាស់ភាសា ពាក្យសំដីដែលស្តែងចេញពីការសេពសុរា ឬគ្រឿងញៀនជាហេតុនាំឱ្យមានការប្រព្រឹត្តអំពើហិង្សា ឬការបង្ខិតបង្ខំ បំភិតបំភ័យណាមួយ។

៦.២៥ ដាក់តាំង ឬបង្ហាញ ឬចែកចាយខិត្តបណ្ណ ដែលពិពណ៌នាអំពីការវាយប្រហារដោយពាក្យសម្តី ឬដោយអាវុធ។

៦.២៦ ប្រើភាសា ឬរូបភាពរំលោភបំពាន ខ្វះសីលធម៌ ដែលមានលក្ខណៈអុជអាល បង្ក្រជម្លោះ ឬបង្កឱ្យមានបរិយាកាសតានតឹង ឬជាងនេះទៀតបង្កឱ្យកើតមានអំពើហិង្សាតាមរយៈសេចក្តីថ្លែងការណ៍ សេចក្តីប្រកាស ខិត្តបណ្ណ រូបភាពបិទផ្សាយ និងសម្ភារយោសនាបោះឆ្នោតផ្សេងទៀត។

៦.២៧ ចាក់ផ្សាយព័ត៌មាន ឬការប្រើប្រាស់ឧបករណ៍បំពងសំឡេងតាមផ្លូវសាធារណៈណាមួយ ដែលមានសំឡេងខ្លាំងៗលុបលើសំឡេងយោសនារបស់គណបក្សនយោបាយ ឬបេក្ខជនដទៃទៀត។

៦.២៨ ធ្វើសកម្មភាពយោសនាដោយឧបករណ៍បំពងសំឡេង នៅក្បែរមន្ទីរពេទ្យ ឬក្បែរសាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា។

៦.២៩ ប្រើប្រាស់ព្រះនាយាលក្ខណ៍ ឬព្រះនាមព្រះមហាក្សត្រ ឬព្រះនាមព្រះមហាវីរក្សត្រ ឬស្លាកសញ្ញា គ.ជ.ប ដើម្បីយោសនារកសំឡេងឆ្នោត។

៦.៣០ ចម្លងយកសញ្ញាសម្គាល់របស់គណបក្សនយោបាយដទៃទៀតមកប្រើប្រាស់ បម្រើឱ្យផលប្រយោជន៍គណបក្សនយោបាយរបស់ខ្លួន។

៦.៣១ បិទបណ្ណ ខិត្តបណ្ណ រូបភាពយោសនា សេចក្តីថ្លែងការណ៍នយោបាយ ឬឯកសារយោសនាដទៃទៀតពីលើឯកសារផ្សេងៗរបស់អ្នកដទៃ ឬគណបក្សនយោបាយដទៃ។

៦.៣២ បក ឬធ្វើឱ្យខូចខាត ឬបំផ្លាញចោលនូវបណ្ណបិទផ្សាយ ខិត្តបណ្ណ សេចក្តីប្រកាសនយោបាយ ឬឯកសារយោសនា ឬសេចក្តីណែនាំផ្សេងៗរបស់គណបក្សនយោបាយដទៃ ក្រសួង ស្ថាប័ននានា ឬអាជ្ញាធរដែនដី។

៦.៣៣ បិទបណ្ណផ្សព្វផ្សាយរូបភាពយោសនា សេចក្តីប្រកាសនយោបាយ ចងបដា ឬឯកសារយោសនាបោះឆ្នោតដទៃទៀតក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ឬការិយាល័យបោះឆ្នោតក្នុងចម្ងាយតិចជាង១០០ (មួយរយ) ម៉ែត្រ លើកលែងតែទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ។

៦.៣៤ ចងបដា ឬរូបសញ្ញាយោសនាណាមួយឆ្លងកាត់ផ្លូវសាធារណៈ។

៦.៣៥ ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារយោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឱ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ។

៦.៣៦ ប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដូចជា រថយន្ត ទោចក្រយានយន្ត និងជលយានគ្រប់ប្រភេទ ដែលប្រើប្រាស់ស្លាកសញ្ញារាជការ ឬរដ្ឋ រាជរដ្ឋាភិបាល នគរបាល ឬ ន.ប ខេមរភូមិន្ទ ឬ ខ.ម ដើម្បីធ្វើសកម្មភាពយោសនាបោះឆ្នោតឱ្យគណបក្សណាមួយ ឬបេក្ខជនណាម្នាក់ និងដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត។

៦.៣៧ ផ្តល់វិភាគទាន ជូនសគុណ ឬផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់កាស ឬជាសម្ភារ ដើម្បីទទួលបានសំឡេងឆ្នោត ទោះបីតាមមធ្យោបាយណាក៏ដោយក្នុងអំឡុងពេលយោសនាបោះឆ្នោតរហូតដល់ថ្ងៃបោះឆ្នោត។

៦.៣៨ ប្រើប្រាស់តួនាទី សិទ្ធិអំណាច បុព្វសិទ្ធិ ឥទ្ធិពល ឬសិទ្ធិអំណាចខាងមេបា ខាងមេគ្រួសារ ខាងអាពាហ៍ពិពាហ៍ ខាងសាសនា និងខាងប្រពៃណីទំនៀមទម្លាប់ ដើម្បីបង្ខំ ឬគំរាមកំហែង ក្នុងគោលបំណងទទួលបានការគាំទ្រ។

៦.៣៩ ក្លែងបន្លំ បំផ្លាញ ឬគូសសញ្ញាសម្គាល់ណាមួយលើសន្លឹកឆ្នោត។

៦.៤០ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោត។

៦.៤១ នៅក្បែរបន្ទប់សម្ងាត់ សម្រាប់គូសសន្លឹកឆ្នោត។

៦.៤២ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ ត្រូវជៀសវាងៈ

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.៤៣ ល្បែង

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ មិនត្រូវលេងល្បែងស៊ីសងឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧- សំណូមពរ និងការអនុវត្ត

គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម។

៧.១- សំណូមពរ

គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយត្រូវគោរពតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះឱ្យបានខ្ជាប់ខ្ជួន។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤២ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្ម ទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រាវាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬ រាវាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅ បញ្ជីបោះឆ្នោត។
- បង្ការអុកឡុក ឬរាវាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យ បញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះ បោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើ ហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រាវាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រាវាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាម ការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្ការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្ការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិ ការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៤៣ .ـ

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា ១៤២ ខាងលើនេះ។

មាត្រា១៥០ .ـ

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោត បង្ក្រាប់បញ្ជាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៥១ .ـ

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៥២ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ នៅក្នុងពេលយោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល 0៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

មាត្រា១៥៣ .-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ៣0.000.000 (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥២ ខាងលើនេះ។

មាត្រា១៥៥ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្សួនយោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា ៧២ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល 0៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

មាត្រា១៥៦ .-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥៥ ខាងលើនេះ។

មាត្រា១៥៧ .-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា ៧២ នៃច្បាប់នេះ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៦០ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា១៦២ .-

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ។

២- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៧១ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្ម ទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- ការារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬ ការារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅ បញ្ជីបោះឆ្នោត។
- បង្ការអុកឡុក ឬការារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យ បញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះ បោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើ ហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- ការារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- ការារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យយោសនាបោះឆ្នោត តាម ការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្ការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្ការរំខានមិនឱ្យពាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាង លើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៧២ .-

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាក ពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន)

រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្ម ទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា ១៧១ ខាងលើនេះ។

មាត្រា១៧៧ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោត បង្ហាប់បញ្ជាលូងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឱ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៧៨ .-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២៥.000.000 (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលមានចេតនាធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឱ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឱ្យបាត់ ដកហូត លូច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត។

...

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា១៨១ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឱ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

មាត្រា១៨២ .-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៨១ ខាងលើនេះ។

មាត្រា១៨៤ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៦៨ ក្នុងការហែក្សួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី១ នៃមាត្រា ៧០ នៃច្បាប់នេះ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត។

មាត្រា១៨៥ .-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៨៤ ខាងលើនេះ។

មាត្រា១៨៨ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

មាត្រា១៩0 .-

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ។

អង្គការ ឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការ ឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ។

ឧបសម្ព័ន្ធទី ៣

ក្រមសីលធម៌

សម្រាប់

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងដំណើរការបោះឆ្នោត

១- សេចក្ដីផ្ដើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោតតាំងពីចាប់ផ្ដើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានអនុវត្តក្នុងដំណើរការបោះឆ្នោត ដើម្បីលើកកម្ពស់ថែមទៀតនូវប្រសិទ្ធភាពនៃការផ្សព្វផ្សាយអំពីការបោះឆ្នោតប្រកបដោយវិជ្ជាជីវៈ ត្រឹមត្រូវ និងតម្លាភាព។

២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធានសំខាន់ៗ ដើម្បីឱ្យប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន អនុវត្តសេរីភាពសារព័ត៌មាន និងសេរីភាពខាងការផ្សព្វផ្សាយព័ត៌មាន ផ្តល់ព័ត៌មានអំពីការបោះឆ្នោតបានត្រឹមត្រូវ ច្បាស់លាស់ ទាន់ពេលវេលា ចូលរួមធានាឱ្យដំណើរការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។

៣- ១សាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ដែលធ្វើការផ្សព្វផ្សាយព័ត៌មាន និងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត។

៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន** សំដៅលើអង្គភាពទាំងឡាយដែលធ្វើសកម្មភាពនៃការផ្សព្វផ្សាយព័ត៌មាន ដែលត្រូវធ្វើឡើងជាទៀងទាត់ តាមរយៈការបោះពុម្ព ការផ្សព្វផ្សាយ រួមមាន សារព័ត៌មានទស្សនាវដ្តី និងតាមរយៈ វិទ្យុ ទូរទស្សន៍ និងតាមរយៈគេហទំព័រ។

៤.២- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៣- **ដំណើរការបោះឆ្នោត** សំដៅលើ៖

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់មានសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវក្នុងការយកព័ត៌មាន និងផ្សព្វផ្សាយអំពីការងារបោះឆ្នោត។

៥.១- សិទ្ធិរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់មានសិទ្ធិដូចខាងក្រោម៖

៥.១.១ សមាគមអ្នកសារព័ត៌មាន ឬអង្គភាពអ្នកសារព័ត៌មាន ឬអ្នកសារព័ត៌មានឯករាជ្យដែលមានបំណងចូលរួមយកព័ត៌មានក្នុងដំណើរការបោះឆ្នោត មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានដោយផ្ទាល់ទៅ គ.ជ.ប។

៥.១.២ អាចទាញយកពាក្យសុំចុះឈ្មោះជាអ្នកសារព័ត៌មានពីគេហទំព័រ គ.ជ.ប បានដោយឥតគិតថ្លៃ។

៥.១.៣ បំពេញបែបបទនៃការស្នើសុំចុះឈ្មោះជាអ្នកសារព័ត៌មាន ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតនីមួយៗ។

៥.១.៤ ថត និងយកព័ត៌មានអំពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការយោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥.១.៥ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលមានបំណងថតយករូបភាពក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវជម្រាបជូនដំណឹងទៅប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ នោះជាមុន។

៥.១.៦ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីជួយដោះស្រាយឱ្យបានទាន់ពេលវេលា ។

៥.២- តួនាទីរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវផ្សព្វផ្សាយព័ត៌មានដល់សាធារណជន អ្នកបោះឆ្នោតឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។ ក្នុងន័យនេះ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានទាំងអស់ត្រូវបំពេញការកិច្ចដូចខាងក្រោម៖

៥.២.១ ចូលរួមក្នុងការអប់រំអ្នកបោះឆ្នោត ដើម្បីឱ្យអ្នកបោះឆ្នោតមានការយល់ដឹងត្រឹមត្រូវពីការបោះឆ្នោត។

៥.២.២ ផ្តល់ព័ត៌មាន និងការអប់រំអំពីការបោះឆ្នោតដែលងាយយល់សម្រាប់អ្នកបោះឆ្នោត រួមមានសិទ្ធិចុះឈ្មោះបោះឆ្នោត សិទ្ធិបោះឆ្នោត និងសិទ្ធិចូលរួមក្នុងសកម្មភាពផ្សេងៗទៀតនៃការបោះឆ្នោតតាមច្បាប់កំណត់។

៥.២.៣ ស្វែងរក និងផ្សព្វផ្សាយព័ត៌មានអំពីទស្សនៈ និងគំនិតផ្សេងៗគ្នារបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការបោះឆ្នោត។

៥.២.៤ ផ្សព្វផ្សាយព័ត៌មានអំពីសារៈសំខាន់នៃការចូលរួមរបស់ព្រះសង្ឆ យុវជន យុវនារី ស្ត្រី ជនជាតិភាគតិច និងជនមានពិការភាព ក្នុងជីវភាពសង្គម និងនយោបាយដើម្បីបង្កើនការយល់ដឹង។

៥.២.៥ ចូលរួមលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋ អំពីដំណើរការបោះឆ្នោត តាមរយៈការអប់រំ និងកម្មវិធីផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យអ្នកបោះឆ្នោតបានទទួលព័ត៌មានគ្រប់ជ្រុងជ្រោយ។

៥.២.៦ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរដ្ឋ ត្រូវមានអព្យាក្រឹតភាព យុត្តិធម៌ និងភាពត្រឹមត្រូវ ក្នុងការផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងដំណើរការបោះឆ្នោត។ ដោយឡែកប្រព័ន្ធផ្សព្វផ្សាយព័ត៌មានឯកជន ត្រូវចូលរួមសហការធ្វើការផ្សព្វផ្សាយព័ត៌មានប្រកបដោយអព្យាក្រឹត យុត្តិធម៌ និងត្រឹមត្រូវ។

៥.២.៧ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ត្រូវគោរពតាមក្រមសីលធម៌ វិជ្ជាជីវៈអ្នកសារព័ត៌មាន គោរពច្បាប់ស្តីពីរបបសារព័ត៌មាន គោរពច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងក្រមសីលធម៌នេះ។

៥.២.៨ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ ត្រូវខិតខំប្រឹងប្រែងឱ្យអស់សមត្ថភាពក្នុងការចូលរួមធ្វើឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស។

៥.៣- ការទទួលខុសត្រូវ និងកាតព្វកិច្ចរបស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន និងមានកាតព្វកិច្ចគោរពគោលការណ៍ចាំបាច់ដូចតទៅ៖

៥.៣.១ គោរពសច្ចធម៌ និងគោរពសិទ្ធិយល់ដឹងនូវសច្ចធម៌របស់សាធារណជន។

៥.៣.២ គោរពសិទ្ធិ និងសេរីភាពរស់នៅក្នុងជីវភាពឯកជនរបស់បុគ្គល។

៥.៣.៣ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ត្រូវបានលើកទឹកចិត្តក្នុងលក្ខណៈជាដៃគូជាមួយ គ.ជ.ប ដើម្បីធ្វើការផ្តល់ព័ត៌មាន និងអប់រំអ្នកបោះឆ្នោតអំពីការបោះឆ្នោត។

៥.៣.៤ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ ត្រូវបង្ហាញនូវកម្រិតគុណភាពខ្ពស់នៃវិជ្ជាជីវៈអ្នកសារព័ត៌មាន និងត្រូវផ្តល់ព័ត៌មាន និងហេតុការណ៍ថ្មីៗឱ្យបានសមរម្យពិតប្រាកដ និងឥតលម្អៀង ដើម្បីធានានូវយុត្តិធម៌ និងតុល្យភាពព័ត៌មានសម្រាប់គណបក្សនយោបាយដែលចូលរួមក្នុងការបោះឆ្នោត។

៥.៣.៥ ពង្រឹង និងណែនាំអ្នកសារព័ត៌មាន មិនត្រូវបោះបង់គោលជំហរ ឬក្រមសីលធម៌របស់ខ្លួនដោយសារតែអំណោយ ផលប្រយោជន៍ ឬចំណង់ចំណូលចិត្តពិសេសទេ។

៥.៣.៦ ត្រូវផ្ទៀងផ្ទាត់អំពីប្រភពព័ត៌មាន ភាពសុក្រឹត និងភាពច្បាស់លាស់នៃហេតុការណ៍ និងព្រឹត្តិការណ៍ដែលខ្លួនត្រូវរាយការណ៍។

៥.៣.៧ ត្រូវរាយការណ៍តែតាមហេតុការណ៍ ដែលខ្លួនដឹងពីប្រភពដើមតែប៉ុណ្ណោះ។ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានមិនត្រូវបំបាត់ចោលនូវព័ត៌មានសំខាន់ៗ ឬកែបន្ថែ ឯកសារផ្សេងៗឡើយ។

៥.៣.៨ ប្រើវិធីសុចរិត ត្រឹមត្រូវ ដើម្បីស្វែងរកដំណឹង រូបថត និងឯកសារផ្សេងៗ។

៥.៣.៩ ត្រូវផ្សាយដំណឹងទាំងឡាយដោយសុចរិត ព្រមទាំងធ្វើអត្ថាធិប្បាយ ឬរិះគន់ឱ្យបានត្រឹមត្រូវ និងសមស្របតាមគោលការណ៍គតិយុត្តិធម៌ និងសីលធម៌។

៥.៣.១០ ថ្លឹងថ្លែងឱ្យបានត្រឹមត្រូវ មានប្រភពឯកសារច្បាស់លាស់ និងទទួលខុសត្រូវខ្ពស់ក្នុងការផ្សព្វផ្សាយលទ្ធផលនៃការបោះឆ្នោត។

៥.៣.១១ ត្រូវផ្តល់ព័ត៌មានឱ្យបានត្រឹមត្រូវ មិនលម្អៀង និងដោយមានការថ្លឹងថ្លែងឱ្យមានតុល្យភាព។

៥.៣.១២ ផ្តល់ឱកាសស្មើគ្នាដល់គណបក្សនយោបាយ ឬបេក្ខជនដែលចូលរួមក្នុងការបោះឆ្នោតឱ្យមានលទ្ធភាពប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន។

៥.៣.១៣ ក្នុងពេលយុទ្ធនាការឃោសនាបោះឆ្នោត ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានរបស់រដ្ឋ និងឯកជនត្រូវបែងចែកឱ្យបានច្បាស់ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពជាផ្លូវការរបស់តំណាងរាជរដ្ឋាភិបាល និងសកម្មភាពឃោសនាបោះឆ្នោត ដែលធ្វើឡើងក្នុងនាមគណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រ។

៥.៣.១៤ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន ត្រូវធ្វើការបែងចែកឱ្យបានច្បាស់លាស់រវាងហេតុការណ៍ជាក់ស្តែង និងទស្សនៈយោបល់។ ការផ្សព្វផ្សាយព័ត៌មានត្រូវឆ្លុះបញ្ចាំងពីហេតុការណ៍ជាក់ស្តែង។

៥.៣.១៥ ត្រូវចៀសវាងការផ្សព្វផ្សាយព័ត៌មាន ដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៥.៣.១៦ ត្រូវធ្វើការកែតម្រូវនូវព័ត៌មានណា ដែលចេញផ្សាយរួចហើយៗមានលក្ខណៈមិនជាក់លាក់ និងនាំឱ្យមានការយល់ច្រឡំ។

៦- បម្រាមចំពោះប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

ត្រូវបានហាមឃាត់ ចំពោះសកម្មភាពដែលត្រូវបានចាត់ទុកថា ជាការរំលោភធ្ងន់ធ្ងរខាងផ្នែកវិជ្ជាជីវៈអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចខាងក្រោម៖

៦.១ ការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យមានការភ័ន្តច្រឡំ នាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។

៦.២ ការបន្លំឱ្យគេយល់ខុសដូចជា ការសរសេរបញ្ជិតបញ្ជៀង ដើម្បីឱ្យសាធារណជនមានការសង្ស័យដោយអយុត្តិធម៌លើបុគ្គលណាម្នាក់ ក្រុមបក្សណាមួយ។

៦.៣ ការផ្សព្វផ្សាយព័ត៌មានដោយសំអាងលើពាក្យចចាមអារ៉ាម ឬព័ត៌មានដែលពុំមានភស្តុតាងបញ្ជាក់។

៦.៤ ការផ្សព្វផ្សាយដែលមានលក្ខណៈមូលបង្កាច់ បរិហារកេរ្តិ៍ និងជេរប្រមាថដល់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រណាមួយ។

៦.៥ ការប្រើប្រាស់ភាសាញុះញង់ ឬវាយប្រហារ ដែលអាចបង្កភាពគ្មានសណ្តាប់ធ្នាប់ ឬអាចឱ្យមានអំពើហិង្សា។

៦.៦ ការបោះពុម្ពផ្សាយ ឬចែកចាយព័ត៌មានណាដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបង្កឱ្យមានការភ័យខ្លាច ឬបង្កជាអំពើហិង្សាណាមួយកើតឡើង។

៦.៧ ការផ្សព្វផ្សាយព័ត៌មានដែលញុះញង់ឱ្យមានការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា មតិ ឬនិន្នាការនយោបាយ ដើមកំណើត ឋានៈ សង្គម ធនធាន ឬស្ថានភាពដទៃទៀត។

៦.៨ ការបោះពុម្ពផ្សាយ ឬផ្សាយបន្តនូវព័ត៌មានដែលបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខជាតិ ស្ថេរភាពនយោបាយ និងស្ថេរភាពសង្គម។

៦.៩ ការបោះពុម្ពផ្សាយ ឬផ្សាយបន្តហេតុការណ៍ ឬព្រឹត្តិការណ៍មិនពិតដែលជាការជេរប្រមាថការមើលងាយដល់ស្ថាប័នជាតិ។

៦.១០ ការផ្សព្វផ្សាយមានលក្ខណៈរើសអើង ប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១១ ការសម្តែងចេញនូវនិន្នាការនយោបាយ ការមាក់ងាយ ឬការប្រមាថ តាមរយៈកាយវិការ ឬឥរិយាបថជាក់ស្តែងផ្សេងទៀត។

៦.១២ ការបញ្ចេញ បញ្ចូលនូវទស្សនៈផ្ទាល់ខ្លួន ឬក៏ធ្វើបុរេនិច្ឆ័យនៅក្នុងហេតុការណ៍កំពុងកើតមានដែលខ្លួនធ្វើសេចក្តីរាយការណ៍។

៦.១៣ ការជ្រៀតជ្រែក ឬរំខានដល់ការងារចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត។

៦.១៤ ការផ្សព្វផ្សាយមិនឱ្យប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោត។

៦.១៥ ការទទួលសំណូក អំណោយក្នុងបែបណាមួយ ឬការជំរិតយកប្រាក់ ដើម្បីជាថ្នូរនឹងការផ្សព្វផ្សាយ ឬមិនផ្សព្វផ្សាយនូវព័ត៌មានណាមួយ។

៦.១៦ ការធ្វើសម្ភាសន៍នៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៦.១៧ ការប្រើប្រាស់តូនាទីរបស់ខ្លួន (ទោះឯកជន ឬរដ្ឋ) ដើម្បីគាបសង្កត់លើមន្ត្រីចុះឈ្មោះបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ឬគាបសង្កត់លើអ្នកសង្កេតការណ៍ ឬភ្នាក់ងារគណបក្សនយោបាយ ឬអ្នកបោះឆ្នោត។

៦.១៨ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

អ្នកសារព័ត៌មាន ត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.១៩ ល្បែង

អ្នកសារព័ត៌មាន មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧- សំណូមពរ និងការអនុវត្ត

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម។

៧.១- សំណូមពរ

ដើម្បីធានាឱ្យដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មាន ត្រូវគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ច្បាប់ស្តីពីរបបសារព័ត៌មាន និងក្រមសីលធម៌នេះ។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងអ្នកសារព័ត៌មានទាំងអស់ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានអំពីដំណើរការបោះឆ្នោតឱ្យមានប្រសិទ្ធភាពប្រកបដោយវិជ្ជាជីវៈ ឯករាជ្យ ត្រឹមត្រូវ និងមិនលម្អៀង។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រាប់ទោសប្បញ្ញត្តិ

ក- សម្រាប់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤២ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្ម ទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រាវាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬ រាវាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅ បញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរាវាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យ បញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះ បោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើ ហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រាវាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រាវាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យយោសនាបោះឆ្នោត តាម ការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មា ធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

ខ- សម្រង់មាត្រាអំពីទោសបញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៧១ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្ម ទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រាវាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬ រាវាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅ បញ្ជីបោះឆ្នោត។
- បង្ការអុកឡុក ឬរាវាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យ បញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះ បោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើ ហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រាវាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រាវាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យយោសនាបោះឆ្នោត តាម ការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្ការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្ការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាង លើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

ឧបសម្ព័ន្ធទី ៤

ក្រមសីលធម៌

សម្រាប់

អ្នកសង្កេតការណ៍បោះឆ្នោតក្នុងដំណើរការបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោត តាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខសុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះ សម្រាប់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ និងតម្លាភាពនៃការបោះឆ្នោត។

២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធានសំខាន់ៗ សម្រាប់ឱ្យអង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកសង្កេតការណ៍បោះឆ្នោត អនុវត្តក្នុងការបំពេញការកិច្ចរបស់ខ្លួនប្រកបដោយជំហរអព្យាក្រឹត មិនលម្អៀង ដើម្បីធានាឱ្យ៖

- កិច្ចសង្កេតការណ៍បោះឆ្នោត ត្រូវធ្វើឡើងដោយសុចរិត និងតម្លាភាព
- អ្នកសង្កេតការណ៍បោះឆ្នោតបំពេញការងារដោយពុំមានការជ្រៀតជ្រែក។

៣- ទិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះសមាគម អង្គការមិនមែនរដ្ឋាភិបាលជាតិ អង្គការមិនមែនរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងអង្គការអន្តរជាតិ និងអ្នកសង្កេតការណ៍ដែលត្រូវបាន គ.ជ.ប អនុញ្ញាតជាផ្លូវការឱ្យសង្កេតការណ៍បោះឆ្នោត។

៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **អ្នកសង្កេតការណ៍ជាតិ** គឺជាជនជាតិខ្មែរ ឬជនបរទេសដែលជាសមាជិកនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ឬជនបរទេស ដែលត្រូវបានអញ្ជើញដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលត្រូវបានទទួលស្គាល់ និងអនុញ្ញាតដោយ គ.ជ.ប។

អ្នកសង្កេតការណ៍អន្តរជាតិ គឺជាអ្នកសង្កេតការណ៍នៃអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការអន្តរជាតិ និងប្រទេសនានាដែលត្រូវបានអញ្ជើញ និងទទួលស្គាល់ដោយរាជរដ្ឋាភិបាល ហើយនឹងអនុញ្ញាតដោយ គ.ជ.ប។

៤.២- **អ្នកសង្កេតការណ៍ជាតិចល័ត** សំដៅលើថ្នាក់ដឹកនាំសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ ដែលត្រូវបាន គ.ជ.ប សម្រេចទទួលស្គាល់ និងអនុញ្ញាតឱ្យសង្កេតមើលដំណើរការបោះឆ្នោតទូទាំងប្រទេស។

៤.៣- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៤- **ដំណើរការបោះឆ្នោត** សំដៅលើ៖

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត

- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍ឆ្នោត

បន្ទាប់ពី គ.ជ.ប បានទទួលស្គាល់ជាផ្លូវការហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍បោះឆ្នោត ដោយឯករាជ្យពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង គ.ជ.ប ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធរដែនដី គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

សិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍ មានដូចខាងក្រោម។

៥.១- សិទ្ធិរបស់អ្នកសង្កេតការណ៍ឆ្នោត

នៅពេលត្រូវបានទទួលស្គាល់ជាផ្លូវការ និងទទួលបានបណ្ណសម្គាល់អ្នកសង្កេតការណ៍រួចហើយ អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិដូចខាងក្រោម៖

៥.១.១ អ្នកសង្កេតការណ៍ជាតិអាចធ្វើដំណើរសង្កេតការណ៍ក្នុងរាជធានី ខេត្ត ដែលអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមរបស់ខ្លួនបានស្នើសុំប៉ុណ្ណោះ លើកលែងតែអ្នកសង្កេតការណ៍ជាតិចល័តទូទាំងប្រទេសដែលត្រូវបានអនុញ្ញាត និងផ្តល់បណ្ណសម្គាល់ខ្លួនដោយ គ.ជ.ប។

៥.១.២ អ្នកសង្កេតការណ៍អន្តរជាតិអាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងដែនដី នៃព្រះរាជាណាចក្រកម្ពុជាដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ។

៥.១.៣ ក្នុងករណីជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយ អ្នកសង្កេតការណ៍ត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោត និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីជួយដោះស្រាយទាន់ពេលវេលា។

៥.១.៤ អមដំណើរជាមួយក្រុមចុះឈ្មោះបោះឆ្នោត (ក.ច.ប) គណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) លេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត (លធ.ខប) គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) និង គ.ជ.ប នៅរាល់ពេលដឹកជញ្ជូនសម្ភារ បរិក្ខារចុះឈ្មោះបោះឆ្នោត ហិបឆ្នោត និងសម្ភារបោះឆ្នោត។

៥.១.៥ សង្កេតការណ៍នូវរាល់សកម្មភាពរបស់ លធ.ខប ក.ច.ប ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ឬ គ.ក.ប ឬ គឃ.សប ឬ គធ.ខប និង គ.ជ.ប នៅមុនពេល ក្នុងពេល និងក្រោយពេលចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត តាមប្រតិទិនកំណត់ដោយ គ.ជ.ប។

៥.១.៦ ចេញ ចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ដោយមិនត្រូវបង្ករការរំខាន។

៥.១.៧ ជួប ឬនិយាយ ឬលើកសំណួរជាមួយបេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោត នៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ហើយកម្មវត្ថុនៃការជជែកនោះ មិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

៥.២- តួនាទីរបស់អ្នកសង្កេតការណ៍ឆ្នោត

អ្នកសង្កេតការណ៍ទាំងឡាយមានភារកិច្ចដូចខាងក្រោម៖

៥.២.១ ត្រូវគោរពច្បាប់ដែលមានជាធរមាននៅព្រះរាជាណាចក្រកម្ពុជា និងត្រូវទទួលស្គាល់ និងគោរពអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា។

៥.២.២ ត្រូវយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។ ក្នុងករណីមានការរំលោភច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធី ត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវ ព្រមទាំងភស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន។

៥.២.៣ ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្ខពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀត ដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ។

៥.២.៤ រក្សាការសម្ងាត់នៃការបោះឆ្នោត។

៥.២.៥ ត្រូវបង្ហាញភស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ចដែលបានសាកសួរខ្លួន ហើយត្រូវពាក់បណ្ណសម្គាល់ខ្លួន ដែលត្រូវបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយ លធ.ខប ឬ គធ.ខប ឬ គ.ជ.ប។

៥.២.៦ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធី ដែលបានកំណត់ដោយ គ.ជ.ប និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរនៃការបោះឆ្នោត ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតណាមួយ។

៥.២.៧ ធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួនឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន។

៥.២.៨ ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធី ដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងអាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរនានាជាបន្ទាន់ ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ផង។

៥.២.៩ ត្រូវគោរពតាមការកំណត់របស់ប្រធាន ក.ច.ប ឬ គ.ក.ប/គ.ក.រ ដែលតម្រូវឱ្យផ្លាស់ប្តូរគ្នាចូលសង្កេតការណ៍ម្តង ៤(បួន) នាក់ ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពី ៤(បួន) នាក់ សម្រាប់ការិយាល័យមួយ។

៥.៣- ការទទួលខុសត្រូវរបស់អ្នកសង្កេតការណ៍ចោះឆ្នោត

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬ/និងអ្នកសង្កេតការណ៍ត្រូវទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួនទៅតាមច្បាប់ជាធរមាន។

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ឬ/និងអ្នកសង្កេតការណ៍ត្រូវទទួលបន្ទុកចំណាយរបស់ខ្លួននៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន។

៦- ហ្វាមចំពោះអ្នកសង្កេតការណ៍ចោះឆ្នោត

ក្នុងការសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានានៅការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត នៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោតអ្នកសង្កេតការណ៍មិនត្រូវ៖

៦.១ ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា។

៦.២ ជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត ឬអ្នកបោះឆ្នោត។

៦.៣ យកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញការកិច្ចសង្កេតការណ៍របស់ខ្លួន។

៦.៤ បញ្ចុះបញ្ចូល ឬប្រមូលផ្តុំប្រជាពលរដ្ឋឱ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៥ ចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៦ ចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារៈឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៧ ចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ។

៦.៨ ស្វែងមតិក្នុងគោលបំណងបម្រើឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.៩ សរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១០ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១១ និយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១២ ដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៣ ផ្តល់យានយន្តគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៤ ផ្តល់ថវិកា សម្ភារ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៥ ផ្តល់ថវិកា សម្ភារ និងបរិក្ខារសម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្តែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្តី ឬប្រយោលក្តី ដើម្បីគាំទ្រគណបក្សនយោបាយបាយណាមួយ ឬបេក្ខជនណាម្នាក់។

៦.១៦ រំខាន ឬជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយ នៅពេលដំណើរការនៃការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ។

៦.១៧ ប៉ះពាល់ឯកសារ ឬសម្ភារ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង។

៦.១៨ ប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរសព្ទថតរូប ឬឧបករណ៍ថតរូបផ្សេងៗនៅក្នុងការិយាល័យបោះឆ្នោត។

៦.១៩ នៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោត។

៦.២០ ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត និងបង្អាក់ដំណើរការបោះឆ្នោត។

៦.២១ រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់បោះឆ្នោត ឬបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត។

៦.២២ ចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោត ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយបណ្តឹងនេះបាន។

៦.៤២ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

អ្នកសង្កេតការណ៍បោះឆ្នោត ត្រូវជៀសវាង៖

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.៤៣ ល្បែង

អ្នកសង្កេតការណ៍បោះឆ្នោត មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧- សំណូមពរ និងការអនុវត្ត

អង្គការមិនមែនរដ្ឋាភិបាល សមាគម និងអ្នកសង្កេតការណ៍ត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម។

៧.១- សំណូមពរ

បន្ទាប់ពីដំណើរការបោះឆ្នោតបានចប់សព្វគ្រប់ហើយ សាមីអង្គការសង្កេតការណ៍ទាំងឡាយត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន នៅក្នុងដំណើរការបោះឆ្នោត ផ្ញើជូន គ.ជ.ប។ គ.ជ.ប មានសិទ្ធិផ្តល់យោបល់លើរបាយការណ៍នេះ។ អង្គការសង្កេតការណ៍បោះឆ្នោតអាចធ្វើការកែតម្រូវ ឬមិនកែតម្រូវតាមយោបល់របស់ គ.ជ.ប។ ក្នុងករណីមិនធ្វើការកែតម្រូវតាមយោបល់របស់ គ.ជ.ប ត្រូវភ្ជាប់យោបល់នេះ នៅក្នុងផ្នែកចុងក្រោយនៃរបាយការណ៍របស់ខ្លួនដែលត្រូវផ្សព្វផ្សាយ។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពអនុវត្តចាប់តាំងពីថ្ងៃចុះហត្ថលេខាដោយប្រធាន គ.ជ.ប និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤២ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្ម ទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬ រារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅ បញ្ជីបោះឆ្នោត។
- បង្ការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យ បញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះ បោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើ ហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យឃោសនាបោះឆ្នោត តាម ការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្ការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្ការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មា ធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៤៨ .-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬ

សមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលបំពានលើបញ្ញត្តិនៃមាត្រា ៨៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

មាត្រា១៤៩ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាយោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា តាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

មាត្រា១៥០ .-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាលឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៣៧ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

មាត្រា១៦០ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោតចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

២- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា១៧១ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្ម ទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬ រារាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅ បញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យ បញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះ បោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើ ហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យយោសនាបោះឆ្នោត តាម ការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្ការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្ការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាង លើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា១៧៩ .-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬ សមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារ

ក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោល បំពានលើបញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

មាត្រា១៨០ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀលទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាយោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាតាមបែបបទដូចបានចែងក្នុងច្បាប់ស្តីពីអន្តោប្រវេសន៍។

មាត្រា១៨៧ .-

ត្រូវផាកពិន័យជាប្រាក់ពី ១0.000.000 (ដប់លាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៥៩ នៃច្បាប់នេះ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ។

មាត្រា១៨៨ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.000.000 (មួយលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ឧបសម្ព័ន្ធទី ៥

ក្រមសីលធម៌

សម្រាប់

យោធិនទៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ

និងភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដំណើរការបោះឆ្នោត

១- សេចក្តីផ្តើម

ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ តែងតែប្រាថ្នាចង់ឱ្យរាល់ការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌។ ដើម្បីសម្រេចនូវគោលដៅនេះបាន យើងទាំងអស់គ្នាជាប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត គណបក្សនយោបាយ បេក្ខជន និងភ្នាក់ងារគណបក្សនយោបាយ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ក្រសួង ស្ថាប័ន កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ និងភាគីពាក់ព័ន្ធត្រូវរួបរួមគ្នាគោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត ព្រមទាំងក្រមសីលធម៌ឱ្យបានខ្ជាប់ខ្ជួន។

ក្រមសីលធម៌នេះ ត្រូវបានរៀបចំតាក់តែងឡើងស្របទៅតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការបោះឆ្នោត។

ការប្រតិបត្តិតាមក្រមសីលធម៌ជាផ្នែកមួយដ៏សំខាន់សម្រាប់ធ្វើឱ្យបរិយាកាសនៃដំណើរការបោះឆ្នោតតាំងពីចាប់ផ្តើមរហូតដល់ប្រកាសលទ្ធផលបោះឆ្នោតផ្លូវការប្រព្រឹត្តទៅដោយរលូន និងប្រកបដោយសន្តិសុខ សុវត្ថិភាព។ ការប្រតិបត្តិតាមក្រមសីលធម៌បានល្អជាកត្តាជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋ មន្ត្រីបោះឆ្នោត អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ គណបក្សនយោបាយជាគូប្រកួតប្រជែងមានសុទិដ្ឋិនិយមរវាងគ្នានឹងគ្នា សហការគ្នា និងបំពេញការងារតាមភារកិច្ច និងមុខនាទីរៀងៗខ្លួន រួមចំណែកពង្រឹងសាមគ្គីភាព និងកិច្ចសហការជាតិ និងអន្តរជាតិក្នុងការបោះឆ្នោត។ ការគោរពក្រមសីលធម៌បានល្អ នាំឱ្យកាត់បន្ថយបាននូវអំពើហិង្សា ជម្លោះ ការរើសអើង ការបែងចែករវាងអ្នកដែលមាននិន្នាការនយោបាយផ្សេងៗគ្នាក្នុងសង្គម។ ការគោរពក្រមសីលធម៌បានល្អគឺជាការលើកស្ទួយកិត្យានុភាពជាតិលើឆាកអន្តរជាតិ បង្ហាញពីការគោរពច្បាប់ ការឯកភាពជាតិ ការជឿទុកចិត្តគ្នារវាងគណបក្សនយោបាយ ប្រជាពលរដ្ឋ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ក្នុងសង្គម។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) អនុម័តក្រមសីលធម៌នេះសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតចូលរួមក្នុងការបោះឆ្នោត ពិសេសក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល។

២- គោលបំណង

ក្រមសីលធម៌នេះ មានគោលបំណងកំណត់វិធាន និងគោលការណ៍សំខាន់ៗសម្រាប់យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោត អនុវត្តនូវសិទ្ធិ តួនាទី និងភារកិច្ចរបស់ខ្លួនចូលរួមក្នុងដំណើរការបោះឆ្នោត ដើម្បី៖

- ធានាឱ្យដំណើរការនៃការរៀបចំការបោះឆ្នោតទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខ សុវត្ថិភាព គ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សាផ្សេងៗ និងសម្រេចបានជោគជ័យ
- ការពារសន្តិសុខ និងសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋអ្នកចុះឈ្មោះបោះឆ្នោត អ្នកបោះឆ្នោត បេក្ខជន យោសនិក និងភ្នាក់ងារគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មន្ត្រីបោះឆ្នោតគ្រប់លំដាប់ថ្នាក់ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងរក្សាស្ថិរភាពសម្រាប់សង្គមជាតិទាំងមូល
- ចាត់វិធានការបង្ការ រារាំង ទប់ស្កាត់ និងបង្ក្រាបរាល់អំពើល្មើស អំពើវិទ្ធង្សនា និងអំពើគេរវកម្មផ្សេងៗ ដែលអាចបង្កឱ្យមានការរាំងស្ទះដល់ដំណើរការបោះឆ្នោត។

៣- ទិសាលភាព

ក្រមសីលធម៌នេះ មានវិសាលភាពអនុវត្តចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិក្នុងការចូលរួមក្នុងការបោះឆ្នោត ពិសេសភ្នាក់ងារសន្តិសុខបោះឆ្នោតក្នុងការការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល ទៅតាមមុខសញ្ញា និងទីតាំងជាក់លាក់។

៤- និយមន័យ

វាក្យស័ព្ទសំខាន់ៗនៅក្នុងក្រមសីលធម៌នេះមានន័យដូចតទៅ៖

៤.១- **យោធិននៃកងយោធពលខេមរភូមិន្ទ** គឺជាពលទាហាន នាយទាហានរង និងនាយទាហាន ក្នុងនេះមានកងរាជអាវុធហត្ថ។

៤.២- **នគរបាលជាតិ** គឺជាមន្ត្រីនគរបាលជាតិនៃព្រះរាជាណាចក្រកម្ពុជា។

៤.៣- **ភ្នាក់ងារសន្តិសុខបោះឆ្នោត** គឺជាយោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ ដែលត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត។

៤.៤- **ការបោះឆ្នោត** សំដៅដល់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលរៀបចំឡើងដោយ គ.ជ.ប។

៤.៥- **ដំណើរការបោះឆ្នោត** សំដៅលើ៖

- ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត
- ការចុះបញ្ជីគណបក្សនយោបាយ និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត
- ការឃោសនាបោះឆ្នោត
- ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលនៃការបោះឆ្នោត
- ការដាក់ ការទទួល និងការដោះស្រាយបណ្តឹង
- ការប្រកាសលទ្ធផលនៃការបោះឆ្នោត។

៥- សិទ្ធិ តួនាទីកិច្ច និងការទទួលខុសត្រូវរបស់យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវអនុវត្តសិទ្ធិ ភារកិច្ច និងការទទួលខុសត្រូវដូចខាងក្រោម។

៥.១- សិទ្ធិរបស់យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិ

យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិមានសិទ្ធិចូលរួមក្នុងការបោះឆ្នោត ដូចជាប្រជាពលរដ្ឋទូទៅដែរ ហើយសិទ្ធិនេះ ត្រូវបានកំណត់ដោយច្បាប់បោះឆ្នោត និងច្បាប់ពាក់ព័ន្ធដែលនៅជាធរមាន។

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឱ្យមានការគំរាមកំហែងឡើយ។

៥.២- តួនាទីកិច្ចរបស់មេបញ្ជាការ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

មេបញ្ជាការ និងភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវអនុវត្តភារកិច្ចដូចខាងក្រោម។

៥.២.១ មេបញ្ជាការ ឬតំណាងនៃកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងនគរបាលជាតិ មានភារកិច្ច៖

- ត្រូវចូលរួមប្រជុំជាមួយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ដើម្បីចាត់វិធានការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតទាំងមូល
- ត្រូវចេញសេចក្តីណែនាំ ឬបទបញ្ជាទៅដល់មន្ត្រីនៅក្រោមឱវាទ ដើម្បីពិនិត្យមើលសកម្មភាពរបស់មន្ត្រីនៃអង្គភាពរៀងៗខ្លួនពាក់ព័ន្ធទៅនឹងគណបក្សនយោបាយ បេក្ខជន អ្នកគាំទ្រគណបក្សនយោបាយ និងប្រជាពលរដ្ឋគ្រប់រូប ព្រមទាំងកិច្ចការពារសិទ្ធិសេរីភាពជាមូលដ្ឋានដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ត្រូវសហការ និងត្រៀមលក្ខណៈសហការជាមួយ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ក្នុងការចាត់ចែងកម្លាំងសន្តិសុខបោះឆ្នោត ដើម្បីផ្តល់ការការពារសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងដំណើរការបោះឆ្នោត។

៥.២.២ ភ្នាក់ងារសន្តិសុខបោះឆ្នោតមានភារកិច្ច៖

- រក្សាបរិយាកាសសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈក្នុងពេលចុះឈ្មោះបោះឆ្នោត បិទផ្សាយបញ្ជីបោះឆ្នោតដំបូង បញ្ជីបោះឆ្នោតផ្លូវការ បញ្ជីទីតាំងការិយាល័យបោះឆ្នោត បញ្ជីបេក្ខជន ពេលឃោសនាបោះឆ្នោត ពេលបោះឆ្នោត និងពេលរាប់សន្លឹកឆ្នោត
- នៅថ្ងៃបោះឆ្នោត ភ្នាក់ងារសន្តិសុខបោះឆ្នោតចំនួន ៣ (បី) នាក់ ការពារបរិវេណសន្តិសុខនៃការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ត្រូវស្លៀកពាក់ឯកសណ្ឋានកងកម្លាំងឱ្យបានត្រឹមត្រូវ និងមានពាក់ប្រឡង់ដៃសន្តិសុខបោះឆ្នោតរបស់ គ.ជ.ប
- ចូលរួមចំណែកការពារការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ដែលជាបរិវេណរដ្ឋបាល និងសន្តិសុខ
- ស្ថិតនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដើម្បីត្រៀមបំពេញការកិច្ច ក្នុងករណីមានសំណូមពរពីប្រធាន គ.ក.ប/គ.ក.រ ក្នុងគោលបំណងស្នើសុំឱ្យជួយរក្សាសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងការិយាល័យណាមួយនោះ។

៥.៣- ការទទួលខុសត្រូវរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត

ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវមានការទទួលខុសត្រូវដូចខាងក្រោម៖

៥.៣.១ ប្រកាន់ជំហរអព្យាក្រឹត មិនលម្អៀង និងមិនត្រូវបង្ហាញការគាំទ្រ ឬប្រឆាំងចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ និងត្រូវដឹងថា៖

- ប្រជាពលរដ្ឋ អ្នកសុំចុះឈ្មោះបោះឆ្នោត និងអ្នកបោះឆ្នោតគ្រប់រូបមានសិទ្ធិទទួលបានសន្តិសុខ សុវត្ថិភាព ដើម្បីឱ្យដំណើរការចុះឈ្មោះបោះឆ្នោត និងដំណើរការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌
- បេក្ខជន វាគ្មិន ឬយោសនិក តំណាងគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតមានសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពក្នុងគ្រប់សកម្មភាពស្របច្បាប់។

៥.៣.២ ធានាចំពោះបេក្ខជនគ្រប់រូប និងគណបក្សនយោបាយពាក់ព័ន្ធទាំងអស់នូវសិទ្ធិស្មើៗគ្នាក្នុងការទទួលការការពារសន្តិសុខ និងសុវត្ថិភាពនៅក្នុងសម័យបោះឆ្នោត។

៥.៣.៣ យាម និងត្រួតពិនិត្យគ្រប់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតយ៉ាងតឹងរ៉ឹងបំផុតនៅក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

៥.៣.៤ ហាមឃាត់ជនណាម្នាក់ដែលប្រដាប់ដោយអាវុធ ឬមានលាក់អាវុធជាតិផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងខ្លួនចូល ឬឈរក្បែរការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងតែជននោះជាយោធិននៃកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ ដែលមានភារកិច្ច និងត្រូវបានស្នើសុំដើម្បីដោះស្រាយបាតុភាព ដែលកើតមានក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ឬ/និងបរិវេណខាងក្នុង ឬ/និងបរិវេណខាងក្រៅ។

៥.៣.៥ ជួយការពារការដឹកជញ្ជូនសម្ភារ ឯកសារបោះឆ្នោត សន្លឹកឆ្នោត កំណត់ហេតុរាប់សន្លឹកឆ្នោត កំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោត និងកំណត់ហេតុសរុបលទ្ធផលនៃការបោះឆ្នោត ពីគោលដៅមួយទៅកាន់គោលដៅមួយ តាមការកំណត់របស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ តាមការស្នើសុំ។

៥.៣.៦ ត្រូវមានស្មារតីប្រុងប្រយ័ត្ន ពង្រឹង និងកសាងសមត្ថភាព ស្វែងយល់ឱ្យបានច្បាស់អំពីគោលការណ៍ច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត ផែនការអន្តរស្ថាប័នមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប ក្រមសីលធម៌ រួមទាំងសេចក្តីណែនាំផ្សេងៗ ស្តីពីកិច្ចការពារសន្តិសុខបោះឆ្នោតសម្រាប់ធ្វើជាមូលដ្ឋាននៅក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន។

៦- ហ្វាមចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវបាន៖

៦.១ ហាមប្រើឥទ្ធិពលអំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោលឬចំពោះទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យ

គំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចទ្រព្យសម្បត្តិ ការដាក់បង្ហាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ។ ការគំរាមកំហែង ការបំភិតបំភ័យ និងបំបាក់ទឹកចិត្ត រួមមាន៖

- ការវាយតប់លើបុគ្គលណាម្នាក់
- ការរំលោភដោយពាក្យសម្តីថា នឹងធ្វើទុក្ខទោសដល់រាងកាយ
- ការលើកឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដោយយោងទៅលើព្រឹត្តិការណ៍ពីអតីតកាល មានជាអាទ៍ ឃាតកម្ម ការវាយដំ ឬការបង្ករបួសស្នាម ការរំលោភ ការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិរបស់ជនណាម្នាក់
- ការបាញ់ ការផ្ទុះអាវុធគំរាមបុគ្គលណាម្នាក់ ទោះតាមរូបភាពណាមួយក៏ដោយ
- ការយកសាកសពសត្វធាតុ ឬសញ្ញាផ្សេងៗ ឬឧបករណ៍ទាំងឡាយណាទៅដាក់មុខផ្ទះជនណាម្នាក់ដែលអាចធ្វើឱ្យជននោះមានការភ័យខ្លាចដល់អាយុជីវិតរបស់ខ្លួន ឬដល់បងប្អូនគ្រួសាររបស់ពួកគេ
- ការបណ្តើរ ឬបង្ខាំងជនណាម្នាក់ដោយបង្ខំ ដែលធ្វើឱ្យអារម្មណ៍របស់ជននោះមានការភ័យខ្លាច ឬធ្វើឱ្យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួន ឬសុវត្ថិភាពគ្រួសាររបស់ពួកគេ
- ការប្រើភាសាអសីលធម៌បង្ហាញពីការគំរាមកំហែង
- ការគំរាមកំហែងខាងផ្នែកហិរញ្ញវត្ថុ ដូចជាការបញ្ឈប់ពីការងារ ការដកហូតដីធ្លី ផ្ទះ សម្បែង និងផលប្រយោជន៍ផ្សេងទៀត។

៦.២ ហាមប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីយោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឱ្យគណបក្សនយោបាយ ឬបេក្ខជនណាមួយ។

៦.៣ ហាមចូលរួមសកម្មក្នុងការយោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយ ក្នុងពេលម៉ោងធ្វើការ ឬពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ។ ការចូលរួមសកម្មត្រូវបានកំណត់ដូចតទៅ៖

- ការចូលរួមជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈកម្មការយោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ
- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការដាក់តាំងរូបភាពផ្សាយ ឬឯកសារផ្សេងៗ ដើម្បីគាំទ្រ ឬប្រឆាំងនឹងគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ និងតាមយានជំនិះផ្ទាល់របស់ខ្លួន ឬ/និងអង្គភាព

- ការចូលរួមក្នុងការស្វង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការធ្វើសកម្មភាពចែកចាយសម្ភារយោសនាបោះឆ្នោតដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់
- ការចេញសេចក្ដីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់
- ការចូលរួមក្នុងសកម្មភាពយោសនាជាសាធារណៈណាមួយ ក្នុងសម្លៀកបំពាក់ឯកសណ្ឋានកងកម្លាំងប្រដាប់អាវុធ។

៦.៤ ហាមចូលរួមក្នុងសកម្មភាពយោសនាណាមួយ ក្នុងពេលបំពេញភារកិច្ច។

៦.៥ ហាមដើរ ឬឈរកៀកពេកទៅនឹងមធ្យោបាយ ឬទីកន្លែងដែលកំពុងធ្វើសកម្មភាពយោសនាបោះឆ្នោត លើកលែងតែមានការស្នើសុំដោយ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់។

៦.៦ ហាមជ្រៀតជ្រែកក្នុងកិច្ចប្រតិបត្តិការបោះឆ្នោត។

៦.៧ ហាមយកអាវុធជាតិផ្ទុះ និងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ព្រមទាំងការស្លៀកពាក់ឯកសណ្ឋាន ជាកងកម្លាំងប្រដាប់អាវុធ ចូលទៅក្នុងបរិវេណខាងក្រៅ បរិវេណខាងក្នុង និងក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត ព្រមទាំងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីចាំបាច់ និងមានការស្នើសុំអន្តរាគមន៍ពីប្រធាន គ.ជ.ប ប្រធាន លធ.ខប ឬប្រធាន គធ.ខប ប្រធាន គយ.សប ឬ កបយ.ស ឬប្រធាន ក.ច.ប ឬពីប្រធាន គ.ក.ប/គ.ក.រ។

៦.៨ ភ្នាក់ងារសន្តិសុខបោះឆ្នោតមិនត្រូវចូលទៅក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត លើកលែងក្នុងករណីចាំបាច់ និងមានការស្នើសុំអន្តរាគមន៍ពីប្រធាន គ.ជ.ប ប្រធាន លធ.ខប ឬប្រធាន គធ.ខប ប្រធាន គយ.សប ឬពីប្រធាន គ.ក.ប/គ.ក.រ។

៦.៩ ការជក់បារី និងការបង្ការភ្លើង អគ្គិភ័យ

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវជៀសវាងៈ

- ការជក់បារីនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ការគូសឈើគូស កេះដែកកេះ ឬឧបករណ៍ដែលអាចធ្វើឱ្យឆេះណាមួយនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត ដោយគ្មានការចាំបាច់តម្រូវឱ្យធ្វើ។

៦.១០ ល្បែង

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត មិនត្រូវលេងល្បែងស៊ីសង ឬល្បែងកំសាន្តនៅក្នុងទីស្តីការ គ.ជ.ប ទីស្នាក់ការ លធ.ខប ទីស្នាក់ការគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

៧- សំណូមពរ និងការអនុវត្ត

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត រួមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធនឹងការងារសន្តិសុខ ត្រូវយកចិត្តទុកដាក់អនុវត្តដូចខាងក្រោម។

៧.១- សំណូមពរ

ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវលើការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្តល់កិច្ចសហការដល់ គ.ជ.ប ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពក្នុងរយៈពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងសម្រាប់ដំណើរការបោះឆ្នោតនីមួយៗ ឱ្យទទួលបានជោគជ័យ។

យោធិននៃកងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាព ការបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌ ឬសកម្មភាពបំពារបំពានច្បាប់ផ្សេងៗទៀតដែលជាហេតុបង្កឱ្យមានការភ័យខ្លាច និងប៉ះពាល់ដល់បរិយាកាសនយោបាយ និងសន្តិសុខជាតិទាំងមូល។

តាមសំណើរបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ភ្នាក់ងារសន្តិសុខបោះឆ្នោត ត្រូវយកចិត្តទុកដាក់ការពារសុវត្ថិភាពសម្រាប់ទីតាំងរោងពុម្ពផលិតសន្លឹកឆ្នោត ទីកន្លែងរក្សាទុក ឬការដឹកជញ្ជូនសម្ភារ បរិក្ខារ និងគ្រឿងសង្ហារឹមចាំបាច់ផ្សេងៗដែលបម្រើការងារបោះឆ្នោត ការដឹកជញ្ជូនសន្លឹកឆ្នោត និងឯកសារបោះឆ្នោតនៅគ្រប់ដំណាក់កាល ប្រកបដោយប្រសិទ្ធភាពខ្ពស់ សុវត្ថិភាព និងគ្មានការរអាក់រអូល។

យោធិននៃកងយោធពលខេមរភូមិន្ទ និងនគរបាលជាតិទាំងមូល ជាពិសេសកងកម្លាំងដែលត្រូវបានចាត់តាំងឱ្យបំពេញការកិច្ចការពារសន្តិសុខសម្រាប់ការបោះឆ្នោត គឺភ្នាក់ងារសន្តិសុខបោះឆ្នោតត្រូវប្រមូលផ្តុំកម្លាំងសហការឱ្យបានល្អ និងប្រើប្រាស់តាមគ្រប់វិធានការជំនាញគ្រប់មធ្យោបាយ និងសម្ភារ លើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន និងទទួលខុសត្រូវខ្ពស់ក្នុងកិច្ចការពារសន្តិសុខ សណ្ដាប់ធ្នាប់ និងសុវត្ថិភាពសម្រាប់ការបោះឆ្នោត។

៧.២- ការអនុវត្ត

ក្រមសីលធម៌នេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ និងត្រូវអនុវត្តគ្រប់សម័យកាលនៃការបោះឆ្នោត ដែលរៀបចំឡើងដោយ គ.ជ.ប។

សម្រង់ទោសប្បញ្ញត្តិ

ក- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

មាត្រា១៤២ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ២0.000.000 (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្ម ទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រាវាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬ រាវាំងមិនឱ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅ បញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរាវាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យ បញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះ បោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើ ហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រាវាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រាវាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យយោសនាបោះឆ្នោត តាម ការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្កការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្កការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មា ធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា ១៤៦ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៥៨៩ (បទផលិត ឬធ្វើចរាចរណ៍ អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា ៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត ដូចបានបញ្ញត្តក្នុងមាត្រា ១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិកឬជាសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារ និងមិនឱ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅបន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា ១៤៧ .-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាលចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលល្មើសនឹងមាត្រា ៨៧ នៃច្បាប់នេះ។

មាត្រា ១៤៨ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពយោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

២- សម្រង់មាត្រាអំពីទោសប្បញ្ញត្តិក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់

មាត្រា ១៧១ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយទុច្ចរិត៖

- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឱ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឱ្យចុះឈ្មោះ ប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត។
- បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត។
- ឱ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោតប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សាទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ។
- រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឱ្យទៅបោះឆ្នោត។
- រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឱ្យយោសនាបោះឆ្នោតតាមការកំណត់។
- ធ្វើឱ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត។
- ធ្វើឱ្យមានការភាន់ច្រឡំនាំឱ្យបាត់ទំនុកចិត្តលើការបោះឆ្នោត។
- បង្ការរំខានមិនឱ្យដំណើរការបោះឆ្នោតបាន។
- បង្ការរំខានមិនឱ្យរាប់សន្លឹកឆ្នោតបាន។
- ធ្វើឱ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត។
- ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្ម ដែលបានចែងក្នុងកថាខណ្ឌទី១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើស ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើនេះ។

មាត្រា ១៧៥ .-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា ៥៨៩ (បទផលិត ឬធ្វើចរាចរណ៍អាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ដោយបំពានលើបញ្ញត្តិ នៃមាត្រា ២៨ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុ អនុញ្ញាតដោយច្បាប់។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិកនៃគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មការរៀបចំការបោះ ឆ្នោតគ្រប់លំដាប់ថ្នាក់ ត្រូវលុបឈ្មោះចេញពីការងារនិងមិនឱ្យសាមីខ្លួនចូលបម្រើការងារ ជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់ លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើ ទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ។

មាត្រា ១៧៦ .-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់ការបណ្តេញចេញពីមុខតំណែងចំពោះ មន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលល្មើសនឹងមាត្រា ១០ នៃច្បាប់នេះ។

មាត្រា ១៨០ .-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បី ធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.000.000 (ប្រាំលាន) រៀល ទៅ ១0.000.000 (ដប់លាន) រៀល ដោយគណៈកម្មាធិ ការជាតិរៀបចំការបោះឆ្នោត ។

ឧបសម្ព័ន្ធទី ៦

ស្តីពី

សម្ភារ ឯកសារ ដែលត្រូវប្រគល់ជូន គណ.ខប

សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល

១- ប័ណ្ណសម្គាល់សមាសភាព គ.ក.ប ចំនួន ៦ (ប្រាំមួយ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុនបម្រុង) ។

២- ប័ណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយចំនួន ១០ (ដប់) សន្លឹក គុណនឹងចំនួនក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុនបម្រុង) ។

៣- ប័ណ្ណសម្គាល់អ្នកសង្កេតការណ៍ជាតិ ចំនួនពីរ (២) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុន) ។

៤- ទម្រង់បែបបទលេខ ១០០២ សម្រាប់បំពេញកិច្ចសន្យាបម្រើការងាររបស់សមាសភាព គ.ក.ប ចំនួន ១២ (ដប់ពីរ) សន្លឹក គុណនឹងការិយាល័យបោះឆ្នោតក្នុងរាជធានី ខេត្ត (ត្រូវបញ្ជូនមុនដើម្បីបន្តចែកជូន គយ.សប) ។

៥- ទម្រង់បែបបទលេខ ១០០៤ សម្រាប់បំពេញបញ្ជីវត្តមាន និងប្រាក់កម្រៃសមាសភាព គ.ក.ប ចំនួន ៣ (បី) ច្បាប់ (ត្រូវបញ្ជូនមុន ដើម្បីបន្តចែកជូន គយ.សប) ។

៦- កញ្ចប់សន្លឹកឆ្នោតបម្រុងចំនួន ១ (មួយ) កញ្ចប់ ។

៧- ទម្រង់បែបបទលេខ ១១០៦ ចំនួនបី (៣) ច្បាប់ សម្រាប់កត់ត្រាការត្រួតពិនិត្យការបែងចែក និងបញ្ជូនសន្លឹកឆ្នោត ។

៨- ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារបោះឆ្នោតចំនួន ៩ (ប្រាំបួន) ច្បាប់ គុណនឹងចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ។

៩- ទម្រង់បែបបទលេខ ១១១០ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ចំនួន ២ (ពីរ) ច្បាប់ និងថាសទន់ផ្ទុកទម្រង់បែបបទលេខ ១១១០ ចំនួន ១ (មួយ)។

១០- ទម្រង់បែបបទលេខ ១១១១ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំនួន ៥ (ប្រាំ) ច្បាប់ ។

១១- ទម្រង់បែបបទលេខ ១១១៤ សម្រាប់បំពេញក្រដាសលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តចំនួន ១៥ (ដប់ប្រាំ) ច្បាប់ ។

១២- ទម្រង់បែបបទលេខ ១១១៦តព សម្រាប់បំពេញតារាងត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ផ្ទៀងផ្ទាត់ដោយក្រុមត្រួតពិនិត្យលទ្ធផលនៃ គជ.ខប ចំនួន ៥ (ប្រាំ) ច្បាប់ គុណនឹងចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ។

១៣- ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ចំនួន ៥ (ប្រាំ) ក្បាល ក្នុងមួយក្បាលមាន ២០ (ម្ភៃ) ច្បាប់ ។

១៤- ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសម្រង់សេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ា ឬ បណ្តឹងជំទាស់ចំនួន ៥ (ប្រាំ) ក្បាល ក្នុងមួយក្បាលមាន ២០ (ម្ភៃ) ច្បាប់ ។

១៥- ស្រោមសំបុត្រធំចំនួន ៤ (បួន) គុណនឹងចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ស្រោមសំបុត្រមធ្យមចំនួន ៧ (ប្រាំពីរ) និងបន្ថែមស្រោមសំបុត្រមធ្យម ចំនួនគិតសមាមាត្រនឹងស្បោង " ឃ " ដែលត្រូវប្រើនៅ គជ.ខប ។

១៦- ម៉ាស៊ីនគិតលេខបែងចែកតាមរាជធានី ខេត្តតូច ឬធំ ។

១៧- ប៊ិកហ្វឺតធំលុបមិនជ្រះបែងចែកតាមរាជធានី ខេត្ត តូច ឬ ធំ ។

១៨- ប៊ិកហ្វឺតធំខៀវ បែងចែកតាមរាជធានី ខេត្ត តូច ឬ ធំ។

១៩- កញ្ចប់សុវត្ថិភាព " ឃ ពិសេស " បែងចែកតាមរាជធានី ខេត្តតូច ឬធំ ។

២០- ស្បោង " ឃ " បែងចែកតាមរាជធានី ខេត្តតូច ឬធំ ។

២១- សោឃ្លុំជ័រធំមានលេខ សម្រាប់ឃ្លុំស្បោង " ឃ " ចំនួនស្មើនឹងស្បោង " ឃ " ។

២២- បន្ទប់សម្ងាត់បម្រុង (បែងចែកតាម គជ.ខប តូច ឬ ធំ) ។

២៣- ហិបឆ្នោតបម្រុង (បែងចែកតាម គជ.ខប តូច ឬ ធំ) ។

ឧបសម្ព័ន្ធទី ៧

ស្តីពី

សម្ភារ ឯកសារ ដែលត្រូវប្រគល់ជូន គឃ.សប និងឯកសារផ្សេងទៀតដែលត្រូវប្រគល់ជូន គ.ក.ប សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតិបត្តិការបោះឆ្នោតទាំងមូល

១- ប័ណ្ណសម្គាល់សមាសភាព គ.ក.ប ចំនួន ៦ (ប្រាំមួយ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ត្រូវបញ្ជូនមុន) ។

២- ប័ណ្ណសម្គាល់ភ្នាក់ងារនៃគណបក្សនយោបាយ ចំនួន ២០ (ម្ភៃ) សន្លឹក គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (ត្រូវបញ្ជូនមុន) ។

៣- ស្លាកសម្គាល់ទីស្នាក់ការ គឃ.សប ចំនួន ១ (មួយ) ។

៤- ត្រា គឃ.សប ចំនួន ១ (មួយ) (ត្រូវបញ្ជូនមុន) ។

៥- ត្រាសម្ងាត់ចំនួន ១ (មួយ) គុណនឹងចំនួនការិយាល័យក្នុងឃុំ សង្កាត់ (បែងចែកបន្តជូន គ.ក.ប) ។

៦- ត្រាសម្ងាត់ចំនួនពីរ (២) (បម្រុង) ។

៧- តាំប៉ុងក្រហមចំនួន ១ (មួយ) ប្រអប់ និងទឹកតាំប៉ុងពណ៌ក្រហមចំនួន ១ (មួយ) ដប (ត្រូវបញ្ជូនមុន) ។

៨- បញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ចំនួន ៣ (បី) ច្បាប់ (ត្រូវបញ្ជូនមុន) ។

៩- បញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតទាំងអស់ក្នុងឃុំ សង្កាត់ ចំនួន ២ (ពីរ) ច្បាប់ (ត្រូវបញ្ជូនមុន) ។

១០- កញ្ចប់សន្លឹកឆ្នោត ១ (មួយ) កញ្ចប់ គុណនឹងចំនួនការិយាល័យក្នុងឃុំ សង្កាត់ (បែងចែកបន្តជូន គ.ក.ប) ។

១១- ទម្រង់បែបបទលេខ ១១០៣ សម្រាប់បំពេញកំណត់ហេតុបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួន ៥ (ប្រាំ) ច្បាប់ ។

១២- ទម្រង់បែបបទលេខ ១១០៥ សម្រាប់បំពេញលទ្ធផលបឋមនៃការបោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួន ១០ (ដប់) ច្បាប់ ។

១៣- ទម្រង់បែបបទលេខ ១១០៦ សម្រាប់កត់ត្រាការត្រួតពិនិត្យការបែងចែកសន្លឹកឆ្នោតចំនួន ៣ (បី) ច្បាប់ ។

១៤- ទម្រង់បែបបទលេខ ១១០៧ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារ ឯកសារ បោះឆ្នោត ចំនួន ៦ (ប្រាំមួយ) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់។

១៥- ទម្រង់បែបបទលេខ ១១០៩ សម្រាប់បំពេញតារាងបូកសរុបលទ្ធផលបណ្តោះអាសន្ននៃការ បោះឆ្នោតក្នុងឃុំ សង្កាត់ ចំនួន ៥ (ប្រាំ) ច្បាប់ ។

១៦- ទម្រង់បែបបទលេខ ១១១៣ សម្រាប់បំពេញការវាយតម្លៃសមាសភាពនៃ គ.ក.ប ចំនួន ១២ (ដប់ពីរ) ច្បាប់ គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ។

១៧- ទម្រង់បែបបទលេខ ១២០២ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ចំនួន ៥ (ប្រាំ) ក្បាល ក្នុង១ក្បាល មានម្តេ (២០) ច្បាប់ ។

១៨- ទម្រង់បែបបទលេខ ១២០៣ សម្រាប់បំពេញសេចក្តីសម្រេចលើពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ចំនួន ៥ (ប្រាំ) ក្បាល ក្នុង១ក្បាលមានម្តេ (២០) ច្បាប់ ។

១៩- ស្រោមសំបុត្រធំ ១ មធ្យម ៤ និងបន្ថែមស្រោមសំបុត្រមធ្យមចំនួនគិតសមាមាត្រនឹងស្បោង " គ " ដែលត្រូវប្រើនៅ គយ.សប ។

២០- ម៉ាស៊ីនគិតលេខ ១ (មួយ) គ្រឿង ។

២១- ក្រដាសវ៉ាម ចំនួន ៥០ (ហាសិប) សន្លឹក សម្រាប់ប្រើប្រាស់ការងារផ្សេងៗ ។

២២- ប៊ិកខៀវ ចំនួន ៦ (ប្រាំមួយ) ដើម ។

២៣- ប៊ិកហ្វឺតធំលុបលាងមិនជ្រះចំនួន ២ (ពីរ) ដើម ។

២៤- ប៊ិកហ្វឺតធំពណ៌ខៀវ ចំនួន ២ (ពីរ) ដើម ។

២៥- កញ្ចប់សុវត្ថិភាព " គ ពិសេស " ចំនួន ១ (មួយ) ។

២៦- ស្បោង " គ " ចំនួនគិតតាមសមាមាត្រនឹងចំនួនការិយាល័យបោះឆ្នោតតិច ឬច្រើន ក្នុងឃុំ សង្កាត់ ។

២៧- សោឃ្លុំជ័រធំមានលេខសម្រាប់ឃ្លុំស្បោង " គ " ចំនួនស្មើនឹងស្បោង " គ " ។

២៨- បន្ទប់សម្ងាត់ចំនួន ១ (មួយ) កញ្ចប់មានចំនួន ២ផ្ទាំង គុណនឹងចំនួនការិយាល័យបោះឆ្នោត ក្នុងឃុំ សង្កាត់ (បែងចែកបន្តជូន គ.ក.ប) ។

២៩- ហិបឆ្នោតចំនួន ១ (មួយ) គុណនឹងចំនួនការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ (បែងចែកបន្ត ជូន គ.ក.ប) ។

ឧបសម្ព័ន្ធទី ៨

ស្តីពី

សម្ភារ ឯកសារ ដែលត្រូវប្រគល់ជូន គ.ក.ប/គ.ក.រ

សម្រាប់ប្រើប្រាស់ក្នុងកិច្ចប្រតបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោត

១- លេខកូដការិយាល័យបោះឆ្នោតចំនួន ២ (ពីរ) ច្បាប់ សម្រាប់បិទនៅខាងមុខការិយាល័យបោះឆ្នោត ១ (មួយ) ច្បាប់ និងសម្រាប់បិទនៅខាងមុខហិបឆ្នោតចំនួន ១ (មួយ) ច្បាប់ ។

២- ស្លាកសម្គាល់ " ការិយាល័យបោះឆ្នោត " បោះពុម្ពលើកំណាត់ប្លាស្ទិកចំនួន ១ (មួយ) ។

៣- ប័ណ្ណប្រកាសហាមប្រើទូរស័ព្ទដៃ និងម៉ាស៊ីនថតចំនួន ២ (ពីរ) សន្លឹក ។

៤- ទឹកខ្មៅលុបលាងមិនជ្រះចំនួន ២ (ពីរ) ដប ។

៥- ត្រាការិយាល័យបោះឆ្នោតចំនួន ១ (មួយ) ។

៦- តាំប៉ុងពណ៌ក្រហមចំនួនមួយ (១) ប្រអប់ និងទឹកតាំប៉ុងក្រហម ចំនួនមួយ (១) ដប ។

៧- បិកមានខ្សែចងសម្រាប់គូសសន្លឹកឆ្នោត និងបិកធម្មតាសម្រាប់ គ.ក.ប សរុបទាំងពីរមុខចំនួន ៨ (ប្រាំបី) ដើម ។

៨- បិកហ្វឺតធំលុបមិនជ្រះចំនួន ១ (មួយ) ដើម ។

៩- បិកហ្វឺតធំចំនួន ១ (មួយ) ដើម ។

១០- បន្ទាត់ជ័រចំនួន ១ (មួយ) ដើម ។

១១- ប្រដាប់ចោះសន្លឹកឆ្នោតចំនួន ១ (មួយ) ។

១២- ជ័រការវារ ១ (មួយ) ដប ។

១៣- ស្ពុតថ្លាធំចំនួន ១ (មួយ) ដុំ ។

១៤- កៅស៊ូកងមួយចំនួន សម្រាប់ចងសន្លឹកឆ្នោតតាមគណបក្ស ។

១៥- ស្រោមសំបុត្រធំ ចំនួនមួយ (១) មធ្យម ចំនួនដប់ (១០) និងតូចចំនួនពីរ (២) ។

១៦- ក្រដាសស្តើងសម្រាប់បិទពាសសន្ទះបិទប្រឡោះស៊ិកសន្លឹកឆ្នោតចំនួន ៦ (ប្រាំមួយ) សន្លឹក ។

១៧- ក្រដាសរ៉ាម សម្រាប់សរសេរសម្គាល់លេខការិយាល័យបោះឆ្នោតបិទលើហិបឆ្នោត និងសម្រាប់ប្រើប្រាស់ការងារផ្សេងៗ ចំនួន ២០ (ម្ភៃ) សន្លឹក ។

១៨- ក្របក្រដាសពិសេសសម្រាប់អ្នកបោះឆ្នោតពិការភ្នែកទាំងសងខាងបោះឆ្នោតដោយខ្លួនឯង ចំនួន ១ (មួយ) ។

១៩- ផ្ទាំងក្រដាស សម្រាប់ទ្រាប់គូសសន្លឹកឆ្នោតចំនួន ២ (ពីរ) ផ្ទាំង ។

២០- ផ្ទាំងក្រដាសធំ សម្រាប់កត់ត្រាសំឡេងឆ្នោតចំនួន ១ (មួយ) សន្លឹក ។

២១- ទម្រង់បែបបទលេខ ១១០១ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការបោះឆ្នោត ។

២២- ទម្រង់បែបបទលេខ ១១០២ ចំនួន ២០ (ម្ភៃ) ច្បាប់ សម្រាប់បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ។

២៣- ទម្រង់បែបបទលេខ ១១០៧ ចំនួន ៦ (ប្រាំមួយ) ច្បាប់ សម្រាប់បំពេញលិខិតបញ្ជូន និងប្រគល់ ទទួលសម្ភារឯកសារបោះឆ្នោត ។

២៤- ទម្រង់បែបបទលេខ ១១០៨ ចំនួន ៤ (បួន) ច្បាប់ សម្រាប់កត់ត្រាសំឡេងឆ្នោត ។

២៥- ទម្រង់បែបបទលេខ ១១១២ ចំនួនបួន (៤) ច្បាប់ សម្រាប់បំពេញតារាងត្រួតពិនិត្យសម្ភារឯកសារបោះឆ្នោតដែល គ.ក.ប បានទទួល ។

២៦- ទម្រង់បែបបទលេខ ១១១៥ ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ស្រង់វត្តមានភ្នាក់ងារនៃគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ក្នុងពេលនៃការរាប់សន្លឹកឆ្នោត ។

២៧- ទម្រង់បែបបទលេខ ១១២០ ចំនួន ២ (ពីរ) ច្បាប់ សម្រាប់ស្រង់វត្តមានអ្នកសង្កេតការណ៍ក្នុងពេលបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

២៨- ទម្រង់បែបបទលេខ ១២០២ ចំនួន ២ (ពីរ) ក្បាល ក្នុងមួយក្បាលមានម្ភៃ (២០) ច្បាប់ សម្រាប់បំពេញពាក្យបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ ។

២៩- កញ្ចប់សម្រាប់ដាក់សន្លឹកឆ្នោតដែលមិនទាន់ប្រើ និងគល់សន្លឹកឆ្នោតដែលប្រើហើយចំនួន ១ (មួយ) ។

៣០- កញ្ចប់សម្រាប់ដាក់សន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការចំនួន ១ (មួយ) ។

៣១- កញ្ចប់សុវត្ថិភាព " ក " សម្រាប់ដាក់កំណត់ហេតុនៃការបោះឆ្នោត និងសម្ភារឯកសារបោះឆ្នោត ចំនួន ១ (មួយ) ។

៣២- ស្បោង " ខ " សម្រាប់ដាក់កញ្ចប់សុវត្ថិភាព " ក " និងសម្ភារ ឯកសារបោះឆ្នោត ចំនួន ១ (មួយ) ។

៣៣- សោឃ្លុំជ័រតូចមានលេខសម្រាប់បិទគម្របខាងក្នុង និងខាងក្រៅនៃហិបឆ្នោត ចំនួន ៣ (បី) ។

៣៤- សោឃ្លុំជ័រមធ្យមមានលេខសម្រាប់ឃ្លុំបិទមាត់ស្បោង " ខ " ចំនួន ១ (មួយ) ។

ឧបសម្ព័ន្ធទី ៩
ស្តីពី
ប្រព័ន្ធបោះឆ្នោត និងការបែងចែកអាសនៈ

១- យោងតាមមាត្រា ៥ និងមាត្រា ១៣៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមរាជធានី ខេត្ត ដោយយករាជធានី ខេត្តជាមណ្ឌលបោះឆ្នោត ហើយការបែងចែកអាសនៈតាមរាជធានី ខេត្ត ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ។

២- បេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រដែលជាសមាជិករដ្ឋសភា ត្រូវបានប្រកាសដោយអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ដែលត្រូវបានជាប់ឆ្នោតនៅក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត និងអនុវត្តតាមលំដាប់លេខរៀង ។

៣-អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ មាត្រា ១៣៥ អាសនៈនៃមណ្ឌលរាជធានី ខេត្តត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈក្នុងរាជធានី ខេត្ត និងលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត ។ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈ និងកំណត់ចំនួនអាសនៈ សម្រាប់គណបក្សនយោបាយជាប់ឆ្នោតនីមួយៗតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗ។

៤- ដើម្បីបែងចែកអាសនៈតាមមណ្ឌលរាជធានី ខេត្តនីមួយៗ គ.ជ.ប ត្រូវអនុវត្តតាមករណីដូចតទៅ ៖

៤.១ មណ្ឌលបោះឆ្នោតរាជធានី ខេត្តណាដែលមានអាសនៈតែមួយ ការបែងចែកអាសនៈក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តនោះ ត្រូវផ្តល់ជូនគណបក្សនយោបាយណាដែលទទួលបានសន្លឹកឆ្នោតបានការច្រើនជាងគេ ។

៤.២ មណ្ឌលបោះឆ្នោតរាជធានី ខេត្តណាមានអាសនៈលើសពី ១ (មួយ) អាសនៈនៅក្នុងមណ្ឌលរាជធានី ខេត្តនោះត្រូវបែងចែកដោយផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តនោះតាមជំហានទាំងឡាយដូចខាងក្រោម ៖

ការកត្ថតា ៖

៤.២.១ ជំហានទីមួយ ៖ ការកំណត់ក្វតា (**Quota**)

ក្វតា គឺជាចំនួននៃសន្លឹកឆ្នោតបានការនៅក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗ ដែលកំណត់ឡើងសម្រាប់ឱ្យគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតនៅក្នុងមណ្ឌលនោះ ទទួលបាន ១ (មួយ)អាសន:។

៤.២.២ ដើម្បីកំណត់ក្វតា ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ចែកនឹងចំនួនអាសន:សរុបក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តនោះ ។

$$\boxed{\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}}$$

ក្នុងនោះ ៖

- ក$_{\text{ត}}$: តាងឱ្យក្វតា ជាផលចែកដោយមិនគិតសំណល់ចែក ។
- ស$_{\text{ស}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ។
- អ$_{\text{ស}}$: តាងឱ្យចំនួនអាសន:សរុប ។

ឧទាហរណ៍ទី១ ៖ ការកំណត់ក្វតា

នៅមណ្ឌលបោះឆ្នោតខេត្ត **A** មាន ៖

- សន្លឹកឆ្នោតបានការសរុប ៖ ស$_{\text{ស}}$ = ៥៣៣.៣៧៨ សន្លឹក
- អាសន:សរុប ៖ អ$_{\text{ស}}$ = ១១ អាសន:

ការកំណត់ក្វតា ៖

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}} \quad \frac{\text{៥៣៣.៣៧៨}}{\text{១១}} = \text{៤៨.៤៨៨,៦០}$$

ក្វតាស្មើនឹង ៤៨.៤៨៨ (ក$_{\text{ត}}$ = ៤៨.៤៨៨)

ការកំណត់ចំនួនអាសនៈបឋម

<u>ជំហានទីពីរ</u> ៖ **ការកំណត់ចំនួនអាសនៈបឋម ឬការបែងចែកអាសនៈ លើកទី១**

ដើម្បីកំណត់ចំនួនអាសនៈបឋមដែលគណបក្សនយោបាយនីមួយៗ ត្រូវបាន ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលគណបក្សនីមួយៗទទួលបាន មកចែកនឹងកូតា តាមរូបមន្តដូចខាងក្រោម ៖

$$\text{អ}_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក}_{\text{ត}}}$$

ក្នុងនោះ ៖

- $\text{អ}_{\text{ទ}}$: ជាផលចែកដែលមិនគិតសំណល់ចែក តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗមានសិទ្ធិទទួលបានមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣ ។
- $\text{ស}_{\text{ប}}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឱ្យគណបក្សនយោបាយណាមួយក្នុងរាជធានី ខេត្ត ។
- $\text{ក}_{\text{ត}}$: តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី១ ។

<u>ឧទាហរណ៍ទី២ ៖</u> **ការបែងចែកអាសនៈលើកទី ១**

នៅមណ្ឌលបោះឆ្នោតខេត្ត **A** ដដែល ដែលមានគណបក្សនយោបាយឈរឈ្មោះចំនួន ១២ ៖

- គណបក្ស ក មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ប}}\text{ក}$ = ៤៩.៦៨២ សន្លឹក
- គណបក្ស ខ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ប}}\text{ខ}$ = ៤៨.៧៥៤ សន្លឹក
- គណបក្ស គ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ប}}\text{គ}$ = ១១២.៩៧៨ សន្លឹក
- គណបក្ស ឃ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ប}}\text{ឃ}$ = ១០៨.៣៣៤ សន្លឹក
- គណបក្ស ង មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ប}}\text{ង}$ = ១៥.១៦២ សន្លឹក
- គណបក្ស ច មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ប}}\text{ច}$ = ២៥.២៨៦ សន្លឹក
- គណបក្ស ឆ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ប}}\text{ឆ}$ = ២៨.២៤៥ សន្លឹក

- គណបក្ស ជ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ជ}}$ = ៥០.៥២៣ សន្លឹក
- គណបក្ស ឈ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ឈ}}$ = ១១.៥៧៦ សន្លឹក
- គណបក្ស ញ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ញ}}$ = ៤៨.៧៥១ សន្លឹក
- គណបក្ស ដ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ដ}}$ = ១៨.៦៩៤ សន្លឹក
- គណបក្ស ឋ មានសន្លឹកឆ្នោតបានការ $\text{ស}_{\text{ឋ}}$ = ១៥.៣៩៣ សន្លឹក

អនុវត្តតាមរូបមន្ត ដូចចែងក្នុងចំណុច ៤.២.៣ ខាងលើ យើងបាន ៖

- គណបក្ស ក ៖ $\text{អ}_{\text{ក}} = \frac{\text{៤៩.៦៨២}}{\text{៤៨.៤៨៨}} = \text{១,០២}$ ត្រូវជា ០១ អាសន:
- គណបក្ស ខ ៖ $\text{អ}_{\text{ខ}} = \frac{\text{៤៨.៧៥៤}}{\text{៤៨.៤៨៨}} = \text{១,០០}$ ត្រូវជា ០១ អាសន:
- គណបក្ស គ ៖ $\text{អ}_{\text{គ}} = \frac{\text{១១២.៩៧៨}}{\text{៤៨.៤៨៨}} = \text{២,៣៣}$ ត្រូវជា ០២ អាសន:
- គណបក្ស ឃ ៖ $\text{អ}_{\text{ឃ}} = \frac{\text{១០៨.៣៣៤}}{\text{៤៨.៤៨៨}} = \text{២,២៣}$ ត្រូវជា ០២ អាសន:
- គណបក្ស ង ៖ $\text{អ}_{\text{ង}} = \frac{\text{១៥.១៦២}}{\text{៤៨.៤៨៨}} = \text{០,៣១}$ ត្រូវជា ០០ អាសន:
- គណបក្ស ច ៖ $\text{អ}_{\text{ច}} = \frac{\text{២៥.២៨៦}}{\text{៤៨.៤៨៨}} = \text{០,៥២}$ ត្រូវជា ០០ អាសន:
- គណបក្ស ឆ ៖ $\text{អ}_{\text{ឆ}} = \frac{\text{២៨.២៤៥}}{\text{៤៨.៤៨៨}} = \text{០,៥៨}$ ត្រូវជា ០០ អាសន:
- គណបក្ស ជ ៖ $\text{អ}_{\text{ជ}} = \frac{\text{៥០.៥២៣}}{\text{៤៨.៤៨៨}} = \text{១,០៤}$ ត្រូវជា ០១ អាសន:
- គណបក្ស ឈ ៖ $\text{អ}_{\text{ឈ}} = \frac{\text{១១.៥៧៦}}{\text{៤៨.៤៨៨}} = \text{០,២៣}$ ត្រូវជា ០០ អាសន:
- គណបក្ស ញ ៖ $\text{អ}_{\text{ញ}} = \frac{\text{៤៨.៧៥១}}{\text{៤៨.៤៨៨}} = \text{១,០០}$ ត្រូវជា ០១ អាសន:

- គណបក្ស ដ ៖ $អ_{ទ}ដ = \frac{១៨.៦៩៤}{៤៨.៤៨៨} = ០,៣៨$ ត្រូវជា ០០ អាសន:

- គណបក្ស ប ៖ $អ_{ទ}ប = \frac{១៥.៣៥៣}{៤៨.៤៨៨} = ០,៣១$ ត្រូវជា ០០ អាសន:

៤.២.៤ បន្ទាប់ពីបានគណនាគ្រប់គណបក្សនយោបាយទាំងអស់ ក្នុងជំហានទីពីរ ហើយប្រសិនបើគ្មានអាសន:នៅសល់ដើម្បីបែងចែកបន្តទៀតទេនោះ ចំនួនអាសន:ត្រូវកំណត់យកតែម្តង ។

ការកំណត់យកមធ្យមភាគខ្ពស់បំផុត

៤.២.៥ <u>ជំហានទីបី ៖</u> **ករណីមានអាសន:នៅសល់**

ក្នុងករណីមានអាសន:នៅសល់ ត្រូវបន្តបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមការគណនាដូចខាងក្រោម ។

៤.២.៦ ត្រូវកំណត់ជាដំបូងនូវមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ ដោយយកចំនួនសន្លឹកឆ្នោតបានការដែលគណបក្សនយោបាយនីមួយៗ ទទួលបានចែកនឹងចំនួនអាសន:ជាបឋម ដែលគណបក្សនយោបាយនីមួយៗ បានទទួល បូកនឹងលេខនិមិត្តមួយ (+១) តាមរូបមន្តដូចខាងក្រោម ៖

$$\boxed{\text{មធ} = \frac{\text{ស}_{\text{ប}}}{\text{អ}_{\text{ទ}} + ១}}$$

ក្នុងនោះ ៖

- មធ : តាងឱ្យមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ ។
- $\text{ស}_{\text{ប}}$: តាងឱ្យសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- $\text{អ}_{\text{ទ}}$: តាងឱ្យចំនួនអាសន:ជាបឋមដែលគណបក្សនយោបាយនីមួយៗ ទទួលបាន ។
- ១ : ជាលេខនិមិត្ត ។

៤.២.៦.១ ក្នុងការរកមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ ត្រូវគណនាឱ្យដល់ចំនួន ២ (ពីរ)ខ្ទង់ក្រោយក្បៀស ដើម្បីកំណត់គណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់ជាងគេ។

៤.២.៦.២ បន្ទាប់ពីកំណត់បានមធ្យមភាគ របស់គណបក្សនយោបាយនីមួយៗរួចហើយត្រូវធ្វើការប្រៀបធៀបគ្នា ។ គណបក្សនយោបាយណាមានមធ្យមភាគធំជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ត្រូវទទួលបានអាសន: ១ (មួយ) ។

<u>ឧទាហរណ៍ទី៣ ៖</u> ការបែងចែកអាសន:លើកទី ២

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** ដដែល តាមការបែងចែកអាសន:លើកទី ១ ៖

គណបក្ស ក	បានទទួលអាសន: ១
គណបក្ស ខ	បានទទួលអាសន: ១
គណបក្ស គ	បានទទួលអាសន: ២
គណបក្ស ឃ	បានទទួលអាសន: ២
គណបក្ស ង	បានទទួលអាសន: ០
គណបក្ស ច	បានទទួលអាសន: ០
គណបក្ស ឆ	បានទទួលអាសន: ០
គណបក្ស ជ	បានទទួលអាសន: ១
គណបក្ស ឈ	បានទទួលអាសន: ០
គណបក្ស ញ	បានទទួលអាសន: ១
គណបក្ស ដ	បានទទួលអាសន: ០
គណបក្ស ឋ	បានទទួលអាសន: ០

- អាសន:ដែលបានបែងចែកលើកទី ១ មាន ៨ អាសន:
- អាសន:សរុបក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** មាន ១១ អាសន:
- អាសន:នៅសល់ដែលត្រូវបន្តធ្វើការបែងចែកមាន ៣ អាសន:

ការអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុតក្នុងជំហានទីបី ៖

- គណបក្ស ក ៖ $\text{ម}_{\text{ធ}}\text{ក} = \frac{\text{៤៩.៦៨២}}{\text{១+១}} = \text{២៤.៨៤១,០០}$

- គណបក្ស ខ ៖ $\text{មធ}_{\text{ខ}} = \frac{\text{៤៨.៧៥៤}}{\text{១+១}} = \text{២៤.៣៧៧,០០}$

- គណបក្ស គ ៖ $\text{មធ}_{\text{គ}} = \frac{\text{១១២.៩៧៨}}{\text{២+១}} = \text{**៣៧.៦៥៩,៣៣**}$

- គណបក្ស ឃ ៖ $\text{មធ}_{\text{ឃ}} = \frac{\text{១០៨.៣៣៤}}{\text{២+១}} = \text{៣៦.១១១,៣៣}$

- គណបក្ស ង ៖ $\text{មធ}_{\text{ង}} = \frac{\text{១៥.១៦២}}{\text{០+១}} = \text{១៥.១៦២,០០}$

- គណបក្ស ច ៖ $\text{មធ}_{\text{ច}} = \frac{\text{២៥.២៨៦}}{\text{០+១}} = \text{២៥.២៨៦,០០}$

- គណបក្ស ឆ ៖ $\text{មធ}_{\text{ឆ}} = \frac{\text{២៨.២៤៥}}{\text{០+១}} = \text{២៨.២៤៥,០០}$

- គណបក្ស ជ ៖ $\text{មធ}_{\text{ជ}} = \frac{\text{៥០.៥២៣}}{\text{១+១}} = \text{២៥.២៦១,៥០}$

- គណបក្ស ឈ ៖ $\text{មធ}_{\text{ឈ}} = \frac{\text{១១.៥៧៦}}{\text{០+១}} = \text{១១.៥៧៦,០០}$

- គណបក្ស ញ ៖ $\text{មធ}_{\text{ញ}} = \frac{\text{៤៨.៧៥១}}{\text{១+១}} = \text{២៤.៣៧៥,៥០}$

- គណបក្ស ដ ៖ $\text{មធ}_{\text{ដ}} = \frac{\text{១៨.៦៩៤}}{\text{០+១}} = \text{១៨.៦៩៤,០០}$

- គណបក្ស ឋ ៖ $\text{មធ}_{\text{ឋ}} = \frac{\text{១៥.៣៥៣}}{\text{០+១}} = \text{១៥.៣៥៣,០០}$

ប្រៀបធៀបមធ្យមភាគនៃគណបក្សទាំង១២ ខាងលើ គណបក្ស **គ** មានមធ្យមភាគខ្ពស់ជាងគេគឺ **៣៧.៦៥៩,៣៣** ដែលជាមធ្យមភាគខ្ពស់បំផុត។ ដូចនេះគណបក្សនយោបាយ **គ** ត្រូវទទួលបានអាសន: ១ (មួយ) បន្ថែមទៀត ។

៤.២.៧ ប្រសិនបើមាននៅសល់អាសនៈទៀត អាសនៈដែលនៅសល់នោះ ត្រូវបន្តបែងចែកម្តងមួយអាសនៈ។ រហូតដល់អស់អាសនៈ តាមរូបមន្ត មធ្យមភាគខ្ពស់ក្នុងជំហានទីបីដដែល ដោយត្រូវបង្កើនតម្លៃអ១ ចំនួន ១ (មួយ) ចំពោះគណបក្សនយោបាយណា ដែលទើបទទួលបានអាសនៈ បន្ថែមចំនួន ១ (មួយ) បន្ទាប់ពីការបែងចែកមួយលើក។ ។

<u>**ឧទាហរណ៍ទី៤ ៖**</u> **ការបែងចែកអាសនៈលើកទី ៣**

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** ដដែលតាមការបែងចែកអាសនៈលើកទី ២ ៖

គណបក្ស ក	បានទទួលអាសនៈ ១+0	ដដែល
គណបក្ស ខ	បានទទួលអាសនៈ ១+0	ដដែល
គណបក្ស គ	បានទទួលអាសនៈ ២+១	កើនមួយអាសនៈ
គណបក្ស ឃ	បានទទួលអាសនៈ ២+0	ដដែល
គណបក្ស ង	បានទទួលអាសនៈ 0+0	ដដែល
គណបក្ស ច	បានទទួលអាសនៈ 0+0	ដដែល
គណបក្ស ឆ	បានទទួលអាសនៈ 0+0	ដដែល
គណបក្ស ជ	បានទទួលអាសនៈ ១+0	ដដែល
គណបក្ស ឈ	បានទទួលអាសនៈ 0+0	ដដែល
គណបក្ស ញ	បានទទួលអាសនៈ ១+0	ដដែល
គណបក្ស ដ	បានទទួលអាសនៈ 0+0	ដដែល
គណបក្ស ឋ	បានទទួលអាសនៈ 0+0	ដដែល

- សរុបអាសនៈដែលបានបែងចែកលើកទី១ និងលើកទី២ មាន ៩ អាសនៈ
- អាសនៈសរុបក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** មាន ១១ អាសនៈ

ដូចនេះនៅសល់អាសនៈ ២ (ពីរ) ទៀតដែលត្រូវបន្តបែងចែក ។ អនុវត្តតាមរូបមន្ត ជំហានទីបី ដោយបង្កើនតម្លៃ អ១ ចំនួន ១ (មួយ) ដល់គណបក្ស **គ** ដែលទើបនឹងទទួលបាន ១ (មួយ) អាសនៈកន្លងមកនេះ យើងបាន ៖

- គណបក្ស ក ៖ $\text{ម}_{\text{ធ}}\text{ក} = \frac{\text{៤៩.៦៨២}}{\text{១+១}} = \text{២៤.៨៤១,00}$

- គណបក្ស ខ ៖ $\text{ម}_{\text{ធ}}\text{ខ} = \frac{\text{៤៨.៧៥៤}}{\text{១+១}} = \text{២៤.៣៧៧,00}$

- គណបក្ស គ ៖ $\text{មធ}_{\text{គ}} = \frac{\text{១១២.៩៧៨}}{\text{៣+១}} = \text{២៨.២៥៥,៥០}$

- គណបក្ស ឃ ៖ $\text{មធ}_{\text{ឃ}} = \frac{\text{១០៨.៣៣៤}}{\text{២+១}} = \mathbf{\text{៣៦.១១១,៣៣}}$

- គណបក្ស ង ៖ $\text{មធ}_{\text{ង}} = \frac{\text{១៥.១៦២}}{\text{០+១}} = \text{១៥.១៦២,០០}$

- គណបក្ស ច ៖ $\text{មធ}_{\text{ច}} = \frac{\text{២៥.២៨៦}}{\text{០+១}} = \text{២៥.២៨៦,០០}$

- គណបក្ស ឆ ៖ $\text{មធ}_{\text{ឆ}} = \frac{\text{២៨.២៥៥}}{\text{០+១}} = \text{២៨.២៥៥,០០}$

- គណបក្ស ជ ៖ $\text{មធ}_{\text{ជ}} = \frac{\text{៥០.៥២៣}}{\text{១+១}} = \text{២៥.២៦១,៥០}$

- គណបក្ស ឈ ៖ $\text{មធ}_{\text{ឈ}} = \frac{\text{១១.៥៧៦}}{\text{០+១}} = \text{១១.៥៧៦,០០}$

- គណបក្ស ញ ៖ $\text{មធ}_{\text{ញ}} = \frac{\text{៥៨.៧៥១}}{\text{១+១}} = \text{២៤.៣៧៥,៥០}$

- គណបក្ស ដ ៖ $\text{មធ}_{\text{ដ}} = \frac{\text{១៨.៦៩៤}}{\text{០+១}} = \text{១៨.៦៩៤,០០}$

- គណបក្ស ប ៖ $\text{មធ}_{\text{ប}} = \frac{\text{១៥.៣៥៣}}{\text{០+១}} = \text{១៥.៣៥៣,០០}$

ប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំង ១២ ខាងលើ គណបក្ស **ឃ** មានមធ្យមភាគខ្ពស់ជាងគេគឺ **៣៦.១១១,៣៣** ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះគណបក្សនយោបាយ **ឃ** ត្រូវបានទទួលអាសន: ១ (មួយ) ដែលនាំឱ្យ ៖

គណបក្ស ក	បានទទួលអាសន: ១	ដដែល
គណបក្ស ខ	បានទទួលអាសន: ១	ដដែល
គណបក្ស គ	បានទទួលអាសន: ៣	ដដែល
គណបក្ស ឃ	**បានទទួលអាសន: ២+១**	**កើនមួយអាសន:**

គណបក្ស ង	បានទទួលអាសន: ០	ដដែល
គណបក្ស ច	បានទទួលអាសន: ០	ដដែល
គណបក្ស ឆ	បានទទួលអាសន: ០	ដដែល
គណបក្ស ជ	បានទទួលអាសន: ១	ដដែល
គណបក្ស ឈ	បានទទួលអាសន: ០	ដដែល
គណបក្ស ញ	បានទទួលអាសន: ១	ដដែល
គណបក្ស ដ	បានទទួលអាសន: ០	ដដែល
គណបក្ស ឋ	បានទទួលអាសន: ០	ដដែល

សរុប = ដប់ (១០) អាសន:

<u>ឧទាហរណ៍ទី៥ ៖</u> **ការបែងចែកអាសន:បន្ត**

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** ដដែល បន្ទាប់ពីការបែងចែកអាសន:លើកទី៣ (ឧទាហរណ៍ទី៤) នៅមាន**សល់**អាសន:ចំនួន ១ (មួយ) ទៀតដែលត្រូវបន្តបែងចែក ។ អនុវត្តតាមរូបមន្តក្នុងជំហានទីបី ដោយបង្កើនតម្លៃ $អ_{ខ}$ ចំនួន ១ (មួយ) ដល់គណបក្ស **ឃ** ដែលទើបនឹងទទួលបានអាសន:ចំនួនមួយក្នុងការបែងចែកអាសន:លើកទី៣ យើងបាន ៖

- គណបក្ស ក ៖ $\text{ម}_{\text{ធ}}\text{ក} = \frac{\text{៤៩.៦៨២}}{\text{១+១}} = \text{២៤.៨៤១,០០}$

- គណបក្ស ខ ៖ $\text{ម}_{\text{ធ}}\text{ខ} = \frac{\text{៤៨.៧៥៤}}{\text{១+១}} = \text{២៤.៣៧៧,០០}$

- គណបក្ស គ ៖ $\text{ម}_{\text{ធ}}\text{គ} = \frac{\text{១១២.៩៧៨}}{\text{៣+១}} = \text{២៨.២៤៤,៥០}$

- គណបក្ស ឃ ៖ $\text{ម}_{\text{ធ}}\text{ឃ} = \frac{\text{១០៨.៣៣៤}}{\text{៣+១}} = \text{២៧.០៨៣,៥០}$

- គណបក្ស ង ៖ $\text{ម}_{\text{ធ}}\text{ង} = \frac{\text{១៥.១៦២}}{\text{០+១}} = \text{១៥.១៦២,០០}$

- គណបក្ស ច ៖ $\text{ម}_{\text{ធ}}\text{ច} = \frac{\text{២៥.២៨៦}}{\text{០+១}} = \text{២៥.២៨៦,០០}$

- គណបក្ស ឆ ៖ $\text{ម}_{\text{ធ}}\text{ឆ} = \frac{\text{២៨.២៥៥}}{\text{០+១}} = \text{២៨.២៥៥,០០}$

- គណបក្ស ជ ៖ $\text{ម}_{\text{ធ}}\text{ជ} = \frac{\text{៥០.៥២៣}}{\text{១+១}} = \text{២៥.២៦១,៥០}$

- គណបក្ស ឈ ៖ $\text{ម}_{\text{ធ}}\text{ឈ} = \frac{\text{១១.៥៧៦}}{\text{០+១}} = \text{១១.៥៧៦,០០}$

- គណបក្ស ញ ៖ $\text{ម}_{\text{ធ}}\text{ញ} = \frac{\text{៤៨.៧៥១}}{\text{១+១}} = \text{២៤.៣៧៥,៥០}$

- គណបក្ស ដ ៖ $\text{ម}_{\text{ធ}}\text{ដ} = \frac{\text{១៨.៦៩៤}}{\text{០+១}} = \text{១៨.៦៩៤,០០}$

- គណបក្ស ឋ ៖ $\text{ម}_{\text{ធ}}\text{ឋ} = \frac{\text{១៥.៣៥៣}}{\text{០+១}} = \text{១៥.៣៥៣,០០}$

តាមការប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំង ១២ ខាងលើ យើញថា គណបក្ស ឆ មានមធ្យមភាគខ្ពស់ជាងគេគឺ **២៨.២៥៥,០០** ដែលជាមធ្យមភាគខ្ពស់បំផុត ។ ដូចនេះ គណបក្ស ឆ ត្រូវបានទទួលអាសន: ១ (មួយ) ដែលនៅសល់ចុងក្រោយនេះ ។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** ៖

- គណបក្ស ក បានទទួលអាសន: ១
- គណបក្ស ខ បានទទួលអាសន: ១
- គណបក្ស គ បានទទួលអាសន: ៣
- គណបក្ស ឃ បានទទួលអាសន: ៣
- គណបក្ស ឆ បានទទួលអាសន: ១
- គណបក្ស ជ បានទទួលអាសន: ១
- គណបក្ស ញ បានទទួលអាសន: ១
- គណបក្ស ង ច ឈ ដ និង ឋ ពុំបានទទួលអាសន:

សរុប = ដប់មួយ (១១) អាសន:

៤.៣ ក្នុងករណីដែលការបែងចែកអាសនៈលើកទី១ (តាមរូបមន្តក្នុងជំហានទី២) ពុំមានគណបក្សនយោបាយណាមួយទទួលបានអាសនៈទេនោះ គ.ជ.ប ត្រូវអនុវត្តបន្តទៅជំហានទី៣ តាមរូបមន្តមធ្យមភាគខ្ពស់បំផុត និងបន្តគណនាបែងចែកតាមរូបមន្តក្នុងជំហានទី៣ រហូតដល់អស់អាសនៈ ដូចមានចែងក្នុងចំណុច ៤.២ ទាំងមូល។

<u>ឧទាហរណ៍ទី៦ ៖</u> ក្នុងករណីដែលការបែងចែកអាសនៈលើកទី១ ពុំមានគណបក្សនយោបាយណាមួយទទួលបានអាសនៈ

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **B** មាន ៖

- គណបក្សនយោបាយមានចំនួន = ១៤
- សន្លឹកឆ្នោតបានការសរុប ៖ $ស_{ស}$ = ៣៩៦.២០៧
- អាសនៈសរុប ៖ $អ_{ស}$ = ៨ អាសនៈ
- កូតា ៖ $ក_{ត}$ = ៤៩.៥២៥

គណបក្ស នយោបាយ	សិស	អ្ន លើកទី១	ម ១	អ្ន លើកទី២	ម ២	អ្ន លើកទី៣	ម ៣	អ្ន លើកទី៤	ម ៤	អ្ន លើកទី៥	ម ៥	អ្ន លើកទី៦	ម ៦	អ្ន លើកទី៧	ម ៧	អ្ន លើកទី៨	ម ៨	អ្ន លើកទី៩
ក	២០២៣១	០	២០២៣១ ០+១	០	២០២៣១ ០+១	០	២០២៣១ ០+១	០	២០២៣១ ០+១	០	២០២៣១ ០+១	០	២០២៣១ ០+១	០	២០២៣១ ០+១	០	២០២៣១ ០+១	០
ខ	៣១១៣៥	០	៣១១៣៥ ០+១	០	៣១១៣៥ ០+១	០	៣១១៣៥ ០+១	០	៣១១៣៥ ០+១	០	៣១១៣៥ ០+១	០	៣១១៣៥ ០+១	១	៣១១៣៥ ១+១	០	៣១១៣៥ ១+១	០
គ	២២៦០៤	០	២២៦០៤ ០+១	០	២២៦០៤ ០+១	០	២២៦០៤ ០+១	០	២២៦០៤ ០+១	០	២២៦០៤ ០+១	០	២២៦០៤ ០+១	០	២២៦០៤ ០+១	០	២២៦០៤ ០+១	០
ឃ	៣២៩១០	០	៣២៩១០ ០+១	០	៣២៩១០ ០+១	០	៣២៩១០ ០+១	០	៣២៩១០ ០+១	១	៣២៩១០ ១+១	០	៣២៩១០ ១+១	០	៣២៩១០ ១+១	០	៣២៩១០ ១+១	០
ង	១៩៧២០	០	១៩៧២០ ០+១	០	១៩៧២០ ០+១	០	១៩៧២០ ០+១	០	១៩៧២០ ០+១	០	១៩៧២០ ០+១	០	១៩៧២០ ០+១	០	១៩៧២០ ០+១	០	១៩៧២០ ០+១	០
ច	២៥៧៦២	០	២៥៧៦២ ០+១	០	២៥៧៦២ ០+១	០	២៥៧៦២ ០+១	០	២៥៧៦២ ០+១	០	២៥៧៦២ ០+១	០	២៥៧៦២ ០+១	០	២៥៧៦២ ០+១	០	២៥៧៦២ ០+១	០
ឆ	២០៨១៥	០	២០៨១៥ ០+១	០	២០៨១៥ ០+១	០	២០៨១៥ ០+១	០	២០៨១៥ ០+១	០	២០៨១៥ ០+១	០	២០៨១៥ ០+១	០	២០៨១៥ ០+១	០	២០៨១៥ ០+១	០
ជ	៣៧៦៨១	០	៣៧៦៨១ ០+១	០	៣៧៦៨១ ០+១	០	៣៧៦៨១ ០+១	១	៣៧៦៨១ ១+១	០	៣៧៦៨១ ១+១	០	៣៧៦៨១ ១+១	០	៣៧៦៨១ ១+១	០	៣៧៦៨១ ១+១	០
ឈ	១៧៥២៦	០	១៧៥២៦ ០+១	០	១៧៥២៦ ០+១	០	១៧៥២៦ ០+១	០	១៧៥២៦ ០+១	០	១៧៥២៦ ០+១	០	១៧៥២៦ ០+១	០	១៧៥២៦ ០+១	០	១៧៥២៦ ០+១	០
ញ	២៨០៧១	០	២៨០៧១ ០+១	០	២៨០៧១ ០+១	០	២៨០៧១ ០+១	០	២៨០៧១ ០+១	០	២៨០៧១ ០+១	០	២៨០៧១ ០+១	០	២៨០៧១ ០+១	១	២៨០៧១ ១+១	០
ដ	៣៩១៣៩	០	៣៩១៣៩ ០+១	០	៣៩១៣៩ ០+១	១	៣៩១៣៩ ១+១	០	៣៩១៣៩ ១+១	០	៣៩១៣៩ ១+១	០	៣៩១៣៩ ០+១	០	៣៩១៣៩ ១+១	០	៣៩១៣៩ ១+១	០
ឋ	៣១២៦៥	០	៣១២៦៥ ០+១	០	៣១២៦៥ ០+១	០	៣១២៦៥ ០+១	០	៣១២៦៥ ០+១	០	៣១២៦៥ ០+១	១	៣១២៦៥ ១+១	០	៣១២៦៥ ១+១	០	៣១២៦៥ ១+១	០
ឌ	២៧៩៧០	០	២៧៩៧០ ០+១	០	២៧៩៧០ ០+១	០	២៧៩៧០ ០+១	០	២៧៩៧០ ០+១	០	២៧៩៧០ ០+១	០	២៧៩៧០ ០+១	០	២៧៩៧០ ០+១	០	២៧៩៧០ ០+១	១
ឍ	៩១៣៧៨	០	៩១៣៧៨ ០+១	១	៩១៣៧៨ ១+១	០	៩១៣៧៨ ១+១	០	៩១៣៧៨ ១+១	០	៩១៣៧៨ ១+១	០	៩១៣៧៨ ១+១	០	៩១៣៧៨ ១+១	០	៩១៣៧៨ ១+១	០

ករណីពុំមានគណបក្សណាមួយទទួលបានអាសនៈក្នុងការបែងចែកលើកទី១ អាចកើតមាននៅក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តណាដែលមានគណបក្សនយោបាយឈរឈ្មោះច្រើន ហើយសន្លឹកឆ្នោតបានការរបស់គណបក្សមានចំនួនប្រហាក់ប្រហែលគ្នា តាមតារាងឧទាហរណ៍ខាងលើ ៖

- $ស_{ប}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ។
- $អ_{ទ}$: (លើកទី១) តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ ដែលពុំមានគណបក្សនយោបាយណាមួយទទួលបានអាសនៈឡើយ ។ ដូចនេះត្រូវបន្តគណនាដោយអនុវត្តតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដើម្បីកំណត់គណបក្សដែលត្រូវទទួលបានអាសនៈ ។
- $ម_{ធ}$១ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនយោបាយនីមួយៗដែលលទ្ធផលបង្ហាញថា គណបក្សនយោបាយ ណ មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត។
- $អ_{ទ}$: (លើកទី២) គណបក្សនយោបាយ ណ ត្រូវទទួលបានអាសនៈចំនួន ១ (មួយ) ។

នៅសល់អាសនៈចំនួន ៧ (ប្រាំពីរ) ទៀត ដែលត្រូវបន្តគណនាបែងចែក ១ (មួយ) អាសនៈម្តងៗរហូតដល់អាសនៈ តាមរូបមន្តមធ្យមភាគខ្ពស់បំផុតដោយ ត្រូវបង្កើនតម្លៃ $អ_{ទ}$ ចំនួន ១ (មួយ) របស់គណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត និងដែលទើបនឹងទទួលបានអាសនៈចំនួន ១ (មួយ) ក្នុងការបែងចែកមួយលើកៗ ។

- $ម_{ធ}$២ : គណបក្សនយោបាយ ដ មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$: (លើកទី៣) គណបក្សនយោបាយ ដ ត្រូវទទួលបានអាសនៈចំនួន ១ (មួយ) ។
- $ម_{ធ}$៣ : គណបក្សនយោបាយ ជ មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$: (លើកទី៤) គណបក្សនយោបាយ ជ ត្រូវទទួលបានអាសនៈចំនួន ១ (មួយ) ។

- $ម_{ធ}$៤ : គណបក្សនយោបាយ ឃ មានមធ្យមភាគខ្ពស់ជាងគេដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$: (លើកទី៥) គណបក្សនយោបាយ ឃ ត្រូវទទួលបានអាសន:ចំនួន ១ (មួយ) ។
- $ម_{ធ}$៥ : គណបក្សនយោបាយ ឋ មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$: (លើកទី៦) គណបក្សនយោបាយ ឋ ត្រូវទទួលបានអាសន:ចំនួន ១ (មួយ) ។
- $ម_{ធ}$៦ : គណបក្សនយោបាយ ខ មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$: (លើកទី៧) គណបក្សនយោបាយ ខ ត្រូវទទួលបានអាសន:ចំនួន ១ (មួយ) ។
- $ម_{ធ}$៧ : គណបក្សនយោបាយ ញ មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$: (លើកទី៨) គណបក្សនយោបាយ ញ ត្រូវទទួលបានអាសន:ចំនួន ១ (មួយ) ។
- $ម_{ធ}$៨ : គណបក្សនយោបាយ ឌ មានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ។
- $អ_{ទ}$: (លើកទី៩) គណបក្សនយោបាយ ឌ ត្រូវទទួលបានអាសន:ចំនួន ១ (មួយ) ។

លទ្ធផលសម្រេចគឺ ៖

- គណបក្សនយោបាយ ណ ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ ដ ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ ជ ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ ឃ ទទួលបាន ១ (មួយ) អាសន:

- គណបក្សនយោបាយ ឋ ទទួលបាន ១ (មួយ) អាសនៈ
- គណបក្សនយោបាយ ខ ទទួលបាន ១ (មួយ) អាសនៈ
- គណបក្សនយោបាយ ញ ទទួលបាន ១ (មួយ) អាសនៈ
- គណបក្សនយោបាយ ឌ ទទួលបាន ១ (មួយ) អាសនៈ

សរុប = ៨ (ប្រាំបី) អាសនៈ

ករណីគណបក្សនយោបាយដាច់ឆ្នោតណាមួយបោះបង់ចោលអាសនៈ ឬអាសនៈនៅទំនេរ

៥- ក្នុងករណីដែលគណបក្សនយោបាយណាមួយបានទទួលអាសនៈមួយ ឬច្រើនក្នុងរដ្ឋសភា ប៉ុន្តែគណបក្សនយោបាយនោះបានប្រកាសបោះបង់ចោលអាសនៈរបស់ខ្លួន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយ តាមច្បាប់ស្តីពីគណបក្សនយោបាយ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ទៅឱ្យគណបក្សនយោបាយផ្សេងទៀត ដែលមានអាសនៈនៅក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ក្នុងអំឡុងពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីទទួលបានលិខិតបោះបង់អាសនៈចោល ឬលិខិតលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយជាផ្លូវការ ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយដូចខាងក្រោម ៖

<u>ជំហានទីមួយ ៖</u> ការកំណត់រកកូតាដែលតម្រូវឱ្យគណបក្សនយោបាយទទួលបានមួយអាសនៈ

ដើម្បីរកកូតាដែលតម្រូវឱ្យគណបក្សនយោបាយមួយ ទទួលបាន ១ (មួយ) អាសនៈ ត្រូវយកសន្លឹកឆ្នោតបានការសរុបរបស់គណបក្សនយោបាយទាំងអស់ ដែលបានទទួលអាសនៈក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ដកចេញចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយដែលបោះបង់ចោលអាសនៈ រួចយកមកចែកនឹងចំនួនអាសនៈដែលនៅទំនេរតាមរូបមន្ត ៖

$$ក'_{ត} = \frac{ស'_{ប}}{អ'_{ប}}$$

ក្នុងនោះ ៖

- $ក'_{ត}$: តាងឱ្យកូតាជាផលចែក ដោយមិនគិតសំណល់ចែក ។

- ស'ᵢ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យគណបក្សនយោបាយទាំងអស់ដែលបានទទួលអាសនៈក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត ដកចេញចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយ ដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ។
- អ'ᵢ : តាងឱ្យចំនួនអាសនៈដែលបោះបង់ចោល ឬនៅទំនេរ ។

<u>ឧទាហរណ៍ទី៧ ៖</u> ការកំណត់ក្បួតានៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** ដដែល ៖

- គណបក្ស ក បានទទួលអាសនៈ ១
- គណបក្ស ខ បានទទួលអាសនៈ ១
- គណបក្ស គ បានទទួលអាសនៈ ៣
- គណបក្ស ឃ បានទទួលអាសនៈ ៣
- គណបក្ស ឆ បានទទួលអាសនៈ ១
- គណបក្ស ជ បានទទួលអាសនៈ ១
- គណបក្ស ង ច ឈ ដ និង ឋ ពុំបានទទួលអាសនៈ

គណបក្សនយោបាយ **ឃ** បានបោះបង់ចោលអាសនៈទាំង ៣ (បី) ។ គណបក្សនយោបាយដែលបានទទួលអាសនៈក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** មាន ៧ គឺគណបក្សនយោបាយ **ក ខ គ ឃ ឆ ជ** និង **ញ** ។

នៅពេលដែលគណបក្សនយោបាយ **ឃ** បានបោះបង់ចោលអាសនៈរបស់ខ្លួន អាសនៈដែលបោះបង់ចោលនោះត្រូវយកមកបែងចែកឱ្យគណបក្សនយោបាយ **ក ខ គ ឆ ជ** និង **ញ** ដែលមានអាសនៈក្នុងមណ្ឌលបោះឆ្នោតខេត្តនោះ រីឯគណបក្ស **ង ច ឈ ដ** និង **ឋ** ដែលពុំបានទទួលអាសនៈក្នុងមណ្ឌលបោះឆ្នោតនោះ ពុំត្រូវបានរាប់បញ្ចូលក្នុងការបែងចែកអាសនៈដែលគណបក្ស **ឃ** បានបោះបង់ចោលឡើយ ។

អនុវត្តតាមរូបមន្តក្នុងជំហានទី១ ដែលបានកំណត់ក្នុងចំណុច ៥.១ ការកំណត់ក្បួតា នៃអាសនៈដែលបានបោះបង់ចោល ឬនៅទំនេរ ៖

ស'ប = (៤៩.៦៨២+៤៨.៧៥៤+១១២.៩៧៨+១០៨.៣៣៤+២៨.២៤៥+៥០.៥២៣+
៤៨.៧៥១) - ១០៨.៣៣៤ = ៣៣៨.៩៣៣

អ'ប = ៣ អាសន:

យើងបាន ៖

$$ក'ត = \frac{ស'ប}{អ'ប} = \frac{៣៣៨.៩៣៣}{៣} = ១១២.៩៧៧,៦៦$$

កូតាស្មើនឹង ១១២.៩៧៧ (ក'ត = ១១២.៩៧៧)

៥.២ <u>ជំហានទីពីរ ៖</u> ការកំណត់ចំនួនអាសន:ជាបឋម ឬលើកទី១

ដើម្បីកំណត់ចំនួនអាសន: (ដែលត្រូវបានបោះបង់ចោល ឬនៅទំនេរ) ដែលគណបក្ស ក ខ គ ឆ ជ និង ញ ទទួលបានលើកទី១ ត្រូវយកចំនួនសន្លឹកឆ្នោតបានការដែលគណបក្សនីមួយៗបានទទួលមកចែកនឹងកូតានៃអាសន:ដែលបានបោះបង់ចោលតាមរូបមន្តដូចខាងក្រោម ៖

$$\boxed{អ'ទ = \frac{ស_ប}{ក'ត}}$$

ក្នុងនោះ ៖

- អ'ទ : តាងឱ្យចំនួនអាសន:ដែលបោះបង់ចោល ឬនៅទំនេរ ដែលគណបក្សនីមួយៗបានទទួល មុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី៣ ។
- ស$_ប$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបោះឱ្យគណបក្សនយោបាយនីមួយៗ ។
- ក'ត : តាងឱ្យកូតានៃអាសន:ដែលបានបោះបង់ចោល ឬនៅទំនេរដែលបានកំណត់ក្នុងជំហានទី១ ។

<u>ឧទាហរណ៍ទី៨ ៖</u> **ការបែងចែកលើកទី១នៃអាសន: ដែលត្រូវបានបោះបង់ចោល**

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** ដដែល អាសន: ៣ (បី) របស់គណបក្ស **យ** ដែលបានបោះបង់ចោល ត្រូវយកមកធ្វើការបែងចែកតាមជំហានទីពីរ ដោយអនុវត្តតាមរូបមន្តក្នុងចំណុច ៥.២ ។

យើងបាន ៖

- គណបក្ស ក ៖ $\text{អ}'_{\text{ក}} = \frac{\text{៤៩.៦៨២}}{\text{១១២.៩៧៧}} = \text{0,៤៣}$

- គណបក្ស ខ ៖ $\text{អ}'_{\text{ខ}} = \frac{\text{៤៨.៧៥៤}}{\text{១១២.៩៧៧}} = \text{0,៤៣}$

- គណបក្ស គ ៖ $\text{អ}'_{\text{គ}} = \frac{\text{១១២.៩៧៨}}{\text{១១២.៩៧៧}} = \text{១,00}$

- គណបក្ស ឆ ៖ $\text{អ}'_{\text{ឆ}} = \frac{\text{២៨.២៥៥}}{\text{១១២.៩៧៧}} = \text{0,២៥}$

- គណបក្ស ជ ៖ $\text{អ}'_{\text{ជ}} = \frac{\text{៥0.៥២៣}}{\text{១១២.៩៧៧}} = \text{0,៤៤}$

- គណបក្ស ញ ៖ $\text{អ}'_{\text{ញ}} = \frac{\text{១១.៥៧6}}{\text{១១២.៩៧៧}} = \text{0,៤៣}$

តាមការគណនាខាងលើគណបក្ស គ ត្រូវទទួលបានអាសនៈចំនួន ១ (មួយ) រីឯគណបក្ស ក ខ ឆ ជ និង ញ ពុំទាន់ទទួលបានអាសនៈដែលបោះបង់ចោលនេះទេ ។
ដូចនេះគណបក្ស គ បានទទួល ៤ (បួន) អាសនៈ (កើនលើសមុន ១ (មួយ) អាសនៈ) ។

៥.៣ បន្ទាប់ពីបានធ្វើការគណនាបែងចែកអាសនៈ ដែលបោះបង់ចោលក្នុងជំហានទី៣ សម្រាប់គណបក្សទាំងអស់ដែលមានអាសនៈក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្ត លើកលែងតែគណបក្សដែលបោះបង់អាសនៈចោល ក្នុងករណីគ្មានអាសនៈនៅសល់ដើម្បីបន្តបែងចែកទៀតនោះ ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

៥.៤ ក្នុងករណីការគណនាក្នុងជំហានទី២ ឬបន្ទាប់ពីការបែងចែកអាសនៈដែលត្រូវបានបោះបង់ចោលលើកទី១ ហើយនៅមានសល់អាសនៈដែលត្រូវបន្តបែងចែកទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តក្នុងជំហានទីបី ។

៥.៥ <u>ជំហានទីបី ៖</u> **ការកំណត់មធ្យមភាគខ្ពស់បំផុត**

៥.៥.១ ជាដំបូងត្រូវកំណត់មធ្យមភាគរបស់គណបក្សនីមួយៗតាមរូបមន្ត ៖

$$\text{ម'}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ'}_{\text{ទ}} + ១}$$

ក្នុងនោះ ៖

- ម'ធ : តាងឱ្យមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ ។
- ស$_{\text{ប}}$: តាងឱ្យចំនួនសន្លឹកឆ្នោតដែលបានបោះឱ្យគណបក្សនយោបាយនីមួយៗ ។
- អ'$_{\text{ទ}}$: តាងចំនួនអាសន:ដែលបោះបង់ចោល និងដែលបានបែងចែកទៅឱ្យគណបក្សនយោបាយនីមួយៗ ។
- ១ : ជាលេខនិមិត្ត ។

៥.៥.២ បន្ទាប់ពីកំណត់បានមធ្យមភាគរបស់គណបក្សនយោបាយនីមួយៗ ហើយត្រូវធ្វើការប្រៀបធៀបគ្នា ។ គណបក្សនយោបាយណាមានមធ្យមភាគខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុតនឹងត្រូវទទួលបានអាសន: ១ (មួយ) ។

<u>ឧទាហរណ៍ទី៩ ៖</u> ការបែងចែកលើកទី២ នៃអាសន:ដែលត្រូវបានបោះបង់ចោល

បន្ទាប់ពីការបែងចែកលើកទី១ ដែលអាសន: ១ (មួយ) ត្រូវបានទៅគណបក្ស **គ** នៅមានសល់អាសន:ចំនួន ២ (ពីរ) ទៀតដែលត្រូវបន្តធ្វើការបែងចែក ។

អនុវត្តតាមរូបមន្តក្នុងជំហានទីបី ដោយបង្កើនតម្លៃ អ'$_{\text{ទ}}$ ចំនួន ១(មួយ) របស់គណបក្សទាំងអស់ យើងបាន ៖

- គណបក្ស ក ៖ ម'$_{\text{ធ}}$ក = $\frac{\text{៤៩.៦៨២}}{0+\text{១}}$ = ៤៩.៦៨២,00
- គណបក្ស ខ ៖ ម'$_{\text{ធ}}$ខ = $\frac{\text{៤៨.៧៥៤}}{0+\text{១}}$ = ៤៨.៧៥៤,00
- គណបក្ស គ ៖ ម'$_{\text{ធ}}$គ = $\frac{\text{១១២.៩៧៨}}{\text{១}+\text{១}}$ = **៥៦.៤៨៩,00**

- គណបក្ស ឆ ៖ $\text{ម'}_{\text{ធ}}\text{ឆ} = \frac{\text{២៨.២៤៥}}{\text{0+១}} = \text{២៨.២៤៥,00}$

- គណបក្ស ជ ៖ $\text{ម'}_{\text{ធ}}\text{ជ} = \frac{\text{៥0.៥២៣}}{\text{0+១}} = \text{៥0.៥២៣,00}$

- គណបក្ស ញ ៖ $\text{ម'}_{\text{ធ}}\text{ញ} = \frac{\text{៤៨.៧៥១}}{\text{0+១}} = \text{៤៨.៧៥១,00}$

តាមការប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងប្រាំមួយខាងលើ គណបក្ស **គ** មានមធ្យមភាគ **៥៦.៤៨៩,00** ខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះគណបក្ស **គ** ត្រូវទទួលបានអាសនៈចំនួន ១ (មួយ) បន្ថែមទៀត ។

<u>ឧទាហរណ៍ទី១០ ៖</u> ការបែងចែកលើកទី៣ នៃអាសនៈដែលត្រូវបានបោះបង់ចោល

បន្ទាប់ពីការបែងចែកអាសនៈលើកទី២ (ឧទាហរណ៍ទី៩) នៅមានសល់អាសនៈចំនួន ១ (មួយ) ទៀតដែលត្រូវបន្តបែងចែក ។

អនុវត្តតាមរូបមន្តក្នុងជំហានទីបី ដោយបង្កើនតម្លៃ $\text{អ}_{\text{ទ}}$ ចំនួន ១ (មួយ) ដល់គណបក្ស **គ** ដែលទើបនឹងទទួលបានអាសនៈ ១ (មួយ) ក្នុងការបែងចែកកន្លងមកនេះ យើងបាន ៖

- គណបក្ស ក ៖ $\text{ម'}_{\text{ធ}}\text{ក} = \frac{\text{៤៩.៦៨២}}{\text{0+១}} = \text{៤៩.៦៨២,00}$

- គណបក្ស ខ ៖ $\text{ម'}_{\text{ធ}}\text{ខ} = \frac{\text{៤៨.៧៥៤}}{\text{0+១}} = \text{៤៨.៧៥៤,00}$

- គណបក្ស គ ៖ $\text{ម'}_{\text{ធ}}\text{គ} = \frac{\text{១១២.៩៧៨}}{\text{២+១}} = \text{៣៧.៦៥៩,00}$

- គណបក្ស ឆ ៖ $\text{ម'}_{\text{ធ}}\text{ឆ} = \frac{\text{២៨.២៤៥}}{\text{0+១}} = \text{២៨.២៤៥,00}$

- គណបក្ស ជ ៖ $\text{ម'}_{\text{ធ}}\text{ជ} = \frac{\text{៥0.៥២៣}}{\text{0+១}} = \text{៥0.៥២៣,00}$

- គណបក្ស ញ ៖ $\text{ម'}_{\text{ធ}}\text{ញ} = \frac{\text{៤៨.៧៥១}}{\text{0+១}} = \text{៤៨.៧៥១,00}$

តាមការប្រៀបធៀបមធ្យមភាគរបស់គណបក្សនយោបាយទាំងប្រាំមួយខាងលើ គណបក្ស ជ មានមធ្យមភាគ **៥០.៥២៣,០០** ខ្ពស់ជាងគេ ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះគណបក្ស ជ ត្រូវទទួលបានអាសនៈចំនួន ១ (មួយ) ។

ជាលទ្ធផលសម្រេចក្នុងមណ្ឌលបោះឆ្នោតខេត្ត **A** ៖

- គណបក្ស ក បានទទួលអាសនៈ ១
- គណបក្ស ខ បានទទួលអាសនៈ ១
- គណបក្ស គ បានទទួលអាសនៈ ៥
- គណបក្ស ឆ បានទទួលអាសនៈ ១
- គណបក្ស ជ បានទទួលអាសនៈ ២
- គណបក្ស ញ បានទទួលអាសនៈ ១

សរុប = ១១ (ដប់មួយ) អាសនៈ

៥.៥.៣ វិធីសាស្ត្រគណនាដូចមានចែងក្នុងជំហានទីបី ចំណុច ៥.៥ ត្រូវអនុវត្តម្តង ហើយម្តងទៀត ក្នុងករណីមាននៅសល់អាសនៈដែលត្រូវបន្តបែងចែក។

ករណីលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន

៦- ក្នុងករណីដែលការគណនាតាមរូបមន្តបែងចែកអាសនៈដូចមានចែងក្នុងចំណុច ៤.២ និងចំណុច ៥ នៃឧបសម្ព័ន្ធនេះ មានលទ្ធផលស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន នោះការបែងចែកអាសនៈត្រូវកំណត់ដូចខាងក្រោម ៖

៦.១ ក្នុងករណីគណបក្សនយោបាយមួយចំនួនមានមធ្យមភាគខ្ពស់ជាងគេស្មើគ្នា ដែលជាមធ្យមភាគខ្ពស់បំផុត អាសនៈដែលនៅសល់ត្រូវផ្តល់ជូនគណបក្សនយោបាយណាដែលទទួលបានសន្លឹកឆ្នោតបានការច្រើនជាងគេ ។

<u>ឧទាហរណ៍ទី១១ ៖</u> **ករណីគណបក្សនយោបាយមួយចំនួនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុត (ចែកដល់ពីរ (២) ខ្ទង់ក្រោយក្បៀស) ស្មើគ្នា អាសនៈដែលនៅសល់ត្រូវផ្តល់ជូនទៅគណបក្សនយោបាយណា ដែលមានចំនួនសន្លឹកឆ្នោតបានការច្រើនជាងគេ ។**

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **C** មាន ៖

- គណបក្សនយោបាយចំនួន ៖ ១៥

- សន្លឹកឆ្នោតបានការសរុប ៖ $ស_{ស}$ = ៥៥៩.៦៤២
- អាសនៈសរុប ៖ $អ_{ស}$ = ១២
- កូតា ៖ $ក_{ត}$ = ៤៦.៦៣៦

គណបក្ស នយោបាយ	$ស_{ប}$	$អ_{ទ}$ លើកទី១	$ម_{ធ}$១	$អ_{ទ}$ លើកទី២	$ម_{ធ}$២	$អ_{ទ}$ លើកទី៣
ក	៥២.៦៤២	១	៥២.៦៤២ / ១+១ = ២៦.៣២១,០០	០	៥២.៦៤២ / ១+១ = ២៦.៣២១,០០	០
ខ	១២.៩៣៥	០	១២.៩៣៥ / ០+១ = ១២.៩៣៥,០០	០	១២.៩៣៥ / ០+១ = ១២.៩៣៥,០០	០
គ	១៨៧.៨៩៤	៤	១៨៧.៨៩៤ / ៤+១ = ៣៧.៥៧៨,០០	១	១៨៧.៨៩៤ / ៥+១ = ៣១.៣១៥,៦៦	១
ឃ	៥០.៧៧៤	១	៥០.៧៧៤ / ១+១ = ២៥.៣៨៧,០០	០	៥០.៧៧៤ / ១+១ = ២៥.៣៨៧,០០	០
ង	៨.៦៥៧	០	៨.៦៥៧ / ០+១ = ៨.៦៥៧,០០	០	៨.៦៥៧ / ០+១ = ៨.៦៥៧,០០	០
ច	១២.១៥០	០	១២.១៥០ / ០+១ = ១២.១៥០,០០	០	១២.១៥០ / ០+១ = ១២.១៥០,០០	០
ឆ	៦.៧៥៩	០	៦.៧៥៩ / ០+១ = ៦.៧៥៩,០០	០	៦.៧៥៩ / ០+១ = ៦.៧៥៩,០០	០
ជ	៩៣.៩៤៧	២	៩៣.៩៤៧ / ២+១ = ៣១.៣១៥,៦៦	០	៩៣.៩៤៧ / ២+១ = ៣១.៣១៥,៦៦	០
ឈ	៩.០៥៣	០	៩.០៥៣ / ០+១ = ៩.០៥៣,០០	០	៩.០៥៣ / ០+១ = ៩.០៥៣,០០	០
ញ	៤.៧១១	០	៤.៧១១ / ០+១ = ៤.៧១១,០០	០	៤.៧១១ / ០+១ = ៤.៧១១,០០	០
ដ	៤៨.១៦៣	១	៤៨.១៦៣ / ១+១ = ២៤.០៨១,៥០	០	៤៨.១៦៣ / ១+១ = ២៤.០៨១,៥០	០
ឋ	៧.៤៦១	០	៧.៤៦១ / ០+១ = ៧.៤៦១,០០	០	៧.៤៦១ / ០+១ = ៧.៤៦១,០០	០
ឌ	៥.២៤៧	០	៥.២៤៧ / ០+១ = ៥.២៤៧,០០	០	៥.២៤៧ / ០+១ = ៥.២៤៧,០០	០
ឍ	៥៥.១៣០	១	៥៥.១៣០ / ១+១ = ២៧.៥៦៥,០០	០	៥៥.១៣០ / ១+១ = ២៧.៥៦៥,០០	០
ណ	៤.១១៩	០	៤.១១៩ / ០+១ = ៤.១១៩,០០	០	៤.១១៩ / ០+១ = ៤.១១៩,០០	០

$ស_{ប}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។

$អ_{ទ}$: (លើកទី១) តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ ។

ម$_{ធ}$១ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនយោបាយនីមួយៗ ។ គណបក្សនយោបាយ គ មានមធ្យមភាគខ្ពស់ជាងគេគឺ ៣៧.៥៧៨,៨០ ដែលជាមធ្យមភាគខ្ពស់បំផុត ។

អ$_{ទ}$: (លើកទី២) គណបក្សនយោបាយ គ ត្រូវបានទទួលអាសន: ១ (មួយ) បន្ថែមទៀត ។

នៅសល់អាសន:ចំនួន ១ (មួយ) ទៀត ដែលត្រូវបន្តគណនាបែងចែក ។

ម$_{ធ}$២ : គណបក្សនយោបាយ គ និង ជ មានមធ្យមភាគខ្ពស់ជាងគេ (ចែកដល់ពីរ (២) ខ្ទង់ក្រោយក្បៀស) ស្មើគ្នាគឺ ៣១.៣១៥,៦៦ ដែលជាមធ្យមភាគខ្ពស់បំផុត ប៉ុន្តែដោយគណបក្ស គ មានសន្លឹកឆ្នោតបានការចំនួន ១៨៧.៨៩៤ សន្លឹក ច្រើនជាងគណបក្ស ជ ដែលមានតែ ៩៣.៩៤៧ សន្លឹក ដូចនេះអាសន:ដែលនៅសល់ត្រូវផ្តល់ជូនទៅគណបក្ស គ ។

លទ្ធផលសម្រេចគឺ ៖

- គណបក្សនយោបាយ ក ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ គ ទទួលបាន ៦ (ប្រាំមួយ) អាសន:
- គណបក្សនយោបាយ ឃ ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ ជ ទទួលបាន ២ (ពីរ) អាសន:
- គណបក្សនយោបាយ ដ ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ ណ ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ ខ ង ច ឆ ឈ ញ ប ឌ និង ណ ពុំបានទទួលអាសន:

សរុប = ១២ (ដប់ពីរ) អាសន: ។

៦.២ ក្នុងករណីដែលចំនួនអាសន:នៅសល់ត្រូវបែងចែកមានចំនួនស្មើ ឬលើសចំនួនគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នានោះ គ.ជ.ប ត្រូវបែងចែកអាសន:ដែលនៅសល់ឱ្យគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ដោយគណបក្សនយោបាយនីមួយៗបានទទួលអាសន: ១ (មួយ) ។ បើមានអាសន:នៅសល់ទៀត ត្រូវបន្តបែងចែកតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដដែល ។

<u>ឧទាហរណ៍ទី១២ ៖</u> អំពីករណីចំនួនអាសនៈដែលនៅសល់ត្រូវបែងចែកបន្តមានចំនួនស្មើគ្នា បើប្រៀបធៀបនឹងចំនួនគណបក្សនយោបាយដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **D** មាន ៖

- គណបក្សនយោបាយចំនួន ៖ ១៣
- សន្លឹកឆ្នោតបានការសរុប ៖ $ស_{ស}$ = ៣៣១.៦៧២
- អាសនៈសរុប ៖ $អ_{ស}$ = ៧ អាសនៈ
- កូតា ៖ $ក_{ត}$ = ៥៧.៣៨១

គណបក្សនយោបាយ	$ស_{ប}$	$អ_{១}$ លើកទី១	$ម_{ធ}$១	$អ_{១}$ លើកទី២	$ម_{ធ}$២	$អ_{១}$ លើកទី៣
ក	៥.៨៦៦	០	៥.៨៦៦ / ០+១ = ៥.៨៦៦,០០	០	៥.៨៦៦ / ០+១ = ៥.៨៦៦,០០	០
ខ	១៣.៨៦៥	០	១៣.៨៦៥ / ០+១ = ១៣.៨៦៥,០០	០	១៣.៨៦៥ / ០+១ = ១៣.៨៦៥,០០	០
គ	១០៧.៩២៨	២	១០៧.៩២៨ / ២+១ = ៣៥.៩៧៦,០០	០	១០៧.៩២៨ / ២+១ = ៣៥.៩៧៦,០០	១
ឃ	៦.៨៧៤	០	៦.៨៧៤ / ០+១ = ៦.៨៧៤,០០	០	៦.៨៧៤ / ០+១ = ៦.៨៧៤,០០	០
ង	៥៨.១៥៣	១	៥៨.១៥៣ / ១+១ = ២៩.០៧៦,៥០	០	៥៨.១៥៣ / ១+១ = ២៩.០៧៦,៥០	០
ច	៤.១៦៨	០	១២.១៥០ / ០+១ = ១២.១៥០,០០	០	១២.១៥០ / ០+១ = ១២.១៥០,០០	០
ឆ	៥.៤៣៧	០	៥.៤៣៧ / ០+១ = ៥.៤៣៧,០០	០	៥.៤៣៧ / ០+១ = ៥.៤៣៧,០០	០
ជ	៣៧.៤៥៤	០	៣៧.៤៥៤ / ០+១ = ៣៧.៤៥៤,០០	១	៣៧.៤៥៤ / ១+១ = ១៨.៧២៧,០០	០
ឈ	៧.១៦៧	០	៧.១៦៧ / ០+១ = ៧.១៦៧,០០	០	៧.១៦៧ / ០+១ = ៧.១៦៧,០០	០
ញ	៧.៤៨៥	០	៧.៤៨៥ / ០+១ = ៧.៤៨៥,០០	០	៧.៤៨៥ / ០+១ = ៧.៤៨៥,០០	០
ដ	៧១.៩៥២	១	៧១.៩៥២ / ១+១ = ៣៥.៩៧៦,០០	០	៧១.៩៥២ / ១+១ = ៣៥.៩៧៦,០០	១
ឋ	២.៨១៣	០	២.៨១៣ / ០+១ = ២.៨១៣,០០	០	២.៨១៣ / ០+១ = ២.៨១៣,០០	០
ឌ	២.៥១០	០	២.៥១០ / ០+១ = ២.៥១០,០០	០	២.៥១០ / ០+១ = ២.៥១០,០០	០

$ស_{ប}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។

$អ_{ទ}$: (លើកទី១) តាងឱ្យចំនួនអាសន:ដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ ។

$ម_{ធ}$១ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនយោបាយនីមួយៗ ។ គណបក្សនយោបាយ ជ មានមធ្យមភាគខ្ពស់ជាងគេគឺ ៣៧.៥៥៤,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។

$អ_{ទ}$: (លើកទី២) គណបក្សនយោបាយ ជ ត្រូវទទួលបានអាសន: ១ (មួយ) ។

នៅសល់អាសន:ចំនួន ២ (ពីរ) ទៀត ដែលត្រូវបន្តគណនាបែងចែក ។

$ម_{ធ}$២ : គណបក្សនយោបាយ **គ** និង ដ មានមធ្យមភាគខ្ពស់ជាងគេស្មើគ្នាគឺ ៣៥.៩៧៦,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ដូចនេះអនុវត្តតាមចំណុច ៦.២ គ.ជ.ប ត្រូវបែងចែកអាសន:ទាំង ២ (ពីរ) នេះ ឱ្យទៅគណបក្សនយោបាយ **គ** ១ (មួយ) អាសន: និងគណបក្សនយោបាយ ដ ១ (មួយ) អាសន: ។

លទ្ធផលសម្រេចគឺ ៖

- គណបក្សនយោបាយ គ ទទួលបាន ៣ (បី) អាសន:
- គណបក្សនយោបាយ ង ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ ជ ទទួលបាន ១ (មួយ) អាសន:
- គណបក្សនយោបាយ ដ ទទួលបាន ២ (ពីរ) អាសន:
- គណបក្សនយោបាយ ក ខ យ ច ឆ ឈ ញ ប ឌ ពុំបានទទួលអាសន:

សរុប = ៧ (ប្រាំពីរ) អាសន: ។

<u>ឧទាហរណ៍ទី១៣ ៖</u> ករណីចំនួនអាសន:ដែលនៅសល់ត្រូវបែងចែកបន្ត មានចំនួនលើសពីចំនួនគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា ។

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **E** មាន ៖

- គណបក្សនយោបាយ ៖ ១០
- សន្លឹកឆ្នោតបានការសរុប ៖ $ស_{ស}$ = ២៧៨.៣៦១
- អាសន:សរុប ៖ $អ_{ស}$ = ៦ អាសន:
- កូតា ៖ $ក_{ត}$ = ៤៦.៣៩៣

គណបក្ស នយោបាយ	សប	អ១ លើកទី១	ម១		អ១ លើកទី២	ម២		អ១ លើកទី៣
ក	៣១.៣៩២	០	៣១.៣៩២ ០+១	= ៣១.៣៩២,០០	១	៣១.៣៩២ ១+១	= ១៥.៦៩៦,០០	០
ខ	១៧.៤៥៣	០	១៧.៤៥៣ ០+១	= ១៧.៤៥៣,០០	០	១៧.៤៥៣ ០+១	= ១៧.៤៥៣,០០	០
គ	៩៤.១៧៦	២	៩៤.១៧៦ ២+១	= ៣១.៣៩២,០០	១	៩៤.១៧៦ ៣+១	= ២៣.៥៤៤,០០	០
ឃ	៨.១៦៥	០	៨.១៦៥ ០+១	= ៨.១៦៥,០០	០	៨.១៦៥ ០+១	= ៨.១៦៥,០០	០
ង	១៨.១៥៧	០	១៨.១៥៧ ០+១	= ១៨.១៥៧,០០	០	១៨.១៥៧ ០+១	= ១៨.១៥៧,០០	០
ច	៤៧.០៨៩	១	៤៧.០៨៩ ១+១	= ២៣.៥៤៤,៥០	០	៤៧.០៨៩ ១+១	= ២៣.៥៤៤,៥០	១
ឆ	១៤.៥៣៩	០	១៤.៥៣៩ ០+១	= ១៤.៥៣៩,០០	០	១៤.៥៣៩ ០+១	= ១៤.៥៣៩,០០	០
ជ	១៤.៤១៥	០	១៤.៤១៥ ០+១	= ១៤.៤១៥,០០	០	១៤.៤១៥ ០+១	= ១៤.៤១៥,០០	០
ឈ	១២.៩៣១	០	១២.៩៣១ ០+១	= ១២.៩៣១	០	១២.៩៣១ ០+១	= ១២.៩៣១,០០	០
ញ	២០.០៤៤	០	២០.០៤៤ ០+១	= ២០.០៤៤,០០	០	២០.០៤៤ ០+១	= ២០.០៤៤,០០	០

សប : តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។

អ១ : (លើកទី១) តាងឱ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗទទួលបានក្នុងការបែងចែកលើកទី១ ។

ម១ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី១ របស់គណបក្សនយោបាយនីមួយៗ ។ គណបក្សនយោបាយ **ក** និងគណបក្សនយោបាយ **គ** មានមធ្យមភាគខ្ពស់ជាងគេស្មើគ្នាគឺ ៣១.៣៩២,០០ ដែលជាមធ្យមភាគខ្ពស់បំផុត ។

អ១ : (លើកទី២) **អនុវត្ត**តាមចំណុច ៦.២ គ.ជ.ប ត្រូវបែងចែកអាសនៈទៅឱ្យគណបក្សនយោបាយ **ក ១** (មួយ) អាសនៈ និងគណបក្សនយោបាយ **គ** ១ (មួយ) អាសនៈ។

នៅសល់អាសនៈ ១ (មួយ) ទៀត ដែលត្រូវបន្តគណនាបែងចែក ។

ម២ : គណបក្សនយោបាយ **ច** មានមធ្យមភាគខ្ពស់ជាងគេគឺ ២៣.៥៤៤,៥០ ដែលជាមធ្យមភាគខ្ពស់បំផុត ។

អ១ : (លើកទី៣) ដូចនេះ អាសនៈ ១ (មួយ) ដែលនៅសល់ត្រូវបែងចែកទៅឱ្យគណបក្សនយោបាយ **ច** ។

ជាលទ្ធផលសម្រេចគឺ ៖

- គណបក្សនយោបាយ ក ទទួលបាន ១ (មួយ) អាសនៈ
- គណបក្សនយោបាយ គ ទទួលបាន ៣ (បី) អាសនៈ
- គណបក្សនយោបាយ ច ទទួលបាន ២ (ពីរ) អាសនៈ
- គណបក្សនយោបាយ ខ យ ង ឆ ជ ឈ និង ញ ពុំបានទទួលអាសនៈ

សរុប = ៦ (ប្រាំមួយ) អាសនៈ ។

ករណីគណបក្សនយោបាយមួយចំនួនមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងចំនួនសន្លឹកឆ្នោតបានការស្មើគ្នា ត្រូវអនុវត្តនីតិវិធីចាប់ឆ្នោតជាសាធារណៈ

៦.៣ ក្នុងករណីលទ្ធផលនៃការគណនារកមធ្យមភាគខ្ពស់បំផុតស្មើគ្នា ហើយចំនួនសន្លឹកឆ្នោតបានការក៏ស្មើគ្នារវាងគណបក្សនយោបាយមួយចំនួន ដែលមិនអាចកំណត់ឱ្យគណបក្សនយោបាយណាមួយបានទទួលអាសនៈដែលត្រូវបែងចែកនេះ គ.ជ.ប ត្រូវអនុវត្តវិធីចាប់ឆ្នោតជាសាធារណៈ ដើម្បីកំណត់យកគណបក្សនយោបាយណាដែលត្រូវបានទទួលអាសនៈដែលត្រូវបែងចែក ។

៦.៤ ករណីនេះ គ.ជ.ប ត្រូវប្រគល់ភារកិច្ចឱ្យអគ្គលេខាធិការដ្ឋានចាត់ចែងរៀបចំពិធីចាប់ឆ្នោតជាសាធារណៈនោះ ។

៦.៥ ពិធីចាប់ឆ្នោតជាសាធារណៈត្រូវធ្វើនៅទីស្តីការ គ.ជ.ប ក្រោយពេលបញ្ចប់ការគណនាបែងចែកអាសនៈ តាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តទូទាំងប្រទេសនៅ គ.ជ.ប ។ គ.ជ.ប ត្រូវកំណត់ទីកន្លែង ពេលវេលា និងកម្មវិធីចាប់ឆ្នោតជាសាធារណៈ ហើយត្រូវយាង និងអញ្ជើញ ៖

- សម្តេចព្រះសង្ឆរាជ ឬព្រះរាជតំណាង ជាអធិបតីក្នុងពិធីចាប់ឆ្នោត
- តំណាងផ្លូវការនៃគណបក្សនយោបាយ ដែលមានលទ្ធផលនៃការគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងមានសន្លឹកឆ្នោតបានការស្មើគ្នា
- តំណាងផ្លូវការនៃគណបក្សនយោបាយដែលបានចូលរួមបោះឆ្នោតក្នុងមណ្ឌលរាជធានី ខេត្តពាក់ព័ន្ធ
- អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ

ដើម្បីចូលរួមក្នុងពិធីចាប់ឆ្នោតនេះ ។

៦.៦ ពិធីចាប់ឆ្នោតត្រូវអនុវត្តតាមជំហានដូចខាងក្រោម ៖

- ត្រូវសរសេរ ឬបោះពុម្ពនៅលើក្រដាសដែលមានប្រភេទ ទំហំ និងពណ៌ស ដូចគ្នា នូវឈ្មោះនៃគណបក្សនយោបាយទាំងឡាយដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងមានសន្លឹកឆ្នោតបានការស្មើគ្នា ។ ក្រដាសឆ្នោតមួយសន្លឹកត្រូវសរសេរ ឬបោះពុម្ពឈ្មោះតែមួយគណបក្សនយោបាយប៉ុណ្ណោះ។ តួអក្សរឈ្មោះរបស់គណបក្សនយោបាយត្រូវមានប្រភេទ ទំហំ និងពណ៌ដូចគ្នា។ ក្រដាសសន្លឹកឆ្នោតដែលសរសេរ ឬបោះពុម្ពឈ្មោះគណបក្សនយោបាយរួចហើយ ត្រូវបត់ជាផ្នត់ដូចគ្នា ដាក់ក្នុងស្រោមសំបុត្រដែលមានប្រភេទ ពណ៌ និងទំហំដូចគ្នា រួចបិទភ្ជិត ដោយមូរនិងចងកៅស៊ូកងពណ៌ដូចគ្នា ។
- ត្រូវបង្ហាញហិបឆ្នោតទទេជាសាធារណៈ មុននឹងដាក់សំបុត្រសន្លឹកឆ្នោតទៅក្នុងហិបនោះ និងបិទគម្រប ។
- ត្រូវក្រឡុកហិបឆ្នោត រួចហើយលើកហិបឆ្នោតនោះទៅដាក់លើតុមួយខ្ពស់ ។
- ត្រូវយាងសម្តេចព្រះសង្ឆរាជ ឬព្រះរាជតំណាង ចាប់យកសំបុត្រសន្លឹកឆ្នោតមួយពីក្នុងហិបឆ្នោតនោះ រួចជូនទៅមន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ។
- មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប ដែលត្រូវបានចាត់តាំង ត្រូវបើកស្រោមសំបុត្រសន្លឹកឆ្នោតនោះជាសាធារណៈ រួចអានប្រកាសឈ្មោះគណបក្សនយោបាយដែលត្រូវទទួលបានអាសនៈ និងលើកបង្ហាញឱ្យតំណាងគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ទាំងអស់ដែលបានចូលរួមក្នុងពិធីចាប់ឆ្នោត បានឃើញច្បាស់ថា ឈ្មោះគណបក្សនយោបាយដែលបានប្រកាសដូចគ្នានឹងឈ្មោះគណបក្សនយោបាយដែលបានសរសេរ ឬបោះពុម្ពលើសន្លឹកឆ្នោតនោះប្រាកដមែន។

៦.៧ អគ្គលេខាធិការដ្ឋាន គ.ជ.ប ត្រូវធ្វើកំណត់ហេតុនៃការចាប់ឆ្នោតនេះ ដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង និងតំណាងចូលរួម (គ.ជ.ប តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ...) ដំណើរការចាប់ឆ្នោត និងលទ្ធផលនៃការចាប់ឆ្នោត ។

៦.៧.១ កំណត់ហេតុត្រូវចុះហត្ថលេខាដោយ ៖

- អ្នកធ្វើកំណត់ហេតុ ដែលត្រូវបានចាត់តាំង
- អគ្គលេខាធិការ គ.ជ.ប
- តំណាងគណបក្សនយោបាយ ដែលមានលទ្ធផលគណនាមធ្យមភាគខ្ពស់បំផុតស្មើគ្នា និងមានសន្លឹកឆ្នោតបានការស្មើគ្នា ។

៦.៧.២ កំណត់ហេតុត្រូវធ្វើជាច្រើនច្បាប់តាមតម្រូវការដូចខាងក្រោមដើម្បី ៖

- ជូន គ.ជ.ប ១ (មួយ) ច្បាប់
- ផ្ញើជូនគ្រប់គណបក្សនយោបាយ ដែលបានចូលរួមបោះឆ្នោតក្នុងមណ្ឌលពាក់ព័ន្ធ
- រក្សាទុកជាឯកសារ ១ (មួយ) ច្បាប់ ។

<u>ឧទាហរណ៍ទី១៤ ៖</u> ករណីគណបក្សនយោបាយពីរមានលទ្ធផលគណនាមធ្យមកាគខ្ពស់បំផុតស្មើគ្នា និងមានសន្លឹកឆ្នោតបានការស្មើគ្នាដែលតម្រូវឱ្យធ្វើការចាប់ឆ្នោត ដើម្បីទទួលយកអាសនៈនៅសល់ចុងក្រោយ ១ (មួយ)

នៅក្នុងមណ្ឌលបោះឆ្នោតខេត្ត **F** ៖

- គណបក្សនយោបាយមាន ៩
- សន្លឹកឆ្នោតបានការសរុប ៖ $ស_{ស}$ = ៣៦៦.៩៥៧ សំឡេង
- កូតា ៖ $ក_{ត}$ = ៤៥.៨៦៩
- អាសនៈសរុប ៖ $អ_{ស}$ = ៨ អាសនៈ

គណបក្សនយោបាយ	$ស_{ប}$	$អ_{១}$ លើកទី១	$ម_{ធ}$១	$អ_{១}$ លើកទី២	$ម_{ធ}$២	$អ_{១}$ លើកទី៣
ក	៤៨.១៥២	១	$\frac{\text{៤៨.១៥២}}{\text{១+១}}$ = ២៤.០៧៦,០០	០	$\frac{\text{៤៨.១៥២}}{\text{១+១}}$ = ២៤.០៧៦,០០	០
ខ	៧.៣៨៧	០	$\frac{\text{៧.៣៨៧}}{\text{០+១}}$ = ៧.៣៨៧,០០	០	$\frac{\text{៧.៣៨៧}}{\text{០+១}}$ = ៧.៣៨៧,០០	០
គ	៩២.៥២៩	២	$\frac{\text{៩២.៥២៩}}{\text{២+១}}$ = ៣០.៨៤៣,០០	០	$\frac{\text{៩២.៥២៩}}{\text{២+១}}$ = ៣០.៨៤៣,០០	?
ឃ	១៣.៩៨០	០	$\frac{\text{១៣.៩៨០}}{\text{០+១}}$ = ១៣.៩៨០,០០	០	$\frac{\text{១៣.៩៨០}}{\text{០+១}}$ = ១៣.៩៨០,០០	០
ង	៥៥.៥៤៤	១	$\frac{\text{៥៥.៥៤៤}}{\text{១+១}}$ = ២៧.៧៧២,០០	០	$\frac{\text{៥៥.៥៤៤}}{\text{១+១}}$ = ២៧.៧៧២,០០	០
ច	៣៥.៦៧១	០	$\frac{\text{៣៥.៦៧១}}{\text{០+១}}$ = ៣៥.៦៧១,០០	១	$\frac{\text{៣៥.៦៧១}}{\text{១+១}}$ = ១៧.៨៣៥,៥០	០
ឆ	៩២.៥២៩	២	$\frac{\text{៩២.៥២៩}}{\text{២+១}}$ = ៣០.៨៤៣,០០	០	$\frac{\text{៩២.៥២៩}}{\text{២+១}}$ = ៣០.៨៤៣,០០	?
ជ	៨.៨៦៥	០	$\frac{\text{៨.៨៦៥}}{\text{០+១}}$ = ៨.៨៦៥,០០	០	$\frac{\text{៨.៨៦៥}}{\text{០+១}}$ = ៨.៨៦៥,០០	០
ឈ	១២.៣០០	០	$\frac{\text{១២.៣០០}}{\text{០+១}}$ = ១២.៣០០,០០	០	$\frac{\text{១២.៣០០}}{\text{០+១}}$ = ១២.៣០០,០០	០

$ស_{ច}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយនីមួយៗ ។

$អ_{ទ}$: (លើកទី១) តាងឱ្យចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗបានទទួលក្នុងការបែងចែកលើកទី១ ។

$ម_{ធ}$១ : តាងឱ្យលទ្ធផលនៃការគណនារកមធ្យមភាគលើកទី ១ របស់គណបក្សនយោបាយនីមួយៗ ។ គណបក្សនយោបាយ ច មានមធ្យមភាគខ្ពស់ជាងគេគឺ ៣៥.៦៧១ ដែលជាមធ្យមភាគខ្ពស់បំផុត ។

$អ_{ទ}$: (លើកទី២) គណបក្សនយោបាយ ច ត្រូវទទួលបានអាសនៈ ១ (មួយ) ។

នៅសល់អាសនៈចំនួន ១ (មួយ) ទៀត ដែលត្រូវបន្តគណនាបែងចែក ។

$ម_{ធ}$២ : គណបក្សនយោបាយ **គ** និង **ឆ** មានមធ្យមភាគខ្ពស់ជាងគេស្មើគ្នាគឺ ៣០.៨៥៣ ដែលជាមធ្យមភាគខ្ពស់បំផុត និងមានសន្លឹកឆ្នោតបានការស្មើគ្នា ដូចនេះត្រូវធ្វើការចាប់ឆ្នោត ។

ការស្រង់បញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ

៧- បន្ទាប់ពីបានធ្វើការគណនាកំណត់ចំនួនអាសនៈ ដែលគណបក្សនយោបាយនីមួយៗបានទទួលហើយ គ.ជ.ប ត្រូវស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រក្នុងមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗតាមលក្ខខណ្ឌដូចខាងក្រោម ៖

៧.១ ឈ្មោះបេក្ខជនជាប់ឆ្នោតទាំងអស់ត្រូវស្រង់ចេញពីបញ្ជីបេក្ខជន នៃគណបក្សនយោបាយដែលជាប់ឆ្នោត ទៅតាមចំនួនអាសនៈដែលគណបក្សនយោបាយជាប់ឆ្នោតនីមួយៗបានទទួល ។

៧.២ ឈ្មោះបេក្ខជនជាប់ឆ្នោតត្រូវស្រង់តាមលំដាប់លេខរៀង ពីលើចុះក្រោម តាមបញ្ជីបេក្ខជននៃគណបក្សនយោបាយជាប់ឆ្នោតនីមួយៗ ។

៧.៣ ក្នុងករណីនៅមណ្ឌលបោះឆ្នោតរាជធានី ខេត្តមួយ មានគណបក្សនយោបាយតែមួយគត់ ដែលត្រូវបានសម្រេចយល់ព្រមឱ្យចុះបញ្ជី ដូចមានចែងក្នុងចំណុច ៤.១ នៃឧបសម្ព័ន្ធនេះ ឬមានគណបក្សនយោបាយតែមួយគត់ដែលជាប់ឆ្នោតនោះ ឈ្មោះបេក្ខជនជាប់ឆ្នោត ត្រូវស្រង់ពីបញ្ជីបេក្ខជនឈរឈ្មោះនៃគណបក្សនយោបាយតែមួយនោះ តាមលំដាប់លេខរៀងពីលើចុះក្រោមរហូតដល់គ្រប់អាសនៈក្នុងមណ្ឌលរាជធានី ខេត្តនោះ ។

៧.៤ ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៃគណបក្សនយោបាយមានអ្នកជាប់ឆ្នោតណាម្នាក់ទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពតំណាងរាស្ត្រ បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត នៃគណបក្សនយោបាយនោះត្រូវបានប្រកាសថា ជាប់ឆ្នោតជាតំណាងរាស្ត្ររបស់សាមីគណបក្សនយោបាយ ។

៧.៥ ក្នុងករណីដែលគណបក្សនយោបាយណាមួយមានបេក្ខជនមិនគ្រប់គ្រាន់ ដោយមូលហេតុ ដូចមានចែងក្នុងចំណុច ៧.៤ ខាងលើ គ.ជ.ប ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះឱ្យបន្ថែមឈ្មោះក្នុងរយៈពេល ១៤ (ដប់បួន)ថ្ងៃ ក្រោយពីបានទទួលសំណើ ។ បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៨ មាត្រា ៣២ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ និងមាត្រា ៣៦ នៃ ច.ប.ត.រ ។

៧.៥.១ ដើម្បីដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែម គណបក្សនយោបាយដូចមានចែងក្នុងចំណុច ៧.៥ ខាងលើ ត្រូវធ្វើពាក្យសុំតាមបែបបទដែលកំណត់ដោយ គ.ជ.ប ។ គណបក្សនយោបាយត្រូវបំពេញពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែមជា ២ (ពីរ) ច្បាប់។ ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ ។ ការផ្ទេរសិទ្ធិបន្ត ត្រូវតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយ។ ពាក្យសុំចុះបញ្ជីនេះ ត្រូវភ្ជាប់ជាមួយនូវ ៖

- ឈ្មោះមណ្ឌលដែលគណបក្សនយោបាយ ត្រូវចុះបញ្ជីបេក្ខជនបន្ថែម និងបញ្ជីបេក្ខជនបន្ថែមឈរឈ្មោះតាមមណ្ឌលទាំងនោះ។
- បញ្ជីបេក្ខជនបន្ថែមឈរឈ្មោះតាមមណ្ឌល ត្រូវមានបេក្ខជនយ៉ាងតិចស្មើនឹងចំនួនអាសនៈនៅក្នុងមណ្ឌលនោះ ។

៧.៥.២ ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខជនបន្ថែម ពលរដ្ឋម្នាក់ៗត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត ។

- មានអាយុម្ភៃប្រាំ (២៥) ឆ្នាំឡើងទៅ គិតដល់ថ្ងៃដាក់ពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែម ។
- មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។
- មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ។
- មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

៧.៥.៣ គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺ ៖

- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទក្នុងមុខតំណែង និងបព្វជិតសាសនា ឬ
- ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ
- ជនដែលត្រូវផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត ឬដកសិទ្ធិឈរឈ្មោះឱ្យគេបោះឆ្នោត
- ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ
- ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោតដោយ គ.ជ.ប ឬ
- សមាជិកនៃ គ.ជ.ប និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ
- សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ
- សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

៧.៥.៤ មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនា ដែលមានបំណងឈរឈ្មោះជាបេក្ខជនបន្ថែម ប្រសិនបើជាប់ឆ្នោត សាមីខ្លួនត្រូវធ្វើពាក្យសុំតាមហានានុក្រមទៅក្រសួង ឬអង្គភាពរបស់ខ្លួនទៅបម្រើការងារក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីជនត្រូវមានសិទ្ធិឡើងឋានន្តរស័ក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ

និងរក្សាអតីតភាពការងារ សម្រាប់ទទួលសោធននិវត្តន៍ ។ នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

៧.៥.៥ គណបក្សនយោបាយ ដែលបានតែងតាំងបេក្ខជនបន្ថែម ត្រូវបំពេញបែបបទសេចក្តីប្រកាសបេក្ខភាពដែលផ្តល់ដោយ គ.ជ.ប ។ បញ្ជីបេក្ខជនបន្ថែមតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗត្រូវ ៖

- ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។
- មានសេចក្តីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរឃុំ សង្កាត់ ដែលសាមីខ្លួនបេក្ខជននោះបានចុះឈ្មោះបោះឆ្នោត ។
- ភ្ជាប់សេចក្តីប្រកាសរបស់បេក្ខជន យល់ព្រមទទួលការតែងតាំងជាបេក្ខជនតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗរបស់គណបក្សនយោបាយ ។

៧.៥.៦ គ.ជ.ប ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីបេក្ខជនបន្ថែមជាបន្ទាន់ សមស្រប បន្ទាប់ពីថ្ងៃទទួលបានពាក្យសុំ ។

- ក្នុងករណីយល់ព្រមលើបញ្ជីបេក្ខជនបន្ថែម គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីបេក្ខជនបន្ថែមជូនគណបក្សនយោបាយ ។
- ប្រសិនបើបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនណាមួយត្រូវបានបដិសេធ ស្របតាមចំណុច ៧.៥.២ ៧.៥.៣ ៧.៥.៤ និងចំណុច ៧.៥.៥ ខាងលើ គ.ជ.ប ត្រូវ ៖
  - បំពេញបែបបទបដិសេធបេក្ខភាព ឬបញ្ជីបេក្ខជនបន្ថែម ចុះហត្ថលេខា និងកាលបរិច្ឆេទលើសេចក្តីសម្រេចបដិសេធចំនួន ៣ (បី)ច្បាប់ រួចផ្ញើជូនសាមីខ្លួន និងសាមីគណបក្សនយោបាយ ១ (មួយ)ច្បាប់ ក្រុមប្រឹក្សាធម្មនុញ្ញ ១(មួយ)ច្បាប់ និងរក្សាទុកឯកសារ ១ (មួយ)ច្បាប់ ។
  - ផ្តល់ព័ត៌មានទៅសាមីខ្លួន ឬសាមីគណបក្សនយោបាយថា គាត់អាចប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរប្រាំ (៥)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ។

៧.៥.៧ បេក្ខភាពណាដែលត្រូវបានបដិសេធ ឬបញ្ជីបេក្ខជនបន្ថែមរបស់គណបក្សនយោបាយណាដែលត្រូវបានបដិសេធដោយ គ.ជ.ប សាមីខ្លួន ឬសាមីគណបក្សនយោបាយ ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលសេចក្តីសម្រេចបដិសេធ ។

- ក្នុងករណីទទួលសេចក្តីសម្រេចបដិសេធ និងទម្រង់បែបបទសម្រាប់ប្តឹងតវ៉ាហើយ ប៉ុន្តែសាមីគណបក្ស ឬតំណាង ពុំបានដាក់ពាក្យប្តឹងតវ៉ាទៅតាមពេលវេលា ដូចចែងក្នុងចំណុច ៧.៥.៧ ទេនោះ ត្រូវចាត់ទុកថាមិនបានប្តឹងតវ៉ា ។
- ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់)ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

៧.៥.៨ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមលើពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្តីសម្រេចយល់ព្រម និងជូនដំណឹងទៅអ្នកប្តឹងតវ៉ា ហើយបង្គាប់ឱ្យ គ.ជ.ប ចុះបញ្ជីបេក្ខជនបន្ថែមជូនសាមីគណបក្សនយោបាយជាបន្ទាន់ ។

- បន្ទាប់ពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាធម្មនុញ្ញ គ.ជ.ប ត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីបេក្ខជនបន្ថែម ។
- គ.ជ.ប ត្រូវផ្ញើលិខិតបញ្ជាក់នេះ ១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

៧.៥.៩ ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធបណ្តឹងតវ៉ា សេចក្តីសម្រេចនេះគឺជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ហើយក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

- ផ្តល់សេចក្តីសម្រេចបដិសេធនេះ ១ (មួយ) ច្បាប់ ទៅសាមីគណបក្សនយោបាយ ឬតំណាង ។
- ផ្ញើសេចក្តីសម្រេចបដិសេធ ១ (មួយ) ច្បាប់ ទៅ គ.ជ.ប ។

៧.៥.១០ ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាដូចចែងក្នុងចំណុច ៧.៥ ខាងលើ ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។ ក្នុងករណីនេះ គ.ជ.ប ត្រូវធ្វើការបែងចែកអាសនៈ ដែលនៅទំនេរនោះក្នុងរយៈពេល

យ៉ាងយូរ ៧ (ប្រាំពីរ)ថ្ងៃ បន្ទាប់ពីថ្ងៃបោះបង់ចោលជាផ្លូវការ ដោយអនុវត្ត តាមវិធីគណនាដូចមានចែងក្នុងចំណុចទី ៥ ឧបសម្ព័ន្ធទី៩ នៃ ប.ន.ត.រ នេះ ។

៧.៦ ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុចទី៤ ទី៥ និងទី៦ នៃ ឧបសម្ព័ន្ធនេះ គ.ជ.ប អាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលបោះឆ្នោតរាជធានី ខេត្តនីមួយៗជាបន្តបន្ទាប់ ។

៧.៧ មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គ.ជ.ប ត្រូវធ្វើសេចក្តីរាយការណ៍ជូនគ្រប់គណបក្សនយោបាយដែលចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុប ដែលបានបោះពុម្ព ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧

ប្រតិទិនការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៦ ឆ្នាំ២០១៨

ល.រ	ការកិច្ចត្រូវធ្វើ	កាលបរិច្ឆេទ
១	ការផ្តល់សុពលភាព និងប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០១៧ ដោយ គ.ជ.ប	ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨
២	ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតជាតិ	ថ្ងៃទី២៣ ខែមេសា-១៨ ខែកក្កដា ឆ្នាំ ២០១៨
៣	ការចុះឈ្មោះអ្នកសង្កេតការណ៍បោះឆ្នោតអន្តរជាតិ	ថ្ងៃទី២៣ ខែមេសា-២៥ ខែកក្កដា ឆ្នាំ២០១៨
៤	ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជននៅ គ.ជ.ប រយៈពេល ១៥ថ្ងៃ	ថ្ងៃទី៣០ ខែមេសា-១៤ ខែឧសភា ឆ្នាំ២០១៨
៥	ការប្តឹងតវ៉ាទៅនឹងការបដិសេធការសុំចុះបញ្ជីគណបក្សទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៥ថ្ងៃ	ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
៦	ការដោះស្រាយបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១០ថ្ងៃ	ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
៧	ការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត	ថ្ងៃទី០៦ ខែមិថុនា-០៥ ខែកក្កដា ឆ្នាំ២០១៨
៨	ការបិទផ្សាយបញ្ជីឈ្មោះ ទីតាំងការិយាល័យបោះឆ្នោត និងបញ្ជីបោះឆ្នោតនៅ គយ.សប	ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨
៩	ការបិទផ្សាយបញ្ជីកាយនាមគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះតាមមណ្ឌលរាជធានី ខេត្ត	ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
១០	ការយោសនាបោះឆ្នោត	ថ្ងៃទី០៧ ខែកក្កដា-២៧ ខែកក្កដា ឆ្នាំ២០១៨
១១	ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ	ថ្ងៃទី២៥ ខែមិថុនា-០៥ ខែកក្កដា ឆ្នាំ២០១៨
១២	ការបិទផ្សាយបញ្ជីបោះឆ្នោត និងបញ្ជីឈ្មោះទីតាំងការិយាល័យបោះឆ្នោត នៅការិយាល័យបោះឆ្នោត	ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨
១៣	ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត	ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៨
១៤	ការប្តឹងតវ៉ាទៅ គយ.សប អំពីលទ្ធផលនៃការបោះឆ្នោត ឬកាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោត	ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៨ (យ៉ាងយូរត្រឹមម៉ោង ១១:៣០នាទី)
១៥	គយ.សប សម្រេចលើបណ្តឹង ត្រួតពិនិត្យ ឬកសរុបលទ្ធផល ធ្វើកំណត់ហេតុ និងបិទផ្សាយកំណត់ហេតុ	ថ្ងៃទី៣០-៣១ ខែកក្កដា ឆ្នាំ២០១៨
១៦	ការប្តឹងតវ៉ាទៅ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ គយ.សប	ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៨ (ថ្ងៃចុងក្រោយ)
១៧	ការដោះស្រាយពាក្យបណ្តឹងដោយ គធ.ខប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹង	ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
១៨	ការប្តឹងតវ៉ាទៅ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ២ថ្ងៃ បន្ទាប់ពីការសម្រេចរបស់ គធ.ខប	ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
១៩	ការដោះស្រាយពាក្យបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៣ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្តឹង	ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
២០	ការប្រកាសលទ្ធផលបណ្តោះអាសន្នដោយ គ.ជ.ប (ករណីគ្មានការបោះឆ្នោតសាជាថ្មី)	ថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៨
២១	ការប្តឹងតវ៉ាទៅ គ.ជ.ប ឬក្រុមប្រឹក្សាធម្មនុញ្ញអំពីលទ្ធផលបណ្តោះអាសន្ន ក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង	ថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
២២	ការដោះស្រាយពាក្យបណ្តឹងដោយ គ.ជ.ប ក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង បន្ទាប់ពីបានទទួលពាក្យបណ្តឹង	ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
២៣	ការប្តឹងតវ៉ាទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេលយ៉ាងយូរ ៧២ម៉ោង បន្ទាប់ពីទទួលលិខិតបដិសេធរបស់ គ.ជ.ប	ថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
២៤	ការដោះស្រាយពាក្យបណ្តឹងដោយក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេលយ៉ាងយូរពី ១០-២០ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹង	ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
២៥	ការបោះឆ្នោតសាជាថ្មី (ប្រសិនបើមាន)	ថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០១៨(ថ្ងៃចុងក្រោយ)
២៦	ប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងការកំណត់បេក្ខជនជាប់ឆ្នោត (តាមករណីគ្មានឬមានបណ្តឹង និងករណីគ្មានការបោះឆ្នោតសាជាថ្មី)	ថ្ងៃទី១៨ ខែសីហា-ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៨